# ទៅហួសពីមូលដ្ឋានគ្រឹះ

## មគ្គុទេសក៍កម្រិតខ្ពស់ក្នុងវិជ្ជាជីវៈសារព័ត៌មាន

បោះពុម្ពលើកទីមួយ













និពន្ធដោយលោក JEFF HODSON និងលោក GRAHAM WATTS
សម្រាប់ THE INDOCHINA MEDIA MEMORIAL FOUNDATION

# ទៅហួសពីមូលដ្ឋានគ្រឹះ – មគ្គុទេសក៍កម្រិតខ្ពស់ក្នុងវិជ្ជាជីវៈសារព័ត៌មាន

និពន្ធដោយលោក JEFF HODSON និងលោក GRAHAM WATTS

សម្រាប់

**THE INDOCHINA MEDIA MEMORIAL FOUNDATION**

*បោះពុម្ពលើកទីមួយជាភាសាខ្មែរ*

កែសម្រួលនិពន្ធភាសាអង់គ្លេសដោយលោក DOMINIC FAULDER

ផលិតដោយមានការឧបត្ថម្ភពីសំណាក់

**THE OPEN SOCIETY NETWORK MEDIA PROGRAMME**
**THE MCGEE FOUNDATION**
**JAY MOWATT**

បោះពុម្ពលើកទីមួយជាភាសាខ្មែរ ខែធ្នូ ឆ្នាំ២០១២ ចំនួន ៥00 ក្បាល

Copyright © 2012 Foreign Correspondents’ Club of Thailand. All rights reserved.
រក្សាសិទ្ធិគ្រប់បែបយ៉ាង។ គ្មានផ្នែកណាមួយនៃសៀវភៅនេះ ត្រូវបានយកទៅផលិតឡើងវិញ ឬបញ្ជូនបន្ត
ទោះក្នុងទម្រង់ ឬមធ្យោបាយណាក៏ដោយ ជាអេឡិចត្រូនិកក្តី ជាមេកានិកក្តី - ក្នុងនោះមានផងដែរ
នូវការថតចម្លងដាក់ក្នុងប្រព័ន្ធតម្កល់ឯកសារណាមួយសម្រាប់យកមកប្រើប្រាស់ថ្ងៃមុខ - ដោយគ្មាន
ការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីសំណាក់ម្ចាស់កម្មសិទ្ធិ
Foreign Correspondents’ Club of Thailand។

IMMF បានផលិតសៀវភៅមគ្គុទេសក៍សម្រាប់បង្ហាត់អ្នកសារព័ត៌មានជាភាសា
អង់គ្លេស ភូមា ខ្មែរ ថៃ និងវៀតណាម ដែលអាចទាញយកបានតាមរយៈគេហទំព័រ

http://www.immf.or.th/download/manual.html

Indochina Media Memorial Foundation
Foreign Correspondents’ Club of Thailand
Penthouse, Maneeya Centre Building
518/5 Ploenchit Road, Lumpini
Pathumwan, Bangkok 10330, Thailand

Tel: +66(0)2652 0580-1 / Fax: +66(0)2652 0582
E-mail: info@fcctthai.com / Web: www.fccthai.com

ប្រែសម្រួលជាភាសាខ្មែរដោយលោក កែ មុនធិត

Khmer edition layout by Graphic Roots Co., Ltd., Phnom Penh, Cambodia
Printed by Ouddompheap Advertising & Printing Co., Ltd., Phnom Penh, Cambodia

# មាតិកាសង្ខេប


| | | |
|---|---|---|
| បុព្វកថា | | xiii |
| អារម្ភកថា | | xvi |
| សន្ធានុក្រម | | xix |
| **ជំពូក ១ :** | ទៅហួសពី 5Ws និង H | ២២ |
| **ជំពូក ២ :** | ការសរសេរអត្ថបទពិពណ៌នា - ភាគ ១ | ៣៦ |
| **ជំពូក ៣ :** | ការសរសេរអត្ថបទពិពណ៌នា - ភាគ ២ | ៥១ |
| **ជំពូក ៤ :** | ទម្រង់ឈានមុខផ្សេងទៀតនៃវិជ្ជាជីវៈសារព័ត៌មាន | ៧២ |
| **ជំពូក ៥ :** | យកព័ត៌មានអំពីប្រធានបទឯកទេស | ១០៤ |
| **ជំពូក ៦ :** | ធុរកិច្ច និងសេដ្ឋកិច្ច | ១២១ |
| **ជំពូក ៧ :** | បរិស្ថាន | ១៥៤ |
| **ជំពូក ៨ :** | នយោបាយ និងរដ្ឋាភិបាល | ១៨២ |
| **ជំពូក ៩ :** | ប្រមូលព័ត៌មានបែបស៊ើបអង្កេត និងស៊ីជម្រៅ | ២០១ |
| **ជំពូក ១០:** | យកព័ត៌មានអំពីបទល្មើសព្រហ្មទណ្ឌ និងតុលាការ | ២១២ |
| **ជំពូក ១១:** | អ្នកសារព័ត៌មាន និងច្បាប់ | ២៣១ |
| **សេចក្ដីសន្និដ្ឋាន** | | ២៣៨ |
| **អំពីអ្នកនិពន្ធ** | | ២៤០ |
| **ឯកសារអានបន្ថែម** | | ២៤៣ |
| **សេចក្ដីថ្លែងអំណរគុណ** | | ២៤៥ |

# មាតិកាលម្អិត


| | |
|---|---|
| បុព្វកថា | xiii |
| អារម្ភកថា | xvi |
| សន្ទានុក្រម | xix |
| **ជំពូក ១ : ទៅហួសពី 5Ws និង H** | **២២** |
| សារតារ | ២២ |
| ទិដ្ឋភាពទូលំទូលាយ | ២៤ |
| សារៈសំខាន់ | ២៦ |
| រំលេចមុខមនុស្សក្នុងសាច់រឿង | ២៧ |
| បញ្ចូលទស្សនៈចម្រុះក្នុងសាច់រឿង | ២៩ |
| ចូរអះអាងបញ្ជាក់គោលគំនិតរបស់អ្នក | ២៩ |
| ការនិទានខ្លីៗអះអាងបញ្ជាក់គោលគំនិត | ៣៤ |
| **ជំពូក ២ : ការសរសេរអត្ថបទពិពណ៌នា - ភាគ ១** | **៣៦** |
| ផ្ដោតគោលគំនិត | ៣៨ |
| រៀបផែនការប្រមូលព័ត៌មាន | ៤០ |
| កុំនៅតែក្នុងការិយាល័យ | ៤១ |
| អ្នកចង់បានអ្វីពីការប្រមូលព័ត៌មាន | ៤១ |
| អត្ថបទពិពណ៌នាបុគ្គលភាព | ៤២ |
| ប្រើស្ទីលបទពិពណ៌នាក្នុងការសរសេរដំណឹង | ៤៥ |
| វែងប៉ុណ្ណា? | ៥០ |
| **ជំពូក ៣ : ការសរសេរអត្ថបទពិពណ៌នា - ភាគ ២** | **៥១** |
| អង្គុយចុះ ចាប់ផ្ដើមចាត់ការ | ៥១ |
| ចាប់ផ្ដើមសរសេរ | ៥១ |
| ដងខ្លួនបទពិពណ៌នា | ៥៥ |
| ចូរប្រមើលគិតជារបៀបរូបភាព | ៥៦ |
| តែងសាច់រឿងឲ្យណែន | ៥៦ |
| ករណីសិក្សា : ជនជាតិនៅកម្ពុជា | ៥៦ |
| គ្រោងរឿង : ជនជាតិនៅកម្ពុជា | ៦៤ |
| ករណីសិក្សា : រក្សាចំណាប់អារម្មណ៍អ្នកអាន | ៦៦ |
| អនុសាសន៍មួយចំនួន | ៧១ |



*ការងាររបស់អ្នកសារព័ត៌មានបានវិវត្តន៍រស់រវើកជានិច្ចក្នុងតំបន់មួយ ដែលមានការប្រែប្រួលយ៉ាងសម្បើមក្នុងមួយជំនាន់មនុស្សកន្លងមកនេះ។*


**ជំពូក ៤ :  ទម្រង់កម្រិតខ្ពស់ផ្សេងទៀតក្នុងវិជ្ជាជីវៈសារព័ត៌មាន** **៧២**

បទវិភាគដំណឹង ៧៣

រិះគិតអំពីបទវិភាគដំណឹង ៧៣

សរសេរបទវិភាគដំណឹង ៧៤

ការសរសេរបទវិភាគដំណឹងច្រើនថ្ងៃក្រោយព្រឹត្តិការណ៍ ៧៥

វិចារណកថា និងអត្ថាធិប្បាយ ៨៤

រិះគិតអំពីបទវិចារណកថា ៨៤

សរសេរបទវិចារណកថា ៨៥

វេទិកាស្មេរ ៨៨

រិះគិតអំពីអត្ថបទសំរាប់វេទិកាស្មេរ ៨៨

និពន្ធអត្ថបទសម្រាប់វេទិកាស្មេរ ៨៩

គេហទិនានុលេខន៍ ( Blogs) ៩៦

តើបច្ចេកវិទ្យាធ្វើឲ្យសារព័ត៌មានបោះពុម្ពប្រែប្រួលដូចម្តេចខ្លះ? ៩៨

# មាតិកាលម្អិត


**ជំពូក ៥ : យកព័ត៌មានប្រធានបទឯកទេស** **១០៤**
ស្វែងយល់អំពី "មុខព្រួញ" (beat) ក្នុងការយកព័ត៌មាន ១០៤
លៃលកជាមួយពាក្យឯកទេស សម្រាយវាក្យសព្ទ - បច្ចេកទេសពន្យល់ដំណើរការ ១០៨
ការប្រើប្រាស់លេខ ១១១
ប្រភាគ ១១២
បំនួនភាគរយ ១១២
ទិន្នផល ១១៣
សន្ទស្សន៍ ១១៣
សម្រាប់មនុស្សម្នាក់ (Per Capita) ១១៤
អនុបាត ១១៤
សម្ភាសន៍ជំនាញការ ១១៨
សន្សំទំនុកចិត្ត ១១៨
ភាពប្រឈម ១១៩
ស្វែងយល់ពីកេរ្តិ៍ឈ្មោះ និងភាពលម្អៀងរបស់ប្រភព ១២០

**ជំពូក ៦ : ធុរកិច្ច និងសេដ្ឋកិច្ច** **១២១**
**សេដ្ឋកិច្ច** ១២២
តើវាជាស្អី? ១២២
ហេតុអ្វីបានជាវាសំខាន់ ឬគួរឲ្យចាប់អារម្មណ៍ដល់អ្នកអាន? ១២២
តើរឿងប្រភេទណាខ្លះ ដែលអាចកើតចេញពីប្រធានបទនេះ? ១២៣
គោលគំនិតសំខាន់ៗមួយចំនួន ១២៣
**រដ្ឋាភិបាល និងនយោបាយសេដ្ឋកិច្ច** ១២៥
តើវាជាស្អី? ១២៥
ហេតុអ្វីបានជាវាសំខាន់ ឬគួរឲ្យចាប់អារម្មណ៍ដល់អ្នកអាន? ១២៦
តើរឿងប្រភេទណាខ្លះ ដែលអាចកើតចេញពីប្រធានបទនេះ? ១២៧
គោលគំនិតសំខាន់ៗមួយចំនួន ១២៧
**កសិកម្ម និងវត្ថុធាតុដើម** ១២៩
តើវាជាស្អី? ១២៩
ហេតុអ្វីបានជាវាសំខាន់ ឬគួរឲ្យចាប់អារម្មណ៍ដល់អ្នកអាន? ១៣០
តើរឿងប្រភេទណាខ្លះ ដែលអាចកើតចេញពីប្រធានបទនេះ? ១៣០
គោលគំនិតសំខាន់ៗមួយចំនួន ១៣០

**ក្រុមហ៊ុន** ១៣១
តើវាជាអ្វី? ១៣១
ហេតុអ្វីបានជាវាសំខាន់ ឬគួរឲ្យចាប់អារម្មណ៍ដល់អ្នកអាន? ១៣៣
តើរឿងប្រភេទណាខ្លះ ដែលអាចកើតចេញពីប្រធានបទនេះ? ១៣៣
គោលគំនិតសំខាន់ៗមួយចំនួន ១៣៥

**វិស័យហិរញ្ញវត្ថុ និងធនាគារ** ១៣៦
តើវាជាអ្វី? ១៣៦
ហេតុអ្វីបានជាវាសំខាន់ ឬគួរឲ្យចាប់អារម្មណ៍ដល់អ្នកអាន? ១៣៨
តើរឿងប្រភេទណាខ្លះ ដែលអាចកើតចេញពីប្រធានបទនេះ? ១៣៩
គោលគំនិតសំខាន់ៗមួយចំនួន ១៣៩

**វិស័យទីផ្សារ** ១៤០
តើវាជាអ្វី? ១៤០
ហេតុអ្វីបានជាវាសំខាន់ ឬគួរឲ្យចាប់អារម្មណ៍ដល់អ្នកអាន? ១៤៤
តើរឿងប្រភេទណាខ្លះ ដែលអាចកើតចេញពីប្រធានបទនេះ? ១៤៥
គោលគំនិតសំខាន់ៗមួយចំនួន ១៤៥

**ពាណិជ្ជកម្ម និងសកលភាវូបនីយកម្ម** ១៤៧
តើវាជាអ្វី? ១៤៧
ហេតុអ្វីបានជាវាសំខាន់ ឬគួរឲ្យចាប់អារម្មណ៍ដល់អ្នកអាន? ១៤៨
តើរឿងប្រភេទណាខ្លះ ដែលអាចកើតចេញពីប្រធានបទនេះ? ១៤៨
គោលគំនិតសំខាន់ៗមួយចំនួន ១៤៩

**អនុសាសន៍បុងក្រោយ** ១៥០

**ជំពូក ៧ : បរិស្ថាន** **១៥៤**
ហេតុអ្វីបានជាវាមានសារៈសំខាន់? ១៥៥
តួនាទីអ្នកសារព័ត៌មាន ១៥៦
ប្រព័ន្ធអេកូឡូស៊ី ១៥៩
សុខភាព និងបរិស្ថាន ១៦១
ឆ្ងាយផុតពីដែនកំណត់ ១៦២
ការប្រែប្រួលអាកាសធាតុ ១៦៣
ភាពប្រឈមក្នុងការយកព័ត៌មានអំពីបរិស្ថាន ១៦៥
ករណីសិក្សា : ធ្វើមនុស្សកម្មសាច់រឿង ១៦៩
ករណីសិក្សា : ផលិតផលអាវយឺតចិន សកលភាវូបនីយកម្ម
និងការបំពុលខ្យល់បរិយាកាស ១៧០

# មាតិកាលម្អិត


**ជំពូក ៨ : នយោបាយ និងរដ្ឋាភិបាល ១៨២**
ស្វែងយល់ពីដំណើរការប្រព័ន្ធនយោបាយ និងរដ្ឋាភិបាល ១៨៣
ស្វែងយល់ដូចម្តេចបានជាប្រព័ន្ធនយោបាយ និងរដ្ឋាភិបាលមិនដំណើរការ ១៨៣
មើលឲ្យហួសពីនយោបាយផ្លូវការ ១៨៥
កុំរំលងនយោបាយថ្នាក់មូលដ្ឋាន ១៨៥
តាមឃ្លាំមើលការស្រាវជ្រាវ ១៨៦
ឃ្លាំមើលនិន្នាការ និងតារាកំពុងរះ ១៨៧
យកព័ត៌មានអំពីស្ថាប័ននីតិប្បញ្ញត្តិ ១៨៧
គោលនយោបាយ និងការឡប់ប៊ី ១៨៩
ថវិកា ១៨៩
ឈ្មុសឈ្មុលតាមកម្មវត្ថុព័ត៌មាន ១៩០
ទស្សនវិស័យ ១៩១
ការបោះឆ្នោត ១៩៥
ការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ ១៩៥
យល់អំពីដំណើរការ និង "កលល្បិចក្រខ្វក់" ១៩៦
ការរាយការណ៍ព័ត៌មានលើអ្នកបោះឆ្នោត ១៩៩
សេចក្តីសន្និដ្ឋាន ២០០

**ជំពូក ៩ : រាយការណ៍ព័ត៌មានបែបស៊ើបអង្កេត និងស៊ីជម្រៅ ២០១**
ធ្វើបែបណាខ្លះ ២០២
គោលគំនិត ២០២
សាវតារ ២០៣
ធ្វើសម្ភាសន៍ល្អិតល្អន់ ២០៣
ឯកសារ ២០៣
ការសង្កេត ២០៤
ភាពប្រឈមនានា ២០៥
សីលធម៌ ២០៥
ផ្គុំជាតុផ្សំចូលគ្នា ២០៦
ករណីសិក្សា : ការជួញដូរសត្វព្រៃខុសច្បាប់ ២០៧



*តើយើងសម្លឹងទៅអនាគតបែបណានៅក្នុងតំបន់មួយ ដែលមានសន្តិភាពសឹងតែពេញលេញទៅហើយនោះ ?*


**ជំពូក ១០: យកព័ត៌មានអំពីបទល្មើសព្រហ្មទណ្ឌ និងតុលាការ** **២១១**

ស្វែងយល់អំពីប្រព័ន្ធ ២១៣

តុលាការព្រហ្មទណ្ឌ ២១៣

តុលាការរដ្ឋប្បវេណី ២១៣

តុលាការធម្មនុញ្ញ ២១៤

តុលាការអន្តរជាតិ ២១៥

# មាតិកាលម្អិត


ស្វែងយល់អំពីនីតិវិធី ២១៥
រាយការណ៍ព័ត៌មានបទព្រហ្មទណ្ឌ និងតុលាការ ២១៨
ប្រភពព័ត៌មាន ២១៨
តុល្យភាព ២១៩
សង្កេតរកមើលលំអានហេតុការណ៍ ២២០
ស្វែងរកមើលអ្វីដែលអធម្មតា ២២០
មើលក្រោយឆាកផង ២២១
ទង្វើបំពានគន្លងយុត្តិធម៌ ២២៣
រំលេចមុខមនុស្សក្នុងសាច់រឿង ២២៦
ឧបទ្ទវហេតុ និងគ្រោះមហន្តរាយ ២២៧
ជជែកជាមួយអ្នករួចជីវិតពីគ្រោះកាច ២២៨
ការពារជនរងគ្រោះអំពើឧក្រិដ្ឋកម្ម ២២៩
អនុសាសន៍ចុងក្រោយមួយចំនួន ២២៩

**ជំពូក ១១: អ្នកសារព័ត៌មាន និងច្បាប់ ២៣០**

អ្នកជាពលរដ្ឋស្ថិតក្រោមច្បាប់ក្នុងប្រទេសដែលអ្នកកំពុងប្រតិបត្តិការ ២៣០
បទបរិហារកេរ្តិ៍រដ្ឋប្បវេណី បទនិយាយមួលបង្កាច់ បទបង្ខូចកេរ្តិ៍ ២៣០
បទបរិហារកេរ្តិ៍ព្រហ្មទណ្ឌ ២៣៣
បទប្រមាថព្រះចេស្ដាក្សត្រ ២៣៣
សន្តិសុខជាតិ ២៣៥
បទមាក់ងាយតុលាការ ២៣៥
ការរក្សាសិទ្ធិស្នាដៃ និងការលួចចម្លងស្នាដៃនិពន្ធ ២៣៦

**សេចក្ដីសន្និដ្ឋាន ២៣៧**

**អំពីអ្នកនិពន្ធ ២៣៩**

**ឯកសារអានបន្ថែម : សៀវភៅ សៀវភៅខ្នាតតូច វិបសាយ ២៤១**

**សេចក្ដីថ្លែងអំណរគុណ ២៤៤**

សារព័ត៌មានបោះពុម្ពក្នុងប្រទេសមួយចំនួន ដូចជា ប្រទេសឥណ្ឌា និងប្រទេសមីយ៉ាន់ម៉ា បានបង្ហាញសញ្ញារីកលូតលាស់គួរឲ្យកត់សម្គាល់ តែទោះជាយ៉ាងនេះក្ដី កាសែត និងទស្សនាវដ្ដីជាច្រើននៅជុំវិញពិភពលោកក្នុងពេលបច្ចុប្បន្ននេះ កំពុងប្រឈមនឹងការគំរាមកំហែងធំធេងមួយចំពោះអត្ថិភាពអាជីពរបស់ខ្លួន ដែលគេពុំធ្លាប់ពើបប្រទះសោះពីមុនមក។ នៅសហរដ្ឋអាមេរិក កាសែតធំៗជាច្រើន ដែលធ្លាប់តែចេញផ្សាយមិនដែលអាក់ខានតាំងតែពីសតវត្សរ៍ទី ១៩ មក ឥឡូវនេះត្រូវបានបិទទ្វារ ឬមួយក៏បន្តចេញផ្សាយតែលើអ៊ិនធឺណិត តែប៉ុណ្ណោះ។ កាសែត និងទស្សនាវដ្ដីទាំងឡាយ ដែលនៅមានជីវិតក្នុងអាជីពនៅឡើយ បន្តការកស៊ីដោយនាំគ្នាកាត់បន្ថយបុគ្គលិក និងការចំណាយរបស់ខ្លួន។ ការិយាល័យព័ត៌មានជាច្រើនត្រូវបានបិទទ្វារ ហើយអ្នកឆ្លើយឆ្លងព័ត៌មានបរទេស កំពុងប្រឈមនឹងស្ថានភាពមួយប្រៀបបាននឹងសត្វព្រៃជិតផុតពូជអញ្ចឹង។

កាសែតប្រចាំសប្ដាហ៍ ឥឡូវនេះក្លាយជារបស់ហួសសម័យហើយ ដោយសារថាក្នុងយុគ្គសម័យអ៊ិនធឺណិតនេះ គ្មាននរណាអានដំណឹងប្រចាំសប្ដាហ៍នោះទេ។ អាស៊ីអាគ្នេយ៍លែងមានឈ្មោះជាមជ្ឈមណ្ឌលតំបន់សារព័ត៌មានបោះពុម្ពជាភាសាអង់គ្លេសមានឥទ្ធិពលទៀតហើយ។ ទីក្រុងបាងកក ដែលធ្លាប់តែជាជង្រុករាយការណ៍ព័ត៌មានក្នុងតំបន់ មានកាសែតជាភាសាអង់គ្លេសដល់ទៅ ៦ ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០។ ឥឡូវនេះ វានៅមានកាសែតភាសាអង់គ្លេសតែ ២ ទេ ហើយកាសែតទាំង ២ នេះ កំពុងស្វះស្វែងរកម៉ូដែលធុរកិច្ចថ្មី ដើម្បីអាចនៅរស់តទៅទៀតបាន។ សេវាកម្មព័ត៌មានទូរលេខ (wire services) ដែលអាស្រ័យលើការជាវពីសំណាក់កាសែតដើម្បីរកចំណូលនោះ ក៏ទទួលរងនូវផលប៉ះពាល់ធ្ងន់ធ្ងរដែរ។ អ្នកសារព័ត៌មានល្អៗជាច្រើននាក់ មិនត្រូវបានសារព័ត៌មានបោះពុម្ពណាជួលមកធ្វើការឡើងវិញទេ ព្រោះនិយាយឲ្យងាយស្ដាប់ គឺវាគ្មានការងារឲ្យអ្នកទាំងនោះធ្វើ។

នេះជាដំណាក់កាលគួរឲ្យកត់សំគាល់មួយសម្រាប់សម្ពោធសៀវភៅមគ្គុទេសក៍កម្រិតខ្ពស់ក្នុងវិជ្ជាជីវៈសារព័ត៌មាននៅអាស៊ីអាគ្នេយ៍។ ទម្រង់ និងការបង្ហាញរបស់វា ត្រូវបានកែច្នៃឡើងវិញ រីឯគោលការណ៍មូលដ្ឋាននៃសារព័ត៌មានល្អៗ ត្រូវបានធ្វើឲ្យកាន់តែមានភាពស៊ីជម្រៅថែមទៀត។ យើងទាំងអស់គ្នាសង្ឃឹមថា ទម្រង់ថ្មីៗក្នុងសារព័ត៌មាននឹងមានអត្ថិភាពយឺនយូរក្នុងពិភពលោកដែលមានការប្រែប្រួលឥតឈប់ឈរនេះ។ ដូច្នេះ នេះជាពេលវេលាស័ក្ដិសមមួយក្នុងការរម្លឹកខ្លួនយើងថា តើវិស័យសារព័ត៌មានល្អប្រពៃនោះមានអត្ថន័យដូចម្ដេចខ្លះ។

សៀវភៅមគ្គុទេសក៍ថ្មីនេះ ត្រូវបាននិពន្ធឡើងលើមូលដ្ឋានសៀវភៅ Reporting and Writing News – A Basic Handbook ដែលបានចេញផ្សាយជាលើកដំបូងនៅឆ្នាំ ២០០១ ហើយក៏ត្រូវបានបកប្រែពីភាសាអង់គ្លេសទៅភាសា ភូមា ខ្មែរ ឡាវ ថៃ និងវៀតណាម នៃប្រទេសប្រាំក្នុងអាស៊ីអាគ្នេយ៍ ដែលអង្គការ Indochina Media Memorial Foundation (IMMF) ធ្លាប់តែដើរតួយ៉ាងសកម្មក្នុងការបណ្ដុះបណ្ដាលវិជ្ជាជីវៈសារព័ត៌មានកន្លងមក។ ទន្ទឹមនឹងនេះ សៀវភៅមគ្គុទេសក៍ជាមូលដ្ឋាន ក៏ត្រូវបានធ្វើបច្ចុប្បន្នភាពរៀបរៀងរចនាបទថ្មី និងបកប្រែជាភាសាទាំងប្រាំនោះដែរ។

ដូចគ្នានឹងសៀវភៅជាមូលដ្ឋានដែរ សៀវភៅមួយនេះ មិនប៉ុនប៉ងដាក់បញ្ញាកំណត់ឲ្យអ្នកសារព័ត៌មានកំពុងប្រកបវិជ្ជាជីវៈ និងនិស្សិតសារ-ព័ត៌មានថា តើពួកគេគួរធ្វើការរបៀបណានោះទេ។ វិជ្ជាជីវៈសារព័ត៌មាននៅអាស៊ីអាគ្នេយ៍ ត្រូវបានប្រើប្រាស់តាមការយល់ឃើញក្រោមឥទ្ធិពលទម្លាប់



*ការងាររបស់អ្នកសារព័ត៌មាន គឺធ្វើការបកស្រាយរឿងរ៉ាវស្មុគស្មាញឲ្យបានត្រឹមត្រូវ និងច្បាស់លាស់ ដើម្បីឲ្យអ្នកអាន និងទស្សនិកជនយល់។*

ភាសា វប្បធម៌ នយោបាយ នីតិកម្ម និងធុរកិច្ចផ្សេងៗគ្នា។ មាគ៌ាប្រតិបត្តិរបស់ IMMF គឺលើកយកមកបង្ហាញឧទាហរណ៍ទម្លាប់ល្អៗក្នុងវិជ្ជាជីវៈសារព័ត៌មាន ដែលអតីតសិក្ខាកាមរបស់យើងអាចយកមកពិចារណា និងអនុវត្តន៍ឲ្យសមតាមស្ថានភាពជាក់ស្តែងរបស់គេនីមួយៗ។ លោក Jeff Hodson សញ្ជាតិអាមេរិក និងលោក Graham Watts សញ្ជាតិអាហ្វ្រិកខាងត្បូងជាអ្នកនិពន្ធសៀវភៅនេះ ហើយអ្នកទាំងពីរជាអ្នកសារព័ត៌មានដ៏ប៉ិនប្រសប់ មានបទពិសោធន៍សឹងថាគ្មានអ្វីប្រៀបផ្ទឹមបានខាងបង្រៀនអ្នកសារព័ត៌មានជាច្រើននាក់មកពីអាស៊ីអាគ្នេយ៍។

រីឯផ្នែកស្ថាប័នវិញ IMMF និងការិយាល័យរបស់ខ្លួននៅក្រុងឈៀងម៉ៃ ដែលស្ថិតនៅភាគខាងជើងប្រទេសថៃ បានបិទទ្វារកាលពីដើមឆ្នាំ ២00៩ បន្ទាប់ពីអង្គការមួយនេះ បានសម្រេចរួចមកនូវអ្វីដែលគេបានកំណត់ពីដើមទីថាជាគោលដៅចម្បងរបស់គេ។ ការបិទទ្វារនេះ ក៏បានបញ្ចប់ផងដែរនូវការហ្វឹកហ្វឺនជាច្រើនវគ្គ ដែលបានចាប់ផ្តើមតាំងពីឆ្នាំ ១៩៩៤ ក្នុងនោះមាន ២៦ វគ្គ នៅកម្រិតតំបន់ និង ២៧ វគ្គ នៅតាមប្រទេស។ វគ្គទាំងអស់នោះមានសិក្ខាកាមអ្នកសារព័ត៌មាន ៨៨0 នាក់ ចូលរួមមកពីប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម។ អ្នកសារព័ត៌មានចិន ៤ នាក់ ក៏បាន

ចូលរួមសិក្សាផងដែរ។ ភាគច្រើននៃវគ្គបណ្តុះបណ្តាលផ្តោតទៅលើសារព័ត៌មានបោះពុម្ព និងផ្នែកវិទ្យុ ប៉ុន្តែក្នុងនោះ មានការបង្ហាត់ជាមូលដ្ឋានផ្នែកសារព័ត៌មានទូរទស្សន៍ និងថតរូបផងដែរ។

អ្នកទាំងឡាយដែលមានការពាក់ព័ន្ធជាមួយ IMMF នៅប្រទេសថៃ ក្នុងពេលប៉ុន្មានឆ្នាំមកនេះ ពេញចិត្តជាមួយនឹងបទពិសោធន៍សំបូរបែបដែលពួកគេទទួលបានតាមរយៈចំណងមិត្តភាពយូរអង្វែង និងការផ្លាស់ប្តូរគំនិតជាច្រើនដោយសេរី។ បទ-ពិសោធន៍របស់ IMMF គឺដូច្នេះឯង គឺប្រៀបបាននឹងផ្លូវមានទិសដៅទៅមកសម្រាប់ការផ្លាស់ប្តូរគំនិតផ្សេងៗគ្នា។ គ្រូបង្វឹកខ្លះរបស់ IMMF ក្រោយពីត្រឡប់ទៅដល់ផ្ទះសម្បែងរបស់ពួកគេវិញ តែងមានអារម្មណ៍ប្លែកថា ពួកគេហាក់ដូចជារៀនសូត្រពីបណ្តាសិក្ខាកាមរបស់ពួកគេ ច្រើនជាងអ្វីដែលពួកគេបានបង្រៀនទៅដល់អ្នកទាំងនោះទៅទៀត។ អតីតសិក្ខាកាមខ្លះបានឈានទៅធ្វើការសិក្សាជាន់ខ្ពស់ ឬក៏កាន់តំណែងខ្ពស់ក្នុងអាជីពជាអ្នកកាសែតទៀតផង។ យើងក៏មានមោទនភាពនឹងរាយការណ៍ជូនផងដែរថា ៣៩ ភាគរយ នៃអតីតសិក្ខាកាម IMMF ទាំងអស់ជាស្ត្រី ហើយពួកគេបន្តដើរតួនាទីកាន់តែទូលំទូលាយ និងមានសារៈសំខាន់ក្នុងការតម្រង់អនាគតវិស័យសារព័ត៌មានក្នុងតំបន់។

យើងសង្ឃឹមថា សៀវភៅមគ្គុទេសក៍នេះនឹងបន្សល់ទុកជាមរតករាប់ឆ្នាំទៅមុខ ហើយជួយរក្សាពន្លឺប្រទីបរបស់ IMMF ឲ្យនៅបានយូរតទៅទៀត។ យើងសូមថ្លែងអំណរគុណជាអនេកប្បការចំពោះ Foreign Correspondents’ Club of Thailand ដែលជាអ្នកគាំទ្រមោះមុតបំផុតចំពោះបេសកកម្មរបស់ IMMF តាំងពីដើមទីមក ដែលបានរក្សាទុកវិបសាយ IMMF ឲ្យនៅដំណើរការ និងជួយធ្វើការសម្របសម្រួលគម្រោងសៀវភៅទៅថ្ងៃមុខ រួមមានការបកប្រែជាភាសាក្នុងតំបន់ផង។

**DENIS GRAY** និង **DOMINIC FAULDER**
អតីតសហប្រធាន **IMMF**

**SARAH MCLEAN**
អតីតប្រធានគម្រោង **IMMF**

បាងកក ខែកុម្ភៈ ឆ្នាំ២០១០

# អារម្ភកថា

***មានន័យដូចម្ដេច ការធ្វើខ្លួនឲ្យទៅជាអ្នកសារព័ត៌មានល្អប្រពៃមួយរូប?***

ការងារភាគច្រើនចាប់ផ្ដើមពេលដែលមនុស្សទៅដល់កន្លែងធ្វើការរបស់ពួកគេ។ អ្នកសារព័ត៌មានបំណានៗ ចាប់ផ្ដើមការងារភ្លាមបន្ទាប់ពីពួកគេក្រោកពីដំណេក។ គេធ្វើការបណ្ដើរ ស្ដាប់កម្មវិធីផ្សាយវិទ្យុ ឬមើលទូរទស្សន៍បណ្ដើរ។ ចំពោះអ្នកមានអ៊ិនធឺណិតនៅផ្ទះ មុននឹងចាកចេញពីផ្ទះទៅធ្វើការ ពួកគេភ្ជាប់អ៊ិនធឺណិត ដើម្បីឆែកមើលព័ត៌មានថា តើមានអ្វីខ្លះកំពុងកើតឡើងក្នុងប្រទេសតំបន់របស់ពួកគេ និងនៅជុំវិញពិភពលោក។ អ្នកខ្លះជាវកាសែតចែកចាយដល់ផ្ទះរបស់គេតែម្ដង។ ដូច្នេះ ពួកគេអានកាសែតពីរ-បីច្បាប់ឯណោះ ក្នុងពេលទទួលទានអាហារពេលព្រឹក ក្នុងពេលដែលគេបញ្ចុកអាហារកូន ឬមួយក៏ក្នុងពេលដែលជូនកូនទៅរៀន (ដោយមានត្រចៀកមួយស្ដាប់វិទ្យុ ឬភ្នែកមួយមើលទូរទស្សន៍)។ ពួកគេព្យាយាមអស់លទ្ធភាព ដើម្បីអានអត្ថបទនានាក្នុងកាសែតរបស់ខ្លួន។ សម្រាប់អ្នកសារព័ត៌មានម្នាក់ គ្មានអ្វីដែលគួរឲ្យអាម៉ាស់ជាងការឆ្លើយថាអត់ដឹង នៅពេលដែលសហសេវិក ឬចៅហ្វាយនាយរបស់ខ្លួនសួរថា "តើឯងមានបានអានរឿងមួយហ្នុំងនៅក្នុងកាសែតរបស់យើង ឬទេ កាលពីព្រឹកមិញនេះ?"

អ្នកសារព័ត៌មានខ្លះមានមុខព្រួញជំនាញ (beat) របស់គេ ហើយពួកគេអានអ្វីៗទាំងអស់ទាក់ទងនឹងមុខព្រួញនោះដែលចុះផ្សាយក្នុងកាសែតប្រចាំថ្ងៃ។ ទន្ទឹមនឹងនោះ ពួកគេក៏អានផងដែរនូវអត្ថបទដំណឹង និងអត្ថបទពិពណ៌នាអំពីប្រធានបទផ្សេងទៀតឲ្យបានច្រើនតាមតែគេអាចធ្វើទៅបាន។ គេធ្វើដូច្នេះក៏ដោយសារពួកគេមានភាពចាំបាច់ត្រូវតែដឹងអ្វីៗឲ្យបានច្រើន ដែលកំពុងកើតឡើងក្នុងប្រទេសរបស់ខ្លួនក្នុងតំបន់ និងក្នុងពិភពលោក ដែលអាចមានឥទ្ធិពលមកលើប្រធានបទ ដែលជាមុខព្រួញការងាររបស់ពួកគេ។ ការធ្វើរបៀបនេះ គឺជួយ**ពង្រីក**លទ្ធភាព សរសេររឿង និងផ្ដល់ឲ្យពួកគេនូវបរិបទគ្រប់គ្រាន់ក្នុងការសរសេរ។ **អ្នកអាចវិនិច្ឆ័យថាអ្វីមួយជារឿងថ្មីបាន នៅពេលណាដែលអ្នកដឹងថាស្អីខ្លះជារឿងចាស់**។ បើមានអ៊ិនធឺណិតប្រើអ្នកនឹងឃើញថាមានព័ត៌មានរាប់លានដង ច្រើនជាងពេលវេលាដែលអ្នកមានសម្រាប់អានវាទៅទៀត ដូច្នេះ អ្នកគ្រាន់តែអានត្រួសៗ ហើយជ្រើសរើសមើល គឺដំបូងគេជ្រើសយកតែប្រភពព័ត៌មានណាដែលគួរឲ្យទុកចិត្តបំផុត ហើយអានល្អិតល្អន់តែរឿងទាំងឡាយណាដែលអ្នកចាំបាច់ត្រូវដឹងស៊ីជម្រៅប៉ុណ្ណោះ។ គ្មានទេលេសថា មិនបានដឹងនូវអ្វីដែលគេដឹងជាសាធារណៈរួចទៅហើយនោះ។ អ្នកសារព័ត៌មានបំណានៗ ក៏ត្រូវអានសៀវភៅអំពីបញ្ហាបច្ចុប្បន្នភាព និងប្រវត្តិសាស្ត្រ និងប្រលោមលោកផងដែរ។

ការអាន គឺមិនគ្រាន់តែដើម្បីទទួលព័ត៌មាននោះទេ បើទោះជាថានោះជាគោលបំណងមួយនៃការអានស្អីក៏ដោយ។ តែអ្នកសារព័ត៌មានបំណានៗអានដើម្បីមើលអំពីរបៀបសរសេរ។ យើងហៅ ការអានរបៀបនេះថា អានដើម្បីស្វែងយល់អំពីទម្រង់ការសរសេរ និងស្វែងយល់អំពីខ្លឹមសារ។ ទម្រង់ គឺសំដៅលើទ្រង់ទ្រាយ គ្រោងរបស់រឿង។ រីឯខ្លឹមសារសំដៅលើធាតុផ្សំ។ វាមានសារៈសំខាន់ក្នុងការពិនិត្យ និងត្រងត្រាប់តាមសំណេរដែលមានទម្រង់ល្អ។ ចូរចែករម្លែកវាជាមួយសហសេវិក ហើយសាទរអ្នកទាំងឡាយដែលបានសរសេរល្អ។ ប្រាប់គេថាអ្នកពេញចិត្តនឹងសំណេរនោះណាស់។ ទាំងអស់នឹងវាបំពេញបន្ថែមដល់លទ្ធភាព និងសេចក្ដីរីករាយរបស់យើងចំពោះការងារ និងបំពេញដល់សញ្ញាណនៃភាពជាអាជីពនៅក្នុងការិយាល័យផងដែរ។

ការអាន ក៏រួមចំណែកដល់គោលការណ៍មួយទៀតនៃសារព័ត៌មានប្រពៃដែរ នោះ គឺសំណួរថាតើមានហេតុផលគ្រប់គ្រាន់សម្រាប់ខ្ញុំនឹងជឿថាអ្វីមួយមានការពិត ឬក៏អត់? ក្នុងរបរជាអ្នកសារព័ត៌មាន យើងជួបប្រទះព័ត៌មាន ទស្សនៈ និងមតិគ្រប់បែបយ៉ាងទាំងអស់។ ប្រសិនបើយើងត្រូវ

បញ្ជូនវាបន្តទៅឲ្យអ្នកអាន អ្នកស្តាប់ ឬទស្សនិកជន
យើងចាំបាច់ត្រូវតែជួយពួកគេក្នុងការពិនិត្យ
ភស្តុតាង។ យើងត្រូវតែបេះមន្ទិល និងទិតៀន។
មន្ទិលមានន័យថា អ្នកមិនបេះតែងាយជឿអ្វីមួយ
ដោយគ្មានភស្តុតាងមកគាំទ្រនោះទេ។ ប៉ុន្តែនេះ
ក៏មិនមែនមានន័យថា អ្នកត្រូវតែឃើញអ្វីៗក្នុងផ្លូវ
អាក្រក់ទាំងអស់ (cynical) នោះដែរ (បើទោះជា
ជាអ្នកសារព័ត៌មានភាគច្រើនប្រកាន់ជំហរបែបនោះ
មែន) ដែលតែងគិតថាអ្នកដទៃសុទ្ធតែនិយាយ
កុហកទាំងអស់។ មន្ទិលក្នុងបរិបទនេះមានន័យថា
ស្អីក៏ដោយដែលគេនិយាយប្រាប់អ្នក ត្រូវតែឆ្លងកាត់
តេស្តមុននឹងយកជាការបាន។ សាកល្បងបង្កើតនូវ
ទម្លាប់ក្នុងការសួរសំណួរដូច្នេះថា ហេតុអ្វីបានជា
មនុស្សម្នាក់នេះនិយាយប្រាប់ខ្ញុំដូច្នេះ? តើមាន
ហេតុផលអ្វីខ្លះទៅ ដែលពួកគេមើលឃើញអ្វីមួយ
តាមបែបម្យ៉ាងជាជាងតាមបែបណាផ្សេងទៀត។
ក្នុងន័យម្យ៉ាងទៀត តើពួកគេមានប្រយោជន៍ណា
មួយទេដឹងក្នុងការប្រកាន់ជំហរបែបនេះ? តើគេនឹង
បំណេញ ឬខាតអ្វីខ្លះទៅ ប្រសិនបើព័ត៌មាន ឬមតិ
បែបនេះត្រូវបានគេយកទៅចុះផ្សាយ? តើពួកគេ
ស្ថិតក្នុងស្ថានភាពមួយ ដែលពួកគេអាចដឹងពិត
ប្រាកដអំពីអ្វី ដែលពួកគេកំពុងនិយាយនោះទេ?
តើគេមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងធ្វើការ
វិនិច្ឆ័យលើអ្វីមួយ បើគ្រាន់តែពួកគេធ្លាប់ស្គាល់ ឬ
ធ្លាប់មានបទពិសោធន៍ជាមួយវានោះ? តើពួកគេ
កំពុងបញ្ជូនពីមួយទៅមួយនូវអ្វី ដែលយើងហៅថា
ការនិយាយតៗគ្នា? ក្នុងករណីនេះ អ្នកគួរព្យាយាម
រកព័ត៌មាននោះពីប្រភពដើមឲ្យបាន។ គួរសួរខ្លួនឯង
ផងថា តើខ្ញុំបានព្យាយាមអស់សមត្ថភាពទេក្នុងការ
ស្វែងរកអ្នកផ្សេង ដែលអាចផ្តល់ព័ត៌មានធ្វើអត្ថបទ
របស់ខ្ញុំឲ្យមានតុល្យភាព? តើខ្ញុំបានព្យាយាមរកឲ្យ
បានប្រភពដែលមានឈ្មោះ និងអាជ្ញា ដែលខ្ញុំអាច
ដាក់បន្ទុកព័ត៌មានបាន ដើម្បីឲ្យអ្នកអានអាចវាយ
តម្លៃបាននូវអ្វីដែលគេបាននិយាយនោះ? ជាធម្មតា
វាអូខេក្នុងការជឿភ្នែករបស់ខ្លួន តែក្នុងករណីភាគ
ច្រើន អ្នកគួរធ្វើឲ្យប្រាកដថា ត្រូវមានប្រភពច្រើន
ជាងមួយសម្រាប់ជាសំអាង គាំទ្រដល់អ្វីមួយដែល
អ្នកមិនបានឃើញផ្ទាល់ភ្នែក។ ចូរចាំថា ពេលណា
ព័ត៌មានកាន់តែសុក្រឹត អ្នកក៏គួរតែកាន់តែប្រយ័ត្ន-
ប្រយែងផងដែរ។

និយាយម្យ៉ាងទៀត ធ្វើខ្លួនជាអ្នកសារព័ត៌មានល្អ
មួយរូប វាប្រៀបបាននឹងធ្វើខ្លួនជាចៅក្រមម្នាក់ផង
ដែរ។ បានន័យថា អ្វីដែលអ្នកសម្រេចថានឹងបញ្ជូន
បន្តទៅឲ្យអ្នកអាន គួរត្រូវបានត្រិះរិះឲ្យបានល្អិតល្អន់
ដូចគ្នានឹងចៅក្រមពិចារណាចេញសាលក្រមលើ
ករណីមួយដែរ។ អ្នកត្រូវធ្វើការសម្រេចថា តើអ្នកមាន
អំណះអំណាងគ្រប់គ្រាន់ សាក្សីគ្រប់គ្រាន់ ភស្តុតាង
ឯកសារ និងរូបវន្តគ្រប់គ្រាន់ហើយ ឬនៅ។ ធម្មតា
ក្នុងការងារយកព័ត៌មានប្រចាំថ្ងៃ របស់ទាំងអស់នេះ
អាចងាយរកបានទេ (ប៉ុន្តែចូរប្រយ័ត្ន កុំបន្ទាប
ស្តង់ដាររបស់ខ្លួន បើទោះជាជាមួយរឿងដែលយើង
ធ្លាប់សរសេរជាប្រចាំហើយក្តី)។ យ៉ាងណាមិញ
ក្នុងទម្រង់វិជ្ជាជីវៈសារព័ត៌មានកម្រិតខ្ពស់ ដូចជា
ការសរសេរអំពីធុរកិច្ច សេដ្ឋកិច្ច វិទ្យាសាស្ត្រ បរិស្ថាន
នយោបាយ និងរដ្ឋាភិបាលជាដើម ភស្តុតាងអាចនឹង
ពិបាករកបានដែរ ហើយបច្ច័យនៃការខ្វះការមន្ទិល
សង្ស័យ ក៏អាចមានសភាពធ្ងន់ធ្ងរផងដែរ។

**ភាពឈ្មុសឈ្មុល** និង**ឧស្សាហ៍ព្យាយាម** ក្នុងការ
ប្រមូលព័ត៌មាន និងទស្សនៈសម្រាប់យកមកសរសេរ
រឿងរបស់អ្នក នឹងជួយធ្វើឲ្យរឿងនោះកាន់តែមាន
**ភាពជឿជាក់បាន** ព្រមទាំងនាំមកនូវ**កេរ្តិ៍ឈ្មោះ**ល្អ
ដល់អង្គភាពរបស់អ្នកផងដែរ។ បើនិយាយក្នុងន័យ
បែបរកស៊ីវិញ វាក៏កាន់តែមានប្រយោជន៍ក្នុងការធ្វើ
ឲ្យគេទុកចិត្ត ពីព្រោះអ្នកអានគេនឹងចូលចិត្តកាសែត
របស់អ្នក។ ប៉ុន្តែការធ្វើតាមស្តង់ដារទាំងអម្បាលម៉ាន
នេះ ក៏ជាផ្នែកមួយផងដែរនៃ **ក្រមសីលធម៌សារ-**

**ព័ត៌មានអាជីព** ដែលក្នុងនោះ យើងត្រូវមានភារកិច្ច និងភក្ដីភាពជាបឋមបំផុតចំពោះអ្នកអាន។ ម្ដងទៀត គឺអ្នកអាន មិនមែនចំនួនកាសែតចេញផ្សាយក្នុងមួយលេខៗនោះទេ។ អ្នកអាន គឺមនុស្សដូចរូបអ្នក និងខ្ញុំដែរ ដែលមានគ្រួសារ សេចក្ដីសង្ឃឹម និងគុណវិបត្តិ។

ព័ត៌មាន ពុទ្ធិ និងសេចក្ដីរីករាយ ដែលកើតមានពីការអាន អាចនាំមកនូវអត្ថប្រយោជន៍ធំធេងចំពោះគុណភាពនៃជីវិតសម្រាប់មនុស្សភាគច្រើន។ យើងមានកាតព្វកិច្ចក្នុងការផ្ដល់ជូនពួកគេនូវវិស័យសារព័ត៌មានមួយ ដែលយកចិត្តទុកដាក់ចំពោះភាព**ទៀងត្រង់ជាក់លាក់ ភាពត្រឹមត្រូវសមរម្យ និងតុល្យភាព** ដែលក្នុងនោះ **យើងសម្ដែងភាពសេចក្ដីស្មោះត្រង់ និងវិស្សុតចិត្ត** ហើយមិនលួចស្នាដៃស្មេររបស់អ្នកដទៃយកមកចុះផ្សាយថាជារបស់ខ្លួនឯងនោះ។ ក្នុងជីវភាពប្រចាំថ្ងៃ យើងពិតជាយល់ថាមានន័យយ៉ាងម៉េច ហើយពេលណាយើងនិយាយថានរណាម្នាក់មានសេចក្ដីស្មោះត្រង់ និងមានវិស្សុតចិត្ត។ តើមានហេតុផលអ្វីដែលមិនរាប់បញ្ចូលអ្នកសារព័ត៌មានផងទៅក្នុងនោះ?

ពិតណាស់ នេះមិនមានន័យថា រៀងរាល់រឿងដែលយើងសរសេរនឹងនាំទៅដល់សច្ចភាពអស្ចារ្យនោះទេ ឬមួយក៏ថា វិស័យសារព័ត៌មានជាអាជីពប្រកបដោយ**កម្មវិស័យភាព (objective)** ទាំងស្រុង និងមិនអាចស្ថិតក្រោមឥទ្ធិពលវប្បធម៌របស់យើង ទីតាំងប្រទេសយើងនៅលើពិភពលោក កំហិតនៃបទពិសោធន៍របស់កម្រិតអប់រំ និងពុទ្ធិរបស់យើងនោះទេ។ អ្វីដែលយើងចង់មានន័យនៅទីនេះ គឺថាយើងគួរ ហើយពិតជាព្យាយាមយកអស់សមត្ថភាពជំនះការខ្វះចន្លោះរបស់យើង ហើយតាមការធ្វើរបៀបនេះ យើងទទួលស្គាល់ថាចាំបាច់ត្រូវតែប្រឹង-ប្រែងស្រាវជ្រាវ និងធ្វើការផ្ទៀងផ្ទាត់ឲ្យបានហ្មត់ចត់ទោះជារឿងមួយ ឬវត្ថុមួយមានការពិតប្រកបដោយសារៈសំខាន់តូចតាចក្ដី។ យើងហៅវាថា **ការណ៍ពិត (អង្គហេតុ / facts )**។ វាជាភារកិច្ចរបស់យើងក្នុងការរកការណ៍ពិតឲ្យឃើញ យកមកចុះផ្សាយជាបំណាប់អារម្មណ៍ដល់អ្នកទាំងឡាយដែលយើងហៅថា មិត្តអ្នកអាននោះ។

**JEFF HODSON និង GRAHAM WATTS**
**បាងកក ខែឧសភា ឆ្នាំ ២០១០**

***សេចក្ដីនិទានខ្លី (Anecdote)***

ជាការដំណាលអង្គហេតុខ្លីៗក្នុងបទពិពណ៌នា។ តាមធម្មតា វាមានតែប៉ុន្មានកថាខណ្ឌទេ ដែលឆ្លុះបញ្ចាំងអំពីចំណុចគោលគំនិតសំខាន់ៗដែលអ្នកសរសេរចង់និយាយ។

***មុម (Angle)***

ជារបៀប ឬចំណុចទស្សនៈជាក់លាក់មួយក្នុងការសរសេររឿង។ ព្រឹត្តិការណ៍ខ្លះអាចមានទិដ្ឋភាពគួរចាប់អារម្មណ៍ប្រហាក់ប្រហែលគ្នាច្រើន ហើយអ្នកសារព័ត៌មានអាចជ្រើសរើសយកទិដ្ឋភាពណាមួយក្នុងចំណោមទិដ្ឋភាពទាំងនោះ មកធ្វើជាចំណុចផ្ដោតការសរសេរ។

***ប្រភពអនាមិក (Anonymous source)***

ជាប្រភពដែលផ្ដល់ព័ត៌មានតែក្នុងករណីដែលអ្នកយកព័ត៌មានមិនបញ្ចេញឈ្មោះរបស់គេនៅក្នុងអត្ថបទរឿង។

***បន្ទុកព័ត៌មាន (Attribution)***

ជាវិធីដែលអ្នកសារព័ត៌មានបង្ហាញប្រភពសម្ដីដើម ឬព័ត៌មាននៅក្នុងរឿង។

***សាវតារ (Background)***

ជាព័ត៌មាននៅក្នុងរឿងដែលប្រាប់អ្នកអាននូវអ្វីដែលបានកើតឡើងពីអតីតកាល ហើយដែលមានទំនាក់ទំនងជាមួយព្រឹត្តិការណ៍ ដែលកំពុងតែត្រូវបានគេរាយការណ៍នៅក្នុងរឿង។ សាវតារជួយអ្នកអានឲ្យយល់សាច់រឿងបានកាន់តែច្បាស់។

***តុល្យភាព និងភាពទៀងត្រង់ (Balance and fairness)***

ជាលក្ខណៈសម្បត្តិសំខាន់សម្រាប់រឿងល្អមួយ គឺថាអ្នកយកព័ត៌មានប្រាប់ដល់អ្នកអានអំពីជ្រុងទាំងសងខាងនៃបញ្ហាដោយមិនលម្អៀងទៅខាងភាគីណាមួយ។

***តួសេចក្ដី (Body)***

ជាផ្នែកធំមួយរបស់អត្ថបទដំណឹង ដែលក្នុងនោះមានសេចក្ដីលម្អិត សម្ដីដើម និងធាតុផ្សំដទៃទៀត។

***បរិបទ (Context)***

ជាព័ត៌មានក្នុងសាច់រឿងដែលប្រាប់អ្នកអាននូវស្ថានភាពទូទៅបច្ចុប្បន្ន ដែលមានទំនាក់ទំនងជាមួយព្រឹត្តិការណ៍ កំពុងត្រូវបានរាយការណ៍នៅក្នុងរឿងនោះ។

***វិចារណកថា (Editorial)***

ជាអត្ថបទ ដែលក្នុងនោះ អ្នកសរសេរសំដែងមតិរបស់ខ្លួន ឬក៏យោបល់របស់កាសែតមួយថា តើបញ្ហា ឬរឿងមួយនុ៎ះវាល្អ ឬអាក្រក់។ ក្នុងបណ្ដាកាសែតល្បីឈ្មោះ វិចារណកថាត្រូវបានគេញែកឲ្យនៅដោយឡែកពីអត្ថបទដំណឹង ហើយគេចុះផ្សាយវាលើអ្វី ដែលគេហៅថា ទំព័រវិចារណកថា។

***បម្រាមផ្សាយមុនកាលបរិច្ឆេទ (Embargo)***

ជាបំរាមការផ្សាយសេចក្ដីប្រកាសព័ត៌មាន ឬរបាយការណ៍មុនថ្ងៃ ឬម៉ោងកំណត់។ ក្នុងករណីនេះ អ្នកសារព័ត៌មានត្រូវបានគេឲ្យឯកសារជាមុន (ដូចជាពង្រាងសុន្ទរកថាសំខាន់ៗ) មុននឹងការបញ្ចេញជាផ្លូវការរបស់វាក្នុងលក្ខខណ្ឌថាពួកគេនឹងមិនយកទៅសរសេរចុះផ្សាយមុនកាលបរិច្ឆេទ។

***បទពិពណ៌នា (Feature)***

ជាអត្ថបទមានលក្ខណៈជូនព័ត៌មាន (informative) និងកំសាន្ត (entertaining) ដែលមិនចាំបាច់ជាទាក់ទិនព្រឹត្តិការណ៍ណាមួយ ដែលទើបនឹងកើតឡើងនោះទេ ហើយធម្មតាអត្ថបទប្រភេទនេះ ត្រូវការធ្វើការស្រាវជ្រាវច្រើនយកមកសរសេរ។

***រឿងចំណាប់អារម្មណ៍មនុស្ស (Human interest)***

សំដៅព្រឹត្តិការណ៍ ឬស្ថានការណ៍ណាមួយ ដែលអាចមានឥទ្ធិពលលើមនោសញ្ចេតនារបស់អ្នកអាន។

***ពីរ៉ាមីដផ្ការ (Inverted pyramid)***

ជាគ្រោងរបស់រឿង ដែលក្នុងនោះ ព័ត៌មានសំខាន់ជាងគេត្រូវបានដាក់នៅខាងលើបំផុត (ឬសេចក្តីផ្តើម) បន្តដោយព័ត៌មានដែលជាជន្ទល់ដល់សេចក្តីផ្តើមនោះ និងព័ត៌មានសំខាន់បន្ទាប់បន្សំផ្សេងទៀត។

***ពាក្យឯកទេស (Jargon)***

ជាពាក្យពិសេសប្រើដោយក្រុមមនុស្សដែលមានការងារដូចគ្នា ដូចជា មន្ត្រីរដ្ឋាភិបាល សេដ្ឋកិច្ចវិទូ និងអ្នកសារព័ត៌មាន។ មនុស្សទូទៅមិនសូវយល់ពាក្យទាំងនោះទេ។

***សេចក្តីផ្តើម (Lead)***

ជាក្បាលរបស់អត្ថបទ។ សេចក្តីផ្តើមត្រង់នាំអ្នកអានទៅដល់ចំណុចគោលរបស់សាច់រឿងភ្លាមគ្មានដំអក់ទេ។ ភាគច្រើននៃដំណឹងព្រឹត្តិការណ៍ចាប់ផ្តើមដោយសេចក្តីផ្តើមត្រង់។ សេចក្តីផ្តើមដំអក់នាំអ្នកអានទៅដល់ចំណុចសំខាន់ និងសាច់រឿងបន្ទាប់ពីអ្នកសរសេរបង្ហាញនូវឧទាហរណ៍ ឬសេចក្តីនិទានខ្លីៗ ឬក៏រៀបរាប់ឆាកសិន។ ភាគច្រើននៃបទពិពណ៌នាប្រើសេចក្តីផ្តើមដំអក់។

***ដំណឹង (News)***

ជារឿងស្តីអំពីព្រឹត្តិការណ៍ដែលទើបនឹងកើតឡើង ហើយគួរត្រូវបានរាយការណ៍ជូនអ្នកអានភ្លាមៗតែម្តង។ ជួនកាលគេហៅវាថា "ដំណឹងទាន់ហេតុ-ការណ៍ " ឬ "ដំណឹងភ្លាមៗ "។

***បទដំណឹងពិពណ៌នា (News feature)***

ជារឿងដែលកសាងឡើងលើព្រឹត្តិការណ៍ ដោយប្រើតិចនិកសរសេរ បទពិពណ៌នា រួមបញ្ចូលដោយផ្ទាក់ទាញអារម្មណ៍មនុស្ស។

***កម្មវិស័យភាព (Objectivity)***

ជាលក្ខណៈសម្បត្តិសំខាន់សម្រាប់រឿងល្អមួយ គឺអ្នកយកព័ត៌មានទុកយោបល់ និងអារម្មណ៍ផ្ទាល់ខ្លួនដោយឡែកឲ្យឆ្ងាយពីសាច់រឿងតាមតែអាចធ្វើទៅបាន ហើយរៀបរាប់ជូនអ្នកអានតអង្គហេតុប៉ុណ្ណោះ។

***ក្នុងកំណត់ត្រា* (On the record)**

ការរៀបរាប់ព័ត៌មានពីសំណាក់ប្រភពមួយ ដែលប្រភពនោះ យល់ព្រមថាអាចប្រើប្រាស់បាន នៅក្នុងសាច់រឿង ហើយដាក់បន្ទុកទៅលើពួកគេវិញ ដោយចំហ។

***ក្រៅកំណត់ត្រា* (Off the record)**

ការរៀបរាប់ព័ត៌មានពីសំណាក់ប្រភពមួយ ដែលប្រភពនោះមិនចង់ឲ្យគេយកទៅចុះផ្សាយ ឬ យល់ព្រមឲ្យគេយកទៅចុះផ្សាយដែរ តែភ្ជាប់ជាមួយ ការដាក់កំហិតលើការដាក់បន្ទុកព័ត៌មាន។

***សម្រង់សម្ដីដើម* (Quotation)**

ជាពាក្យពេចន៍ដើមសុទ្ធសាធដែលប្រពកមួយ បាននិយាយពេលដែលគេធ្វើសុន្ទរកថា ឬផ្ដល់ បទសម្ភាសន៍។ តាមធម្មតា ពាក្យពេចន៍ដើមបែបនេះ ត្រូវប្រើដោយដាក់ក្នុងចន្លោះអព្ភន្តរសញ្ញា ("") ក្នុងអត្ថបទដំណឹង ឬបទពិពណ៌នា។

***ចុះវាយ៉ាងម៉េច* ? (So what?)**

ពាក្យនេះ មានន័យក្រើនរម្លឹកអ្នកយកព័ត៌មាន ឲ្យបញ្ចូលក្នុងរឿងរបស់ពួកគេនូវសារៈសំខាន់នៃ ព្រឹត្តិការណ៍ ដំណឹង ឬបទពិពណ៌នារបស់ពួកគេ។ វាជួយប្រាប់ដល់អ្នកអានថាហេតុអ្វីពួកគេគួរខ្វល់នឹង រឿងនោះ ហើយថាតើរឿងនោះអាចមានឥទ្ធិពលមក លើមនុស្សម្នាដូចម្ដេចខ្លះ។

***ការផ្ទៀងផ្ទាត់* (Verification)**

ជាបណ្ដាជំហានទាំងឡាយដែលអ្នកយក ព័ត៌មានធ្វើ ដើម្បីធានាឲ្យបានថាព័ត៌មានដែលគេ ទទួលបានពីប្រភពមានសច្ចភាព។ ការផ្ទៀងផ្ទាត់ នោះ អាចមានការសង្កេត ការនិយាយជាមួយប្រភព ដទៃទៀត ឬក៏ការពិនិត្យមើលឯកសារ។

# ជំពូក ១
# ទៅហួសពី 5Ws និង H

ការប្រមូលព័ត៌មានទៀងត្រង់ដាក់លាក់យកមកសរសេររឿងផ្សាយដល់សាធារណជនឲ្យបានទាន់ពេលវេលា តែងតែទាមទារឲ្យមានការខិតខំមែនទែន ហើយវាក៏មិនមែនងាយប៉ុន្មានទេក្នុងការប្រមូលឲ្យបានអស់នូវអង្គហេតុសំខាន់ៗនៃព្រឹត្តការណ៍ គឺអង្គហេតុអំពី " អ្នកណា ស្អី ទីណា ពេលណា ហេតុអ្វី និងដោយរបៀបម៉េច "(who, what, where, when, why and how)។ ប៉ុន្តែអ្នកសារព័ត៌មានបច្ចុប្បន្ននេះ ត្រូវធ្វើច្រើនជាងនេះទៅទៀតដោយហេតុថា ការណ៍ពិត ឬអង្គហេតុជាមូលដ្ឋាននោះ មិនទាន់គ្រប់គ្រាន់នឹងជួយអ្នកអានឲ្យយល់អំពីដំណឹងមួយបានទេ។ អ្នកអានពិតជាចង់ដឹងថា រឿងមួយហ្នឹងធ្លាប់កើតពីមុនម្តងហើយ ឬនៅ? តើវាអាចកើតម្តងទៀតទេ? តើវានឹងមានផលប៉ះពាល់បែបណាខ្លះមកលើខ្ញុំ? តើមានអ្វីដែលខ្ញុំអាចធ្វើបានទេ ចំពោះហេតុការណ៍ហ្នឹង?

អ្នកសារព័ត៌មានអាចជួយបានតាមរយៈការបន្ថែមសាវតារ បរិបទ និងអត្ថន័យ ទៅនឹងអត្ថបទរឿង។ ពួកគេក៏អាចជួយផលិតនូវរឿងដ៏គួរឲ្យជក់ចិត្តផងដែរ តាមរយៈការបញ្ចូលនូវសម្លេងឲ្យបានច្រើន ជាពិសេសពីក្នុងចំណោមជនសាមញ្ញ ដែលនឹងទទួលរងនូវឥទ្ធិពលរបស់ដំណឹងក្នុងរឿងនោះ។ ក្រោយមកទៀត អ្នកសារព័ត៌មានអាចជួយអ្នកអានរបស់ខ្លួនឲ្យកាន់តែយល់បានប្រសើរថែមទៀតនូវបញ្ហា និងព្រឹត្តិការណ៍នានា ដោយផ្តល់ជូននូវភស្តុតាងគួរឲ្យជឿទុកចិត្តអំពីអ្វីដែលកំពុងកើតឡើង ហើយថាតើវាកើតឡើងដោយរបៀបណា។

## សាវតារ

សាវតារជួយប្រាប់ឲ្យយើងដឹងថាតើរឿងមួយនឹងចេញមកពីណា ហើយថាតើពីមុនមកមានអ្វីកើតឡើងទាក់ទិនជាមួយនឹងរឿងនេះ។ តាមធម្មតា អ្នកសារព័ត៌មាន និងនិពន្ធនាយករបស់គេដឹងច្បាស់អំពីសាវតារនៃបញ្ហាមួយ តែគេច្រើនមិនយកវាមកប្រើក្នុងសាច់រឿង។ នេះជាកំហុសមួយ។ អ្នកសរសេរព័ត៌មានមិនត្រូវសន្មតថាអ្នកអាននៅចាំអ្វីៗគ្រប់បែបយ៉ាងដែលបានកើតពីមុនមកនោះទេ។ អ្នកអានភាគច្រើនជាប់រវល់ជាមួយនឹងការងារ គ្រួសារ និងមិត្តភក្តិ ហើយពួកគេក៏នៅមានរឿងច្រើនដែរ ដែលគេត្រូវការយកចិត្តទុកដាក់លើរាល់ថ្ងៃ។ សាវតារ និងការពន្យល់បន្តិចបន្តួចអាចជួយពួកគេឲ្យយល់សាច់រឿងបានល្អជាងមុន។ ក្នុងសាវតារអាចមាននិយមន័យ និងការពន្យល់។ វាអាចជាព្រឹត្តិការណ៍ថ្មីៗ ឬក៏ប្រវត្តិសាស្ត្រអតីតកាល។ និយាយឲ្យខ្លីវាជាការរម្លឹកឡើងវិញនូវអ្វីដែលបានកន្លងផុតទៅ។

ចូរក្រឡេកមើលសេចក្តីផ្តើមនៃរឿងខាងក្រោមនេះ ដែលសាវតារមានការគូសបន្ទាត់បញ្ជាក់ពីខាងក្រោម ៖

*HANOI, Vietnam (AP) - សហរដ្ឋអាមេរិក និងប្រទេសវៀតណាម កាលពីថ្ងៃច័ន្ទ កន្លងទៅនេះ បានបើកកិច្ចប្រជុំលើកទីបីនៃកិច្ចចរចាប្រចាំឆ្នាំ របស់ខ្លួន ដើម្បីរកវិធីកំហិតផលប៉ះពាល់បរិស្ថាន ពីសំណាក់សារធាតុ Agent Orange ដែលជាសារធាតុគីមីពុលជម្រុះស្លឹកឈើសហរដ្ឋអាមេរិក បានបាចយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងអំឡុងសង្គ្រាមវៀតណាម។*

*ក្រុមមន្ត្រី និងអ្នកឯកទេសមកពីប្រទេសទាំងពីរ បានបើកកិច្ចប្រជុំពេញមួយសប្ដាហ៍ រួមមាន ដំណើរទស្សនកិច្ចទៅកាន់អតីតមូលដ្ឋានទ័ពអាកាសអាមេរិកនៅ Bien Hoa ជាកន្លែងមួយក្នុងចំណោម "ចំណុចក្ដៅ " Agent Orange ដែលនៅទីនោះ យោធាអាមេរិកស្តុកទុក និងលាយ Agent Orange មុននឹងគេលើកដាក់ក្នុងយន្តហោះចេញប្រតិបត្តិការ។*

*ភាគីទាំងពីរត្រូវបានរំពឹងថានឹងប្រកាសផែនការសម្រាប់ប្រើប្រាស់ថវិកា ៣ លានដុល្លារ ដែលសភាអាមេរិកបានអនុម័តនៅឆ្នាំ ២០០៧ សម្រាប់សម្អាតសារធាតុឌីអុកស៊ីន ដែលជាធាតុផ្សំមានសារជាតិពុលខ្ពស់បំផុតក្នុង Agent Orange។*

*កងកម្លាំងយោធាសហរដ្ឋអាមេរិកបានបាច Agent Orange បំណុះរាប់លានលីត្រទៅលើព្រៃប្រទេសវៀតណាមក្នុងអំឡុងពេលសង្គ្រាម ដើម្បីកុំឲ្យទាហានវៀតណាមមានព្រៃធ្វើជម្រកលាក់ខ្លួន និងដើម្បីកម្ទេចនូវដំណាំស្បៀង។*

*ប្រទេសវៀតណាមជឿថា យ៉ាងហោចណាស់មានប្រជាជនរបស់ខ្លួនដល់ទៅ ៤ លាននាក់ ដែលមានបញ្ហាសុខភាពធ្ងន់ធ្ងរ ដោយសារតែសារធាតុ Agent Orange នោះ។ សហរដ្ឋអាមេរិកនិយាយថា ចំនួនអ្នករងគ្រោះអាចមានទាបជាងនេះឆ្ងាយណាស់ ហើយថាគេចាំបាច់ត្រូវមានការសិក្សាបែបវិទ្យាសាស្ត្រមួយ ដើម្បីស្វែងយល់អំពីទំនាក់ទំនងរវាង Agent Orange និងសុខភាព។*

សាវតារចាប់ផ្ដើមដោយឃ្លាមួយ ដែលបន្ថែមន័យទៅឲ្យសេចក្ដីផ្ដើម ហើយវាបន្តដោយឃ្លាមួយទៀតនៅខាងចុងកថាខណ្ឌទីពីរ។ នៅមានជំនួយសាវតារថែមទៀតនៅខាងចុងកថាខណ្ឌទីបី។ រីឯកថាខណ្ឌទីបួន និងទីប្រាំ ក៏សុទ្ធតែជាសាវតារដែរ។



*នៅអាស៊ីអាគ្នេយ៍ ប្រពៃណីចាស់ និងទម្លាប់ថ្មីសម័យទំនើប កំពុងប្រជែងគ្នាយ៉ាងរស់រវើក។*

ដូច្នេះ អ្នកអានអាចយល់បានថា ហេតុអ្វីបានជា Agent Orange ត្រូវបានគេប្រើ ហើយថាតើយល់ខុសគ្នាបែបណាខ្លះអំពីផលប៉ះពាល់របស់វាក្នុងពេលសង្គ្រាម។ ក្នុងករណីនេះ សាវតារក៏បានប្រាប់យើងដែរថាហេតុអ្វីបានជារឿងនេះសំខាន់នោះ គឺនៅត្រង់ថាមានមនុស្សរហូតដល់ទៅ ៤ លាននាក់ ដែលអាចមានបញ្ហាសុខភាពធ្ងន់ធ្ងរ ដោយសារតែ Agent Orange។ រឿងនេះនឹងមិនសូវមានប្រយោជន៍ទេ ប្រសិនបើគេមិនបានពន្យល់ប្រាប់ថា Agent Orange ជាស្អី ហើយថាតើវាមានផលប៉ះពាល់អ្វីខ្លះទៅលើប្រជាជន។

អ្នកសារព័ត៌មានខ្លះរអ៊ូថា ពួកគេមិនទទួលបានប្រឡោះគ្រប់គ្រាន់ទេក្នុងទំព័រកាសែត សម្រាប់ចុះផ្សាយរឿងរបស់គេ ដូច្នេះហើយពួកគេទុកចោល

សារតារនៅក្រៅសាច់រឿង។ នេះជាភាពប្រឈមធំមួយ។ អ្នកសារព័ត៌មានចាំបាច់ត្រូវចេះសៀតចំរៀកសារតារទៅក្នុងសាច់រឿងរបស់គេ យ៉ាងហោចណាស់ក៏មួយឃ្លាដែរ។ អ្នកសារព័ត៌មានចំណានៗដឹងអំពីរបៀបប្រើប្រាស់សារតារ ដោយដាក់វាក្នុងឃ្លាប្រយោគណា ដែលគេគិតថាអ្នកអានត្រូវការវាបំផុត។

## ទិដ្ឋភាពទូលំទូលាយ

អត្ថបទរឿងទាំងឡាយកាន់តែមានប្រយោជន៍ថែមទៀត បើវាមានបរិបទនៅក្នុងនោះ។ បន្ថែមបរិបទទៅក្នុងរឿង មានន័យថា បញ្ចូលព័ត៌មានអំពីអ្វីផ្សេងទៀតដែលកំពុងកើតឡើង ដែលអាចទាក់ទិនជាមួយនឹងព្រឹត្តិការណ៍ ឬបញ្ហាដែលអ្នកកំពុងសរសេរ។ វាមានន័យថា យកព្រឹត្តិការណ៍ ឬការវិវត្តចុងក្រោយ ហើយប្រៀបធៀបវាជាមួយនឹងអ្វីមួយផ្សេងទៀត។ បរិបទផ្តល់ឲ្យអ្នកអាននូវទិដ្ឋភាពមួយកាន់តែធំ និងពេញលេញជាងមុន។

បើអ្នកសរសេរអំពីសេដ្ឋកិច្ចជាតិ ឬអំពីផ្សារភាគហ៊ុនក្នុងស្រុក វាប្រហែលជាមានប្រយោជន៍ក្នុងការនិយាយរម្លឹកថាតើមានអ្វីខ្លះកំពុងកើតឡើងដល់សេដ្ឋកិច្ច ឬផ្សារភាគហ៊ុនដទៃទៀតក្នុងតំបន់។ តើតម្លៃផ្សារភាគហ៊ុនកំពុងធ្លាក់ចុះនៅគ្រប់ទីកន្លែងឬ? ប្រហែលជាបុព្វហេតុមានដូចតែគ្នាទេ ៖ ការរឹតបន្តឹង ការផ្តល់ឥណទាន ធនាការរកស៊ីមិនសូវកាក់កប ការធ្លាក់ចុះនូវការជឿជាក់របស់អ្នកប្រើប្រាស់។ វាពិតដូចគ្នាដែរសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចឯទៀត។ វិបត្តិសេដ្ឋកិច្ចឆ្នាំ ២០០៨ បានប៉ះទង្គិចទៅលើសេដ្ឋកិច្ចនៅអាស៊ីទាំងអស់ពេលដែលការនាំចេញទៅអាមេរិកខាងជើង និងអឺរ៉ុបធ្លាក់ចុះ។ ខាងក្រោមជាឧទាហរណ៍ពីកាសែត Washington Post ដែលបង្ហាញអំពីរបៀបប្រើទិដ្ឋភាពទូលំទូលាយពីឃ្លាមួយទៅឃ្លាមួយ។ *[ចូរមើលផ្នែកដែលមានគូសបន្ទាត់ពីក្រោម]* ៖

*ប្រទេសជប៉ុនបានរាយការណ៍ឲ្យដឹងកាលពីម្សិលមិញថា ការនាំចេញរបស់គេបានធ្លាក់ចុះខ្លាំងមិនដែលធ្លាប់មាន គឺរហូតដល់ទៅ ២៧ ភាគរយក្នុងខែវិច្ឆិកា ដែលនេះជាសញ្ញានៃភាពចុះខ្សោយមែនទែននៃសេដ្ឋកិច្ចធំទីពីររបស់ពិភពលោក និងការដួលរលំនូវកំណើនដឹកមុខ ដោយការនាំចេញដែលបានជួយស្តួចសេដ្ឋកិច្ចនៃប្រជាជាតិអាស៊ីជាច្រើនឲ្យកើនឡើងកន្លងមក។*

*សូម្បីតែក្រុមហ៊ុន Toyota ដែលធ្លាប់តែខ្លាំងនោះ ក៏និយាយពីម្សិលមិញដែរថា គេនឹងប្រកាសការខាតផ្នែកប្រតិបត្តិការរបស់គេជាលើកដំបូងក្នុងប្រាំពីរទសវត្សរ៍ ដែលបង្ហាញជាឧទាហរណ៍នៃឥទ្ធិពលការធ្លាក់ចុះសេដ្ឋកិច្ចសកលលោក ដែលសូម្បីតែក្រុមហ៊ុនធំៗ ដែលធ្លាប់តែរកស៊ីបានផលចំណេញច្រើន ក៏ទប់ទល់មិនបានដែរ។*

*ឱនភាពនៃការនាំចេញរបស់ប្រទេសជប៉ុនកំពុងជះឥទ្ធិពលនៅទូទាំងទ្វីបអាស៊ី ដែលនៅទីនោះពីប្រទេសមួយទៅប្រទេសមួយ គេបានរាយកាណ៍ទិន្នន័យ ដែលមានការព្យាករណ៍គួរឲ្យអាប់អួមែនទែន។ ម្សិលមិញ ប្រទេសថៃនិយាយថា ការនាំចេញរបស់គេក្នុងខែវិច្ឆិកា ធ្លាក់ចុះជិត ១៩ ភាគរយ ដែលខ្លាំងមែនទែនក្នុង ១៧ ឆ្នាំកន្លងមកនេះ។ ប្រហែលគ្នានេះដែរ ការនាំចេញរបស់តៃវ៉ាន់ធ្លាក់ចុះ ២៣ ភាគរយ ក្នុងខែវិច្ឆិកា ហើយរបាយការណ៍របស់រដ្ឋាភិបាលស្តីពីការបញ្ជាទំនិញនាំចេញដែលគេនឹងផ្សព្វផ្សាយនៅថ្ងៃស្អែក ត្រូវគេរំពឹងទុកថានឹងបង្ហាញឲ្យឃើញនូវការធ្លាក់ចុះគំហុកថែមទៀត។*

*លោក Easwar Presad សាស្ត្រាចារ្យជាន់ខ្ពស់ផ្នែកគោលនយោបាយពាណិជ្ជកម្មនៅ Cornell University និយាយថា "សេដ្ឋកិច្ចប្រទេសនីមួយៗកំពុងតែដាំក្បាលចុះហើយ។ ការធ្លាក់ចុះ ២៧ ភាគរយ គឺវាខ្លាំងមែនទែន ហើយជាប្រផ្នូលនៃភាពចុះខ្សោយកាន់តែធំធេងថែមទៀត។ រួមសេចក្ដីមកប្រទេសទាំងនេះដែលធ្លាប់តែពឹងផ្អែកលើកំណើននៃការនាំចេញ នឹងត្រូវតែងាកមកពឹងអាស្រ័យលើតម្រូវការក្នុងស្រុកវិញ ដើម្បីរើខ្លួនចេញពីស្ថានភាពនេះ"។*

*ប្រទេសចិនបានរាយការណ៍ថា ការនាំចេញទំនិញរបស់គេក្នុងខែវិច្ឆិកា ដាំទីងក្បាលចុះយ៉ាងខ្លាំងមែនទែនជាលើកដំបូងក្នុងប្រាំពីរឆ្នាំនេះ - ជាការធ្លាក់ចុះដែលធ្វើឲ្យរង្គើទូទាំងទ្វីបអាស៊ី ព្រោះប្រទេសចិនបានក្លាយជាផ្សារដ៏ធំមួយសម្រាប់ប្រទេសជិតខាងនាំទំនិញចេញទៅលក់។ ក្រសួងហិរញ្ញវត្ថុជប៉ុននិយាយថា ការនាំចេញពីជប៉ុនទៅប្រទេសចិនធ្លាក់ចុះ ២៥ ភាគរយ ដែលនេះជាការធ្លាក់ចុះក្នុងបំណោតបោទមែនទែនក្នុង ១៣ ឆ្នាំនេះ។*

*ប្រមាណជា ៥០ ភាគរយ នៃពាណិជ្ជកម្មរបស់ចិនទាក់ទិននឹងការកែច្នៃ ក្នុងនោះ មានការទិញវត្ថុពាក់កណ្ដាលចម្លង (semiconductors) ពីប្រទេសជប៉ុន កូរ៉េខាងត្បូង និងប្រទេសជិតខាងដទៃទៀត ហើយក្នុងតម្លៃមួយទាប យកវាមកផ្គុំចូលគ្នាឲ្យទៅជាផលិតផលសម្រេចសម្រាប់ក្រុមហ៊ុននានា ដូចជាក្រុមហ៊ុន Sony, Panasonic និង Samsung ជាដើម។ ដូច្នេះប្រទេសចិនជាស្ថានីយផ្គុំចុងក្រោយនៃបណ្ដាញផលិតកម្មសកលជាច្រើន ដែលពេលនេះកំពុងតែមានដំណើរការរងិបរង៉ុប។*

*ប្រទេសជប៉ុន ជាផ្លូវការបានចូលក្នុងស្ថានភាពទ្រឹងគ្មានកំណើនសេដ្ឋកិច្ចរួចទៅហើយ តែនៅមានជន្ទលទ្រទ្រង់ដោយសារតែទំនាក់ទំនងជិតស្និទ្ធរបស់ខ្លួនជាមួយសហរដ្ឋអាមេរិក ហើយរដ្ឋាភិបាលបានកាត់បន្ថយអត្រាការប្រាក់ និងបង្កើនចំណាយក្នុងស្រុក ក្នុងកិច្ចខិតខំមួយ ដើម្បីបន្ធូរបន្ថយឥទ្ធិពលប៉ះពាល់ពីសំណាក់ស្ថានភាពទ្រឹងគ្មានកំណើននេះ។ ប៉ុន្តែស្ថានភាពអាក្រក់ដែលក្រុមហ៊ុន Toyota កំពុងជួបប្រទះនេះ ជាសញ្ញាចុងក្រោយមួយនៃអ្វីដែលធនាគារពិភពលោកបានព្យាករណ៍ទុកថា ជាការធ្លាក់ចុះលើកដំបូងក្នុងពាណិជ្ជកម្មសាកលតាំងពីឆ្នាំ ១៩៨២ មក។*

ឧទាហរណ៍បន្ទាប់មកទៀត គឺនិយាយអំពីទូកនេសាទត្រីថៃមួយ ដែលលិចនៅជិតឆ្នេររបស់ប្រទេសសុម៉ាលី បន្ទាប់ពីវាត្រូវបានទទួលរងការបាញ់ទៅលើដោយកងនាវាសមុទ្ររបស់ឥណ្ឌា ដែលបានយល់ច្រឡំទូកនេសាទនោះ ថាជានាវាចោរសមុទ្រ។ មួយផ្នែកធំនៃរឿង និយាយអំពីនាវានោះ និងក្រុមអ្នកនេសាទរបស់វា (ក្នុងនោះ មានជនជាតិកម្ពុជាម្នាក់ផង ដែលបានរួចរស់រានមានជីវិត) និងអំពីប្រតិកម្មពីមន្ត្រីឥណ្ឌា និងម្ចាស់របស់ទូកនេសាទដែលមានមូលដ្ឋាននៅទីក្រុងបាងកក។ ប៉ុន្តែក្នុងរឿងនោះ ក៏មានបញ្ចូលនូវ "ទិដ្ឋភាពទូលំទូលាយ" ដែរ ស្ដីអំពីគ្រោះថ្នាក់ទាំងឡាយ និងទំហឹងនៃការប្លន់តាមសមុទ្រក្នុងតំបន់នោះ។

*នាវាចម្បាំងប្រទេសដាណឺម៉ាក ឥណ្ឌា ម៉ាឡេស៊ី រុស្ស៊ី សហរដ្ឋអាមេរិក និងអង្គការ NATO នាំគ្នាល្បាតប្រកផ្លូវសមុទ្រអន្តរជាតិដ៏ធំល្វឹងល្វើយមួយនេះ ដោយធ្វើការអមនាវាទំនិញខ្លះ និងឆ្លើយតបទៅនឹងភាពមានអាសន្នទៅលើនាវាក្នុងតំបន់នោះ។ (ក្នុងកថាខណ្ឌទី ១០ នៃរឿង)*

*សុម៉ាលី ដែលជាប្រជាជាតិក្រីក្រមួយ ដែលជាប់គាំង ដោយសារការបះបោរឧទ្ទាមអ៊ីស្លាម មិនដែលមានរដ្ឋាភិបាលពេញរូបពេញរាងមួយតាំងពីឆ្នាំ ១៩៩១ មកម្ល៉េះ។ កាលពីពេលថ្មីៗនេះ ពួកចោរសមុទ្រសុម៉ាលី កាន់តែព្រហើនឡើងៗ ដោយបាន*

*ស្ទាក់ឃាត់នាវាពាណិជ្ជកម្មចំនួនប្រាំបីក្នុងរយៈពេលពីរសប្តាហ៍កន្លងទៅនេះ ក្នុងនោះ មាននាវាប្រទេសអារ៉ាប៊ី សាអូឌីត មួយ ដែលផ្ទុកប្រេងឆៅមានតម្លៃប្រមាណជា ១០០ លានដុល្លារអាមេរិកឯណោះ ។ (កថាខណ្ឌទី ២១ នៃរឿង)*

*ឆ្នាំនេះ មានការវាយប្រហារដោយចោរសមុទ្រ ៩៦ លើក ក្នុងដែនសមុទ្រសូម៉ាលី ក្នុងនោះ នាវាចំនួន ៣៩ ត្រូវបានគេប្លន់ ។ នាវាចំនួន ១៥ គ្រឿង ជាមួយនឹងនាវិកប្រមាណជា ៣០០ នាក់ កំពុងស្ថិតក្នុងដៃរបស់ចោរសមុទ្រនៅឡើយ ដែលបានទាមទារប្រាក់រំលោះរាប់លានដុល្លារអាមេរិកជាថ្នូរនឹងការដោះលែង ។ (កថាខណ្ឌទី ២២)*

*អ្នករកស៊ីតាមនាវា បានអំពាវនាវឲ្យមានការប្រើកម្លាំងយោធាក្នុងដែនទឹកសមុទ្រសូម៉ាលី ដើម្បីស្ទាក់ចាប់នាវាចោរកុំឲ្យចេញជ្រៅទៅក្នុងដែនសមុទ្រ ក៏ប៉ុន្តែ មន្ត្រី NATO និយាយថា ពួកគេគ្មានផែនការនឹងធ្វើបែបនេះទេ ។ (កថាខណ្ឌទី ២៣)*

## សារៈសំខាន់

រឿងនានានឹងកាន់តែមានអត្ថន័យខ្លាំងថែមទៀត បើអ្នកសារព័ត៌មានអាចឆ្លើយនឹងសំណួរទាំងនេះ ៖ ហេតុអ្វីបានជារឿងនេះមានសារៈសំខាន់ ហើយសារៈសំខាន់បែបម៉េច ? តើវាមានន័យយ៉ាងម៉េចដល់អ្នកអាន ? តើអ្នកអាននឹងទទួលរងផលប៉ះពាល់បែបណាខ្លះ ? តើរឿងមួយហ្នឹងមានឥទ្ធិពលយ៉ាងណាខ្លះទៅ ?

យើងច្រើនតែហៅវាថា ការឆ្លើយសំណួរ "ចុះវាយ៉ាងម៉េច ?" (So What?) ។ វាជាឃ្លាដែលមានន័យថា "ហេតុអ្វីបានជាខ្ញុំគួរខ្វល់ទៅអានរឿងមួយហ្នឹង ?" ។ ស្តាប់ទៅវាហាក់ដូចជាសំណួរល្ងីល្ងើមួយដែលត្រូវសួរ ប៉ុន្តែដូចយើងបាននិយាយរួចមកហើយ អ្នកអានជាមនុស្សដែលរវល់ណាស់ ។ រាល់ថ្ងៃមានរឿងច្រើនណាស់ដែលត្រូវអាន និងព័ត៌មានសន្ទឹក-សន្ធាប់ដែលត្រូវស្រូបយក ។ អ្នកសារព័ត៌មានចំណាប់ៗ តែងដកឃ្លាពីការដេញតាមរក 5Ws និង H ដោយងាកមកផ្តល់ការយកចិត្តទុកដាក់ថា "អូខេ មិត្តអ្នកអានខ្ញុំបានប្រាប់ដល់អ្នករួចហើយនូវអង្គហេតុ និងសេចក្តីពិស្តារ តែឥឡូវនេះ ខ្ញុំសូមងាកមកប្រាប់អ្នកវិញម្តងថា ទាំងអស់នេះមានន័យថាម៉េច" ។

ត្រង់នេះ ជាផ្នែកមួយក្នុងសាច់រឿងដែលពិបាកសរសេរបំផុត ។ អ្នកសារព័ត៌មានត្រូវយល់ដឹងអំពីប្រធានបទរបស់គេឲ្យបានល្អ ឬមួយក៏សួរទៅអ្នកឯកទេសថា តើរឿងនេះនឹងអាចមានឥទ្ធិពលបែបណាខ្លះ ។ ដោយគ្រាន់តែអនុវត្តន៍បន្តិច និងស្វែងយល់អំពីរបៀបសរសេររបស់អ្នកសារព័ត៌មានជើងចាស់ អ្នកសារព័ត៌មានថ្មីៗអាចជួយអ្នកអានឲ្យយល់កាន់តែបានប្រសើរជាងមុននូវអ្វី ដែលបានកើតឡើងជុំវិញខ្លួនគេនោះ ។ ដូចគ្នានឹងរបៀបប្រើប្រាស់សាវតារដែរ ស្មេរចំណានៗមិនដាក់ព័ត៌មាននៅតែមួយកន្លែងទេក្នុងសាច់រឿង ។ គេបញ្ចូលវាទៅកន្លែងណាដែលគេគិតថាអ្នកអានត្រូវការវាចាំបាច់បំផុត ។

សេចក្តីផ្តើមខាងក្រោមនេះ ដែលសរសេរដោយអ្នកសារព័ត៌មានកម្ពុជាម្នាក់ មានបង្កប់សំណួរ "ចុះវាយ៉ាងម៉េច ?" នៅខាងចុងបំផុតនៃឃ្លា ៖

អាវុធបានផ្ទុះកាលពីថ្ងៃពុធ រវាងទាហានថៃ និងកម្ពុជា នៅតំបន់ជម្លោះព្រំដែនក្បែរប្រាសាទបុរាណពីសតវត្សរ៍ទី ១១ ដោយសម្លាប់ទាហានកម្ពុជាពីរនាក់ និងបង្កើនទំហឹងនៃវិវាទដែលបានធ្វើឲ្យមានការភ័យខ្លាចថានឹងមានសង្គ្រាមផ្ទុះឡើងរវាងប្រទេសទាំងពីរ ។

ការបាញ់ស្លាប់មនុស្សពីរនាក់ជាដំណឹង ។ រីឯលទ្ធភាពថានឹងអាចមានសង្គ្រាមវាឆ្លើយទៅនឹងសំណួរថា "ចុះវាយ៉ាងម៉េច ?" ។

ជារឿយៗ សំណួរ "ចុះវាយ៉ាងម៉េច?" ច្រើនតែត្រូវបានគេដាក់នៅប៉ែកខាងលើនៃរឿង ហើយវាច្រើនតែចេញពីប្រភពឯកទេសទៀតផង។ នៅក្នុងកថាខណ្ឌបីដំបូង នៃរឿងអំពីការធ្លាក់ចុះនៃចំនួនដំរីនៅប្រទេសឡាវ យើងស្វែងយល់បានថាដំរីមានសារៈសំខាន់ ដោយវាជាផ្នែកមួយនៃបេតិកភ័ណ្ឌជាតិរបស់ប្រទេសនោះ ៖

*លោកស្រី Connie Speight ធ្លាប់បានជិះលើខ្នងដំរី ឆ្លងកាត់ព្រៃអស់ពេលជាយូរណាស់មកហើយ និងថែមទាំងបានទទួលយកសត្វខ្លាតធំនេះចំនួនប្រាំបួនក្បាល មកបីបាច់ចិញ្ចឹមថែមទៀតផង។ ក្នុងវ័យ ៨៣ ឆ្នាំ គ្រូបង្រៀនចូលនិវត្តន៍សញ្ជាតិអាមេរិកម្នាក់នេះ បានវិលត្រឡប់មកនៅក្នុងប្រទេសអាស៊ីអាគ្នេយ៍មួយនេះវិញទៀតហើយ ដើម្បីជួយការពារនូវអ្វីដែលពីមុនធ្លាប់តែជាហ្វូងសត្វដ៏ធំមួយ។*

*<u>ពីមុនធ្លាប់តែមានឈ្មោះល្បីថាជាទឹកដីដំរីរាប់លានក្បាល ប្រទេសឡាវដែលឡូវនេះត្រូវបានគេគិតថានៅមានសល់ដំរីប្រមាណជា ៧០០ ក្បាលតែប៉ុណ្ណោះក្នុងព្រៃរបស់ខ្លួន។</u>*

*<u>លោកស្រី Speight និយាយថា "មានមនុស្សច្រើនណាស់នៅអាស៊ី ដែលអាចនិយាយថា តើដំរីមានសារៈសំខាន់ប៉ុណ្ណាចំពោះបេតិកភ័ណ្ឌជាតិប្រកបដោយមោទនភាពរបស់គេ។ ខ្ញុំអាចនិយាយទៅកាន់គេវិញថា ត្រូវហើយ វាធ្លាប់តែជាបេតិកភ័ណ្ឌរបស់អ្នក ហើយអ្នកនឹងធ្វើអ្វីខ្លះទៅ ដើម្បីនាំវាមកវិញ? ជារឿយៗ គឺតិចណាស់"</u>។*

ក្នុងរឿងមួយអំពីការសម្លាប់ជនបរទេសបុគ្គលិកអង្គការនៅទីក្រុងកាប៊ុល អ្នកសរសេរព័ត៌មានបានបញ្ចូលឃ្លានេះ ៖

*<u>ការសម្លាប់បាននាំឲ្យមានការភ័យខ្លាចថា ពួកឧទ្ទាមតាលីបង់ អាចតម្រង់គោលដៅលើជនបស្ចិមប្រទេស ដើម្បីបន្លាចបុគ្គលិកអង្គការជំនួយ និងដើម្បីបំផ្លាញកិច្ចខិតខំនាំមកនូវការអភិវឌ្ឍ និងសន្តិសុខ</u>។*

មិនមែនរាល់រឿងត្រូវតែឆ្លើយនឹងសំណួរ "ចុះវាយ៉ាងម៉េច?" នោះទេ។ ពេលខ្លះចម្លើយទៅនឹងសំណួរនេះវាប្រត្យក្សរួចទៅហើយ។ ពេលណាដែលមានជីវិតបាត់បង់ក្នុងគ្រោះថ្នាក់ ឬគ្រោះមហន្តរាយណាមួយយើងដឹងថាវាសំខាន់បាត់ទៅហើយ។

## រំលេចមុខមនុស្សក្នុងសាច់រឿង

របៀបមួយធ្វើឲ្យរឿងកាន់តែចាប់អារម្មណ៍ថែមទៀតនោះ គឺការដាក់បញ្ចូលសម្លេងរបស់ជនសាមញ្ញទៅក្នុងនោះ។ អ្នកអានចូលចិត្តអានអំពីអ្នកដទៃអំពីការតស៊ូ ឬជោគជ័យ និងមតិយោបល់របស់ពួកគេ។ ប្រសិនបើអ្នកអានរបស់អ្នកជាជនវណ្ណៈខ្ពស់ ឬមានការអប់រំខ្ពស់ វាជាប្រការល្អក្នុងការឲ្យពួកគេដឹងអ្វីដែលជនសាមញ្ញកំពុងគិត ព្រោះវានឹងអាចនាំឲ្យមាននូវសង្គមមួយដែលមានយុត្តិធម៌ និងប្រជាធិបតេយ្យជាងមុន។

ជាញឹកញយ យើងច្រើនតែមិនបានបញ្ចូលសម្លេងបែបនេះទៅក្នុងការយកព័ត៌មានរបស់យើង។ វាប្រហែលជាមកពីយើងខ្ជិល ឬមួយក៏យើងមិនបានគិតថាជនសាមញ្ញមានសារៈសំខាន់។ មានអ្នកសារព័ត៌មានច្រើននាក់ដែលគិតថា មានតែអ្នកនយោបាយ មន្ត្រី និងអ្នកឯកទេសទេដែលសំខាន់។ ប៉ុន្តែសាច់រឿងមានលក្ខណៈធុញនឹងអានណាស់បើសិនជាយើងដាក់តែសម្លេងអ្នកឯកទេស និងពួកអាជ្ញាធរនៅក្នុងនោះ។ គឺសម្លេងជនសាមញ្ញ កសិករ អ្នកបើកតាក់ស៊ី ម្ចាស់ហាង បុគ្គលិក ការិយាល័យ ដែលថែមនូវរសជាតិ ភាពសំបូរបែប និងអត្ថន័យដល់សាច់រឿង។

យើងនឹងឃើញថា ការផ្តោតទៅលើមនុស្សទូទៅ វាសំខាន់សម្រាប់អ្នកសរសេរបទពិពណ៌នា ហើយ រំលេចមនុស្សក្នុងសាច់រឿង ជារបៀបក្លាស៊ីកមួយ ក្នុងការធ្វើឲ្យរឿងកាន់តែងាយយល់។ ជំនួសឲ្យការ ប្រាប់យើងថារឿងមួយនេះ សំខាន់អ្នកយកព័ត៌មាន បង្ហាញយើងថាហេតុអ្វីបានជាវាសំខាន់។

ខាងក្រោមនេះជាសេចក្តីផ្តើមនៃរឿងមួយដែល សរសេរដោយអ្នកយកព័ត៌មានម្នាក់របស់ទីភ្នាក់ងារ ព័ត៌មាន Associated Press បន្ទាប់ពីមានព្យុះស៊ីក្លូន បក់បោកទៅលើប្រទេសមីយ៉ាន់ម៉ា ៖

*បើទោះជានាងមានក្តីស្រឡាញ់ចំពោះទន្លេ និង សមុទ្រ ដែលធ្លាប់តែផ្តល់ស្បៀងប្រចាំថ្ងៃដល់គ្រួសារ នាងយ៉ាងណាក្តី នាង Tin Tin Latt ឥឡូវនេះចង់ តែរស់នៅឲ្យឆ្ងាយពីទឹក ដែលបានធ្វើឲ្យនាងក្លាយ ជាស្ត្រីមេម៉ាយ ធ្វើឲ្យកូនរបស់គាត់ពីរនាក់ស្លាប់ និង បានបំផ្លាញរបរចិញ្ចឹមជីវិតរបស់គ្រួសារនាងអស់ រលីង។*

រឿងនេះបានបន្តទៅស្រង់សម្តីដើមរបស់នាង Tin Tin Latt និយាយអំពីការភ័យខ្លាចរបស់គាត់ ហើយវាបានធ្វើការកត់សម្គាល់បន្ថែមទៀតថា នាង ស្ថិតក្នុងចំណោមស្ត្រីមេម៉ាយរាប់ពាន់នាក់ទៀត នៅតំបន់ដីសណ្ត Irrawaddy Delta។

*ស្ត្រីមេម៉ាយមានវ័យ ៣៣ឆ្នាំ ម្នាក់នេះនិយាយថា " ខ្ញុំចេះតែបារម្ភថា កូនប្រុសតែមួយរបស់ខ្ញុំនឹងក្លាយ ខ្លួនជាអ្នកនេសាទ ដូចប្តីរបស់ខ្ញុំដែរ។ ខ្ញុំមិនចង់ឃើញ វាស្លាប់ដោយសារខ្យល់ព្យុះដូចជាឪពុករបស់វាទេ"។*

*".... នាង Tin Tin Latt និយាយថា គាត់មាន អង្ករនៅសល់ល្មមសម្រាប់តែប្រាំមួយថ្ងៃប៉ុណ្ណោះ ហើយមិនដឹងថាតើកូនរបស់គាត់នឹងបានអ្វីញ៉ាំទេ បន្ទាប់ពីនោះ។ បើទោះជានាងខ្លាចក៏ដោយ នាង និយាយថា នាងគ្មានជម្រើសទេ ក្រៅតែបញ្ជូនកូន ប្រុសអាយុ ១៥ ឆ្នាំ របស់នាងឲ្យទៅរៀនបញ្ជាទូក នៅលើផ្ទៃសមុទ្រ។*



*ការរំលេចមុខមនុស្សក្នុងអត្ថបទនឹងធ្វើឲ្យរឿងកាន់តែចាប់អារម្មណ៍គួរឲ្យចង់អានថែមទៀត។*

*នាងយំសម្រក់ទឹកភ្នែក ហើយបន្លឺថា "បើអាចធ្វើបាន ខ្ញុំចង់តែឡើងទៅនៅជីគោកឲ្យឆ្ងាយពីកន្លែងនេះទេ ជាជាងបណ្តោយឲ្យកូនប្រុសរបស់ខ្ញុំធ្វើជាអ្នកនេសាទ។ រាល់ព្រឹកពេលដែលវាចេញទៅឡើងទូក ខ្ញុំតែងតែបន់ស្រន់ថាកុំឲ្យវាទៅបាត់ហួតឲ្យសោះ"។*

## បញ្ចូលទស្សនៈចម្រុះក្នុងសាច់រឿង

ជាមួយគ្នានឹងការរំលេចមុខមនុស្ស ដែលធ្វើសាច់រឿងឲ្យកាន់តែគួរឲ្យចាប់អារម្មណ៍ ការដាក់ទស្សនៈចម្រុះទូលំទូលាយនឹងធ្វើឲ្យសាច់រឿងកាន់តែចង់អានថែមទៀត។ តើជនជាតិដើមភាគតិចគិតយ៉ាងណាខ្លះអំពីបញ្ហាមួយ? ស្ត្រី? ជនបរទេស? គណបក្សប្រឆាំង? ជនក្រីក្រ? កាលណាអ្វីមួយកើតឡើង វាតែងតែមានទស្សនៈខុសៗគ្នានៅជុំវិញបញ្ហានោះ។ បើយើងបញ្ចូលទស្សនៈខុសៗគ្នាបានច្រើនគ្រប់គ្រាន់ក្នុងសាច់រឿង យើងនឹងជួយអ្នកអានឲ្យកាន់តែយល់បានពេញលេញ អំពីអ្វីដែលកំពុងកើតឡើង និងត្រិះរិះអំពីលទ្ធភាពដំណោះស្រាយចំពោះបញ្ហានោះទៀតផង។

ក្នុងរឿងមួយដែលនិយាយអំពីការភ័យព្រួយថានឹងមានរដ្ឋប្រហារមួយទៀតនៅប្រទេសថៃ អ្នកយកព័ត៌មានបានចំណាយពេលច្រើនថ្ងៃ ដើម្បីសម្ភាសន៍មនុស្សម្នាក្នុងក្រុងបាងកក។ ជាលទ្ធផល រឿងនោះបានបង្ហាញថា បើទោះជាភាពប្រឈមនយោបាយត្រូវបានដោះស្រាយហើយក្តី ក៏បញ្ហាសង្គម និងនយោបាយនៅតែបន្តដដែល។ រឿងនោះមានរួមបញ្ចូលសម្តីដើមរបស់ស្ត្រីម្នាក់ធ្វើការនៅហាងលក់ចម្រៀង អ្នករត់ម៉ូតូឌុប ម្ចាស់ហាងគុយទាវ ម្ចាស់ហាងវត្ថុលេង និងអ្នករចនាម៉ូតសម្លៀកបំពាក់។ អ្នករចនាម៉ូតសម្លៀកបំពាក់និយាយថា ៖

*"ខ្ញុំនឿយណាយណាស់ជាមួយនឹងស្ថានការណ៍នយោបាយសព្វថ្ងៃ។ ខ្ញុំគ្រាន់តែតាមដានមើលថាតើពួកបាតុករកំពុងធ្វើអ្វី ហើយសង្ឃឹមថាអ្វីៗនឹងមានភាពប្រសើរឡើងវិញ"។*

គឺសម្លេងបែបនេះឯង ដែលធ្វើឲ្យយើងយល់សាច់រឿងបានជាងមុន។

## ចូរអះអាងបញ្ជាក់គោលគំនិតរបស់អ្នក

ចូរកុំភ្លេចឲ្យសោះថា ក្នុងនាមជាអ្នកសារព័ត៌មានគោលដៅចម្បងរបស់អ្នក គឺអះអាងឲ្យអ្នកអានទទួលយកបាននូវគោលគំនិតដែលអ្នកកំពុងចង់និយាយ។ ការដែលមានសេចក្តីផ្តើម និងសេចក្តីសង្ខេបល្អមួយអំពីស្ថានការណ៍ក្នុងសាច់រឿងវាមិនគ្រប់គ្រាន់ទេ។ អ្នកអាននឹងមិនពេញចិត្តទេជាមួយនឹងការសរសេរបែបទូលំទូលាយនោះ ពួកគេត្រូវការភស្តុតាងដើម្បីធ្វើឲ្យគេជឿទុកចិត្តបានចំពោះព័ត៌មាននោះ។ ភស្តុតាងអាចមានជាទម្រង់សេចក្តីពិស្តារ អង្គហេតុតួលេខ បន្ទុកប្រយោគ និងសម្រង់សម្តីដើមរបស់អ្នកមានឯកទេសលើបញ្ហាក្នុងរឿង។ ប៉ុន្តែអ្វីដែលកាន់តែធ្វើឲ្យមានការជឿជាក់ខ្លាំងនោះ គឺឧទាហរណ៍ដែលមានសេចក្តីពិស្តារជាក់លាក់ និងមនុស្សពិតប្រាកដ។

ក្នុងរឿងមួយដែលនិយាយអំពីការបំពុលគុណភាពខ្យល់ក្នុងក្រុងឈៀងម៉ៃ អ្នកនិពន្ធមិនគ្រាន់តែប្រាប់អ្នកអានថា មនុស្សម្នាកំពុងទទួលរងផលមិនល្អពីការស្រូបផ្សែងតាមការដកដង្ហើមប៉ុណ្ណោះទេ តែពួកគេបង្ហាញថា តើវាមានផលប៉ះពាល់ដូចម្តេច៖ ផ្សែងមានសភាពអាក្រក់មែនទែន រហូតដល់ថាមនុស្សម្នាក្រោកពីដំណេកដោយមានឈាមក្នុងច្រមុះ ឈឺបំពង់ក និងឈឺក្បាល រហូតដល់ទៅពីរសប្តាហ៍

ឯណោះ។ គ្រួសារមួយចំនួនបានភៀសខ្លួនទៅនៅក្រុងបាងកក ដោយទ្រាំលែងបានជាមួយគុណភាពខ្យល់អាក្រក់នោះ។ ឧទាហរណ៍ពិស្តារជាក់លាក់បែបនេះហើយ ដែលមានលក្ខណៈគួរឲ្យជឿទុកចិត្តបាន។

ក្នុងរឿងមួយនិយាយអំពីទីផ្សារអចលនទ្រព្យដែលកំពុងពុះកញ្ជ្រោលក្នុងទីក្រុងភ្នំពេញ លោកកៃ មុនធិត អ្នកយកព័ត៌មានរបស់ទីភ្នាក់ងារព័ត៌មាន Associated Press បានព្យាយាមអះអាងបញ្ជាក់ដល់អ្នកអាន ដោយប្រើឧទាហរណ៍ និងភាពលម្អិតជាក់លាក់ថា តើការរីកលូតលាស់នោះ វានាំមកនូវការប្រែប្រួលជើងមេឃរបស់ទីក្រុងបែបណាខ្លះ ទន្ទឹមនឹងការបន្សល់ទុកនូវគម្លាតកាន់តែធំឡើងរវាងអ្នកមាន និងអ្នកក្រ។

*ឧទាហរណ៍ជាក់លាក់ក្នុងសេចក្តីផ្តើមជួយអ្នកអានឲ្យមើលឃើញនោះ គឺអគារ ៤២ ជាន់ តំបន់ជម្រកដែលពោរពេញដោយសំរាម។ ឧទាហរណ៍ទាំងនេះទ្រទ្រង់ដល់បំណុចគោលដែលមាននៅក្នុងកថាខណ្ឌទីពីរ។*

*ភ្នំពេញ - មន្ទីរពេទ្យចាស់មួយ ត្រូវបានគេវាយកម្ទេចចោលដើម្បីយកទីតាំងសង់អគារខ្ពស់ជាងគេក្នុងទីក្រុងភ្នំពេញ ដែលនោះ គឺជាអគារគេហដ្ឋានភ្លោះ ៤២ ជាន់។ តំបន់ជម្រកមួយដែលធ្លាប់តែមានសំរាមពាសវាលពាសកាល បានក្លាយទីតាំងអចលនទ្រព្យកម្រិតខ្ពស់មួយ បន្ទាប់ពីនគរបាលបណ្តេញប្រជារាស្ត្រចេញពីទីនោះ ឲ្យទៅរស់នៅលើវាលស្រែក្រៀមផ្អេះមួយនៅជាយក្រុងភ្នំពេញ។*

*វិស័យសំណង់នៅប្រទេសកម្ពុជាកំពុងតែមានការលូតលាស់ដោយសារតែវិនិយោគបរទេស ជាពិសេសពីសំណាក់វិនិយោគិនកូរ៉េខាងត្បូង ព្រមគ្នានឹងការទិញលក់អចលនទ្រព្យក្នុងចំណោមអ្នកមានថ្មីមួយក្តាប់តូច ដោយបន្សល់ទុកមនុស្សជាច្រើនក្នុងភាពក្រីក្រ។*

*អគារទំនិញធំៗ និងអគារលំនៅដ្ឋានខ្ពស់ច្រើនជាន់ កំពុងតែលេចធ្លោត្រដែត ដោយបានប្រែក្លាយទស្សនីយភាពទីក្រុងដែលធ្លាប់តែលំអទៅដោយវីឡាម៉ូតបារាំង តែក៏ធ្លាប់មានសភាពជាទីក្រុងខ្មោចដែរ នៅពេលរបបខ្មែរក្រហមត្រូវបានផ្តួលរំលំកាលពី ៣០ ឆ្នាំមុន។*

*ស្ថេរភាពនយោបាយ និងកំណើនសេដ្ឋកិច្ចជិត ១០ ភាគរយបានអូសទាញវិនិយោគិនមកដាក់ទុនរកស៊ីផ្នែកទីផ្សារអចលនទ្រព្យ ដែលតម្លៃរបស់វាមានភាពពុះកញ្ជ្រោលក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ បើទោះជាវានៅមានកម្រិតទាបជាងប្រទេសជិតខាងវៀតណាម និងថៃ ក៏ដោយ។*

*ត្រង់នេះ មានសម្ដីដើមមានទម្ងន់មួយពីសំណាក់ទីភ្នាក់ងារអចលនទ្រព្យម្នាក់ ដើម្បីទ្រទ្រង់ដល់គំនិតគោលក្នុងសាច់រឿង ។*

*អ្នកស្រី Claire Brown នាយកគ្រប់គ្រងក្រុមហ៊ុន Claire Brown Realty នៅប្រទេសអង់គ្លេស បានចាប់ផ្ដើមរកស៊ីទិញ-លក់អចលនទ្រព្យនៅភ្នំពេញកាលពីពីរឆ្នាំមុន ហើយនាងបាននិយាយថា "ប្រទេសកម្ពុជា កំពុងភ្ញាក់ពីដំណេក បន្ទាប់ពីបានលង់លក់អស់ជាច្រើនឆ្នាំមកហើយ ។ ពេលនេះ អ្នកណាក៏ចង់មានចំណែកសកម្មភាពក្នុងទីផ្សារអចលនទ្រព្យដែរ ។ នេះ គឺជាពេលដែលត្រូវចូលប្រឡូក ព្រោះថាបើចាំបន្តិចទៀត វានឹងយឺតពេលជាមិនខាន" ។*

*ចូរកត់សម្គាល់សេចក្ដីលម្អិត៖ តម្លៃកើនបីដងដល់ទៅ ៣.០០០ ដុល្លារអាមេរិក ពេលដែលផលចំណេញមានដល់ទៅ ២០០ ភាគរយ ។*

*តម្លៃដីនៃតំបន់លេខមួយក្នុងទីក្រុង បានកើនបីដងក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ រហូតទៅដល់ ៣.០០០ ដុល្លារអាមេរិកក្នុងមួយម៉ែត្រការ៉េ ។ គឺផលចំណេញបែបនេះ ហើយដែលបានទាក់ទាញអ្នកមាន អ្នកវណ្ណៈមធ្យម និងជនកម្ពុជាឯទៀតដែលរស់នៅក្រៅប្រទេសផងដែរ ។*

*លោក ឱត ចាន់ណា នាយកផ្នែកលក់នៃក្រុមហ៊ុន Cambodia Properties Ltd. ដែលជាភ្នាក់ងារអចលនទ្រព្យមួយនៅភ្នំពេញ និយាយថា៖ "ក្នុងការទិញ និងលក់ដី ពួកគេអាចចំណេញពី ១០០ ទៅ ២០០ ភាគរយ ក្នុងមួយឆ្នាំ ប្រសិនបើពួកគេទិញចំកន្លែង" ។*

*ប៉ុន្តែការរីកលូតលាស់ពុះកញ្ជ្រោលនៃទីផ្សារអចលនទ្រព្យនេះក៏កំពុងតែបង្កើនគម្លាតជំឡើងរវាងអ្នកមាន និងអ្នកក្រផងដែរ ។*

*ការកើនឡើងនៃវិនិយោគិន ត្រូវបានយកមកឆ្លុះបញ្ចាំងឲ្យឃើញភាពផ្ទុយគ្នា តាមរយៈអត្ថាធិប្បាយរបស់អ្នកក្រីក្រ ដែលធ្លាប់រស់នៅក្នុងភ្នំពេញ និងសកម្មជនសិទ្ធិមនុស្ស។ ក្នុងនោះគឺការឆ្លុះបញ្ចាំងឲ្យឃើញនូវគម្លាតរវាងអ្នកមាន និងអ្នកក្រ។ ត្រង់នេះ វាគាំទ្រទៅដល់អនុមូលបទនៅក្នុងកថាខណ្ឌទីពីរ "ដោយបន្សល់ទុកនូវអ្នកក្រីក្រដ៏ច្រើនលើសលុបនៅពីក្រោយ" ហើយផ្តល់តុល្យភាពក្នុងរឿងទៀតផង។*

*អ្នកស្រី ឈន អេត ធ្លាប់មានលំនៅក្នុងតំបន់អ្នកក្រីក្រនៅភ្នំពេញ តែឥឡូវនេះត្រូវបានគេបណ្តេញឲ្យមករស់នៅជាមួយមនុស្សរាប់រយនាក់ទៀត នៅភូមិមួយកណ្តាលវាលស្រែប្រហែល ២០ គីឡូម៉ែត្រ ពីក្រុងភ្នំពេញ។ អ្នកស្រីនិយាយថា៖ "ពិតណាស់ក្រុងភ្នំពេញឥឡូវកាន់តែទំនើបឡើងៗជាងមុន តែសម្រាប់តែអ្នកមានស្តុកស្តម្ភទេ"។*

*អ្នកស្រីអាយុ ៣៤ ឆ្នាំ ម្នាក់នេះ ដែលដើររើសកំប៉ុង និងដបដើម្បីលក់យកមកចិញ្ចឹមជីវិត បាននិយាយទៀតថា៖ "រដ្ឋាភិបាលបោសសម្អាតយើងមកទីនេះ ដោយគេចាត់ទុកពួកយើងជាវាពិបាកភ្នែកពួកគេពេក"។*

*ការលូតលាស់ទីផ្សារអចលនទ្រព្យនេះ កំពុងកើតមានព្រមគ្នាជាមួយនឹងបញ្ហាជាច្រើននៃវិវាទសិទ្ធិដីធ្លី ដែលក្នុងប៉ុន្មានឆ្នាំមកនេះ ជាញឹកញយបណ្តាលឲ្យមានទំនាស់រវាងអ្នកក្រីក្រ និងអ្នកអភិវឌ្ឍន៍ទីផ្សារអចលនទ្រព្យស្តុកស្តម្ភ ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយស្ថាប័ននយោបាយនៃប្រទេសកម្ពុជា។*

*អ្នកស្រី Naly Pilorge នាយកអង្គការសិទ្ធិមនុស្ស លីកាដូ និយាយថា៖ "យើងកំពុងតែឈានទៅរកស្ថានភាពមួយដែល ១០ ភាគរយ នៃប្រជាជននឹងកាន់កាប់ដី ៩០ ភាគរយ នៅប្រទេសកម្ពុជា"។*

*អ្នកស្រី និងអ្នកឯទៀតនិយាយថែមថា ស្ថានភាពបែបនេះអាចនឹងនាំឲ្យមានភាពរឹករវសេង្គម និងនយោបាយផងដែរ។*

*គម្រោងធំជាងគេ មានការឧបត្ថម្ភហិរញ្ញប្បទានពីវិនិយោគិន និងក្រុមហ៊ុនកូរ៉េខាងត្បូង ដែលជាវិនិយោគិននាំមុខគេនៅកម្ពុជាក្រោយពីប្រទេសទាំងពីរបង្កើតទំនាក់ទំនងការទូតឡើងវិញនៅឆ្នាំ ១៩៩៧ រួចមក។ ការវិនិយោគ និងអ្នកទេសចរកូរ៉េខាងត្បូងបានកើនឡើងបន្ទាប់ពីមានទស្សនកិច្ចប្រធានាធិបតី Roh Moo-hyun មកកម្ពុជា នៅឆ្នាំ ២០០៦។*

*ចូរកត់សម្គាល់ឈ្មោះក្រុមហ៊ុនកូរ៉េខាងត្បូង ដែលរួមចំណែកដល់កំណើនវិស័យសំណង់។ កថាខណ្ឌនេះក៏បានប្រាប់ផងដែរនូវសេចក្តីលម្អិត និងតម្លៃរបស់គម្រោង។*

*ក្រុមហ៊ុនកូរ៉េខាងត្បូងឈ្មោះ World City Co., Ltd. កំពុងវិនិយោគទឹកប្រាក់ចំនួន ២ ពាន់លានដុល្លារអាមេរិក ដើម្បីសាងសង់ទីក្រុងរណបមួយ ដែលមានឈ្មោះថា Camko City នៅលើផ្ទៃដី ១០០ ហិកតា នាប៉ែកនិរតីទីក្រុងភ្នំពេញ។ គម្រោងនេះ ដែលមកទល់ពេលនេះជាគម្រោងវិនិយោគធំជាងគេបង្អស់នៅកម្ពុជា រួមមាន ហេដ្ឋារចនាសម្ព័ន្ធលំនៅដ្ឋាន និងពាណិជ្ជកម្ម ដូចជា វីឡា ខុនដូ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងហិរញ្ញវត្ថុ អគារការិយាល័យ មជ្ឈមណ្ឌលលក់ដូរ សណ្ឋាគារ សាលារៀន និងមន្ទីរពេទ្យ។*

*ចូរកត់សម្គាល់មើលអំពីការប្រើក្រិតឬមាត្រដ្ឋាន។ គាត់ប្រាប់អ្នកអានថា គម្រោងមួយជាការវិនិយោគបរទេសធំជាងគេ ឯគម្រោងមួយទៀតជាគម្រោងអគារប្រណិតដំបូងគេ និងក៏ជាអគារដែលខ្ពស់ជាងគេនៅប្រទេសកម្ពុជាផងដែរ។*

*ព្រមពេលជាមួយគ្នានេះដែរ មន្ទីរពេទ្យចាស់មួយ ដែលស្ថិតនៅកាច់ជ្រុងវិថីឆ្ពោះទៅកាន់វិមានឯករាជ្យក្នុងទីក្រុង ត្រូវបានគេវាយរំលំចោល ដើម្បីយកទីតាំងសង់អគារ ៤២ ជាន់ សម្រាប់ខុនដូ និងមជ្ឈមណ្ឌលហាងទំនិញ ដែលគម្រោងនេះមានតម្លៃប្រមាណ ២៥០ លានដុល្លារអាមេរិក។ គម្រោងនេះនឹងនាំមកនូវការប្រែប្រួលដ៏កំភួនចំពោះជើងមេឃលើទីក្រុងភ្នំពេញ ដែលមកទល់ពេលនេះ អគារខ្ពស់បំផុតមានត្រឹមតែ ១៥ ជាន់ប៉ុណ្ណោះ។*

*លោក Kim Tae-Yeon ប្រធានក្រុមហ៊ុន Yon Woo Inc. របស់កូរ៉េខាងត្បូងដែលជាអ្នកអភិវឌ្ឍន៍គម្រោងនេះ និយាយថា អគារនេះ វានឹងក្លាយទៅជាអគារលំនៅដ្ឋានប្រណិតខ្ពស់ជាងគេនៅប្រទេសកម្ពុជា។*

*លោក Kim និយាយថា អគារនេះនឹងមានលំនៅដ្ឋានការិយាល័យ និងហាងទំនិញជិត ៥០០ ឯកតា ដែលថ្លៃចាប់ពី ១១២.០០០ ដុល្លារអាមេរិក ដល់ ១,៨ លានដុល្លារអាមេរិកក្នុងមួយឯកតា។ ការសាងសង់នឹងចាប់ផ្តើមខែក្រោយ ហើយនិងត្រូវបានបញ្ចប់ក្នុងរយៈពេល ៣ ឆ្នាំកន្លះ ប៉ុន្តែលោក Kim និយាយថាជិតពាក់កណ្តាលនៃចំនួនឯកតាបន្ទប់ទាំងអស់នេះ ត្រូវបានគេទិញរួចទៅហើយ។*

ទោះជាអ្នកសរសេរអត្ថបទដំណឹង ឬអត្ថបទពិពណ៌នាក៏ដោយ ចូរសួរខ្លួនឯងថា៖

- តើខ្ញុំមានឧទាហរណ៍សម្រាប់គាំទ្រ និងពន្យល់សេចក្តីផ្តើមរបស់ខ្ញុំដែរ ឬទេ?
- តើខ្ញុំមានបានសួរប្រភពរបស់ខ្ញុំឲ្យបង្ហាញភស្តុតាងគាំទ្រដល់អ្វី ដែលគេកំពុងនិយាយដែរ ឬទេ?
- តើខ្ញុំបានបញ្ចូលសេចក្តីលម្អិតគ្រប់គ្រាន់ហើយ ឬនៅ ដើម្បីឲ្យអ្នកអានជឿសាច់រឿងរបស់ខ្ញុំ?
- តើខ្ញុំអាចបង្ហាញបានទេ នូវមនុស្សធ្វើសកម្មភាពនានា ដើម្បីធ្វើឲ្យសាច់រឿងរបស់ខ្ញុំកាន់តែរស់រវើកថែមទៀត?

## ការនិទានខ្លីអះអាងបញ្ជាក់គោលគំនិត

(Anecdotes Prove the Point)

វិធីមួយទៀត សម្រាប់អះអាងបញ្ជាក់គោល-គំនិតរបស់អ្នក គឺប្រើការនិទានខ្លី។ ការនិទានខ្លី គឺរឿងតូចៗ ដែលអាចមានលក្ខណៈគួរអស់សំណើចឬគួរឲ្យសោកសៅ។ វាជាការរ៉ាយរ៉ាប់អំពីមនុស្សឬស្ថានការណ៍ពិត។ វាជារបៀបមួយដែលនាំអ្នកអានចូលទៅក្នុងសាច់រឿងទៅដល់ពេលវេលា និងទីកន្លែងនៃសកម្មភាពតែម្តង។ អ្នកសរសេរជាច្រើនចូលចិត្តផ្តើមអត្ថបទពិពណ៌នារបស់គេ ដោយប្រើការនិទានខ្លីៗជក់ចិត្ត ប៉ុន្តែគេអាចដាក់ការនិទានខ្លីកន្លែងណាក៏បានដែរក្នុងសាច់រឿង ដើម្បីអះអាងបញ្ជាក់ដល់គោលគំនិតមេ។

ជាធម្មតា ការនិទានខ្លីមានច្រើនឃ្លា ហើយភាពប្រឈម គឺនៅត្រង់ថា តើសរសេរយ៉ាងណាឲ្យខ្លីមានសេចក្តី ដោយមិនបាច់ប្រើប្រាស់អស់ភ្លាមតែម្តងនូវសេចក្តីពិស្តារ ដែលប្រមូលបានក្នុងពេលយកព័ត៌មាន។

ខាងក្រោមជាឧទាហរណ៍ពីអ្នកយកព័ត៌មាន Reuters ស្តីអំពីចំនួនមនុស្សរងរបួស ដោយសារការផ្ទុះគ្រាប់បែកនៅប្រទេសឡាវជារៀងរាល់ឆ្នាំ។ គ្រាប់បែកទាំងនោះ ដែលគេច្រើនហៅថាគ្រាប់បុមប៊ី ត្រូវបានយន្តហោះអាមេរិកទម្លាក់ក្នុងជំនាន់សង្គ្រាមទសវត្សរ៍ឆ្នាំ ១៩៦០ និង ១៩៧០ ប៉ុន្តែមានគ្រាប់ជាច្រើនដែលមិនទាន់ផ្ទុះ ហើយនៅពួនសំងំក្រោមដីនៅឡើយ។

*នៅថ្ងៃទី ៣ ធ្នូ ឆ្នាំនេះ ប្រទេសជាង ១០០ នឹងចុះហត្ថលេខាលើអនុសញ្ញាហាមប្រាមការប្រើគ្រាប់បែកចង្កោម ដើម្បីរាំងស្កាត់នូវសោកនាដកម្មដូចដែលមានចំពោះបុរសឈ្មោះ តា ដែលជាឪពុកមានកូន ៧ នាក់ រស់នៅភូមិដាច់ស្រយាលមួយក្នុងខេត្តខាំមួន ភាគខាងត្បូងប្រទេសឡាវ។*

*មានព្រឹកមួយនោះកាលពីបួនឆ្នាំមុន គាត់បានឃើញអ្វីមួយ ដែលគាត់ស្គាល់ថាជាគ្រាប់បុមប៊ី។ គាត់ដឹងថាវាជារបស់មានគ្រោះថ្នាក់ ប៉ុន្តែគាត់ក៏ធ្លាប់ឮដែរថា ជាតិផ្ទុះខាងក្នុងអាចយកទៅប្រើបានសម្រាប់ចាប់ត្រីផងដែរ។ គាត់ក៏យកមែកឈើមួយទៅប៉ះវា។*

*ការគោះតែបន្តិចនោះ ហើយបានធ្វើឲ្យគាត់បាត់បង់ដៃទាំងពីរ និងភ្នែកម្ខាង។ លោក តា ត្រូវធ្វើដំណើរ ៩ ម៉ោង ដើម្បីទទួលជំនួយពេទ្យព្យាបាល។ គាត់ត្រូវលក់សត្វចិញ្ចឹមក្នុងផ្ទះ ដើម្បីបង់ថ្លៃព្យាបាល ហើយពេលដែលគាត់អស់អ្វីៗសម្រាប់លក់តទៅទៀត គាត់ក៏ត្រូវបង្ខំចិត្តត្រឡប់ទៅផ្ទះវិញ។*

*លោក តា និយាយថា តាំងពីពេលនោះមក គាត់ត្រូវ "ហូបចុកដូចសត្វឆ្កែ" អស់រយៈពេលបួនឆ្នាំ ទម្រាំអង្គការក្រៅរដ្ឋាភិបាលមួយឈ្មោះ COPE ផ្តល់ដៃសិប្បនិម្មិតដល់គាត់។ ដោយសារដៃសិប្បនិម្មិតនោះ ឥឡូវគាត់អាចមានលទ្ធភាពជួយធ្វើកិច្ចការក្នុងផ្ទះបានខ្លះៗដែរ។*

*ក្រៅពីគាត់ នៅមានលោក យី លី អាយុ ៣១ ឆ្នាំ។ កាលពីខែសីហា គាត់កំពុងតែកាប់គាស់ដីក្នុងសួនរបស់គាត់ ស្រាប់តែពេលនោះចបកាប់របស់គាត់បានធ្លាក់ពេញទំហឹងទៅលើគ្រាប់បុមប៊ីមួយ។ គាត់ត្រូវរបួសដាច់ជើងទាំងសងខាង និងម្រាមដៃពីរ។*

*នៅឯមន្ទីរពេទ្យខេត្ត ស្វៀងឃួង ដែលគាត់កំពុងឲ្យគេធ្វើពុម្ពជើងសិប្បនិម្មិត លោក យី លី និយាយថា៖ "ខ្ញុំមានកូនតូចៗ ៥ នាក់ ហើយប្រពន្ធរបស់ខ្ញុំកំពុងមានផ្ទៃពោះ ៦ ខែ ទៀតផង"។ ដោយមានក្ដីកង្វល់លាយឡំផង គាត់មិនដឹងថាតើអនាគតរបស់គ្រួសារគាត់នឹងទៅជាយ៉ាងណាទេ។*

*សម្រាប់បច្ចុប្បន្ន ឪពុកម្ដាយចាស់ៗ និងប្អូនប្រុសរបស់គាត់ជាអ្នកជួយទំនុកបម្រុងដល់គ្រួសារគាត់។ គាត់និយាយថា៖ "ខ្ញុំគ្រាន់តែសង្ឃឹមថាជាមួយនឹងជើងសិប្បនិម្មិត ខ្ញុំនឹងអាចវិលទៅធ្វើការបានវិញខ្លះ ទោះជានៅឯចំការក្ដី ឬនៅជុំវិញផ្ទះក្ដី"។*

ចូរនាំគ្នាកត់សម្គាល់មើលនូវការប្រើជាតុផ្សំពេលវេលាសម្រាប់ការនិទានរឿងខ្លីៗទាំងនេះ។ ឧទាហរណ៍ទីមួយរបស់លោកតា ចាប់ផ្ដើមឡើងដូចរឿងធម្មតាដទៃទៀតដែរ៖ "មានព្រឹកមួយនោះកាលពីបួនឆ្នាំមុន"។ ឧទាហរណ៍ទីពីររបស់លោក យី លី "កាលពីខែសីហា គាត់កំពុងតែកាប់គាស់ដីក្នុងសួនរបស់គាត់ស្រាប់តែពេលនោះ"។

ក្នុងពេលសម្ភាសន៍ អ្នកគួរស្ដាប់ដោយប្រុងប្រយ័ត្ននូវការរៀបរាប់ដំណាលរឿង។ ពេលណាអ្នកស្ដាប់ការដំណាលរឿងពីសំណាក់ប្រភព ចូរប្រឹងកត់ត្រាឲ្យបានល្អ ហើយឈ្លេចសួរយកសេចក្ដីពិស្ដារបន្ថែមទៀត ដើម្បីធ្វើការនិទាននោះកាន់តែពេញលេញតាមតែអាចធ្វើទៅបាន។ ពេលសរសេរចូរព្យាយាមធ្វើការដំណាលនោះឲ្យពេញសេចក្ដីតែខ្លីដោយមានសេចក្ដីផ្ដើម តួសេចក្ដី និងសេចក្ដីបញ្ចប់ជាមួយផង។ កន្លែងណាធ្វើបាន ចូរប្រើសម្រង់សម្ដីដើម ការសន្ទនា ការពិពណ៌នា និងសកម្មភាព។ ប៉ុន្តែកុំប្រើការនិទានឲ្យសោះ មិនថាវាល្អពិរោះស្ដាប់ប៉ុណ្ណាទេ បើសិនជាវាមិនមាន ទំនាក់ទំនង អ្វីសោះជាមួយនឹងគំនិតមេក្នុងសាច់រឿងនោះ។

ពេលណាអ្នកយកព័ត៌មានត្រូវបានគេចាត់តាំងឲ្យសរសេរអត្ថបទពិពណ៌នាជាលើកដំបូង ពួកគេប្រើនតែសួរសំណួរមិនសូវសំខាន់មុនគេថា តើអត្ថបទនោះគួរវែងប៉ុណ្ណា? ក្រោយមកទៀត ពួកគេចង់ដឹងថាតើគេមានពេលប៉ុន្មានសម្រាប់សរសេរវា។ ពួកគេកម្រសួរសំណួរសំខាន់បំផុតណាស់ ដែលជាសំណួរថាតើអត្ថបទពិពណ៌នានោះនិយាយពីអ្វីទៅ? ជាលទ្ធផល ពួកគេតែងចាប់ផ្ដើមសរសេរមុននឹងពួកគេបានត្រៀមខ្លួនរួចទៅទៀត ដោយគិតថានេះគ្រាន់តែជាការសរសេរអត្ថបទដំណឹងវែងមួយតែប៉ុណ្ណោះ។ ខុសហើយ។

# ជំពូក ២
# ការសរសេរអត្ថបទពិពណ៌នា - ភាគ ១

អត្ថបទពិពណ៌នាមិនជារឿងលំបាកណាស់ណាទេក្នុងការតាក់តែង។ តាមពិត វាជាផ្នែកមួយបែបនិម្មិតកម្ម ឬបែបអក្សរសិល្ប៍ក្នុងវិស័យសារព័ត៌មាន ហើយវាអាចនាំមកនូវសេចក្ដីរីករាយដល់អ្នកនិពន្ធ និងអ្នកអានផងដែរ។ អត្ថបទពិពណ៌នាមានច្រើនប្រភេទណាស់ ដែលយើងនឹងឃើញបន្តិចទៀតក្នុងសៀវភៅនេះ។

អត្ថបទពិពណ៌នាមានលក្ខណៈខុសពីអត្ថបទដំណឹងជាប្រពៃណីត្រង់ថា តាមរយៈវា អ្នកអានមិនគ្រាន់តែទទួលបានព័ត៌មានទេ តែពួកគេក៏ទទួលបាននូវអារម្មណ៍លំហែកំសាន្ត ការពន្យល់ និងការយល់ឃើញថ្មីៗទៀតផង។ វាអាចមានលក្ខណៈគួរឲ្យចង់សើច ឬក៏ម៉ឹងម៉ាត់ និងសោកសៅ។ ផ្ទុយនឹងអត្ថបទដំណឹង ដែលផ្ដោតទៅលើព្រឹត្តិការណ៍ទើបនឹងកើត ដែលត្រូវតែបានរាយការណ៍ភ្លាមៗ អត្ថបទពិពណ៌នាផ្ដោតលើមនុស្ស ទីកន្លែង បញ្ហា និងនិន្នាការផ្សេងៗ។ អត្ថបទប្រភេទនេះ មិនសូវជាបន្ទាន់ណាស់ណាទេ បើទោះជាថាគោលគំនិតសម្រាប់សរសេរផ្ដើមចេញមកពីព្រឹត្តិការណ៍បច្ចុប្បន្នកាលក៏ដោយ។

អត្ថបទពិពណ៌នាមានស្ទីលផ្សេង។ វាមានលក្ខណៈលំហែជាងអត្ថបទដំណឹង ដែលច្រើនតែផ្ដើមដោយព័ត៌មានសំខាន់បំផុត និងបន្តដោយព័ត៌មានមានសារៈសំខាន់តាមលំដាប់លំដោយ។ ក្នុងអត្ថបទពិពណ៌នា អ្នកអានត្រូវបានគេនាំសន្សឹមៗចូលទៅក្នុងសាច់រឿង មុននឹងពួកគេស្វែងយល់បាននូវគំនិតមេរបស់វា។ អត្ថបទអាចផ្ដើមដោយការពិពណ៌នារ៉ាយរ៉ាប់ ដោយឆាកមួយ ដោយការបំអក - និយាយរួមជារបៀបណាមួយ ដែលធ្វើឲ្យអ្នកអានចង់តាមដានអានតទៅមុខ។ បន្ទាប់ពីនោះ គំនិតមេក្នុងសាច់រឿង នឹងលេចត្រដែតឡើងឲ្យគេយល់បាន។

តាមរយៈសំណេរប៉ិនប្រសប់ និងការយកព័ត៌មានបានក្បោះក្បាយ អ្នកអាននឹងមានអារម្មណ៍ថាហាក់ជាបានទៅដល់ឆាកនៃរឿងដោយផ្ទាល់ដែរ មិនថាឆាកនោះនៅក្នុងរោងចក្រកាត់ដេរ ឬនៅតាមឆ្នេរភក់នៃដងទន្លេមេគង្គនោះឡើយ។ តាមរយៈនេះ គេអាចប្រមើលឃើញនូវទស្សនីយភាព ស្ដាប់ឮសម្លេង ស្រង់ក្លិន និងបទពិសោធន៍របស់មនុស្សក្នុងសាច់រឿងបានយ៉ាងងាយ។

ក្នុងអត្ថបទពិពណ៌នាខាងក្រោម ស្ដីអំពីការតស៊ូផ្ដល់ការអប់រំសិក្សាដល់ជនជាតិភាគតិចនៅតំបន់ដាច់ស្រយាល ទីភ្នាក់ងារព័ត៌មានអនឡាញ VietNamNet Bridge បាននាំយើងទៅដល់សាលារៀននៅឯជើងភ្នំដាច់ស្រយាលមួយ៖

*នាព្រឹកមួយដែលពោរពេញដោយពន្លឺព្រះអាទិត្យក្នុងរដូវក្ដៅ អ្នកស្រី Vi Kieu Oanh និងប្ដីរបស់គាត់ក្រោកពីដំណេកលឿនខុសពីធម្មតា។ ថ្ងៃនេះពួកគេនឹងធ្វើដំណើរយ៉ាងឆ្ងាយទៅកាន់ភូមិកំណើតរបស់ពួកគេនៅឯលើភ្នំ ដែលមានជនជាតិភាគតិច Kho Mu រស់នៅ។ អ្នកស្រី Vi Kieu Oanh ជាគ្រូបឋមសិក្សានៅភូមិ Huoi Xen ក្នុងខេត្ត Nghe An ជិតព្រំដែនវៀតណាម និងឡាវ។ អ្នកខ្លះក្នុងចំណោមសិស្សរបស់គាត់ជាជនជាតិ Kho Mu ហើយកាលពីពេលថ្មីៗនេះ គាត់សង្កេតឃើញថាចំនួនសិស្សទាំងនោះមានការធ្លាក់ចុះយ៉ាងគំហុក។*

*អ្នកស្រី Vi Kieu Oanh និយាយថា៖ "កូនសិស្សរបស់យើងឈប់រៀនច្រើននាក់ណាស់ ដូច្នេះហើយខ្ញុំត្រូវតែទៅផ្ទះរបស់ពួកគេ ដើម្បីបញ្ចុះបញ្ចូលឪពុកម្ដាយឲ្យបញ្ជូនកូនទៅរៀនវិញ"។ សាលារបស់អ្នកស្រីស្ថិតនៅលើភ្នំ។ នៅទីនោះ មានបន្ទប់សិក្សាពីរធ្វើអំពីឈើ និងប្រក់ស្លឹកឈើ។ បន្ទប់សិក្សានោះ*

*គ្មានប្រដាប់ប្រដាសិក្សាគ្រប់គ្រាន់ទេ។ កម្រាលរបស់បន្ទប់សិក្សានោះ គឺដីផ្ទាល់តែម្ដង។ នៅពានហាលខាងមុខមានស្តូកញ្ចាស់មួយព្យួរនៅទីនោះ។*

*ពីលើភ្នំ សាលារៀននោះមើលទៅប្រៀបបាននឹងបំណុចល្អិតតូចមួយ ដែលអាចប៉ើងតាមខ្យល់បាន។ ក្មេងៗដើរមករៀនដោយជើងទទេ។ អ្នកខ្លះមិនទាំងមានអាវពាក់ផង។ ពេលណាមានភ្លៀងម្ដងៗ ទឹកដក់នៅលើកម្រាលដីនៅខាងក្រោមតុក្មេងៗកំពុងអង្គុយរៀន។*

ដោយសារថាអត្ថបទពិពណ៌នាផ្ដោតទៅលើមនុស្ស អ្នកនិពន្ធជួយឲ្យយើងស្តាប់ឮសម្លេងរបស់គ្រូបង្រៀន និងសិស្ស។ សេចក្តីសង្ខេបខាងក្រោមផ្ដើមឡើង ដោយផ្ដោតទៅលើគ្រូឈ្មោះ Tran Thi Yen វិញម្ដង។

*ពួកក្មេងៗនាំគ្នាឱនក្បាលចុះ នៅពេលដែលពួកគេប្រឹងរៀនសរសេរអក្សរជាលើកដំបូងក្នុងជីវិតរបស់ខ្លួន។ អ្នកគ្រូ Tran Thi Yen និយាយថា៖ "ក្មេងខ្លះពិតជាចូលចិត្តមកសាលា ប៉ុន្តែអ្នកឯទៀតដូចជាមិនសូវខ្វល់ចង់រៀនទេ។ ខ្ញុំមិនប្រាកដទេថាថ្ងៃស្អែកពួកវានឹងមករៀន ឬក៏អត់នោះ"។*

*អ្នកគ្រូនិយាយបន្ថែមថា៖ "ខ្ញុំបង្រៀនពួកគេឲ្យបេះអាន និងសរសេរអក្ខរក្រមវៀតណាម នៅពេលដែលពួកគេប្រើភាសាកំណើតនិយាយរកគ្នា។ វាជារឿងមួយលំបាកដែរ"។ ក្នុងខែកញ្ញានេះ មានសិស្សតែ ១៥ នាក់ ប៉ុណ្ណោះ មកពីភូមិផ្សេងៗក្នុងតំបន់នេះដែលបានមករៀន។*

*អ្នកគ្រូ Tran Thi Yen និយាយថា៖ "ពួកវាមកពីគ្រួសារក្រីក្រដែលឃ្វាលក្របី និងដាំពោត ជាមុខរបរចិញ្ចឹមជីវិត។ ពួកវាគ្មានសៀវភៅសរសេរ ឬប្រដាប់ប្រដាសិក្សាអ្វីទេ ហើយខ្ញុំត្រូវតែទិញអ្វីៗទាំងអស់មកឲ្យពួកគេរៀន"។ កុមារា Oc Kham Muon អាយុ ១៣ ឆ្នាំ និយាយថា នេះជាលើកទីមួយហើយដែលគេមានឱកាសទៅរៀន។ តែមុននឹងគេមកសាលារៀន រូបគេត្រូវឡើងភ្នំទៅច្រូតស្មៅទុកឲ្យក្របីស៊ី និងប្រមូលអុសទុកឲ្យគ្រួសាររបស់គេប្រើប្រាស់ក្នុងផ្ទះសិន។*

*ដោយមានអ្នកគ្រូ Tran Thi Yen ជាអ្នកជួយបកប្រែ កុមារានោះនិយាយក្នុងភាសាកំណើតរបស់ខ្លួនថា៖ "បន្ទាប់ពីនោះ នៅម៉ោង ៦ ព្រឹក ខ្ញុំដើរទៅសាលារៀន។ ជាធម្មតា ខ្ញុំត្រូវចំណាយពេលមួយម៉ោងកន្លះ ទើបដើរទៅដល់។ ខ្ញុំត្រឡប់ទៅផ្ទះវិញក្រោយថ្ងៃត្រង់។ បន្ទាប់ពីនោះ ខ្ញុំត្រូវធ្វើកិច្ចការនៅផ្ទះ និងជួយមើលថែទាំប្អូនប្រុស-ប្អូនស្រីរបស់ខ្ញុំទៀត"។*

រឿងនេះ បញ្ចប់ដោយសម្លេងរបស់ម្ដាយរបស់សិស្សម្នាក់ឈ្មោះ Moong Ta Loc។

*ស្ត្រីនោះនិយាយថា៖ "ខ្ញុំទុកឲ្យកូនស្រីរបស់ខ្ញុំនាង Loc រៀនឲ្យត្រឹមតែចេះអានទៅបានហើយ។ ហេតុអ្វីបានជាចាំបាច់ត្រូវការរៀនសូត្រនៅទីនេះ? ក្មេងទាំងនេះធំឡើងរៀបការជាប្តីប្រពន្ធហើយ។ វាតែប៉ុណ្ណឹងឯង។ ខ្ញុំមានអាយុ ៦០ ឆ្នាំហើយ ៗខ្ញុំមិនដែលទៅឆ្ងាយពីវាលស្រែទាំងនេះទេ"។*

ទោះជាអត្ថបទពិពណ៌នាមានក្បួនតិចតួចសម្រាប់ប្រតិបត្តិតាមមិនដូចអត្ថបទដំណឹងក្តី វាក៏មិនមែនជាអត្ថបទបញ្ចេញយោបល់ ឬក៏ជាអត្ថបទអធិប្បាយសាកល្បង (essay) ទេ។ វាក៏មិនមែនជាអត្ថបទដែលមានការរ៉ាយរ៉ាប់ដោយគ្មានគោលបំណងច្បាស់លាស់នោះដែរ។ វាជាប្រភេទអត្ថបទដែលតម្រូវឲ្យមានការស្រាវជ្រាវថ្មី ដើម្បីយកមកសរសេរ។ ម្យ៉ាងវិញទៀត វាជាការប៉ុនប៉ងសិក្សាអំពីគំនិត ឬសំណួរណាមួយជាក់លាក់។

# ផ្តោតគោលគំនិត

ជំហានដំបូង គឺតម្រង់ការផ្តោតគោលគំនិតឲ្យចំបញ្ហា។ ចូរព្យាយាមរៀបសំណួរ ឬគំនិតតាមរបៀបមួយដែលគួរឲ្យចាប់អារម្មណ៍ (ប្រើពាក្យខ្លីៗ ទន់ភ្លន់ចំៗ និងសាមញ្ញ)។ ការដែលរៀបចំគំនិត ខុស ឬស្រពិចស្រពិល ជាមូលហេតុធំបំផុតនាំទៅរកបរាជ័យក្នុងការធ្វើអត្ថបទពិពណ៌នា។ ចូរកុំព្យាយាមចាប់យកច្រើនចំណុច ឬសួរសំណួរធំ ឬដែលមានភាពអរូបិយពេក ដូចជាសំណួរថា "ស្អីទៅអត្ថន័យនៃជីវិតនោះ?"។ សួរសំណួរណាដែលជាក់លាក់។ "តើសាសនានៅតែមានសារៈសំខាន់នៅប្រទេសរបស់ខ្ញុំ?" សំណួរបែបនេះ វាមានលក្ខណៈទូលំទូលាយពេកហើយ។ ប៉ុន្តែអ្នកអាចសរសេរអំពីវិហារសាសនាណាមួយជាក់លាក់ ដែលកំពុងព្យាយាមទាក់ទាញយុវជនឲ្យចូលជាសមាជិករបស់ខ្លួន។ ធ្វើដូច្នេះ អត្ថបទរបស់អ្នកវានឹងងាយគ្រប់គ្រងក្នុងការសរសេរជាងការសរសេរក្រោមគំនិតស្តីអំពី "អត្ថន័យនៃជីវិត" ទៅទៀត។ ចូរពិភាក្សាគោលគំនិតនេះជាមួយនិពន្ធនាយក ឬជាមួយសហសេវិកក្នុងទម្រង់ pitch ឬអាចនិយាយជាភាសាខ្មែរបានថាជាការ "ពពាយនាយ"។ Pitch គឺជាការប៉ុនប៉ងបញ្ចុះបញ្ចូលនិពន្ធនាយកឲ្យ "ទិញ" គោលគំនិតរឿងរបស់អ្នកដែលវាជាសេចក្តីសង្ខេបច្បាស់លាស់អំពីសំណួរ ឬគំនិតដែលអ្នកចង់ស្រាវជ្រាវធ្វើជាអត្ថបទ។ ការពពាយនាយនេះ ក៏គួរនិយាយអំពី***របៀបដូចម្តេច* (how)** ដែលអ្នកនឹងសរសេរអត្ថបទនោះ មិនត្រឹមតែតើវានឹងនិយាយអំពី ***ស្អី* (what)** នោះទេ។ ក្នុងការពពាយនាយ អ្នកមិនបាច់សរសេរ ហើយអ្នកអាចបង្ហាញវាតាមការពន្យល់ផ្ទាល់មាត់ដល់និពន្ធនាយកក៏បានដែរ។ ប៉ុន្តែបើសរសេរ វាជាការប្រសើរជាប្រយោជន៍ឲ្យច្បាស់ទាំងអស់គ្នាថាតើអ្វីដែលអ្នកចង់សរសេរ។ ការពពាយនាយជាលាយលក្ខណ៍អក្សរគួរមានប្រហែល ៣០០ ពាក្យ (ជាភាសាអង់គ្លេស)



*បើនៅតែក្នុងការិយាល័យ អ្នកនឹងមិនអាចរកបានប្រធានបទល្អៗយកមកសរសេរទេ។*

ដែលក្នុងនោះមានសេចក្ដីខ្លឹម (ប្រយោគស្នូល) នៃរឿង ហើយដែលបង្ហាញឲ្យនិពន្ធនាយកបានយល់ផងថាតើវានឹងត្រូវសរសេររបៀបម៉េច។

ដប់ឆ្នាំក្រោយពីមានវិបត្តិហិរញ្ញវត្ថុនៅឆ្នាំ ១៩៩៧ អ្នកយកព័ត៌មានកាសែត Bangkok Post គឺអ្នកនាង Anchalee Kongrut បង់ពិនិត្យមើលឡើងវិញថា តើអគារជាច្រើនដែលគេមិនបានសាងសង់ចប់សព្វគ្រប់ វាក្លាយទៅជាយ៉ាងម៉េចទៅហើយ។ ប៉ុន្តែកាលណានិយាយដល់អគារច្រើន វាជាប្រធានបទមួយធំ ដូច្នេះ នាងសម្រេចចិត្តផ្ដោតលើជោគវាសនារបស់អគារតែមួយវិញ។ ខាងក្រោមនេះជាផ្នែកទីមួយនៃរឿងរបស់នាងដែលមានចំណងជើងថា "ខ្មោចនៃវិបត្តិសេដ្ឋកិច្ចឆ្នាំ ១៩៩៧" (Ghosts of the crash of '97)៖

*ក្រោយពីត្រូវបានគេបោះបង់ចោលអស់មួយទសវត្សរ៍មក អគារ Sathon Unique ស្ថិតក្នុងសភាពស្រដៀងនឹងកន្លែងមួយដែលអារ្យធម៌មនុស្សជាតិត្រូវបានវិនាសសាបសូន្យទៅហើយ មិនមែនជាអគារខុនដូសម្រាប់អ្នកមានចំណូលខ្ពស់ ដែលជាគោលបំណងដំបូងក្នុងការសាងសង់អគារនេះទេ។*

*ដើមពោធិបានដុះព័ទ្ធជុំវិញអគារនោះ។ គំនូសក្រវេមក្រវាមមានពាសពេញលើសសរដែលមានក្បាច់បុរាណក្រិច។ សសរមួយមានរូបភាពសត្វពីភពក្រៅ ហើយសសរមួយទៀតមានគំនូររូបព្រះ Ganesh របស់សាសនាហិណ្ឌូ។*

*ផ្លូវក្នុងអគារដែលគេបម្រុងថានឹងធ្វើជាកន្លែងឡប់ប៊ី ពោរពេញដោយភាពងងឹត ហើយអ្វីមួយដែលអាចថាជាសញ្ញាតែមួយគត់នៃពរសព្វសាធុការនោះ គឺបដិមា Phra Siam Dhevatirat ដែលជាអាទិទេពពិសិដ្ឋការពារជនជាតិថៃ នៅក្បែរទ្វារចូល។*

*លោក Suthep Karnjana អាយុ ៣៧ ឆ្នាំ ដែលជាឆ្មាំអគារកំពស់ ៤៩ ជាន់នេះ និយាយថា៖ "តាមគម្រោង គឺនឹងមានរូបបដិមាពីរដាក់ការពារច្រកទ្វារ ដើម្បីប្រសិទ្ធពរភ្ញៀវ។ ប៉ុន្តែវិបត្តិសេដ្ឋកិច្ចឆ្នាំ ១៩៩៧ បានបន្ទុចបង្អាក់គម្រោងសាងសង់នេះ។ អ្នកអភិវឌ្ឍន៍គម្រោងបានបោះបង់ចោលទីនេះដោយទាំងមិនទាន់បានយករូបបដិមាទីពីរមកដាក់ផង"។*

*គ្មាននរណាដឹងថាអគារនេះ ដែលស្ថិតក្នុងទីតាំងសំខាន់មួយទល់មុខនឹងចំណតរថភ្លើង Taksin នឹងត្រូវបានសង់ចប់នោះទេ។ លោក Suthep ដែលនៅធ្វើការទីនេះអស់ប្រាំពីរឆ្នាំមក ហើយនិយាយថា វិនិយោគិនដែលចាប់អារម្មណ៍បានធ្លាប់ឈៀងចូលមើលកន្លែងនេះដែរ តែគ្មានអ្វីកើតឡើងទៀតទេ ក្រោយពីពួកគេមកមើលនោះ។*

*ទោះជាគាត់ប្រឹងការពារប៉ុណ្ណាក៏ដោយ ពួកចោរចេះតែមកលួចយកប្រដាប់ប្រដាសំណង់ និងគ្រឿងតាំងលំអជានិច្ច។ ពួកគេបានវាយបំបែកបង្អួចកញ្ចក់អស់ជាច្រើនផ្ទាំង។ បានបង្គន់ប្រហែល ៦០០ បាននៅជាន់ខាងលើៗ ត្រូវបានគេលួចដោះយកទៅអស់។ ខ្សែភ្លើង និងខ្សែកាបដែកទាំងប៉ុន្មានក៏មិននៅសេសសល់ដែរ។*

*គម្រោងជាច្រើនទៀតដែលត្រូវបានគេបោះបង់ចោល ក៏មានជោគវាសនាប្រហាក់ប្រហែលគ្នានេះដែរ ដោយចោរចេះតែលួចយកគ្រឿងសំណង់មានតម្លៃទៅអស់។*

*អគារ Sathon Unique ស្ថិតក្នុងចំណោម ៥០៨ អគារ ដែលម្ចាស់គម្រោងបានបោះបង់ចោលបន្ទាប់ពីមានវិបត្តិសេដ្ឋកិច្ចឆ្នាំ ១៩៩៧។ គម្រោងទាំងនោះ ត្រូវបានដាក់ក្រោមការគ្រប់គ្រងរបស់ Financial Sector Restructuring Authority (FRA) ជាអង្គភាពរដ្ឋសម្រាប់រៀបចំរចនាសម្ព័ន្ធបំណុលឡើងវិញ។ អង្គភាពនេះបានដាក់អគារទាំងនោះ លក់ដេញថ្លៃឡាយឡុងដល់ស្ថាប័នហិរញ្ញវត្ថុនានាក្នុងតម្លៃទាប ...*

# រៀបផែនការប្រមូលព័ត៌មាន

ពេលណាអ្នកដឹងសំណួរ ឬគោលគំនិតដែលអ្នកនឹងស្រាវជ្រាវធ្វើរឿងហើយ ចូរសាកបំបែកវាទៅជា **ធាតុផ្សំតូចៗ** ទៅជាប្រាំចំណែកបានហើយ (ព្រោះថាអ្នកពិតជានឹងភ្ញាក់ផ្អើលចំពោះលទ្ធភាពតិចតួចដែលអ្នកនឹងមានសម្រាប់សិក្សាស្រាវជ្រាវធ្វើអត្ថបទពិពណ៌នាមួយ)។ ចំណុចតូចៗទាំងប្រាំនេះ (ឬបួនក៏បានដែរ) នឹងផ្តល់ចម្លើយដល់សំណួរមេ ឬក៏ពិនិត្យគោលគំនិតរបស់សាច់រឿង។ ក្នុងការធ្វើរឿង គេអាចដើរតាមធាតុផ្សំទូទៅដូចខាងក្រោមនេះ៖

- អ្នកណាខ្លះនឹងទទួលរងផលប៉ះពាល់ដោយសារបញ្ហានោះ ហើយពួកគេទទួលរងដោយរបៀបម៉េច? តើអ្នកអាចផ្តោតទៅលើមនុស្សណាម្នាក់ កន្លែងណាមួយ ឬមុខរបរធុរកិច្ចណាមួយ ដើម្បីបង្ហាញដល់អ្នកអានបានទេ?
- តើបញ្ហានោះមានទំហំធំប៉ុណ្ណាទៅ? មានន័យថា តើមនុស្សប៉ុន្មាននាក់ ឬទីកន្លែង ឬរបររកស៊ីប៉ុន្មានកន្លែងដែលនឹងជួបប្រទះស្ថានភាពប្រហាក់ប្រហែលគ្នានេះដែរ?
- តើពីមុនមក បញ្ហាមួយហ្នឹងមានប្រវត្តិ និងសាវតារយ៉ាងណាខ្លះ? និយាយមួយបែបទៀត តើអ្វីខ្លះជាបុព្វហេតុនៃបញ្ហាទាំងនេះ ឬជាមូលហេតុដែលនាំឲ្យមានស្ថានភាពបច្ចុប្បន្ន?
- តើគេបានធ្វើអ្វីខ្លះចំពោះបញ្ហានោះ ហើយតើមានអ្នកណាកំពុងព្យាយាមដោះស្រាយវាទេ? ត្រង់នេះជាសំណួរសំដៅស្វែងយល់អំពីដំណោះស្រាយ។
- តើកិច្ចប្រឹងប្រែងទាំងនេះនឹងនាំឲ្យមានផលបច្ច័យយ៉ាងណាខ្លះ ហើយថាតើនឹងមានអ្វីកើតឡើងទៀតនាពេលអនាគត?

ចូរពិនិត្យចំណុចនីមួយៗ ហើយសាកល្បងមើលថាតើអ្នកនឹងឆ្លើយវារបៀបម៉េច។ ដូចធ្លាប់ធ្វើរាល់ដងអញ្ចឹង ចូរផ្តើមដោយធ្វើ**ការសិក្សាស្រាវជ្រាវឯកសារ (archive homework)** ជាមុនសិន។ ធ្វើយ៉ាងណាឲ្យអ្នកយល់ដឹងថា តើមានអ្វីខ្លះដែលបានសរសេរ និងចុះផ្សាយរួចហើយ ឬនៅលើប្រធានបទនេះ។ បន្ទាប់មកទៀត ធ្វើបញ្ជីឈ្មោះប្រភពដែលអ្នកត្រូវជួប ដើម្បីសាកសួរអំពីបញ្ហាក្នុងប្រធានបទនោះ។

ប្រភពព័ត៌មានរបស់អ្នកនាង Anchalee រួមមាន ផ្ទាំងសន្តិសុខ ម្ចាស់គម្រោង អ្នកឯកទេសពីរូបផ្នែកវិស្វកម្ម និងស្ថាបត្យកម្ម និងរបាយការណ៍អធិការកិច្ចពីរដ្ឋបាលក្រុងបាងកក។ បន្ទាប់ពីផ្តោតលើអគារមួយហើយ នាង Anchalee ពង្រីករឿងរបស់នាង ដោយបញ្ចូលក្នុងរឿងនូវអគារឯទៀតដែលមិនទាន់បានសាងសង់ចប់សព្វគ្រប់បញ្ហាសង្គមនានាទាក់ទិននឹងអគារទាំងនោះ និងដំណោះស្រាយ ដែលអាចកើតមានសម្រាប់អភិវឌ្ឍន៍អគារទាំងនោះឡើងវិញ។

# កុំនៅតែក្នុងការិយាល័យ

សំខាន់ជាងអ្វីទាំងអស់ ចូរសួរខ្លួនឯងថា ***កន្លែងណា* ដែលខ្ញុំអាចទៅ ដើម្បី *មើលឃើញ* សាច់រឿងកំពុងស្ថិតក្នុងសកម្មភាព?** ត្រង់នេះឯងជាគន្លឹះសម្ងាត់សម្រាប់សរសេរអត្ថបទពិពណ៌នាមួយឲ្យបានល្អនោះ។ វាប្រៀបបាននឹងការហុចវីឌីអូកាមេរ៉ាមួយទៅឲ្យអ្នកយកព័ត៌មានម្នាក់ ហើយនិយាយថា

"យកវាទៅ ហើយពេលត្រឡប់មកវិញ យករូបមានចលនាល្អៗមកជាមួយផង"។ អ្នកសរសេរអត្ថបទពិពណ៌នានាំត្រឡប់មកវិញនូវ**រូបភាពជាពាក្យពេចន៍** ដែលគេច្រើនហៅថា **ពណ៌លំអសាច់រឿង (colors)**។ ពណ៌លំអសាច់រឿងនេះ នឹងមានប្រសិទ្ធភាពប្រហែលគ្នានឹងរូបភាពមានចលនាដែរ។ បើអ្នកដឹងថាអ្នកត្រូវថតរូបភាពវីឌីអូយកមកធ្វើរឿង អ្នកពិតជានឹងមិនត្រូវនៅក្នុងការិយាល័យធ្វើរឿងនោះតាមទូរស័ព្ទទេ។

បន្ទាប់មកទៀត អ្នកគួរពិភាក្សាអំពី **គំនិតសោតទស្សន៍ (visual ideas)** ជាមួយនិពន្ធនាយក ឬអ្នកថតរូប ពីព្រោះថា អត្ថបទពិពណ៌នាតែងត្រូវមានរូបភាពមកអមជាមួយវា។ បើសិនជាអ្នកជាអ្នកសារព័ត៌មានអនឡាញ ចូរកុំភ្លេចនាំមកវិញនូវរូបវីឌីអូ ឬរូបភាពរបស់អ្នកធ្វើសេចក្ដីរាយការណ៍រឿងក្នុងវីឌីអូនោះផង។

## អ្នកចង់បានអ្វីពីការប្រមូលព័ត៌មាន

ដូចគ្នានឹងអ្នកសារព័ត៌មានចំណានៗឯទៀតដែរ អ្នកពិតជាចង់បាននូវភស្តុតាងមួយ មានតុល្យភាពក្នុងការសិក្សាគោលគំនិតមួយសម្រាប់ធ្វើរឿង។ ក្នុងនេះ ត្រូវមាន**ព័ត៌មានជាឯកសារ ឬស្ថិតិ** ដែលទាក់ទងនឹងសាច់រឿង (តែសូមកុំយកច្រើនពេក)។ អ្នកក៏ត្រូវនិយាយជាមួយមនុស្សដែលពាក់ព័ន្ធនឹងរឿងនោះដែរ - ដោយផ្ដើមពី **ពលរដ្ឋសាមញ្ញ** ដែលជីវិតរបស់ពួកគេអាចទទួលឥទ្ធិពលពីបញ្ហាដែលអ្នកកំពុងពិនិត្យមើលនោះ។ ពួកគេជា**អ្នកឯកទេសពិតប្រាកដក្នុងប្រធានបទ**នោះ។ វាក៏អាចជាការចាំបាច់ដែរក្នុងការជជែកជាមួយអ្នកឯកទេសផ្លូវការ ដែលជា**អ្នកមានសមត្ថកិច្ចលើប្រធានបទ**។

នាង Anchalee បានដកស្រង់សម្ដីពីរបាយការណ៍មួយដែលបាននិយាយថា អគារខ្លះបានក្លាយជាទីតាំងប្រព្រឹត្តបទឧក្រិដ្ឋ។ នាងក៏បានពិគ្រោះយោបល់ជាមួយអ្នកឯកទេសមួយចំនួនដែររួមមាន ព្រឹទ្ធបុរសនៃមហាវិទ្យាល័យវិស្វកម្មស៊ីវិលនៃវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី (Asian Institute of Technology' s School of Civil Engineering) ដែលនិយាយថា ភាគច្រើននៃអគារដែលត្រូវបានទុកចោលនោះ ស្ថិតក្នុងស្ថានភាពល្អនៅឡើយ ហើយវានឹងមិនរលំទេ។ នាងក៏បានដកស្រង់សម្ដីរបស់សាស្ត្រាចារ្យម្នាក់នៅមហាវិទ្យាល័យស្ថាបត្យកម្មនៃសាកលវិទ្យាល័យជូឡាឡុងកន (Chulalongkorn University) ដែលគាត់បានផ្ដល់គំនិតមួយចំនួនថាតើទីក្រុងបាងកកអាចអភិវឌ្ឍន៍ឡើងវិញនូវអគារទាំងនោះបានតាមបែបណាខ្លះ។ រីឯឆ្មាំសន្តិសុខវិញគាត់ គឺជាតួអង្គ **មនុស្សសាមញ្ញ** របស់នាងនៅក្នុងរឿងនោះ។

ក្នុងការចុះប្រមូលព័ត៌មាន ចូរអ្នក**សង្កេត**មើលអ្វីៗ ដែលកើតឡើងនៅជុំវិញខ្លួនរបស់អ្នក។ ហើយកុំភ្លេចស្រង់កំណត់ហេតុទុកផង រួមមាន**ការសន្ទនា**មិនមែនគ្រាន់តែសម្រង់សម្ដីប៉ុណ្ណោះទេ។

នាង Anchalee មានការ**ពិពណ៌នា**យ៉ាងល្អអំពីទីទទួលភ្ញៀវដ៏ងងឹត និងគ្មានមនុស្សក្នុងអគាររួមទាំងរូបបដិមាទីពីរដែលគេមិនបានយកមកដាក់នោះផង។ ចូរចាំផងថា អ្នកត្រូវមានអ្វីមួយដែលមានទម្ងន់ប្រកបដោយថាមពលសម្រាប់ធ្វើការបញ្ចប់រឿងផងដែរ។ វាអាចជាសម្រង់សម្ដីដើម ស្ថិតិ ឬព័ត៌មានណាមួយអំពីព្រឹត្តិការណ៍ទៅអនាគតដើម្បីធ្វើឲ្យរឿងមានដំណើរទៅមុខទៀត។ សេចក្ដីបញ្ចប់បែបនេះ ជួនកាល ត្រូវបានគេហៅថា outro (អាចនិយាយបានថាជា**ច្រកចេញ** ផ្ទុយទៅនឹង intro ដែលប្រៀបបាននឹង**ច្រកចូល** ទៅក្នុងសាច់រឿង ដែលយើងតែងហៅថា **សេចក្ដីផ្ដើម** នោះ)។ **ច្រកចេញ (outro)** មានន័យថា ការសរសេររឿងកំពុងឈានដល់ប្រយោគបញ្ចប់របស់វា ដែលគួរតែ



*ចូរកុំភ្លេចសង្កេតមើលអ្វីៗដើលកំពុងកើតឡើងនៅជុំវិញខ្លួនរបស់អ្នក។*

មានលក្ខណៈប្រកបដោយថាមពលគ្រប់គ្រាន់ដើម្បីធ្វើឲ្យអ្នកអានជក់ចិត្តចាំសាច់រឿងដូចគ្នានឹង intro មួយមានថាមពល និងគួរឲ្យចាប់អារម្មណ៍ធ្វើឲ្យអ្នកអានជក់ចិត្តភ្លាមតែម្តង។ ដូច្នេះចូរចងចាំចំណុចនេះពេលណាអ្នកប្រមូលព័ត៌មានយកមកសរសេរ។

នាង Anchalee បញ្ចប់រឿងជាមួយនឹងសម្រង់សម្តីដើមសាស្ត្រាចារ្យសាកលវិទ្យាល័យ ដែលធ្លាប់បានធ្វើការស្រាវជ្រាវអំពីផលប៉ះពាល់របស់អគារដែលត្រូវបានគេទុកចោលនោះ។

*លោកសាស្ត្រាចារ្យនិយាយថា៖ "យើងនៅមានអគារជាង ១០០ ដែលមិនទាន់សង់រួចរាល់ផង ហើយឥឡូវយើងប្រហែលជានឹងមានអគារថ្មីថែមទៀត។ បើនិន្នាការនេះនៅបន្តទៅមុខទៀត បាងកកនឹងក្លាយជាទីក្រុងអគារដែលសង់មិនទាន់ហើយ ដែលទាំងអស់នេះជាសារីរិកធាតុនៃវិបត្តិសេដ្ឋកិច្ច"។*

# អត្ថបទពិពណ៌នាបុគ្គលភាព (Profiles)

អត្ថបទពិពណ៌នាបុគ្គលភាព (profiles) ជារឿងរៀបរាប់អំពីបុគ្គល។ រឿងប្រភេទនេះអាចខ្លី ឬវែង។ ក្នុងប្រវែងខ្លី គេច្រើនប្រើវាជាឧទាហរណ៍បង្ហាញអ្នកអានថា តើជីវិតរបស់មនុស្សម្នាក់ត្រូវបានឆ្លុះបញ្ចាំងដូចម្តេចនៅក្នុងបញ្ហាធំមួយ។ អត្ថបទពិពណ៌នាបុគ្គលដែលមានប្រវែងខ្លី ច្រើនត្រូវគេយកមកចុះផ្សាយជា**អត្ថបទអម (sidebar)** ជាផ្នែកនៃកញ្ចប់រឿងនៅលើប្រធានបទមួយ។ អត្ថបទពិពណ៌នាបុគ្គលមានលក្ខណៈស៊ីជម្រៅ មានគោលដៅប្រាប់អ្នកអានថា តើបុគ្គលម្នាក់ជាមនុស្សប្រភេទណាពិតប្រាកដ ហើយថាតើអ្វីខ្លះដែលធ្វើឲ្យគេក្លាយជាមនុស្សមានជោគជ័យ ឬជាមនុស្សសំបូររឿងរ៉ាវចម្រូងចម្រាស់។ ចូរសួរនាំមនុស្សដទៃទៀតដែលស្គាល់បុគ្គលជាកម្មវត្ថុក្នុងរឿងនោះ។ ធ្វើដូច្នេះសំខាន់ណាស់សម្រាប់ការសរសេរអត្ថបទពិពណ៌នាបុគ្គលដែលវែង។ ចូរជជែកជាមួយមិត្តអតីតសហសេវិក ឬមួយក៏សត្រូវរបស់បុគ្គលនោះក៏បានដែរ។ មានតែធ្វើដូច្នេះទេ ទើបអ្នកអាចកសាងបាននូវរូបភាពបុគ្គលិកលក្ខណៈត្រឹមត្រូវមួយអំពីមនុស្សម្នាក់នោះ។

ក្បួនជាមូលដ្ឋាននៃវិជ្ជាជីវៈសារព័ត៌មាន ដូចជាគោលការណ៍ ភាពទៀងត្រង់ ជាក់លាក់ និងភាពត្រឹមត្រូវមិនលំអៀង (accuracy and fairness) នៅតែអាចប្រើបានក្នុងអត្ថបទពិពណ៌នាបុគ្គលភាពដូចដែលគេប្រើវាក្នុងអត្ថបទដំណឹង និងអត្ថបទពិពណ៌នាទូទៅដែរ។ ចូរសាកប្រតិបត្តិតាមយុទ្ធសាស្ត្រដូចខាងក្រោមនេះ៖

- ធ្វើការស្រាវជ្រាវអំពីបុគ្គលកម្មវត្ថុរបស់អ្នកឲ្យបានច្រើនតាមតែអាចធ្វើទៅបានមុននឹងទៅសម្ភាសន៍មនុស្សនោះ។ ឆែកមើលអត្ថបទកាសែតពីមុនមក ហើយសួរសហសេវិកឲ្យជួយលើកជាសំណួរដែលគេចង់សួរ បើសិនជាគេជាអ្នកទៅសម្ភាសន៍។
- សម្ភាសន៍បុគ្គលជាកម្មវត្ថុនៅកន្លែងណាដែលធ្វើបុគ្គលនោះមានអារម្មណ៍សុខដុម។

អ្នកខ្លះអាចជ្រើសរើសយកគេហដ្ឋានរបស់គេតែម្តងសម្រាប់ផ្តល់សម្ភាសន៍។ អ្នកផ្សេងអាចជ្រើសយកកន្លែងធ្វើការ។ សង្កេតដោយប្រុងប្រយ័ត្ន ហើយពេលសរសេរអត្ថបទ ចូររៀបរាប់អំពីទឹកមុខ រាងរៅ កាយវិការរបស់បុគ្គលជាកម្មវត្ថុ សកម្មភាពរបស់គាត់ និងបរិយាកាសជុំវិញកិច្ច-សម្ភាសន៍ផង។

- ព្យាយាមឈ្លេចរកមើលថា តើអ្វីដែលវិសេសដោយឡែកអំពីបុគ្គលនោះ។ តើគាត់មានសុបិនការសោកស្តាយវីរជនគំរូ ចំណុចខ្លាំង ចំណុចខ្សោយ បែបណាខ្លះ ឬមួយក៏សៀវភៅ ឬភាពយន្តប្រភេទណាខ្លះដែលជាចំណង់ចំណូលចិត្តរបស់គាត់? តើអ្វីដែលញ៉ាំងឲ្យគេធ្វើនូវអ្វី ដែលគេកំពុងតែធ្វើនោះ? តើបុគ្គលនោះជំនះការតស៊ូរបស់គេបានយ៉ាងដូចម្តេចខ្លះ?
- ចូរសម្ភាសន៍ឲ្យបានវែង តែសរសេរឲ្យខ្លី។ អត្ថបទពិពណ៌នាបុគ្គលភាពដែលល្អនោះ គឺអត្ថបទ ដែលមានតែជាតុផ្សំខ្លាំងបំផុតពីកិច្ចសម្ភាសន៍ និងសម្រង់សម្តីដើម ដែលលេចធ្លោជាងគេតែប៉ុណ្ណោះ។



*តើមានអ្វីពិសេសអំពីបុគ្គលជាកម្មវត្ថុនៃរឿងរបស់អ្នក?*

- លើកទឹកចិត្តបុគ្គលជាកម្មវត្ថុឲ្យនិទានរឿងនានា ដែលអ្នកយកមកប្រើជាការដំណាលនៅក្នុងអត្ថបទរបស់អ្នកបាន។
- ចូរកុំភ្លេចបញ្ចូលសារតៈដែលប្រាប់ដល់អ្នកអានថា ហេតុអ្វីបានជាពួកគេគួរខ្វល់អានអំពីបុគ្គលនោះ។ តើលោកនោះ ឬនាងនោះធ្លាប់មានវត្តមានក្នុងសារព័ត៌មានកាលពីពេលថ្មីៗនេះទេ ឬមួយក៏ពួកគេធ្លាប់ពាក់ព័ន្ធក្នុងព្រឹត្តិការណ៍ណាមួយដែលត្រូវបានគេយកទៅផ្សាយជាដំណឹងទេ? តើគាត់ ឬនាង ជាឧទាហរណ៍នៃបញ្ហាធំមួយ ឬនិន្នាការមួយក្នុងសង្គម ឬយ៉ាងណា?

អត្ថបទពិពណ៌នាបុគ្គលភាពអាចមានប្រវែងវែង ឬខ្លី។ ខាងក្រោមនេះ ជាឧទាហរណ៍មួយដែលមាន ៤00 ពាក្យ ជាភាសាអង់គ្លេស ដែលត្រូវបានសរសេរដោយនាង Minh Phuong នៃកាសែត Than Nien នៅវៀតណាម។ ការរ៉ាយរ៉ាប់របស់នាងមានលក្ខណៈជា**កាលប្បវត្តិ** ចាប់ផ្តើមពីពេលដែលក្មេងប្រុសនោះត្រូវបានប្រសូត្រ ហើយនាំយើងទៅដល់ពេលអាយុបច្ចុប្បន្នរបស់ក្មេងប្រុសនោះ គឺអាយុ ១៣ ឆ្នាំ។

*ទារក ម៉ៃ វូ (Mai Vu) ជួបភាពអកុសលច្រើនណាស់ក្នុងជីវិតដ៏ខ្លីរបស់គេ ដែលអ្នកឯទៀតកម្រជួបប្រទះ។*

*ពេលដែលគេចាប់កំណើតភ្លាម សោកនាដកម្មកកើតមានមកជាមួយរូបគេដែរ។ ជំងឺល្អិតល្អៃមួយបានធ្វើឲ្យទារករូបនេះបេះតែប្រកាច់ ដែលមិនអាចឲ្យវាធ្វើចលនាជម្មតាបាន។ ដៃទាំងពីររបស់វាពត់ក្រងង់ មាត់វៀច ហើយជើងទាំងពីរស្វិត។*

*ពេលវាមានអាយុមួយឆ្នាំ ស្ថានភាពរបស់វាក៏ចុះដុនដាបដែរ។ វូ នៅដេកទ្រឹងមួយកន្លែង នៅពេលដែលទារកឯទៀតក្នុងវ័យប្រហែលគ្នានេះដែរ ចាប់*

*ផ្តើមរៀនដើរ និងរៀននិយាយ។ វាមិនអាចទាំងយំបានផង កុំថាឡើយអាចនិយាយបាននោះ។*

*ប៉ុន្តែមានថ្ងៃមួយនោះ គ្រួសាររបស់វាដែលរស់នៅទីក្រុងវ៉េ (Hue) នៃភូមិភាគកណ្តាលប្រទេសវៀតណាម ទទួលដំបូន្មានឲ្យនាំកូននោះទៅកាន់មជ្ឈមណ្ឌលកុមារពិការ Son Ca (Son Ca Center for Disabled Children)។ គឺពេលនោះហើយដែលធ្វើឲ្យជីវិតរបស់គេមានការប្រែប្រួល។*

*នៅមជ្ឈមណ្ឌលនោះ គ្រូបង្រៀនបានជួយឲ្យក្មេងប្រុសនេះឲ្យមានថាមពលប្រសើរឡើងវិញ ហើយចេះប្រើសម្លេងរបស់វា។ ជារឿងគួរឲ្យភ្ញាក់ផ្អើលដល់មនុស្សជាច្រើន ទារក វូ ស្រាប់តែអាចកម្រើកខ្លួនរបស់វាបាន ហើយថែមទាំងអាចបន្លឺពាក្យខ្លះៗទៀតផង។*

*ក្រោយបន្តិចមកទៀត វាអាចយកម្រាមជើងរបស់វាគាបខ្មៅដៃ និងដីស ហើយរៀនគូរគំនូរ។*

*គ្រូរបស់ វូ បានប្រឹងខ្លាំងណាស់ក្នុងការបង្រៀនវាឲ្យចេះអានសរសេរ ហើយក្មេងប្រុសនេះ ក៏ស្រាប់តែមានការជក់ចិត្តក្នុងការរៀនសរសេរ និងគូររូបដែរ។*

*វាមានសេចក្តីសប្បាយរីករាយបំផុត នៅពេលដែលវាអាចសម្តែងគំនិតបានតាមរយៈរូបសិល្បៈរបស់វា។*

*ក្មេងប្រុសនោះនិយាយថា៖ "ពេលខ្ញុំធំឡើង ខ្ញុំចង់ក្លាយខ្លួនជាជាងគំនូរ"។*

*មុនដំបូង វូ ប្រឹងពេញសមត្ថភាព ដើម្បីគូររូបលើកម្រាល ប៉ុន្តែម្រាមជើងរបស់វាក៏ចាប់ផ្តើមរោយដោយសារការខំប្រឹងខ្លាំងពេកទាំងលំបាក។*

*ឪពុករបស់វា លោក ម៉ៃ ង៉យ (Mai Ngoi) និយាយថាដំបូងឡើយ ការគូររូបជាការប្រឹងប្រែងមែនទែនរបស់ក្មេងប្រុសនេះ ដោយវាត្រូវប្រមៀលខ្លួនវាចុះឡើងដើម្បីផលិតឲ្យចេញជាគំនូរមួយបាន។*

*លោកនិយាយថា៖ "យើងតានតឹងក្នុងអារម្មណ៍មែនទែន ពេលដែលឃើញវាប្រមៀលខ្លួនចុះឡើង ប៉ុន្តែយើងមិនអាចបន្ទច់បង្អាក់វាទេ ព្រោះវាសប្បាយ និងជក់ចិត្តនឹងធ្វើបែបនោះណាស់"។*

*គាត់បន្ថែមថា៖ "យើងបានត្រឹមតែអង្គុយក្បែរវា ដើម្បីលើកទឹកចិត្តវាឲ្យប្រឹងអស់សមត្ថភាពតែប៉ុណ្ណោះ"។*

*ពេលនេះវាមានអាយុ ១៣ ឆ្នាំ ហើយវាគូររូបភាពបានជាច្រើនរហូតដល់ថា ឪពុកម្តាយរបស់វាមិនអាចចាំបានថា តើសៀវភៅគំនូរសិល្បៈចំនួនប៉ុន្មានក្បាលទេដែលវាបានគូរចប់នោះ។*

*កុមារ វូ និយាយថា៖ "ខ្ញុំចូលចិត្តគូររូបទូក ពីព្រោះវាអាចឲ្យខ្ញុំជិះលើវាហោះទៅលើមេឃបាន"។*

*រូបគំនូរទាំងនោះ មិនមែនសម្រាប់តែវាម្នាក់ទេ តែវាក៏ជាប្រភពលើកទឹកចិត្តដល់ឪពុកម្តាយរបស់ឲ្យជំនះបាននូវការលំបាកនានាក្នុងជីវិតផងដែរ។*

*ឪពុករបស់ វូ និយាយថា៖ "ក្រោយត្រឡប់ពីធ្វើការវិញ ខ្ញុំមានអារម្មណ៍ថា ការនឿយហត់របស់ខ្ញុំទាំងអម្បាលម៉ានសោយបាត់អស់ទៅវិញ ហើយពេលដែលខ្ញុំឃើញគំនូររបស់កូនប្រុសខ្ញុំ និងការខិតខំរបស់វា"។*

# ប្រើស្ទីលបទពិពណ៌នាក្នុងការសរសេរដំណឹង

អ្នកយកព័ត៌មាន និងនិពន្ធនាយកជាច្រើនគិតថា អត្ថបទពិពណ៌នាជាអត្ថបទ "ទន់ជ្រាយ" ដូច្នេះវាមិនគួរត្រូវបានចុះផ្សាយនៅទំព័រមុខកាសែត ឬនៅលើគេហទំព័រនៃវិបសាយណាមួយទេ។ តែអត្ថបទពិពណ៌នាខ្លះក្នុងចំណោមបទពិពណ៌នាល្អៗបំផុតនិយាយអំពីព្រឹត្តិការណ៍ទើបនឹងកើតឡើង ឬកំពុងតែវិវត្តន៍។ ដូច្នេះ រឿងប្រភេទនេះមិនមែនជាអត្ថបទទន់ជ្រាយទេ។ អ្នកយកព័ត៌មានរៀបរាប់វិនាដកម្មនៃព្រឹត្តិការណ៍មួយ ដោយផ្តោតទៅលើមនុស្សម្នាពាក់ព័ន្ធ និងបទពិសោធន៍ដែលពួកគេជួបប្រទះ។ និយាយយ៉ាងខ្លី ខ្សែបន្ទាត់ខណ្ឌរវាងអត្ថបទដំណឹង និងអត្ថបទពិពណ៌នានៅមានភាពស្រពិចស្រពិលនៅឡើយ។

ខាងក្រោមនេះជាឧទាហរណ៍ខ្លះអំពីស្ទីលអត្ថបទពិពណ៌នា ដែលអាចយកមកប្រើជាមួយអត្ថបទដំណឹងបាន៖

- សម្ភាសន៍អ្នករស់រានពីគ្រោះមហន្តរាយ ដើម្បីស្វែងយល់អំពីអ្វីដែលពួកគេបានពើបប្រទះ ហើយថាតើពួកគេលៃលកជាមួយបទពិសោធន៍នោះរបៀបម៉េច។
- សម្ភាសន៍ជនរងគ្រោះ ឬសាក្សីនៃឧក្រិដ្ឋកម្មណាមួយ ដើម្បីបង្កើតឡើងវិញនូវរូបភាពនៃអ្វីដែលបានកើតឡើងកន្លងមក។
- រកមើលថាតើមនុស្សម្នាលៃលករបៀបម៉េចជាមួយនឹងវិបត្តិសេដ្ឋកិច្ច។ តើពួកគេកាត់បន្ថយការចាយវាយឬ? តើពួកគេឈប់បង់វិក្កយបត្រសេវាផ្សេងៗ? តើពួកគេប្រឹងសន្សំប្រាក់ ឬយ៉ាងណា?
- ក្នុងពេលបោះឆ្នោត ចូរសួរអ្នកបោះឆ្នោតតើពួកគេគិតដូចម្តេចដែរអំពីបេក្ខជនឈរឈ្មោះ។ តើពួកគេនឹងទទួលផលប៉ះពាល់បែបណាខ្លះពីសំណាក់គោលនយោបាយដែលគណបក្សនយោបាយបានស្នើឡើងក្នុងយុទ្ធនាការបោះឆ្នោតនោះ?

ពីរថ្ងៃក្រោយពីមានការវាយប្រហារដោយភេរវកម្មនៅក្រុងមុមបៃ (Mumbai) ប្រទេសឥណ្ឌា នៅឆ្នាំ ២០០៨ អ្នកយកព័ត៌មាន Associated Press បង្កើតឡើងវិញនូវរូបភាពឆាកនៃការវាយប្រហារនោះ តាមរយៈការរ៉ាយរ៉ាប់ផ្ទាល់ពីអ្នករស់រានពីព្រឹត្តិការណ៍នោះ៖

*សម្តីរបស់អ្នករួចផុតពីការវាយប្រហារនៅក្រុងមុមបៃ៖ "សពមនុស្សដែលត្រូវបានគេសម្លាប់មាននៅពាសវាលពាសកាលទាំងអស់"។*

មុមបៃ, ឥណ្ឌា – *"មុនដំបូង លោក Walter Joy Pulithara ស្មានថាជាសម្លេងផ្ទុះដបស្រាដោយមូលហេតុណាមួយនោះ នៅក្នុងបារសណ្ឋាគារក្នុងទីក្រុងមុមបៃ។ គាត់ក៏រត់សំដៅកន្លែងមានសម្លេងផ្ទុះ តែពេលទៅដល់គាត់ឃើញស្ត្រីម្នាក់កំពុងស្រែកយំ ហើយបុរសវ័យក្មេងម្នាក់កំពុងបាញ់រះកាំភ្លើងពីក្នុងដៃរបស់ខ្លួន។*

*ខ្មាន់កាំភ្លើងនោះជាសមាជិកម្នាក់នៃក្រុមប្រដាប់អាវុធមួយ មានការត្រៀមរៀបចំត្រឹមត្រូវដែលបានធ្វើការឡោមព័ទ្ធអស់ពីរថ្ងៃ ធ្វើឲ្យរដ្ឋធានីឧស្សាហកម្មហិរញ្ញវត្ថុ និងឧស្សាហកម្មកំសាន្តរបស់ឥណ្ឌា បិទមិនដំណើរការ។ ព្រឹត្តិការណ៍នោះបណ្តាលឲ្យមនុស្សជាង ១៥០ នាក់ ស្លាប់ និងជាង ៣៧០ នាក់ ទៀតរបួស ហើយប្រែក្លាយសង្កាត់មាត់សមុទ្ររបស់ទីក្រុងឲ្យទៅជាកន្លែងពោរពេញដោយក្តីរន្ធត់។*

*មនុស្សម្នាសឹងតែរកពេលគេចខ្លួនមិនបានផង។ ពីលើគ្រែពេទ្យ ដែលនាងកំពុងទទួលការព្យាបាល*

*ប្តីស នាង Andreina Varagona ពលរដ្ឋអាមេរិក មកពីក្រុង Nashville រដ្ឋ Tennessee និយាយថា៖ "តែពីរនាទីប៉ុណ្ណោះ ពួកខ្មាន់កាំភ្លើងទាំងនោះតម្រង់មកដល់ពួកយើងបាត់ទៅហើយ"។ នាងត្រូវរបួសជើងស្តាំ និងដៃស្តាំ ឯសក់រួញរបស់នាងនៅប្រឡាក់ស្អិតឈាមរបស់មិត្តនាងពីរថ្ងៃក្រោយពីមានការវាយប្រហារនោះនៅឡើយ។*

*ទាហានកុម្ម៉ង់ដូឥណ្ឌាម្នាក់និយាយថា ខ្មាន់កាំភ្លើងទាំងនោះគ្មានរើសមុខទេ។ "ពួកវាបាញ់ទៅលើអ្នកណាក៏ដោយដែលនៅពីមុខពួកវា"។*

*មានគោលដៅចំនួន ១០ ក្នុងទីក្រុងទាំងមូលដែលត្រូវបានទទួលការវាយប្រហារ រួមមានសណ្ឋាគារផ្កាយប្រាំចំនួនពីរ ស្ថានីយអយស្ម័យយានភោជនីយដ្ឋានពេញនិយមមួយ និងវិហារជ្វីមួយដែរ។*

របៀបប្រើស្ទីលអត្ថបទពិពណ៌នា ធ្វើឲ្យអ្នកអានចាប់អារម្មណ៍ជក់ចិត្ត តាមរយៈសំណេររៀបរាប់ជាតុផ្សំ ដែលបង្កការចាប់អារម្មណ៍តែចង់តាមដានទៅមុខទៀត និងតាមរយៈការប្រើមុមផ្សេងៗគ្នាចំពោះដំណឹង។ តាមរយៈនេះ អ្នកអានយល់បញ្ហាបានល្អជាង ក្រោយពីអានរឿងដែលប្រើតិចនិកសរសេរអត្ថបទពិពណ៌នា។

ខាងក្រោមជាឧទាហរណ៍រឿងដែលប្រើស្ទីលអត្ថបទពពិពណ៌នា ដែលរៀបរៀងដោយអ្នកយកព័ត៌មាន Associated Press ម្នាក់ពីប្រទេសមីយ៉ាន់ម៉ា តែប៉ុន្មានថ្ងៃក្រោយពីមានគ្រោះធម្មជាតិខ្យល់ព្យុះណាហ្គីស (Nargis) បក់បោកទៅលើប្រទេសនេះ។ រឿងនេះប្រើរួមគ្នានូវជាតុផ្សំស្ទីលសរសេរអត្ថបទពិពណ៌នា និងស្ទីលសរសេរដំណឹងទាន់ហេតុការណ៍ (feature-writing and hard news)។

*សូមកត់សម្គាល់អំពីការផ្តោតលើមនុស្ស និងការប្រើការរៀបរាប់ក្នុងកថាខណ្ឌពីរដំបូង។*

***បុរសម្នាក់បាត់បង់ញាតិអស់ ២៨ នាក់ ក្នុងភូមិមួយដែលរងព្យុះស៊ីក្លូន***

*បុរសអ្នកនេសាទ ដែលមានអាយុ ៦៨ ឆ្នាំម្នាក់នេះ ព្យាយាមពន្យល់អំពីព្រឹត្តិការណ៍ ដែលព្យុះស៊ីក្លូនបក់បោកយកគ្រួសារទាំងមូលរបស់គាត់ទៅបាត់ តែគាត់បានតែត្រឹមបន្លឺពាក្យប៉ុន្មានម៉ាត់ប៉ុណ្ណោះ ដោយភាពក្តុកក្តួលក្នុងចិត្ត និងហូរទឹកភ្នែកនឹកដល់គ្រួសាររបស់គាត់។*

*លោក Thein Myint ដែលផ្ទះរបស់គាត់ត្រូវបានវាយបាក់បែកខ្ទេច ដោយរលកសមុទ្រកំណាចកើតមានពីព្យុះណាហ្គីស និយាយក្នុងភាពទួញសោកថា៖ "សមាជិកគ្រួសារខ្ញុំទាំង ២៨ នាក់ បានស្លាប់បាត់អស់ហើយ។ ខ្ញុំតែម្នាក់ឯងគត់ដែលនៅរស់"។*

*ភូមិរបស់គាត់ស្ថិតក្នុងខ្សែក្រវាត់ភូមិសាស្ត្រខូចខាតនៅ Bogalay ដែលស្ថិតក្នុងចំណោមទីប្រជុំជនទទួលរងការខ្ទេចខ្ទាំងធ្ងន់ធ្ងរ ដោយសារថាវាមានចម្ងាយប្រមាណជា ៣២ គីឡូម៉ែត្រប៉ុណ្ណោះពីសមុទ្រឥណ្ឌាក្នុងតំបន់ដីសណ្ត Irrawaddy។*

*បើគេសរសេរអត្ថបទដំណឹងធម្មតាវិញ អង្គហេតុខ្លះក្នុងកថាខណ្ឌទីបួននេះ នឹងអាចយកទៅប្រើក្នុងអត្ថបទដំណឹងបាន។*

*កាលពីថ្ងៃសុក្រ អ្នកភូមិនាំគ្នាត្រដរធ្វើដំណើរនៅលើអ្វីមួយដែលធ្លាប់តែជាវិថីមមាញឹកនៅក្នុងក្រុង Bogalay ដែលនៅទីនោះរដ្ឋាភិបាលនិយាយថា មនុស្ស ១០.០០០ នាក់ ត្រូវបានគេប្រមាណថាបានស្លាប់ និង ៩៥ ភាគរយ នៃគេហដ្ឋានត្រូវបានខូចខាត។ ខ្យល់នៅទីនោះពោរពេញដោយក្លិនល្វេយ និងខ្មោចរបស់សត្វក្របី និងសត្វដទៃទៀតដែលហើមស្ពឹងៗ។*

*អ្នកយកព័ត៌មានប្រើការសង្កេតដែលរួមមានការស្រង់រូបភាពតាមចក្ខុ និងការស្រង់ក្លិន។*

*កម្ទេចកម្ទី សំរាម មែកឈើរលំមានពាសវាលពាសកាលតាមដងវិថី រីឯសំណល់គ្រោងអគារ គឺជាសញ្ញាតែមួយគត់ឲ្យគេសម្គាល់ដឹងថា ទីនេះ ពីមុនមកធ្លាប់មានអគារធំៗអមដងផ្លូវ។*

*មកដល់ត្រឹមនេះ រឿងរ៉ាវត្រឡប់ទៅនិយាយអំពីអ្នករស់រានមានជីវិតវិញម្តង និងអំពីបទពិសោធន៍ផ្ទាល់ដែលពួកគេបានឆ្លងកាត់ក្នុងកថាខណ្ឌទីប្រាំមួយ។*

*អ្នកនៅរស់ ភាគច្រើនសល់ពីគ្រួសារមានសមាជិកច្រើនដែលជារឿងធម្មតានៅប្រទេសមីយ៉ាន់ម៉ា។ ពួកគេរៀបរាប់នូវសេចក្តីវេទនាដែលគេបានឆ្លងកាត់ ដូចជាការនៅរស់ឯកោទល់នឹងភាពស្រេកឃ្លាន ជំងឺ និងភាពឯកោគួរឲ្យព្រឺព្រួច បន្ទាប់ពីបានឃើញញាតិសន្តានត្រូវរលកសមុទ្រឆក់យកទៅបាត់។*

*នៅឯវត្តព្រះពុទ្ធមួយ ដែលមានមនុស្សជាច្រើនយកធ្វើជាទីជម្រកបណ្តោះអាសន្ននោះ លោកតា Htay Maung អាយុ ៧០ ឆ្នាំ និយាយក្នុងសម្លេងខ្សាវៗថា៖ "យើងតោងគ្នាជាប់ ប៉ុន្តែឈើធំៗដែលទឹករលកបោកមក បានវាយទម្លាក់កូនខ្ញុំពីរនាក់ និងប្រពន្ធរបស់ខ្ញុំទៅបាត់"។*

*មុនដំបូងពេលដែលខ្យល់ចាប់ផ្តើមបក់បោក ហើយព្យុះកាន់តែមានសន្ទុះខ្លាំង គាត់ ប្រពន្ធគាត់ និងកូនបួននាក់ នាំគ្នាឡើងលើដំបូលផ្ទះ ហើយពួកគេតោងដៃគ្នាជាប់នៅទីនោះ។*

*"ខ្ញុំសល់តែកូនពីរនាក់ទេ នៅរស់" - លោកតា Htay Maung និយាយដូច្នេះប្រាប់អ្នកយកព័ត៌មាន Associated Press ដែលបានទៅដល់ទីនោះតាមរថយន្តពីទីក្រុងយ៉ាំងហ្គុន ក្នុងដំណើរជាង ១៦០ គីឡូម៉ែត្រ តែត្រូវចំណាយពេលជិតប្រាំម៉ោង ដើម្បីទៅដល់ ដោយសារឧបសគ្គ ទឹកជំនន់ និងស្ពានបាក់។*

*អ្នកនៅរស់មានជីវិត នាំគ្នារៀបរាប់អំពីភូមិជាច្រើនត្រូវវិនាសបាត់សូន្យសុងដោយសារព្យុះ ដែលបានចាប់ផ្តើមបក់បោកកាលពីថ្ងៃទី ៣ ឧសភា ជាមួយខ្យល់ក្នុងល្បឿនជាង ១៩០ គីឡូម៉ែត្រ ក្នុងមួយម៉ោង ដោយរុញច្រានរលកដល់កម្ពស់ ៤ ម៉ែត្រ និងធ្វើឲ្យតំបន់ដីសណ្តដែលធ្លាប់មានមនុស្សរស់នៅកុះករលិចលង់ក្នុងទឹកជំនន់។*

*ផ្នែកនេះនៃរឿង វាដូចគ្នានឹងអត្ថបទដំណឹងដែរ។*

មនុស្សជាង ៦៥.០០០ នាក់ ត្រូវបានស្លាប់ ឬបាត់ខ្លួននៅក្នុងតំបន់នេះ ព្រមគ្នានឹងការមានក្ដីបារម្ភថា ចំនួនមនុស្សស្លាប់អាចកើនដល់ ១០០.០០០ នាក់។ អ្នកជួយសង្គ្រោះមិនទាន់អាចទៅដល់ទីនោះទេ ដោយសារផ្លូវនៅលិចក្នុងទឹកនៅឡើយក្នុងតំបន់ទទួលរងការខូចខាតធ្ងន់ធ្ងរ។

ដំណាំស្រូវដែលជាផលិតផលស្បៀងសំខាន់របស់ មីយ៉ាន់ម៉ា ត្រូវបានលិចលង់ខូចអស់ ដែលធ្វើឲ្យកាន់តែមានក្ដីព្រួយបារម្ភថែមទៀតអំពីអនាគត។

លោក Felix Leger ប្រធានប្រចាំប្រទេសនៃអង្គការ Action Against Hunger និយាយថា៖ "ព្យុះស៊ីក្លូននេះបានវាយប្រហារមុនរដូវប្រមូលផលកាត់មកដល់"។ គាត់មានប្រសាសន៍ក្នុងពេលដែលជំនួយសង្គ្រោះបានមកដល់ក្រោមការត្រួតពិនិត្យរបស់យោធា។

*អ្នកយកព័ត៌មានពិពណ៌នាសកម្មភាព៖ ទាហានលើកបាវក្មេងយំ អ្នកនៅរស់អង្គុយជុំគ្នា។*

តែក្នុងពេលដែលពួកទាហានកំពុងលីបាវជំនួយចុះពីឧទ្ធម្ភាគចក្រ មនុស្សម្នានាំគ្នាអះអាងថា អាជ្ញាធរមិនបានចែកស្រូវអង្ករសើម ឲ្យពួកគេយកមកចម្អិនជាអាហារនៅឡើយទេ។

អង្គុយជុំគ្នា អ្នករួចផុតពីគ្រោះកាចនោះនិយាយថា ការប្រកាសអាសន្នមកដល់យឺតពេក ហើយថាគ្មានការណែនាំអ្វីទាំងអស់ថាតើប្រជាជនគួរធ្វើដូចម្ដេចខ្លះក្នុងស្ថានភាពបែបនេះ។

បុរសម្នាក់ក្នុងចំណោមបុរសជាច្រើន ដែលកំពុងស្នាក់ក្រោមជម្រកគ្មានជញ្ជាំងក្នុងបរិវេណវត្តមួយ និយាយថា៖ "យើងដឹងថានឹងមានខ្យល់ព្យុះ តែយើងមិនដឹងថាវានឹងមានគ្រោះថ្នាក់បែបណាទេ ដូច្នេះខ្ញុំគ្រាន់តែប្រាប់កូនៗថាឲ្យនៅក្នុងផ្ទះ ដូចដែលខ្ញុំធ្លាប់ធ្វើពីមុនមកអញ្ចឹង"។

បុរសម្នាក់ទៀតបន្ថែមថា៖ "យើងបានឮអំពីការប្រកាសអាសន្នខ្យល់ព្យុះនៅម៉ោង ១ រសៀល ហើយព្យុះស៊ីក្លូនបានបក់មកដល់ ៥ ម៉ោង ក្រោយមកទៀត"។

អ្នកស្រុក Bogalay និយាយថា ការប្រកាសអាសន្នត្រូវបានធ្វើឡើង តាមប្រព័ន្ធសាធារណៈមួយក្នុងទីប្រជុំជន រីឯការជូនដំណឹងលាយលក្ខណ៍អក្សរ ត្រូវបានគេចែកចាយតាមទូកទៅកាន់ភូមិជុំវិញនោះដែលទទួលរងការខូចខាតយ៉ាងដំណំពេលព្យុះណាហ្គីសចាប់ផ្ដើមវាយប្រហារ។



ការរៀបរាប់ពិពណ៌នាជាមធ្យោបាយល្អមួយក្នុងការរក្សាចំណាប់អារម្មណ៍អ្នកអាន។

*អ្នកយកព័ត៌មានគូររូបភាព ដោយមានសេចក្ដីពិស្ដារ ដូចជា៖ មនុស្សរស់នៅក្រោមជាងដូង និងប្រើសំបកកំប៉ុងត្រងទឹកភ្លៀង។*

*កន្លែងខ្លះទៀតគ្មានទេ ជម្រកត្រឹមត្រូវនោះ ដូច្នេះអ្នករួចផុតពីគ្រោះអាក្រក់នេះច្រើននាក់ ប្រជ្រៀតគ្នាជ្រកក្រោមជាងដូងបួន-ប្រាំជាងដែលគេចងភ្ជាប់គ្នា ដោយមានថ្លុកទឹកក្លិនអសោចិ៍ហ៊ុំព័ទ្ធជុំវិញ។*

*ពួកគេប្រើសំបកកំប៉ុងត្រងទឹកភ្លៀង យកមកចម្អិនអង្ករបន្តិចបន្តួច ដែលពួកគេរកប្រមូលបានមកក្រោយពីព្យុះ។ អ្នកខ្លះព្យាយាមសំងួតស្រូវសើម ដោយដាក់វាហាលតាមដងផ្លូវ។*

*បុរសម្នាក់បានបង្ហាញស្នាមកន្ទួល ធ្នូតក្រហម ក្រវែមក្រវាមពេញខ្នងរបស់គាត់ ដែលបណ្ដាលមកពីការវាយធែប៉ះទង្គិចជាមួយមែកឈើ និងកំណាត់ឈើដែលរំលើងបាក់ ដោយសារទំហឹងនៃទឹកជំនន់។*

*សាកសពត្រូវបានគេយកចេញពីដងផ្លូវក្រុង Bogalay ហើយរីឯការជួសជុល ក៏បានចាប់ផ្ដើមដែរទៅលើបណ្ដាផ្ទះដែលបាត់ដំបូល និងសំណង់ដែលខូចខាត។ កម្មករនាំគ្នាអូសទាញបង្គោលភ្លើងបាក់ និងបន្ទះស័ង្កសីយកមកធ្វើដំបូល។*

*ក្នុងស្ទីលក្លាស៊ីកនៃការសរសេរអត្ថបទពិពណ៌នា អ្នកយកព័ត៌មានវិលត្រឡប់ទៅនិយាយអំពីបុរសនេសាទនៅឯខាងដើមរឿងវិញ។*

*លោក Thein Myint បុរសនេសាទកំសត់មានកូនប្រាំបីស្ថិតក្នុងចំណោមញាតិ ២៨ នាក់ ដែលត្រូវរលកបក់បោកយកទៅក្នុងសមុទ្របាត់នោះ ហាក់ដូចជាមិនរវីរវល់នឹងការជួសជុល ការស្ដារឡើងវិញ ឬក៏ជាមួយលុយទេ។*

*កំពុងហូបបាយលាយជាមួយត្រយ៉ូងចេកស្ងោរ គាត់និយាយថា៖ "ពេលនេះ លុយគ្មានន័យអ្វីទៀតទេសម្រាប់ខ្ញុំ ក្រោយពីខ្ញុំបាត់បង់គ្រួសារអស់ទៅ។ ពួកគេត្រូវបានទឹករលកឆក់យកទៅអស់ហើយ"។*

## វែងប៉ុណ្ណា ?

ឥឡូវនេះ ចូរងាកមកសំណួរមួយនៅពីខាងដើមជំពូកនេះវិញម្ដង៖ តើអត្ថបទពិពណ៌នាមួយគួរវែងប៉ុណ្ណា ? វាអាស្រ័យលើអង្គភាពព័ត៌មានរបស់អ្នក តាមប្រភេទនៃរឿងដែលអ្នកធ្វើ និងនៅផ្នែកទំព័រកាសែតដែលរឿងនោះនឹងត្រូវបានគេចុះផ្សាយ។ អត្ថបទពិពណ៌នាបុគ្គលភាពក្នុងកាសែត Than Nien មានប្រវែងជិត ៤០០ ពាក្យ (ជាភាសាអង់គ្លេស)។ អ្នកសរសេរសម្រាប់ទស្សនាវដ្ដីប្រចាំសប្ដាហ៍ ឬសម្រាប់ទំព័រទីមួយ អត្ថបទពិពណ៌នាច្រើនផលិតរឿងនីមួយៗដល់ទៅជាង ១.០០០ ពាក្យ (ជាភាសាអង់គ្លេស) ឯណោះ។ រឿងនីមួយៗក្នុងចំណោមឧទាហរណ៍ដែលយើងទើបនឹងពិនិត្យកន្លងមកនេះ មានប្រហែល ៨០០ ពាក្យ (ជាភាសាអង់គ្លេស) ដែលនេះជាកម្រិតប្រវែងមួយយើងគួរចងចាំកាលណាចាប់ផ្ដើមធ្វើអត្ថបទពិពណ៌នា។

# ជំពូក ៣
# ការសរសេរអត្ថបទពិពណ៌នា - ភាគ ២

ទោះជាអ្នកសរសេរបទពិពណ៌នាមានសេរីភាពជាងអ្នកយកព័ត៌មានដំណឹងទូទៅក៏ដោយ វាមិនមែនមានន័យថា អ្នកសរសេរម្នាក់អាចចេះតែញាត់ការរ៉ាយរ៉ាប់ សម្រង់សម្ដីល្អ និងឧទាហរណ៍នានាចូលទៅក្នុងសាច់រឿង ហើយរំពឹងថាអ្វីៗនឹងផ្គូរផ្គងសមគ្នាកើតទៅជា "អត្ថបទពិពណ៌នា" មួយបាននោះទេ។ វាពិតជាមិនដូច្នោះឡើយ។

អត្ថបទពិពណ៌នាល្អ គឺជាអត្ថបទដែលមានការរៀបរៀងសមទំនង មានមូលបទច្បាស់លាស់ ហើយអ្វីៗក្នុងរឿងនោះមានភាពប្រទាក់ប្រទងទៅនឹងមូលបទនោះ។ មានតែសេចក្ដីពិស្ដារសំខាន់ និងស្ដែងបំផុត ត្រូវបានយកមកបញ្ចូលក្នុងរឿង។ ដូចគ្នានឹងអត្ថបទដំណឹងដែរ អត្ថបទពិពណ៌នាត្រូវធ្វើសារគមនាគមន៍គំនិតច្បាស់លាស់ ឬមួយព្យាយាមឆ្លើយសំណួរ ហើយអះអាងបញ្ជាក់ដល់អ្នកអាន ដោយប្រើឧទាហរណ៍ ការពន្យល់ និងសម្រង់សម្ដីដើម។ វាក៏ត្រូវបន្ថែមបរិបទ និងសាវតារដែរ ហើយបង្ហាញថា ហេតុអ្វីបានជាបញ្ហាមួយដែលលើកឡើងក្នុងរឿងនោះវាសំខាន់។ ជាធម្មតា វាបញ្ចប់ដោយរបៀបមួយ ដែលជួយអ្នកអានឲ្យចងចាំគោលគំនិតក្នុងរឿងនោះបានទៀតផង។

## អង្គុយចុះ ចាប់ផ្ដើមចាត់ការ

ពេលណាអ្នកចាប់ផ្ដើមគិតថា តើត្រូវកសាងអត្ថបទពិពណ៌នារបស់អ្នកដោយរបៀបណា សូមកុំចាប់ផ្ដើមជាមួយនឹងសេចក្ដីផ្ដើម ឬជាមួយក្បាលអត្ថបទពិពណ៌នា (lead/intro or feature top)។ ផ្ទុយទៅវិញ ផ្ដើមដោយសរសេរ **កថាខណ្ឌមិត្តអ្នកអានជាទីរាប់អាន (Dear Reader Paragraph)** ដែលគេឲ្យឈ្មោះថា កថាខណ្ឌស្នូល **(nut graph)**។ កថាខណ្ឌស្នូលនេះមានមួយ ឬពីរឃ្លាពន្យល់ច្បាស់-លាស់ថា តើរឿងនេះនិយាយអំពីអ្វី (បានន័យថា កថាខណ្ឌនេះ វាដូចគ្នានឹងសេចក្ដីផ្ដើមនៃអត្ថបទដំណឹងដែរ។ ជាធម្មតា កថាខណ្ឌស្នូល គឺជាកថាខណ្ឌទីបី ឬទីបួន នៃអត្ថបទពិពណ៌នា។ បើសិនជាអ្នករកឃើញកថាខណ្ឌស្នូល ហើយសរសេរវាទុកជាមុនធ្វើដូច្នេះ វានឹងជួយអ្នកក្នុងការតម្រង់សាច់រឿងរបស់អ្នកបានងាយ។ ប៉ុន្តែចូរចាំថា កថាខណ្ឌនេះមិនទាន់ល្អឥតខ្ចោះនៅឡើយទេ ពីព្រោះថាអ្នកនឹងត្រូវភ្ជាប់វាជាមួយនឹងផ្នែកលើនៃរឿងដែលអ្នកមិនទាន់បានរៀបរៀងនៅឡើយទេ។ បន្ទាប់មកទៀត អ្នកត្រូវពង្រីកសាច់រឿងទៅដល់ចំណុចដែលអ្នកបានកត់ត្រាទុកជាមុន ដោយបញ្ចូលក្នុងនោះនូវព័ត៌មានពិស្ដារប្រភពការរ៉ាយរ៉ាប់លំអ និងសម្លេងរបស់មនុស្សដែលពាក់ព័ន្ធក្នុងរឿងនោះ។ លើសពីនេះទៀត អ្នកត្រូវបន្ថែមសាវតាររឿង បរិបទ និងស្ថិតិ ដែលចាំបាច់ធ្វើឲ្យរឿងកាន់តែមានភាពជឿជាក់បានថែមទៀត។

## ចាប់ផ្ដើមសរសេរ

ឥឡូវនេះ អ្នកអាចចាប់ផ្ដើមកសាងផ្នែកខាងលើនៃអត្ថបទពិពណ៌នារបស់អ្នកបានហើយ។ មានវិធីច្រើនណាស់សម្រាប់ធ្វើដូច្នេះ។ វាអាចជាការរ៉ាយរ៉ាប់អំពីបុគ្គលម្នាក់ ទីកន្លែង ឬព្រឹត្តិការណ៍មួយ។ វាអាចជាការដំណាលខ្លី ឬករណីសិក្សាណាមួយដែលមានការពាក់ព័ន្ធដល់មនុស្ស។ វាអាចជាការសង្កេត ឬគោលគំនិតទស្សនវិជ្ជា (ប៉ុន្តែមិនមែនយោបល់ផ្ទាល់ខ្លួនទេ)។ អ្នកអាចនិយាយយោងទៅដល់ភាពយន្ត

សៀវភៅ រឿងនិទានសម្រាប់ក្មេងៗ ដែលគេធ្លាប់ស្គាល់ជាទូទៅ ឬព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ឬវប្បធម៌ណាមួយ។ ភាពផ្ទុយគ្នារវាងមនុស្សពីរនាក់ ទីកន្លែងពីរ ឬពេលវេលាពីរ ក៏អាចយកមកធ្វើជាសេចក្ដីផ្ដើមបានដែរ ជាមួយនឹងការលេងពាក្យបន្ដិចបន្តួចក្នុងការសរសេរ។

កាលណាយើងរៀបរៀងបាននូវសេចក្ដីផ្ដើមហើយ ចូរភ្ជាប់វាជាមួយផ្នែកដទៃទៀតនៃរឿងតាមរយៈ **កថាខណ្ឌមិត្តអ្នកអានជាទីរាប់អាន (Dear Reader Paragraph)** ឬកថាខណ្ឌស្នូល។ បើនិយាយឲ្យស្រួលស្ដាប់ បន្ទាប់ពីសរសេរបានផ្នែកក្បាលរបស់រឿង ហើយអ្នកត្រូវប្រាប់អ្នកអានរបស់អ្នកឲ្យបានយល់ច្បាស់ថា តើក្បាលសាច់រឿងនឹងមានទំនាក់ទំនងដូចម្ដេចជាមួយផ្នែកឯទៀតនៃអត្ថបទពិពណ៌នានោះ។ ព្រោះថាផ្នែកក្បាលរឿងគ្រាន់តែជាអ្វីមួយដែលរំលេច ឬតំណាងឲ្យចំណុចឬគំនិតគោលដែលអ្នកនឹងសិក្សាបង្ហាញក្នុងអត្ថបទតែប៉ុណ្ណោះ។ អ្នកអានពិតជាមិនយល់អស់ ហើយនឹងគិតថា សេចក្ដីផ្ដើមជារឿងទាំងមូល។ ដូច្នេះចូរប្រាប់គេថា តើផ្នែកក្បាលនៃរឿងមានទំនាក់ទំនងដូចម្ដេចជាមួយផ្នែកឯទៀតក្នុងរឿង។ ហេតុនេះហើយបានជាគេហៅវាថាជា **កថាខណ្ឌមិត្តអ្នកអាន ជាទីរាប់អាន (Dear Reader Paragraph)** ឬ**កថាខណ្ឌស្នូល** ព្រោះវានិយាយទៅកាន់អ្នកអានថា "អូ! លោកអ្នកទើបនឹងបានអានសេចក្ដីផ្ដើម ឥឡូវនេះ ខ្ញុំសូមពន្យល់ដល់អ្នកថា តើសេចក្ដីផ្ដើមនេះ ទាក់ទិនយ៉ាងម៉េចជាមួយនឹងផ្នែកបន្តបន្ទាប់ទៀតក្នុងរឿងនេះ"។

ក្នុងការសរសេរ អ្នកគួរព្យាយាមកែសម្រួលកថាខណ្ឌស្នូលម្ដងហើយម្ដងទៀត រហូតទាល់តែភ្ជាប់ដោយរលូនទៅនឹងកថាខណ្ឌបន្ទាប់ទៀត។ វាត្រូវការពេលវេលាក្នុងការដុសខាត់ឲ្យមានភាពរលូនក្នុងការតាក់តែងកថាខណ្ឌស្នូលនេះ ប៉ុន្តែវាជាការព្យាយាមមានប្រយោជន៍ ពីព្រោះកថាខណ្ឌស្នូលនេះជាចំណុចដែលអាចធ្វើឲ្យអ្នកអានឈប់អាន - ពួកគេឈប់អាន ដោយសារគេងឿងឆ្ងល់អំពីអ្វីដែលពួកគេកំពុងអាន ហើយមានអារម្មណ៍អស់សង្ឃឹមដោយគេមិនយល់។ ដូច្នេះ ពួកគេនឹងងាកទៅអានអត្ថបទផ្សេងវិញជាមិនខាន។

ចូរនាំគ្នាងាកមកមើលសេចក្ដីផ្ដើមនៃរឿងខាងក្រោម ស្ដីអំពីផលប៉ះពាល់ពីការបិទព្រលានយន្តហោះក្នុងទីក្រុងបាងកក ដោយសារការបាតុកម្មនយោបាយ។ វាជាសេចក្ដីផ្ដើមនៃអត្ថបទដែលសរសេរដោយលោក Thomas Fuller អ្នកយកព័ត៌មានកាសែត International Herald Tribune។

*សណ្ឋាគារ Four Seasons បានលុបម្ហូប French oysters និង artichokes ចេញពីតារាងមុខម្ហូបរបស់គេហើយ។ រីឯអ្នកដាំផ្កាអ័រគីដេ ពួកគេបានកើតក្ដីមួម៉ៅ ដោយគេមិនអាចនាំផ្កាចេញទៅលក់ក្រៅប្រទេសបានដូចសព្វដង ហើយគេត្រូវបង្ខំចិត្តលក់ផលិតផលរបស់គេនៅផ្សារក្នុងស្រុក ក្នុងតម្លៃមួយភាគបីនៃតម្លៃធម្មតា។ ក្រុមហ៊ុនប្រៃសណីយ៍អន្តរជាតិ FedEx លែងអាចចែកចាយកញ្ចប់ប្រៃសណីយ៍ទាន់ពេលបានទៀតហើយ នៅពេលដែលកញ្ចប់ប្រៃសណីយ៍ជាច្រើនកំពុងជាប់គាំងស្ទះក្នុងប្រទេសថៃ ដែលកំពុងហ៊ុំព័ទ្ធដោយវិបត្តិ។*

*ជិតមួយសប្ដាហ៍បន្ទាប់ពីក្រុមបាតុកររំលោភព័ទ្ធព្រលានយន្តហោះទីក្រុងបាងកកមក រដ្ឋធានីប្រទេសថៃកំពុងតែស្ថិតក្នុងភាពឯកោតាមផ្លូវអាកាសហើយ។*

*ការបិទព្រលានយន្តហោះ Suvarnabhumi និង Don Muang មិនបានធ្វើឲ្យអ្នកណាម្នាក់ជួបប្រទះភាពអត់ឃ្លានទុរ្ភិក្សទេ។ ប្រទេសថៃជាប្រទេសអាចផ្គត់ផ្គង់ខ្លួនឯងបានគ្រប់គ្រាន់ផ្នែកស្បៀងចាំបាច់ជាមូលដ្ឋាន។*

*ប៉ុន្តែ វិបត្តិនេះកំពុងតែធ្វើឲ្យវិស័យទេសចរណ៍រងនូវភាពយ៉ាប់យ៉ឺន។ ប្រធានអាជ្ញាធរទេសចរណ៍ថៃបានរំពឹងថា ធុរកិច្ចផ្នែកនេះនឹងប្រទះស្ថានភាពអាក្រក់ជាងកាលពីក្រោយព្រឹត្តិការណ៍ព្យុះសមុទ្រស៊ូណាមិ ឆ្នាំ ២០០៤ ទៅទៀត។ ជាមួយគ្នានេះ ធុរកិច្ចឯទៀត ជាពិសេសផ្នែកនាំចេញ កំពុងតែត្រូវរស្វែងរកវិធីផ្សេងមកជំនួស នោះគឺព្រលានយន្តហោះដែលដំណើរការមិនរអាក់រអួល។*

ក្បាលរឿងផ្តើមដោយមុខម្ហូប oysters, artichokes និងផ្កាអ័រគីដេ តែជិតដល់ចុងបញ្ចប់នៃកថាខណ្ឌទីមួយ អ្នកអានក៏យល់បានភ្លាមថារឿងនេះនិយាយអំពីវិបត្តិនៅប្រទេសថៃ។ កថាខណ្ឌទីពីរ ជាចំណុចស្នូលនៃរឿង ដោយមានការលេបខាយពាក្យនិយាយថា ទីក្រុងបាងកក "កំពុងតែស្ថិតក្នុងភាពឯកោតាមផ្លូវអាកាស"។ ជាក់ស្តែង កថាខណ្ឌស្នូលនេះ បានហៀរចូលទៅក្នុងកថាខណ្ឌពីរបន្ទាប់ទៀត ដែលពន្យល់ក្បោះក្បាយថែមទៀត ដូចជាវិស័យទេសចរណ៍កំពុងប្រទះស្ថានភាពអាក្រក់ ហើយធុរកិច្ចផ្សេងទៀតកំពុងព្យាយាមរកផ្លូវផ្សេងទៀត ដើម្បីនាំទំនិញរបស់គេចេញទៅលក់។

ចូរនាំគ្នាក្រឡេកមើលឧទាហរណ៍សេចក្តីផ្តើម និងកថាខណ្ឌអត្ថបទពិពណ៌នាមួយចំនួនទៀតរបស់លោក Seth Mydans អ្នកឆ្លើយឆ្លងព័ត៌មានប្រចាំអាស៊ីអាគ្នេយ៍របស់កាសែត International Herald Tribune។ ឧទាហរណ៍ទីមួយ រៀបរាប់ទិដ្ឋភាពកំសត់មួយតាមរយៈការសង្កេតយ៉ាងជិតដល់។

*គៀនឃ្លាំង, កម្ពុជា - ជើងជ័រទំហំតូចបំផុតក្នុងមជ្ឈមណ្ឌលផលិតជើងសិប្បនិម្មិតនេះ គឺមានទំហំលេខ ៥។ ប៉ុន្តែទំហំនេះមិនសូវមានតម្រូវការទេ ព្រោះថាវាជាលេខកូនក្មេង ហើយក្មេងៗតិចណាស់ដែលអាចនៅរស់រានមានជីវិតបានបន្ទាប់ពីគ្រោះថ្នាក់ក្នុងការផ្ទុះគ្រាប់មីន។*

*កៅសិបភាគរយនៃពលរដ្ឋដែលមកទទួលអវយវៈសិប្បនិម្មិតនៅមជ្ឈមណ្ឌលនេះ ក្នុងខណ្ឌឫស្សីកែវក្រុងភ្នំពេញ ជាជនរងគ្រោះដោយសារគ្រាប់មីន។ មានជនកម្ពុជាច្រើនយ៉ាងហោចណាស់ ៤០.០០០ នាក់ដែរ ឬម្នាក់ក្នុងចំណោម ២៥០ នាក់ បានរងរបួសដាច់ដៃ ឬជើង ក្នុងការផ្ទុះគ្រាប់មីននៅកម្ពុជាដែលអ្នកឯកទេសនិយាយថា នេះជាអត្រាមួយខ្ពស់បំផុតក្នុងពិភពលោក។*

ខាងក្រោមនេះ ជាសេចក្តីផ្តើមទម្រង់អាថ៌កំបាំងក្នុងរឿងមួយនិយាយអំពីឃាតកម្មទៅលើមនុស្សម្នាក់ដែលមានកេរ្តិ៍ឈ្មោះល្បី។

*ភ្នំពេញ - ឥឡូវនេះ ជនកម្ពុជាម្នាក់ៗដឹងចម្លើយទៅនឹងពាក្យទាំងនេះហើយ៖ "ខ្ញុំមិនដឹងថាតើគេនឹងទុកឲ្យខ្ញុំរស់ ឬស្លាប់ទេ ពីព្រោះផែនដីកំពុងតែស្ថិតក្រោមការគ្រប់គ្រងរបស់គេហើយ"។*

*នាង ពិសិដ្ឋ ពិលិកា ដែលជាសិល្បៈការិនីមួយរូបស្រស់ស្អាត និងដែលគេពេញនិយមចូលចិត្តបានស្លាប់បាត់ទៅហើយ ដោយត្រូវគេបាញ់កណ្តាលថ្ងៃកាលពីខែកក្កដា ក្នុងអំពើឃាតកម្មដ៏ជំនាញមួយទៅលើរូបនាង ពេលដែលនាងកំពុងដើរផ្សារទិញឥវ៉ាន់ជាមួយក្មួយស្រីអាយុ ៧ ឆ្នាំ ម្នាក់។*

*កន្លះឆ្នាំបានកន្លងផុតទៅហើយ ប្រទេសកម្ពុជានៅតែស្លុងក្នុងសំណួរនេះដដែលក្នុងសៀវភៅកំណត់ហេតុបុគ្គលមួយ ដែលត្រូវបានចាត់ទុកថាជារបស់នាងពិលិកា៖ សំណួរនោះ គឺតើជនមានអំណាចមួយណា -- ជនមួយណាដែលកំពុងគ្រប់គ្រងផែនដី -- បញ្ជាការធ្វើឃាតនេះ?*

រីឯឧទាហរណ៍ខាងក្រោមនេះ បង្ហាញនូវការរៀបឡើងវិញនូវឆាកព្រឹត្តិការណ៍។

*ហាណូយ - នាង Nguyen Thi Men កំពុងគេងនៅលើគ្រែ ក្រោយពីបានភ្ញាក់ដឹងខ្លួនពីសន្លប់អស់ ៩ ថ្ងៃ កាលពីពាក់កណ្តាលខែមិនា ហើយនៅជុំវិញ*

គ្រែនោះ គ្រូពេទ្យ និងគិលានុបដ្ឋាយិកា នៅអមចាំមើលជាមួយនឹងការអង្វរករឲ្យនាងប្រឹងនៅរស់តទៅទៀត។

ពួកគេនិយាយថា៖ "ដកដង្ហើម ដកដង្ហើម។ ព្យាយាមឡើង។ ប្ដី និងកូនរបស់នាងកំពុងនៅរង់ចាំនាង"។

ក្នុងបទសម្ភាសន៍នៅឯគេហដ្ឋានរបស់នាងកាលពីចុងសប្ដាហ៍កន្លងទៅនេះ នាង Nguyen Thi Men និយាយថា នាងបានឮគេនិយាយ ហើយប្រឹងព្យាយាមដូចគេបានប្រាប់នាង បើទោះជានាងមានអារម្មណ៍ដូចកំពុងតែលង់ទឹកក៏ដោយ។

នាងនិយាយថា៖ "ខ្ញុំបានឃើញវេជ្ជបណ្ឌិតជាច្រើនមើលមកកាន់ខ្ញុំ ហើយវាពិតជាលើកទឹកចិត្តខ្ញុំមែនទែន។ មនុស្សច្រើននាក់ណាស់មើលមកខ្ញុំ ហើយខ្ញុំរំភើបក្នុងចិត្តខ្លាំងមែនទែន"។

អ្វីដែលនាងមិនបានដឹងនៅឡើយនាពេលនោះ គឺថាពួកគេបានមកចោមរោមមើលអ្វីមួយ ដែលអាចចាត់ទុកបានថាជាអភូតហេតុអស្ចារ្យ។ ព្រោះថានាងជាអ្នកនៅរស់តែម្នាក់គត់ ក្នុងចំណោមអ្នកជំងឺធ្ងន់ធ្ងរប្រាំមួយនាក់ ដែលបានទទួលឆ្លងជំងឺបន្ទាប់ពីមានការផ្ទុះមេរោគ SARS នៅមន្ទីរពេទ្យ Hano French Hospital កាលពីជាងពីរខែមុន។

ការរស់រានឡើងវិញរបស់នាង ជានិមិត្តរូបក្ដីសង្ឃឹមមួយសម្រាប់ប្រទេសវៀតណាម ដែលកាលពីថ្ងៃទី ២៨ មេសា កន្លងមកនេះ ត្រូវបានអង្គការសុខភាពពិភពលោកប្រកាសថាជាប្រទេសទីមួយដែលត្រូវធ្វើការទប់ស្កាត់ និងលុបបំបាត់មេរោគនេះ។ ប្រទេសវៀតណាមទទួលបានលក្ខណៈពិសេសបែបនេះ ដោយគ្មានករណីថ្មីណាមួយនៃជំងឺនេះកើតឡើងទេក្នុង ២០ ថ្ងៃ ជាប់គ្នាកន្លងមកនេះ បន្ទាប់ពីមានការឆ្លង ៦៣ ករណី កន្លងមកក្នុងនោះ មានប្រាំជាករណីធ្ងន់ធ្ងរ។ មនុស្សប្រាំនាក់បានស្លាប់បាត់ហើយដោយសារមេរោគនេះ។

ហើយខាងក្រោមនេះ ជាឧទាហរណ៍សេចក្ដីផ្ដើមដែលបង្ហាញភាពផ្ទុយគ្នា៖

ភ្នំពេញ - ថ្ងៃមួយ ពេលដែលមេដឹកនាំខ្មែរក្រហមពីររូប ដែលរងការចោទប្រកាន់ថាបានសម្លាប់មនុស្សអស់ជាងមួយលាននាក់ ធ្វើដំណើរកំសាន្តឆ្នេរសមុទ្រដោយមានកម្លាំងយោធា និងអ្នកនាំភ្ញៀវអមដំណើរផងនោះ ពួកគេបានជិះឡានកាត់មុខគុកមួយ ដែលនៅទីនោះ សកម្មជនសិទ្ធិមនុស្សកម្ពុជាពីររូបកំពុងទទួលការប្រព្រឹត្តបែបផ្សេងទៅវិញ។

សកម្មជនសិទ្ធិមនុស្សពីររូបនោះ កំពុងត្រូវបានគេឃុំឃាំងក្រោមបទចោទស្រពិចស្រពិលមួយក្រោយពីពួកគេបានឲ្យដំបូន្មានដល់ក្រុមបាតុករដែលបានបះបោរប្រឆាំងនឹងការចាក់កាកសំណល់ជាតិពុលគីមី នៅឯជាយក្រុងនេះ។ បាតុករ ១០ នាក់ផ្សេងទៀត ក៏ត្រូវបានគេចាប់ខ្លួនដែរ។

នេះជារូបភាពផ្ទុយគ្នាស្រឡះដែលកាន់តែរំលេចឲ្យឃើញនូវវិសមធម៌ក្នុងដំណើរវិវត្តន៍របស់ប្រទេសកម្ពុជាឲ្យក្លាយទៅជារដ្ឋសេរី និងកាន់លទ្ធិប្រជាធិបតេយ្យមួយ។ វាក៏ជះស្រមោលមិនល្អមួយដែរទៅលើការដែលនិយាយថា ប្រទេសកម្ពុជាអាចមានវិធីដោយខ្សែកក្នុងការលៃលកជាមួយឧក្រិដ្ឋកម្ម និងភាពឈឺចាប់រ៉ាំរ៉ៃផ្លូវចិត្ត ដែលបានកើតមានក្នុងប្រទេសរបស់ខ្លួន។

ទីនេះជាទឹកដីយុត្តិធម៌តាមទំនើងចិត្ត ដែលគ្មាននរណាម្នាក់ មិនថាឃាតក ឬជាសកម្មជនសិទ្ធិមនុស្សទេ អាចប្រាកដក្នុងចិត្តបានជាមុនថាគេនឹងរំពឹងទទួលបាននូវប្រព្រឹត្តកម្មបែបណាឡើយចំពោះទង្វើរបស់គេនីមួយៗរបស់គេនោះ។



*អ្នកសារព័ត៌មានត្រូវវាសរវៃចុះទៅដល់កន្លែងហេតុការណ៍ ដើម្បីយកព័ត៌មាន។*

## ដងខ្លួនបទពិពណ៌នា

ក្រោយពីសរសេរសេចក្ដីផ្ដើម និងកថាខណ្ឌស្នូលបានហើយ ជាពេលដែលអ្នកត្រូវចាត់ការជាមួយចំណុចដទៃ ដែលអ្នកចង់រំលេចឡើងក្នុងសាច់រឿង ដោយលើកមកបង្ហាញនូវប្រភពនានា សាវតាររឿងរ៉ាវ បរិបទ សម្ដីដើម និងស្ថិតិ ដែលអ្នកប្រមូលបាន។ ធាតុផ្សំណាដែលទាក់ទិនគ្នា សូមដាក់វាក្បែរគ្នា ហើយរកមើលកន្លែងណាដែលអ្នកអាចរំញោចចំណាប់អារម្មណ៍អ្នកអានឡើងវិញ ក្រែងគេមានភាពធុញទ្រាន់នឹងសាច់រឿង។

បន្ទាប់ទៀត ចូរចាប់ផ្ដើមបន្ថែម **តំណ (links) ឬស្ពានចម្លង (អន្តរកម្ម/transitions)** ដែលនាំអ្នកអានពីចំណុចមួយទៅកាន់ចំណុចមួយទៀត។

ឧទាហរណ៍ បើអ្នកកំពុងដកស្រង់សម្ដីអ្នកឯកទេសម្នាក់និយាយអំពីអ្វីមួយ អ្នកក៏គួរតែដកស្រង់សម្ដីអ្នកឯកទេសដែលមានការយល់ឃើញផ្ទុយផងដែរ។ ចូរប្រាប់អ្នកអានតាមរយៈការសរសេរ ឧទាហរណ៍ដូចជាប្រើពាក្យថា ៖ ("ផ្ទុយទៅវិញ មនុស្សមួយចំនួនបានយល់ឃើញផ្ទុយទៅនឹងទស្សនៈបែបនោះដែរ"។)

ឥឡូវនេះ ចូរត្រឡប់មកមើលអត្ថបទម្ដងទៀតក្នុងក្រសែភ្នែករិះគន់មួយ ហើយកន្លែងណាដែលកថាខណ្ឌមានភាពណែនក្ដន់ពេក សូមសាកបំបែកវាដើម្បីកុំឲ្យវាស្ទះលំហូរសាច់រឿង។ ម៉្យាងវិញទៀត សូមព្យាយាមធ្វើឲ្យ**សូរស័ព្ទ**របស់រឿងមានចម្រុះភាព ដោយយកសម្រង់សម្ដីដើម និងសម្លេងរបស់មនុស្សមកសៀតបញ្ចូលនៅកន្លែងណា ដែលអ្នកមើលទៅហាក់ដូចជាខ្វះទឹកដម។

មកដល់ចំណុចនេះ ទើបអ្នកចាប់ផ្តើមសរសេរសេចក្តីបញ្ចប់ (outro)។ បើចាំបាច់ ចូរយកពេលឲ្យបានគ្រប់គ្រាន់ដូចគ្នានឹងកាលដែលអ្នកប្រើក្នុងការសរសេរសេចក្តីផ្តើមដែរ។ វាសំខាន់ណាស់។ ចូរងាកទៅមើលរឿងពីខាងដើមម្តងទៀត ឬព័ត៌មានទាំងឡាយដែលអ្នកប្រមូលបាន ហើយយកអ្វីមួយដែលល្អ ដូចជាសម្រង់សម្តីជាដើមយកមករៀបរៀងសេចក្តីបញ្ចប់។ តែធ្វើយ៉ាងណាឲ្យវាហូរសមទំនងផងពីកថាខណ្ឌមួយទៅកថាខណ្ឌមួយ។

## ចូរប្រមើលគិតជារបៀបរូបភាព

អ្នកក៏គួរជួយសម្រេចផងដែរក្នុងការជ្រើសរើសរូបថត និងកញ្ចប់អត្ថបទតូចៗអមទៅនឹងអត្ថបទធំដែលរួមគ្នាបង្កើតបានទិដ្ឋភាពពេញលេញមួយអំពីរឿងទាំងមូល។ ក្រៅពីអត្ថបទ និងរូបថត គួរព្យាយាមថតវីដេអូ សម្រាប់យកមកដាក់លើវិបសាយថែមទៀតផងដែរ។

## តែងសាច់រឿងឲ្យណែន

គ្មានអ្វីដែលអន់ជាងអត្ថបទពិពណ៌នាមួយដែលវែងអន្លាយ ហើយរយីករយាកនោះទេ។ រឿងណាដែលមានសម្រង់សម្តីដើមវែងអន្លាយ ឬឧទាហរណ៍ច្រើនពេក ក៏អាចធ្វើឲ្យអ្នកអានបាត់បង់ការអត់ធ្មត់លែងចង់អានតទៅទៀតដែរ។ ដូច្នេះ ចូរប្រើតែអង្គផ្សំណា ដូចជាសេចក្តីពិស្តារ សម្រង់សម្តីដើម និងទិន្នន័យដែលសំខាន់ចាំបាច់បំផុត។ ចូរកុំសន្ទប់អ្វីៗគ្រប់បែបយ៉ាងទៅលើអ្នកអានរបស់អ្នក។ ក្នុងការសរសេរ ចូរឆ្លៀតស៊កពណ៌ បរិបទ និងសារតារខ្លះៗ ដើម្បីពន្យល់សចក្តីក្នុងរឿងដល់អ្នកអាន។

បើអ្នកសរសេរជាភាសាអង់គ្លេស ចូរប្រើវាក្យសព្ទ និងឃ្លាខ្លីៗ ដែលងាយក្នុងការអាន និងយល់។ ពេលណាសរសេរចប់ហើយ សូមវិលមកពិនិត្យវាឡើងវិញ ហើយសាកកាត់ ១០ ភាគរយ ចេញពីអត្ថបទទាំងមូល មុននឹងប្រគល់វាទៅឲ្យនិពន្ធនាយកកែសម្រួល។

## ករណីសិក្សា ៖ ជនជរានៅកម្ពុជា

ឥឡូវចូរនាំគ្នាងាកមកមើលអត្ថបទពិពណ៌នាមួយ ហើយសិក្សាថា តើគេផ្គុំវាចូលគ្នាដោយរបៀបណា។ នេះជាអត្ថបទកាសែត Phnom Penh Post។ ក្នុងនោះ មានអ្វីដែលគេហៅថា "អនុចំណងជើង" (subheads) ដែលញែកសាច់រឿងជាផ្នែកៗ ជាប្រយោជន៍ធ្វើឲ្យវាងាយអាន។

*សេចក្តីផ្តើមជាការដំណាលរឿងខ្លីមួយអំពីស្ត្រីចំណាស់ម្នាក់ អមដោយការពិពណ៌នា និងសម្រង់សម្តីដើមល្អៗផង នៅប៉ែកខាងលើ។*

***ជនរងគ្រោះដោយសារពេលវេលា :*** *ធ្លោះទៅរកជរាភាពក្នុងរាជាណាចក្រដែលសម្បូរដោយមនុស្សវ័យក្មេង។*

***និពន្ធដោយកញ្ញា មុំ គន្ធា និង Eleanor Ainge Roy***

*លោកយាយ ឡុង ហាង បានរស់នៅក្នុងខ្ទមតូចមួយអស់ជាច្រើនឆ្នាំមកហើយ។ ខ្ទមនោះប្រក់ដោយផ្ទាំងកៅស៊ូ និងធាងដូង ដែលលិចទឹកកាលណាមានភ្លៀង។ លោកយាយអាយុ ៧០ ឆ្នាំម្នាក់នេះ ត្រូវបានគ្រួសារបណ្តេញចេញពីផ្ទះ ដោយគាត់ជរាទន់ខ្សោយមិនអាចធ្វើការបាន។ ឥឡូវនេះ គាត់ចំណាយពេលវេលារបស់គាត់គេងនៅនឹងដីដែលជាកម្រាលផ្ទះរបស់គាត់ ដោយមានរោគាពាធមិនអាចកម្រើកខ្លួនបាន ហើយភ្នែកទាំងសងខាងងងឹតថែមទៀតផង។*

*លោកយាយមានប្រសាសន៍ថា៖ "ខ្ញុំធ្លាប់រស់នៅជាមួយក្មួយស្រី ប៉ុន្តែនាងបានដេញខ្ញុំចេញពីផ្ទះ ពេលដែលភ្នែកខ្ញុំមើលលែងឃើញ។ ខ្ញុំក៏ក្លាយខ្លួនជាអ្នកសុំទានតាមដងផ្លូវ ហើយអ្នកដំណើរខ្លះពេលណាគេឃើញការលំបាករបស់ខ្ញុំ គេក៏ឈប់ ហើយងាកមកឲ្យលុយខ្ញុំ។ ប៉ុន្តែមនុស្សភាគច្រើនគេមិនអើពើទេ។ ខ្ញុំគ្មានសល់ញាតិសន្តានអីទេ ហើយខ្ញុំសង្ឃឹមតែទៅលើមនុស្សចម្លែកឲ្យបំណីអាហារ និងជួយខ្ញុំតែប៉ុណ្ណោះ"។*

*ត្រង់នេះជាកថាខណ្ឌស្នូលដែលប្រើភាពផ្ទុយគ្នាខ្លាំងពីរ (ភាពរស់រានផុតពីរបបខ្មែរក្រហម តែឥឡូវជាជនរងគ្រោះ)។ ជាមួយគ្នានេះដែរ កថាខណ្ឌស្នូលនេះកំណត់បានយ៉ាងច្បាស់នូវមូលបទនៃសាច់រឿង (ក្នុងកថាខណ្ឌទីបី)។*

*លោកយាយ ឡុង ហាង បានរស់រានផុតពីរបបខ្មែរក្រហម តែជាជនរងគ្រោះនៃជរាភាព ដោយកំពុងត្រដររស់ក្នុងសង្គមមួយដែលខ្វះប្រព័ន្ធសុខុមាលភាព ហើយដែលក្នុងនោះ ប្រពៃណី ការគាំទ្រគ្រួសារ កំពុងត្រូវបានគេបោះបង់បន្តិចម្តងៗ។*

*លោក អ៊ូ វិរៈ ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានិយាយថា៖ "ជនមនុស្សចាស់នៅប្រទេសកម្ពុជាបច្ចុប្បន្ន កំពុងតែមានការលំបាកច្រើន។ ពួកគេលែងជាបុព្វហេតុគួរឲ្យរំភើបចិត្តទៀតហើយ ៗមនុស្សម្នាទាំងឡាយគេចូលចិត្តជួយដល់បុព្វហេតុណា ដែលធ្វើឲ្យគេរំភើបចិត្តតែប៉ុណ្ណោះ"។*

*អត្ថាធិប្បាយរបស់អ្នកឯកទេសត្រូវបានគេដាក់ក្នុងផ្នែកខាងលើនៃរឿង (កថាខណ្ឌទីបួន)។*

***"ក្រុមជនងាយរងគ្រោះ"***

*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦-១០ បានធ្វើអត្តសញ្ញាណជនជរាក្នុងប្រទេសកម្ពុជា (ចាប់ពីអាយុ ៦០ ឆ្នាំឡើងទៅ) ដែលមាន ៦ ភាគរយ នៃចំនួនប្រជាជនសរុបថាជា "ក្រុមជនងាយរងគ្រោះ ដែលត្រូវការយកចិត្តទុកដាក់ជាអាទិភាព"។*

*បន្ទាប់ពីនោះ មានស្ថិតិដើម្បីផ្តល់ជាបរិបទ។ ជាតុផ្សំទាំងអស់នេះបន្ថែមទម្ងន់អាផ្សា ដែលធ្វើរឿងឲ្យកាន់តែជឿជាក់បានថែមទៀត។*

*ប៉ុន្តែ លោក អ៊ូ វិរៈ និយាយថា ការយកចិត្តទុកដាក់ទៅលើក្រុមនេះត្រូវបានគេកំពុងមើលរំលង បើប្រៀបធៀបទៅនឹងវិស័យដទៃទៀតដូចជា វិស័យការពារជាតិ ដែលថវិការបស់វាត្រូវបានបង្កើនទ្វេដងកាលពីពេលថ្មីៗនេះ។ លោក អ៊ូ វិរៈ និយាយថា៖ "អ្នកផ្តល់ការថែទាំបឋមបំផុតដល់ជនជរានៅកម្ពុជា គឺក្រុមគ្រួសារ ហើយនេះជាប្រពៃណីយូរអង្វែងមកហើយនៅប្រទេសកម្ពុជា"។*

*ត្រង់នេះ សាវតារល្អឥតខ្ចោះមួយជួយពន្យល់អំពីស្ថានភាពប្រជាសាស្ត្រក្នុងប្រទេស ដែលការពន្យល់នោះ គឺថាប្រទេសនេះមិនសូវសំបូរមនុស្សវ័យកណ្តាលជួយមើលថែទាំជនវ័យចំណាស់ទេ។ ត្រង់នេះ អ្នកនិពន្ធ ក៏សម្តែងភាពទៀតត្រង់ជាមួយអ្នកអានដែរ ដោយប្រាប់ថា មិនមានព័ត៌មានផ្លូវការគ្រប់គ្រាន់ទេសម្រាប់យកមកប្រើ។*

***គម្លាតរវាងជំនាន់***

*លោក អ៊ូ វិរៈ និយាយថា៖ "ក្នុងសម័យខ្មែរក្រហម និងក្នុងបណ្តាឆ្នាំមុន និងក្រោយជំនាន់នោះ មិនសូវមានក្មេងកើតច្រើនទេ។ ក្នុងចំណោមក្មេងដែលបានកើត ភាគច្រើនក៏មិនបានឆ្លងផុតទារកភាពរបស់ខ្លួនដែរ។ ពេលនេះគេឃើញមានគម្លាតរវាងជំនាន់ហើយ ហេតុដូច្នេះហើយបានជាយើងមានមនុស្សចាស់ក៏ច្រើន មនុស្សវ័យក្មេងក៏ច្រើន។ ប៉ុន្តែយើងកំពុងខ្វះអ្នករកចំណូលក្នុងសង្គម បានន័យថាមនុស្សក្នុងវ័យការងារពីអាយុ ៣៥ ទៅ ៤៥ ឆ្នាំ។ ចំណុចនេះ វានឹងក្លាយទៅជាបញ្ហាធំមួយនាពេលអនាគត ហើយដែលជាបញ្ហាមួយដែលគេត្រូវតែលៃលកចាត់ការចាប់ពីពេលនេះតទៅ"។*

*លោក វ៉ែន សារិទ្ធ ប្រធានអង្គការ Aged Care International ប្រចាំនៅខេត្តបាត់ដំបង ឯកភាពជាមួយការវាយតម្លៃស្តីអំពីគម្លាតរវាងជំនាន់ ប៉ុន្តែគាត់និយាយថា ទិន្នន័យត្រង់ចំណុចនេះនៅមានភាពខ្សត់ខ្សោយនៅឡើយ។*

*ត្រង់នេះនិយាយពីមូលហេតុមួយទៀតនៅពីក្រោយការធ្លាក់ចុះតម្លៃគុណធម៌ប្រពៃណីក្នុងគ្រួសារ។*

*ក្រសួងសង្គមកិច្ច និងក្រសួងសុខាភិបាល មិនអាចផ្តល់តាមសំណើកាសែតភ្នំពេញប៉ុស្តបេ នូវស្ថិតិផ្លូវការស្តីពីអត្រាកំណើតមុន និងក្រោយរបបខ្មែរក្រហមបានទេ។*

អ្នកនិពន្ធបានពន្យល់ និងព្យាយាមអះអាងបញ្ជាក់ដល់យើងថាវាពិតជាមានបញ្ហា។

លោក អ៊ូ វិរៈ និយាយថា ទំនោរវប្បធម៌យុវវ័យ ដែលក្នុងនោះជនកម្ពុជាវ័យក្មេងងាកទៅរកមគ្គុទ្ទេសក៍វប្បធម៌ពីសំណាក់បស្ចិមលោក ក៏មានចំណែកក្នុងការនាំឲ្យមានការធ្លាក់ចុះនូវទម្លាប់ជាប្រពៃណីក្នុងការថែទាំជនជរាដែរ។ ជាមួយគ្នានេះ ជនវ័យក្មេងបានប្រកាន់យកទម្លាប់សម្ភារៈនិយម ហើយវាយតម្លៃជោគជ័យក្នុងជីវិតរបស់គេក្នុងនាមបុគ្គលនីមួយៗ ជាជាងក្នុងនាមគ្រួសារទៅវិញ។

លោក អ៊ូ វិរៈ និយាយថា៖ "វិស័យអប់រំកំពុងតែកើនឡើង ហើយមនុស្សម្នានៅជនបទកំពុងនាំគ្នាចូលមកនៅតាមទីក្រុង ដើម្បីចូលរៀនសាកលវិទ្យាល័យ និងរកការងារធ្វើ។ បច្ចុប្បន្ននេះ យុវជនមិនសូវបេះតែពឹងពាក់លើគ្រួសារ ដើម្បីការឧបត្ថម្ភនានាដូចមុនទៀតទេ ហើយនេះក៏មានន័យដែរថា ពួកគេក៏នឹងមិនរំពឹងថានឹងនៅថែទាំយកចិត្តទុកដាក់មាតាបិតារបស់គេដែរ"។

គាត់បន្ថែមទៀតថា៖ "គម្លាតក្នុងទំនាក់ទំនងកាន់រីកធំឡើងរវាងជនជំនាន់មុន និងជនជំនាន់ក្រោយ ហើយនៅកណ្តាល គឺមានរណ្តៅខ្មៅងងឹតមួយយ៉ាងធំ"។

## យ៉ាប់យ៉ឺនជាងគេក្នុងតំបន់

ក្នុងផ្នែកនេះ គេបន្ថែមបរិបទដោយពង្រីកសាច់រឿងឲ្យយើងដឹងអំពីស្ថានភាពប្រៀបធៀបទៅនឹងប្រទេសឯទៀត។

ការអង្កេតមនុស្សចាស់កម្ពុជាកាលពីឆ្នាំ ២០០៤ បានរកឃើញថា ជនមនុស្សចាស់នៅកម្ពុជាស្ថិតក្នុងស្ថានភាពយ៉ាប់យ៉ឺនជាងគេ បើប្រៀបធៀបជាមួយមនុស្សចាស់ក្នុងប្រទេសជិតខាងខ្លួន ក្នុងនោះមានប្រទេសមីយ៉ាន់ម៉ា ថៃ ហ្វីលីពីន និងឥណ្ឌូនេស៊ី។

កថាខណ្ឌមួយនេះបង្ហាញយើងអំពីផលប៉ះពាល់នៃបញ្ហានោះ គឺសុខភាពមិនមាំមួន មានន័យថា ជនមនុស្សចាស់សឹងតែមិនអាចថែទាំខ្លួនឯងបានផង។

ការអង្កេតនេះរកឃើញថា មនុស្សចាស់នៅទីជនបទជួបប្រទះការលំបាកជាងជនជរានៅទីប្រជុំជន ដោយពួកគេត្រូវបានភាពក្រីក្របាប់បង្ខំឲ្យធ្វើការរហូតដល់អាយុចាស់។ នៅទីប្រជុំជន ៣០.៩ ភាគរយនៃមនុស្សចាស់អាយុ ៦០ ឆ្នាំ ឬលើសនេះ នៅប្រឡូកក្នុងកម្លាំងពលកម្ម រីឯនៅជនបទវិញ វ័យដូចគ្នានេះមានរហូតដល់ទៅជាង ៦៥ ភាគរយ ដែលនៅបន្តធ្វើការ ជាពិសេសជាពលករកសិកម្ម។

ជាលទ្ធផលនៃការងារបែបនេះ ជនមនុស្សចាស់កម្ពុជាមានសុខភាពយ៉ាប់យ៉ឺនជាងក្នុងតំបន់នេះ និងការលំបាកច្រើនសណ្ឋាន ដូចជាក្នុងការអង្គុយងូតទឹកសំអាតខ្លួន និងក្នុងការហូបចុក។

ត្រង់នេះជាអន្តរកម្មល្អមួយទៅរកគំនិតផ្ទុយពីសំណាក់ប្រភពជាអ្នកឯកទេសម្នាក់វិញ ។

ត្រង់នេះផ្តោតលើដំណោះស្រាយមួយចំពោះបញ្ហា គឺបង្ហាញអំពីអ្វីដែលបុរសម្នាក់កំពុងធ្វើ ដើម្បីជួយដល់ជនមនុស្សចាស់ ។ ក្នុងនេះក៏មានផងដែរនូវការចងចាំអាក្រក់មួយពីកុមារភាពដែលដាស់បំណាប់អារម្មណ៍របស់មិត្តអ្នកអាន ។

## *អស្ថិរភាពផ្នែកស្មារតី*

*ការអង្កេតនោះក៏បានរកឃើញដែរថា មនុស្សចាស់ជាច្រើនបានទទួលរងការឈឺចាប់ស្ងាត់ស្ងៀមពីជំងឺស្មារតី ដែលមិនមានការវិនិច្ឆ័យច្បាស់លាស់ ដូចជាភាពតានតឹងអារម្មណ៍ភ័យព្រួយពុំរើបន្ទាប់ពីប្រទះហេតុការណ៍អាក្រក់ៗ ដែលជាកេរ្តិ៍ដំណែលរបបខ្មែរក្រហមបន្សល់ទុកឲ្យ ។*

*លោក វ៉ែន សារិទ្ធ ប្រធានអង្គការ Aged Care International មើលឃើញដូច្នេះវិញថា អត្រាខ្ពស់នៃមនុស្សចាស់កំពុងធ្វើការជាមោទនភាពមួយរបស់កម្ពុជា ហើយគាត់គិតថាបទពិសោធន៍ និងជំនាញរបស់គេគួរតែត្រូវបានដកស្រង់រៀនសូត្រតាម ដើម្បីជាវិភាគទានថែមទៀតដល់ការអភិវឌ្ឍប្រទេសកម្ពុជា ។*

*គាត់និយាយថា រដ្ឋាភិបាលគួរលើកទឹកចិត្តអង្គការមិនមែនរដ្ឋាភិបាលឲ្យមានការពាក់ព័ន្ធកាន់តែច្រើនឡើងជាមួយមនុស្សចាស់ ព្រោះថា ពួកគេមានសក្តានុពលជាសមាជិកប្រកបដោយផលិតភាពមានប្រយោជន៍ដល់សង្គម ។*



តើអ្វីដែលធ្វើឲ្យនរណាម្នាក់លេចធ្លោក្នុងចំណោមអ្នកឯទៀត ?

*លោក កែវ ចន្ថា ប្រធានកម្មវិធីទ្រទ្រង់មនុស្សចាស់កម្ពុជា (Cambodian Elder Support Program) ជាអ្នកចាត់ចែងគ្រប់គ្រងមជ្ឈមណ្ឌលសម្រាប់មនុស្សចាស់មួយនៅក្នុងខណ្ឌសែនសុខ នៅជាយក្រុងភ្នំពេញ ។ គាត់បានបង្កើតមជ្ឈមណ្ឌលនេះឡើងដោយហេតុថា គាត់បារម្ភថាកូនចៅរបស់គាត់នឹងមិនយកចិត្តទុកដាក់ចំពោះគាត់នៅពេលណាដែលគាត់មានវ័យកាន់តែចាស់ ។*

*លោក កែវ ចន្ថា និយាយថា "កាលដែលខ្ញុំនៅតូច ខ្ញុំមានគ្រួសារមួយរស់ជិតខាងខ្ញុំ ហើយពួកគេប្រព្រឹត្តយ៉ាងអាក្រក់ណាស់ទៅលើយាយរបស់ពួកគេ ។*

*ពួកគេបានវាយជំយាយនោះ បង្អត់អាហារគាត់ ហើយចាក់សោគាត់ជាប់នៅក្នុងបន្ទប់តូចមួយ។ យាយនោះក៏ស្លាប់បាត់ទៅ ហើយតាំងពីពេលនោះមក ខ្ញុំចេះតែបារម្ភថា ពេលដែលខ្ញុំចាស់ទៅ ប្រហែលជាមានរឿងដូចគ្នាតនេះកើតដល់រូបខ្ញុំដែរទេដឹង។ វាមិនទាន់មានរឿងបែបនោះកើតឡើងទេ ប៉ុន្តែនៅតែមានក្តីបារម្ភរហូត។ ខ្ញុំខ្លាចថា ប្រសិនបើគ្មានអ្នកណាមើលថែទាំខ្ញុំទេ ឬមួយក៏កូនរបស់ខ្ញុំបោះបង់ខ្ញុំចោល ខ្ញុំនឹងក្លាយខ្លួនជាអ្នកសុំទានតាមដងផ្លូវ ជាមិនខាន"។*

*លោក កែវ ចន្ថា ដែលជាអតីតសាស្ត្រាចារ្យភាសាបារាំងនៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ បានបង្កើតមជ្ឈមណ្ឌលនេះឡើងនៅឆ្នាំ ១៩៩៧ ជាមួយនឹងមូលនិធិឯកជនផ្ទាល់ខ្លួន។ ប៉ុន្មានឆ្នាំក្រោយមកទៀត គាត់ទទួលបានជំនួយម្តងម្កាលពីអ្នកជំនួយនៅប្រទេសកាណាដា និងអាហ្វ្រិកខាងត្បូង ប៉ុន្តែជារួម គាត់ប្រើប្រាស់ប្រាក់សន្សំផ្ទាល់ខ្លួន រួមជាមួយនឹងវិភាគទានបន្តិចបន្តួចពីកូនៗ ដើម្បីផ្គត់ផ្គង់មជ្ឈមណ្ឌលរបស់គាត់។*

*គាត់ធ្លាប់បានសរសេរលិខិតជាច្រើនលើកផ្ញើជូននាយករដ្ឋមន្ត្រី ហ៊ុន សែន និងព្រះមហាក្សត្រ នរោត្តម សីហមុនី ស្នើសុំជំនួយដល់គំរោងរបស់គាត់ ប៉ុន្តែមកទល់ពេលនេះ គាត់មិនទាន់ទទួលបានចម្លើយទេ។ ភ្នែករបស់គាត់រលីងរលោង ពេលគាត់និយាយមកដល់បំណុចនេះ។*

*លោកនិយាយថា៖"រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលមិនចាប់អារម្មណ៍ក្នុងការជួយមនុស្សចាស់ទេ។ ពួកគេផ្តោតទៅលើមនុស្សដែលមានថាមពល និងកម្លាំងគ្រប់គ្រាន់ធ្វើការតែប៉ុណ្ណោះ"។*

*មជ្ឈមណ្ឌលរបស់គាត់ជួយមនុស្សចាស់ ៤៥ នាក់ ក្នុងឃុំរបស់គាត់ដោយផ្តល់ការផ្តល់អាហារបិញ្ចឹម និងទីកន្លែងស្អាត និងមានសុវត្ថិភាពសម្រាប់រស់នៅ។ សម្រាប់មនុស្សចាស់ជាច្រើននាក់ ដែលគ្មានគ្រួសារ ឬជំនួយរដ្ឋាភិបាលសម្រាប់ពឹងពាក់មជ្ឈមណ្ឌលរបស់គាត់ ពិតជាបានផ្តល់សេវាមួយមានសារៈសំខាន់មែនទែន។*

*លោក កែវ ចន្ថា និយាយថា៖"ខ្ញុំចាត់ទុកមនុស្សចាស់ទាំងអស់ជាឪពុកម្តាយរបស់ខ្ញុំ។ ខ្ញុំមិនមានឱកាសមើលថែទាំឪពុកម្តាយរបស់ខ្ញុំទេ ដោយពួកគេបានស្លាប់ក្នុងជំនាន់ ប៉ុល ពត បាត់ទៅហើយ។ ឥឡូវនេះជាឱកាសសម្រាប់ខ្ញុំធ្វើអ្វីល្អមួយ ដើម្បីតបស្នងសងគុណដល់ពួកគាត់កាលដែលនៅរស់"។*

*ត្រង់នេះជាអន្តរកម្មមួយទៀត ឆ្ពោះទៅរកចម្លើយរបស់រដ្ឋាភិបាល និងការដែលថា តើអាចមានអ្វីកើតឡើងនៅពេលអនាគត។*

***ផែនការអនាគត***

*ក្នុងពេលដែលមានមនុស្សចាស់ជាច្រើននិយាយថា រដ្ឋាភិបាលបានព្រងើយកន្តើយចំពោះពួកគេនោះ លោកវេជ្ជបណ្ឌិត ផៃ សំបូរ អនុប្រធាននាយកដ្ឋាននិវត្តន៍ជននៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និយាយថា រដ្ឋាភិបាលកំពុងរៀបចំផែនការផ្តល់ការថែទាំដល់ជនមនុស្សចាស់កម្ពុជា។*

*គាត់និយាយថា កិច្ចប្រជុំមួយនឹងត្រូវបានធ្វើឡើងនៅថ្ងៃច័ន្ទនេះ រវាងក្រសួងពាក់ព័ន្ធ និងអ្នកឯកទេសការងារថែទាំជនជរានៅក្នុងប្រទេស។*

*គាត់និយាយប្រាប់កាសែតភ្នំពេញប៉ុស្តិ៍ថា៖ "បច្ចុប្បន្ននេះ ខ្ញុំកំពុងព្យាយាមរកមូលនិធិសម្រាប់កសាងមជ្ឈមណ្ឌលធំមួយ ដែលជនជរាអាចស្នាក់នៅ ហើយខ្ញុំប្រឹងធ្វើកិច្ចការលើរឿងនេះមែនទែន ដើម្បីឲ្យផែនការនេះសម្រេច"។*

*"ប៉ុន្តែ រដ្ឋាភិបាលអត់មានលុយគ្រប់គ្រាន់ ដើម្បីជួយដល់គ្រប់គ្នាដូច្នេះ ខ្ញុំព្យាយាមអនុវត្តន៍គំរោងជំនួយម្តងមួយជំហានៗប៉ុណ្ណោះ។ ប្រទេសយើងមានបញ្ហាធំផេងច្រើនជាងប្រទេសជិតខាង ព្រោះតែគេរបន្សល់ទុកដោយរបបខ្មែរក្រហម និងស្ថានភាពរបស់យើងជាប្រទេសកំពុងអភិវឌ្ឍន៍។ តែយើងមិនបានបំភ្លេចបោលជនជរានោះទ"។*

*រឿងនេះបញ្ចប់ដោយជនជរាម្នាក់ដែលត្រូវបានភ្ជាប់ទៅនឹងផ្នែកខាងលើនៃសាច់រឿងតាមរយៈអត្ថាធិប្បាយរបស់គាត់អំពីរដ្ឋាភិបាលក្នុងរឿងថែទាំជនជរា។*

*លោកតា លិច ស្រេង អាយុ ៧០ ឆ្នាំ កំពុងរស់នៅមជ្ឈមណ្ឌលថែទាំមួយនៅឃុំអំពិល ខេត្តព្រៃវែង។ គាត់និយាយថាគាត់នឹងរង់ចាំមើលការសន្យាដែលលោក ផៃ សំបូរ បានធ្វើថាតើវានឹងក្លាយជាការពិតឬយ៉ាងណា។*

*"ខ្ញុំចង់ឲ្យរដ្ឋាភិបាលធ្វើការថែទាំជនជរា។ ដល់អញ្ចឹងទៅ យើងនឹងមានអារម្មណ៍កក់ក្តៅចំពោះមេដឹកនាំរបស់យើង។ ឥឡូវនេះ ខ្ញុំខ្មាសបរទេសណាស់ ព្រោះខ្ញុំដឹងថា មនុស្សចាស់ក្នុងប្រទេសរបស់គេត្រូវបានរដ្ឋាភិបាលមើលការថែទាំ ដែលវាផ្ទុយនឹងស្ថានភាពនៅប្រទេសកម្ពុជា"។*

រឿងនេះត្រូវបានអមដោយអត្ថបទបន្ថែម (sidebar) ដូចខាងក្រោម៖

*ជនជាតិស្វែងរកជម្រក និងកាន់ធម៌នៅវត្តអារាម*

*ជនជាតិកម្ពុជារាប់ពាន់អ្នកបានចំណាយពេលរបស់ពួកគេមករស់នៅក្នុងទីវត្តអារាម កាលពីឆ្នាំមុននេះ។ សម្រាប់អ្នកខ្លះ វត្តអារាមជាជម្រកថ្មី។ អ្នកឯទៀត បានយកពេលវេលានេះដើម្បីរៀនធម៌ព្រះពុទ្ធ ដោយសង្ឃឹមថានឹងបានចាប់កំណើតឡើងវិញល្អជាងមុន។ លោកយាយ អ៊ុក សេត អាយុ ៧៨ ឆ្នាំ បាននិងកំពុងរស់នៅវត្តស្វាយពពែតាំងពីឆ្នាំ ១៩៧៩ មកម្ល៉េះ។ ប្ដីរបស់គាត់ និងកូនប្រុសពីរនាក់ ត្រូវបានគេសម្លាប់ក្នុងរបបខ្មែរក្រហម ហើយបន្ទាប់ពីរបបនេះត្រូវបានផ្ដួលរលំ លោកយាយមិនដឹងទៅរស់ឯណា ហើយក៏គ្មានអ្នកណាមើលរក្សាថែទាំគាត់ដែរ។ លោកយាយនិយាយដូច្នេះថា៖ "បើទោះជាកូនខ្ញុំនៅរស់ក៏ដោយ ក៏ខ្ញុំនឹងនៅតែមករស់នៅវត្តដែរ ព្រោះថាវាជាកន្លែងមួយល្អសម្រាប់រៀនធម៌។ ខ្ញុំនឹងរស់នៅទីនេះរហូតដល់ស្លាប់ ហើយខ្ញុំសប្បាយចិត្តណាស់។ ទីនេះជាផ្ទះរបស់ខ្ញុំ។ ទោះជាខ្ញុំគ្មានគ្រួសារក៏ដោយ ខ្ញុំនៅមានមិត្តចាស់ៗរបស់ខ្ញុំ ហើយយើងមើលថែទាំគ្នាទៅវិញទៅមក"។ រីឯលោកតា ពេជ្រ ពយ អាយុ ៥០ ឆ្នាំ គាត់បានមករស់នៅវត្តឧណ្ណាលោមប្រាំបីឆ្នាំហើយ ដោយដាក់កាយដាក់ចិត្តរបស់គាត់ចំពោះធម៌ព្រះពុទ្ធ។ លោកតានិយាយថា៖ "ខ្ញុំយល់ថា មនុស្សចាស់ៗភាគច្រើនរស់នៅក្នុងស្ថានភាពលំបាក ពីព្រោះពួកគេមិនមានទីកន្លែងស្នាក់នៅ ដូច្នេះ ខ្ញុំដូចជាមានសំណាងជាងអ្នកឯទៀតដែរ។ ពេលណាខ្ញុំស្លាប់ទៅជាតិក្រោយរបស់ខ្ញុំនឹងមានភាពប្រសើរជាងនេះ។ ខ្ញុំជឿថា ខ្ញុំនឹងចាប់កំណើតឡើងវិញក្នុងសភាពមួយល្អជាងនេះ ពីព្រោះឥឡូវនេះ ខ្ញុំប្រឹងប្រែងធ្វើតែកុសលល្អ និងសន្សំធម៌តែប៉ុណ្ណោះ"។*

នៅក្នុងជំពូកមុននេះ យើងនិយាយថា នៅពេលដែលត្រូវរៀបផែនការយកព័ត៌មាន យកល្អ គួរបំបែករឿងចេញជាធាតុផ្សំសំខាន់ៗ។ គេគួរធ្វើដូចគ្នាដែរពេលសរសេររឿង។ សាករៀបចំរឿងជា "ប្រអប់ៗ" មុននឹងអ្នកសរសេរ ឬមួយក៏គូរជាផែនទីបង្ហាញផ្លូវមួយថា តើអ្នកចង់ឲ្យរឿងនោះមានទិសដៅទៅណា។ ប្រសិនបើយើងបំបែកជាធាតុផ្សំរបស់រឿងពិពណ៌នាស្ដីពីជនជាតិកម្ពុជាជាប្រអប់ ឬជាផ្នែក យើងនឹងបានអ្វីមួយ ដែលមានទម្រង់ដូចខាងក្រោមនេះ៖

# គ្រោងរឿង ៖ ជនជរានៅកម្ពុជា ...

*ផ្តល់ឧទាហរណ៍នៃបញ្ហាដោយផ្តោតលើករណីបុគ្គលម្នាក់។*

**សេចក្តីផ្តើម៖** យាយ ឡុង ហាង អាយុ ៧០ ឆ្នាំ ដែលជាអ្នកសុំទាន s 1-2

↓

*ដាក់បញ្ហាបុគ្គលម្នាក់ទៅក្នុងបរិបទធំមួយ។*

**ចំណុចសំខាន់** (ប្រយោគសង្ខេប ឬប្រយោគមិត្តអ្នកអានជាទីរាប់អាន)៖ លោកយាយ ឡុង ហាង បានរស់រានពីរបបខ្មែរក្រហម តែជាជនរងគ្រោះនៃជរាភាព។ កម្ពុជាមិនទាន់មានប្រព័ន្ធសុខុមាលភាព ហើយប្រពៃណីការគាំពារគ្រួសារកំពុងត្រូវបានគេបោះបង់បន្តិចម្តងៗ។

↓

*ត្រង់នេះបង្ហាញថាហេតុអ្វីបានជាបញ្ហានេះកំពុងកើតឡើង។*

**អត្ថាធិប្បាយរបស់អ្នកជំនាញ៖** ត្រង់នេះជាសម្តីរបស់លោក អ៊ូ វិរៈ អ្នកតស៊ូមតិសិទ្ធិមនុស្ស ដែលពិនិត្យមើលនូវគម្លាតរវាងមនុស្សជំនាន់មុន និងជំនាន់ក្រោយ។ (ប្រយោគពីរនៃសម្តីរបស់គាត់ គឺជាការប៉ុនប៉ងបញ្ជាក់ការពន្យល់របស់គាត់) s 4-12

↓

**បរិបទ សារៈសំខាន់៖** មនុស្សនៅកម្ពុជាមានភាពយ៉ាប់យ៉ឺនជាងមនុស្សចាស់នៅប្រទេសជិតខាង ដោយត្រូវធ្វើការយូរ និងមានសុខភាពអន់ជាងគេក្នុងតំបន់។ ពួកគេសឹងតែមិនអាចដើបអង្គុយ និងលាងសំអាតខ្លួនឯងបានផង។

↓

**ទស្សនៈផ្ទុយ៖** លោក វ៉ែន សារិទ្ធ នៃអង្គការ Aged Care International ធ្វើការពន្យល់អំពីជ្រុងវិជ្ជមាននៃការដែលមនុស្សចាស់អាចនៅធ្វើការបាន។ s 17-18

↓

*ការពន្យល់បន្ថែម និងសារតៅថាបញ្ហាមិនមែនថ្មីទេ តែវាកំពុងរីកសាយភាយ។*

**ករណីសិក្សា៖** ត្រង់នេះគេបង្ហាញលោក កែវ ចន្ធា ដែលកំពុងព្យាយាមជួយជនជរានៅមជ្ឈមណ្ឌលមួយនៅជាយក្រុងភ្នំពេញ។ នេះជាឧទាហរណ៍ល្អមួយបង្ហាញថា មាននរណាម្នាក់កំពុងតែលៃលករកដំណោះស្រាយដល់បញ្ហានោះ។ s 19-25

*ត្រង់នេះក្រឡេកមើលលទ្ធភាពដំណោះស្រាយទៅនឹងបញ្ហា ហើយថា តើច្បាប់និយាយថាម៉េចខ្លះ។ នេះជាកន្លែងល្អមួយសម្រាប់ជជែកជាមួយអ្នកឯកទេស។*

**ការឆ្លើយតបរបស់រដ្ឋាភិបាល៖** ត្រង់នេះជួយផ្ដល់តុល្យភាពក្នុងសាច់រឿង ហើយថែមទាំងរ៉ាយរ៉ាប់ក្បោះក្បាយអំពីចំណាត់ការ ឬមួយក៏យ៉ាងហោចណាស់ នូវអ្វីដែលរដ្ឋាភិបាលគ្រោងនឹងធ្វើនាពេលអនាគត។ s 26-29

↓

**ចុងបញ្ចប់៖** ដូចគ្នានឹងការចាប់ផ្ដើមដែរ ផ្នែកនេះផ្ដោតទៅលើមនុស្សម្នាក់ នោះ គឺលោកតា លិច ស្រេង អាយុ ៧0 ឆ្នាំ ដែលហាក់ដូចជាមិនសូវជឿសោះនូវអ្វីដែលរដ្ឋាភិបាលបាននិយាយ។ s 30-31

បើសិនជាមានចំណុចខ្សោយណាមួយនៅក្នុងអត្ថបទនោះ ក៏ដោយសារតែថា រឿងនោះខ្វះឧទាហរណ៍ និយាយឲ្យចំ គឺឧទាហរណ៍ផ្ដោតលើមនុស្សមករំលេចកណ្ដាលសាច់រឿង។ អ្នកសរសេរបទពិពណ៌នាច្រើនតែដាក់ឧទាហរណ៍មកបង្ហាញនៅខាងដើម និងខាងចុងរឿង តែច្រើនតែរំលងវានៅពាក់កណ្ដាលសាច់រឿងទៅវិញ។ ម៉្យាងវិញទៀត ការប្រើអត្ថាធិប្បាយអ្នកជំនាញច្រើនពេក ក៏អាចនាំឲ្យអាក់អួលដល់ដំណើររៀបរាប់សាច់រឿងផងដែរ។

ក្នុងករណីនេះ អ្នកសរសេរអាចគួរបញ្ចូលបន្ថែមនូវជនសាមញ្ញក្នុងសាច់រឿងបន្តទៅទៀត ដើម្បីរក្សាចំណាប់អារម្មណ៍របស់អ្នកអាន។ តែធ្វើដូច្នោះ រឿងអាចនឹងមានប្រវែងកាន់តែវែង។ ដូច្នេះអ្នកសរសេរ ក៏បំបែកសាច់រឿងស្ដីអំពីជនជាពីរនាក់ទៅដាក់ក្នុងអត្ថបទអមទៅវិញ។ គេអាចធ្វើម៉្យាងទៀតបាន ដោយបំបែកសាច់រឿងទាក់ទិននឹងលោក កែវ ចន្ថា និងមជ្ឈមណ្ឌលរបស់គាត់ ទៅជារឿងមួយដោយឡែកក៏បានដែរ។ និយាយឲ្យខ្លីមក គេអាចប្រើវិធីច្រើនយ៉ាងក្នុងការសរសេរអត្ថបទពិពណ៌នាមួយ។

អ្នកសរសេរអត្ថបទពិពណ៌នាខ្លះ ផ្ដោតតែលើបុគ្គលម្នាក់ ឬគ្រួសារមួយតាំងពីដើមដល់ចប់។ គេចាប់ផ្ដើមដោយសេចក្ដីផ្ដើមបែបដំណាល ឬរ៉ាយរ៉ាប់។ បន្ទាប់ពីប្រយោគស្នូល និងការធ្វើអត្ថាធិប្បាយខ្លីមួយដោយអ្នកឯកទេស អ្នកសរសេរបានងាកមកផ្ដោតលើបុគ្គលនោះម្ដងទៀត ដោយរៀបរាប់បន្ថែមអំពីរឿងរបស់ជននោះដល់អ្នកអានព្រមពេលជាមួយគ្នានោះដែរ បង្ហាញឲ្យឃើញនូវឥទ្ធិពលនៃបញ្ហា។ ក្រោយប៉ុន្មានប្រយោគមកទៀត អ្នកសរសេរងាកមកបង្ហាញទិដ្ឋភាពធំវិញម្ដង (ដោយបន្ថែមបរិបទ សារតារ ឬការពន្យល់បញ្ហាទូទៅថែមទៀត) មុននឹងវិលមកផ្ដោតការសរសេរលើបុគ្គលនៅខាងដើមរឿងជាថ្មីម្ដងទៀត។

យុទ្ធសាស្ត្របង្ហាញភាពផ្ទុយបែបនេះ គឺពីការបង្ហាញភាពជាក់លាក់ប្រៀបនឹងព័ត៌មានទូទៅ បង្កើតបានជាចលនាយ៉ាងល្អមួយក្នុងអត្ថបទ ប្រៀបបាននឹងអ្នកដឹកនាំរឿងផ្លាស់ប្ដូរឆាកក្នុងសាច់រឿងដូច្នោះដែរ។ បុគ្គល និងរឿងរ៉ាវរបស់ពួកគេជាសរសៃអំបោះត្បាញផ្គុំអត្ថបទពិពណ៌នានោះ។ តែមានពេលខ្លះមានករណីសិក្សាច្រើន ត្រូវបានគេលើកយកមកប្រើដើម្បីរក្សាចំណាប់អារម្មណ៍អ្នកអាន ក៏ដូចជាប្រើសម្រាប់អះអាងបញ្ជាក់គោលគំនិតមួយដែរ។

# ករណីសិក្សា ៖ រក្សាចំណាប់អារម្មណ៍អ្នកអាន

ខាងក្រោមចូរនាំគ្នាក្រឡេកមើលថា តើលោក Seth Mydans អ្នកយកព័ត៌មានល្បីម្នាក់របស់កាសែត New York Times ធ្វើដូចម្តេចក្នុងការចងក្រងសាច់រឿង រក្សាចំណាប់អារម្មណ៍អ្នកអាន អំពីក្រុមមនុស្សដែលរស់នៅជាមួយវីរុស HIV នៅភាគខាងជើងប្រទេសវៀតណាម។ ក្រុមនេះជួយគ្នាទៅវិញទៅមក ស្របពេលជាមួយគ្នាដែលគេប្រឹងជំនះនឹងទស្សនៈអវិជ្ជមានដែលសង្គមមានទៅលើពួកគេ។ ពាក្យថា "shroud" ដែលមាននៅក្នុងកថាខណ្ឌទីពីរ ឬនៃអត្ថបទ មានន័យថា ក្រណាត់សំពត់ដែលគេប្រើសម្រាប់គ្របសព។ ដោយសាររឿងនេះវាវែង យើងសូមដកស្រង់ផ្នែកខ្លះៗតែប៉ុណ្ណោះយកមកបង្ហាញ។ សូមមើលសេចក្តីផ្តើម៖

*សេចក្តីផ្តើមដែលគួរឲ្យភ្ញាក់ផ្អើល ព្រោះថា យើងមិនរំពឹងថាមនុស្សដែលស្លាប់ទៅហើយអាចសើចបានទេ។*

*ហៃហ្វុង, វៀតណាម - អ្នកនៅជិតខាងដឹងថាមានអ្វីកើតឡើងពេលពួកគេឮសូរសំណើចចេញពីផ្ទះរបស់លោកស្រី Pham Thi Hue។ ស្ត្រីៗដែលឈឺជិតស្លាប់ហើយនោះបានមកជួបជុំគ្នាជាថ្មីម្តងទៀត។*

*ដោយអង្គុយប្រជ្រៀតគ្នាលើសាឡុងវែងមួយ និងកៅអីតូចៗមួយចំនួន ពួកគេនាំគ្នាស្រែកហោរ និងទះដៃ ក្នុងពេលដែលពួកគេជជែកគ្នាអំពីការដែលទីក្រុងខ្វះក្រណាត់គ្របសព ឬអំពីបុរសឈឺពោះកំប៉ោងជិតស្លាប់ម្នាក់ កំពុងដេកនៅក្រោមស្ពានមួយ។*

*ត្រង់នេះបង្ហាញថា អ្នកសរសេរចេញពីការិយាល័យទៅស្វែងយល់អំពីរឿងនេះ ហើយប្រឹបមុមមួយមកសរសេរផ្ទុះបញ្ចាំងអំពីប្រធានបទធំមួយ ហើយប្រធានបទនោះស្តីអំពីក្រុមមួយដែលកំពុងជួយដល់អ្នកផ្ទុកវីរុសហ៊ីវ។ អ្នកសរសេរបានទៅចូលរួមក្នុងការជួបជុំមួយរបស់អ្នកទាំងនោះ។*

*ភាគច្រើនជាស្ត្រី ពួកគេជាសមាជិកក្រុមជួយគ្នាមួយ ដែលជួយដល់អ្នកដែលឆ្លងវីរុស HIV ក្នុងសង្គមមួយដែលពួកគេច្រើនទទួលការរើសអើង ដែលថ្នាំសង្កូវមិនសូវសំបូរ ហើយការព្យាបាលថ្លៃ ហើយដែលការវិនិច្ឆ័យរោគឆ្លងសម្រាប់មនុស្សភាគច្រើន ប្រៀបស្មើបាននឹងការកាត់ទោសប្រហារជីវិត។*

*កាលពីថ្ងៃសៅរ៍កន្លងទៅនេះ ស្ត្រី ១៥ នាក់ និងបុរសម្នាក់ - ភាគច្រើននៃពួកគេ មិនដែលប្រាប់ញាតិថាខ្លួនបានឆ្លងមេរោគហ៊ីវនៅឡើយ - បានមកជួបជុំគ្នានៅជិតក្រុងហាណូយ ដើម្បីផ្តល់ការគាំទ្រឲ្យគ្នាទៅវិញទៅមក និងការសើចក្អាកក្អាយឲ្យធូរអារម្មណ៍ពីភាពតានតឹងក្នុងជីវិតក្រីក្រ មានជំងឺ និងការខ្វះខាត។*

*ប្រឈមនឹងការរើសអើង ព្រមគ្នាជាមួយនឹងគ្មានការទទួលបានការថែទាំសុខភាពគ្រប់គ្រាន់ផងនោះ ពួកគេមានតែអ្នកជំងឺ ដូចគ្នាតែប៉ុណ្ណោះសម្រាប់ពឹងពាក់ទៅវិញទៅមក។*

រឿងនេះបន្តដោយពន្យល់ថា ហេតុអ្វីបានជាវីរុសហ៊ីវជាបញ្ហា ហើយនិងអំពីរបៀបដែលវាកំពុងរីករាលដាលពីក្រុមមនុស្ស ដែលមានហានិភ័យខ្ពស់ ដូចជាអ្នកសេពគ្រឿងញៀនដោយប្រើសេរ៉ាំងចាក់ទៅកាន់ក្រុមមហាជនទូទៅ។ ត្រង់នេះឯងដែលគេហៅថា"ទិដ្ឋភាពធំ"។ បន្ទាប់មកទៀត គេងាកទៅនិយាយអំពីស្ត្រីនៅក្នុងក្រុមនោះវិញ ដែលគេប្រសិទ្ធិនាមឲ្យថាក្រុម Haiphong Red Flamboyant ដែលជាឈ្មោះរបស់ផ្កាម្យ៉ាង។

*លើកលែងតែពេលណាពួកគេចំអន់គ្នាលេង អ្វីដែលស្ត្រីទាំងនោះកម្រនិយាយនោះ គឺភាពប្រត្យក្សមួយថា ពេលណានឹងមកដល់ដែលពួកគេនឹងធ្លាក់ខ្លួនឈឺធ្ងន់ បញ្ចុកអាហារ ងូតទឹក និយាយលួងលោម មើលថែទាំកូនគ្នាទៅវិញទៅមក រហូតដល់ពួកគេស្លាប់ម្តងមួយៗ។*

*ត្រង់នេះ អ្នកសរសេរបានធ្វើការឆ្លាស់ការពន្យល់ជាមួយនឹងសម្រង់សម្តី ដើម្បីធ្វើឲ្យយើងអាច"ស្តាប់ឮ" សម្លេងរបស់មនុស្សក្នុងរឿងនេះ។ ធ្វើដូច្នេះជាការបន្ថែមនូវចម្រុះភាពទៅក្នុងរឿង ដែលធ្វើឲ្យអ្នកអានជក់ចិត្តអានបន្ត។*

*នាង Nguyen Thi Sau អាយុ ២៩ ឆ្នាំ ដែលប្តីរបស់នាងបានស្លាប់ដោយជំងឺអេដស៍បាត់ទៅហើយនោះ បាននិយាយថា៖ "អត្ថន័យនៃក្រុមរបស់យើងនៅត្រង់ថា ពេលដែលយើងស្លាប់ទៅយើងនឹងមិនឯកោទេ"។*

*ក្នុងអ្វីមួយដែលពួកគេថាជាការព្យាបាលផ្លូវចិត្ត ស្ត្រីទាំងនោះបានសម្រេចចិត្តប្រឈមមុខនឹងសេចក្តីលំបាកវេទនា ដែលនឹងរង់ចាំពួកគេនៅខាងមុខ។ ក្នុងនោះមាន ការថែទាំ ជូតសំអាត និងបញ្ចុកអាហារអ្នកជំងឺ ការប្រមូលសពអ្នកដែលស្លាប់តែឯងនៅតាមមន្ទីរពេទ្យ ឬតាមដងផ្លូវ និងចូលរួមធ្វើបុណ្យសពអ្នកទាំងឡាយដែលគ្រួសាររបស់គេលែងអើពើជាមួយយូរមកហើយនោះ។*

*នាង Sau ដែលធ្លាប់ធ្វើការនៅរោងចក្រស្បែកជើងមួយមុន នឹងត្រូវបានគេបណ្តេញចេញ និយាយថា៖"មានថ្ងៃខ្លះ ខ្ញុំត្រូវមើលខុសត្រូវសពបួននាក់ដែលបានស្លាប់ក្នុងមន្ទីរពេទ្យ"។ ភាគច្រើន អ្នកជំងឺជាទណ្ឌិតដែលត្រូវបានគេបញ្ជូនឲ្យទៅដេកពេទ្យ ទៅស្លាប់ គឺស្លាប់ដោយគ្មានអ្នកមើលថែទាំសំអាត និងស្លាប់ទាំងជាប់ច្រវាក់ជើងទៅនឹងគ្រែតែម្តង។*

*នាង Sau និយាយថា៖"រូបខ្ញុំនេះឯង ជាអ្នកយកដៃបិទភ្នែករបស់ពួកគេពេលដែលគេស្លាប់"។*

*"ក្រោយពីនោះមក ខ្ញុំដេកមិនលក់ទេ"។*

*សំណើច និងភាពនៅឲ្យបានជាគ្នា ជាមូលបទរបស់រឿងនេះក៏ពិតមែន ប៉ុន្តែអ្នកសរសេរបង្ហាញយើងថា ការថែទាំអ្នកដែលមានវីរុសហ៊ីវជាកិច្ចការមួយធ្ងន់ធ្ងរ។*

*ភាគច្រើននៃស្ត្រីទាំងនោះនិយាយថា ពួកគេបានឆ្លងវីរុសហ៊ីវពីប្តីរបស់គេក្នុងទីក្រុងនេះ ដែលភាពកឹកគ្រឿងញៀនកំពុងរីករាលដាល។ ភាគច្រើននិយាយថា ប្តីរបស់គេបានស្លាប់បាត់ទៅហើយ។ ទាំងអស់គ្នាសុទ្ធបាត់បង់ការងារបន្ទាប់ពីនិយោជកដឹងថា ពួកគេបានឆ្លងមេរោគហ៊ីវ។*

*ប្តីរបស់នាង Pham Thi Hue ឥឡូវកំពុងស្ថិតក្នុងដំណាក់កាលចុងក្រោយនៃជំងឺនេះ នៅឯមជ្ឈមណ្ឌលបន្សាបគ្រឿងញៀនមួយ។ នាងបានបាត់បង់ការងារជាជាងកាត់ដេរ ហើយប្តីបាត់ការងារជាចុងភៅនៅសណ្ឋាគារមួយ បន្ទាប់ពីការឆ្លងមេរោគរបស់ពួកគេ ត្រូវបានគេដឹងឮសុសសាយ។*

*បច្ចុប្បន្ននេះ នាងធ្វើការជាមួយសហជីពស្ត្រីមួយក្នុងការពង្រីកក្រុមជួយគាំទ្រទូទាំងក្រុង ហើយនាងទទួលបានជំនួយបន្តិចបន្តួចពីអង្គការជំនួយបរទេសមួយចំនួនសម្រាប់ធ្វើកិច្ចការនេះ។ ប្រាក់ជំនួយត្រូវបានគេយកទៅប្រើក្នុងកិច្ចឧបត្ថម្ភដល់សមាជិកទាំងឡាយ ដែលស្ថិតក្នុងស្ថានភាពបន្ទាន់ ដើម្បីទិញអង្ករចែកដល់អ្នកទាំងឡាយដែលធ្លាក់ខ្លួនឈឺ ហើយដែលបាត់បង់ប្រភពចំណូលអស់ហើយនោះ។*

រឿងនេះបានលើកឡើងអំពីផែនការរបស់រដ្ឋាភិបាល ក្នុងនោះមានការបង្កើនមូលនិធិ និងសំណើច្បាប់ថ្មីផង។ គេក៏បានបញ្ចូលផងដែរនូវអត្ថាធិប្បាយពីអង្គការ UNAIDS ដែលជាទីភ្នាក់ងារមួយជួយប្រទេសនានាក្នុងការលៃលកជាមួយជំងឺអេដស៍។ ត្រង់នេះជាផ្នែកដែលមានបញ្ចូលការផ្តល់អត្ថាធិប្បាយអ្នកឯកទេសបរិបទ និសាវតារ។ បន្ទាប់ពីនោះ រឿងនេះបានវិលត្រឡប់មកនិយាយអំពីស្ត្រីក្នុងក្រុមនោះជាថ្មីម្តងទៀត។

*ពេលដែលប្តីរបស់នាង Thi Kim Van អាយុ ៣៦ ឆ្នាំ ធ្លាក់ខ្លួនឈឺ ក្រុម Red Flamboyant ទិញគ្រែមួយឲ្យគាត់ ដើម្បីគាត់អាចគេង ដាច់ដោយឡែកពីអ្នកឯទៀតក្នុងគ្រួសារ ដែលរស់នៅជុំគ្នាក្នុងផ្ទះតូច មួយរបស់ឪពុកម្តាយគាត់។*

*ក្រោយពីប្តីស្លាប់ ឪពុកម្តាយបុរសនោះក៏ដេញនាងចេញពីផ្ទះ ហើយនាងក៏យកកូនទាំងបីរបស់នាងទៅរស់នៅផ្ទះម្តាយ ដែលកាន់តែ តូចចង្អៀត ហើយនៅទីនោះ ទាំងប្រាំនាក់នាំគ្នាប្រជ្រៀតគ្នាគេងលើគ្រែ ដែលប្តីរបស់នាងធ្លាប់គេងពីលើ។*

*ទីនេះមានសេចក្តីពិស្តារគួរឲ្យ ជក់ចិត្ត នោះ គឺការនិយាយថា មនុស្សប្រាំនាក់គេងនៅលើគ្រែ តែមួយ និងការលក់តែលើ បិញ្ជើមថ្នល់។*

*នាង Van ដែលផ្ទុកវីរុសហ៊ីវ ព្យាយាមរកស៊ីចិញ្ចឹមទាំងកូន និងម្តាយ ដោយលក់តែលើបិញ្ជើមថ្នល់ ហើយនាងទទួលបានអង្ករ អំណោយពីក្រុមឧបត្ថម្ភ និងប្រាក់កាសមួយចំនួន ដើម្បីបញ្ជូនកូន ប្រុសបងគេឲ្យទៅសាលារៀន។*

*គឺរូបនាងនេះឯងដែលបានលូនក្រោមស្ពានទៅព្យាយាមជួយ បុរសម្នាក់ដែលមានពោះហើមកំប៉ោង។ នាងនិយាយថា បុរសនោះ គឃ្លើន និងគួរឲ្យខ្លាច ហើយនាងក៏លោតរត់ចេញមកវិញមក។*

*ជាមួយនឹងសំណើច មិត្តរបស់នាងបានស្រែកសួរថា៖ "តើឯង មានបានបុចពោះគាត់មើលទេ? ឯងប្រុងយកបំណោញពីលើបុរស នោះហើយមើលទៅ?"*

ត្រង់នេះវាសំខាន់ដែរដោយសារថា វាទ្រទ្រង់បន្ថែមទៅដល់មូលបទថាស្ត្រីទាំងនោះកំពុងជួយគ្នា ទៅវិញទៅមកក្នុងការប្រឈមនឹងជំងឺ តាមរយៈការសើចសប្បាយ។ បន្ទាប់ពីនោះ វាចូលដល់ទីបញ្ចប់ ដោយប្រើធាតុមួយទៀត ដែលបានកើតមានកាលក្នុងពេលជួបជុំគ្នាពីថ្ងៃសៅរ៍ ៖

*ត្រង់នេះជាសេចក្តីដែលមានភាព ដើមរបស់វា នោះគឺការសន្ទនា ដែលបានមកពីការត្រងត្រាប់ស្តាប់ដោយប្រុងប្រយ័ត្ន។ សេចក្តីបញ្ចប់បានវិលត្រឡប់ទៅកាន់មូលបទ ដែលគួរភ្ញាក់ផ្អើលនៃរឿងមួយនេះ។*

*រសៀលបានកន្លងផុតទៅ នាង Sau ដែលបានចំណាយពេលព្រឹកសំអាតនិងបញ្ចុកអាហារអ្នកជំងឺអេដស៍ បានទម្រេតក្បាលកើយលើស្មាមិត្តម្នាក់ឈ្មោះ Doan Thi Khuyen អាយុ ២៣ ឆ្នាំ ហើយពួកគេក៏នាំគ្នាច្រៀងរហឹមៗ។*

*នាង Khuyen ដែលធ្លាប់ធ្វើការជាលេខាម្នាក់ ស្លិតក្នុងសំពត់អៀមវែងពណ៌ស ជាមួយនឹងសក់ស្ទីល និងម្សៅផាត់មុខស្រស់ស្អាត វាហាក់ដូចជានាងកំពុងត្រៀមខ្លួនទៅការិយាល័យអីចឹង។*

*ប៉ុន្តែ នាងត្រូវបានគេបណ្តេញចេញពីការងារកាលពីប៉ុន្មានខែមុន ដោយសារតែជំងឺរបស់នាង ហើយឥឡូវនាងលក់សន្លឹកឆ្នោតឡូតេរីតាមដងផ្លូវដើម្បីចិញ្ចឹមខ្លួន និងកូនពៅគេ ដែលក៏មានរោគសញ្ញាហ៊ីវវិជ្ជមានដែរ។*

*លាយឡំដោយសំណើចរបស់មិត្តនាងជាមួយផងនោះ នាង Khuyen និយាយរង្វ៉ូវៗថា៖ "ខ្ញុំចង់ក្លាយខ្លួនជាក្មេងស្រីខាត់ស្បែកជើង តែអ្វីដែលគេមានដូចសព្វថ្ងៃនេះ គឺក្មេងប្រុសខាត់ស្បែកជើងទៅវិញ។*

*នាង Hue ក៏បន្លឺថា៖ "ណ្ហើយ យ៉ាងហោចណាស់ក៏នាងនៅរស់មានជីវិតដែរ។ នាងឯងមិនទាន់ស្លាប់ឯណា?"*

*មួយឃ្លានេះ គួរឲ្យអស់សំណើចដែរសម្រាប់ស្ត្រីទាំងនោះ ហើយពួកគេក៏សើចទៀតទៅ។*



*តើនេះជារូបសកម្មភាពនយោបាយ ឬជារូបអំពីការបំពុលបរិយាកាស?*

## អនុសាសន៍មួយចំនួន

ឧទាហរណ៍ខាងលើបង្ហាញនូវភាពត្រេកត្រអាលក្នុងការសរសេរ។ របៀបនេះផ្តល់ជូនអ្នកនូវការពេញចិត្តពេញថ្លើមមួយ ហើយក៏ផ្តល់ការយល់ដឹងដល់អ្នកអានដែរ។ ចូរចាំថា វាមិនដែលស្រួលទេ ប៉ុន្តែវាពិតជាមានប្រយោជន៍គ្រប់ពេលវេលា។ ក្នុងអាជីពសារព័ត៌មាន មនុស្សភាគច្រើនដោយធឿយណាយជាមួយនឹងការងារដដែលៗក្នុងការប្រមូលព័ត៌មានផងនោះ ធ្លាប់និយាយថាពួកគេចង់ក្លាយខ្លួនជាអ្នកនិពន្ធសៀវភៅ តែទីបញ្ចប់ ធ្វើជាអ្នកសារព័ត៌មានដដែល។ វាមិនចាំបាច់ទៅជាដូច្នោះទេ។ បើអ្នកទទួលបានសេចក្តីរីករាយក្នុងការសរសេរអត្ថបទពិពណ៌នាផ្តល់ឲ្យអ្នកនូវឱកាសស្វែងយល់អំពីទម្រង់សិល្បៈ ហើយអាចពង្រីកការពេញចិត្តរបស់អ្នកជាមួយនឹងការងារផងដែរ។ ចូរសាកធ្វើខ្លួនឲ្យទៅហួសពីអ្នកយកព័ត៌មាន គឺឲ្យក្លាយទៅជាអ្នកនិពន្ធម្នាក់មើល។

# ជំពូក ៤ ទម្រង់ឈានមុខផ្សេងទៀតនៃវិជ្ជាជីវៈសារព័ត៌មាន

ពិតណាស់ ការអនុវត្តក្នុងអាជីពសារព័ត៌មានតែងមានព្រឹត្តិការណ៍បច្ចុប្បន្នភាពជាកត្តាកំណត់ ប៉ុន្តែ គេមិនត្រូវមានកំហិតក្នុងការយក និងរាយការណ៍ព័ត៌មាននោះទេ។ ផ្នែកមួយដែលសំខាន់ និងកំពុងរីកលូតលាស់ក្នុងផលិតកម្មប្រព័ន្ធផ្សព្វផ្សាយនោះ គឺការធ្វើយ៉ាងណាដើម្បីជួយអ្នកអាន អ្នកស្តាប់ និងទស្សនិកជន ឲ្យយល់អំពីពិភពលោកនៅជុំវិញខ្លួនយើងនេះ។ ទិន្នន័យចៅ (ដូចជា ពិន្ទុប្រកួតកីឡា និងតម្លៃផ្សារភាគហ៊ុនជាដើម) និងព័ត៌មាន (ដូចជាដំណឹងខ្លីៗ) អាចត្រូវបានគេផ្តល់ជូនគ្រប់ពេល គ្រប់ទីកន្លែង។ ដូច្នេះមានន័យថា អ្នកសារព័ត៌មានត្រូវធ្វើឲ្យស៊ីជម្រៅក្នុងការយកព័ត៌មានក្នុងការប្រកួតដណ្តើមអតិថិជន។ ជំពូកនេះពិនិត្យមើលថាតើគេអាចធ្វើបានដូចម្តេចខ្លះ។

## បទវិភាគដំណឹង

កន្លងមក សារព័ត៌មានអាជីពរក្សាភាពតឹងតែងណាស់ក្នុងការញែក "អង្គហេតុ និងអត្ថាធិប្បាយ" ឲ្យដាច់ពីគ្នា គឺតឹងរ៉ឹងរហូតដល់ថា អ្នករាយការណ៍ព័ត៌មានត្រូវបានគេហាមមិនឲ្យបញ្ចូលទៅក្នុងរឿងក្រៅពីអ្វី ដែលជាអង្គហេតុដែលអាចផ្ទៀងផ្ទាត់បាន (verifiable fact)។ បើសិនជាមានការវិនិច្ឆ័យ ឬមតិណាមួយ គេត្រូវតែយោងវាទៅប្រភពមានឈ្មោះ។ ធ្វើដូច្នោះជាប្រការល្អមែន តែវាក៏បណ្តាលឲ្យមានផលអាក្រក់មួយដែរ គឺវាធ្វើឲ្យអ្នកសារព័ត៌មានខ្វះសេចក្តីក្លាហានធ្វើវិភាគ។

ក្រោយមក អ្វីៗត្រូវបានផ្លាស់ប្តូរ។ ពេលដែលបច្ចេកវិទ្យាធ្វើឲ្យព័ត៌មានបែកចាយបានយ៉ាងរហ័ស វិស័យសារព័ត៌មានបានផ្តោតកាន់តែច្រើនឡើងទៅលើការវិភាគដំណឹង ជាជាងគ្រាន់តែផ្តល់ដំណឹង។ ខ្លឹមសារក្នុងអត្ថបទដំណឹងកាន់តែមានលក្ខណៈវិភាគជាងមុន។ គេធ្វើដូច្នេះបានដោយ៖

- ឆ្លើយទៅនឹងសំណួរថា "ចុះវាយ៉ាងម៉េច?" (So What?)
- រៀបរាប់បញ្ចូលសាវតារ និងបរិបទឲ្យកាន់តែក្បោះក្បាយក្នុងសាច់រឿង
- ពង្រីកសាច់រឿងដើម្បីបញ្ចូលព្រឹត្តិការណ៍ដទៃទៀត ដែលជួយឲ្យអ្នកអានកាន់តែយល់បានល្អជាងមុន
- រៀបរាប់ពីព្រឹត្តិការណ៍ និងអ្នកពាក់ព័ន្ធក្នុងសាច់រឿងតាមលំដាប់លំដោយសារៈសំខាន់ តើមួយណាគួរនៅលំដាប់ទីមួយ ឬធំជាងគេ ឬវែងជាងគេ?
- ដកស្រង់សម្តីមនុស្សដែលទទួលរងផលប៉ះពាល់ដោយព្រឹត្តិការណ៍មួយ និងសម្តីអ្នកឯកទេស ដែលដឹងច្រើនអំពីបញ្ហាក្នុងសាច់រឿង។

មានអង្គភាពសារព័ត៌មានខ្លះ ជាពិសេសវិបសាយកាសែតអាមេរិក បច្ចុប្បន្នបានប្រើការវិភាគច្រើនក្នុងរឿងរបស់គេ រហូតដល់ថាបរិមាណដំណឹង និងការវិភាគមានប្រហាក់ប្រហែលគ្នាដែរ។ អត្ថបទរឿងរបស់គេវែងៗគួរសម (ជាង ១.០០០ ហើយពេលខ្លះរហូតដល់ទៅជាង ២.០០០ ពាក្យ អង់គ្លេសឯណោះ) ព្រោះថា ពួកគេផ្តល់ការវិភាគ និងផ្តល់ព័ត៌មានក្នុងពេលជាមួយគ្នាតែម្តង។

អង្គភាពព័ត៌មានខ្លះចូលចិត្តរក្សាអត្ថបទដំណឹងរបស់គេឲ្យនៅខ្លី (យ៉ាងច្រើន ៥០០ ពាក្យអង់គ្លេស) ហើយចុះផ្សាយបទវិភាគមួយដោយឡែកវិញជាជំនួយឲ្យគេកាន់តែយល់អំពីរឿងហេតុ។ ឧទាហរណ៍

បើអត្ថបទដំណឹងមួយនោះ មានភាពរឹងប៉ឹងពេញលេញ ហើយត្រូវបានចុះផ្សាយលើទំព័រមុខ អត្ថបទវិភាគនឹងត្រូវបានគេដាក់ទៅទំព័រខាងក្នុងវិញ។ តែបើអត្ថបទដំណឹងត្រូវបានគេចុះផ្សាយលើទំព័រខាងក្នុងវិញ តាមធម្មតា គេនឹងចុះផ្សាយអត្ថបទវិភាគក្បែរ ឬនៅខាងក្រោមអត្ថបទដំណឹង។ សម្រាប់ប្រព័ន្ធផ្សព្វផ្សាយតាមអ៊ិនធឺណិត អត្ថបទទាំងពីរមាន **ភ្ជាប់តំណ (linked)** ជាមួយគ្នា។

ក្នុងករណីខ្លះទៀត អត្ថបទវិភាគត្រូវបានចុះផ្សាយនៅថ្ងៃបន្ទាប់ ឬឆាប់តាមតែអាចធ្វើបាន។ (សម្រាប់ការផ្សាយប្រចាំសប្តាហ៍វិញ បើព្រឹត្តិការណ៍កន្លងផុតទៅច្រើនថ្ងៃបាត់ទៅហើយនោះ ចាំបាច់គេត្រូវរកមុមថ្មីមកសរសេរអំពីដំណឹងនោះវិញ ហើយគេក៏គួរធ្វើដូច្នោះដែរជាមួយនឹងបទវិភាគ)។

## រិះគិតអំពីបទវិភាគដំណឹង

ជាជាងគ្រាន់តែការធ្វើរបាយការណ៍លើព្រឹត្តិការណ៍ អ្នកយកព័ត៌មានត្រូវមានភាពវាងវៃ បញ្ចេញគំនិតផ្តួចផ្តើម និងស្វែងរកនូវទស្សនទានស៊ីជម្រៅក្នុងបញ្ហា ឬព្រឹត្តិការណ៍យកមកសរសេរ ដើម្បីជួយអ្នកអានឲ្យកាន់តែយល់បានថែមទៀត។ នេះឯងជាគោលបំណងធំរបស់បទវិភាគដំណឹង ដូច្នេះ អ្នកត្រូវប្រឹងប្រែងចាំងពន្លឺថែមទៀតលើបញ្ហាដែលជាប្រធានបទសាច់រឿង។

ក្នុងការចាប់ផ្តើម អ្នកគួរពិភាក្សាជាមួយនិពន្ធនាយកអំពីអ្វីដែលអ្នកចង់បង្ហាញក្នុងបទវិភាគនោះ។ វាពិតជាសំខាន់ក្នុងការពិគ្រោះយោបល់ជាមុន ព្រោះថាមានអ្នកយកព័ត៌មានច្រើនណាស់ ដែលថានឹងសរសេរបទវិភាគ តែទីបំផុតបែរជាផលិតនូវសេចក្តីសង្ខេបដុំៗនៃព្រឹត្តិការណ៍ដំណឹង ដែលបានកើតកាលពីប៉ុន្មានថ្ងៃមុនទៅវិញ។

អ្នកត្រូវសញ្ជឹងគិតចោទសួរថា អ្វីដែលនាំឲ្យកើតព្រឹត្តិការណ៍នេះ? គួរវាត្រូវបានគេទប់ស្កាត់ជាមុនឬទេ? តើគេកំពុងធ្វើអ្វីខ្លះ ដើម្បីលៃលកជាមួយហេតុការណ៍នោះ? តើនឹងមានអ្វីទៀតកើតឡើង? កុំប្រឹងក្នុងមហិច្ឆិតាហួសហេតុពេក។ បើសិនជាមានអ្នកណាម្នាក់លាលែងតំណែងពីគណៈរដ្ឋមន្ត្រី កុំបាច់ទៅសួរថា "អូ តើប្រព័ន្ធនយោបាយប្រទេសយើងនឹងជួបគ្រោះថ្នាក់ ឬយ៉ាងណា?" ចូរសាករកចម្លើយនឹងសំណួរថា ហេតុអ្វីបានជាគេលាលែងពីតំណែង តើការលាលែងតំណែងនេះមានន័យដូចម្តេច ហើយតើអ្នកណានឹងឡើងមកជំនួសវិញ។ សូមទុកការគិតរបស់អ្នកអំពីអនាគតរបស់ប្រទេសមួយឡែកសិនទៅ។

បន្ទាប់មកទៀត ចូរធ្វើបញ្ជីប្រភពមួយចំនួនដែលអាចជួយអ្នកបានក្នុងការវិភាគដំណឹង។ អ្នកគួរជជែកជាមួយអ្នកណាដែលឯករាជ្យឲ្យផ្តល់ការវាយតម្លៃលើអ្វីដែលបានកើតឡើង និងអ្នកដែលទាំងឡាយដែលមានភាពជិតស្និទ្ធនឹងព្រឹត្តិការណ៍ ជាអ្នកដែលអាចមានការពាក់ព័ន្ធ ឬទទួលរងផលពីព្រឹត្តិការណ៍នោះ។ ទស្សនៈរបស់ពួកគេទំនងជានឹងកាន់ជើងម្ខាងៗជាមិនខាន ដូច្នេះអ្នកគួរធ្វើយ៉ាងណារក្សាតុល្យភាពក្នុងការសរសេររបស់ខ្លួន។

ដំបូង សាកជជែកជាមួយអ្នកវិភាគឯករាជ្យដោយប្រាប់គេឲ្យដឹងច្បាស់ថា អ្នកស្វែងរកការណែនាំ និងមតិយោបល់ខ្លះដែលអាចដកស្រង់យកមកសរសេរបាន។ សួរថា តើគេគិតឃើញដូចម្តេចដែរអំពីអត្ថន័យនៃអ្វីដែលទើបនឹងកើតឡើងនេះ? បើមិនដូច្នោះទេ សុំដំបូន្មានថាអ្នកណាដែលអ្នកគួរជជែកជាមួយ។ ការសន្ទនាលើកដំបូងនឹងមិនផ្តល់ឲ្យអ្នកអ្វីៗគ្រប់បែបយ៉ាង ដែលអ្នកចង់បាននោះទេ តែវាអាចផ្តល់តម្រុយទស្សនៈ និងសម្តីដែលអ្នកត្រូវស្វែងរកយកមកសរសេរ។

បន្ទាប់ពីអ្នកបានជជែកជាមួយអ្នកវិភាគឯករាជ្យ ដល់ពេលដែលអ្នកត្រូវជជែកជាមួយអ្នកពាក់ព័ន្ធ ឬអ្នកដែលយល់ស្របនឹងព្រឹត្តិការណ៍ដែលបានកើតឡើង។ ក្រុមនេះប្រហែលជាពិបាកនឹងលែលកជាមួយ ព្រោះថាពួកគេអាចមិនទុកចិត្ត ឬខ្លាចអ្នកសារព័ត៌មាន។ ដូច្នេះ មុននឹងទាក់ទងអ្នកទាំងនោះ សាកត្រៀមសំណួរមួយចំនួនទុកជាមុនសិន។ សរសេរសំណួរទាំងនោះទុកក្នុងសៀវភៅកំណត់ត្រា ដើម្បីអ្នកអាចដឹងថាវានៅកន្លែងណាងាយនឹងរកមើលយកមកសួរក្នុងពេលសម្ភាសន៍។ ប៉ុន្តែ ចូរកុំសួរតាមតែសំណួរដែលបានគ្រោងទុកនោះ។ បើក្នុងពេលធ្វើសម្ភាសន៍មានអ្នកបង្ហាញទស្សនៈវិញ្ញាណ៍ផ្ទុយ ចូរកុំប្រឹងអូសទាញគេចូលក្នុងគ្រោងគំនិតដែលអ្នកបានត្រៀមទុកជាមុននោះ លើកលែងតែថាគេនិយាយចាកប្រធាន។ វាសំខាន់ក្នុងការសុំឲ្យគេធ្វើការសម្រាយបញ្ជាក់អ្វី ដែលគេនិយាយ និងសួរសំណួរដេញបន្តលើចំណុចមតិរបស់គេ ជាជាងការងាកមកយកសំណួរព្រាងទៅសួរ។

# សរសេរបទវិភាគដំណឹង

បន្ទាប់ពីអ្នកប្រមូលបានអ្វី ដែលអ្នកស្វែងរកពីប្រភពរបស់អ្នករួចហើយ ចូរធ្វើតាមការណែនាំខាងក្រោមនេះក្នុងការសរសេរបទវិភាគ៖

១. គូសវាសត្រួសៗ (outline) គ្រោងរឿងដោយរាយជាបញ្ជីនូវចំណុចដែលអ្នកចង់លើកយកមកនិយាយ។ បើអ្នកមិនត្រាយផ្លូវជាមុនទេ អ្នកនឹងធ្លាក់ក្នុងភាពជំពាក់ជំពិនជាមិនខានក្នុងការសរសេរ។ នេះដោយសារថាអ្នកយកព័ត៌មានភាគច្រើនមានទម្លាប់សរសេរដំណឹង ហើយដល់ពេលសរសេរបទវិភាគ ពួកគេងាយធ្លាក់ចូលក្នុងគន្លងដដែលនេះណាស់ ដោយសរសេរអត្ថបទប្រហាក់ប្រហែលនឹងអត្ថបទដំណឹងថែមទៀតជាជាងសរសេរអត្ថបទវិភាគ។ នេះមិនមែនជាប្រការល្អទេ។ មួយទៀតអ្នកប្រហែលជាប្រមូលបានព័ត៌មានក្នុងសៀវភៅកំណត់ហេតុរបស់អ្នកច្រើនជាងសេចក្តីត្រូវការក្នុងរឿងទៅទៀត។ ដូច្នេះ ផែនការវានឹងបង្ខំអ្នកឲ្យសម្រេចលើអាទិភាពថា អ្វីដែលសំខាន់បំផុត ហើយទុកមួយអន្លើនូវអ្វីដែលមិនសូវសំខាន់។

២. ផ្តើមសរសេរពីមុមណាមួយ ដែលខុសពីអត្ថបទដំណឹង ឬសរសេររបៀបស៊ើលអត្ថបទពិពណ៌នាជាដើម។ សំខាន់សូមចាំថា បទវិភាគមិនគួរមានសូរសៀងស្រដៀងនឹងអត្ថបទដំណឹងដែលគេកំពុងវិភាគនោះទេ។

៣. យ៉ាងយូរត្រឹមកថាខណ្ឌទីបី សូមសង្ខេបចំណុចសំខាន់ៗនៃដំណឹងក្នុងបទវិភាគនោះ ឲ្យអ្នកអានបានយល់ក្នុងករណីដែលគេអានអត្ថបទវិភាគមុនអត្ថបទដំណឹង។ ម្យ៉ាងទៀត ក្នុងការសរសេរគួរចាំថាយើងគ្រាន់តែរំលឹកអ្នកអានអំពីព្រឹត្តិការណ៍ដំណឹងតាមរយៈបទវិភាគតែប៉ុណ្ណោះ ដើម្បីកុំឲ្យគេមានការយល់ច្រឡំថាយើងចាត់ទុកអ្នកអានថាមិនដឹងអ្វីសោះ។

៤. បញ្ចូលមនុស្សជាក់ស្តែង និងសម្រង់សម្តីល្អៗ ដើម្បីធ្វើឲ្យរឿងមានភាពស្រស់រស់រវើក។ សំខាន់ធ្វើយ៉ាងណាកុំ ទីបំផុតទៅសរសេររឿងមួយ ដែលធ្វើឲ្យគេធុញនឹងអានទៅវិញ។

៥. តាមភាពចាំបាច់ចូរផ្តល់សាវតារនៃរឿងក្នុងន័យជាការរំលឹកបន្ថែម មិនត្រឹមតែអំពីជាតុផ្សំនានានៃព្រឹត្តិការណ៍ដំណឹងប៉ុណ្ណោះទេ តែអំពីព្រឹត្តិការណ៍ផ្សេងៗទៀតដែលនឹងជួយអ្នកអានឲ្យកាន់តែយល់ថា ហេតុអ្វីបានជាមានរឿងរ៉ាវកើតឡើងដូច្នេះ។

៦. កុំទោរទន់ចង់ផ្តល់អត្ថាធិប្បាយ ឬបញ្ចេញយោបល់របស់ខ្លួនឲ្យសោះ។ យើងគ្រាន់តែជាយានចម្លងមួយសម្រាប់ឲ្យអ្នកគាំទ្រព្រឹត្តិការណ៍ និងអ្នកវិភាគឯករាជ្យនិយាយនូវអ្វីដែលគេគិតឃើញតែប៉ុណ្ណោះ។ អ្វីដែលអ្នកយល់ឃើញនោះមិនមែនជារឿងសំខាន់ទេ។

ផ្តល់ផងដែរនូវឱកាសយកមកគិតគូរនូវប្រតិកម្មថែមទៀតទៅនឹងព្រឹត្តិការណ៍ដំណឹង ក្នុងនោះមានសម្តីរបស់អ្នកដទៃ ដែលអ្នកមិនទាន់បានដដែកជាមួយ ប៉ុន្តែអត្ថាធិប្បាយរបស់គេត្រូវលេចឡើងក្នុងសារព័ត៌មានផ្សេងរួចទៅហើយ។



*បើចង់ដឹងថាមនុស្សនៅតាមផ្លូវគិតដូចម្តេចខ្លះ សូមសាកសួរគេទៅ។*

## ការសរសេរបទវិភាគដំណឹងច្រើនថ្ងៃក្រោយព្រឹត្តិការណ៍

គោលការណ៍ណែនាំសំខាន់ គឺនៅត្រង់ថាអ្នកគួរសន្មតទុកជាមុនថា មានមនុស្សច្រើនដែលមិនទាន់បានអានអត្ថបទដំណឹង។ មានន័យថាអ្នកគួរផ្តល់ក្នុងអត្ថបទនូវសេចក្តីរំលឹកអំពីជាតុផ្សំសំខាន់ៗនៃសាច់រឿងនោះ។

បន្ទាប់មកទៀត បទវិភាគចាំបាច់ត្រូវតែមានតម្លៃបន្ថែម មានន័យថា វាគេគួរប្រើពេលធ្វើការឆ្លុះបញ្ចាំង និងរិះគិតឲ្យបានគ្រប់គ្រាន់។ នេះមិនសំដៅតែលើពេលសម្រាប់លោកអ្នកដែលជាអ្នកសារ-ព័ត៌មានត្រិរិះទេ។ អ្នកឯកទេស និងអ្នកវិភាគក៏ត្រូវការពេលវេលាសម្រាប់ធ្វើការត្រិះរិះដែរ។ ពេលវេលាបទវិភាគមួយថ្ងៃបន្ទាប់ពីព្រឹត្តិការណ៍ ក៏នឹងអនុញ្ញាតឲ្យអ្នកចេញពីការិយាល័យទៅស្រង់ទស្សនៈពីអ្នកទាំងឡាយ ដែលអ្នកមិនអាចទាក់ទងតាមទូរស័ព្ទបានដូចសព្វដង។ ដូច្នេះ អ្នកមានពេលថែមទៀតសម្រាប់ក្រេបសាច់រឿងឲ្យបានស៊ីជម្រៅ ហើយមានតែការចេញទៅក្រៅការិយាល័យទេ ទើបអាចធ្វើដូច្នេះបាន។

ខាងក្រោមនេះ ជាឧទាហរណ៍បទវិភាគខ្លីមួយដែលសរសេរក្នុងថ្ងៃតែមួយនៃព្រឹត្តិការណ៍ ហើយត្រូវបានចុះផ្សាយក្នុងកាសែត Straits Times ប្រទេសសិង្ហបុរី៖

**ធម្មនុញ្ញអាស៊ាន**

**សាទរធម្មនុញ្ញអាស៊ាន**

**ច្បាប់សម្រាប់គ្រប់គ្រងការប្រព្រឹត្តរបស់អាស៊ាន ត្រូវបានចាត់ទុកថា សំខាន់ចាំបាច់ ទោះជាមានការបារម្ភអំពីភាពស័ក្តិសិទ្ធិរបស់វាក្តី**

**ដោយ Wahyudi Soeriaatmadja**

**ថ្ងៃទី ១៦ ធ្នូ ឆ្នាំ ២០០៨**

*សេចក្តីផ្តើមមានភាពសាមញ្ញ រួមដោយសេចក្តីសង្ខេប "យោបល់ខុសៗគ្នា" ដែលជាតម្រុយនៃការវិភាគដែលនឹងបន្តនៅខាងក្រោម*

ក្រុងហ្សាការតា : ទោះជាមេដឹកនាំប្រទេសអាស៊ានទាំងដប់កាលពីម្សិលមិញ បានប្រារព្ធសាទរការអនុម័តកម្រងច្បាប់ ដែលតម្រូវឲ្យប្រទេសទាំងនោះអនុវត្តលទ្ធិប្រជាធិបតេយ្យ និងធ្វើសមាហរណកម្មសេដ្ឋកិច្ចក្តី គេនៅតែឃើញមានយោបល់ខុសៗគ្នានៅលើភាពស័ក្តិសិទ្ធិលើធម្មនុញ្ញនោះដែរ។

*បន្ទាប់មកឈានចូលទៅដល់ផ្នែកស្តីពីកង្វល់របស់អ្នករិះគន់*

សំណួរនៅត្រង់ថា តើច្បាប់នេះនឹងនាំឲ្យមានការផ្លាស់ប្តូរបែបណាខ្លះក្នុងប្រព្រឹត្តកម្មរបស់សមាជិកអាស៊ាន ដោយអ្នករិះគន់និយាយថា ពាក្យពេចន៍ក្នុងធម្មនុញ្ញនោះកើតឡើង ដោយគេគ្រាន់តែក្រឡុកប្រលប់ពាក្យទាំងឡាយ ដែលមានក្នុងឯកសារមុនៗរួចមកហើយប៉ុណ្ណោះ។

សមាជិកអាស៊ានធ្លាប់ត្រូវបានគេរាយការណ៍ឲ្យដឹងថា បានគោរពតាមតែមួយភាគបីនៃកម្រងច្បាប់ទាំងនោះតែប៉ុណ្ណោះ។

*ត្រង់នេះមានបំណែកដំណឹងខ្លះៗ ក្នុងនោះ មានទស្សនៈរបស់អ្នកគាំទ្រ ដែលត្រូវបានគេបង្ហាញមុនសាវតារអំពីធម្មនុញ្ញ និងឧទាហរណ៍នៃបញ្ហានានាដែលគេជួបប្រទះពីអតីតកាលដែលអ្នករិះគន់និយាយថានឹងមិនអាចដោះស្រាយបានតាមរយៈការចុះហត្ថលេខាលើធម្មនុញ្ញនេះទេ*

យ៉ាងណាក្តី បរិយាកាសនៅឯកិច្ចប្រជុំម្សិលមិញមានសភាពរស់រាយណាស់ ដោយមេដឹកនាំអាស៊ានទាំងអស់បាននាំគ្នាសាទរធម្មនុញ្ញនោះថាជាជំហានសំខាន់មួយសម្រាប់ដំណើរឆ្ពោះទៅមុខក្នុងប្រវត្តិ ៤១ ឆ្នាំ របស់អង្គការតំបន់មួយនេះ។

លោក Rais Yatim រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ី និយាយថា៖ "យើងជឿថាធម្មនុញ្ញនេះ ផ្តល់ឲ្យយើងនូវនីតិក្រមកម្លាំងជំរុញទៅមុខ ហើយបើសិនជាយើងមិនពឹងផ្អែកលើកម្លាំងនេះទេ តើយើងមានអ្វីផ្សេងពីនេះ? ពីមុនយើងអត់មានយន្តការសម្រាប់ដោះស្រាយវិវាទ តែឥឡូវយើងមានហើយ"។

អគ្គលេខាធិការអាស៊ាន លោក ស៊ូរិន ពិតស៊ូវ៉ាន់ និយាយថា៖ "យើងនឹងមិនសម្រេចបានសមិទ្ធផលធំដុំលើបញ្ហាពិបាកៗមួយចំនួននោះទេ តែយើងត្រូវតែចាប់ផ្តើមពីទីណាមួយ"។

ធម្មនុញ្ញនោះ ត្រូវបានរដ្ឋសមាជិកអាស៊ានចុះហត្ថលេខាកាលពីខែវិច្ឆិកា ហើយប្រទេសនីមួយៗមានពេលមួយឆ្នាំសម្រាប់ឲ្យសភារបស់ខ្លួនផ្តល់សច្ចាប័ន។ សិង្ហបុរី ជាប្រទេសទីមួយដែលបានផ្តល់សច្ចាប័ន ហើយប្រទេសថៃជាអ្នកផ្តល់សច្ចាប័នក្រោយគេ។

ក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ អាស៊ានវង្វេងសម្លាញ់ឲ្យបង្កើតនូវយន្តការផ្លូវការមួយសម្រាប់ដោះស្រាយវិវាទ ដែលអាចយកមកប្រើប្រាស់បាន នៅពេលណាដែលសមាជិករបស់ខ្លួនមានទំនាស់ផ្ទៃក្នុងរវាងគ្នា។

ឧទាហរណ៍ សហគមន៍អន្តរជាតិបានជំរុញឲ្យអាស៊ានចូលពាក់ព័ន្ធរកដំណោះស្រាយវិបត្តិដែលកើតមានឡើង បន្ទាប់ពីមេដឹកនាំយោធាមីយ៉ាន់ម៉ា ធ្វើការបង្ក្រាបបែបបង្ហូរឈាមទៅលើក្រុមអ្នកបះបោរកាលពីខែកញ្ញា ឆ្នាំទៅនេះ។

ប៉ុន្តែ ដោយត្រូវគាំងសរសៃដោយសារតែគោលការណ៍មិនលូកលាន់កិច្ចការផ្ទៃក្នុងសមាជិកផងគ្នា ក្រុមអាស៊ាននេះសម្រេចចិត្តថាមិនចូលពាក់ព័ន្ធ និងមិនបានធ្វើការបញ្ចុះបញ្ចូលមីយ៉ាន់ម៉ាឲ្យធ្វើកំណែទម្រង់ប្រជាធិបតេយ្យ និងដោះលែងពួកអ្នកទោសនយោបាយរាប់ទាំងលោកស្រី អ៊ុងសាន ស៊ូជី ផង។

ទីនេះជាទស្សនៈ
អ្នកឯករាជ្យពីរូប

លោកបណ្ឌិត Dwi Ardhanariswari អ្នកស្រាវជ្រាវម្នាក់នៅ Centre for Global Civil Society Studies & the National Democratic Institute នៅក្រុងហ្សាការតា និយាយប្រាប់កាសែត The Straits Times ថា៖ "បើមើលពីជ្រុងទស្សនទានរបស់បស្ចិមលោកនេះអាចជាទិដ្ឋភាពអវិជ្ជមានមួយ"។

រីឯលោកបណ្ឌិត Yeo Lay Hwee អ្នកស្រាវជ្រាវជាន់ខ្ពស់ម្នាក់នៅ Singapore Institute of International Affairs និយាយទៅកាន់កាសែត The Straits Times ថា៖ "ពិតណាស់ គេបានសម្តែងការចំអកឡកឡឺយខ្លះដាក់ធម្មនុញ្ញនេះ ក៏ព្រោះតែគេមើលឃើញថាវា "ទន់ជ្រាយ" ហើយមិនបានបង្ហាញតម្រុយផ្លូវទៅមុខប៉ុន្មានទេ។ ដូច្នេះ វាបានរំលងឱកាសសម្រាប់បញ្ជូនសញ្ញាមោះមុតមួយអំពីចេតនាអាស៊ានក្នុងការធ្វើអន្តរកម្មខ្លួនទៅជាអង្គការមួយ ដែលឈរលើវិធានច្បាស់លាស់ មានយន្តការ និងឧបករណ៍សម្រាប់ឲ្យគេយកទៅប្រើប្រាស់ក្នុងការលៃលកជាមួយភាពប្រឈមនានាក្នុងសតវត្សរ៍ទី ២១ នេះ"។

*យ៉ាងណាក្តី លោក George Yeo រដ្ឋមន្ត្រីការបរទេសសិង្ហបុរី បាត់ទុកជម្លោះនេះថាជា សញ្ញាដែលអាស៊ានកំពុងតែធ្វើឲ្យមានវឌ្ឍនភាពយឺតៗ តែពិតប្រាកដ។*

*គាត់និយាយថា វាជាជំហានមួយឆ្ពោះទៅរកការ "បង្កើតលក្ខខណ្ឌកាន់តែប្រសើរជាងមុនសម្រាប់សន្តិភាព និងការអភិវឌ្ឍសេដ្ឋកិច្ច" ដោយថាយើងបានរកឃើញនូវវិធីមួយ ដែលមានបែបផែនស្ថាប័នសម្រាប់ដោះស្រាយវិវាទក្នុងចំណោមគ្នាយើងទេ"។*

អត្ថបទនេះជាឧទាហរណ៍មួយនៃបទវិភាគដំណឹងបែបសាមញ្ញ ដែលគេអាចធ្វើបានដោយមិនបាច់ចេញពីការិយាល័យ ដោយគ្រាន់តែទូរស័ព្ទទៅរកមនុស្សមួយចំនួន ដើម្បីប្រមូលទស្សនៈផ្ទុយៗគ្នាយកមកសរសេរតែប៉ុណ្ណោះ។ អត្ថបទនេះ ក៏មានអមនូវប្រអប់សម្រង់ជាតុផ្សំសំខាន់ៗមួយចំនួនពីក្នុងជម្លោះនោះផងដែរ។

រីឯខាងក្រោមនេះជាឧទាហរណ៍បទវិភាគដំណឹងមួយ ដែលមានសភាពស្មុគ្រស្មាញជាងមុន ដែលត្រូវបានដកស្រង់ចេញពីកាសែត International Herald Tribune។ វាផ្តើមចេញពីរឿងដំណឹងទាន់ហេតុការណ៍មួយ ដែលនរណាក៏និយាយអំពីវាដែរ ហើយវាបានពិនិត្យមើលអ្វីនៅពីក្រោយរឿងនោះថា តើវាមានន័យដូចម្តេចចំពោះប្រទេសដែលពាក់ព័ន្ធក្នុងរឿងនេះ៖

***រឿងអាស្រូវរបស់ជនល្បីឈ្មោះបោះសម្លេងកំពុងធ្វើតេស្តច្បាប់ផិតក្បត់នៅប្រទេសកូរ៉េហើយ***
***ដោយ Choe Sang-Hun***

***ថ្ងៃព្រហស្បតិ៍ ទី ១៥ ឧសភា ឆ្នាំ ២០០៨***

*យើងឃើញហើយថា សេចក្តីផ្តើមជាស្ទីលអត្ថបទពិពណ៌នា*

*តារានារី និងប្តីរបស់នាងដែលជាឥស្សរជនម្នាក់ប្រចាំកម្មវិធីទូរទស្សន៍។ បុរសពុងភោម្នាក់ជាជនជាតិអ៊ីតាលី ដែលជាប្តីនិយាយថា គាត់បានធ្វើអ្វីគ្រប់បែបយ៉ាងជូនប្រពន្ធគាត់លើសពីធ្វើម្ហូប និងបង្រៀនភាសាអង់គ្លេសនៅផ្ទះទៅទៀត។*

*តួអង្គមួយទៀត គឺមិត្តរបស់ប្តីនោះដែលជាអ្នកចម្រៀង តែក្រោយមកបានក្លាយជាសហាយរបស់ប្រពន្ធគាត់ទៅវិញ។*

*ពាក្យបណ្តឹងលែងលះគ្នារវាងនាង អុក សូ រី និងប្តីរបស់នាងឈ្មោះ ប៉ាក ឈុល ទាំងពីរនាក់អាយុ ៣៩ ឆ្នាំ ប្រៀបបាននឹងអត្ថបទមួយសម្រាប់យកទៅថតកុន ដែលគេបានកាត់ចេញពីទំព័រកាសែតមុននឹងនាង អុក អូសទាញសត្រូវមួយទៀតចូលទៅក្នុងការឈ្លោះប្រកែកគ្នាឡូងឡាងមួយ សត្រូវនោះ គឺច្បាប់ស្តីពីភាពផិតក្បត់ ដែលវាមានវ័យ*

៥៥ ឆ្នាំមកហើយ ។ដាក់ទណ្ឌកម្មអំពើសាហាយស្មន់ថាជាបទព្រហ្មទណ្ឌមួយ។

នៅក្នុងរឿងអាស្រូវមួយ ដែលធ្វើឲ្យទំព័រប្លុកលើអ៊ិនធឺណិតប្រទេសកូរ៉េ មានភាពមមាញឹកអស់រាប់ខែមកហើយ នោះ នាង អុក មិនគ្រាន់តែបានសារភាពថាមានសាហាយស្មន់ប៉ុណ្ណោះទេ តែថែមទាំងនិយាយថា នាងមិនឃើញហេតុផលអ្វីសោះថា ត្រូវចូលគុក ដោយសារតែផិតប្តីរបស់ខ្លួននោះ។ កាលពីខែកុម្ភៈ កន្លងទៅនេះ នាងបានស្នើទៅតុលាការធម្មនុញ្ញឲ្យធ្វើសេចក្តីសម្រេចថា ច្បាប់ស្តីពីអំពើផិតដើរផ្ទុយនឹងរដ្ឋធម្មនុញ្ញទៀតផង។

ត្រង់នេះ ជាការពន្យល់ពេញលេញថា តើរឿងនេះនិយាយអំពីអ្វី

មិនយូរប៉ុន្មាន រឿងជះភក់ដាក់គ្នាទៅវិញទៅមករវាងគូស្វាមីភរិយានេះ បានប្រែក្លាយហួសពីពាក្យចចាមអារាមទៅទៀត។ គឺវាបានក្លាយទៅជារឿងប្រឈមដ៏ល្បីល្បាញមួយតតាំងទៅនឹងច្បាប់ឯកព័ន្ធភាពដ៏តឹងតែងរបស់ប្រទេសកូរ៉េខាងត្បូង ដែលមនុស្សមួយចំនួនស្រឡាញ់ពេញចិត្ត និងចាត់ទុកថា វាជាកំពែងទប់ទល់នឹង "វប្បធម៌សិចសេរីរបស់ពួកបស្ចិមលោក"។ ប៉ុន្តែអ្នកដទៃបាននាំគ្នាចំអកដាក់ច្បាប់នេះថាជា "រឿងកំប្លែងហួសសម័យ" នៅក្នុងប្រទេសមួយដែល "ម៉ូតែលស្នេហា" ដែលគេស្គាល់ទូទៅថាជាកន្លែងសម្រាប់មានសាហាយស្មន់ កំពុងរីកដុះដាលគ្រប់ទីកន្លែង ហើយដែលការលែងលះ ក៏កំពុងតែកើនឡើងដែរនោះ។

នេះជាសម្រង់សម្តីល្អមួយពីមនុស្សម្នាក់ក្នុងចំណោមមនុស្សដែលមានការពាក់ព័ន្ធ

លោក លីម ស៊ុង ប៊ីន មេធាវីរបស់អ្នកស្រី អុក និយាយថា "វាដូចជាជ្រុលពេកហើយ ដែលរដ្ឋមករវីរវល់ក្នុងរឿងថា តើដៃគូសិចមួយណាដែលគេគួរមាននោះ"។ គាត់មានប្រសាសន៍ដូច្នេះកាលពីថ្ងៃ ៨ ឧសភា បន្ទាប់ពីមានសវនាការអស់បីម៉ោងនៅតុលាការធម្មនុញ្ញ ដែលកូនក្តីរបស់គាត់អវត្តមាន។ លោកបន្ថែមទៀតថា "ជំនាន់សម្រាប់ផ្នត់គំនិតបែបនោះ វាបានកន្លងផុតបាត់ទៅហើយ"។

សាវតារ

តុលាការដែលមានចៅក្រមប្រាំបួនរូប បាននិយាយថាគេនឹងចេញសេចក្តីសម្រេចចិត្តលើករណីនេះ ក្នុងពេលឆាប់ៗខាងមុខ តែមិនបាន់កំណត់ថាថ្ងៃណាទេ។

តុលាការនេះកំពុងពិភាក្សាដេញ ដោលបណ្តឹងរបស់នាង អុក រួមជាមួយញត្តិបីទៀតជំទាស់ទៅនឹងច្បាប់ឯកព័ន្ធភាព ដែលគេបានដាក់បណ្តឹងកាលពីឆ្នាំកន្លងទៅ។

*ពីត្រង់នេះរហូតដល់ទីបញ្ចប់ ជាល្បាយប្រវត្តិសាស្ត្រ និង សាវតារ សម្រង់សម្តីល្អបំផុត និងសម្រង់ករណីមួយចំនួន របស់តុលាការ ហើយព័ត៌មាន ទាំងអស់នេះ ត្រូវបានគេលើក យកមកបង្ហាញតាមរបៀបមួយ ប្រកបដោយតុល្យភាព*

*កូរ៉េខាងត្បូង ស្ថិតក្នុងចំណោមប្រទេសមួយចំនួនតូចដែលមិនមែនប្រកាន់សាសនាឥស្លាម ដែលប្រជាជនអាចត្រូវបានគេដាក់គុក ដោយសារផិតក្បត់ចំណងអាពាហ៍ពិពាហ៍។ ប្រហែល ៧០ ភាគរយ នៃប្រជាជនកូរ៉េខាងត្បូងបានគាំទ្រច្បាប់ឯកព័ន្ធភាពនេះ បើយោងតាម ការស្ទាបស្ទង់មតិមួយដែលរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយបាន ធ្វើកាលពីពេលថ្មីៗនេះ។*

*ជារៀងរាល់ឆ្នាំ មានមនុស្សជាង ១.២០០ នាក់ ទទួលរងការចោទ ប្រកាន់ដោយច្បាប់នេះ ដែលតម្រូវឲ្យដាក់ទណ្ឌកម្មរហូតដល់ ២ ឆ្នាំ ដល់ជនផិត និងដៃគូផិតរបស់គេ។*

*លោក ហាន់ សាំង ដៃ មន្ត្រីក្រសួងយុត្តិធម៌មួយរូប ដែលការពារ ច្បាប់ឯកព័ន្ធភាពក្នុងសវនាការតុលាការធម្មនុញ្ញ និយាយថា "អ្នកខ្លះបានធ្វើទឡ្ហីករណ៍ថា ច្បាប់មិនគួរចូលជ្រៀតជ្រែករឿងក្រោម ភួយរបស់អ្នកដទៃទេ។ តែបើយើងបណ្តោយសេរីភាពផិតក្បត់ក្រៅ អាពាហ៍ពិពាហ៍ វានឹងបង្កការគំរាមកំហែងដល់សីលធម៌ផ្នែកផ្លូវភេទ ក៏ដូចជាឯកព័ន្ធភាពរបស់យើងដែរ ដែលជាមូលដ្ឋានគ្រឹះនៃសង្គម យើង"។*

*តុលាការធម្មនុញ្ញ ក៏បានចេញដីការសម្រេចបីដងរួចមកហើយ ជាការគាំទ្រទៅនឹងច្បាប់ឯកព័ន្ធភាព ដែលលើកចុងក្រោយការសម្រេច នេះ ត្រូវបានគេធ្វើឡើងក្នុងឆ្នាំ ២០០១។*

*ក៏ប៉ុន្តែបញ្ហាប្រឈមរបស់នាង អុក កើតមានព្រមគ្នានឹងពេលដែល ច្បាប់នេះ កំពុងបាត់បង់នូវអ្នកដែលធ្លាប់គាំទ្រមោះមុតរបស់ខ្លួន។ សមាគមស្ត្រីកូរ៉េឯកភាព (Korean Women's Association United) និងក្រសួងសមភាពយេនឌ័រកូរ៉េ (Ministry of Gender Equality) ដែលធ្លាប់ជាជើងឯកគាំទ្រសិទ្ធិស្ត្រី និងច្បាប់ឯកព័ន្ធភាព ឥឡូវនេះបាននិយាយថា វាល្មមដល់ពេលដែលប្រទេសកូរ៉េខាងត្បូង ចាប់ផ្តើមពិចារណាលុបច្បាប់នេះចោលទៅ។*

*នៅប្រទេសកូរ៉េខាងត្បូង គឺសមាគមស្ត្រី ដែលធ្លាប់ជាអ្នកគាំទ្រខ្លាំង បំផុតដល់ការដាក់ការផិតក្បត់ជាអំពើព្រហ្មទណ្ឌ។ ពីមុនពាក្យបណ្តឹង ផិតក្បត់ ច្រើនតែប្រពន្ធដែលជាអ្នកប្តឹងប្រឆាំងប្តី។ ច្បាប់នេះបានផ្តល់ ឲ្យស្ត្រីនូវប្រៀបក្នុងសង្គមមួយ ដែលពួកគេមិនសូវហ៊ានតបតប្រឆាំងប្តី ដែលគ្មានស្មោះត្រង់ភក្តី។*

ជាមួយនឹងស្ថានភាពសេដ្ឋកិច្ច និងសង្គមរបស់គេកាន់តែមានភាពប្រសើរឡើង ស្ត្រីភាគច្រើនលែងអត់ធ្មត់ជាមួយប្តីផិតក្បត់ ឬក៏ខ្លាចការលែងលះទៀតហើយ។ តែនៅពេលដែលមានប្តីចំនួនកាន់តែច្រើនកំពុងប្រើប្រាស់ច្បាប់ប្រឆាំងនឹងប្រពន្ធរបស់ខ្លួន ពួកគេក៏កំពុងពើបប្រទះដែរថា - ដូចជាក្នុងករណីរបស់នាង អុក ជាដើម - ថាច្បាប់នេះអាចជាដាវមុខពីរដែរ គឺវាប្រៀបបាននឹងការបំពានលើឯកជនភាពរបស់ពលរដ្ឋ ច្រើនជាងការការពារដល់ស្ត្រី។

ចំនួនរឿងលែងលះគ្នានៅកូរ៉េខាងត្បូងបានកើនឡើងពី ៧៩.៨៩៥ គូស្វាមីភរិយា ក្នុងឆ្នាំ ១៩៩៦ ដល់ចំនួន ១២៤.៦០០ គូស្វាមីភរិយាក្នុងឆ្នាំកន្លងទៅនេះ។

នៅឆ្នាំ ២០០៦ ស្វាមីភរិយា ១១.២៤៤ គូ បានធ្វើការលែងលះគ្នាក្នុងតុលាការ ដោយសារតែរឿងផិតក្បត់។ ក្នុងចំនួន ៣៩,៧ ភាគរយនៃករណីទាំងនោះ ប្តីជាអ្នកចោទប្រពន្ធ គឺកើន ៣,៥ ភាគរយពីឆ្នាំ ១៩៩៩។

លោក ក្វាក បែ ហ៊ី ប្រធានមជ្ឈមណ្ឌលកូរ៉េជំនួយផ្នែកច្បាប់សម្រាប់ទំនាក់ទំនងគ្រួសារ (Korea Legal Aid Center for Family Relations) ដែលជាអង្គការក្រៅរដ្ឋាភិបាលមួយផ្តល់សេវាប្រឹក្សាពីបញ្ហាគ្រួសារ និយាយថា៖ "កាលពីមុន អំពើផិតធ្លាប់ត្រូវបានគេគិតថាមានតែប្តីទេដែលអាចប្រព្រឹត្តបាន។ តែឥឡូវនេះ ស្ត្រីៗគិតថាពួកគេក៏អាចធ្វើបានដែរ ហើយអ្នកខ្លះក្នុងចំណោមពួកគេពិតជាបានផិតប្តីរបស់ខ្លួនមែន"។

របៀបដែលរឿងអាស្រូវរវាងនាង អុក និងប្តី លោក ប៉ាក បានលាតត្រដាងរំលេចឲ្យឃើញផងដែរ នូវការប្រែប្រួលឌីណាមិកផ្នែកផ្លូវភេទក្នុងប្រទេសកូរ៉េ។

លោក ប៉ាក បានដាក់ពាក្យប្តឹងលែងលះ និងរឿងផិតកាលពីខែតុលា ដោយបាននិយាយថា គាត់មានភស្តុតាងអំពីការដែលប្រពន្ធរបស់គាត់មានសាហាយក្រៅចំណងអាពាហ៍ពិពាហ៍ជាមួយមេចុងភៅជនជាតិអ៊ីតាលីម្នាក់នៅសណ្ឋាគារមួយក្នុងក្រុង សេអ៊ូល និងជាមួយអ្នកចម្រៀងម្នាក់ទៀតផង។ នៅក្នុងចំណាត់ការអេជម្មតាមួយសម្រាប់ស្ត្រីកូរ៉េខាងត្បូងម្នាក់ ដែលកំពុងតែប្រឡាក់ប្រឡូសក្នុងរឿងអាស្រូវផ្លូវភេទ នាង អុក ក៏បានកោះហៅសន្និសីទសារព័ត៌មានមួយ ដើម្បីការពារខ្លួនគាត់។ នាងសារភាពថា នាងពិតជាមានសាហាយស្មន់ជាមួយអ្នកចម្រៀងមែន តែមិនមែនជាមួយមេចុងភៅទេ។

ដោយប្រឹងទប់ទឹកភ្នែកផងនាង អុក និយាយថា៖ "ខ្ញុំមានបំណង អាពាហ៍ពិពាហ៍មួយដែលមានភាពឯកោ និងខ្វះសេចក្តីពេញចិត្ត ព្រោះតែប្តីខ្វះសេចក្តីស្នេហា។ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ១១ ឆ្នាំ កន្លងមក យើងបានរួមភេទជាមួយគ្នាតែ ១០ ដងគត់"។

រីឯលោក ប៉ាក វិញ និយាយថា គាត់មានអារម្មណ៍ប្រៀបបាននឹង "អ្នកថ្មើរជើងតាមដងផ្លូវដែលត្រូវបានឡានបុក" អញ្ចឹង។

នៅឯសន្និសីទសារព័ត៌មានមួយ គាត់និយាយថា៖ "កៅសិបប្រាំបួនភាគរយ នៃអ្វីដែលនាងបាននិយាយនោះ គឺជាការមួលបង្កាច់ ឬខុសស្រឡះ។ ខ្ញុំគ្រាន់តែសង្ឃឹមថានឹងមិនឃើញមុខនាងតទៅទៀត ក្នុងជីវិតរបស់ខ្ញុំទៅពេលខាងមុខ"។

ការជជែកដេញដោលពីរឿងច្បាប់ឯកព័ន្ធភាព ដែលត្រូវបានញោចដោយរឿងអាស្រូវនេះ បានរំលេចឡើងនូវទិដ្ឋភាពផ្ទុយគ្នាក្នុងវប្បធម៌កូរ៉េខាងត្បូង៖ គឺអត្ថិភាពនៃគុណធម៌គោរពប្រពៃណីត្រង់ភ្លឹងក្នុងពេលដែលមានឥរិយាបថសេរីកាន់តែច្រើនឡើងចំពោះរឿងផ្លូវភេទ។

រដ្ឋាភិបាលបានប្រមាណថា របររកស៊ីផ្លូវភេទក្នុងប្រទេសមានប្រហែល ៤.៤ ភាគរយ នៃផលិតផលសរុបក្នុងស្រុក ដែលមានស្ត្រីជាងកន្លះលាននាក់សកម្មក្នុងមុខរបរនេះ។ ដោយនៅមិនឆ្ងាយប៉ុន្មានពីសាលារៀន ម៉ូតែលស្នេហាមានបន្ទប់ជួលស្នាក់រយៈពេលខ្លី ហើយនិងផ្តល់សេវាប្រសរាយផ្សេងៗទៀត ដូចជាការជួយគ្របស្លាកលេខយានយន្តរបស់ភ្ញៀវជាដើម។

រីឯវិបសាយអាសអាភាសវិញ មានការសាយភាយទូទាំងប្រទេសនេះ ដែលប្រាំបីក្នុងចំណោមដប់ផ្ទះបានភ្ជាប់អ៊ិនធឺណិត ប្រដបិន។ ប៉ុន្តែគេមិនលើកទឹកចិត្តឲ្យមានការអប់រំផ្លូវភេទនៅតាមថ្នាក់រៀនទេ។

អ្នកទាំងឡាយដែលមានការជំទាស់ទៅនឹងច្បាប់ឯកព័ន្ធភាព និយាយថា គេពិបាកកសាងរឿងក្តីបទឧក្រិដ្ឋនៃអំពើផិត ដោយសារច្បាប់នឹងសឹងតែបាត់បង់សារៈសំខាន់ទៅហើយ។ ដើម្បីរកឃើញថានរណាម្នាក់មានពិរុទ្ធ គេត្រូវការភស្តុតាងក្នុងពេលរួមភេទ។

មានករណីជាច្រើនដែលត្រូវបានគេរាយការណ៍ ដែលក្នុងនោះជួនកាល ប្តី ឬប្រពន្ធ មានប៉ូលីសអមដំណើរផង បានសម្រុកចូលបន្ទប់ម៉ូតែល ដោយប្រើកាមេរ៉ាថតក្នុងពេលតែមួយ។

វិធីបែបនេះ បណ្តាលឲ្យមានការចោទប្រកាន់ពីបទបំពានសិទ្ធិឯកជន និងរំលោភសិទ្ធិមនុស្ស ហើយចំនួនជាមធ្យមនៃមនុស្សដែលត្រូវបានទទួលការចោទប្រកាន់ពីបទផិតបានធ្លាក់ចុះពី ២.០០០ នាក់

ក្នុងមួយឆ្នាំក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ មកនៅត្រឹម ១.២០០ នាក់ក្នុងមួយឆ្នាំក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ។

រីឯការដាក់ទណ្ឌកម្មវិញ ក៏កាន់តែមានសភាពស្រាលជាងមុនដែរ។ កាលពីឆ្នាំមុន ក្នុងបំណោមមនុស្ស ១.២១៩ នាក់ ដែលទទួលការចោទប្រកាន់ពីបទផិតមានតែ ៤៧ នាក់ប៉ុណ្ណោះ ដែលត្រូវជាប់ពន្ធនាគារ ប្រៀបធៀបនឹង ៣៩៣ នាក់ ក្នុងចំណោមជនជាប់ចោទ ១.៩០២ នាក់ នៅឆ្នាំ ២០០១។ ភាគច្រើនបានត្រឹមតែជាប់ទោសព្យួរ ឬមួយក៏រួចខ្លួនដោយសារប្តី ឬប្រពន្ធដកពាក្យបណ្តឹងវិញ។

អ្នកខ្លះក៏មើលឃើញដែរថា វាជារឿងមិនសមហេតុផល ដែលកូរ៉េខាងត្បូងចាត់ការផិតថាជាអំពើឧក្រិដ្ឋ នៅពេលដែលគេគ្មានច្បាប់ណាមួយសម្រាប់ចាត់ការជាមួយស្នេហ៍ការជាមួយសាច់ញាតិឯងផងនោះ។



កន្លែងស្រស់ប្រិមប្រិយមួយចំនួននៅលើកពផែនដីយើងនេះ ក៏ប្រទះនឹងបញ្ហាច្រើនណាស់ដែរ។

លោក ក្វាក និយាយថាយ៉ាងណាក្តី មនុស្សភាគច្រើនយល់ឃើញថាមិនទាន់ដល់ពេលត្រូវលុបបំបាត់ច្បាប់ឯកព័ន្ធភាពទេ។

នៅក្នុងប្រទេសមួយដែលស្ត្រីភាគច្រើនសុខចិត្តទ្រាំការឈឺចាប់យ៉ាងស្ងប់ស្ងៀមពីចិត្តក្បត់របស់ប្តី ដោយខ្លាចធ្លាក់ខ្លួនក្រដោយសារការលែងលះ បទចោទអំពើផិត នៅតែជាឧបករណ៍មានប្រសិទ្ធភាពមួយសម្រាប់ធានាឲ្យបាននូវដំណោះស្រាយផ្នែកហិរញ្ញវត្ថុ និងការឃុំគ្រងកូន។

នាង ហា ជី អ៊ុន និស្សិតម្នាក់នៅ Ewha Woman's University ក្នុងរដ្ឋធានីសេអ៊ូល និយាយថា "បុរសកូរ៉េ ភាគច្រើននៃពួកគេនៅតែអាចរួចខ្លួនពីអំពើផិតដដែល ព្រោះស្ត្រីជាមនុស្សខ្សោយ។ កាលពីជំនាន់ជួនតាខ្ញុំ បុរសនាំសាហាយចូលផ្ទះ ហើយដេញប្រពន្ធរបស់ខ្លួនឯងចេញវិញ។ បើគេលុបចោលច្បាប់ឯកព័ន្ធភាពនេះមែន ខ្ញុំប្រាកដក្នុងខ្លួនណាស់ថា ស្ត្រីនឹងរងការឈឺចាប់កាន់តែខ្លាំងជាងមុនជាមិនខាន"។

## វិចារណកថា និងអត្ថាធិប្បាយ

ក្នុងរបសារព័ត៌មានអាជីព គេញែក **អង្គហេតុ និងមតិ**ឲ្យនៅដោយឡែកពីគ្នា។ ដូចយើងបានឃើញរួចមកហើយក្នុងផ្នែកបទវិភាគដំណឹងសព្វថ្ងៃនេះ ទំព័រដំណឹងមានអត្ថបទវិភាគកាន់តែច្រើនឡើងៗ។ តែយើងក៏បានដឹងដែរថា បទវិភាគមិនដូចគ្នានឹងបទអត្ថាធិប្បាយ ឬវិចារណកថាទេ។

ទម្លាប់ជាប្រពៃណីមួយ ដែលកាសែតញែកអង្គហេតុ និងមតិចេញពីគ្នានោះ គឺតាមរយៈការចុះផ្សាយវាក្នុងទំព័រដោយដាច់ស្រឡះពីគ្នា ហើយដែលទំព័រនីមួយៗមានឈ្មោះរបស់វាដាក់លាក់។ គេមានទំព័រមួយ ដែលសម្រាប់កាសែតបញ្ចេញមតិយោបល់របស់ខ្លួន (ដែលធម្មតា ត្រូវបានគេចាត់ទុកថាជាមតិរបស់និពន្ធនាយក) ហើយគេឲ្យឈ្មោះវាថាជាទំព័រវិចារណកថា (editorial page)។ ជារឿយៗ នៅលើទំព័រនេះតែងមានគំនូរនយោបាយ ដែលធ្វើអត្ថាធិប្បាយនយោបាយ និងលិខិតជូននិពន្ធនាយក (letters to the editor) ដែលច្រើនតែជាអត្ថបទបញ្ចេញមតិដែរ។ ជួនកាល នៅលើទំព័រនេះមានខ្ទង់មួយសម្រាប់ចុះផ្សាយអត្ថបទអត្ថាធិប្បាយរបស់អ្នកនិពន្ធជាភ្ញៀវ ឬរបស់អ្នកឯកទេស។

រីឯទំព័រនៅខាងស្តាំនៃទំព័រវិចារណកថា (editorial page) នោះ ត្រូវបានគេឲ្យឈ្មោះថាទំព័រ op-ed ដែលមានន័យថា ទំព័រទល់មុខគ្នានឹងទំព័រវិចារណកថា (the page opposite the editorial page)។ ជាធម្មតា ទំព័រនេះតែងចុះអត្ថបទមតិ និងវិចារណកថារបស់និពន្ធនាយក អ្នកនិពន្ធ និងអ្នកឯកទេសនៅខាងក្រៅកាសែត។

អត្ថបទអត្ថាធិប្បាយ និងមតិ អាចមានស្ទីលខុសៗគ្នាច្រើន។ ខាងក្រោមនេះជាមគ្គុទេសក៍ណែនាំមួយចំនួនសម្រាប់អ្នកនិពន្ធ និងអ្នកទាំងឡាយដែលទទួលខុសត្រូវលើទំព័រទាំងនោះ៖

## ការគិតអំពីបទវិចារណកថា

១. អាផ្សា និងជំនាញ មានសារៈសំខាន់ តែវាមិនទាន់គ្រប់គ្រាន់ទេ។ អ្នកដែលសរសេរអត្ថបទសម្រាប់ចុះក្នុងទំព័រទាំងនេះ ត្រូវតែចេះសរសេរឲ្យបានច្បាស់សាមញ្ញ និងឲ្យគេចាប់អារម្មណ៍ចង់អាន។ មានសាស្ត្រាចារ្យ មន្ត្រីជាន់ខ្ពស់ អ្នកការទូត ធុរជន សេដ្ឋកិច្ចវិទូ និងអ្នកនយោបាយច្រើននាក់ ដែលមិនចេះសរសេរឲ្យបានល្អ ងាយយល់ដូចអ្នកឯទៀត។

២. បើគ្រាន់តែថាអ្វីមួយសំខាន់វាមិនមែនមានន័យថា អ្វីៗដែលគេសរសេរអំពីវាសុទ្ធតែជាទីចាប់អារម្មណ៍ដល់អ្នកអាននោះឡើយ។ គេត្រូវតែមានហេតុផលច្បាស់លាស់សម្រាប់ចុះផ្សាយអត្ថបទមួយ៖ វាអាចថាមានអ្វីមួយកើតឡើង ដែលតម្រូវឲ្យគេដាក់វាទៅក្នុងរបៀបវារៈមួយសម្រាប់អ្នកអានដែលកំពុងតាមដានបញ្ហាធំដុំ ដែលគេចាប់អារម្មណ៍។ តែប៉ុណ្ណឹងក៏ដោយ ក៏វាមិនទាន់គ្រប់គ្រាន់ទេ។ អត្ថបទនោះត្រូវតែនិយាយអំពីអ្វីមួយថ្មី ឬក៏និយាយអំពីរឿងចាស់នោះតាមបែបមួយថ្មី។ សេចក្តីសង្ខេបអំពីរបាយការណ៍ពីសិក្ខាសាលា ឬសុន្ទរកថា មិនអាចគ្រប់គ្រាន់នឹងធ្វើឲ្យទៅជាអត្ថបទយកទៅចុះក្នុងទំព័រ op-ed បានទេ។

៣. ទោះជាអ្វីមួយដែលមិនសំខាន់ក៏ដោយ ក៏វាអាចស័ក្តិសមនឹងត្រូវបានគេយកមកចុះផ្សាយលើទំព័រនេះដែរ ពីព្រោះវាគួរឲ្យចាប់អារម្មណ៍គួរឲ្យកំសាន្តរីករាយគាត់តែងបានល្អ ឬមួយវាគួរឲ្យអស់សំណើច។ បើសិនជានិពន្ធនាយក និងអ្នកនិពន្ធនឹក

ឃើញដល់អ្នកអានរបស់ខ្លួន ពួកគេពិតជានឹងដឹងបានថា តើអ្នកអានរបស់ខ្លួនចង់បានអត្ថបទបែបណាខ្លះយកទៅអានជាមិនខាន។

៤. បើអ្នកជានិពន្ធនាយកទំព័រ op-ed សូមពិចារណាមើលអំពីល្បាយអត្ថបទក្នុងទំព័ររបស់អ្នក។ ឧទាហរណ៍ ក្នុងទំព័រនោះ បើមានអត្ថបទតែមួយនិយាយអំពីរឿងកិច្ចការបរទេសវាគ្រប់គ្រាន់ណាស់ទៅហើយ។ ដូចគ្នាដែរជាមួយប្រធានបទដទៃទៀត ដូចជា ធុរកិច្ច សេដ្ឋកិច្ច បរិស្ថាន ឬសាសនា។ បើសិនជាអ្នកមានលំហក្នុងទំព័រសម្រាប់អត្ថបទបី ឬក៏បួន ចូរធ្វើយ៉ាងណាកុំឲ្យអត្ថបទទាំងនោះមានប្រធានបទជាន់គ្នា។ និពន្ធនាយកចំណានៗ តែងក្រឡេកមើលក្នុងបញ្ជីអត្ថបទ ហើយសួរខ្លួនឯងថា តើបញ្ជីនេះមានភាពចម្រុះគ្រប់គ្រាន់សម្រាប់អ្នកអានជ្រើសរើស ឬទេ?

## សរសេរបទវិចារណកថា

មានអ្នកយកព័ត៌មានតិចណាស់ ដែលអាចសរសេរវិចារណកថាបានល្អ ពីព្រោះពួកគេថ្នឹកនឹងការដាក់ខ្លួនគេឲ្យនៅក្រៅសាច់រឿងទៅហើយ។ តាមរយៈនេះ ពួកគេទុកឲ្យព័ត៌មាន និងសម្លេងរបស់មនុស្សដទៃលេចធ្លោទៅវិញ។ បទវិចារណកថាវាផ្ទុយពីនេះ ដោយវាតម្រូវឲ្យសម្លេងរបស់អ្នកនិពន្ធលេចធ្លោទៅវិញ។

យ៉ាងណាក្តី មានភាពស្រដៀងគ្នាមួយចំនួនក្នុងការសរសេរបទវិចារណកថា និងប្រភេទអត្ថបទដទៃទៀតក្នុងវិស័យសារព័ត៌មាន។ ឧទាហរណ៍ ក្នុងការសរសេរបទវិចារណកថា គួរដាក់អ្វីដែលសំខាន់ជាងគេនៅខាងលើបំផុត ព្រោះធ្វើដូច្នេះវាជួយបញ្ជាក់ឲ្យគេដឹងច្បាស់ថា តើអត្ថបទនេះនិយាយអំពីអ្វី ដើម្បីទាក់ទាញការចាប់អារម្មណ៍របស់អ្នកអាន។ ខាងក្រោមជាការណែនាំមួយចំនួន៖

១. ផ្តោតលើ**បញ្ហាមួយ**បានហើយ ៗសរសេរលេចវាឲ្យបានច្បាស់។ បទវិចារណកថាជាច្រើនៗបរាជ័យ ដោយសារវាព្យាយាមពិភាក្សាបញ្ហាច្រើនពេកក្នុងពេលតែមួយ។

២. ផ្តើមដោយសរសេរប្រាប់អ្នកអាននូវសេចក្តីសន្និដ្ឋាន ឬការយល់ឃើញរបស់អ្នកអំពីបញ្ហា ដែលអ្នកលើកយកមកសរសេរ។ បង្ហាញគេថាអ្នកដឹងថាអ្នកកំពុងនិយាយអំពីអ្វីពីដើមទីតែម្តង មិនមែនព្រាវៗថានឹងឈានទៅដល់សេចក្តីសន្និដ្ឋានណាមួយនោះទេ។ ចៀសវាងការចាប់ផ្តើមយឺតៗ មុននឹងឈានដល់ការធ្វើទឡ្ហីករណ៍ សូមនិយាយឲ្យចំបញ្ហាតែម្តង។

៣. បង្ហាញនៅខាងលើឲ្យច្បាស់ថាហេតុអ្វីបានជាអ្នកសរសេរអំពីបញ្ហាមួយនេះ ៖ តើមានព្រឹត្តិការណ៍ថ្មីមួយអាចនឹងកើតឡើងនៅពេលខាងមុខ? តើនឹងមានការសិក្សាស្រាវជ្រាវថ្មី?

៤. សួរខ្លួនឯងថា ហេតុអ្វីបានជាអ្នកអានគួរខ្វល់ខ្វាយនឹងរឿងនេះ? អ្នកត្រូវតែឆ្លើយទៅនឹងសំណួរនេះ ដើម្បីឲ្យអ្នកអានយល់ ហើយបើគេយល់ គេនឹងយកចិត្តទុកដាក់អាន។

៥. សរសេរក្នុងរបៀបមួយដូចអ្នកកំពុងអង្គុយនិយាយទៅកាន់អ្នកណាម្នាក់ដោយផ្ទាល់អញ្ចឹង។ ប្រើភាសាសាមញ្ញ និងឧទាហរណ៍ខ្លីៗ។ កន្លែងណាធ្វើបាន គួរប្រើការលេបខាយកំប្លែង តែក្នុងន័យសមរម្យ។

៦. កុំចំណាយពេលច្រើនក្នុងការ និយាយថាឡើងវិញនូវទស្សនៈរបស់អ្នកដទៃ។ សង្ខេបវាទៅបានហើយ ។ជំនួសវាដោយភស្តុតាង និងហេតុផល រួមមានអ្វីដែលអ្នកដឹងផ្ទាល់។ ចូរពិចារណាប្រើរឿងរ៉ាវរបស់បុគ្គលណាមួយជាករណីសិក្សា ដើម្បីរំលេចភស្តុតាងក្នុងទស្សនៈ។

៧. និយាយឲ្យច្បាស់នូវ **អ្វីដែលគេគួរចាត់ការ ឬធ្វើបន្តទៀត**។ ជារឿយៗ ទស្សនៈទៅជាអត់ន័យទៅវិញ ពីព្រោះពេលដែលអត្ថបទចូលដល់ទីបញ្ចប់ អ្នកអាន ឬអ្នកស្តាប់ និយាយថា៖ អូខេ ការរិះគន់នេះល្អណាស់ ប៉ុន្តែតើអ្នកគិតថាគួរធ្វើយ៉ាងម៉េចទៀត?

៨. **ថាឡើងវិញ**នូវអ្វីដែលអ្នកនិយាយរួចហើយនៅខាងដើម តែដោយប្រើពាក្យផ្សេងក្នុងរបៀបមួយ ដែលធ្វើឲ្យអ្នកអានចងចាំនឹកឃើញអត្ថបទនេះ។

ខាងក្រោមជាឧទាហរណ៍មួយនៃវិចារណកថា ដែលនិយាយចំបញ្ហា ដែលត្រូវបានដកស្រង់ចេញពីកាសែត Thanh Nien នៅវៀតណាម គឺវានិយាយតែអំពី **បញ្ហាមួយ** នឹងលើកជាអនុសាសន៍ថា តើគេគួរធ្វើយ៉ាងម៉េចទៀត៖

*សេចក្តីផ្តើមសាមញ្ញ និងឲ្យជាសញ្ញាថា យើងគួរយកចិត្តទុកដាក់អានតទៅទៀត។ សេចក្តីផ្តើមមានភាពសាមញ្ញច្បាស់ ហើយស្តាប់ទៅដូចសេចក្តីសន្និដ្ឋានអញ្ចឹង។*

*ត្រង់នេះគេពិនិត្យមើលនូវអ្វីដែលគេបានចាត់ការកន្លងមក។*

***វិស័យដែលអាចសង្គ្រោះយើងទាំងអស់គ្នា***

***ដោយ Nguyen Van My***

*នៅក្នុងពេលលំបាកដូចបច្ចុប្បន្ននេះ វិស័យទេចរណ៍អាចជា "អ្នកសង្គ្រោះ" ផ្នែកសេដ្ឋកិច្ចរបស់ប្រទេសវៀតណាម ដោយនាំមកនូវប្រាក់ចំណូល និងលើកស្ទួយមុខមាត់ប្រទេសក្នុងពេលតែមួយ។*

*មកទល់ពេលនេះ ការិយាល័យទេសចរណ៍ជាន់ខ្ពស់របស់ប្រទេសបានសម្រេចបានវិធានការជឿនលឿនមួយចំនួន ដូចជារៀបចំសន្និសីទដែលប្រមូលផ្តុំការជួបជុំឯកទេសទេសចរណ៍ រៀបចំកិច្ចប្រជុំក្នុងបណ្តារដ្ឋបាលខេត្តនានា ដើម្បីជំរុញកិច្ចសហប្រតិបត្តិការផ្នែកទេសចរណ៍ និងកំណត់គោលដៅទេសចរណ៍ចុះតម្លៃ ១០០ កន្លែង នៅទូទាំងប្រទេសជាផ្នែកនៃយុទ្ធនាការទូលំទូលាយមួយ ធ្វើឲ្យវិស័យនេះរស់ឡើងវិញ។*

*ប្រទេសដទៃទៀតក៏យល់ឃើញដែរថា ជំរុញឧស្សាហកម្មទេសចរណ៍អាចជាគន្លឹះទប់ស្កាត់ការធ្លាក់ចុះសេដ្ឋកិច្ចផងដែរ។*

*ឃ្លានេះខ្លី ហើយច្បាស់ចាប់ផ្តើមពិភាក្សាករណីសិក្សាមួយ ដោយផ្តែកលើភស្តុតាង។*

ចូរក្រឡេកមើលថៃ ប្រទេសជិតខាងយើង។

បន្ទាប់ពីការដកថយរបស់ក្រុមបាតុករ ដែលបានបង្កឲ្យមានការអាក់ខានប្រតិបត្តិការព្រលានយន្តហោះអន្តរជាតិរបស់ប្រទេសអស់ជាងមួយសប្តាហ៍រួចមក ក្រសួងទេសចរណ៍ថៃធ្វើយុទ្ធនាការមួយមានឈ្មោះថា "ប្រទេសថៃសូមអភ័យទោស" (Apologies Thailand) ក្នុងកិច្ចខិតខំបែចង់អូសទាញពួកទេសចរដែលខកចិត្តឲ្យត្រឡប់មកទស្សនាប្រទេសថៃវិញ។

*គោលគំនិតសំខាន់ត្រូវបានលើកយកមកបង្ហាញម្តងទៀត បន្ទាប់ពីករណីសិក្សា។*

ក្នុងយុទ្ធនាការនេះ តម្លៃទួរស៍ទស្សនាប្រាំមួយថ្ងៃ គឺត្រឹមតែ ៣០០ ដុល្លារអាមេរិកតែប៉ុណ្ណោះ ហើយក្រៅពីនោះ នៅមានសំបុត្រយន្តហោះឥតគិតថ្លៃ ១០០.០០០ សំបុត្រ និងប្រយោជន៍ជាច្រើនទៀតដល់ពួកទេសចរ។

ទោះជាប្រទេសវៀតណាមមិនធ្លាប់ជួបប្រទះវិបត្តិនយោបាយបែបនេះក៏ដោយ ក៏យើងត្រូវតែចាត់វិធានការ ដើម្បីទាក់ទាញទេសចរណ៍ក្នុងពេលនេះ និងទៅអនាគត។

*ប្រយោគយ៉ាងសាមញ្ញមួយទៀត រាយនាមនូវសកម្មភាពដែលគេគួរធ្វើ។*

មានវិធីច្រើនដែលអាចធ្វើដូច្នេះបាន។

មន្ត្រីគយរបស់យើងគួរបង្ហាញមុខញញឹមជាងមុន។ ទឹកមុខញញឹមនៅច្រកអន្តោប្រវេសន៍ អាចមានឥទ្ធិពលខ្លាំងក្នុងការលើកមុខមាត់ប្រទេសថាជាកន្លែងមួយមានភាពស្វាគមន៍មេត្រីដល់ភ្ញៀវ។

សណ្ឋាគារ និងភោជនីយដ្ឋាន អាចធ្វើការបញ្ចុះតម្លៃបន្ថែម។ មានសណ្ឋាគារធំៗខ្លះ តម្រូវឲ្យក្រុមហ៊ុនទេសចរណ៍បង់ប្រាក់តំកល់ ដើម្បីកក់បន្ទប់ទុក។

យើងអាចផ្តួចផ្តើមឲ្យមានវេទិកាទូទាំងប្រទេសមួយ ដើម្បីជាឱកាសដល់អ្នកពាក់ព័ន្ធទាំងអស់ លើកសំណូមពរសម្រាប់ធ្វើការកែលំអវិស័យទេសចរណ៍របស់វៀតណាម។

ដំណោះស្រាយមួយទៀត អាចជាយុទ្ធនាការលើកទឹកចិត្តពលរដ្ឋឲ្យសម្អាតភូមិដ្ឋានរបស់ខ្លួន ក៏ដូចជាចូលរួមសហការក្នុងការកាត់បន្ថយចំនួនអ្នកសុំទាន ចោរលួចហោប៉ៅ និងអ្នកលក់ដូរតាមចិញ្ចើមថ្នល់ ដែលបួលចិត្តរំខានអ្នកទេសចរខ្លាំង។

*តួលេខសាមញ្ញតែសំខាន់សម្រាប់គោលគំនិតដែលជាទឡ្ហីករណ៍។*

*ក្នុងឆ្នាំនេះ មានអ្នកទេសចរ ៤ លាននាក់ប៉ុណ្ណោះ មកទស្សនាប្រទេសវៀតណាម បើប្រៀបធៀបនឹង ១៤ លាន ទៅប្រទេសថៃ ១៨ លាន ទៅប្រទេសម៉ាឡេស៊ី និងជិត ៩ លាននាក់ ទៅប្រទេសសឹង្ហបុរី។ បួនលាននាក់ជាចំនួនមួយមិនច្រើនណាស់ណាទេក្នុងបរិបទនេះ។*

*ជាឡើងវិញនូវគោលគំនិតដែលផ្សាភ្ជាប់ទៅនឹងទឡ្ហីករណ៍។*

*បើយើងមិនចាត់វិធានការផ្ទេរនេះទេ វានឹងស៊ីពេលយូរណាស់សម្រាប់យើងតាមឲ្យទាន់ប្រទេសជិតខាងក្នុងតំបន់ ដោយមិនបាច់និយាយដល់ការប្រើប្រាស់វិស័យទេសចរណ៍ សម្រាប់ទប់ស្កាត់ការធ្លាក់ចុះសេដ្ឋកិច្ចផង។*

## វេទិកាស្មេរ (Columns)

ការសរសេរសម្រាប់វេទិកាស្មេរ ជាការងារដ៏គួរឲ្យពេញចិត្តមួយក្នុងមុខរបរសារព័ត៌មាន។ តាមរយៈវេទិកាស្មេរ អ្នកអាចចែករំលែកគំនិតរបស់អ្នកជាមួយមនុស្សរាប់ពាន់រាប់លាននាក់។ អ្នកអាចសរសេរក្នុងស្ទីលម៉ឺងម៉ាត់ វិភាគ ឬចំអកលែបខាយ (satirical)។ អ្នកអាចយកស្ទីលដែលអ្នកសរសេរអត្ថបទពិពណ៌នា ឬបទអត្ថាធិប្បាយមកប្រើក៏បាន។ ជួនកាល គេអាចនឹងចុះរូបថតរបស់អ្នកភ្ជាប់ជាមួយនឹងអត្ថបទនោះផងដែរ។

គេឲ្យឈ្មោះវាថា វេទិកាស្មេរ ដោយសារថាអត្ថបទប្រភេទនេះជាប្រពៃណី ច្រើនត្រូវបានគេចុះផ្សាយក្នុងខ្ទង់តែមួយវែងត្រង់ពីលើចុះក្រោម។ ខ្ទង់របៀបនេះ គេច្រើនប្រគល់ឲ្យអ្នកសរសេរដែលមានថ្វីដៃខ្ពស់ ឬបើមិនដូច្នេះទេ ឲ្យទៅអ្នកយកព័ត៌មានបទពិសោធន៍ជើងចាស់ និងពុទ្ធិជ្រៅជ្រះអំពីបញ្ហានានា។ បើនិយាយអំពីវដ្តនៃការចេញផ្សាយវិញ អត្ថបទវេទិកាស្មេរ តែងត្រូវបានចុះផ្សាយនៅថ្ងៃទៀងទាត់ប្រចាំសប្តាហ៍ ដែលងាយដល់អ្នកអានដឹង និងតាមដានកុំឲ្យអាក់ខាន។ អ្នកនិពន្ធវេទិកាស្មេរតាមធម្មតា ជាមនុស្សមានឯកទេសក្នុងវិស័យដូចជា នយោបាយ ភាពយន្ត បរិស្ថាន តែក៏មានអ្នកសរសេរខ្ទង់ទស្សនៈដែលជំនាញទូទៅ ហើយសរសេរគ្រប់មុខដែរ។ អ្នកនិពន្ធវេទិកាស្មេរ មានថ្វីដៃពូកែ អត្ថបទរបស់គេច្រើនត្រូវបានគេយកទៅចុះផ្សាយមិនមែនត្រឹមក្នុងកាសែតតែមួយទេ តែក្នុងកាសែតឬបណ្តាញផ្សព្វផ្សាយព័ត៌មានជាច្រើនជុំវិញពិភព-លោក។ នេះគេឲ្យឈ្មោះថា អ្នកនិពន្ធវេទិកាស្មេរស៊ីនឌីខិត (syndicated columnists)។

វេទិកាស្មេរ មិនមែនមានតែក្នុងទំព័រអត្ថាធិប្បាយទេ។ វាអាចមានក្នុងទំព័រអត្ថបទពិពណ៌នា អត្ថបទរឿងធុរកិច្ច ឬអត្ថបទរឿងកីឡា ក៏ថាបាន។ និយាយសរុបមក អ្នកនិពន្ធវេទិកាស្មេរមានច្រើនប្រភេទ រាប់តាំងពីអ្នកសរសេរអំពីអាហារដល់អ្នកនិពន្ធរឿងសំណើច។

## វិះគិតអំពីអត្ថបទសំរាប់វេទិកាស្មេរ

ដូចគ្នានឹងអត្ថបទពិពណ៌នា និងបទអត្ថាធិប្បាយដែរ អត្ថបទវេទិកាស្មេរល្អមួយ វាផ្តើមចេញពីគំនិតក្នុងសាច់រឿង។ អត្ថបទវេទិកាស្មេរណាដែលផ្តោតលើបញ្ហាច្បាស់លាស់ ប្រើឧទាហរណ៍ ឬការប្រៀបធៀប គឺជាអត្ថបទល្អបំផុត ព្រោះវាជួយឲ្យអ្នកអានយល់សាច់រឿងបាន។ អ្នកមិនអាចសរសេរអំពី

"គុណភាពអប់រំ" បានទេ ពីព្រោះប្រធានបទនេះវាធំទូលំទូលាយពេក ហើយអ្នកមានលំហខ្ទង់សម្រាប់ដាក់បានតែ ៨០០ ពាក្យអង់គ្លេស ឬតិចជាងនេះតែប៉ុណ្ណោះ។ យកល្អ បង្រួមការផ្តោតរបស់អ្នកទៅលើជ្រុងណាមួយនៃបញ្ហា ដែលអ្នកអាចលៃលកបាត់បែងបានមិនពិបាកខ្លាំង ដូចជាបញ្ហាដែលគ្រូមិនបានទទួលបៀវត្សរ៍គ្រប់គ្រាន់ ឬក៏អំពីសាលារៀនដែលមានក្មេងជាសិស្សជាងពាក់កណ្តាលដែលមិនចេះអាន។

បើទោះជាថាអ្នកមានសេរីភាពក្នុងការចែករំលែកមតិយោបល់របស់ខ្លួនដល់អ្នកដទៃ វាមិនមែនមានន័យថា អ្នកចេះតែសេរីក្នុងការនិយាយអ្វីដែលអ្នកនឹងឃើញចង់និយាយនោះទេ។ លោក កាវី ចុងគីតាវ៉ន (Kavi Chongkittavorn) របស់កាសែត The Nation (Bangkok) ដែលនិពន្ធអត្ថបទវេទិកាស្នេរ និងបទអត្ថាធិប្បាយរាប់មិនអស់លើបញ្ហានយោបាយថៃ និងបញ្ហាតំបន់ និយាយថា៖ "អ្នកសរសេរ ត្រូវមានភាពសមរម្យប្រកបដោយគុណធម៌ និងសេចក្តីទៀងត្រង់ផងដែរ"។ ហើយអ្នកក៏ត្រូវតែប្រយ័ត្នប្រយែង កុំទៅសរសេរ **បង្ខូចកេរ្តិ៍** ឬ **មួលបង្កាច់** អ្នកណាមួយឲ្យសោះ *[សូមមើលជំពូកទី ១១: អ្នកសារព័ត៌មាន និងច្បាប់]*។

ម្យ៉ាងវិញទៀត អ្នកចាំបាច់ត្រូវតែធ្វើការស្រាវជ្រាវដោយខ្លួនឯងផងដែរ ដើម្បីយកភស្តុតាងរឹងមាំមកគាំទ្រដល់គំនិតដែលអ្នកលើកមកពិភាក្សាក្នុងអត្ថបទ។ អ្នកនិពន្ធវេទិកាស្នេរអានច្រើនណាស់ ហើយក៏មានពុទ្ធិទូលំទូលាយដែរ។ លោក កាវី និយាយថា គាត់ចំណាយ ៤ ទៅ ៥ ម៉ោង ក្នុងមួយថ្ងៃ ដើម្បីអានកាសែតនៅលើអ៊ិនធឺណិត។ អ្នកនិពន្ធវេទិកាស្នេរក៏ប្រមូលព័ត៌មានដោយខ្លួនឯងដែរពីគ្រប់ជ្រុងដែលពាក់ព័ន្ធក្នុងរឿង ដោយចេញពីការិយាល័យទៅសង្កេតព្រឹត្តិការណ៍រាល់ពេលតាមតែអាចធ្វើទៅបាន។

ចូរកុំជាប់ផុងក្នុងសាវតារ និងសេចក្តីក្បោះក្បាយច្រើនពេក។ ប្រើតែល្មមនឹងសេចក្តីត្រូវការរបស់អ្នកអាន ដើម្បីយល់នូវគោលគំនិតដែលអ្នកចង់និយាយបានហើយ។ ការស្រាវជ្រាវវាជួយឲ្យអ្នកនិយាយទៅកាន់អ្នកអានក្នុងន័យមួយជាមនុស្សជំនាញការ។

ទោះជាអ្នកសរសេរពីស្អីក៏ដោយ ចូររំពឹងទុកថានឹងមានគេទិតៀនជាមិនខាន។ មតិយោបល់ដែលមានអានុភាពខ្លាំង វាក៏នឹងនាំមកវិញនូវប្រតិកម្មខ្លាំងពីអ្នកវិញដែរ។ ដូច្នេះ អ្នកត្រូវមានភាពអត់ធ្មត់ទទួលយកការរិះគន់ទាំងនោះ។

## និពន្ធអត្ថបទសម្រាប់វេទិកាស្នេរ

វេទិកាស្នេរមានច្រើនសណ្ឋានដូចអក្សរសិល្ប៍ដែរ។ អ្នកនិពន្ធខ្លះទស្សនៈប្រើតិចនិកចម្រុះរាប់មានស្ទីលអត្ថបទពិព័ណនា និងស្ទីលវិភាគដំណឹង។ អ្នកខ្លះសរសេរក្នុងនាមបុគ្គលទីមួយ ឬមួយក៏សរសេរដោយដាក់ចំណុចគោលនៃគំនិតនៅឯចុង មិនមែនខាងដើមនៃអត្ថបទទៅវិញ។ ពួកគេហាក់ដូចគ្មានវិធានដែលត្រូវតែដើរតាមនោះទេ។ អ្នកខ្លះហ៊ានរហូតទៅដល់បង្កើតជាតួអង្គប្រលោមលោក ប៉ុន្តែគេត្រូវការប្រុងប្រយ័ត្នជាមួយនឹងការប្រើស្ទីលរបៀបនេះ ហើយគេត្រូវតែបញ្ជាក់ឲ្យអ្នកអានដឹងផងដែរថា តួអង្គក្នុងអត្ថបទមិនមែនជាមនុស្សពិតប្រាកដទេ។

មធ្យោបាយមួយក្នុងការធ្វើខ្លួនឲ្យក្លាយទៅជាអ្នកនិពន្ធវេទិកាស្នេរល្អមួយរូប អ្នកត្រូវរៀនសូត្រអំពីអ្នកនិពន្ធណាដែលអ្នកស្ញប់ស្ញែងបំផុត។ តើអ្វីជាស្ទីលរបស់គេ? តើគេប្រឡូកអ្នកអាន និងបញ្ចុះ-បញ្ចូលពួកគេអំពីគោលគំនិតក្នុងអត្ថបទដោយវិធីណា? សាកប្រើតិចនិកដូចគ្នានេះនៅក្នុងការសរសេររបស់អ្នករហូតដល់អ្នកអាចអភិវឌ្ឍន៍នូវ **ស្ទីល** និង **សម្លេង** មួយ ដោយឡែករបស់ខ្លួន។

អ្វីក៏ដោយដែលអ្នកនិយាយក្នុងអត្ថបទ ចូរនិយាយឲ្យសុទ្ធចិត្ត។ លោក ការី និយាយថា៖ "ពេលដែលអ្នកសរសេរ អ្នកត្រូវតែសរសេរដោយភាពត្រេកត្រអាល។ និយាយឲ្យពេញទំហឹង បើមិនដូច្នោះទេ កុំសរសេរល្អជាង"។ ខាងក្រោមនេះជាសេចក្តីផ្តើមមួយនៃអត្ថបទមួយរបស់លោក ការី ស្តីពីផែនការកិច្ចប្រជុំកំពូលមួយរបស់សមាគមអាស៊ាន។ ចូរសំគាល់នូវពាក្យពេចន៍ខ្លាំងៗ និងសេចក្តីអំពាវនាវឲ្យមានវិធានការនៅក្នុងប៉ុន្មានពាក្យដំបូងនៃសេចក្តីផ្តើមរបស់គាត់៖

*ប្រទេសថៃ* ***ត្រូវតែផ្អាក****ដឹកនាំកិច្ចប្រជុំអាស៊ានដែលគេបានគ្រោងធ្វើនៅថ្ងៃទី ១៥-១៨ ធ្នូ ខាងមុខនេះ ដោយសារតែវិបត្តិនយោបាយបច្ចុប្បន្នរបស់ខ្លួន។ ការដែលគ្មានសេចក្តីសម្រេចចិត្តក្នុងរង្វង់ប៉ុន្មានម៉ោងខាងមុខនេះ នឹងកាន់តែធ្វើឲ្យខូចខាតថែមទៀតដល់មុខមាត់ប្រទេស និងកេរ្តិ៍ឈ្មោះរបស់អាស៊ានទៀតផង។*

លោក ការី និយាយថា គាត់សាកល្បងផ្តើមជាមួយនឹងសេចក្តីថ្លែងគួរឲ្យរន្ធត់មួយ តែគាត់ដូរចិត្តដោយទទួលស្គាល់នូវទស្សនៈ ដែលមានអានុភាពខ្លាំងទល់នឹងគោលគំនិតរបស់គាត់ ហើយនេះបង្ហាញដល់អ្នកអានឲ្យឃើញថា គាត់បានធ្វើកិច្ចការជាបឋមរួចហើយមុននឹងសរសេរ។ ក្នុងតួអត្ថបទ គាត់រក្សាទស្សនៈខ្លាំងបំផុតទុកនៅខាងចុងក្រោយគេបង្អស់។ គាត់មិនចង់ទុកបំណុចទន់ជ្រាយនៅខាងចុងឲ្យអ្នកអានទេ។ គាត់បញ្ចប់អត្ថបទជាមួយនឹងការអំពាវនាវឲ្យបាត់វិធានការ លទ្ធភាព ដំណោះស្រាយមួយ ឬទស្សនៈសម្រាប់អនាគត។

ខាងក្រោមនេះមួយទៀត ជារបៀបច្នៃប្រឌិតមួយដែលសហសេវិករបស់លោក ការី គឺនាង ជីរ៉ាវ៉ាត់ណា ថាឡាង (Jeerawat Na Thalang)។ នាងសាកប្រមើលមើលថា តើលោក ថាក់ស៊ីន ស៊ីណាវ៉ាត្រា (Thaksin Shinawatra) អតីតនាយករដ្ឋមន្ត្រីថៃ ដែលរស់នៅក្នុងនិរទេស និងដែលជាប៉ៅកែទូរគមនាគមន៍មួយរូប នឹងនិយាយទៅកាន់អ្នកគាំទ្ររាប់សិបពាន់អ្នកតាមទូរស័ព្ទ បន្ទាប់ពីសម្ព័ន្ធដៃគូរបស់គាត់មួយចំនួនបានបោះបង់លែងគាំទ្ររូបគាត់ទៀតហើយនោះ។ ក្នុងការសរសេរ នាងរៀបចំឆាកមួយសម្រាប់"សុន្ទរកថា" ដោយមានមនុស្សម្នាក់កំពុងសាកប្រព័ន្ធសម្លេង។

*នេះ គឺជាអ្វីដែលនឹងកើតមានថ្ងៃនេះ នៅកីឡាដ្ឋាន Supachalasia National Stadium របស់ក្រុងបាងកក៖*

*សម្លេង ប៊ីប...ប៊ីប...តេស្ត...តេស្ត*

*បងប្អូនទាំងអស់គ្នា,*

*បន្ទាប់ពីខ្ញុំទូរស័ព្ទចូលមកពីលើកមុន ខ្ញុំទទួលបានទូរស័ព្ទជាច្រើនពីអ្នកគាំទ្ររបស់ខ្ញុំ សូមឲ្យខ្ញុំធ្វើការសោសងទូរស័ព្ទម្តងទៀត។ អ្នកគាំទ្រខ្លះទៀតថែមទាំងបានផ្ញើសារមកខ្ញុំដោយសរសេរថា "ថាក់ស៊ីន សូមម្តងទៀត"។ មានក្រុមមួយឈ្មោះថា "នារីថាក់ស៊ីន" បានផ្ញើវីឌីអូឃ្លីបដែលមានភ្ជាប់ក្នុងនោះនូវចម្រៀងរបស់ Britney Spears ដែលមានចំណងជើងថា “Hit Me One More Time”។ ឱលោកអើយ! តើខ្ញុំត្រូវពន្យល់ដល់លោកស្រី Khunying Pojaman (អតីតភរិយារបស់គាត់) ទេថាខ្ញុំ អត់មានបានធ្វើការឆ្លើយឆ្លងចូលតាមទូរស័ព្ទណាទៀតទេ ក្រៅតែការឆ្លើយឆ្លងមួយនៅកីឡាដ្ឋាន Rajamangala Stadium កាលពីខែមុននោះ។ អ្នកខ្លះនិយាយថា សាររបស់ខ្ញុំក្នុងការឆ្លើយឆ្លងសន្ទនានោះ ដូចជាស្លឹកៗខ្វះទឹកដម។ ខ្ញុំមិនដែលគិតដល់ថា អ្នកគាំទ្ររបស់ខ្ញុំនឹងមិននឹកសរសើររូបខ្ញុំសោះក្នុងខែនេះ ដូច្នេះ ខ្ញុំសម្រេចចិត្តថានឹងធ្វើការសន្ទនាតាមទូរស័ព្ទម្តងទៀត។*

ក្នុងសុន្ទរកថាស្រមៃមួយនេះ នាង ជីរ៉ាវ៉ាត់ បានសរសេរនូវអ្វី ដែលនាងគិតថា លោក ថាក់ស៊ីន នឹងនិយាយ គឺគាត់ចំអកឡកឡឺយដាក់សត្រូវនយោបាយរបស់គាត់ការពារខ្លួនគាត់ទល់នឹងការចោទស្តីពីអំពើពុករលួយ និងអត្ថាធិប្បាយលើភាពវឹកវរនយោបាយរបស់ប្រទេសថៃ។ អ្នកអានដឹងបានថា លោកថាក់ស៊ីន មិនបាននិយាយដូច្នេះទេ តែនេះជារបៀបមួយគួរឲ្យចង់សើច ដែលនាង ជីរ៉ាវ៉ាត់ បានយកប្រើ ដើម្បីរំលេចគោលគំនិតរបស់នាងទាក់ទិននឹងស្ថានភាពនយោបាយក្នុងស្រុក។

នាងបញ្ចប់អត្ថបទវេទិកាស្មេរនេះដូច្នេះ៖

*ពិតណាស់ មនុស្សខ្លះមិនសប្បាយចិត្តនឹងអានថាប្រទេសថៃជាប្រជាជាតិ គួរឲ្យ #s@@!! ភ័យខ្លាច។ តែវាមិនមែនជាកំហុសរបស់ខ្ញុំទេ។ អាចថាអ្នកគាំទ្រខ្ញុំ គាត់ស្រវឹងពេលដែលគេនិយាយទៅកាន់ជនបរទេសថា លើកលែងរូបខ្ញុំម្នាក់ចេញអ្វីៗនៅប្រទេសថៃដូចជាមិនសូវល្អប៉ុន្មានទេ។ ហើយគួរឲ្យភ្ញាក់ផ្អើល ពួកបរទេសទាំងនោះជឿ។ ខ្ញុំមិនដែលគិតថា ពួកបរទេសងាយនឹងជឿដូច្នេះសោះ។*

Zzzz...*ស៊ីញ៉ាល់ដាច់...*

*ហេឡូ... ឮខ្ញុំនិយាយទេ។ ឱលោកអើយ!* ខ្ញុំត្រូវតែនិយាយថា ប្រព័ន្ធទូរស័ព្ទចល័តនេះកាន់តែអន់ទៅៗមែនទែនតាំងតែពីខ្ញុំបានលក់វាចេញទៅ។

ជាទូទៅ មគ្គុទ្ទេសក៍ដែលគេប្រើសម្រាប់សរសេរអត្ថបទអត្ថាធិប្បាយ ក៏យកមកប្រើបានដែរក្នុងការសរសេរខ្ទង់ទស្សនៈ ក្នុងនោះ គឺការបញ្ចេញគោលគំនិតច្បាស់ ផ្តោតឲ្យចំបែបសន្ទនា តែឲ្យវាទាក់ទិនទៅនឹងបរិបទ។ ចូរលើកអ្វីថ្មីក្នុងការជជែកវែកញែក ហើយប្រើភាពច្នៃប្រឌិតក្នុងការសរសេរ។

ខាងក្រោមជាឧទាហរណ៍ពីកាសែត Bangkok Post ថ្ងៃអាទិត្យ ដែលសរសេរដោយអ្នកនិពន្ធខ្ទង់ទស្សនៈដ៏ចំណានម្នាក់ឈ្មោះ វរ៉ាណៃ វ៉ានីចាកា (Voranai Vanijaka)។ វាត្រូវបានសរសេរឡើងក្នុងអំឡុងពេលដែលវិបត្តិនយោបាយថៃ កាន់តែមានភាពតានតឹងឡើងៗនៅឆ្នាំ ២០០៨ ពេលដែលក្រុមបាតុករទាមទារឲ្យរដ្ឋាភិបាលលោកនាយករដ្ឋមន្ត្រី សាម៉ាក់ ស៊ុនដារ៉ាវេជ (Samak Sundaravej) ចុះចេញពីតំណែង។ ពួកបាតុករនិយាយថា លោក សាម៉ាក់ និង ឧទ្ទកាល័យរដ្ឋមន្ត្រីរបស់គាត់តំណាងឲ្យផលប្រយោជន៍របស់លោក ថាក់ស៊ីន ស៊ីណាវ៉ាត្រា ដែលគេបានទំលាក់ពីតំណែងនាយករដ្ឋមន្ត្រីហើយនោះ។ វាជាអត្ថបទគួរឲ្យរំជួលចិត្តមួយ ដែលក្នុងនោះបង្ហាញអ្នកនយោបាយ ចង្អុលបន្ទោសកំហុសដាក់គ្នាទៅវិញទៅមក។



*ចង្វាក់ជីវិតប្រចាំថ្ងៃមានសភាពខុសគ្នាពីកន្លែងមួយទៅកន្លែងមួយ។*

## ផ្ទាំងកញ្ចក់ឆ្លុះមុខ ៦០ លាន នាក់

*ការចាប់ផ្តើមដ៏ល្អចេញពីរឿងបុគ្គល ដោយមានការរៀបរាប់ក្នុងលំហូរ ដែលក្នុងនោះមានសេចក្តីក្បោះក្បាយ និងសកម្មភាព។ វាធ្វើឲ្យយើងមិនចង់តាមអាន រហូតទាល់តែយើងយល់ថាមានអ្វីកើតឡើង។ នេះជារបៀបមួយក្នុងការទាញអ្នកអានឲ្យអានអត្ថបទនេះ។*

នាយប់មួយនោះ ក្នុងខែតុលា ឆ្នាំ១៩៧៣ ម្តាយខ្ញុំ (កាលនោះគាត់ពពោះខ្ញុំបានប្រាំបីខែ) កំពុងអង្គុយក្នុងផ្ទះដោយភ័យផង យំ ផង។ ឪពុកខ្ញុំជានគរបាលមួយរូបក្នុងអង្គភាពទប់ស្កាត់បាតុកម្ម កំពុងជាប់ខ្លួនគាំងក្នុងស្ថានីយប៉ូលីស ដែលត្រូវបានឡោមព័ទ្ធដោយក្រុមយុទ្ធកៈជនឆ្វេងនិយម។

ក្នុងថ្នក់ដៃរបស់គាត់ គាត់កំពុងត្រកងកូនចៅរបស់គាត់ម្នាក់ដែលត្រូវគេបាញ់ឲ្យរបួសត្រង់ពោះ។ គាត់ហូរឈាមអស់ច្រើនណាស់ពេលនោះ។

មាននគរបាលពី ១៥ ទៅ ២០ នាក់ ដែលកំពុងជាប់ខ្លួនក្នុងប៉ុស្តិ៍ខៃទល់នឹងពួកប្រឆាំងរាប់រយនាក់ កំពុងធ្វើការឡោមព័ទ្ធពីខាងក្រៅ។ ស្ថានការណ៍គួរឲ្យអស់សង្ឃឹម។ អ្នកលបបាញ់ត្រង់មានវត្តមានគ្រប់កន្លែង។ នគរបាលមួយរូបដែលត្រូវរបួសក៏ស្លាប់ក្នុងពេលនោះ ដោយសារតែខ្សោះឈាម។

យប់កាន់តែជ្រៅ ឪពុកខ្ញុំក៏បញ្ជាឲ្យអ្នកក្រោមបង្គាប់គាត់ស្រាតឯកសណ្ឋានរបស់ពួកគេចេញ ហើយស្លៀកសម្លៀកបំពាក់ស៊ីវិលជំនួសមកវិញ។ ក្នុងភាពងងឹតឈឹង ពួកគេបានគេចខ្លួនចេញពីប៉ុស្តិ៍ប៉ូលីសនោះរួច។

ប៉ុន្មានម៉ោងក្រោយមក ឪពុកខ្ញុំបានមកដល់ផ្ទះជួបជុំជាមួយម្តាយខ្ញុំវិញ។

*សំណួរដែលអត្ថបទនេះចោទឡើង តើភាពវឹកវរទាំងអស់នេះ គឺដើម្បី អ្វី?*

ពេលណានឹកដល់រដ្ឋប្រហារ ការបះបោរ និងការបង្ហូរឈាមទាំងអម្បាលម៉ានដែលប្រទេសថៃបានជួបប្រទះ ខ្ញុំមានការងឿងឆ្ងល់ថាតើយើងបាន និងកំពុងវ៉ៃគ្នាដើម្បីអ្វី? តើយើងសម្រេចបានអ្វីខ្លះ?

ភាគច្រើននៃពលរដ្ឋថៃនៅរស់ក្នុងភាពក្រីក្រនៅឡើយ។ កុមាររបស់យើងជាច្រើននៅដើរសុំទានតាមដងផ្លូវរាល់ថ្ងៃ។ មិនមែនតែនយោបាយទេ តែសង្គមយើងទាំងមូលពោរពេញដោយអំពើពុករលួយ។ ជាមួយគ្នានេះ យើងមិនដឹងថាតើប្រជាធិបតេយ្យជាស្អីនៅឡើយទេ។

រដ្ឋប្រហារ បាតុកម្ម និងជម្លោះទាំងអម្បាលម៉ាននេះ វាគ្មានអ្វីខុសគ្នាពីការឈ្លោះប្រកែករវាងអ្នកមាន និងអ្នកក្រ ដែលវោហារដ៏ក្លៀវក្លា យុទ្ធវិធីដ៏ប៉ិនប្រសប់ និងលុយកាក់របស់គេអាចទាក់ទាញមនុស្សម្នាមកចូលរួមបាន។

*ត្រង់នេះ អ្នកនិពន្ធប្រកាសឲ្យគេដឹងពីជំហររបស់គាត់។*

*ខ្ញុំមិនមែនជាអ្នកគាំទ្ររបស់លោកនាយករដ្ឋមន្ត្រី សាម៉ាក់ ស៊ុនដារ៉ាវេជ ទេ ហើយខ្ញុំក៏មិនមែនជាអ្នកគាំទ្ររបស់មេដឹកនាំទាំងប្រាំរបស់ចលនាប្រជាជន ដើម្បីលទ្ធិប្រជាធិបតេយ្យដែរ។ ប៉ុន្តែខ្ញុំជាមនុស្សគាំទ្រដល់អ្នកទាំងឡាយ ដែលក្រោកពីដំណេកទៅធ្វើការដើម្បីរកចំណូលចិញ្ចឹមគ្រួសារ ចេះជួយអ្នកដល់អ្នកក្រខ្សត់ ហើយរស់នៅជាមួយសេចក្តីទៀងត្រង់ មិនថាគេពាក់អាវពណ៌ស្អីទេ។*

*បើបណ្តេញនាយករដ្ឋមន្ត្រីសាម៉ាក់ចេញពីតំណែង និងរំលាយសភាបាន វានឹងធ្វើឲ្យមនុស្សច្រើននាក់ណាស់សប្បាយចិត្ត ហើយខ្ញុំក៏នឹងសប្បាយចិត្តដែរ។ តែបន្ទាប់ពីហ្នឹងវាទៅជាស្អីទៅវិញ?*

*ក្នុងខ្ទង់នេះ ឃ្លាមានប្រវែងខុសៗគ្នា។ ឃ្លាខ្លះខ្លីមែនទែន។*

*តើអំពើពុករលួយនឹងថយចុះជាងមុន? អំពើអយុត្តិធម៌សង្គមនិងធ្លាក់ចុះ? គម្លាតនៃភាពខុសគ្នាក្នុងចំណូលនឹងរួញតូចមកវិញ? តើជីវភាពរបស់ប្រជាជននឹងគ្រាន់បើជាងមុន ឬយ៉ាងណា?*

*យើងចង់ដេញលោក សាម៉ាក់ ចេញពីតំណែង ពីព្រោះគាត់ពុករលួយ។ ប៉ុន្តែសួរថា តើគាត់ពុករលួយជាងអ្នកឯទៀតខ្លាំងណាស់ទៅឬ? តើក្នុងចំណោមយើងមានប៉ុន្មាននាក់ ដែលមិនដែលលេងផ្លូវកាត់ សូកលុយក្រោមតុ ប្រើបណ្តាញស្គាល់គ្នា ដើម្បីដោះស្រាយបញ្ហាអ្វីមួយនោះ?*

*យើងចង់ដេញគាត់ចេញពីតំណែង ពីព្រោះយើងមិនចង់ឃើញគម្រោងធំៗស្ទីលរបស់លោកថាក់ស៊ីនទៀតទេ។ ប៉ុន្តែ ចូរក្រឡេកមើលប្រព័ន្ធផ្សព្វផ្សាយរបស់យើង សង្គមរបស់យើងវិញ ហេតុអ្វីបានជាយើងងប់ងល់នឹងសម្ភារៈនិយមខ្លាំងម្ល៉េះ?*

*ត្រង់នេះ គឺគំនិតគោលក្នុងអត្ថបទ ដែលត្រូវបានសរសេរយ៉ាងច្បាស់ (សូមមើលឃ្លាដែលមានគូសបន្ទាត់ពីក្រោម)។*

*យើងមិនចង់ឲ្យគាត់ប្តូររដ្ឋធម្មនុញ្ញ ដើម្បីបម្រើប្រយោជន៍របស់គាត់ (ឬរបស់ចៅហ្វាយនាយគាត់)។ ប៉ុន្តែ ហេតុអ្វីបានជាយើងជនសាមញ្ញរាល់ថ្ងៃ នាំគ្នាបំពានច្បាប់ទម្លាប់ដើម្បីបម្រើរបៀបវារៈរបស់យើងដែរ?*

*<u>បើសិនជាយើងចង់ប្រែក្លាយប្រទេសថៃឲ្យគ្រាន់បើជាងមុន យើងមិនអាចនាំឲ្យមានការផ្លាស់ប្តូរ ដោយគ្រាន់តែកំចាត់មនុស្សពីរ-បីនាក់នោះទេ។ ការផ្លាស់ប្តូរត្រូវចាប់ផ្តើមចេញពីយើងរាល់គ្នា</u>។*

*<u>យើងនាំគ្នាដើរហែក្បួន ដើម្បីកំចាត់មនុស្សម្នាក់</u> តែយើងមាននាំគ្នាដើរហែក្បួន ដើម្បីសង្គ្រោះជីវិតកុមាររបស់យើងដែលនាំគ្នាសុំទានតាមដងផ្លូវទេ?*

យើងនាំគ្នាដើរហែក្បួន ដើម្បីកំចាត់មនុស្សម្នាក់ តែយើងមាននាំគ្នាដើរហែក្បួន ដើម្បីសង្គ្រោះជីវិតបងប្អូនប្រុសស្រីរបស់យើង ដែលបណ្តាខេត្តភូមិភាគខាងត្បូងទេ?

យើងនាំគ្នាដើរហែក្បួនដើម្បីកំចាត់មនុស្សម្នាក់ តែយើងមាននាំគ្នាដើរហែក្បួនទេ នៅពេលដែលជនស្លូតត្រង់ ត្រូវបានគេធ្វើឃាតតាមដងផ្លូវ?

បើសិនជាយើងចង់ប្រែក្លាយប្រទេសថៃឲ្យទៅជាគ្រាន់បើជាងមុន យើងមិនអាចនាំឲ្យមានការផ្លាស់ប្តូរ ដោយគ្រាន់តែកំចាត់មនុស្សពីរ-បីនាក់នោះទេ។ ការផ្លាស់ប្តូរត្រូវចាប់ផ្តើមចេញពីយើងរាល់គ្នា។

សម្ព័ន្ធភាពប្រជាជនដើម្បីលទ្ធិប្រជាធិបតេយ្យ មានសិទ្ធិក្នុងការប្រឆាំង ហើយលោក សាម៉ាក់ ក៏មានសិទ្ធិនិយាយដែរថា គាត់ត្រូវបានជ្រើសតាំងដោយសន្លឹកឆ្នោតភ្លូកទឹកភ្លូកដី។

យើងអាចនិយាយបានថា ការបោះឆ្នោតកន្លងទៅនេះត្រូវបានគេទិញ ប៉ុន្តែសួរថាតើមានការបោះឆ្នោតណាមួយនៅស្រុកយើង ដែលមិនត្រូវបានគេប្រើលុយទិញ? ការទិញក្នុងការបោះឆ្នោត វាជារឿងផ្តត់ផ្តង់ និងតម្រូវការ។ គេមិនអាចទិញវាបានទេ បើសិនជាប្រជាជនគ្មានចេតនាលក់ទៅឲ្យគេនោះ។ ហើយប្រជាជន គឺយើងរាល់គ្នានេះឯង គឺប្រជាជនថៃ។ គឺយើងជាអ្នកលក់សេរីភាព និងលទ្ធិប្រជាធិបតេយ្យរបស់យើងទៅឲ្យគេ។

បើសិនជាលោក សាម៉ាក់ លាលែងពីតំណែង គេនឹងមាន សាម៉ាក់ រាប់សិបពាន់នាក់ទៀតមកឡើងជំនួសគាត់វិញ។ ការធ្វើដូចលោក ថាក់ស៊ីន និងលោក សាម៉ាក់ វាប្រៀបបាននឹងសុភាសិត ថា "ត្រីក្នុងទឹក និងស្រូវក្នុងស្រែ" អញ្ចឹង។

មែនហើយ ដូចត្រី និងស្រូវ សំបូរណាស់មនុស្សដូច ថាក់ស៊ីន និងសាម៉ាក់ ក្នុងគ្រប់ស្រទាប់ទាំងអស់ក្នុងសង្គម មានពីអ្នកក្រដល់អ្នកមាន។

ភាពប្រណែន បក្សពួក គំនិតវណ្ណៈនិយម ការស្អប់ ញាតិនិយម ភាពពុករលួយ នយោបាយ ការកេងប្រវ័ញ្ច អត្តទត្តនិយម ការដែលដឹងថាខ្លួនត្រូវរហូត ការមានៈមិនព្រមផ្លាស់ប្តូរឲ្យមានភាពប្រសើរ - ទាំងអស់នេះ សុទ្ធតែអ្វីដែលយើងបានឃើញ កំពុងស្តែងឡើងលើទីលាននយោបាយរបស់យើងរាល់ថ្ងៃ ដែលប្រជាជននាំគ្នាអ៊ូទាំទាំងខ្ទើមរអើមរៀងរាល់ថ្ងៃ - តើយើងមិនមានចំណែកកំហុសដែរទេ ឬក្នុងស្រទាប់

គ្រួសាររបស់យើងក្នុងមជ្ឈដ្ឋានសង្គម ក្នុងសាលារៀន និងនៅតាមកន្លែងធ្វើការ ?

លោក សាម៉ាក់ គ្រាន់តែជាការឆ្លុះបញ្ចាំងមួយប៉ុណ្ណោះនៃសង្គមរបស់យើងជាកញ្ចក់ឆ្លុះថាតើយើងជាអ្នកណា ។ រូបខ្ញុំដែលជាអ្នកនិពន្ធខ្ទង់ទស្សនៈនេះ មិនមែនជាករណីលើកលែងទេ ។

ការរកអ្នកដទៃមកបន្ទោសវាងាយណាស់ ។ អ្នកមានបន្ទោសអ្នកក្រ អ្នកក្របន្ទោសអ្នកមាន ។ យើងបន្ទោសកម្មពៀរ អំពើមន្តអាគមន៍ ហើយមួយទៀតនោះ គឺយើងបន្ទោសជនបរទេស ។

មែនហើយ យើងត្រូវតែងើបប្រឆាំងនឹងអ្នកនយោបាយពុករលួយ ប៉ុន្តែយើងនឹងមិនទទួលបានផលច្រើនអ្វីទេ បើយើងគ្រាន់តែនាំគ្នាស្រែកឡូឡាម្តងម្កាល ហើយបន្ទាប់មកវិលទៅរកភាពពុករលួយ និងភាពកន្តើយដូចសព្វដងវិញនោះ ។

ការពិតនៅត្រង់ថា ៖ យើងម្នាក់ៗ សុទ្ធតែមានការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះប្រទេស សង្គម និងអនាគតរបស់កូនចៅយើង ។

មិនថាមានរឿងអ្វីខុសក្នុងនយោបាយថៃ និងសង្គមទេ យើងដែលជាប្រជាជនជាង ៦០ លាននាក់ សុទ្ធតែមានចំណែកក្នុងនោះទាំងអស់ ។ យើងក៏មានការទទួលខុសត្រូវចំពោះវាដែរ ។

វាឥតបានការអីទេ ការទៅបង្កអំពើហិង្សា សម្រក់ឈាម និងទឹកភ្នែក ដោយសារតែរឿងពាក់ព័ន្ធលោក សាម៉ាក់ នោះ ។ គាត់ក៏មិនស័ក្តិសមនឹងទទួលរងនូវការជេរប្រទេច និងការស្អប់ខ្ពើម ដែលពួកសម្ព័ន្ធប្រជាជនដើម្បីលទ្ធិប្រជាធិបតេយ្យ គ្រវែងទៅលើគាត់រៀងរាល់ថ្ងៃនោះទេ ។

ចូរយើងនាំគ្នាប្រឆាំងតាមដងផ្លូវជាមួយនឹងហេតុផលសមរម្យមួយ ៖ យើងហែក្បួនប្រឆាំងមិនមែនយើងស្អប់លោក សាម៉ាក់ ទេ តែយើងហែក្បួនប្រឆាំង ដោយសារយើងស្រឡាញ់ប្រទេសថៃ ។

អ្វីៗដែលយើងធ្វើរៀងរាល់ថ្ងៃក្នុងជីវិតរបស់យើង ជាបុគ្គលក្តី ជាសមូហភាពក្តី គឺវានឹងនាំឲ្យប្រទេសយើងមានការប្រែប្រួល ទោះក្លាយជាល្អក្តី អាក្រក់ក្តី ។

យើងគួរតែនាំគ្នាបន្តប្រយុទ្ធប្រឆាំងពួកនយោបាយពុករលួយ ។ ប៉ុន្តែ បើយើងពិតជាចង់បានអ្វីៗឲ្យកាន់តែប្រសើរជាងមុនសម្រាប់ប្រទេសថៃ ការប្រែប្រួលត្រូវចាប់ផ្តើមពីយើង គឺប្រជាជនថៃគ្រប់ៗរូបនេះតែម្តង ។

## គេហទិនានុលេខន៍ (Blogs)

Blog ( គេហទិនានុលេខន៍ ) ជាពាក្យកាត់ពីពាក្យពីរ ក្នុងភាសាអង់គ្លេស "Web log" ។ វាជាទំព័រអនឡាញសម្រាប់ចុះផ្សាយអត្ថបទនានា ក្នុងនោះ មានទិនានុលេខន៍ កំណត់ហេតុប្រចាំថ្ងៃ បទអត្ថាធិប្បាយ និងអត្ថបទដំណឹង ។ អ្នកណាក៏ដោយឲ្យតែមានបណ្ដាញអ៊ិនធឺណិត សុទ្ធតែអាចសរសេរគេហទិនានុលេខន៍បាន ។ ពេលដែលការសរសេរសៀវភៅនេះបានចាប់ផ្ដើមទំព័រគេហទិនានុលេខន៍ជាង ១០០ លានទំព័រ មានរួចទៅហើយលើប្រព័ន្ធអ៊ិនធឺណិត ។ អត្ថបទគេហទិនានុលេខន៍ភាគច្រើនមិនសូវវែងទេ គឺប្រហែល ២៥០ ពាក្យអង់គ្លេស ប៉ុណ្ណោះក្នុងមួយអត្ថបទ ដែលអាចមានរួមបញ្ចូលផងនូវហ្វាល (file) ជាវីឌីអូ, អូឌីយ៉ូ (audio) និងតំណ (link) ភ្ជាប់ទៅវ៉ិបសាយដទៃទៀតផង ។ គេហទិនានុលេខន៍ភាគច្រើនមានលក្ខណៈសកម្មដែលអនុញ្ញាតឲ្យអ្នកអានសរសេរ អត្ថាធិប្បាយរបស់ខ្លួនចុះលើគេហទិនានុលេខន៍បាន ។

អ្នកសរសេរគេហទិនានុលេខន៍តែងទម្លាយរឿងសំខាន់ៗមុនគេ ហើយដោយសារតែបច្ចេកវិទ្យា អ្នកណាក៏អាចធ្វើជា **"អ្នកសារព័ត៌មានពលរដ្ឋ" (citizen journalist)** បានដែរ ដោយរាយការណ៍អំពីព្រឹត្តិការណ៍ដែលគេបានជួបប្រទះ ។ តាមរយៈគេហទិនានុលេខន៍ នរណាក៏អាចធ្វើអត្ថាធិប្បាយបានដែរ នៅលើគ្រប់បញ្ហាអ្វីក៏ដោយដែលគេចាប់អារម្មណ៍ ។

សម្រាប់អ្នកសារព័ត៌មានអាជីព គេហទិនានុលេខន៍បានក្លាយជាកាតព្វកិច្ចបន្ថែមមួយទៀតពីលើការសរសេរអត្ថបទដំណឹង អត្ថបទពិពណ៌ និងខ្ទង់ទស្សនៈជាប្រចាំ ។ ប៉ុន្តែវាក៏ផ្ដល់ពួកគេនូវឱកាសធ្វើបច្ចុប្បន្នភាព រឿងដំណឹង ឬក៏ទស្សនវិស័យ និងការពន្យល់ស៊ីជម្រៅ ដែលជាធម្មតាគេមិនសូវបញ្ចូលក្នុងរឿងដំណឹង ។

ខាងក្រោមនេះជាគំរូអត្ថបទគេហទិនានុលេខន៍មួយចំនួនពីកាសែត The Nation ស្ដីអំពីវិបត្តិនយោបាយនៅប្រទេសថៃ ។ ក្រោមចំណងជើងថា "Follow it with the Editor" គេហទិនានុលេខន៍នេះ ត្រូវបានសរសេរដោយនិពន្ធនាយក ទុលសាធីត តាប់ទីម (Tulsathit Taptim) ដែលបានព្យាយាមផ្ដល់ជូនអ្នកនូវដំណឹងបច្ចុប្បន្នភាព ស្ដីអំពីការប្រកួតយកតំណែងនាយករដ្ឋមន្ត្រីនៅប្រទេសថៃ ។ គាត់សរសេរអត្ថបទនេះ បន្ទាប់ពីក្រុមបាតុករបានកាន់កាប់ព្រលានយន្តហោះពីរក្នុងក្រុងបាងកកអស់រយៈពេលពីរសប្ដាហ៍ ។

អត្ថបទនេះចាប់ផ្ដើមដូច្នេះ ៖

*តើលោកអ្នកវង្វេងវិលវល់ ឬនឿយណាយ ឬមួយក៏ខ្លាចលែងចង់ដឹងចង់ឮទៀតហើយ ? បើដូច្នោះមែន កុំភ័យ ព្រោះលោកអ្នកមិនមែនតែម្នាក់ឯងទេ ដែលមានអារម្មណ៍បែបនេះ ។ យើងកំពុងស្ថិតក្នុងស្ថានភាពដូចគ្នា ហើយយើងនឹងឆ្លងកាត់វាជាមួយគ្នា ។ បន្ទាប់ពីសប្ដាហ៍ដ៏គួរឲ្យសោកស្ដាយបានកន្លងផុតទៅ ប៉ុន្មានថ្ងៃខាងមុខអាចនឹងមានរឿងគួរឲ្យរីករាយថានឹងមានការប្រែប្រួលផងក៏មិនដឹង ។ យើងនឹងធ្វើបច្ចុប្បន្នភាព និងការវិភាគស្ថានការណ៍វិវត្តន៍សំខាន់ៗជាបន្តបន្ទាប់ ដូច្នេះសូមអញ្ជើញមកឆែកមើលគេហទិនានុលេខន៍នេះឲ្យបានទៀងទាត់ ។*

ហើយនេះជាការធ្វើបច្ចុប្បន្នភាពជប់ថ្ងៃក្រោយមកទៀត គឺក្នុងថ្ងៃដែលលោក ថាក់ស៊ីន ធ្វើសេចក្ដីថ្លែងការណ៍តាមទូរស័ព្ទទៅកាន់អ្នកគាំទ្ររបស់គាត់ ៖

***ថ្ងៃទី ១៣ ធ្នូ ម៉ោង ១០ យប់៖*** *សម្រាប់ខ្ញុំ ស្ដាប់ទៅវាហាក់ដូចជាបទស្មូតជូនដំណើរព្រលឹងសពអញ្ចឹង ។ ព្រឹត្តិការណ៍ថ្ងៃនេះបានចប់ទៅក្នុងសភាពគួរឲ្យស្រពាប់ស្រពោន ដោយហេតុថា ផ្ទុយនឹងការសន្ធនាតាមទូរស័ព្ទ ដែលគេបានរំពឹងទុកពីមុនមក គេបានត្រឹមតែស្ដាប់ឮសារក្នុងខ្សែអាត់ទៅវិញ ។ លោក ថាក់ស៊ីន មិនបានហៅអ្នកណាចំឈ្មោះទេក្នុងសង្កថានោះ ។ ដូចគេបានរំពឹងទុក គាត់ថ្កោលទោស "រដ្ឋប្រហារបំភ័ន្តភ្នែក" ដោយក្នុងន័យនេះ គាត់និយាយសំដៅទៅលើសេចក្ដីសម្រេចតុលាការរំលាយគណបក្ស និងការលូកដៃរបស់យោធាក្នុងការធ្វើឲ្យសភាងាករស្វាមីភក្ដិរបស់ខ្លួនទៅខាងពួកប្រជាធិបតេយ្យវិញ ។*

*លោក នេវិន ដែលធ្លាប់តែជាអតីតសម្ព័ន្ធមិត្តរបស់លោក ថាក់ស៊ីន ត្រូវបានលោក ថាក់ស៊ីន ប្រទេចថាជាមនុស្ស "អកតញ្ញូ" ហើយគេក៏បានធ្វើការទស្សន៍ទាយដែរថា វិបត្តិប្រទេសថៃនឹងអូសបន្លាយដោយសារតែការបែកបាក់ជ្រាលជ្រៅក្នុងសង្គម ។ ការបិទព្រលានយន្ដហោះសុវណ្ណភូមិ ត្រូវបានគេសម្ដែងការសោកស្ដាយថាជាការសំពងយ៉ាងដំណំមកលើសេដ្ឋកិច្ច និងមុខមាត់ប្រទេសថៃ ។*

*សរុបសេចក្ដីមក សាររបស់លោក ថាក់ស៊ីន មានភាពម៉ឺងម៉ាត់ឱឡារិកជាងការបង្កហេតុ ។ យ៉ាងណាក្ដីជាមួយលោក ថាក់ស៊ីន កុំសូវប្រាកដក្នុងចិត្តខ្លាំងពេក ។*

**ពីរថ្ងៃក្រោយមក គេហទិនានុលេខន៍នោះត្រូវបានបញ្ចប់ដូច្នេះ៖**

**ថ្ងៃទី ១៥ ធ្នូ ម៉ោង ១១ ព្រឹក៖ ឥឡូវនេះ លោក អាភីស៊ិត ជានាយករដ្ឋមន្ត្រីថ្មីរបស់ថៃ។ គាត់ឈ្នះបានសម្លេង ២៣៥ សម្លេង រីឯលោក ប្រាចា ទទួលបាន ១៩៧ សម្លេង។ (រង់ចាំការអនុម័តជាផ្លូវការ)**

*គួរតែខ្ញុំមានអារម្មណ៍ក្មេងជាងមុន ឬក៏ចាស់ជាងមុនឥឡូវនេះ ? លោក អាភីស៊ិត កើតក្រោយខ្ញុំមួយឆ្នាំ ហើយម្នាក់ៗនាំគ្នារំភើបចិត្តដោយប្រទេសថៃមាននាយករដ្ឋមន្ត្រីវ័យក្មេង ។ យ៉ាងណាក៏ក្ដី សូមអបអរសាទរដល់បុរសម្នាក់នេះ ដែលគុណភាពក្នុងសិល្បៈនយោបាយរបស់គាត់ មិនដែលនរណាមន្ទិលសង្ស័យនោះឡើយ ។ ប៉ុន្តែ នៅពីមុខគាត់មានភ្នំដ៏ធំមួយ ហើយយើងដឹងថាហេតុអ្វី ។*

*គាត់នឹងត្រូវដឹកនាំប្រទេសមួយ ដែលមានការប្រេះឆាជ្រាលជ្រៅ ។ ទម្រាំនឹងលោក អាភីស៊ិត ត្រូវបានគេបន្តុបឲ្យធ្វើនាយករដ្ឋមន្ត្រីថ្មីរបស់ថៃ យើងត្រូវឆ្លងកាត់រដ្ឋប្រហារមួយ ការបះបោរពុំរ៉េ ការឡោមព័ទ្ធវិមានរដ្ឋាភិបាល និងព្រលានយន្តហោះ អំពើហិង្សាតាមដងផ្លូវ សេចក្ដីសម្រេចតុលាការរាប់មិនអស់ប្រឆាំងនឹងបច្ចាមិត្តនយោបាយរបស់គាត់ ។ មនុស្សច្រើននាក់បានធ្វើទឡ្ហីករណ៍ថា រឿងរ៉ាវនយោបាយអកុសលទាំងអម្បាលម៉ាន វាបានកើតឡើងដើម្បីហេតុល្អទៅវិញទេ ។ ឥឡូវនេះ វាជាបន្ទុកសម្រាប់លោក អាភីស៊ិត ក្នុងការបញ្ជាក់ថាពួកគេពិតជាត្រូវក្នុងការគិតទុកបែបនេះ ។ ខ្ញុំសូមជូនពរគាត់ឲ្យមានសំណាងល្អបំផុត ។*

*មុននឹងខ្ញុំបញ្ចប់ទៅរកញ៉ាំនំរបស់ខ្ញុំសូមអរគុណជាអនេកដល់អ្នកទាំងឡាយ ដែលបានតាមដានជាមួយខ្ញុំនូវឈុតព្រឹត្តិការណ៍ប្រវត្តិសាស្ត្រក្នុងរយៈពេល ១២ ថ្ងៃ កន្លងមកនេះ ។ វាជាប្រការគួរឲ្យសែនរីករាយណាស់ ជាពិសេសដោយសារមួយផ្នែកគឺអត្ថាធិប្បាយពីសំណាក់អ្នកទាំងអស់គ្នា ។ សំណាងល្អ រហូតដល់យើងជួបគ្នាលោកក្រោយទៀត ។ លាសិនហើយ ។*

## តើបច្ចេកវិទ្យាធ្វើឲ្យសារព័ត៌មានបោះពុម្ពប្រែប្រួលដូចម្ដេចខ្លះ?

វាអាស្រ័យថាពេលណាដែលលោកអ្នកអានសៀវភៅនេះ អ្វីដែលយើងបាននិយាយអំពីរបៀបដែលបច្ចេកវិទ្យាធ្វើឲ្យមានការប្រែប្រួលក្នុងមុខរបរ និងការរស់នៅរបស់យើង វាប្រហែលជានឹងក្លាយទៅជាចាស់គំរិលលែងទាន់សម័យបាត់ទៅហើយ។ អ្វីដែលយើងធ្លាប់តែធ្វើក្នុងនាមជាអ្នកយកព័ត៌មាន និងនិពន្ធនាយក បានឆ្លងកាត់ការប្រែប្រួលយ៉ាងសន្ធឹកសន្ធាប់។ ជាមួយគ្នានេះដែរ អ្វីដែលយើងនឹងធ្វើក្នុងដប់ឆ្នាំខាងមុខចាប់ពីពេលនេះតទៅ ក៏ប្រហែលជានឹងមានការប្រែប្រួលកាន់តែជ្រាលជ្រៅជាងមុនទៀតផងក៏មិនដឹង។

ការប្រែប្រួលធំជាងគេបង្អស់ គឺក្នុង **ល្បឿន (speed) និងលទ្ធភាពទទួលបាន (access)**។ អ្វីដែលយើងធ្វើសព្វថ្ងៃនេះ មានល្បឿនលឿនជាងមុនខ្លាំងណាស់ ដូចជា យើងអាចរកឃើញព័ត៌មានទាក់ទងបានរហ័សជាងមុន ដោយប្រើទូរស័ព្ទចល័ត និងអាចភ្ជាប់អ៊ិនធឺណិតលើទូរស័ព្ទដែល ឬតាមរយៈឧបករណ៍កាន់ក្នុងដៃដទៃទៀតបានដែរ។ វាលែងជារឿងអធម្មតា ពិបាក ឬត្រូវបង់ថ្លៃខ្ពស់ ដូចមុនទៀតហើយ ក្នុងការសម្ភាសន៍នរណាម្នាក់នៅប្រទេសឆ្ងាយសម្រាប់យកខ្លឹមសារបញ្ចូលក្នុងអត្ថបទ។ យើងអាចធ្វើការស្រាវជ្រាវឯកសារនៅកន្លែងណា និងពេលណាក៏បាន។ យើងមិនចាំបាច់ដើរទៅបណ្ណាល័យទៀតទេ ដើម្បីរកមើល**គ្លីបព័ត៌មាន**ចាស់ៗនោះ។ យើងអាចផ្ទៀងផ្ទាត់ព័ត៌មានអង្គហេតុ និងទិន្នន័យតាមរយៈបណ្ដាញអ៊ិនធឺណិត។ ហើយយើងក៏អាចសរសេរកែសម្រួលអត្ថបទ ផ្លាស់ប្ដូរទីតាំង លុប ឬស្ដារផ្នែកនានាក្នុងអត្ថបទបានយ៉ាងងាយ ស្អាត និងរហ័សទាន់ចិត្តទៀតផង។

អត្ថបទគ្រប់ប្រភេទដែលយើងជាអ្នកសារព័ត៌មាននាំគ្នាផលិត អាចយកទៅចុះផ្សាយបានភ្លាមៗលើវិបសាយ ឬក៏បញ្ជូនបន្តតាមតាមបរន្តជីពចរអេឡិចត្រូនិកទៅដល់គោលដៅច្រើនប្រភេទទៀតផង។ រឿងមួយដែលគេសរសេរ និងចុះផ្សាយលើអ៊ិនធឺណិតនៅវៀតណាម អាចត្រូវបានគេឃើញ និងអាននៅទីក្រុងវិនុស ប្រទេសអ៊ីតាលី ឬទីក្រុងវ៉ង់គូវែរ ប្រទេសកាណាដា ភ្លាមៗក្រោយពីវាត្រូវបានគេផ្សាយឡើង។ ក្នុងន័យនេះ កាសែតនីមួយៗ គឺជាកាសែតសាកលដែលប្រជែងគ្នាដណ្ដើមអ្នកអាន។ បើទោះជាយើងនៅផលិតចេញផលិតផលជារូបវន្តក៏ដោយ ដូចជាកាសែត និងទស្សនាវដ្ដី គេអាចព្រីនវានៅកន្លែងផ្សេងទៀតបាន ដោយសារថាយើងអាចបញ្ជូនទំព័ររបស់វាបានពីកន្លែងមួយទៅកន្លែងមួយទៀតតាមប្រព័ន្ធផ្កាយរណប ឬប្រព័ន្ធខ្សែកាបហ្វ៊ីបអុបទិក (fiber optic) ក្រោមដី និងក្រោមបាតសមុទ្រ។ សម័យនេះ គេលែងត្រូវការជាចាំបាច់ទៀតហើយនូវរថយន្តសម្រាប់ដឹកជញ្ជូនកាសែតយកទៅចែកចាយដល់ទីឆ្ងាយៗ។ រោងពុម្ពក្នុងប្រទេសមួយចំនួនអាចទទួលបោះពុម្ពកាសែតពីក្រៅ ដើម្បីចែកចាយក្នុងប្រទេសរបស់ខ្លួន។ ឧទាហរណ៍ កាសែត International Herald Tribune និង Financial Times ត្រូវបានគេបោះពុម្ពនៅក្នុងទីក្រុងមួយចំនួនលើពិភពលោក ដូច្នេះធ្វើឲ្យកាសែតទាំងពីរនេះ ជារូបវន្តជាកាសែតសាកលពិតៗ។ បន្ថែមលើនោះ កាសែតទាំងពីរនេះមានវិបសាយ ដែលគេអាចអាននៅកន្លែង និងគ្រប់ពេលវេលាបានទាំងអស់។ យើងអាចស្ដាប់សម្លេងវិទ្យុរបស់ស្ថានីយ ដែលយើងចូលចិត្តពីជ្រុងណាមួយនៃពិភពលោកក៏បានដែរ។ មិនតែប៉ុណ្ណោះ វាកាន់តែមានភាពងាយស្រួលថែមទៀតក្នុងការមើលទូរទស្សន៍អនឡាញ។ បើយើងរំលងមិនបានមើលព្រឹត្តិការណ៍ ឬកម្មវិធីផ្សាយផ្ទាល់ណាមួយ យើងអាចប្រើមធ្យោបាយ ដូចជា “Listen Again”,

"Watch" "Video on demand" លើវិបសាយ ប្រព័ន្ធផ្សព្វផ្សាយ រួមមាន YouTube និងវិបសាយដទៃទៀត ដែលទៅលើនោះអ្នកណាក៏អាច**ផ្ទុកឡើង/អឹបឡូត (upload)** វីឌីអូ និងរូបភាពចូលបានដែរ។

រីឯការប្រែប្រួលដទៃទៀតនោះ មានទាក់ទិននឹងអ្វីដែលអ្នកសារព័ត៌មានអាច និងត្រូវបានគេរំពឹងថានឹងធ្វើ។ ពិតណាស់ វាជាទម្លាប់ទូទៅនៅឡើយការដែលអ្នកសារព័ត៌មានត្រូវការពេលពេញមួយថ្ងៃ ឬមួយសប្តាហ៍ ឬក៏ច្រើនជាងនេះ ដើម្បីធ្វើរឿងមួយ។ តែសព្វថ្ងៃនេះ មានសំពាធច្រើនណាស់មកលើអ្នកសារព័ត៌មានថា រៀងរាល់ថ្ងៃត្រូវតែ "ដាក់ព័ត៌មានអ្វីមួយលើវិបសាយ" ឲ្យបានរហ័សបំផុត។ ក្នុងន័យមួយទៀត យើងទាំងអស់គ្នាបានក្លាយទៅជាអ្នករាយការណ៍ព័ត៌មាននៃសេវាកម្មចែកចាយព័ត៌មានតាម **ប្រព័ន្ធទូរលេខអេឡិចត្រូនិក និងឌីជីតាល់ (wire service)**។ ក្នុងនោះ ដំបូង គឺបង្ហោះរឿងចេញភ្លាមព្រមគ្នានឹងពេលដែលព្រឹត្តិការណ៍កំពុងវិវត្តន៍ ហើយប៉ុន្មានម៉ោងក្រោយមកធ្វើបច្ចុប្បន្នភាពជាមួយសេចក្តីពិស្តារ និងសម្រង់សម្តី។ ទាំងអស់នេះបានធ្វើឲ្យមានភាពខុសគ្នាធំធេងមែនទែនក្នុងរបៀបដែលយើងធ្វើការ។

ពីមុន អ្នករាយការណ៍ព័ត៌មានធ្លាប់តែសរសេររឿងតែមួយទេក្នុងមួយថ្ងៃសម្រាប់បុះក្នុងទំព័រ "កាសែតថ្ងៃស្អែក" តែបច្ចុប្បន្ននេះ គេត្រូវបានគេរំពឹងថាអាចបំពេញពហុភារកិច្ច (multi-tasking) បាន ដែលក្នុងនោះមាន៖

- សរសេរ និងធ្វើបច្ចុប្បន្នភាពរឿងលើវិបសាយ
- បង្ហាញខ្លួនក្នុងវីឌីអូខ្លីៗធ្វើសេចក្តីរាយការណ៍ដូចអ្នករាយការណ៍ព័ត៌មានតាមទូរទស្សន៍ដែរ
- ផលិតចេញអត្ថបទដើមសម្ភាសន៍ជាវីឌីអូ និងព្រីន ក្រោយពីការធ្វើបទសម្ភាសន៍រួច
- បេះថតរូបភាព និងវីឌីអូ ពេលចេញទៅយកព័ត៌មាន ហើយអឹបឡូត/ផ្ទុកវាឡើងទៅលើវិបសាយ ឬក៏ចែកចាយទៅដល់ស្ថានីយ៍ទូរទស្សន៍
- បេះផលិតអត្ថបទដំណឹងបីនាទី ផ្សាយតាមវិទ្យុ ចេញពីសាច់រឿងដើមដែលគេបានធ្វើ
- ផ្តល់សម្ភាសន៍ដល់សហសេវិកអំពី "រឿងនៅពីក្រោយរឿង" បានន័យថាសម្ភាសន៍អំពីរបៀបដែលអ្នកយកព័ត៌មានប្រើ ដើម្បីធ្វើរឿងនោះបាន
- សរសេរ និងធ្វើបច្ចុប្បន្នភាពទំព័រគេហ-ទិនានុលេខន៍ជាប្រចាំ
- បេះផ្ញើសារ SMS ឬ **សារធ្វីធឺ "twitter"** ខ្លីៗទៅឲ្យសវនជន (audience) នានាតាមរយៈទូរស័ព្ទចល័ត ឬ**អនឡាញ (online)**។ នេះអាចជាដំណឹងខ្លីៗ ឬសារជាបុគ្គល។

ឥឡូវនេះ អង្គភាពប្រព័ន្ធផ្សព្វផ្សាយក៏កំពុងប្រឹងធ្វើពិពិធកម្ម ឬធ្វើឲ្យមានចម្រុះភាពនូវផលិតផលរបស់គេដែរ។ គេធ្វើការជាក្រុម ដែលក្នុងនោះមានគ្នាជាអ្នកសារព័ត៌មានផង និងអ្នកបច្ចេកទេសផង ដើម្បីរៀបចំមាតិកាប្រភេទ (content) ដែលផលិតដោយអ្នកសារព័ត៌មានឯទៀត។ មានន័យថា បើទោះជាគេមិនរំពឹងឲ្យអ្នកសារព័ត៌មានទាំងឡាយធ្វើកិច្ចការបន្ថែមទាំងអស់នោះបាន (តាមពិតទៅតើអ្នកអាច?) អង្គភាពនីមួយៗនៅតែព្យាយាមផលិតចេញមាតិការឿងតាមមធ្យោបាយផ្សេងៗ។ ឧទាហរណ៍ **ផត់ខាស្ទីង (podcasting)** កំពុងតែក្លាយជាមធ្យោបាយកាន់តែពេញនិយមឡើងៗ សម្រាប់មហាជនទទួលបាន (ស្តាប់) ដំណឹង និងមាតិកាប្រភេទដទៃទៀត។ សូម្បីតែអង្គភាព

សារព័ត៌មានដែលមានកេរ្តិ៍ឈ្មោះបោះសម្លេង តួយ៉ាងកាសែត The New York Times និង ទស្សនាវដ្តី The Economist ជាដើម បច្ចុប្បន្ននេះ ក៏គេផលិតរឿងជា**អូឌីយ៉ូ**ដែរ ដែលគេអាច**ទាញយក/ដោនឡូត (download)** ដាក់ក្នុង MP3 player សម្រាប់ស្តាប់ក្នុងពេលធ្វើដំណើរតាមរថយន្ត ឬក្នុងពេលរត់ហាត់ប្រាណជាដើម។



*កុំភ្លេចប្រាប់ផង បើមានដំរីនៅក្នុងបន្ទប់។*

អង្គភាពខ្លះទៀត បញ្ចេញការងារផលិតកម្មសារព័ត៌មានរបស់គេទៅធ្វើនៅប្រទេសក្រៅ **(outsource)**។ វាជារឿងសាមញ្ញទៅហើយដែលទំព័រខ្លះក្នុងកាសែតមួយ ត្រូវបានពិនិត្យកែសម្រួលដោយនិពន្ធនាយក និង**រៀបទំព័រ (layout)** ដោយក្រុមបុគ្គលិកនៅប្រទេសមួយទៀត (ដែលនៅទីនោះចំណាយលើបៀវត្សរ៍ទាបជាងនៅក្នុងប្រទេសដើមកំណើតរបស់កាសែត)។ គេធ្វើដូច្នេះ ដើម្បីកាត់បន្ថយចំណាយ។ ផ្នែកទំព័រពិសេស ដូចជាទំព័រស្តីពីយានយន្ត និងអចលនទ្រព្យ ត្រូវបានគេរៀបចំផលិតនៅក្រៅប្រទេស។

ទាក់ទិននឹងចំណុចនេះ គឺការលេចឡើងនៃ **"អ្នកសារព័ត៌មានពលរដ្ឋ " (citizen journalist)** ឬអ្វី ដែលគេហៅថា I-reporters។ អង្គភាពសារព័ត៌មានធំៗបានលើកទឹកចិត្តមហាជនសាមញ្ញទូទៅឲ្យថតរូបភាព ឬវីឌីអូតាមទូរស័ព្ទ ឬកាមេរ៉ា ហើយផ្ទុកវាឡើងទៅលើវិបសាយរបស់អង្គភាពសារព័ត៌មានទាំងនោះ។ តាមរយៈអ្នកសារព័ត៌មានពលរដ្ឋនេះឯង ដែលគេតែងទទួលបានរូបភាពនានាអំពីគ្រោះមហន្តរាយធម្មជាតិគ្រោះថ្នាក់ បាតុកម្មនយោបាយ ឬក៏អំពើវាយប្រហារភេរវកម្ម។ សម័យនេះគេតែងឃើញថា មិនយូរប៉ុន្មានក្រោយពីមានព្យុះស៊ីក្លូន ឬក៏មានបាតុករបះបោរហ៊ុំព័ទ្ធអគាររដ្ឋាភិបាល ព័ត៌មានអំពីព្រឹត្តិការណ៍ទាំងនេះនឹងត្រូវបានសាយភាយតាមការផ្សាយរបស់ CNN, BBC និងវិបសាយរបស់កាសែតរាប់សិបពាន់នៅទូទាំងពិភពលោកយ៉ាងរហ័សទាន់ចិត្ត។

សម្រាប់**អ្នកសារព័ត៌មានប្រពៃណី *(conventional journalists - អ្នកសារព័ត៌មានដែលធ្វើការតាមទម្លាប់ចាស់)*** នេះមានន័យថា ប្រព័ន្ធការផ្សាយសាកល និងវិបសាយរបស់កាសែត ដែលចុះផ្សាយព័ត៌មានអំពីព្រឹត្តិការណ៍សាកលលោក កំពុងក្លាយជាគូប្រជែង ថែមពីលើគូប្រជែងក្នុងស្រុករបស់ពួកគេទៀតផង។ ដូច្នេះ អ្នកសារព័ត៌មានជាប្រពៃណីខិតខំប្រើឲ្យពេញទំហឹងនូវឧត្តមភាពដែលគេមាន ដូចជា លទ្ធភាពជួបទាក់ទងផ្ទាល់ជាមួយមនុស្ស ឬអង្គការ ស្ថាប័នក្នុងស្រុក បំណេះដឹង និងព័ត៌មានទាក់ទងក្នុងស្រុកជាដើម។ ទោះជាដូច្នោះក៏ដោយ ក៏ក្រុមហ៊ុនសារព័ត៌មានសាកល នៅតែអាចប្រើលទ្ធភាពសំបូរបែបរបស់ខ្លួនក្នុងការជួលអ្នកសារព័ត៌មាន ឬ**ជំនួយការឆ្លើយឆ្លងព័ត៌មាន (stringer)** ក្នុងស្រុកឲ្យជួយបំពេញការងារដូចអ្នកសារព័ត៌មានប្រចាំការក្នុងប្រទេសជំនួសគេផងដែរ។

ការប្រែប្រួលជាសារវន្ត ដែលបច្ចេកវិទ្យាបាននាំមកនោះ គឺ world-wide web (www)។ យើងមិននិយាយត្រឹមតែពីការ **"ចែកចាយ"** **(delivery)** ពីកុំព្យូទ័រមួយទៅកាន់កុំព្យូទ័រមួយទៀត ឬទៅកាន់ឧបករណ៍កាន់ក្នុងដៃណាមួយ ដែលមានភ្ជាប់ **wi-fi** នោះទេ។ និយាយឲ្យចំ គឺការប្រែប្រួលនៃ **"វេទិកា"** **(platform)** ឬវិបសាយកាសែតនេះតែម្តង។ កាលពីមុន ប្រព័ន្ធផ្សព្វផ្សាយធំៗបង្កើតវិបសាយ ដើម្បីគ្រាន់តែធ្វើជាកញ្ចក់អេឡិចត្រូនិកនៃផលិតផលរូបវន្តរបស់គេតែប៉ុណ្ណោះ។ គេអឹបឡូតអត្ថបទរឿងកាសែតទៅលើវិបសាយ ហើយគ្រាន់តែសម្រួលវាបន្តិចបន្តួចឲ្យត្រូវនឹងទម្រង់ទំព័រវិបសាយនោះជាការស្រេច។ តែឥឡូវនេះ វិបសាយកាសែត ទស្សនាវដ្តី និងប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាសមានអត្តសញ្ញាណមួយរបស់ខ្លួន ហើយដើរតួនាទីជាផ្នែកមួយនៃអត្តសញ្ញាណរួមរបស់អង្គភាពទាំងមូលតែម្តង។ គេអាចដាក់សណ្ឋានពិសេសៗច្រើនបែបយ៉ាងទៅលើវិបសាយ ដូចជា៖ បណ្ណសារ តំណភ្ជាប់ (link) ទៅព័ត៌មាន និងវិបសាយផ្សេងទៀត សារគារក្រាហ្វិករស់រវើក កម្រងរូបថត វីឌីអូឃ្លីប គេហទិនានុ-លេខន៍ អ្នកឯកទេស អត្ថាធិប្បាយរបស់អ្នកអានជាដើម។ ដោយសារវិបសាយមានសមត្ថភាពគ្មានព្រំដែនដូច្នេះ គេប្រើប្រាស់វាតម្រូវតាមសេចក្តីត្រូវការខ្ពស់របស់អ្នកឯកទេស និងក្រុមមនុស្សដែលវក់វីងប់-ងល់នឹងបច្ចេកវិទ្យាអនឡាញទៀតផង។ បើសិនជាអ្នកជក់ចិត្តនឹងកីឡាបាល់ទាត់ វីឌីអូហ្គេម ឧបករណ៍អេឡិចត្រូនិក នយោបាយ ឬបុរាណវិទ្យាមានវិបសាយរាប់មិនអស់ទេ ដែលអ្នកអាចអានមើល និងឆ្លើយឆ្លងជាមួយអ្នកឯទៀត ដែលមានចំណាប់អារម្មណ៍ប្រហាក់ប្រហែលនេះដែរ មិនថាគេនៅឯទីក្រុងអ៊ូឡាន់បាទ័រ ប្រទេសម៉ុងហ្គោលី ឬទីក្រុងបាតុនរូហ្សនៃរដ្ឋលូអ៊ីស៊ីអាណា សហរដ្ឋអាមេរិកទេ។ ក្នុងសភាពព័ត៌មានសម្បូរបែបៗនេះ អ្នកសារព័ត៌មានត្រូវតែ**ប្រជែងគ្នា ដើម្បីដណ្តើមយកការយកចិត្តទុកដាក់**ពីមហាជន។

ជាលទ្ធផល កាសែតក្នុងប្រទេសជាច្រើនកំពុងតស៊ូត្រដរធ្វើយ៉ាងណាឲ្យឧស្សាហកម្មរបស់ខ្លួននៅរស់តទៅទៀត។ កាសែតមួយចំនួនដែលក្នុងន័យហិរញ្ញវត្ថុ មិនអាចរស់ជាផលិតផលរូបវន្តតទៅទៀតបាន ឥឡូវនេះមានអត្ថិភាពតែជា **វិបសាយប៉ុណ្ណោះ** ដូចជា កាសែត *Asia Times, The Christian Science Monitor* និងទស្សនាវដ្តី *Far Eastern Economic Review* ជាដើម។ តាមការពិត ពេលណាការផ្សាយថ្មីណាមួយចាប់បដិសន្ធិ ពួកគេច្រើនតែសម្ពោធវិបសាយមុន។ ខ្លះទៀតជាការផ្សាយលើវិបសុទ្ធសាធតែម្តង ដូចជា Asia Sentinel។ ទស្សនាវដ្តីប្រចាំសប្តាហ៍ Asiaweek របស់ហុងកុង ដែលត្រូវបានបិទទ្វារនៅចុងឆ្នាំ ២០០១ នៅមានតែបណ្ណសារអនឡាយតែប៉ុណ្ណោះ។

ចំនួនមហាជនអានអត្ថបទសារព័ត៌មានមានចំនួនកើនឡើងជាដរាប ក៏ប៉ុន្តែនៅក្នុងប្រទេសជាច្រើនលើពិភពលោក ចំនួនច្បាប់កាសែតបោះពុម្ពមានការធ្លាក់ចុះជានិច្ច។ នេះដោយសារអ្នកអានបានងាកទៅអាន**អនឡាញ**វិញ។ នៅផ្នែកដទៃនៃពិភពលោក ចំនួនច្បាប់កាសែតបោះពុម្ពកំពុងមានការកើន តែព្រមគ្នានឹងពេលដែលចំនួនប្រើប្រាស់អ៊ិនធឺណិតកំពុងពង្រីកខ្លួន ចំនួនអ្នកអានវិបសាយទាំងនោះក៏ប្រហែលជានឹងកើនដែរ។

អ្វីដែលបច្ចេកវិទ្យាមិនអាចធ្វើបាន ហើយក៏មិនដែលទាន់ធ្វើបានដែរនោះ គឺធានាឲ្យបានថា អ្វីដែលមហាជនផលិត វាមានលក្ខណៈទៀងត្រង់ត្រឹមត្រូវ មានតុល្យភាព និង**មានស្តង់ដារអាជីពខ្ពស់បំផុត**។ តាមពិត មានមនុស្សមួយចំនួនដែលគិតថា បច្ចេក-វិទ្យាបានបំផ្លាញអស់នូវគោលការណ៍អាជីពទាំងអស់នេះអស់ហើយ ដោយតាមរយៈនេះ នរណាមិនថានៅកន្លែងណាទេ ក៏អាចផ្សព្វផ្សាយព័ត៌មាន និង

មតិយោបល់ មិនថាអ្វីដែលគេសរសេរនោះអាចមានភាពលម្អៀង ឬព្យាបាទដល់អ្នកដទៃប៉ុណ្ណាឡើយ។ មានអ្នកអត្ថាធិប្បាយមួយរូបបានពិពណ៌នាទំព័រគេហទិនានុលេខន៍ថាជា "ការអាសអាភាសបែបថ្មី" ដែលវាសំបូរមែនទែន តែគឺច្រើនដូចសំរាមអញ្ចឹង។ អ្នកឯទៀតជឿថា យើងកំពុងតែធ្វើសាក្សីនៃដំណើរការ "**ប្រជាធិបតេយ្យភាវូបនីយកម្ម**" ដ៏សម្បើមនៃវិស័យសារព័ត៌មាន ដោយដកហូតអំណាចព័ត៌មានពីអ្នកសារព័ត៌មាន ប្រពៃណី (traditionalists) ចាស់គំរិលទៅដាក់ក្នុងដៃ "ប្រជាជន" វិញ។

ខាងក្រោមនេះ ជារឿងគួរឲ្យចាប់អារម្មណ៍មួយដែលត្រូវបានដកស្រង់ចេញពី "digital content blog" របស់កាសែត The Guardian ដែលអត្ថបទនេះបានលើកឡើងចំណុចខ្លះនៃទស្សនៈខាងលើ។ សេវាកម្ម **មីក្រូគេហទិនានុលេខន៍** Twitter បានដណ្តើមបានការចាប់អារម្មណ៍ក្នុងអំឡុងពេលមានការវាយប្រហារភេរវកម្មក្នុងទីក្រុងមុមបៃ ប្រទេសឥណ្ឌា។ ក៏ប៉ុន្តែទូរទស្សន៍ BBC ត្រូវបានទទួលការរិះគន់ចំពោះការប្រើសេចក្តីរាយការណ៍ព័ត៌មានមហាជន ដែលមិនអាចបញ្ជាក់អះអាងបានក្នុងការផ្សាយរបស់ខ្លួន៖

***BBC សារភាពកំហុសក្នុងការប្រើសេចក្តីរាយការណ៍ធ្វីតពី Twitter ផ្សាយអំពីការវាយប្រហារក្នុងក្រុងមុមបៃ***

*ប្រតិកម្មចម្រុះគ្រប់បែបយ៉ាងបានកើតឡើងចំពោះការប្រើប្រាស់របស់ទូរទស្សន៍ BBC នូវសេវារាយការណ៍របស់មីក្រូគេហទិនានុលេខន៍ Twitter ក្នុងការផ្សាយផ្ទាល់របស់ខ្លួនអំពីការវាយប្រហារភេរវកម្មនៅក្រុងមុមបៃ។*

*លោក Steve Hermann និពន្ធនាយកវិបសាយ BBC News បានបន្ថែមការពិចារណារបស់គាត់ទៅក្នុងការជជែកវែកញែក ក្នុងនោះ រួមមានការសារភាពថា អង្គភាពនេះត្រូវតែមានការប្រុងប្រយ័ត្នថែមទៀតចំពោះការយកសេចក្តីរាយការណ៍ហ៊ាសដូចផ្លេកបន្ទោរ តែមិនអាចផ្ទៀងផ្ទាត់បានរបស់មហាជនតាមសេវា Twitter មកដាក់ក្នុងការផ្សាយរបស់ខ្លួននៅពេលអនាគត។*

*គាត់បានលើកឡើងអំពីការខកខានដាក់លាក់មួយទាក់ទិននឹងសេចក្តីរាយការណ៍ ធ្វីត (tweet) ដែលថារដ្ឋាភិបាលឥណ្ឌាបានអំពាវនាវឲ្យបញ្ឈប់ការធ្វើបច្ចុប្បន្នកម្មសភាពការតាម Twitter ពីទីក្រុងមុមបៃ ដែលទូរទស្សន៍ BBC ធ្វើបច្ចុប្បន្នភាពផ្ទាល់ (live updates) លើទំព័រវិបសាយរបស់ខ្លួន។*

*លោក Hermann និយាយថា៖ "គួរយើងធ្វើការផ្ទៀងផ្ទាត់វាសិនទេមុននឹងផ្សាយ? និយាយឲ្យច្បាស់ គឺយើងឥតបានធ្វើការផ្ទៀងផ្ទាត់ជាមុនទេ។ គួរយើងព្យាយាមឆែកវាមើលសិនទេ ទើបធ្វើសេចក្តីរាយការណ៍ជាក្រោយ បើទោះជាយើងត្រូវនិយាយថា យើងមិនអាចរកអំណះអំណាងមកបញ្ជាក់ក៏ដោយ? ខ្ញុំគិតថាយើងគួរតែធ្វើដូច្នោះ តែយើងបានរៀនមេរៀនមួយហើយក្នុងករណីនេះ"។*

*បញ្ហានេះបាននាំឲ្យមានយោបល់ខុសៗគ្នា។ កាសែត The Independent រិះគន់សារព័ត៌មានតាម Twitter ដោយទស្សនៈថា ទូរទស្សន៍ BBC កំពុងតែលេងល្បែងប្រថុយប្រថានជាមួយនឹងកិត្តិនាមរបស់ខ្លួនហើយ។*

*ក្នុងកាសែត Indy លោក Tom Sutcliffe ធ្វើទស្សនៈថា ពួកប្រើ Twitter ច្រើនតែជាពួកហ៊ាសដៃ មិនសូវគិតពិចារណា រីឯគោលការណ៍នៃសារព័ត៌មានអាជីពនោះ មិនមែនការចុះផ្សាយតែពីសតែពាសនោះទេ ពីព្រោះវានឹងនាំមកនូវការបង់ខាតធំណាស់សម្រាប់មុខមាត់អាជីព។*

*គាត់និយាយថា៖ "ពួកប្រើ Twitter មិនជាប់កាតព្វកិច្ចជាមួយអ្នកណាទេ ក្រៅតែពីចំណាប់-អារម្មណ៍ និងផ្នត់គំនិតរបស់ខ្លួន។ ពួកនេះងាយនឹង*

*បញ្ជូនបន្តនូវពាក្យចចាមអារាម ដូចវាជាការណ៍ពិតអញ្ចឹង។ បើ BBC មិនចង់ទទួលការពេបជ្រាយលើពួកគេតទៅទៀតទេ ពួកគេគួរតែប្រុងប្រយ័ត្នជាងនេះបន្តិចទៀត កុំបំពានព្រំដែនរវាងសេចក្តីរាយការណ៍ដោយ twitter និងសេចក្តីរាយការណ៍ព័ត៌មានម៉ឺងម៉ាត់ហ្មត់ចត់"។*

*លោក Jeff Jarvis ដែលសរសេរខ្ទង់ទស្សនៈស្មេរមួយក្នុងកាសែត The Guardian បានបង្កឲ្យមានការជជែកវែកញែកជុំវិញតួនាទីរបស់ Twitter ដែលនាំមកនូវអត្ថាធិប្បាយវិជ្ជមានមួយចំនួនអំពី "ភាពពេញរូបពេញរាង" (coming of age) របស់សេវាមីក្រូគេហទិនានុលេខន៍មួយនេះ។*

*លោក Hermann សារភាពថា សេចក្តីរាយ-ការណ៍ ធ្វីត គ្រាន់តែអាចឲ្យគេដឹងបានខ្លះៗអំពីអ្វីដែលអ្នកពាក់ព័ន្ធនឹងសាច់រឿងបានគិត ឬឃើញ តែប៉ុណ្ណោះ តែ "ធ្វីត ភាគច្រើនមិនបានបន្ថែមសេចក្តីលម្អិតក្បោះក្បាយច្រើនប៉ុន្មានទេដល់អ្វីដែលយើងបានដឹងអំពីព្រឹត្តិការណ៍មួយ"។*

*សហសេវិករបស់គាត់ ឈ្មោះ Rory Cellan-Jones បានធ្វើការគូសបញ្ជាក់គ្រោះថ្នាក់ក្នុងការផ្តេកផ្តួលហួសហេតុលើសេចក្តីរាយការណ៍តាម Twitter កាលពីសប្តាហ៍កន្លងទៅនេះ ដោយឲ្យទឡ្ហីករណ៍ថា ក្នុងយុគសម័យឌីជីតាល់ គេត្រូវមានការប្រុងប្រយ័ត្នខ្ពស់ថែមទៀតក្នុងប្រព័ន្ធផ្សព្វផ្សាយ ជាតួនាទីរបស់វា គឺឲ្យរាយការណ៍លើអង្គហេតុការណ៍ពិត មិនមែនប្រលោមលោកទេ។*

# ជំពូក ៥ យកព័ត៌មានប្រធានបទ

## ស្វែងយល់អំពី "មុខព្រួញ" (beat) ក្នុងការយកព័ត៌មាន

នៅខាងដើមសៀវភៅនេះ យើងបានធ្វើសង្កត់ធ្ងន់លើសារៈសំខាន់ក្នុងការអានឲ្យបានច្រើន។ អ្នកសារព័ត៌មានមានពុទ្ធិទូទៅ និងទូលំទូលាយ ដើម្បីជួយរំលេចព្រឹត្តិការណ៍ ដែលគេកំពុងតាមដានយកព័ត៌មានក្នុងទស្សនៈវែងឆ្ងាយមួយប្រៀបធៀបទៅនឹងព្រឹត្តិការណ៍ប្រហាក់ប្រហែលគ្នានេះដែរ។ ការអានច្រើន ក៏ដើម្បីជួយគេឲ្យអាចវិនិច្ឆ័យបានថា តើអ្វីគួរឲ្យចាប់អារម្មណ៍ ឬសំខាន់ដល់អ្នកអាន។ ប៉ុន្តែ អ្នកសារព័ត៌មានក៏ត្រូវការពុទ្ធិ ឬ**ចំណេះដឹងជាក់លាក់** (specific knowledge) ដែរ ដើម្បីក្លាយជាមនុស្សជោគជ័យក្នុងអាជីពរបស់ខ្លួន។ ពួកគេចាំបាច់ត្រូវយល់ពីភាពជាមូលដ្ឋាននៃប្រធានបទដែលពួកគេសរសេរ រួមមាន **វិធីការ** (processes) និង**ទម្រង់ការ** (procedures) របស់ស្ថាប័នដែលគេប្រចាំការយកព័ត៌មាន។ ពួកគេចាំបាច់ត្រូវដឹងអំពី**សាវតារ** និង**ប្រវត្តិ**ថ្មីៗរបស់ស្ថាប័នទាំងនោះ បើមិនដូច្នោះទេ ពួកគេនឹងគ្មានមធ្យោបាយអាចដឹងបានថា អ្វីមួយវាថ្មី ឬមានសារៈសំខាន់នោះបានឡើយ។ ហើយពួកគេក៏ចាំបាច់ត្រូវចេះ **ភាសាពិសេស** របស់អ្នកឯកទេសជាមួយគ្នានឹង**គោលគំនិតចម្បង** ក្នុងវិស័យរបស់អ្នកទាំងនោះផងដែរ។ នេះមិនមែនបានន័យថា អ្នកសារព័ត៌មានត្រូវក្លាយខ្លួនជាអ្នកឯកទេសទេ តែវាមានន័យថា ពួកគេត្រូវតែដឹងតើអ្នកណាជាអ្នកឯកទេស ហើយតើត្រូវទាក់ទងពួកគេបានដោយរបៀបណាខ្លះ បើជិតដល់កាលបរិច្ឆេទបញ្ចប់រឿង។

ភាគច្រើនអ្នកសារព័ត៌មានទទួលខុសត្រូវចំពោះមុខព្រួញប្រធានបទ ឬតំបន់ភូមិសាស្ត្រជាក់លាក់ខុសៗគ្នា ដែលគេហៅរបៀបនេះថា ជាភាសាអង់គ្លេស ឬជាភាសាខ្មែរ អាចហៅបានថាតាម "មុខព្រួញ"។ នៅតាមអង្គភាព សារព័ត៌មានតូចៗ អ្នកយកព័ត៌មានអាចត្រូវបានគេចាត់តាំងឲ្យយកព័ត៌មានច្រើនមុខព្រួញ ផ្ទុយគ្នានឹងអង្គភាពសារព័ត៌មានធំៗ ដែលនៅទីនោះអ្នកយកព័ត៌មានម្នាក់ៗច្រើនទទួលការចាត់តាំងឲ្យយកព័ត៌មានតែមួយវិស័យជាក់លាក់ប៉ុណ្ណោះ។ "មុខព្រួញ" រួមមានកិច្ចការនយោបាយ និងរដ្ឋាភិបាល ព្រហ្មទណ្ឌនិងតុលាការ ធុរកិច្ចនិងហិរញ្ញវត្ថុ បរិស្ថាន អប់រំសិក្សា កីឡា បញ្ហាសង្គម វប្បធម៌និងសិល្បៈ។ "មុខព្រួញ" ឯទៀតមាន ការដឹកជញ្ជូន បច្ចេកវិទ្យា កសិកម្ម យោធា កិច្ចការបរទេស វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រ សាសនា សុខាភិបាល និងសិទ្ធិមនុស្ស។ មានអ្នកយកព័ត៌មានខ្លះទទួលខុសត្រូវកាន់មុខព្រួញយកព័ត៌មានអំពីសហគមន៍ ក្រុង ខេត្ត ឬប្រទេសណាមួយជាក់លាក់តែម្តង។

នៅក្នុងចំណាត់ថ្នាក់ទាំងនេះមានប្រធានបទឯកទេសច្រើនថែមទៀត។ ឧទាហរណ៍ នាយកដ្ឋានកីឡាក្នុងអង្គភាពសារព័ត៌មានមួយ អាចចាត់តាំងអ្នកសារព័ត៌មានម្នាក់ឲ្យយកព័ត៌មានផ្នែកបាល់ទាត់ ហើយម្នាក់ទៀតកាន់ផ្នែកប្រដាល់។ ក្នុងនាយកដ្ឋានធុរកិច្ចអាចថា អ្នកយកព័ត៌មានម្នាក់កាន់ផ្នែកកម្មសិទ្ធិ និងអចលទ្រព្យ រីឯម្នាក់ទៀតផ្តោតទៅលើរឿងជំនួញ និងទេសចរណ៍។ ក្រោមមុខព្រួញវប្បធម៌ និងសិល្បៈ អ្នកយកព័ត៌មានម្នាក់អាចកាន់ខាងភាពយន្ត រីឯម្នាក់ទៀតសរសេរអំពីស្ថាបត្យកម្ម។ អង្គភាពសារព័ត៌មាននៅក្នុងប្រទេសមួយចំនួនមាន "មុខព្រួញ" ដែលមិនមាននៅក្នុងប្រទេសដទៃទៀត។ នៅប្រទេសឡាវ សំណល់គ្រឿងផ្ទុះ (unexploded ordnance) នៅ

តែជាចំណោទធំធេងមួយក្នុងប្រទេស ហើយគ្រាប់មីននៅតែបន្តជាប្រធានបទឯកទេសមួយក្នុងប្រទេសកម្ពុជានៅឡើយសព្វថ្ងៃនេះ។ ជារឿយៗ "មុខព្រួញ" ត្រូវបានកំណត់ទៅតាមស្ថាប័ន ដោយហេតុនេះហើយ អ្នកយកព័ត៌មានត្រូវបានគេចាត់តាំងឲ្យទៅយកព័ត៌មាននៅរដ្ឋសភា ក្រសួងពាណិជ្ជកម្ម ឬគណៈកម្មការទន្លេមេគង្គ។

មិនថាពួកគេត្រូវទទួលការចាត់តាំងឲ្យកាន់មុខព្រួញណាទេ វាជាការរំពឹងទុកថា អ្នកយកព័ត៌មានត្រូវតែមានពុទ្ធិតំរិះអំពីប្រធានបទដែលគេកាន់។ ខាងក្រោមនេះ គឺអនុសាសន៍មួយចំនួនដែលអ្នកអាចត្រងត្រាប់ ដើម្បីស្វែងយល់អំពី "មុខព្រួញ" ឲ្យបានកាន់តែប្រសើរថែមទៀត៖

- ចូរអាន**ក្លីបសាវតារ** (background clips) **ឬរឿងក្នុងបណ្ណសារ** (archived stories)។ ភាគច្រើនអ្នកសារព័ត៌មានដែលទើបនឹងទទួលការចាត់តាំងឲ្យកាន់មុខព្រួញណាមួយនោះ តែងចំណាយរាប់ម៉ោងដើម្បីអានអត្ថបទដែលអង្គភាពរបស់គេបានចុះផ្សាយកាលពីមុនមក ដើម្បីស្វែងយល់ពីអ្វីដែលទើបកើតឡើងកាលពីពេលថ្មីៗ និងថាតើអ្វីដែលជាជំណឹងត្រូវនឹងមុខព្រួញនោះ។ តាមធម្មតា មានព្រឹត្តិការណ៍ យុទ្ធនាការ និងបញ្ហាដែលកំពុងវិវត្តន៍ ហើយអ្នកសារព័ត៌មាន ដែលទើបទទួលការចាត់តាំង ចាំបាច់ត្រូវតែប្រឹងរត់ឲ្យទាន់សភាពការណ៍កំពុងវិវត្តន៍ឲ្យបានឆាប់តាមតែអាចធ្វើទៅបាន។ ពួកគេក៏ត្រូវអានរឿងពីគូប្រជែងរបស់គេ រួមមាន សេវាព័ត៌មានតាមប្រព័ន្ធទូរលេខអេឡិចត្រូនិក (wire service) និងទីភ្នាក់ងារព័ត៌មានបរទេសផង។
- **សួរនាំអ្នកសារព័ត៌មានជើងចាស់** ឬក៏អ្នកទាំងឡាយដែលកាន់មុខព្រួញដូចអ្នកកាលពីមុន។ ពួកគេអាចរីករាយនឹងចែករំលែកបទពិសោធន៍ផ្តល់មគ្គុទេសក៍ដល់អ្នកបានខ្លះ។
- សិក្សាឲ្យយល់អំពី **វិធីការ និងទម្រង់ការ (process and procedure)** ឲ្យបានឆាប់បំផុត។ អ្នកយកព័ត៌មានតុលាការត្រូវតែដឹងថាប្រព័ន្ធតុលាការធ្វើការរបៀបម៉េច រួមមាន ភាពខុសគ្នារវាងតុលាការរដ្ឋប្បវេណី និងតុលាការព្រហ្មទណ្ឌ សិទ្ធិជនជាប់ចោទ កន្លែងឃុំឃាំងទណ្ឌិត និងថា បើសិនជាមាននរណាម្នាក់ត្រូវបានតុលាការកាត់ឲ្យជាប់ពិរុទ្ធ តើគេអាចប្តឹងឧទ្ធរណ៍ តើគេអាចប្តឹងឧទ្ធរណ៍ចំពោះសាលក្រមនោះបានដោយរបៀបណា។ អ្នកយកព័ត៌មានសភាត្រូវដឹងថា តើគេធ្វើសេចក្តីស្នើច្បាប់របៀបម៉េច វិធានក្នុងការសួរដេញដោល និងថាតើគេត្រូវការរយៈពេលប៉ុន្មានទម្រាំនឹងច្បាប់ថ្មីមួយចូលជាធរមានបាន។ អ្នកយកព័ត៌មានកិច្ចការបរទេសត្រូវដឹងថា ពេលណាដែលមហាសន្និបាតអង្គការសហប្រជាជាតិបើកការប្រជុំ ហើយថាតើសមាគមអាស៊ានអនុម័តសេចក្តីសម្រេចចិត្តដោយរបៀបណា។ គួរដឹងជាមុនផងដែរថា ពេលណាដែលគេនឹងសម្ពោធរបាយការណ៍ថ្មី ពេលណាគេនឹងលើកសេចក្តីស្នើថវិកាថ្មី ពេលណាបេក្ខជនត្រូវចុះឈ្មោះសម្រាប់បោះឆ្នោត។ ទាំងអស់នេះ វាជួយដល់អ្នកក្នុងការត្រៀមខ្លួនផ្តើមសកម្មភាពបានមុនគូប្រជែងរបស់អ្នក។

- **ស្គាត់ជួបទៀងទាត់ជាមួយប្រភពព័ត៌មានសំខាន់ៗ**ក្នុងមុខព្រួញរបស់អ្នក ដើម្បីដើរឲ្យទាន់សភាពការណ៍ បើទោះជាជាព័ត៌មានដែលទទួលបានគ្រាន់តែជាសាវតារ ឬស្ថិតនៅក្រៅកំណត់ត្រាក៏ដោយ។ ការធ្វើដូច្នេះនឹងជួយបង្កើនការយល់ដឹងរបស់អ្នកអំពីអ្វីដែលកំពុងកើតឡើង និងអ្វីទៀតដែលរំពឹងថានឹងកើតមាននៅថ្ងៃមុខ។ អ្នកអាចយកព័ត៌មានបែបនេះទៅប្រើបាននៅថ្ងៃខាងមុខ។ ប្រភពសំខាន់ៗមិនមែនមានត្រឹមតែអ្នកមានអំណាចធ្វើសេចក្តីសម្រេចចិត្ត និងអ្នកដែលជាប្រធានអង្គភាពនោះទេ តែវាក៏អាចរាប់បញ្ចូលស្មៀន លេខា ទីប្រឹក្សាដែលដឹងអ្វីដែលកំពុងកើតមាន និងអ្នកឯទៀតដែលបានធ្វើការក្នុងស្ថាប័នមួយនោះអស់ជាច្រើនឆ្នាំមកហើយ។ ពួកគេអាចពន្យល់នយោបាយនៅពីក្រោយឆាក និងទម្រង់ការទាក់ទិនបញ្ហា។ ចូរព្យាយាមស្គាត់ជួបអ្នកទាំងនោះដោយផ្ទាល់ឲ្យបានញឹកតាមតែអាចធ្វើទៅបាន ដើម្បីអាចឲ្យពួកគេដឹងផងថាអ្នកជានរណា។ ធ្វើដូច្នេះវានឹងជួយសម្រួលការងារបានក្នុងករណីអ្នកស្ថិតក្នុងភាពបន្ទាន់បញ្ចប់សាច់រឿងមុនឱសានវាទ។
- **ចូរប្រព្រឹត្តជាមួយប្រភពឲ្យបានសមរម្យ** និងរាយការណ៍ឲ្យបានទៀងត្រង់នូវព័ត៌មានដែលពួកគេបានឲ្យមកអ្នក។ ធ្វើដូច្នេះវាជួយកសាងនូវការជឿទុកចិត្តពីសំណាក់ប្រភព ក៏ដូចជារក្សានូវឱកាសសម្រាប់គេបន្តចំណាយពេលជាមួយអ្នក និងពន្យល់បញ្ហាឲ្យអ្នកបានយល់។ ប៉ុន្តែ ចូរព្យាយាមកុំស្និទ្ធស្នាលពេកជាមួយប្រភពព័ត៌មាន



*តួលេខតែងជួយយើងក្នុងការសញ្ជឹងគិតអំពីស្ថានភាពនៃបញ្ហាមួយ។*

ពីព្រោះវាអាចនឹងជាការលំបាកដល់អ្នកក្នុងការធ្វើសេចក្តីរាយការណ៍ដោយអព្យាក្រឹតនៅពេលដែលអ្វីមួយចម្រូងចម្រាសកើតឡើង។

- **កុំនឹកឃើញតែពួកមន្ត្រី**នោះ តែចូរពិចារណាផងអំពីអ្នកប្រើប្រាស់ អ្នកបង់ពន្ធនិងមហាជន ដែលប្រើប្រាស់សេវាស្ថាប័នដែលជាមុខព្រួញការងាររបស់អ្នក ហើយត្រិះរិះមើលផងថាអំពីទស្សនៈរបស់ពួកគេចំពោះដំណើរការស្ថាប័ននោះ។ ប្រជាជននិងពលរដ្ឋជាសកម្មជនដែលមិនសប្បាយចិត្ត ក៏អាចជាប្រភពព័ត៌មានមានតម្លៃម៉្យាងដែរ។

- **ចូលរួមសិក្ខាសាលា**សម្រាប់អ្នកសារព័ត៌មានអំពីប្រធានបទដែលអ្នកតាមដាន ហើយសិក្ខាបែបនោះ អាចត្រូវបានផ្តុំផ្តើមដោយសមាគមអ្នកសារព័ត៌មានសាកលវិទ្យាល័យ ឬទីភ្នាក់ងារអន្តរជាតិ។ ចូរត្រៀមត្រាប់ស្វែងយល់ពីពួកអ្នកឯកទេសអ្វីដែលថ្មី និងសំខាន់និងពីរបៀបស្វែងយល់អំពីព្រឹត្តិការណ៍ថ្មីៗ ដូចជា ជំងឺផ្តាសាយបក្សី បញ្ហាសេដ្ឋកិច្ចពិភពលោក ឬអំពើភេរវកម្មក្នុងតំបន់ជាដើម។

- **អានការបោះពុម្ពផ្សាយ របាយការណ៍ និងព្រឹត្តិបត្រព័ត៌មាន** ដែលផលិតដោយទីភ្នាក់ងារ ឬឧស្សាហកម្មដែលជាមុខព្រួញយកព័ត៌មានរបស់អ្នក។ លោក ដេវីដ ប្រោន (David Brown) ដែលកាលនៅរស់ធ្លាប់ធ្វើជានិពន្ធនាយកកាសែត Daily Telegraph និងក៏ធ្លាប់ធ្វើជាគ្រូបង្ហាត់របស់ IMMF ដែរនោះ បានធ្វើការកត់សម្គាល់អត្ថបទខ្លីមួយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រដែលនិយាយអំពីជំងឺម៉្យាងក្នុងខួរក្បាលគោ។ អ្នកវិទ្យាសាស្ត្រហៅជំងឺប្រភេទនេះថា "bovine spongiform encephalophathy" ឬ BSE។ លោក ប្រោន ស្គាល់តម្លៃព័ត៌មាននៃអត្ថបទនោះភ្លាម ហើយក្រោយពីបានធ្វើសេចក្តីរាយការណ៍បន្ថែម បានប្រែក្លាយវាទៅជារឿងមួយដែលចាប់អារម្មណ៍ជាអន្តរជាតិ។ គាត់ឲ្យឈ្មោះជំងឺនោះថា "ជំងឺគោឆ្កួត" (mad cow disease)។

- ពិចារណារចូលរួម**សមាគមអាជីព** តួយ៉ាង Vietnam Forum for Environmental Journalists ឬមួយក៏ផែកវិបសាយរបស់អង្គការសារព័ត៌មានសាកល ដូចជា International Journalists' Network (www.ijnet.org)។ អង្គភាពមួយនេះប្រើនមានព័ត៌មានអំពីប្រធានបទឯកទេស និងតំណភ្ជាប់ទៅនឹងវិបសាយ និងគេហទិនានុលេខន៍ មានប្រយោជន៍ជាច្រើនទៀត។

ជាមួយនឹងអនុសាសន៍ណែនាំទាំងអម្បាលម៉ានខាងលើនេះ បទពិសោធន៍ក៏សំខាន់ណាស់ដែរក្នុងការធ្វើឲ្យយល់អំពី "មុខព្រួញ" របស់អ្នកសារព័ត៌មាន។ អ្នកប្រឡូកកាន់តែយូរ កាលណាអ្នកកាន់តែរៀនពីវាបានកាន់តែច្រើនកាលនោះ។ ដំណាក់កាលដំបូងអាចថាវាពិបាកបន្តិចហើយ ប៉ុន្តែអ្នកសារព័ត៌មានដែលប្រឹងធ្វើការ អាចនឹងជំនះបានការលំបាកទាំងនោះ ហើយតែប៉ុន្មានខែក្រោយមក គេនឹងកាន់តែមានការជឿជាក់ក្នុងខ្លួនគេខ្លាំងជាងមុនជាមិនខាន។

# លៃលកជាមួយពាក្យឯកទេសសម្រាយវាក្យសព្ទ - បច្ចេកទេសពន្យល់ដំណើរការ

នៅក្នុងគ្រប់ជំហាននៃជីវិតយើងបានបង្កើតភាសាមួយ ដែលមានអត្ថន័យជាក់លាក់ចំពោះអ្នកទាំងឡាយដែលជាផ្នែកមួយរបស់វា តែអ្នកក្រៅពីនោះមិនយល់ភាសានោះទេ។ ក្នុងនោះ មានភាសាសម្រាប់ហ្គេម និងសម្រាប់វិទ្យាសាស្ត្រធ្វើរ៉ុក្កែត។ ដូចគ្នាដែរក្នុងអាជីពសារព័ត៌មានរបស់យើង។ ឧទាហរណ៍ យើងនិយាយថា "leads", "briefs" and "sub-heads" និងបង្កើតភាសាច្រើនទៀតដែលអ្នកមិនមែនជាអ្នកសារព័ត៌មានមិនយល់ទេ។ អ្នកខ្លះចំណោមយើងប្រើពាក្យ KISS ដែលមានន័យថា Keep It Simple, Stupid (សរសេរឲ្យវាងាយស្តាប់ទៅ អាភ្លើ!) -- ដែលជារបៀបមួយរម្លឹកដល់យើងទាំងអស់គ្នាថា រឿងរបស់យើងចាំបាច់ត្រូវសាមញ្ញងាយឲ្យគេយល់បាន។

របៀបមួយទៀតក្នុងការចងចាំ គឺជានិច្ចកាលត្រូវនឹកឃើញដល់អ្នកអានរបស់យើង បើទោះជាថាអ្នកសរសេររឿងដាក់ក្នុងផ្នែកអ្នកឯកទេស ដូចជាផ្នែកធុរកិច្ច ឬវិទ្យាសាស្ត្រក្នុងទំព័រកាសែតក៏ដោយ៖

- បើទោះជាថាភាគច្រើននៃអ្នកអានរបស់អ្នកអាចជាមនុស្សឯកទេស ពួកគេមាន **ឯកទេសលើតែមួយមុខណាមួយនោះប៉ុណ្ណោះ**។
- រៀងរាល់ថ្ងៃ មហាជនច្រើនតែគ្រវាសភ្នែកលើអត្ថបទកាសែត មុននឹងសម្រេចចិត្តតើគួរអាន ឬមិនគួរអានអត្ថបទណា។ ពួកគេសុទ្ធជាអ្នកអានមានតម្លៃ ដូច្នេះអ្នកគួរធ្វើយ៉ាងណាកុំឲ្យបាត់បង់ពួកគេ។

នេះមានន័យថា អ្នកចាំបាច់សរសេររឿងរបស់អ្នកឲ្យបានល្អគ្រប់គ្រាន់សម្រាប់អ្នកឯកទេសក្នុងប្រធានបទនោះចាប់អារម្មណ៍ ប៉ុន្តែក៏ត្រូវតែសរសេរល្អក្នុងរបៀបមួយដែលអាចអនុញ្ញាតឲ្យអ្នក ដែលមិនមែនជាអ្នកឯកទេសអាចយល់តាមដានសាច់រឿងផងដែរ។ វាពិតជាពិបាកនឹងធ្វើដូច្នោះ ប៉ុន្តែយើងមានមគ្គុទេសក៍មួយចំនួន ដែលអាចជួយអ្នកបាន៖

១. អ្នកអានដែលចេះដឹងអំពីអ្វីមួយ ឬមានការយល់អំពីដំណើរការអ្វីមួយហើយនោះ ច្រើនតែផ្ទាត់ទំព័រកាសែតរកមើល តើមានអ្វីថ្មីក្នុងនោះដើម្បីអាន។ គ្មានអ្នកណាគេដែលសរសេរសំបុត្រទៅនិពន្ធនាយកដោយរអ៊ូទាំថា កាសែតមួយនេះពន្យល់អំពីអ្វីមួយ ដែលគេយល់រួចទៅហើយនោះទេ។

២. អ្នកទាំងឡាយដែលដឹងថារបស់ ឬការងារអ្វីមួយវាដំណើរការរបៀបម៉េច នឹងកាន់តែមានការជឿជាក់ប្រាកដក្នុងចិត្តជាមិនខាន នៅពេលដែលអ្វីដែលគេបានយល់ឃើញរួចមកហើយ ត្រូវបានអះអាងបញ្ជាក់ដោយអត្ថបទដែលបានចុះផ្សាយក្នុងកាសែត។

៣. ជានិច្ចកាលចូរគិតមើលថា តើមានឃ្លា ឬពាក្យជាទូទៅណាដែលមានន័យដូចគ្នាទេ? បើមាន ប្រើវាទៅ។ ឧទាហរណ៍ ជាជាងនិយាយថាផលិតផលក្នុងស្រុកសរុបបើកបានប្រាំភាគរយ យកល្អសរសេរថាសេដ្ឋកិច្ចលូតលាស់កើនប្រាំភាគរយ។ ប្រសិនបើចាំបាច់ អ្នកអាចប្រើវាក្យសព្ទបច្ចេកទេសនៅផ្នែកខាងក្រោមនៃរឿងក៏បានដែរ។ ប៉ុន្តែប្រហែលជាមិនចាំបាច់នឹងធ្វើដូច្នោះទេ។

៤. ធ្វើយ៉ាងណាកុំឲ្យប្រើវាក្យសព្ទបច្ចេកទេសក្នុងសេចក្តីផ្តើមរបស់អ្នកឲ្យសោះ។

៥. ពេលណាអ្នកមានភាពចាំបាច់ថាត្រូវតែប្រើវាក្យសព្ទបច្ចេកទេស កុំប្រើវាលាយឡំជាមួយអ្វីផ្សេងច្រើនពេក ដែលអាចនាំឲ្យអ្នកអានធុញ ដូចជា បន្ទុកប្រយោគ តួលេខ ឈ្មោះដែលគេមិនស្គាល់របស់មនុស្ស ទីកន្លែង និងអង្គការ ជាដើម។

៦. ផ្តល់សញ្ញាដល់អ្នកអានថា ពួកគេមិនចាំបាច់ត្រូវតែដឹងថាតើវាក្យសព្ទមួយមានន័យថាម៉េចទេ។ ពេលដែលអ្នកប្រើវាក្យសព្ទបច្ចេកទេសជាលើកដំបូង អ្នកអាចឲ្យសញ្ញារបៀបនេះទៅអ្នកអាន ដោយគ្រាន់តែនិយាយថា **"អ្វីដែលគេស្គាល់ថា"** ឬ **"អ្វីដែលសេដ្ឋកិច្ចវិទូហៅថា"** ឬក៏ **"អ្វីដែលជីវវិទូហៅថា"**។ តាមរយៈនេះ អ្នកអាននឹងយល់បានថាមិនមែនតែពួកគេទេដែលមិនយល់ តែសូម្បីតែអ្នកក៏មិនយល់ដែរ។ បន្ទាប់មកទៀត ចូរកុំភ្លេចពន្យល់វាក្យសព្ទទាំងនោះតាមតែអាចធ្វើទៅបាន។

៧. កុំពន្យល់វាក្យសព្ទបច្ចេកទេសដោយប្រើវាក្យសព្ទបច្ចេកទេសឯទៀត។ មានតែវេចនានុក្រមបច្ចេកទេសទេ ដែលធ្វើរបៀបនេះ។ រីឯលោកអ្នក គឺជាអ្នកសារព័ត៌មាន អ្នកឆ្លាក់ពាក្យសម្តីឲ្យគេមើលយល់។ ដូច្នេះ អង្គុយចុះ ហើយគិតមើលថាធ្វើដូចម្តេចសរសេរក្នុងភាសាយ៉ាងសាមញ្ញឲ្យគេចាប់បាន។ វាពិតជាពិបាកធ្វើ ប៉ុន្តែតើមានអ្នកណាដែលនិយាយថា មុខរបរសារព័ត៌មានវាស្រណុកនោះ?

៨. កុំបន្ទុចបង្អាក់សាច់រឿងរបស់អ្នកដោយងាកមកផ្តល់និយមន័យដល់អ្វីមួយនោះ។ ផ្ទុយទៅវិញ គួរទុកឲ្យនិយមន័យលេចស្តែងចេញពីក្នុងឃ្លាដែលនាំមកជាមួយនូវព័ត៌មានផ្សេងទៀតដែរនោះ។ ការធ្វើដូច្នេះគេឲ្យឈ្មោះថា **ការលាក់និយមន័យ**។ វាធ្វើឲ្យសាច់រឿងបន្តហូរ ហើយអ្នកអានក៏មិនសូវមានអារម្មណ៍ថា ទទួលការប្រៀនប្រដៅច្រើនដែរ។ ឧទាហរណ៍៖ *ក្រសួងនិយាយថា អត្រាអតិផរណាបានឈានដល់ប្រាំភាគរយ ហើយដែលជាលើកទីមួយ ហើយការកើនថ្លៃទំនិញ និងសេវាកម្មនានាឈានដល់លេខពីរខ្ទង់ចាប់តាំងពីឆ្នាំ ១៩៩៧ មក។*

៩. បើមានរបស់ច្រើនត្រូវកំណត់ និងពន្យល់ ចូរកុំធ្វើការពន្យល់អ្វីៗទាំងអស់ក្នុងកញ្ចុំឃ្លាមួយកន្លែង។ ធ្វើរបៀបនេះនឹងនាំឲ្យចង្វាក់រឿងនេះវាធ្លាក់ចុះ អ្នកអាចពន្យល់ផ្នែកទាំងឡាយណាដែលចាំបាច់ធ្វើឲ្យរឿងមានចលនាទៅមុខ ដោយទុកការពន្យល់បន្ថែមទៀតទៅដាក់ផ្នែកខាងក្រោមនៃរឿង។

១០. មានពេលខ្លះ វាប្រសើរជាងក្នុងការនិយាយអំពីមុខងាររបស់អ្វីមួយជាជាងគ្រាន់តែប្រាប់ថា វត្ថុ ឬរបស់នោះជាអ្វី។ ឧទាហរណ៍៖ *ឧបករណ៍និស្សន្ទអនុញ្ញាតឲ្យអ្នកទិញ និងអ្នកលក់ឯកភាពគ្នាលើតម្លៃទំនិញនាពេលអនាគត។ ឧទាហរណ៍មួយទៀត៖ ជាលិកាស្តើង (stem cell) អាចជួសជុលសរីរាង្គទាំងឡាយ ដែលរងការខូចខាតដោយសារវ័យកាន់តែចាស់ របួស ឬមេរោគ។ អ្នកវិទ្យាសាស្ត្រសង្ឃឹមថា នឹងអាចរៀនយល់ដឹងបានថែមទៀតអំពីថាតើគេគួរប្រើវិធីជាធម្មជាតិមួយនេះ ដោយរបៀបម៉េច ដើម្បីព្យាបាលអ្នកជំងឺ។*

១១. ការពន្យល់អំពីដំណើរការអាចមានប្រសិទ្ធភាពជាងការព្យាយាមពន្យល់វាក្យសព្ទនីមួយៗ។ ឧទាហរណ៍៖ ជំនួសឲ្យការប្រើវាក្យសព្ទ "អន្តរាគមន៍ការដោះដូររូបិយប័ណ្ណបរទេស" (foreign exchange intervention) យកល្អ អ្នកគួរសរសេរដូច្នេះវិញថា៖ ធនាគារមជ្ឈិមលក់ ឬទិញរូបិយប័ណ្ណរបស់ខ្លួន ដើម្បីឲ្យរូបិយប័ណ្ណដទៃទៀតរុញអត្រាប្តូរប្រាក់ឡើងចុះទៅតាមអ្វីដែលគេគិតថាវានឹងនាំមកនូវផលចំណេញដល់សេដ្ឋកិច្ចរបស់គេ។

១២. វាមានប្រសិទ្ធភាពជាងក្នុងការពន្យល់ភាពអវិជ្ជមាននៃវត្ថុមួយជាមុនសិន។ ឧទាហរណ៍៖ ជាលិកាស្តើងផ្តល់កំណើត (embryonic stem cell) មិនមែនកើតមកពីស៊ុតក្នុងខ្លួនស្ត្រី ដែលគេបញ្ចូលសុក្កាណូនោះទេ។ ជាលិកាកំណើតបានមកដោយស្ត្រីប្រគល់ឲ្យគេសម្រាប់បម្រើសេចក្តីត្រូវការស្រាវជ្រាវ ហើយត្រូវបានគេយកទៅចញ្ចឹមក្នុងមន្ទីរពិសោធន៍សម្រាប់ផ្តល់កំណើត។

១៣. ចូរសាកផ្តល់ឧទាហរណ៍ជាក់ស្តែងអំពីអ្វីដែលអ្នកកំពុងព្យាយាមពន្យល់។

១៤.ប្រើសម្រង់សម្តី (ចូរក្រឡេកមើលផ្នែកមានគូសបន្ទាត់ពីក្រោម) នៅចុងបញ្ចប់រឿង ដើម្បីគូសបញ្ជាក់ឡើងវិញនូវសារៈសំខាន់នៃអ្វីមួយ។ ឧទាហរណ៍៖ ពេលដែលអ្នកវិទ្យាសាស្ត្រទទួលជោគជ័យក្នុងការប្រែជាលិកាស្តើងរបស់មនុស្សឲ្យក្លាយទៅជាជាលិកាស្តើងផ្តល់កំណើត មានមនុស្សជាច្រើនបានគិតថា នេះមានន័យថាពួកគេលែងចាំបាច់ប្រើពន្លកកំណើតក្នុងស្បូនសម្រាប់គោលបំណងនេះទៀតហើយ។ តែវាមិនពិតដូច្នោះទេ។ *អ្នកស្រាវជ្រាវនិយាយថា ការស្រាវជ្រាវផ្នែកជាលិកាស្តើងផ្តល់កំណើតនឹងនៅតែបន្ត។ អ្នកស្រាវជ្រាវម្នាក់និយាយថា៖ "ជាលិកាស្តើងរបស់មនុស្ស គឺជាស្តង់ដារមាស"*។

១៥.កុំបញ្ចូលព័ត៌មានបន្ទាប់បន្សំដែលមិនចាំបាច់ (*មើលផ្នែកមានគូសបន្ទាត់ពីក្រោម*) ក្នុងឃ្លា ឬប្រយោគដដែលនៃការពន្យល់របស់អ្នក។ ឧទាហរណ៍៖ SARS *ដែលជាជំងឺស្រួចស្រាវផ្លូវដង្ហើមដំបូងកើតឡើងនៅតំបន់អាស៊ី ហើយក្រោយមកបានរាលដាលដល់ប្រទេសជាងដប់នៅទ្វីបអាមេរិកខាងជើង អាមេរិកខាងត្បូង និងទ្វីបអឺរ៉ុប* គឺបណ្តាលមកពីវីរុសម្យ៉ាង ហើយឆ្លងតាមរយៈមនុស្សនៅជិតគ្នា។

១៦.មធ្យោបាយម្យ៉ាងល្អក្នុងការពន្យល់អំពីទម្រង់ការ គឺដោយនិទានរឿង ឧទាហរណ៍ដូចជា ករណីសិក្សាណាមួយពាក់ព័ន្ធនឹងមនុស្ស។ អ្នកអានយល់អ្វីៗបានគ្រាន់បើជាងតាមរយៈការនិទានរឿងជាងតាមមធ្យោបាយណាផ្សេងទៀត។

១៧. បើសិនជាអ្នកសរសេរអត្ថបទវិភាគដំណឹង ឬបទពិពណ៌នា ចូរពិចារណាកុំយកនិយមន័យនៃអ្វីមួយមកឡុកឡំក្នុងសាច់រឿង ចូរយកវាទៅដាក់ក្នុងប្រអប់ ឬក្រាហ្វិកមួយដោយឡែកវិញ។

## ការប្រើប្រាស់លេខ

មនុស្សតិចនាក់ណាស់ ហើយជាមនុស្សអធម្មតា ដែលចូលចិត្តលេខ (យ៉ាងណាមិញ យើងគួរមានសេចក្ដីរីករាយថាមានមនុស្សធន់នេះ ពីព្រោះពួកគេធ្វើរឿងមានប្រយោជន៍ច្រើនណាស់ដល់សង្គមមនុស្ស ដូចជាបើកយន្តហោះឲ្យយើង ឬប្រឌិតវត្ថុឲ្យមនុស្សម្នាប្រើប្រាស់ជាដើម)។ ប៉ុន្តែភាគច្រើននៃពួកយើងជាមនុស្ស ក្នុងនោះ មានអ្នកអានរបស់យើងផង ពិតជាធុញទ្រាន់កាលណាឃើញលេខច្រើនហួសហេតុពេក។

យើងមិនអាចគេចវេសពីលេខបានទេ។ តាមពិតលេខសំខាន់ណាស់សម្រាប់សិល្បៈសរសេររបស់យើង ដូច្នេះ យើងត្រូវចេះប្រែក្លាយវាក្នុងការប្រើជាប្រយោជន៍ដល់យើង។ នេះមានន័យថាដឹងពីរបៀបប្រើលេខសម្រាប់ពង្រឹងខ្លឹមសាររឿង និងពីរបៀបដែលគួរចៀសវាងនៅពេលដែលលេខច្រើនពេកអាចរំខានដល់គុណភាពសាច់រឿងទៅវិញ។ និយាយឲ្យខ្លី លេខជួយពង្រីកអត្ថន័យរឿងពេលណាដែលគេប្រើវាតំណាងឲ្យអ្វីមួយដែលបានកើតឡើង ឬមួយក៏ដើម្បីធ្វើការប្រៀបធៀបអ្វីមួយជាមួយនឹងអ្វីមួយទៀត។ ប៉ុន្តែលេខនឹងបង្ករំខានដល់សារជាតិនៃរឿងទៅវិញ បើសិនជាអ្នករាយកាណ៍ព័ត៌មានមិនចេះគិត ហើយប្រើប្រាស់វាដោយគ្រាន់តែកូរពីវាចេញពីឯកសារមួយទៅដាក់ក្នុងរឿងជាមួយនឹងក្ដីសង្ឃឹមថានឹងមានមនុស្សចាប់អារម្មណ៍ជាមួយលេខទាំងនោះ។

បើអ្នកឃើញថាលេខតំណាងឲ្យអ្វីម្យ៉ាង អ្នកពិតជាមិនសូវមានអារម្មណ៍មួយហ្នងជាមួយវាប៉ុន្មានទេ។ ប្រសិនបើអ្នកកំពុងព្យាយាមសរសេររឿងមួយអំពីកម្មករ ១០០ នាក់ ដែលត្រូវបានគេបញ្ឈប់ពីការងារនៅរោងចក្រស្បែកជើង ABC Shoe Company អ្នកពិតជាមិនសប្បាយក្នុងការសរសេរទេ បើសិនជាអ្នកត្រូវសរសេរបង្ហាញឈ្មោះនីមួយៗរបស់កម្មករទាំងអស់នោះ។ លេខ ១០០ គឺតំណាងឲ្យបុគ្គលទាំងអស់នោះ។



*ពាណិជ្ជករប្រកបរបរចិញ្ចឹមជីវិតតាមរយៈការយល់អំពីលេខ។*

មុខងារមួយទៀតរបស់លេខ គឺវាឲ្យយើងធ្វើការប្រៀបធៀប។ អ្នកយកព័ត៌មានទូទៅម្នាក់អាចសរសេរថា៖ មនុស្សប្រាំនាក់បានស្លាប់ក្នុងគ្រោះថ្នាក់អគ្គីភ័យមួយ ដែលបានឆាបឆេះឡើងនៅក្លឹបរាត្រីមួយក្នុងទីក្រុង។ វាជារឿងល្អមួយ (តែគួរឲ្យសោកសៅផងដែរ)។ តែសម្រាប់អ្នកយកព័ត៌មានហិរញ្ញវត្ថុវិញ គេពិតជាមិនអាចគ្រាន់តែសរសេរថា រោងចក្រ ABC Shoe Company ផលិតបានស្បែកជើង ១.០៥០ គូក្នុងឆ្នាំនេះនោះទេ។ ដើម្បីឲ្យរឿងនេះមានអត្ថន័យគ្រប់គ្រាន់យើងត្រូវតែសរសេរបន្ថែមថា ប្រៀបធៀបទៅនឹង ១.០០០ គូ កាលពីឆ្នាំមុន។ អ្នកយកព័ត៌មានទូទៅមិនចាំបាច់និយាយថា "ប្រៀបធៀបនឹងចំនួនមនុស្សស្លាប់បីនាក់កាលពីឆ្នាំមុននោះទេ ប៉ុន្តែអ្នកយកព័ត៌មានវិស័យឯកទេស ត្រូវតែធ្វើការប្រៀបធៀបបែបនេះ។

អ្វីដែលអ្នកយកព័ត៌មានវិស័យឯកទេសចាំបាច់ត្រូវដឹងអំពីលេខ មាន៖

- ស្ថិតិអ្វីខ្លះដែលអ្នកចាំបាច់ត្រូវយល់
- តើប្រើវារបៀបម៉េចពេលអ្នកសរសេរ ឬកែសម្រួលអត្ថបទរឿង

## ប្រភាគ

ប្រភាគជាមូលដ្ឋាន គឺលេខដែលសាមញ្ញបំផុតសម្រាប់អ្នកអានទូទៅ ដូចជា ពាក់កណ្តាល មួយភាគបួន មួយភាគបី មួយភាគប្រាំ និងមួយភាគដប់។ ប្រភាគបែបផ្សេងទៀតអាចនាំឲ្យអ្នកអានវង្វេងទៅវិញទេ ដូច្នេះចៀសវាងកុំប្រើវា។ កន្លែងណាដែលអ្នកមានលេខ ឬភាគរយច្រើន ចូរតម្រឹមវាឡើង ឬចុះឲ្យទៅជាប្រភាគជាមូលដ្ឋាន។

ឧទាហរណ៍*ជាជាងនិយាយថា ៥១,២ ភាគរយ ចូរសរសេរថា "ប្រហែលពាក់កណ្តាល" វិញ ស្រួលស្តាប់ជាង។ ជាជាងសរសេរថា ៧៣,៩ ចូរនិយាយថា "ជិតបីភាគបួន" វិញ ល្អជា។*

វិធីមួយទៀតក្នុងការប្រើប្រភាគ គឺប្រើពាក្យជាជាងតួលេខក្នុងការពន្យល់។ ឧទាហរណ៍ជាជាងនិយាយថា មួយភាគបី ចូរសរសេរថា "មួយក្នុងចំណោមបីនាក់" វិញ។ ជាជាងសរសេរថា ៦៨,៩ ភាគរយ ចូរនិយាយថា "ប្រាំពីរក្នុងចំណោមដប់" វិញ។

មានពេលដែលគេត្រូវតែប្រើ បើសិនជាមានលេខជាក់លាក់ ឧទាហរណ៍ ពេលរាយការណ៍អំពីលទ្ធផលបោះឆ្នោត ការឡើងចុះរូបិយវត្ថុ ទិន្នន័យផ្សារភាគហ៊ុន សូចនាករសេដ្ឋកិច្ចសំខាន់ៗ ដូចជាតួលេខថ្មីៗស្តីអំពីអត្រាគ្មានការងារធ្វើ ឬក៏ការផ្លាស់ប្តូរអត្រាអតិផរណា ឬអត្រាការប្រាក់ជាដើម។

## ចំនួនភាគរយ

ចំនួនភាគរយប្រហែលជាប្រភេទស្ថិតិដែលគេប្រើញឹកញាប់ជាងគេ ដោយហេតុថា វាមានលក្ខណៈប្រៀបធៀបនៅក្នុងនោះរួចទៅហើយ។ ចំនួនភាគរយជារបៀបរិះគិតអំពីអ្វីមួយដែលជាផ្នែកនៃអ្វីមួយ។

ចូរចាំថា កុំធ្វើកំហុសក្នុងការនិយាយថា អ្វីមួយរួមតូច ដោយវាកើនបានបីភាគរយប្រៀបនឹងប្រាំភាគរយនៅឆ្នាំមុន។ វានៅតែកើនអញ្ចឹង គ្រាន់តែវាកើនយឺតជាងមុនតែប៉ុណ្ណោះ។

ចូរចាំថា ភាពខុសគ្នារវាងចំនួនពីរភាគរយ គឺពីរខ្ទង់ភាគរយនេះតែម្តង។ ដូចបង្ហាញក្នុងឧទាហរណ៍ខាងលើ អត្រាកំណើនមានពីរខ្ទង់ភាគរយយឺតជាងឆ្នាំមុន។

## ទិន្នផល

ពាក្យនេះក៏ជាចំនួនភាគរយដែរ តែវាសំដៅលើ **ចំណូលពីការវិនិយោគ (return on investment)** វិញ។

## សន្ទស្សន៍

សន្ទស្សន៍ គឺជាការវិវត្តបន្តនៃចំនួនភាគរយ។ ជាជាងហៅចំនួនដើមថា ១០០ (វាល្អ ដោយសារថា វាជាចំនួនធំ ត្រឹម ងាយយល់) ពេលណាដែលអ្នកចង់ធ្វើការប្រៀបធៀប ឬធ្វើការគណនាការប្រែប្រួលណាមួយ អ្វីដែលសន្ទស្សន៍ធ្វើបាន គឺវាហៅចំនួនដើម ១០០ នៅកាលវេលាមួយជាក់លាក់ ហើយតាមដានការប្រែប្រួលនៅក្នុងរយៈពេលនោះ។ ហេតុដូច្នេះ ហើយអ្នកឃើញលេខដូចជា (1997=100) សរសេរនៅក្បែរសន្ទស្សន៍។ នេះមានន័យថា យើងហៅអ្វីមួយដែលយើងកំពុងស្វែងរកជាចំនួន ១០០ ក្នុងឆ្នាំ ១៩៩៧។ ដូច្នេះច្រើនឆ្នាំកន្លងមក ពេលដែលសន្ទស្សន៍ឡើងដល់ ១៩៧,៥ យើងអាចនិយាយបានថារបស់មួយហ្នឹង (មិនមែនសន្ទស្សន៍ទេ) មានទំហំសឹងតែទ្វេដងទៅហើយ។ និយាយម្យ៉ាងទៀត សន្ទស្សន៍ គឺជារបៀបមួយសម្រាប់តាមដានមើលការប្រែប្រួលក្នុងដំណាក់កាលណាមួយ។

សន្ទស្សន៍ចាប់ផ្តើមមានភាពស្មុគស្មាញពេលដែលវាធ្វើការវាស់វែងរបស់ច្រើនមុខ ដូចជាតម្លៃទំនិញសម្រាប់អ្នកប្រើប្រាស់ ឬក៏ទំនិញរាយ ឬសេវានានា។ ត្រង់នេះគេហៅថា សន្ទស្សន៍ទំនិញប្រើប្រាស់ ឬសន្ទស្សន៍ថ្លៃទំនិញរាយ។ ក្នុងករណីនេះ នាយកដ្ឋានស្ថិតិរៀបចំបញ្ជីមុខឥវ៉ាន់ដែលគ្រួសារនីមួយៗ អាចត្រូវចំណាយជាមធ្យមទៅលើក្នុងមួយខែ (ដូចជា ថ្លៃឈ្នួលផ្ទះ មធ្យោបាយធ្វើដំណើរ កាត់សក់ ឌីវីឌី ម្ហូប សម្លៀកបំពាក់ ជាដើម) ហើយគេធ្វើការគណនាចំណាយសរុបលើទំនិញ និងសេវាមួយ "កន្ត្រក" នោះ។ ឧទាហរណ៍ថា ចំនួនជាប់ខាតមួយ ដែលមានតម្លៃ $173។ ខែបន្ទាប់ចំនួននេះ គឺ $174.29 និង $174.87 នៅខែបន្ទាប់មកទៀត។ ក្នុងនេះ តម្លៃខែទីមួយអាចចាត់ទុកបានថាជាចំនួន ១០០ ទៅចុះ ហើយលេខក្នុងខែបន្តបន្ទាប់មកទៀត ឆ្លុះបញ្ចាំងឲ្យឃើញនូវការប្រែប្រួលភាគរយ ដែលមិនមែនជាចំនួនជាប់ខាតទេ។

អ្វីដែលកើតមានជាមួយនឹងសន្ទស្សន៍ផ្សារភាគហ៊ុនមានភាពស្រដៀងគ្នានេះដែរ។ វាជាតួលេខនព្វន្តសាស្ត្រប្រមូលផ្តុំពីតម្លៃចំណែកភាគហ៊ុនរបស់ក្រុមហ៊ុនជាច្រើន ដោយមានការថ្លឹងថ្លែងទៅតាមទំហំរបស់ក្រុមហ៊ុន ឬកត្តាផ្សេងទៀត។ លទ្ធផលចុងក្រោយបានន័យថា សន្ទស្សន៍ គឺបារ៉ូម៉ែត្រមួយដែលឆ្លុះបញ្ចាំងនូវអ្វី ដែលបានកើតឡើងដល់ភាគហ៊ុនទាំងនោះ។ ភាគហ៊ុនខ្លះឡើង ភាគហ៊ុនខ្លះស្រុតចុះ។ វាអាស្រ័យថា ភាគហ៊ុនមួយណាឡើង មួយណាចុះ ហើយវាឡើងចុះកម្រិតណា សន្ទស្សន៍ក៏នឹងប្រែប្រួលតាមនោះដែរ។

សន្ទស្សន៍មិនមែនជាឯកតា (ដូចជា ឯកតាប្រាក់ដុល្លារ ឬរង្វាស់សង់ទីម៉ែត្រ) នោះទេ។ វាគ្រាន់តែជាចំនួនលេខប៉ុណ្ណោះ។ ភាពខុសគ្នារវាងឯកតា និងសន្ទស្សន៍ក្នុងថ្ងៃដែលវាចាប់ផ្តើមជួញដូរ គឺចំនួនភាគរយ។ មួយរយៈពេលក្រោយមក ការប្រៀបធៀបរវាងសន្ទស្សន៍ថ្ងៃនេះជាមួយនឹងពេលដែលវាចាប់ផ្តើមជួញដូរ លែងយកជាបានការហើយ។ អ្វីដែលគេខ្វល់ គឺភាពខុសគ្នារវាងតួលេខបច្ចុប្បន្ន និងតួលេខមុននេះបន្តិចតែប៉ុណ្ណោះ។

សន្ទស្សន៍ទាំងឡាយមានប្រយោជន៍ពេលណាដែលវាធ្វើឲ្យគេតាមដានការវិវត្តរបស់ពីរបាន ឬអាចប្រៀបធៀបរបស់ពីរនោះបានក្នុងដំណាក់កាលណាមួយ តាមរយៈការគណនាសន្ទស្សន៍ទាំងពីរក្នុងថ្ងៃ

ជាមួយនឹងថ្ងៃចាប់ផ្តើមដូចគ្នាដូរតែមួយ ដូចជាសន្ទស្សន៍ប្រាក់បៀវត្សរ៍ ឬថ្លៃឈ្នួលផ្ទះជាដើម។ បើសិនជាថ្លៃឈ្នួលផ្ទះរបស់អ្នកឡើងលឿនជាងប្រាក់បៀវត្សរ៍ អ្នកឯងជួបការយ៉ាប់យ៉ឺនជាងមុនក្នុងការរស់នៅ ហើយសន្ទស្សន៍នឹងអាចប្រាប់អ្នកបានថាតើយ៉ាប់ជាងមុនប៉ុណ្ណា។

សន្ទស្សន៍ដែលមានរួចមកហើយ តែមិនមានថ្ងៃចាប់ផ្តើមដូចគ្នាទេនោះ អាចយកមកប្រៀបធៀបគ្នាបានតាមរយៈការប្តូរថ្ងៃចាប់ផ្តើមរបស់វាជាលក្ខណៈនព្វន្តសាស្ត្រឲ្យទៅដូចគ្នាវិញ ដែលនេះជាដំណើរការមួយគេឲ្យឈ្មោះថា rebasing។

ភាពលម្អៀងខុសគ្នា អាចមាននៅពេលដែលអ្វីមួយដែលមានចំនួនតិច ក្រៅពីចំនួនពលរដ្ឋទាំងមូលត្រូវបានគេវាស់វែងដែរ។ ប្រសិនបើប្រទេស A និងប្រទេស B មានវេជ្ជបណ្ឌិត ១.០០០ នាក់ ដូចគ្នា អ្នកនឹងអាចបានយល់កាន់តែច្រើនថែមទៀត បើសិនជាគេប្រាប់អ្នកថា ប្រទេស A មានវេជ្ជបណ្ឌិត ៥ នាក់ សម្រាប់ពលរដ្ឋចំនួននីមួយៗ ១០.០០០ នាក់ ហើយប្រទេស B មានវេជ្ជបណ្ឌិត ១០ នាក់ សម្រាប់ពលរដ្ឋចំនួននីមួយៗ ១០.០០០ នាក់។ នេះជា **សូចនាករសង្គម**មួយ មានប្រយោជន៍ដល់អ្នកអានទូទៅយល់បាន។

## សម្រាប់មនុស្សម្នាក់ (Per Capita)

ចំនួនលេខខ្លះមានអត្ថន័យ គេអាចយល់បាន ប្រសិនបើអ្នកដឹងថា មានមនុស្សប៉ុន្មាននាក់ដែលចំនួនលេខនោះមានការពាក់ព័ន្ធជាមួយ។ ពាក្យ **per capita** ជាពាក្យឡាតាំងដែលមានអត្ថន័យត្រង់ថា **សម្រាប់ក្បាលនីមួយៗ** ឬដែលយើងនិយាយឲ្យស្រួលស្តាប់ គឺសម្រាប់មនុស្សម្នាក់ ឬក្នុងមនុស្សម្នាក់។ គេប្រើវាក្យសព្ទនេះ ដើម្បីជួយពន្យល់អំពីការប្រមាណសម្បត្តិ ឬចំណូលក្នុងមនុស្សម្នាក់នៅក្នុងប្រទេសមួយ។ អ្នកប្រហែលយល់បានពេញលេញទេ ប្រសិនបើគេនិយាយប្រាប់អ្នកថា ផលិតផលក្នុងស្រុកសរុប (gross domestic product/GDP: ផលិតផលសរុប ដែលប្រទេសមួយផលិតបានក្នុងមួយឆ្នាំ ) របស់ប្រទេស A គឺមានតម្លៃ ១០០ ពាន់-លានដុល្លារអាមេរិក ហើយប្រទេស B មានតម្លៃ ៥០ ពាន់លានដុល្លារអាមេរិក។ ប្រទេស A មានប្រជាជនពីរដងច្រើនជាងប្រទេស B ដូច្នេះ វាមានន័យថា ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ - ឬ GDP - ក្នុងប្រទេសទាំងពីរស្មើគ្នា។

## អនុបាត (Ratios)

និយាយក្នុងន័យចង្អៀត អនុបាត ឬផលធៀប គឺជាខ្នាតមួយដែលគេប្រើជាពហុមេគុណទៅនឹងរបស់មួយផ្សេងទៀត។ ឧទាហរណ៍ ដូចគេនិយាយថាមួយនៃអាមួយនេះ ឬ ២០ នៃមួយក្រុមនោះជាដើម។ ឧទាហរណ៍ដែលគេតែងប្រើ គឺជាមួយគ្រូបង្រៀនក្នុងការធ្វើផលធៀបជាមួយកូនសិស្សក្នុងថ្នាក់។ ឧទាហរណ៍ គ្រូម្នាក់សម្រាប់សិស្ស ៤០ នាក់។ តែក៏សូមប្រយ័ត្នផងដែរ ដោយសារថាមានរបស់ច្រើនមុខ ដែលគេប្រើក្នុងន័យអនុបាត ឬផលធៀប តែតាមពិតវាជាចំនួនភាគរយទៅវិញទេ។ ពាក្យអនុបាត ឬផលធៀបនេះ បានបាត់បង់អត្ថន័យនព្វន្តសាស្ត្រដើមរបស់វាទៅហើយ ។បច្ចុប្បន្នត្រូវបានគេប្រើ ដើម្បីសម្តែងទំនាក់ទំនងលេខរវាងវត្ថុពីរ។ អ្នកដែលចូលចិត្តប្រើពាក្យឯកទេស គេហៅអនុបាត ឬផលធៀបនេះថាជា **មេទ្រិក (metrics)**។

បន្ថែមលើស្ថិតិទាំងនេះ មានគោលគំនិតមួយចំនួន ដែលអ្នកត្រូវដឹងពេលណាអ្នកត្រូវលែលកជាមួយលេខ។ គោលគំនិតទាំងនោះមាន៖

- **និន្នាការ :** គឺនៅពេលដែលអ្នកឯកទេសស្ថិតិ ធ្វើការពិនិត្យតាមដានដំណើរវិវត្តន៍ជាទ្រឹស្តីនៃអ្វីមួយក្នុងរយៈកាលណាមួយនោះ ដោយព្យាយាមកំណត់ឲ្យបាននូវនិន្នាការឡើង និងចុះរបស់វា។
- **រយៈកាល :** អ្នកត្រូវដឹងឲ្យប្រាកដថា តើរយៈកាលណាមួយ ដែលតួលេខនោះនិយាយយោងទៅរក។ តើតួលេខទាំងនោះជាតួលេខក្នុងខែនេះប្រៀបទៅនឹងខែមុន ឬក៏ជាតួលេខក្នុងខែនេះប្រៀបទៅនឹងតួលេខក្នុងខែដូចគ្នាកាលពីឆ្នាំមុនទៅវិញ? តើតួលេខទាំងនោះ ជាតួលេខក្នុងត្រីមាសនេះប្រៀបទៅនឹងត្រីមាសកន្លងទៅ ឬក៏ជាតួលេខក្នុងត្រីមាសនេះប្រៀបទៅនឹងតួលេខក្នុងត្រីមាសដូចគ្នាកាលពីឆ្នាំមុនទៅវិញ? ឬមួយក៏វាជាតួលេខប្រចាំខែ ឬប្រចាំត្រីមាស ដែលគេចងក្រងសម្រាប់ពេញមួយឆ្នាំ? ជានិច្ចកាល អ្នកត្រូវតែសួរអ្នកណាដែលបញ្ចេញតួលេខទាំងនោះ បើសិនជាវាមិនច្បាស់ទេថា តើវាតំណាងឲ្យរយៈកាលណា ហើយអ្នកក៏ត្រូវតែពន្យល់វាឲ្យបានភ្លឺច្បាស់ដែរ ចាប់ពីតាំងពីខណៈដំបូង ដែលអ្នកប្រើវានៅក្នុងរឿង។
- **ការកែសម្រួលតាមរដូវ (Seasonal adjustment):** ការកែសម្រួលតាមរដូវនេះ គឺអ្វីដែលពួកស្ថិតិតែងធ្វើ ដើម្បី "ពង្រាប" តួលេខឲ្យរាបស្មើ។ ឧទាហរណ៍ នៅរដូវដាំដុះ និងរដូវទេសចរណ៍ តួលេខ មានភាពខុសគ្នាច្រើនក្នុងដំណាក់កាលមួយឆ្នាំ ដូច្នេះតួលេខត្រូវបានគេលៃសម្រួលឲ្យមកជា "មធ្យម" វិញតំណាងឲ្យឆ្នាំនោះ។ ដូច្នេះ ចូរកុំភ្លេចបញ្ជាក់ជាមួយអ្នកកាន់ស្ថិតិថា តួលេខហ្នឹង ត្រូវបានគេកែសម្រួលតាមរដូវរួចហើយឬនៅ ហើយពន្យល់វាឲ្យច្បាស់ក្នុងរឿងផង។
- **ជាតុផ្សំអនិយត ឬមិនទៀងទាត់ (Allowing for erratic items) :** ត្រង់នេះ មានភាពប្រហាក់ប្រហែលនឹងការកែសម្រួលតាមរដូវដែរ។ បានន័យថា យកចេញនូវតួលេខទាំងឡាយណាដែលតំណាងឲ្យមួយខែ ឬមួយត្រីមាសដែលអាចបកស្រាយខុសនូវទិដ្ឋភាពរួមទាំងមូល។ ឧទាហរណ៍ បើក្រុមហ៊ុនអាកាសចរណ៍ជាតិមួយ ចំណាយលើការទិញយន្តហោះប្រាំគ្រឿងក្នុងខែមេសាតែមួយ ការហូរចេញនៃរូបិយវត្ថុនឹងមានសភាពធំធេងណាស់។ ដូច្នេះ ចូរដកជាតុផ្សំអនិយតបែបនេះចេញ ហើយអ្នកនឹងទទួលបាននូវទិដ្ឋភាពមួយប្រសើរជាងមុន ស្តីអំពីតុល្យការចំណាយរបស់ប្រទេសនោះ។
- **ថ្លឹងថ្លែង :** ស្នៀតមួយទៀតរបស់អ្នកនព្វន្តសាស្ត្រ គឺការយកមកពិចារណានូវទំហំ ឬ "ទម្ងន់" ផ្សេងៗគ្នានៃវត្ថុជាតុផ្សំក្នុង "កន្ត្រក" តែមួយ។ បើសិនជាគ្រួសារថ្នាក់មធ្យមមួយចំណាយមួយភាគបួននៃថវិការបស់ខ្លួនទៅលើថ្លៃឈ្នួលផ្ទះ ប្រការនេះនឹងត្រូវបានគេផ្តល់ "ទម្ងន់" ធំធេងជាងក្នុងការគណនាសូចនាករថ្លៃចាយវាយទូទៅរបស់អ្នកប្រើប្រាស់។ ដូច្នេះ បើថ្លៃឈ្នួលផ្ទះកើន ១០ ភាគរយ និងថ្លៃស្ករកៅស៊ូកើន ៥០ ភាគរយ កំណើនភាគរយនៅក្នុងសូចនាករទូទៅនឹងឆ្លុះបញ្ចាំងនូវទម្ងន់សារៈសំខាន់ធំធេងជាងរបស់ថ្លៃឈ្នួលផ្ទះជាតម្លៃស្ករកៅស៊ូ។

- **លក្ខខណ្ឌជាក់ស្តែងក្នុងតម្លៃថេរ ៈ** នេះ គឺនៅពេលដែលតួលេខត្រូវបានគេលៃសម្រួលតាមអតិផរណា។ ឧទាហរណ៍ជាប្រពៃណីនោះ គឺផលិតផលក្នុងស្រុកសរុប ឬមួយក៏តម្លៃនៃរបស់របរទំនិញ និងសេវាទាំងអស់ ដែលសេដ្ឋកិច្ចមួយផលិតបានក្នុងមួយឆ្នាំ។ បើសិនជាទំហំនៃរបស់របរ និងសេវាដែលផលិតបានឆ្នាំនេះមានទំហំដូចគ្នានឹងឆ្នាំទៅមិញដែរ ហើយថ្លៃទំនិញគ្រប់សារពើបានកើន ១០ ភាគរយ ដូច្នេះផលិតផលក្នុងស្រុកសរុបធម្មតា *(nominal GDP)* ដែលបានកំណត់ទុកជាមុននោះ ក៏នឹងកើន ១០ ភាគរយដែរ។ ប៉ុន្តែកំណើនផលិតផលក្នុងស្រុកសរុបជាក់ស្តែង *(real GDP)* នឹងមានតម្លៃសូន្យទៅវិញ។ ដូច្នេះ អ្នកត្រូវតែធ្វើការផ្ទៀងផ្ទាត់បញ្ជាក់ឲ្យបានច្បាស់ថា តើតួលេខនោះជាក់ស្តែង (ដែលគេហៅបានដែរថាតួលេខក្នុងតម្លៃថេរ) ឬក៏ជាតួលេខធម្មតា (ដែលគេស្គាល់ថាជាតួលេខក្នុងតម្លៃបន្ត) ហើយ ចូរកុំភ្លេចបញ្ជាក់ឲ្យច្បាស់អំពីភាពខុសគ្នានេះនៅក្នុងរឿងឲ្យអ្នកអានបានដឹងផង។

វាត្រូវការពេលវេលាទំរាំអ្នកយល់បានអំពីចំណុចទាំងអស់នេះ លើកលែងតែថាអ្នកជាមនុស្សពូកែជាមួយលេខស្រាប់។ ប៉ុន្តែព្យាយាមកុំមើលស្រាលជាមួយវា។ ការគណនាលេខខុសយកមកសរសេរសម្រាប់អ្នកសារព័ត៌មានឯកទេស វាស្មើគ្នានឹងអ្នកសារព័ត៌មានរាយការណ៍ខុសអំពីពិន្ទុក្នុងវិស័យកីឡាដែរ។ អាហ្នឹងជាប្រការដែលអ្នកមិនត្រូវបណ្តោយឲ្យកើតបានទេក្នុងអាជីពសារព័ត៌មាន។

និយាយដល់ការសរសេររឿង មានមគ្គុទ្ទេសក៍មួយចំនួនសម្រាប់ការប្រើដ៏មានប្រសិទ្ធភាពបំផុតនូវតួលេខ៖

១. ប្រើតួលេខដើម្បីបម្រើសាច់រឿង តែមិនមែនធ្វើសាច់រឿងឲ្យទៅបម្រើតួលេខទេ។ ត្រិះរិះមើលថាតើរឿងនិយាយអំពីអ្វី? បន្ទាប់មកសាកឆ្លើយនឹងសំណួរនេះដោយមិនប្រើតួលេខអ្វីទាំងអស់។ តាមរបៀបនេះ អ្នកនឹងមិនធ្លាក់ខ្លួនជាឧបករណ៍របស់លេខទេ។ និយាយម្យ៉ាងទៀត យើងត្រូវចាត់ទុកតួលេខថាគ្រាន់តែជាឧបករណ៍សម្រាប់ប្រាប់សាច់រឿងដល់អ្នកអានតែប៉ុណ្ណោះ តែវាមិនមែនជាសារជាតុស្នូលរបស់រឿងទេ។

២. បើអ្នកគិតថាតួលេខសំខាន់ដល់ការយល់សាច់រឿង ធ្វើយ៉ាងណាកុំដាក់តួលេខលើសពីពីរក្នុងសេចក្តីផ្តើម។ ក្នុងការអនុវត្តទូទៅបច្ចុប្បន្នសម្រាប់សេចក្តីផ្តើម គឺគេសង្កត់ធ្ងន់ទៅលើសំណួរ **ហេតុអ្វី (Why?) និងបុះវាយ៉ាងម៉េច (So what?)** មិនមែនតួលេខទេ។

៣. តាមធម្មតា រឿងនីមួយៗមិនគួរមានតួលេខលើសពីប្រាំ ឬប្រាំមួយទេ។ វាច្រើនណាស់ទៅហើយសម្រាប់អ្នកអាន ដូច្នេះតួលេខកាន់តែតិចកាន់តែល្អ។

៤. ចូពង្រាយលេខក្នុងទូទាំងសាច់រឿង កុំដាក់វាឲ្យនៅមួយក្រញុំ។

៥. ទុកឲ្យនៅជាមួយជុំលេខណាដែលមានទំនាក់ទំនងជាមួយគ្នា។ បើនៅក្នុងកថាខណ្ឌទីមួយនៃរឿង អ្នកធ្វើសេចក្តីរាយការណ៍អំពីតួលេខនៃការលក់ដូរក្រុមហ៊ុនមួយ

កុំចាំទាល់តែដល់កថាខណ្ឌចុងក្រោយ ទើបបង្ហាញតួលេខនៃការលក់ក្រុមហ៊ុនមួយទៀតប្រហាក់ប្រហែលនេះដែរ។

៦. ចូរចងចាំថា លេខគ្រាន់តែជាកត្តាមួយប៉ុណ្ណោះ ដែលអាចសម្លាប់នូវចំណាប់អារម្មណ៍របស់អ្នកអាន។ នៅមានកត្តាផ្សេងទៀត ដូចជាឃ្លាវែងៗ ឈ្មោះក្រុមហ៊ុន ទីកន្លែង ឬមនុស្សដែលគេមិនសូវស្គាល់ និងពាក្យសព្ទបច្ចេកទេស ដែលអាចធ្វើឲ្យអ្នកអានបាត់បំណង់ចង់អានអត្ថបទតទៅទៀត។ ដូច្នេះ បើអ្នកមានធាតុផ្សំទាំងអស់នេះ ព្យាយាមដាក់វាឲ្យនៅដោយឡែកពីគ្នា ហើយចំពោះតួលេខវិញ កុំយកវាច្រើនពេកមកប្រើក្នុងរឿង។

៧. វិធីម៉្យាងទៀត គឺសាកយកតួលេខខ្លះទៅដាក់ក្នុងតារាង ឬប្រែក្លាយវាទៅក្រាហ្វិកវិញ ព្រោះតាមរបៀបនេះ គេនៅតែអាចទទួលបានព័ត៌មានអំពីតួលេខទាំងនោះ ហើយសាច់រឿង ក៏នៅតែហូរដោយរលូនដែរ។

៨. កាលណាមានតួលេខ កុំភ្លេចផ្ទៀងផ្ទាត់វាម្តងហើយម្តងទៀត ដើម្បីឲ្យប្រាកដថា វាជាលេខពិតឥតក្លែងបន្លំ។

ខាងក្រោមជាអត្ថបទព័ត៌មានមួយដែលបង្ហាញឧទាហរណ៍ល្អឥតខ្ចោះអំពីការប្រើលេខ។ វាជាអត្ថបទដែលយើងបានប្រើជាឧទាហរណ៍រួចមកហើយក្នុងជំពូក ១។

*តួលេខធំត្រូវបានគេប្រែក្លាយទៅជាគំនិតមួយសាមញ្ញ ងាយយល់ នោះគឺយន្តហោះទម្លាក់គ្រាប់បែករៀងរាល់ប្រាំបីនាទី អស់ពេលប្រាំបួនឆ្នាំជាប់គ្នា។*

*ជាជាងនិយាយថា ៣៥ ឆ្នាំ គេប្រើពាក្យបីទសវត្សរ៍ជំនួសវិញ។*

*"ស្វាគមន៍" គ្រាន់តែជាពាក្យឡកឡឺយសម្រាប់ទាក់ទាញអារម្មណ៍អ្នកអានដល់គោលគំនិតធំក្នុងរឿងតែប៉ុណ្ណោះ។*

***ប្រទេសឡាវនៅតែបង់ថ្លៃក្នុងរឿងសង្គ្រាមវៀតណាម***
***ដោយ Thin Lei Win***

*XIEN KHOUANG, Laos, Nov 27 (Reuters) - ចូរប្រមើលមើលថា តើជីវិតមានសភាពបែបណានៅក្នុងប្រទេសមួយ ដែលត្រូវបានទទួលរងការទម្លាក់គ្រាប់បែកកញ្ចុំពីយន្តហោះ B52 រៀងរាល់ប្រាំបីនាទី អស់រយៈពេលប្រាំបួនឆ្នាំ។*

*បន្ទាប់មកទៀត សាកស្រមៃមើលវាយ៉ាងម៉េចដែរ បើមានកូន និងចៅរបស់អ្នកដែលត្រូវបានសម្លាប់ និងរបួសដាច់ដៃដាច់ជើង ដោយសារគ្រាប់បែកទាំងនោះ បីទសវត្សរ៍ក្រោយពីសង្គ្រាមបានចប់ទៅហើយនោះ។*

*ស្វាគមន៍មកប្រទេសឡាវ ជាប្រទេសមួយ - បើគិតក្នុងអត្រាមនុស្សម្នាក់ - ដែលទទួលរងការទម្លាក់គ្រាបបែកធ្ងន់ធ្ងរជាងគេលើពិភពលោក ដែលនេះពិតជាកេរ្តិ៍ឈ្មោះគ្មាននរណាម្នាក់ចង់បានទេ។*

*តួលេខជាក់ស្តែងនៅត្រង់នេះ ដែលត្រូវបានគេតម្រឹមឲ្យងាយយល់។ ជាមួយគ្នានេះដែរ គឺការប្រៀបធៀប។*

*រវាងឆ្នាំ ១៩៦៤ និង ១៩៧៣ យោធាអាមេរិកទម្លាក់គ្រឿងផ្ទុះជាងពីរលានតោនមកលើប្រទេសឡាវ រួមមាន ក្នុងនោះគ្រាប់បែកកញ្ចុំដែលគេឲ្យឈ្មោះថាគ្រាប់បុមប៊ី ជាង ២៦០ លានគ្រាប់ផង។ បើនិយាយក្នុងទិដ្ឋភាពទូលំទូលាយជាងនេះ បរិមាណនេះវាច្រើនលើសពីបរិមាណនៃគ្រាប់ ដែលគេទម្លាក់លើទ្វីបអឺរ៉ុបក្នុងអំឡុងសង្គ្រាមលោកលើកទីពីរទៅទៀត។*

*តួលេខជាក់ស្តែងថែមទៀត តែត្រូវបានគេតម្រឹម ហើយសរសេរជាពាក្យសាមញ្ញវិញថា "រាប់រយ"។*

*ការទម្លាក់គ្រាប់បែករបស់អាមេរិកជាចម្បង គឺសំដៅបំផ្លាញបណ្តាញផ្លូវផ្គត់ផ្គង់របស់សត្រូវ ដែលឆ្លងកាត់ប្រទេសឡាវក្នុងអំឡុងសង្គ្រាមវៀតណាម។ សង្គ្រាមបានបញ្ចប់ទៅកាលពី ៣៥ ឆ្នាំ មុនរួចទៅហើយ តែសេចក្តីវិនាសគ្រោះថ្នាក់នៅតែបន្តកើតមានដល់ជនស៊ីវិលនៅឡើយ។ យោងតាមទីភ្នាក់ងារជំនួយអន្តរជាតិ Handicap International ជនស៊ីវិលរហូតដល់ទៅប្រមាណជា ១២.០០០ នាក់ ត្រូវបានសម្លាប់ ឬគ្រោះថ្នាក់ពិការដៃជើងចាប់តាំងពីពេលនោះមក ហើយគ្រោះថ្នាក់រាប់រយករណីកើតមានជារៀងរាល់ឆ្នាំ។*

## សម្ភាសន៍អ្នកឯកទេស

សឹងតែគ្រប់រឿងទាំងអស់អំពីប្រធានបទឯកទេស ចាំបាច់ត្រូវមានការពន្យល់ ឬក៏ពាក្យអត្ថាធិប្បាយពីសំណាក់អ្នកជំនាញការ។ ភាពប្រឈមរបស់អ្នកយកព័ត៌មាននៅត្រង់ថា គេមិនគ្រាន់តែត្រូវរកឲ្យបាននូវអ្នកជំនាញការដែលចេះដឹងជាងគេនោះទេ តែគឺត្រូវរកឲ្យបាននូវអ្នកជំនាញការ ដែលមានចេតនានិយាយក្នុងកំណត់ត្រា ឬក៏ជាមនុស្សដែលគេងាយយល់ និងដកស្រង់សម្តីផងដែរ។

ដំបូង អ្នកត្រូវដឹងថាកន្លែងណាដែលត្រូវរកអ្នកជំនាញទាំងនោះបាន។ សហសេវិកដែលកាន់ការងារយូរអង្វែងមកហើយអាចជួយបានក្នុងរឿងនេះ។ ពួកលេខា ឬអ្នកកាន់កិច្ចការសាធារណៈ ក៏អាចផ្តល់ជាអនុសាសន៍បានខ្លះដែរ។ តាមធម្មតា សាកលវិទ្យាល័យមានបញ្ជីសមាជិកគណៈសាស្ត្រាចារ្យ និងវិស័យមុខជំនាញរបស់គេ។ រីឯសាយអង្គការអន្តរជាតិតែងមានបញ្ជីអ្នកជំនាញ និងទំនាក់ទំនងសារព័ត៌មានតាមវិស័យផ្សេងៗ ដូចជាការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយភាពក្រីក្រជាដើម។

## សន្សំទំនុកចិត្ត

មានពេលខ្លះ វាពិបាកនឹងការសន្សំបានទំនុកចិត្តពីសំណាក់អ្នកជំនាញការដែរ។ ឧទាហរណ៍ អ្នកវិទ្យាសាស្ត្រមួយចំនួនគិតថា "អ្នកសារព័ត៌មានតែងតែសរសេរខុសជានិច្ច" ឬធ្វើការសម្រាយច្រើនពេក ឬក៏មិនយល់អ្វីទាំងអស់អំពីការស្រាវជ្រាវដ៏លំបាករបស់គេទេ។ ពិតណាស់ អ្នកវិទ្យាសាស្ត្រធ្វើការស្រាវជ្រាវរយៈពេលយូរអង្វែង ហើយជាធម្មតាពួកគេប្រយ័ត្នប្រយែងណាស់មុននឹងផ្តល់ចម្លើយណាមួយ។ វាក៏ពិតដែរថា អ្នកសារព័ត៌មានតែងតែស្ថិតក្នុងភាពប្រញាប់ប្រញាល់ស្វែងរកចម្លើយ និងព្យាយាមសំរាយអ្វីៗគ្រប់បែបយ៉ាងឲ្យអ្នកអានយល់។

នេះជាភាពតានតឹងមួយ តែមិនមែនដល់ថ្នាក់ថា វាជំនះមិនបាននោះទេ។

ដោយប្រើការអត់ធ្មត់ និងការអនុវត្តឲ្យបានច្រើន អ្នកសារព័ត៌មានបន្តិចម្តងៗ អាចធ្វើឲ្យអ្នកឯកទេស ផ្តល់ទំនុកចិត្តបាន។ តែជំហានដំបូង គឺការត្រៀមខ្លួនជាមុនសម្រាប់ធ្វើការសម្ភាសន៍ រួមមាន ទាំងការសាករៀនឲ្យចេះឲ្យបានច្រើនតាមតែអាចធ្វើទៅបាន នូវពាក្យឯកទេសរបស់អ្នកឯកទេសផងដែរ។ រៀបចំសំណួរសំខាន់ៗដែលអ្នកប្រុងនឹងសួរ។ កុំខាតពេលឥតប្រយោជន៍ជាមួយសំណួរមិនសូវសំខាន់ដែលអ្នកអាចទៅរកចម្លើយពីកន្លែងផ្សេងទៀតបាន។ អ្នកសារព័ត៌មានដែលបានត្រៀមខ្លួនមុនសម្ភាសន៍ តែងធ្វើឲ្យគេចាប់អារម្មណ៍ចង់និយាយជាមួយ។ កាលណាអ្នកសារព័ត៌មានកសាងបានកេរ្តិ៍ឈ្មោះតាមរយៈការធ្វើសេចក្តីរាយការណ៍ត្រឹមត្រូវ និងហ្មត់ចត់ ហើយទ្វារនឹងបើកចំហសម្រាប់ពួកគេ ហើយអ្នកឯកទេសឯទៀតនឹងពិតជាចង់ធ្វើសម្ភាសន៍ជាមួយដែរ។

ទន្ទឹមគ្នានេះក៏អាចមានបញ្ហាផងដែរ។ អ្នកឯកទេសខ្លះ ក្នុងនោះ មានអ្នកធ្វើអត្ថាធិប្បាយនយោបាយផង ចូលចិត្តបង្ហាញឈ្មោះរបស់ខ្លួនក្នុងទំព័រកាសែត និងក៏ជួយដល់អ្នកសារព័ត៌មាន។ ពួកគេឲ្យសម្រង់សម្តីល្អៗ ដែលធ្វើឲ្យអត្ថបទរឿងរស់រវើក ដូច្នេះអ្នកសារព័ត៌មានចេះតែងាកទៅរកអ្នកទាំងនោះសុំសម្ភាសន៍រហូត។ ប៉ុន្តែ វាក៏ជាប្រការមិនល្អទេ ក្នុងការពឹងផ្អែកទៅលើប្រភពដដែលខ្លាំងពេក។ នេះបានន័យថា យោបល់ប្រហាក់ប្រហែលដដែលៗ ត្រូវបានយកមកប្រើច្រើនលើកច្រើនសារ ដោយមើលរំលងមតិយោបល់ ដែលអាចគួរឲ្យចាប់អារម្មណ៍ជាងនេះទៅទៀត។ ដូច្នេះ កុំខ្ជិលពេក។ រកអ្នកឯកទេសផ្សេងទៀតសម្រាប់សួរសុំអត្ថាធិប្បាយផងទៅ។

## ភាពប្រឈម

អ្វីដែលពិបាកជាងគេក្នុងការសម្ភាសន៍អ្នកឯកទេស គឺការប្រឹងស្វែងយល់ពាក្យឯកទេស និងដំណើរការ និងទម្រង់ការដ៏ស្មុគស្មាញដែលជាផ្នែកនៃការងារប្រចាំថ្ងៃរបស់ពួកគេ។ ដូច្នេះ កុំខ្លាចសួរសុំការស្រាយបំភ្លឺលើបញ្ហាបច្ចេកទេសណាដែលអ្នកមិនច្បាស់ ឬក៏ការប្រៀបធៀបនានាដែលអាចជួយឲ្យអ្នកយល់បាន។ អ្នកឯកទេសភាគច្រើនពិតជារីករាយនឹងពន្យល់ឲ្យអ្នកយល់។ អ្វីដែលគ្រោះថ្នាក់បំផុតនោះ គឺការធ្វើការសន្មតលើអ្វីដែលអ្នកមិនដឹង ហើយផ្ទេរបន្តនូវកំហុសនោះទៅឲ្យអ្នកអាន។

អ្នកអាចថាឡើងវិញ ឬសង្ខេបអ្វីដែលអ្នកបានសិក្សាស្វែងយល់ ដើម្បីឲ្យអ្នកឯកទេសអាចជួយកែតម្រូវបើគេឃើញថាអ្នកមិនការយល់ខុស។ មុននឹងបញ្ចប់បទសម្ភាសន៍ ចូរសួរពួកឯកទេស តើអ្នកអាចទូរស័ព្ទមកម្តងទៀតបានទេ ដើម្បីសុំការស្រាយបញ្ជាក់លើចំណុចណាដែលអ្នកមិនច្បាស់។ សូមឲ្យអ្នកឯកទេសជួយផ្តល់អនុសាសន៍ តើអ្នកណាទៀតដែលអាចជាប្រភពដែលអ្នកគួរសួរនាំផងដែរ។ តាមធម្មតា អ្នកឯកទេសក្នុងវិស័យណាមួយតែងស្គាល់គ្នាទៅវិញទៅមក ហើយអ្នកឯកទេសម្នាក់ទៀតអាចជួយបញ្ជាក់បន្ថែមការយល់ដឹងរបស់អ្នកអំពីដំណើរការអ្វីមួយ ដែលអ្នកបានសួរនាំពីអ្នកឯកទេសមុននោះ។



*ភាពលម្អៀងរបស់អ្នកឯកទេស ពេលខ្លះក៏អាចទាញអ្នកឲ្យងាកខុសទិសដៅដែរ។*

# ស្វែងយល់ពីកេរ្តិ៍ឈ្មោះ និងភាពលម្អៀងរបស់ប្រភព

នៅក្នុងមុខរបរសារព័ត៌មាននេះមានពាក្យស្លោកមួយថា "អ្នកអាចមានកេរ្តិ៍ឈ្មោះល្អ ទាល់តែប្រភពរបស់អ្នកជាមនុស្សមានកេរ្តិ៍ឈ្មោះល្អដែរ" (you are only as good as your sources)។ ព្យាយាមរកមើលឲ្យដឹងថា តើមានអ្វីដែលធ្វើឲ្យមនុស្សម្នាក់មានលក្ខណៈសម្បត្តិបែបណា ដែលឲ្យគេផ្តល់អត្ថាធិប្បាយលើបញ្ហាមួយបាន។ តើគេបានរៀនសូត្រអំពីប្រធានបទមួយពីសាលាកសិកម្មពីមុនមកមានបទពិសោធន៍ ២០ ឆ្នាំ ធ្លាប់សរសេរចុះផ្សាយអត្ថបទស្រាវជ្រាវ ឬក៏ធ្លាប់ធ្វើបឋកថានៅតាមសន្និសីទធំៗ? តើអ្នកណាជាប្រភពល្អបំផុតសម្រាប់រឿងរបស់អ្នក?

ជាមួយគ្នានេះដែរ អ្នកគួរព្យាយាមកំណត់ឲ្យបានថាតើអ្នកឯកទេសដែលអ្នកកំពុងពិគ្រោះយោបល់ជាមួយ មានបុរេនិច្ឆ័យលំអៀងទៅខាងណា។ មានអ្នកខ្លះមិនលាក់លៀមភាពលំអៀងរបស់គេទេ ហើយថែមទាំងហ៊ានតស៊ូមតិសម្រាប់បុព្វហេតុដែលគេជឿជាក់លើដោយចំហទៀតផង។ វាជារឿងធម្មតាទេ ដែលមនុស្សមានភាពលំអៀងទៅខាងណាមួយ តែចូរអ្នកបញ្ជាក់ត្រង់នេះឲ្យបានច្បាស់ ដើម្បីបង្ហាញនូវបំណុចទស្សនៈខុសៗគ្នាក្នុងរឿង។

សម្រាប់អ្នកឯកទេសខ្លះ វាអាចមានភាពស្រពិចស្រពិលថា តើគេលំអៀងទៅខាងណា។ អ្នកខ្លះធ្វើការឲ្យក្រុមហ៊ុនឯកជន ដូច្នេះគេគិតតែធ្វើយ៉ាងណាឲ្យបានចំណេញ។ មន្ត្រីរដ្ឋការស៊ីវិលអាចប្រឹងលើកស្ទួយរបៀបវារៈគណបក្សនយោបាយ ឯអ្នកខ្លះទៀតធ្វើការផ្នែកស្រាវជ្រាវជាន់ខ្ពស់ ដែលផ្គត់ផ្គង់ថវិកាដោយក្រុមហ៊ុនធំៗ។ មានអ្នកវិទ្យាសាស្ត្រដ៏ល្បីជើងចាស់ម្នាក់នៃក្រុមហ៊ុនធ្វើបារីធំមួយលើពិភពលោក បានទៅធ្វើការឲ្យវិទ្យាស្ថានស្រាវជ្រាវថ្នាំពេទ្យប្រទេសថៃអស់ជាច្រើនឆ្នាំ ដោយលាក់លៀមមិនឲ្យគេដឹងអំពីទំនាក់ទំនងរបស់គាត់ជាមួយនឹងក្រុមហ៊ុនថ្នាំជក់នោះទេ។ អ្នកវិទ្យាសាស្ត្រម្នាក់នោះ ត្រូវបានគេចោទប្រកាន់ថាបានប្រឹងធ្វើឥទ្ធិពលទៅលើការស្រាវជ្រាវរបស់ថៃលើផ្នែកបរិស្ថាន រួមទាំងផលប៉ះពាល់ពីការហឺតផ្សែងបារីរបស់អ្នកមិនជក់ពីអ្នកជក់ផង។

ពេលណាអ្នកវិទ្យាសាស្ត្រធ្វើការចុះផ្សាយរបាយការណ៍ស្រាវជ្រាវរបស់គេ ឬប្រកាសលទ្ធផលការស្រាវជ្រាវរបស់គេក្នុងសន្និសីទសារព័ត៌មានណាមួយ ឬក្នុងអំឡុងពេលធ្វើសម្ភាសន៍ ចូរព្យាយាមស៊ើបមើលថាតើការស្រាវជ្រាវរបស់គេទទួលការឧបត្ថម្ភថវិកាពីខាងណា។ អ្នកអានមានសិទ្ធិដឹងអំពីបំណុចនេះ។

# ជំពូក ៦
# ធុរកិច្ច និងសេដ្ឋកិច្ច

ជាញឹកញាប់អ្នកពិតជាបានឮមនុស្សជាច្រើន រួមទាំងអ្នកសារព័ត៌មានផងនិយាយថា ពួកគេមិនចាប់អារម្មណ៍ជាមួយរឿងធុរកិច្ច និងសេដ្ឋកិច្ចទេ ហើយវាពិតជាគួរឲ្យស្រឡាំងពេលដែលឮដូច្នោះ។ យ៉ាងណាក៏ដោយ ទោះជាមិនច្រើនក្តី ក៏នៅមានអ្វីមួយចំនួន ដែលអាចជះឥទ្ធិពលតិច ឬច្រើនទៅលើសង្គមដែរ។ អាជីពសារព័ត៌មានល្អតែងរម្លេចបញ្ហាធុរកិច្ច និងសេដ្ឋកិច្ចឲ្យរស់រវើក ដោយធ្វើឲ្យវាមានទំនាក់ទំនង និងគួរចាប់អារម្មណ៍ដល់អ្នកអានជាច្រើន រួមទាំងធុរជនផងដែរ។

យើងពិតជាអាចសរសេរសៀវភៅក្រាស់មួយអំពីធុរកិច្ច និងសេដ្ឋកិច្ច ប៉ុន្តែយើងសូមនិយាយអ្វីដែលជាគ្រឹះមូលដ្ឋានបានហើយក្នុងសៀវភៅនេះ។ ក្នុងការធ្វើដូច្នេះ យើងត្រូវចែកប្រធានបទនេះចេញជាផ្នែកមួយចំនួន ហើយលើកសំណួរបួនឡើងថា៖ តើវាជាស្អី? ហេតុអ្វីបានជាវាមានសារៈសំខាន់ ឬជាទីចាប់អារម្មណ៍ដល់អ្នកអាន? តើរឿងប្រភេទណាខ្លះដែលអាចកើតចេញពីប្រធានបទនេះ? តើអ្វីខ្លះទៀតដែលជាគោលគំនិតសំខាន់ៗ?

មុននឹងយើងចូលដល់រឿងនេះ មានចំណុចមួយចំនួនដែលគួរចងចាំក្នុងការសរសេរព័ត៌មានអំពីវិស័យសេដ្ឋកិច្ច និងធុរកិច្ច៖

- **បើទោះជាយើងសរសេរអំពីធុរកិច្ចក្តី ក៏យើងនៅតែសរសេរក្នុងវិស័យសារព័ត៌មានដែរ**។ ដូច្នេះ ចូររកឲ្យបាននូវដំណឹងពិតប្រាកដ ហើយសរសេរឲ្យប៉ិនប្រសប់ និងសាមញ្ញបំផុតសម្រាប់អ្នកអានទូទៅយល់។
- **អ្នកជាមនុស្សឯកទេសក្នុងវិជ្ជាជីវៈសារព័ត៌មាន មិនមែនជាអ្នកឯកទេសក្នុងរឿងធុរកិច្ចទេ**។ ដូច្នេះ អ្នកត្រូវព្យាយាមបង្កើនជំនាញយកព័ត៌មាន និងជំនាញសរសេររបស់ខ្លួន ជាជាងទៅចូលរួមស្តាប់បទឧទ្ទេសនាមសេដ្ឋកិច្ច ឬមួយអានសៀវភៅសារព័ត៌មានល្អៗ អំពីវិស័យធុរកិច្ចក៏បានដែរ។
- **អ្នកមិនចាំបាច់ត្រូវតែយល់អ្វីៗគ្រប់បែបយ៉ាងទេ តែអ្នកគួរតែស្គាល់មនុស្សទាំងឡាយដែលយល់អ្វីៗជុំវិញរឿងសេដ្ឋកិច្ច និងធុរកិច្ច**។ ដូច្នេះ ចងក្រងការទាក់ទងល្អៗជាមួយអ្នកណាដែលអាចពន្យល់អ្នកអំពីពិភពសេដ្ឋកិច្ច និងធុរកិច្ចបាន។
- **មុននឹងសរសេររឿង អ្នកគួរសួរខ្លួនឯងថា ហេតុអ្វីបានជារឿងហ្នឹងអាចសំខាន់ ឬគួរឲ្យចាប់អារម្មណ៍ដល់មនុស្សទូទៅ**។ សួរសំណួរបែបនេះ គឺវាជួយអ្នកមិនឲ្យធ្លាក់ខ្លួនសរសេរសម្រាប់តែប្រភពរបស់អ្នក និងអ្នកឯកទេសនានា។
- **បើទោះវាជាក្រុមហ៊ុន ឬក្រសួងសេដ្ឋកិច្ចនោះជារបស់គេក៏ដោយ វានៅតែជារឿងរបស់អ្នកដដែល**។ ដូច្នេះ អ្នកត្រូវសម្រេចក្នុងការជ្រើសរើសមុមមកសរសេរ និងថាអ្នកណាខ្លះ ដែលអ្នកត្រូវជជែកសួរនាំ ដើម្បីយកព័ត៌មានមកសរសេរ។
- **បើអ្នកមិនយល់អ្វីមួយ ចូរសួរ ហើយបើនៅតែមិនយល់ទៀត រំលងវាចោលទៅ**។ ព្រោះថាអ្នកអានក៏ប្រហែលជាមិនយល់ដែរ បើសិនអ្នកមិនយល់ទៅហើយនោះ។ តែបើគេយល់វិញ គេនឹងសើចចំអកដាក់អ្នក ឬកាសែតរបស់អ្នកជាមិនខាន។

# សេដ្ឋកិច្ច

## តើវាជាអ្វី?

សេដ្ឋកិច្ច គឺជាបរិមាណសរុបនៃរបស់រាប់លានមុខដែលគេបង្កើតបាន ដូចជា៖

- ដំណាំដែលយើងដាំលើដី ឬអ្វីដែលយើងជីកគាស់ពីក្នុងដីមកវិញ។
- អ្វីដែលមនុស្សធ្វើ ឬបង្កើតបាន។
- របស់របរដែលគេទិញ និងលក់។
- ប្រាក់ដែលយើងរកបានសម្រាប់ទិញរបស់របរ។
- ប្រាក់ដែលយើងបានពីការលក់របស់ ហើយតើយើងយកទៅធ្វើអ្វីខ្លះ។
- កិច្ចការដែលរដ្ឋាភិបាលធ្វើ ដើម្បីជួយ ឬរាំងស្កាត់របស់ទាំងអស់នេះ។

បរិមាណនៃអ្វីៗគ្រប់បែបយ៉ាងដែលមានសម្រាប់លក់ គេហៅវាថា **ការផ្គត់ផ្គង់** រីឯប្រាក់ដែលមានសម្រាប់ទិញឥវ៉ាន់ទាំងនោះ គេហៅវាថា **តម្រូវការ**។ ពេលណាមានការផ្គត់ផ្គង់ច្រើនពេក តែមិនសូវមានតម្រូវការ ថ្លៃឥវ៉ាន់នឹងធ្លាក់ទាប។ តែបើកាលណាមានតម្រូវការខ្ពស់ តែការផ្គត់ផ្គង់តិច ថ្លៃនឹងឡើងខ្ពស់។ ត្រង់នេះគេហៅថា **ច្បាប់នៃការផ្គត់ផ្គង់ និងតម្រូវការ**។ ធនធានធម្មជាតិរបស់ប្រជាជាតិមួយ រដ្ឋាភិបាលរបស់វា ធុរកិច្ចរបស់វា និងឥរិយាបថរបស់បុគ្គលគ្រប់រូបទាំងអស់នេះ មានឥទ្ធិពលលើការផ្គត់ផ្គង់ និងតម្រូវការ។ នេះមិនមែនជាច្បាប់ល្អឥតខ្ចោះទេ ពីព្រោះមានអ្វីៗច្រើនយ៉ាងដែលអាចមកជ្រៀតជ្រែករំខាន។ ប៉ុន្តែ វានៅតែជាគោលការណ៍មូលដ្ឋានមួយ ក្នុងចំណោមគោលការណ៍ជាច្រើនដែលសេដ្ឋកិច្ចវិទូប្រើ ដើម្បីស្វែងយល់អំពីពិភពលោករបស់យើង។

អ្នកសេដ្ឋកិច្ចវាស់វែងរបស់ទាំងអស់នេះ ហើយឲ្យឈ្មោះវា ដូចជា ផលិតផលក្នុងស្រុកសរុបអតិផរណា សមតុល្យសារពើពន្ធជាដើម។ ចំណែកឯរដ្ឋាភិបាល និងក្រុមដទៃ ដូចជាក្រុមធុរកិច្ច និងសហជីពពាណិជ្ជករជាដើម ពួកគេតែងព្យាយាមធ្វើឥទ្ធិពលលើផលិតផលក្នុងស្រុកសរុបតាមរយៈគោលនយោបាយផ្សេងៗ។ ជាមួយគ្នានេះដែរ ប្រជាជនធម្មតា ក៏ប្រឹងធ្វើឥទ្ធិពលទៅលើសមាសភាគសេដ្ឋកិច្ចតាមរយៈឥរិយាបថប្រចាំថ្ងៃរបស់គេដែរ ដោយភាគច្រើនមិនសូវបានគិត ឬដឹងថាពួកគេធ្វើដូច្នោះផងទេ។ ហេតុដូច្នេះហើយបានជាសេដ្ឋកិច្ចមិនមែនជាវិទ្យាសាស្ត្រទេ។ សេដ្ឋកិច្ចទាក់ទិនគ្រប់បែបយ៉ាងជាមួយនឹងសកម្មភាពរបស់មនុស្សរាប់ពីការធ្វើផែនការប្រកបដោយវិចារណញ្ញាណ សេចក្តីលោភលន់គ្មានវិចារណញ្ញាណ ការភ័យខ្លាច និងអំពើពុករលួយ។ ទាំងអស់នេះសុទ្ធតែជារឿងពិបាកគ្រប់គ្រងចាត់ចែង ដូច្នេះហើយបានជាមានសេដ្ឋកិច្ចជោគជ័យ និងបរាជ័យ ហើយគេតែងហៅបរាជ័យសេដ្ឋកិច្ចធំៗថាជាវិបត្តិហិរញ្ញវត្ថុ។

## ហេតុអ្វីបានជាវាសំខាន់ ឬគួរឲ្យចាប់អារម្មណ៍ដល់អ្នកអាន?

បានជាថារឿងមួយវាសំខាន់ និងគួរចាប់អារម្មណ៍ ពីព្រោះវានិយាយអំពីបញ្ហាទាំងឡាយដែលមានឥទ្ធិពលទៅលើអ្វីដែលអ្នកអាច ឬមិនអាចធ្វើបាន ហើយដោយសារហេតុអ្វី។ ស្ថិតិសេដ្ឋកិច្ចប្រាប់យើងឲ្យដឹងពីអ្វី ដែលយើងរស់នៅក្នុងសង្គមមួយបានធ្វើ និងអំពីអ្វី ដែលយើងរំពឹងថានឹងធ្វើនាពេលអនាគត និងថាតើមានគោលនយោបាយបែបណាខ្លះដែលគេអាចយកមកប្រើ ដើម្បីធ្វើឲ្យប្រែប្រួលឥរិយាបថរបស់យើង។ សភាពសុខភាពរបស់សេដ្ឋកិច្ចមួយអាចមានផលប៉ះពាល់ធំដុំមកលើជីវិតរបស់យើងផ្ទាល់តែម្តង ដូចជាលទ្ធភាពថាតើយើងអាចរំពឹងថា

នឹងរក្សាការងារបានឬទេ ឬក៏លទ្ធភាពរកលុយបានច្រើនជាងមុន ឬទេ។ វាក៏អាចមានឥទ្ធិពលជុំកំភួនផងដែរ ទៅលើវិស័យទូលំទូលាយនៃជីវិតតែម្ដង ដូចជាក្នុងស្ថានភាពនយោបាយ និងស្ថេរភាពបរិស្ថានរូបវន្ត សុខភាព និងសុខុមាលភាពរបស់យើង។

## តើរឿងប្រភេទណាខ្លះដែលអាចកើតចេញពីប្រធានបទនេះ?

ក្រោមប្រធានបទនេះ ជាទូទៅ រឿងច្រើនតែទាក់ទិនទៅនឹងស្ថានភាពបច្ចុប្បន្ននៃសេដ្ឋកិច្ច និងទស្សនវិស័យរបស់វាទៅថ្ងៃមុខ។ ទាំងអស់នេះគេហៅថា **សូចនាករសេដ្ឋកិច្ច** ហើយក្នុងនោះមានរង្វាស់នានា ដូចជា កំណើនផលិតផលក្នុងស្រុកសរុប (GDP) អតិផរណា អត្រាអត់ការងារធ្វើ សមតុល្យសារពើពន្ធ ការធ្វើពាណិជ្ជកម្ម និងបញ្ជីទូទាត់ចំណាយជាដើម *[សូមមើលខាងក្រោម]*។ ធម្មតា រដ្ឋាភិបាលចេញផ្សាយព័ត៌មានទាំងនេះជាទៀងទាត់ (ក្នុងប្រទេសខ្លះគេចេញផ្សាយរាល់ខែ) ប៉ុន្តែនៅប្រទេសខ្លះទៀត ទាំងស្ថិតិ និងភាពញឹកញាប់ក្នុងការចេញផ្សាយ គឺមិនអាចគួរឲ្យពឹងអាស្រ័យបានទេ។ ប៉ុន្តែនៅមានស្ថាប័នក្នុងស្រុក និងអន្តរជាតិជាច្រើន រួមទាំងធនាគារតំបន់ផង ដែលចេញផ្សាយតួលេខបែបនេះ ដែលយើងអាចស្វែងរកយកមកប្រើបាន បើទោះជាថាស្ថិតិទាំងនោះអាចយឺតយ៉ាវបន្តិចក្ដី។ ចូរកុំភ្លេចថែមគុណតម្លៃទៅលើស្ថិតិដែលទទួលបាន ដោយស្វែងរកអត្ថាធិប្បាយ និងការវិភាគទាំងពីអ្នកឯកទេស និងមនុស្សម្នាដែលមានការពាក់ព័ន្ធផ្ទាល់ ដូចជា កសិករ កម្មករ អ្នកបាត់បែងការ និងវិនិយោគិន។ កុំគ្រាន់តែសរសេរថាតើតួលេខនោះមានស្អីខ្លះ ចូរផ្ដោតលើផ្នែកនៃរឿងដែលឆ្លើយនឹងសំណួរថា ហេតុអ្វី និងថា តើវាមានអត្ថន័យយ៉ាងម៉េចសម្រាប់អ្នកអាន?

រឿងសេដ្ឋកិច្ចខ្លះទៀត រួមបញ្ចូលការរកឃើញ និងការធ្វើឲ្យហិនហោចដល់ធនធានធម្មជាតិ កំណើន និងចលនាប្រជាជន (ដូចជាពលករចំណាកស្រុក និងនគរូបនីយកម្ម ជាដើម) អក្ខរភាព និងកម្រិតការអប់រំ (ជំនាញ) ការផ្លាស់ប្ដូរ "ទម្លាប់" ក្នុងការសន្សំប្រាក់ និងការខ្ចីបុល និងស្ថានភាពសេដ្ឋកិច្ចប្រទេសជិតខាង និងនៅលើពិភពលោកទាំងមូលដែលមានផលប៉ះពាល់ជុំកំភួនលើសេដ្ឋកិច្ចប្រទេសរបស់អ្នក *[សូមមើលបន្ថែមក្នុងផ្នែកគោលនយោបាយរដ្ឋាភិបាល និងសេដ្ឋកិច្ច នៅខាងក្រោម]*។

## គោលគំនិតសំខាន់ៗមួយចំនួន

**ផលិតផលក្នុងស្រុកសរុប (GDP) :** នេះនិយាយសំដៅតម្លៃសរុបនៃផលិតកម្មដែលប្រទេសមួយផលិតបានក្នុងមួយឆ្នាំ ហើយត្រូវបានគេវាស់វែងចេញជាតម្លៃទឹកលុយ។ វារួមបញ្ចូលវត្ថុរូបវន្តដូចជាទំនិញប្រើប្រាស់ និងផលិតផលនានា (ដូចជាស្បៀង ឧស្ម័នធម្មជាតិ រថយន្ត) និងសេវាកម្ម (ដូចជា ថ្លៃចំណាយលើទូរស័ព្ទចល័ត និងថ្លៃឈ្នួលសាឡាងឆ្លងជាដើម)។ អ្នកសេដ្ឋកិច្ចយកចិត្តទុកដាក់ខ្លាំងណាស់ចំពោះកំណើនតួលេខនេះ ដូច្នេះរង្វាស់មេមួយ គឺ **កំណើន GDP សម្រាប់ម្នាក់ (per capita GDP growth)** ដែលជាកំណើនជាក់ស្ដែងក្នុងសម្បត្តិប្រទេសមួយ (មិនមែនគ្រាន់តែជាលទ្ធផលនៃការឡើងថ្លៃរបស់ទេ) យកមកចែកនឹងចំនួនប្រជាជនសរុប (ពីព្រោះថា បើសិនជា GDP កើនមែននោះ មានន័យថា ទ្រព្យត្រូវបានគេផលិតច្រើន ហើយក៏ត្រូវបានមនុស្សកាន់តែច្រើនប្រើប្រាស់ដែរ)។ ពេលណាដែលកំណើនធ្លាក់ចុះពីរត្រីមាសជាប់គ្នា (មានន័យថា ៦ ខែ ជាប់គ្នា) គេហៅស្ថានភាពបែបនេះថា **ការធ្លាក់ចុះសេដ្ឋកិច្ច (recession)**។ បើស្ថានភាពនេះបន្តមានរាប់ឆ្នាំ គេហៅវាថា **វិសម្ពាធសេដ្ឋកិច្ច (depression)**។

**អតិផរណា (inflation):** ពេលណាដែលថ្លៃទំនិញឡើង យើងហៅថា អតិផរណា។ (ថ្លៃទំនិញកម្រធ្លាក់បានយូរណាស់ តែបើវាធ្លាក់វិញ យើងហៅវាថា **បរិត្តផរណា (deflation)**។ រដ្ឋាភិបាលតែងបញ្ជូនអ្នកស្រាវជ្រាវ ដែលប្រដាប់ដោយកូនសៀវភៅកំណត់ហេតុឲ្យទៅតាមហាង ដើម្បីកត់ត្រាថ្លៃទំនិញរាប់រយមុខ រាប់តាំងពីស្ករកៅស៊ូដល់រថយន្តទំនើប។ ពួកគេក៏ពិនិត្យមើលតម្លៃស្ទើរមួយចំនួនដែរ ដូចជាថ្លៃជួលផ្ទះ និងថ្លៃធ្វើដំណើរជាដើម។ បន្ទាប់មកពួកគេធ្វើការប៉ាន់ប្រមាណមធ្យមភាគនៃអ្វីដែលគ្រួសារបានចំណាយលុយកាក់លើ និងគណនាមើលថាតើការចំណាយរបស់គេក្នុងខែនេះ អាចលើសចំណាយខែមុនទេ ហើយបើលើសតើវាលើសប៉ុន្មាន។ គេហៅ**ភាពខុសគ្នាជាភាគរយ**ថា អត្រាអតិផរណា។ អត្រាអតិផរណាតែភាគរយបន្តិចបន្តួចក៏គ្រោះថ្នាក់ដែរ ពីព្រោះវាបង្កផលប៉ះពាល់ដល់ពលរដ្ឋដែលចំណូលមានកម្រិត (ជាពិសេសមនុស្សចាស់ និងអ្នកក្រីក្រ) ហើយក៏បង្កភាពវិចវិលដល់ប្រាក់សន្សំដែរ។

**ភាពគ្មានការងារ :** ក្នុងប្រទេសសេដ្ឋកិច្ចជឿនលឿន ភាគរយនៃប្រជាជនចង់បានការងារ តែមិនអាចរកវាបាន គឺសំខាន់ ពីព្រោះមនុស្សក្រុមនេះតាមធម្មតា ទទួលការឧបត្ថម្ភពីរដ្ឋ ដែលគេហៅថា វិភាជន៍សង្គម (welfare)។ ផ្ទុយមកវិញ ការផ្តល់ប្រាក់វិភាជន៍ ក៏បង្កើនការចំណាយរដ្ឋដែរ។ ចំនួនមនុស្សប្រភេទនេះមិនពិបាកក្នុងការគណនាទេ។ រីឯក្នុងបណ្តាប្រទេសសេដ្ឋកិច្ចមិនសូវជឿនលឿន មនុស្សដែលគ្មានការងារតែងតែពឹងពាក់លើសមាជិកគ្រួសារ ឬបើមិនដូច្នោះទេ ពួកគេត្រូវទទួលរងការលំបាកមែនទែន។ ស្ថានភាពបែបនេះវាពិតជាអាក្រក់សម្រាប់ពួកគេ និងស្ថេរភាពនយោបាយផងដែរ។ ចំនួនមនុស្សប្រភេទនេះ គឺពិតជាពិបាកគណនា ដោយថាមួយផ្នែកមនុស្សក្នុងចំណោមនេះ ភាគច្រើនប្រកបការងារដែលមន្ត្រីរដ្ឋាភិបាល មិនដែលកត់ត្រាវាស់វែង។ ប៉ុន្តែទាំងនៅប្រទេសមានសេដ្ឋកិច្ចជឿនលឿន និងប្រទេសសេដ្ឋកិច្ចមិនសូវជឿនលឿន ចំនួនប្រជាជនគ្មានការងារ ត្រូវបានគេគណនាជាភាគរយនៃចំនួនប្រជាជនសរុប ដែលចង់រកឲ្យបានការងារមានកម្រៃ ដូច្នេះ តាមរយៈនេះគេហៅវាថា **អត្រាអត់ការងារ**។

**សមតុល្យសារពើពន្ធ (fiscal balance):** សារពើពន្ធសំដៅទៅលើថវិការដ្ឋាភិបាល បានន័យថា ជាចំនួនប្រាក់ដែលរដ្ឋបានពីការប្រមូលពន្ធ និងពីប្រភពដទៃទៀត និងចំណែកដែលរដ្ឋចំណាយលើវិស័យអប់រំ បៀវត្សរ៍បុគ្គលិករដ្ឋការស៊ីវិល យោធា នគរបាល ការផ្តល់ទីលំនៅ សុខាភិបាល ជាដើម។ សមតុល្យសារពើពន្ធ គឺជាភាពខុសគ្នារវាងអ្វីដែលរដ្ឋាភិបាលប្រមូលបាន និងអ្វីដែលខ្លួនត្រូវចំណាយទៅវិញ។ បើសិនជារដ្ឋាភិបាលចាយច្រើនជាងអ្វីដែលខ្លួនរកបាន គេហៅស្ថានភាពនេះថា **ឱនភាពថវិកា (budget deficit)**។ បើស្ថានភាពផ្ទុយពីនេះវិញ គេហៅវាថា **អតិរេកថវិកា (budget surplus)**។ បើរដ្ឋជួបនឹងឱនភាពថវិកា រដ្ឋត្រូវខ្ចីបុល ឬបោះពុម្ពក្រដាសប្រាក់ថែមយកមកប្រើ។ ការខ្ចីបុលខ្ពស់របស់រដ្ឋាភិបាលមានន័យថា ទៅថ្ងៃអនាគត ពន្ធក៏អាចនឹងត្រូវឡើងដែរ ដើម្បីយកប្រាក់មកទូទាត់សងការខ្ចីបុលកន្លងមក។ ឱនភាពដែលមានច្រើនជាង ៣ ភាគរយនៃ GDP ជាស្ថានភាពហានិភ័យមួយ។ ហើយបើសិនជារដ្ឋាភិបាលបោះពុម្ពក្រដាសប្រាក់ច្រើនពេក វានឹងនាំស្ថានភាពធ្លាក់ទៅរកអតិផរណាជាមិនខាន។

**អត្រាសន្សំប្រាក់ និងការវិនិយោគថេរ (saving rate and fixed investment):** វាជាប្រការល្អ សម្រាប់អ្នកក្នុងការសន្សំលុយដែលអ្នកអាចនឹងប្រើប្រាស់ថ្ងៃក្រោយទៀត ដើម្បីទិញផ្ទះ ឬបើកមុខរបរអ្វីមួយ ហើយដូចគ្នានេះដែរ វាល្អសម្រាប់សេដ្ឋកិច្ចមួយ បើសិនជាប្រទេសមានអត្រា

សន្សំប្រាក់ខ្ពស់។ ធ្វើដូច្នេះវាបង្កលទ្ធភាពដល់ធុរកិច្ចនានា និងរដ្ឋាភិបាលឲ្យខ្ចីលុយពីហិបសន្សំ ដើម្បីយកទៅវិនិយោគ និងពង្រីកសេដ្ឋកិច្ចថែមទៀតដែលឈានទៅដល់ការបង្កើតការងារថ្មី។ បើសិនជាការសន្សំទាប ធុរកិច្ច និងរដ្ឋាភិបាលត្រូវបង្ខំចិត្តខ្ចីបុលពីក្រៅប្រទេស ដែលអាចមានហានិភ័យក្នុងរយៈពេលយូរអង្វែង (ឬមួយរដ្ឋាភិបាលអាចបោះពុម្ពលុយថែមទៀត ដែលជាជម្រើសនយោបាយមួយមិនល្អទេ)។ វាជាប្រការសំខាន់ដែលលុយដែលធុរកិច្ច និងរដ្ឋាភិបាលខ្ចីបុល គួរតែត្រូវបានគេចំណាយលើការ**វិនិយោគយូរអង្វែង** ដូចជាលើរោងចក្រ ផ្លូវ កំពង់ផែ និងសាលារៀន ជាជាងលើចំណាយចរន្ត (current costs) ដូចជាលើប្រាក់បៀវត្សរ៍ ឥន្ធនៈរថយន្ត និងការចំណាយមិនទៀងទាត់មួយចំនួនទៀត។ ចំនួនប្រាក់ ដែលចំណាយលើកិច្ចការយូរអង្វែង ត្រូវបានគេឲ្យឈ្មោះថា វិនិយោគថេរ ("ថេរ" ព្រោះវាបន្តវិនិយោគលើមុខព្រួញដែលមានលក្ខណៈអចិន្ត្រៃយ៍)។ ការវិនិយោគថេរកាន់តែច្រើនកាលណា គឺកាន់តែល្អកាលហ្នឹង ពីព្រោះសេដ្ឋកិច្ចវាលូតលាស់ ហើយមនុស្សក៏កាន់តែមានបានជាងមុនដែរ។

**គណនេយ្យចរន្ត និងជញ្ជីងពាណិជ្ជកម្ម (current account and trade balance):** លុយតែងតែហូរចេញចូលប្រទេស ដើម្បីបង់ថ្លៃទំនិញ និងសេវាកម្មនានា ដែលគេធ្វើការជួញដូររវាងប្រទេស និងសម្រាប់ធ្វើការវិនិយោគ។ ពេលមានចរាចរទំនិញ និងសេវាកម្មបែបនេះ រូបិយវត្ថុរបស់ប្រទេសមួយ ត្រូវតែការផ្លាស់ប្ដូរទៅជារូបិយវត្ថុប្រទេសមួយទៀត។ នេះគេហៅថា ការដោះដូររូបិយវត្ថុបរទេស *[មើលខាងក្រោម]*។ ដូច្នេះក្នុងរយៈពេលយូរអង្វែង វាត្រូវតែមានតុល្យភាពរវាងសាច់ប្រាក់ដែលហូរចូល និងសាច់ប្រាក់ដែលហូរចេញ។ ពេលណា ត្រង់នេះនិយាយយោងទៅរកប្រាក់ដែលរកបានពីការ**នាំចេញ** ប្រៀបទៅនឹងប្រាក់ដែលចំណាយលើការ**នាំចូល** គេឲ្យឈ្មោះថា ជញ្ជីងពាណិជ្ជកម្ម។ ពេលយើងបញ្ចូលអ្វីៗផ្សេងទៀត ដូចជា ការបង់ចំណាយលើសេវាកម្ម តួយ៉ាងការដឹកជញ្ជូនតាមនាវា ទូរគមនាគមន៍ ទូទាត់ធនាគារជាដើម ព្រមទាំងការបង់**ការប្រាក់**លើបំណុល និង**ផលចំណេញ**ដល់វិនិយោគិនបរទេស ភាពខុសគ្នាត្រូវបានគេហៅថា តុល្យភាពគណនេយ្យចរន្ត ឬបើហៅតាមឈ្មោះពេញ គណនេយ្យចរន្តលើតុល្យភាពចំណាយ **(current account on the balance of payments)**។

## រដ្ឋាភិបាល និងនយោបាយសេដ្ឋកិច្ច

### តើវាជាស្អី?

រដ្ឋាភិបាលមានសារៈសំខាន់ដល់សេដ្ឋកិច្ច និងធុរកិច្ចដោយហេតុផលពីរយ៉ាង។ ទីមួយ រដ្ឋាភិបាលគឺជាអ្នកចូលរួមធំជាងគេនៅក្នុងសេដ្ឋកិច្ច - ក្នុងន័យនេះរដ្ឋាភិបាល គឺជាអ្នកដែលចាយលុយច្រើនជាងអ្នកណាទាំងអស់ គឺច្រើនជាងធុរកិច្ចធំៗទៅទៀត។ ទីពីរ រដ្ឋាភិបាល គឺជាអ្នកសម្រេចថា តើគួរចាត់ចែងសេដ្ឋកិច្ចរបៀបម៉េច។ ក្នុងប្រទេសខ្លះ រដ្ឋាភិបាលចាត់ចែងសេដ្ឋកិច្ចដោយផ្ទាល់តាមរយៈសហគ្រាសកាន់កាប់ដោយរដ្ឋ និងតាមរយៈសេចក្ដីសម្រេចដែលធ្វើឡើងដោយបណ្ដាក្រសួង។ នៅក្នុងប្រទេសដទៃទៀត រដ្ឋាភិបាលគ្រាន់តែព្យាយាមក្រាលគ្រឹះសម្រាប់ធុរកិច្ចឯកជនចាប់ផ្ដើមបើកមុខរបរ និងប្រមូលមនុស្សមកធ្វើការឲ្យគេ។ ពេលណាដែលរដ្ឋាភិបាលចាត់ចែងច្រើនមុខពេកក្នុងសេដ្ឋកិច្ច គេឲ្យឈ្មោះសេដ្ឋកិច្ចបែបនេះថាជា**សេដ្ឋកិច្ចបញ្ជា (command economy)**។ ពេលណាដែលគេទុកឲ្យធុរកិច្ចឯកជនប្រតិបត្តិសេដ្ឋកិច្ច គេឲ្យឈ្មោះវាថាជា**សេដ្ឋកិច្ចទីផ្សារ (market economy)**។

ប្រទេសភាគច្រើនមានទិដ្ឋភាពសេដ្ឋកិច្ចទាំងពីរបែបនេះដំណើរការជាមួយគ្នាតែម្តង។

ក្នុងសេដ្ឋកិច្ចបញ្ជា រដ្ឋាភិបាលកំណត់ចេញនូវគោលដៅផលិតទិន្នផល ហើយសហគ្រាសរដ្ឋនាំគ្នាប្រឹងសម្រេចឲ្យបានគោលដៅនោះ។ រដ្ឋាភិបាលជាអ្នកកំណត់ថ្លៃឥវ៉ាន់ និងអត្រាប្តូរប្រាក់ ហើយរដ្ឋជាអ្នកប្រាប់ទៅធនាគាររដ្ឋកាន់កាប់ថា អ្នកណាដែលគេគួរឲ្យខ្ចីលុយ ហើយក្នុងអត្រាការប្រាក់កម្រិតណា។ ទិដ្ឋភាពសេដ្ឋកិច្ចបែបនេះ ច្រើនតែនាំឲ្យលេចឡើងនូវ**សេដ្ឋកិច្ចស្រប ឬសេដ្ឋកិច្ចទីងងឹត (parallel or black economy)** ដែលក្នុងនោះ ធុរកិច្ច និងអ្នកជំនួញនាំគ្នារកស៊ីជួញដូរខុសច្បាប់ក្នុងអត្រាការប្រាក់ ឬតម្លៃផ្សារងងឹត។ បើមិនឲ្យមានសេដ្ឋកិច្ចទីងងឹតទេ ជាលទ្ធផល គឺនឹងមានការខ្វះខាតប្រភេទឥវ៉ាន់ណាមួយក្នុងទីផ្សារជាមិនខាន ដូចជាស្បៀងអាហារក្តី ទំនិញប្រើប្រាស់ក្តី ឬរូបិយប័ណ្ណបរទេសជាដើម។

ក្នុងសេដ្ឋកិច្ចផ្សារសេរី រដ្ឋាភិបាលគ្រាន់តែចាត់ចែងនូវអ្វី ដែលហៅថា នយោបាយម៉ាក្រូសេដ្ឋកិច្ច (macroeconomic policy) តែប៉ុណ្ណោះ។ នយោបាយម៉ាក្រូសេដ្ឋកិច្ចនេះមានបីផ្នែក - គឺនយោបាយ**សារពើពន្ធ (fiscal) រូបិយវត្ថុ (monetary) និងអត្រាប្តូរប្រាក់ (exchange rate)**។ ផ្នែកសារពើពន្ធ គឺសំដៅលើថា តើអ្វីខ្លះគួរយកពន្ធហើយយកប៉ុន្មាន - ហើយបន្ទាប់ពីនោះថា តើគេគួរយកលុយពន្ធនោះទៅចាយវាយលើអ្វីខ្លះ។ ផ្នែកនយោបាយទីពីរ គឺសំដៅលើថាតើក្រដាសប្រាក់ប៉ុន្មានគេគួរបោះពុម្ព ហើយតើធនាគារគួរឲ្យលុយខ្ចីក្នុងកម្រិតណាដល់អតិថិជន។ នយោបាយទីបី គឺសំដៅលើថា តើរដ្ឋាភិបាលកំណត់អត្រាក្នុងកម្រិតណាដែលរូបិយប័ណ្ណជាតិអាចធ្វើការដោះដូរជាមួយរូបិយប័ណ្ណមួយទៀតបាន។ វិបត្តិសេដ្ឋកិច្ចអាចនឹងកើតមាន ប្រសិនបើរដ្ឋាភិបាលបណ្តោយឲ្យនយោបាយណាមួយក្នុងចំណោមនយោបាយទាំងបីផ្នែកនេះ មានអតុល្យភាពយូរពេក។ បុព្វហេតុញឹកញាប់ជាងគេក្នុងវិបត្តិបែបនេះ គឺនៅពេលដែលប្រជាជន ឬអ្នករកស៊ី និង/ឬរដ្ឋាភិបាលខ្ចីបុលច្រើនពេក ហើយមិនអាចសងបំណុលវិញបាន។ នេះជាតួនាទីរបស់ធនាគារកណ្តាលក្នុងការរក្សាអត្រាការប្រាក់ក្នុងកម្រិតមួយសមរម្យ ដើម្បីឲ្យមានតុល្យភាពរវាងប្រាក់សន្សំ និងការខ្ចីបុល។

សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ នយោបាយរដ្ឋាភិបាលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ**កំណើន និងការអភិវឌ្ឍ**។ អ្វីដែលរដ្ឋាភិបាលធ្វើ និងអ្វីដែលរដ្ឋាភិបាលអនុញ្ញាត ឬហាមប្រាមមិនឲ្យពលរដ្ឋ និងអ្នករកស៊ីរបស់ខ្លួនធ្វើបាន អាចបណ្តាលឲ្យសេដ្ឋកិច្ចនៅទ្រឹងមិនរីកចម្រើន និងបន្តភាពក្រីក្រក៏ថាបាន ឬវាអាចនាំឲ្យមានកំណើនសេដ្ឋកិច្ចថែមទៀត និងរំដោះប្រជាជនរាប់លាននាក់ឲ្យចាកផុតពីភាពក្រីក្រ និងជំងឺ ក៏ថាបាន។

## ហេតុអ្វីបានជាវាសំខាន់ ឬគួរឲ្យចាប់អារម្មណ៍ដល់អ្នកអាន?

អ្នកណាក៏ដឹងដែរថា រដ្ឋាភិបាលអាចធ្វើអ្វីៗដែលនឹងធ្វើឲ្យជីវភាពមានភាពកាន់តែប្រសើរឡើង (ឬក៏ឲ្យចុះយ៉ាប់យឺនទៅវិញ)។ រដ្ឋាភិបាលអាចសាងសង់សាលារៀន មន្ទីរពេទ្យ លំនៅដ្ឋាន ហើយបង់ប្រាក់បៀវត្សរ៍គ្រូបង្រៀន វេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកា ជាដើម។ រដ្ឋាភិបាលអាចចាយលុយលើមន្ត្រីរដ្ឋាភិបាល និងបុគ្គលិកការិយាល័យ ទាហាន នគរបាល និងអ្វីៗច្រើនផ្សេងទៀត។ របៀប ឬទំហំដែលរដ្ឋាភិបាលចំណាយលុយលើមុខព្រួញទាំងអស់នេះ អាចមានឥទ្ធិពលជាដុំកំភួនទៅលើលក្ខខណ្ឌជីវភាពរស់នៅនៃពលរដ្ឋរបស់ខ្លួន។ ត្រង់នេះគេហៅថា **ចំណាយរបស់រដ្ឋាភិបាល**។ ឯម្ខាងទៀត គឺសំណួរថា តើរដ្ឋាភិបាលបានលុយមកពីណា ដើម្បីចាយវាយទៅលើមុខព្រួញទាំងអស់នេះ - ត្រង់

ហ្នឹងគេហៅថា **ចំណូលរបស់រដ្ឋាភិបាល**។ ប្រភពចម្បង គឺបានមកពីក្រុមធុរកិច្ច (**ពន្ធក្រុមហ៊ុន/corporate tax**) និងបុគ្គល (**ពន្ធចំណូល/income tax)**។ ប្រជាជនពេញចិត្តនឹងការដែលមានសាលារៀនច្រើននិងលំនៅដ្ឋានច្រើន តែពួកគេនឹងមិនសប្បាយចិត្តទេ កាលណាគេទារពន្ធច្រើនពេក។

បើសិនជារដ្ឋាភិបាលចាត់ចែងនយោបាយរូបិយវត្ថុមិនស្រួល សេដ្ឋកិច្ចនឹងមានអតិផរណា *[សូមមើលការពន្យល់ខាងលើ]*។ ថ្លៃទំនិញខ្ពស់ធ្វើឲ្យប្រជាជនមិនសប្បាយចិត្ត។ ហើយបើរដ្ឋាភិបាលធ្វើឲ្យនយោបាយអត្រាប្តូរប្រាក់មានភាពញ៉េរញ៉ៃ ថ្លៃ**នាំចេញ ឬនាំចូល** អាចនឹងឡើងខ្ពស់ហួសប្រមាណ។ ពេលណារដ្ឋាភិបាលបណ្តោយឲ្យរូបិយប័ណ្ណមានការដូរដោយសេរីជាមួយរូបិយប័ណ្ណ ប្រទេសដទៃ ត្រង់នេះគេហៅថា **សេរីភាវូបនីយកម្មអត្រាប្តូរប្រាក់ (exchange rate liberalization)**។

## តើរឿងប្រភេទណាខ្លះដែលអាចកើតចេញពីប្រធានបទនេះ?

អ្វីដែលសំខាន់ជាងគេ គឺនៅពេលដែលរដ្ឋាភិបាលប្រកាសថាអ្វីខ្លះដែលគេត្រូវយកពន្ធលើ និងថាតើគេនឹងយកលុយពន្ធនោះទៅចាយវាយលើអ្វី។ គេធ្វើការប្រកាសបែបនេះ តាមរយៈឯកសារផ្លូវការដែលគេហៅថា **ថវិកា**។ អ្នកសារព័ត៌មានដើរតួនាទីសំខាន់ក្នុងការធ្វើសេចក្តីរាយការណ៍ឲ្យបានក្បោះក្បាយជាក់លាក់ថា តើមានស្អីខ្លះចេញ និងចូលទៅក្នុងហិបថវិការដ្ឋាភិបាល តើលុយបានមកពីណា ហើយគេយកវាទៅណា ហើយថាផ្នែកណាទទួលបានថវិកាតិច ផ្នែកណាទទួលបានច្រើនក្នុងទិដ្ឋភាពទាំងមូលនេះ។ ការប្រព្រឹត្តរបស់រដ្ឋាភិបាលមានឥទ្ធិពលទៅលើដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ច។ ដូច្នេះ វាពិតជាសំខាន់សម្រាប់អ្នកសារព័ត៌មានក្នុងការសរសេររឿងថា តើទាំងអស់នេះមានអត្ថន័យដូចម្តេចសម្រាប់កំណើន និងការអតិវឌ្ឍអតិផរណាអត្រាប្តូរប្រាក់ជាដើម។

## គោលគំនិតសំខាន់ៗមួយចំនួន

**នយោបាយម៉ាក្រូសេដ្ឋកិច្ច** : ត្រង់នេះនិយាយអំពីរបៀបដែលរដ្ឋាភិបាលអនុវត្តន៍ការទទួលខុសត្រូវរបស់ខ្លួនក្នុងការគ្រប់គ្រង**សេដ្ឋកិច្ចឲ្យមានតុល្យភាព** ដែលផ្សំឡើងដោយធាតុផ្សំបីខាងក្រោមនេះ៖

**នយោបាយសារពើពន្ធ : ការយកពន្ធ និងការចំណាយ (taxing and spending)** ដោយរដ្ឋាភិបាល។ បើសិនជារដ្ឋាភិបាលចាយច្រើនជាងខ្លួនរកបានពីការយកពន្ធ នោះ គឺជាស្ថានភាពឱនភាពថវិកាហើយ។ បើស្ថានភាពផ្ទុយពីនេះវិញ គឺអតិរេកថវិកា។

**នយោបាយរូបិយវត្ថុ** : គឺសំដៅលើទង្វើរដ្ឋាភិបាលប្រើក្នុងការចាត់ចែងគ្រប់គ្រងលុយនៅក្នុងសេដ្ឋកិច្ចមួយ។ បើរដ្ឋាភិបាលបោះពុម្ពលុយលើសពីតម្លៃជាក់ស្តែងនៃរបស់របរ និងសេវាកម្មដែលគេផលិតបានក្នុងសេដ្ឋកិច្ច ទង្វើបែបនេះនឹងនាំទៅរកអតិផរណា។ រដ្ឋាភិបាលបោះពុម្ពលុយកាន់តែច្រើនកាលណាអតិផរណានឹងឡើងខ្ពស់តាមហ្នឹងដែរ។ ក្នុងសេដ្ឋកិច្ចផ្សារសេរី ធនាគារកណ្តាលនៃប្រទេសមួយជាស្ថាប័នទទួលខុសត្រូវក្នុងការ**កំណត់អត្រាការប្រាក់**។ បើធនាគារកណ្តាលនោះកាន់តែឯករាជ្យពីឥទ្ធិពលនយោបាយបានកាន់តែច្រើនកាលណាវានឹងកាន់តែមានលទ្ធភាពច្រើនក្នុងការធ្វើតាមនយោបាយរូបិយវត្ថុរឹងមាំ និងមានតុល្យភាព។

**នយោបាយអត្រាប្តូរប្រាក់** : មានវិធីច្រើនដែលរដ្ឋាភិបាលអាចអនុញ្ញាតឲ្យរូបិយប័ណ្ណរបស់ប្រទេសធ្វើការដូរជាមួយរូបិយប័ណ្ណឯទៀត (តែយើងសូមលើកយកតែវិធីធំៗមួយចំនួនទេមកបង្ហាញ)។ រដ្ឋាភិបាលអាច៖

- ឲ្យអ្នកណាមួយប្តូររូបិយប័ណ្ណច្រើនស្រេចនឹងចិត្ត និងពេលណាក៏បាន ដែលនេះគេហៅថា **អត្រាប្តូរប្រាក់ដោយសេរី ឬអណ្តែត (free or floating exchange rate)**។
- ឲ្យប្តូររូបិយប័ណ្ណតែពេលណាដែលរដ្ឋាភិបាលផ្តល់ការអនុញ្ញាតតែប៉ុណ្ណោះ។ **ការគ្រប់គ្រងមូលធន**បែបនេះឲ្យមានអត្រាប្តូរប្រាក់ដោយសេរីតែមួយផ្នែក ឬ **អន្តរការ (intermediate)** តែប៉ុណ្ណោះ។
- ឲ្យមានការប្តូររូបិយប័ណ្ណតែក្នុងពេលជាមួយគ្នានេះដែរ អន្តរាគមន៍ក្នុងទីផ្សារតាមការលក់ ឬទិញរូបិយប័ណ្ណរបស់ខ្លួន (ជាថ្នូរជាមួយរូបិយប័ណ្ណមួយទៀត) ដើម្បីបង្វែរអត្រាប្តូរប្រាក់ទៅទិសដៅមួយដែលខ្លួនចង់បានឲ្យវាទៅ។ ពេលខ្លះគេហៅវាថា dirty float ដែលមានន័យថាអត្រានេះមិនសេរីឡើងចុះតាមកម្លាំងទីផ្សារតែមួយមុខនោះទេ។
- ប្រកាសអត្រាមួយ (ធម្មតាទល់នឹងប្រាក់ដុល្លារ ឬដុល្លារ អឺរ៉ូ និងយ៉េន) ដែលក្នុងអត្រានោះ រដ្ឋាភិបាលរក្សាទុកអត្រាប្តូររូបិយវត្ថុរបស់ខ្លួនដោយទិញ ឬលក់រូបិយវត្ថុលើទីផ្សារឲ្យនៅទ្រឹងត្រឹមចំណុចមួយ។ នេះគេហៅថា **អត្រាប្តូរងាប់ស្តុក (pegged exchanged rate)**។ ដើម្បីធ្វើដូច្នេះបាន ទាល់តែធនាគារកណ្តាលប្រទេសមួយមាន **បំរុង** រូបិយវត្ថុបរទេសគ្រប់គ្រាន់សម្រាប់យកមក "លេង" ក្នុងទីផ្សារ។
- ប្រកាសអត្រាប្តូរប្រាក់ជាដំណាក់កាលក្នុងរយៈពេលណាមួយ ដែលក្នុងពេលនោះរដ្ឋាភិបាលកំណត់អត្រាប្តូរឲ្យនៅទ្រឹង ប៉ុន្តែទម្លាក់វាមកវិញបន្តិចម្តងៗ (ឧទាហរណ៍ ៥ ភាគរយក្នុងមួយឆ្នាំ)។ គេហៅរបៀបនេះថា **អត្រាប្តូររំកិល (crawling peg)**។
- ឲ្យធ្វើការប្តូររូបិយវត្ថុបានតាមរយៈចេញ **ការអនុញ្ញាតលាយលក្ខណ៍អក្សរ** ដោយការិយាល័យប្តូររូបិយវត្ថុផ្លូវការ។ របៀបនេះពិបាកគ្រប់គ្រងការប្តូរប្រាក់ណាស់ ហើយជារឿយៗតែងនាំបង្កើតឲ្យមានផ្សារងងឹតដោះដូររូបិយវត្ថុ។

**នយោបាយអភិវឌ្ឍន៍ :** នេះសំដៅលើវិធានមគ្គុទេសក៍ប្រកាសជាផ្លូវការ ដែលបង្ហាញពីគោលបំណងរដ្ឋាភិបាលចង់ឲ្យសេដ្ឋកិច្ចវិវត្តន៍របៀបណា។ ពេលខ្លះគេឲ្យឈ្មោះ ដូចជានៅវៀតណាមថា *doi moi (renovation)*។ វាក៏អាចជាមគ្គុទេសក៍



*ការរៀបចំចាត់ចែងវិស័យកសិកម្មមានឥទ្ធិពលដោយផ្ទាល់លើវិបុលភាពជាតិ។*

មួយលំដាប់ ឬក៏ជា**ផែនការប្រាំឆ្នាំមានគោលដៅជាក់លាក់** ដូចជាពេលណាត្រូវធ្វើសេរីភាវូបនីយកម្មអត្រាប្តូរប្រាក់ ឬពេលណាទើបបើកផ្សារភាគហ៊ុន។

**អភិបាលកិច្ច :** អ្នកសេដ្ឋកិច្ច និងអ្នកវិទ្យាសាស្ត្រសង្គម តែងពិភាក្សាគ្នាអំពីទំនាក់ទំនងរវាងគោលនយោបាយអភិវឌ្ឍន៍ និងថាតើរដ្ឋាភិបាលមានដំណើរខ្លួនដោយរបៀបណា។ អ្វីៗភាគច្រើនដែលនាំទៅរកកំណើន និងនាំឲ្យបាកផុតពីភាពក្រីក្រ គឺដោយសារ**ឱកាស ជំនឿ និងការទុកចិត្ត** - ទាំងអស់នេះជារបស់ដែលពិបាកវាស់វែង និងអនុវត្តន៍បានណាស់ក្នុងន័យសេដ្ឋកិច្ច។ វាទាក់ទងច្រើនទៅនឹងច្បាប់ បែបបទ និងលទ្ធភាពដែលក្រុមធុរកិច្ច និងបុគ្គល អាចធ្វើការវិនិយោគ និងស្វែងរកការងារបានដោយគ្មានការភិតភ័យដោយសារអំពើពុករលួយ ការកេងប្រវ័ញ្ច និងការរើសអើង។

## កសិកម្ម និងវត្ថុធាតុដើម

### តើវាជាស្អី?

នៅក្នុងថ្នាក់រៀន ក្មេងៗគ្រប់រូបត្រូវបានគ្រូបង្រៀនប្រាប់ថា បណ្តាប្រទេសមាន "ធនធានធម្មជាតិ" ឬ "វត្ថុធាតុដើម" ជាសម្បត្តិរបស់ខ្លួន។ ទាំងអស់នេះជារបស់ដែលយើងដាំក្នុងដី ដុះលើដី ឬក៏ជីកយកពីក្នុងដីមកវិញ គឺមានស្បៀងអាហារ សត្វ និងធនធានរ៉ែ។ បរិមាណនៃរបស់ទាំងអស់នេះដែលប្រទេសនីមួយៗមាន អាចមានសារៈសំខាន់ក្នុងការកំណត់អំពីទស្សនវិស័យសេដ្ឋកិច្ចរបស់ខ្លួន (ប៉ុន្តែដោយសារគោលនយោបាយសេដ្ឋកិច្ចអន់ ប្រទេសខ្លះ ទោះជាមានធនធានធម្មជាតិសំបូរបែបក៏ដោយ ក៏នៅតែក្រ ឯប្រទេសដែលគ្មានធនធានធម្មជាតិសោះ ក្លាយជាប្រទេសអ្នកមាន ដោយសារគេមានគោលនយោបាយសេដ្ឋកិច្ចល្អ)។

របៀបដែលប្រទេសមួយចាត់ចែង **វិស័យកសិកម្ម** របស់ខ្លួនអាចនាំមកនូវភាពខុសគ្នាជាដុំកំភួនចំពោះវិបុលភាពរបស់ខ្លួន។ ពេលដែលប្រទេសចិនបោះបោលវិធីធ្វើកសិកម្មសមូហភាព ហើយអនុញ្ញាតឲ្យកសិករដាំផលិតផលតាមតែចិត្តគេចង់ ហើយលក់តាមតែចិត្តគេចង់ប្រទេសនេះ បានរួចបាកពីភាពក្រីក្រ ហើយក្លាយជាសេដ្ឋកិច្ចដែលមានការលូតលាស់លឿនជាងគេក្នុងប្រវត្តិសាស្ត្រ។ ពេលប្រទេសវៀតណាមបណ្តោយឲ្យពលរដ្ឋរបស់ខ្លួនសាករកចំណេញដោយខ្លួនឯង ផលិតផលអង្ករបានកើនយ៉ាងសម្បើម រហូតដល់ប្រទេសនេះបានក្លាយជាអ្នកនាំអង្ករចេញលំដាប់ទីពីរលើពិភពលោក បន្ទាប់ពីប្រទេសថៃ។

**សម្បត្តិធនធានរ៉ែ** របស់ប្រទេសមួយ (ដែលរួមមានធនធានឥន្ធនៈ ដូចជា ប្រេង និងឧស្ម័នធម្មជាតិជាដើម) ក៏អាចធ្វើឲ្យមានការប្រែប្រួលដុំកំភួនដែរដល់សម្បត្តិសេដ្ឋកិច្ចរបស់ប្រទេស។ ប៉ុន្តែ ការយកប្រេង ឬទង់ដែង ឬមាសចេញពីក្រោមដី ទាមទារឲ្យមានការវិនិយោគច្រើន និងបច្ចេកវិទ្យា ហើយសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ តម្រូវបែបនេះតែងតែមានការពាក់ព័ន្ធប្រឡូកក្រុមហ៊ុនពហុជាតិ ទើបដំណើរការទៅរួច។

អ្នកសេដ្ឋកិច្ចតែងនាំគ្នានិយាយអំពីអ្វី ដែលគេស្គាល់ថា **វត្ថុធាតុដើម (commodities)**។ ស្បៀងអាហារ កប្បាស កាហ្វេ ថ្នាំជក់ និងផលិតផលធ្វើអំពីសាច់សត្វ ត្រូវបានគេហៅថា **វត្ថុធាតុដើមទន់ (soft commodities)** ហើយរបស់ដែលគេយកចេញពីរ៉ែក្រោមដី គេហៅថា **វត្ថុធាតុដើមរឹង (hard commodities)**។ ភាគច្រើននៃផលិតផលមុខទំនិញត្រូវបានធ្វើការដួញដូរតាមរយៈតំណាងផលិតករ និងអ្នកប្រើប្រាស់នៅលើទីផ្សារវត្ថុធាតុដើម **(commodities markets)** ក្នុងទីក្រុងធំៗលើពិភពលោក *[សូមមើលខាងក្រោម]*។

## ហេតុអ្វីបានជាវាសំខាន់ ឬគួរឲ្យចាប់អារម្មណ៍ដល់អ្នកអាន?

អាកាសធាតុ គោលនយោបាយសេដ្ឋកិច្ច ថ្លៃ-សព្វសារពើលើពិភពលោក (ដែលប្រែប្រួលតាមកម្រិតការផ្គត់ផ្គង់ និងតម្រូវការ) គ្រោះមហន្តរាយ និង អស្ថេរភាពនយោបាយទាំងអស់នេះ សុទ្ធតែមានឥទ្ធិពលទៅលើទិន្នផលនៃទំនិញប្រើប្រាស់។ និន្នាការរបៀបនេះអាចធ្វើឲ្យតម្លៃស្បៀងអាហារចុះថ្លៃ ឬក៏ឡើងថ្លៃជាងមុនសម្រាប់ប្រជាជនសាមញ្ញ។ ការយករ៉ែ និងការជីកជញ្ជូន ធនធានរ៉ែ និងផលិតផលថាមពល អាចនាំមកនូវការប្រែប្រួលធំដុំក្នុងជីវភាព និងបរិស្ថានរស់នៅរបស់ប្រជាជនដែលរស់នៅក្បែរតំបន់មានប្រេង និងឧស្ម័ន។ សំណួរថា តើអ្វីខ្លះបានកើតឡើងជាមួយលុយ ដែលបានពីការលក់ទំនិញធនធានធម្មជាតិទាំងនេះ តែងតែជាបុព្វហេតុធំមួយនៃការប្រេះឆាសង្គម និងនយោបាយក្នុងប្រទេសមួយ។

## តើរឿងប្រភេទណាខ្លះដែលអាចកើតចេញពីប្រធានបទនេះ?

រឿងដែលគួរឲ្យរំភើបជាងគេ គឺរឿងអំពីរបកគំហើញថ្មី ដូចជាការរកឃើញមាសអញ្ចឹង! ឬក៏ "មាសខ្មៅ" (ប្រេង)។ ប៉ុន្តែនៅមានរឿងធម្មតាជាច្រើនទៀត ដូចជា អ្នកណាឈ្នះទទួលបានកុងត្រាដើម្បីជីកយករ៉ែ ឬដើម្បីសង់បំពង់បង្ហូរប្រេង និងឧស្ម័ន; រឿងអំពីថាតើវត្ថុធាតុដើមត្រូវបានគេយកទៅកែច្នៃនៅឯណា (ដូចជា រោងចក្រចម្រាញ់ រោងចក្រប្រេងគីមី) ហើយតើគេប្រើ**បច្ចេកវិទ្យា**អ្វី; មានការខូចខាតអ្វីខ្លះដល់ **បរិស្ថាន** និង**សុខភាព** របស់ប្រជាជនរស់នៅក្បែរនោះ; តើចំណូលប៉ុន្មានហូរចូលហិបរដ្ឋាភិបាលទើបធ្លាក់ទៅដល់ប្រជាជនវិញ; អ្នកណាខ្លះដែលជំទាស់នឹងនយោបាយរុករកជីករ៉ែរបស់រដ្ឋាភិបាល ហើយតើពួកគេប្រើមធ្យោបាយនយោបាយ ឬហិង្សាក្នុងការជំទាស់នោះ។

រឿងអំពីកសិកម្មរួមបញ្ចូលនូវ**អាកាសធាតុ គ្រោះមហន្តរាយ និងបរិស្ថាន** (ការប្រើប្រាស់គីមី និងថ្នាំសម្លាប់សត្វល្អិត); **កម្មសិទ្ធិដីធ្លី**; ស្ថានភាពហិរញ្ញវត្ថុរបស់កសិករ និងកម្មករកសិដ្ឋាន ជាពិសេសបំណុល; លទ្ធភាពក្នុងការនាំផលិតផលចូលទៅទាំងទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ; តើ**តម្លៃ**ស្បៀងអាហារ និងផលិតផលកសិកម្មដទៃទៀត ត្រូវបានកំណត់ដូចម្តេច (ដោយរដ្ឋាភិបាល ឬដោយទីផ្សារ "សេរី")។

## គោលគំនិតសំខាន់ៗមួយចំនួន

**ឧត្តមភាពប្រៀបធៀប :** នេះជាវាក្យសព្ទបច្ចេក-ទេសដែលអ្នកសេដ្ឋកិច្ចវិទូប្រើក្នុងការយោងទៅរកអ្វីដែលជា**អំណោយធម្មជាតិ (nature's gift)**។ ពាក្យនេះមានន័យសំដៅលើអ្វីដែលប្រទេសមួយមានដែលអនុញ្ញាតវាឲ្យប្រកួតប្រជែងបានជាមួយសេដ្ឋកិច្ចដទៃទៀត។ លក្ខខណ្ឌដូចជាអាកាសធាតុល្អ ដីមានជីជាតិ ប្រកទៅកាន់កំពង់ផែសមុទ្រអាចផ្តល់ឲ្យប្រទេសមួយនូវឧត្តមភាពប្រៀបធៀបជាប្រទេសផលិតស្បៀង និងធ្វើការនាំចេញ។ បើគ្មានលក្ខខណ្ឌបែបនេះទេ ប្រទេសមួយអាចនឹងមានការលំបាកខ្លាំងក្នុងការអភិវឌ្ឍខ្លួន និងធ្វើការជួញដូរជាមួយប្រទេសដទៃ *[សូមមើលខាងក្រោម]*។

**ផ្សារវត្ថុធាតុដើម (Commodities markets):** ជាអង្គការផ្លូវការមាន រដ្ឋបាល ក្បួន បញ្ញត្តិសម្រាប់ជួញដូរមុខទំនិញតាមរយៈឈ្មួញកណ្តាល។ ផ្សារបែបនេះមាននៅក្នុងទីក្រុងប្រទេសធំៗ ដូចជាក្រុងឡុងដ៍ ញូវយ៉ក ឈីកាហ្គោ សៀងហៃ តែមុខទំនិញជាក់ស្តែងមិនមានវត្តមានទេ ក្នុងពេលជួញដូរនោះ។ ពាណិជ្ជករធ្វើការទាក់ទងរវាងផលិតករ និងអ្នកប្រើប្រាស់។ ក្នុងរបរនេះមាន "ឈ្មួញកណ្តាល" ច្រើនណាស់ រវាងកសិករផលិតកប្បាស និងកម្មកររោងចក្រកាត់ដេរដែលដេរសម្លៀកបំពាក់ធ្វើពីកប្បាស

ឬរវាងអ្នកមេកានិកអណ្តូងប្រេង ដែលពួរបូមប្រេងពីក្រោមដី និងកម្មករ ធ្វើការជាអ្នកបាក់សាំងនៅស្ថានីយប្រេង *[សូមមើលខាងក្រោម]*។

**ក្រុមប្រឹក្សាទីផ្សារ (Marketing boards):** រដ្ឋាភិបាលជាច្រើនធ្លាប់នឹងទម្លាប់មានប្រព័ន្ធគ្រប់គ្រងកណ្តាលមួយសម្រាប់ទិញផលិតផលមុខទំនិញកសិកម្មពីកសិករក្នុងតម្លៃមួយនឹងថ្កល់ ទើបយកទៅលក់បន្តទៀត។ មានរដ្ឋាភិបាលមួយចំនួននៅតែមានទម្លាប់ធ្វើដូច្នេះដដែល។ នៅមានការជជែកវែកញែកច្រើននៅឡើយ ថាតើធ្វើដូច្នេះជាការកេងប្រវ័ញ្ចកសិករ ឬក៏ជាការដាក់បន្ទុកមកលើអ្នកបង់ពន្ធ ហើយដើរខុសទៅនឹងចរន្តទីផ្សារទូទៅ។ **នយោបាយ "សេរីភាវូបនីយកម្ម "** រួមបញ្ចូលផងដែរនូវការលុបបោលក្រុមប្រឹក្សាទីផ្សារ ដើម្បីអនុញ្ញាតឲ្យកសិករ និងអ្នកជួញដូរបងក្រងជាក្រុមពួកបានដោយសេរីជាប្រយោជន៍ គេអាចរកតម្លៃបានល្អសម្រាប់ផលិតផលរបស់ពួកគេ។

**កាតែល (Cartel) :** ជាសម្ព័ន្ធភាពនៃផលិតករ ដែលប្រមូលផ្តុំគ្នា ដើម្បី**គ្រប់គ្រងការផ្គត់ផ្គង់**មុខទំនិញរបស់ពួកគេលើទីផ្សារ ដើម្បីព្យាយាមធ្វើឲ្យតម្លៃស្ថេរ (ដែលតាមពិត គឺរក្សាតម្លៃឲ្យខ្ពស់ដើម្បីចំណេញដល់ខ្លួនគេតែប៉ុណ្ណោះ)។ **អង្គការប្រទេសនាំចេញប្រេង (Organization of Oil Exporting Countries/OPEC)** គឺជាឧទាហរណ៍កាតែលមួយ ដែលគេស្គាល់ច្បាស់ជាងគេ តែក៏នៅមានកាតែលដូចនេះច្រើនទៀតដែរ។ អ្នកសេដ្ឋកិច្ចផ្សារសេរីនិយាយថា ពួកកាតែល ជាពួករកស៊ីកេងប្រវ័ញ្ចលើអ្នកប្រើប្រាស់។

**បណ្តាសាធនធាន (Resource curse):** ពេលណាប្រទេសមួយទទួលប្រសិទ្ធពរដោយធនធានធម្មជាតិសំបូរបែប ដូចជា ប្រេង និងឧស្ម័នជាដើម តែជួនកាលសម្បត្តិទាំងនេះធ្វើឲ្យរដ្ឋាភិបាលរបស់ខ្លួនពុករលួយ ហើយនាំទៅរកនយោបាយសេដ្ឋកិច្ចមិនល្អទៅវិញ។ **ការពឹងផ្អែក**លើសម្បត្តិមួយមុខនេះ (ជាជាងធ្វើ **ពិពិធកម្ម** សេដ្ឋកិច្ចឲ្យមានច្រើនសកម្មភាព) និង**សម្ព័ន្ធភាពពុករលួយ**រវាងមន្ត្រីរដ្ឋាភិបាល និងក្រុមហ៊ុនពហុជាតិ អាចជាអន្ទាក់ដាក់ប្រជាជនក្នុងភាពក្រីក្រ។ សង្គ្រាមស៊ីវិលតែងកើតចេញពីជម្លោះទាក់ទិននឹងធនធានធម្មជាតិ។ ក្នុងសភាពបែបនេះ "ប្រសិទ្ធពរ" ក្លាយជាបណ្តាសាទៅវិញ។

# ក្រុមហ៊ុន

## តើវាជាស្អី?

អ្នកណាក៏អាចបើករបររកស៊ីបានដែរដោយផលិតរបស់អ្វីមួយ ឬផ្តល់សេវាកម្មក្នុងតម្លៃណាមួយដល់អតិថិជន។ កុងត្រាដែលអ្នកចុះហត្ថលេខាលើ និងលុយ ដែលអ្នករកបានពីការបំពេញតាមកុងត្រានោះ គឺជាលុយរបស់អ្នក ហើយជាលុយស្របច្បាប់។ ប៉ុន្តែ បើអ្នកចូលរួមជាមួយអ្នកដទៃក្នុងមុខរបរមួយ អ្នកអាចចុះបញ្ជីជាក្រុមហ៊ុនមានអាជ្ញាប័ណ្ណដែលគេច្រើនហៅថា **ក្រុមហ៊ុនមានការទទួលខុសត្រូវហិរញ្ញវត្ថុមានកម្រិត (limited liability company)**។ នេះមានន័យថា អ្វីៗដែលអ្នកកាន់កម្មសិទ្ធិលើ ដូចជា ផ្ទះ ទោចក្រយានយន្ត រថយន្ត ឬសម្លៀកបំពាក់ អាចត្រូវបានគេរឹបអូសយកពីអ្នក ប្រសិនបើក្រុមហ៊ុនរបស់អ្នកធ្លាក់ក្នុងស្ថានភាពមានបញ្ហា។ **ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ** ចំពោះបំណុល និងពន្ធ **មានកម្រិតចំពោះក្រុមហ៊ុន**។ អ្នកសេដ្ឋកិច្ចជឿថា ធ្វើដូច្នេះលើកទឹកចិត្តឲ្យមនុស្សមានសុវត្ថិភាពក្នុងការបោះជំហានចូលរកស៊ី ពីព្រោះកាលណាគេបរាជ័យក្នុងមុខរបរគេ មិនមែនអត់មានអ្វីនៅសល់ក្នុងដៃទេ។ កាលណាមានមុខរបរកាន់តែច្រើន វាមានន័យថាការងារក៏សំបូរដែរ ដែលនេះប្រការល្អសម្រាប់ទាំងអស់គ្នា។

ក្រុមហ៊ុនអាចកៀរគរលុយមកវិនិយោគលើ**ដីធ្លី បម្លារ និងគ្រឿងចក្រ** ដោយ៖

- ខ្ចីបុលពីធនាគារក្នុងអត្រាការប្រាក់មួយ ដែលអាចឡើងឬចុះ អាស្រ័យលើកុងត្រា។
- ខ្ចីពីវិនិយោគិនដោយលក់**សញ្ញាប័ណ្ណ/ប័ណ្ណបំណុល (bonds)** ឲ្យគេ។ នេះជាឥណទានដោយមាន**អត្រាការប្រាក់ថេរ**។ ម្ចាស់ដើមនៃសញ្ញាប័ណ្ណ អាចលក់វាឲ្យអ្នកផ្សេងទៀតមុននឹងវាផុតកំណត់។ បន្ទាប់មកក្រុមហ៊ុនសងលុយទៅអ្នកណាក៏ដោយ ដែលកាន់សញ្ញាប័ណ្ណក្នុងថ្ងៃ ដែលវាត្រូវផុតកំណត់ *[សូមមើលខាងក្រោម]*។
- លក់សន្លឹកភាគហ៊ុន ដែលគេស្គាល់ផងដែរថាជា**សន្និធិ (stock)** និង**ទុន (equity)** ទៅឲ្យវិនិយោគិន។ លុយបានមកពីពួកវិនិយោគិនគេយកទៅចាយលើប្រតិបត្តិការរបស់ក្រុមហ៊ុន។ ឯអ្នកវិនិយោគិន គេនឹងទទួលបាន**ភាគលាភ (dividend)** ដែលជាចំណែកផលចំណេញ (នោះប្រសិនបើក្រុមហ៊ុនរកបានចំណេញ) ឬបើក្រុមហ៊ុនខាត វិនិយោគិនក៏ខាតជាមួយដែរ។ បើក្រុមហ៊ុនមានចុះបញ្ជីផ្សារភាគហ៊ុន វិនិយោគិនអាចលក់ភាគហ៊ុនរបស់ក្រុមហ៊ុនទៅឲ្យក្រុមហ៊ុនមួយទៀតនៅពេលណាក៏បាន។ វិនិយោគិនទាំងអស់ដែលមានចំណែកភាគហ៊ុនក្នុងក្រុមហ៊ុនត្រូវបានគេហៅថា **ភាគហ៊ុននិក (shareholders)**។ អ្នកគ្រប់គ្រងក្រុមហ៊ុន គឺជាក្រុមនាយកប្រតិបត្តិ (executives) ដែលអាចមានភាគហ៊ុនតែបន្តិចបន្តួចប៉ុណ្ណោះ។ ភាគហ៊ុននិកជាអ្នកបោះឆ្នោតឲ្យនាយកប្រតិបត្តិកាន់តំណែងក្នុងក្រុមហ៊ុន។

ក្រុមហ៊ុនមាន**ផែនការធុរកិច្ច** ដែលជាឯកសារនិយាយអំពី តើអ្វីខ្លះពិតប្រាកដដែលក្រុមហ៊ុនធ្វើ លុយប៉ុន្មានដែលគេកៀរគរបាន អ្វីខ្លះដែលគេនឹងចាយលុយលើផលិតផល ឬសេវាកម្មអ្វីខ្លះដែលគេនឹងលក់ តើគេនឹងធ្វើទីផ្សារកម្ម៉យលក់ផលិតផលដូចម្ដេច ផលចំណេញបែបណា ដែលគេសង្ឃឹមថានឹងរកបាន ហើយថាតើគេនឹងធ្វើអ្វីជាមួយនឹងផលចំណេញទាំងនោះ (បង់ចំណែកណាខ្លះទៅឲ្យភាគ-ហ៊ុននិក ហើយវិនិយោគទៅវិញខ្លះ ដើម្បីពង្រីកមុខរបរ)។ ពេលណាក្រុមហ៊ុនប្រកាសលក់ភាគហ៊ុននេះជាផែនការធុរកិច្ច ដែលគេហៅថា**បរិយាយប័ណ្ណ (prospectus)**។ វាជាវិធីដែលធ្វើឲ្យវិនិយោគិនអាចវិនិច្ឆ័យបានថា តើគួរដាក់លុយទៅក្នុងការទិញភាគហ៊ុនដែរ ឬទេ។ ពួកគេរក្សាទុកដែរនូវគណនីដែលជាកំណត់ត្រាហិរញ្ញវត្ថុរបស់ផែនការធុរកិច្ច។ គណនីមានបីបែប៖ **គណនីចំណេញ និងខាត (profit and loss account)** (ដែលត្រូវបានគេហៅផងដែរថាជា **បញ្ជីចំណូល (income statement)**); **តារាងតុល្យការ (balance sheet) និងបញ្ជីលំហូរសាច់ប្រាក់ (cash flow statement)**។ ទាំងអស់នេះប្រាប់យើងឲ្យដឹងថាតើ៖

១. លុយប៉ុន្មានដែលក្រុមហ៊ុនរកបានមកវិញពីអ្វីដែលគេធ្វើក្នុងរបររកស៊ីរបស់ខ្លួន។

២. លុយប៉ុន្មានដែលគេចំណាយក្នុងដំណើរការក្រុមហ៊ុន (ថ្លៃចំណាយប្រតិបត្តិការ)។

៣. លុយប៉ុន្មានដែលក្រុមហ៊ុនមាននៅសល់ពីថ្លៃចំណាយប្រតិបត្តិការ និងចំណាយលើពន្ធ (ត្រង់នេះគេអាចមើលដឹងអំពីប្រាក់ចំណេញសរុប ឬខាតសរុប)។

៤. អ្វីដែលក្រុមហ៊ុនមាន (ជាទ្រព្យសកម្ម)។

៥. អ្វីដែលក្រុមហ៊ុនជំពាក់ (បំណុល; ទ្រព្យអកម្ម/liabilities)

៦. សំណល់ទូទាត់រវាងចំណុចទី ៤ និង ទី ៥ (សាធនភាព; លទ្ធភាពសងបំណុល/ solvency)។

៧. គេបានលុយពីណា ដើម្បីទិញអ្វីដែលគេកំពុងកាន់កាប់កម្មសិទ្ធិលើ (ហ៊ុន និង បំណុល/equity and debt)។

៨. គេបានសាច់ប្រាក់ពីណា (គឺបានពីការលក់ ការវិនិយោគ និងការខ្ចីបុល)។

៩. គេចាយសាច់ប្រាក់ទៅលើអ្វីខ្លះ (ភាគលាភ (dividend) វិនិយោគចំណាយប្រតិបត្តិការ)។

១០. ក្នុងតារាងតុល្យការ តើសាច់ប្រាក់ហូរចូលច្រើនជាងសាច់ប្រាក់ហូរចេញ ឬយ៉ាងណា។

## ហេតុអ្វីបានជាវាសំខាន់ ឬគួរឲ្យចាប់អារម្មណ៍ដល់អ្នកអាន?

ក្រុមហ៊ុនតែងតែគិតថា អ្វីដែលគេធ្វើវាសុទ្ធតែគួរឲ្យចាប់អារម្មណ៍ទាំងអស់។ វាអាចពិតមែនសម្រាប់ក្រុមហ៊ុនទាំងនោះ តែសម្រាប់អ្នកអានទូទៅ វាអាចជារឿងផ្សេងទៅវិញ។ អ្វីដែលជាទីចាប់អារម្មណ៍នោះ គឺ៖

- ផលិតផល ឬសេវាដែលថ្មីពិតប្រាកដឥតក្លែងបន្លំ។
- វិធីថ្មីសម្រាប់ការលើកតម្កើង និងលក់របស់ ឬសេវាកម្មទាំងនោះ។
- តាមរយៈផលិតផលថ្មីនោះ មានការងារថ្មីត្រូវបានបង្កើតថែមទៀត ឬក៏ការងារខ្លះត្រូវបាត់បង់ទៅវិញ។
- តើមានចំណងជំពាក់វាក់វិនអ្វីទេរវាងប្រតិបត្តិករក្រុមហ៊ុនជាមួយអ្នកនយោបាយ ឬក៏មន្ត្រីរដ្ឋាភិបាល។

## តើរឿងប្រភេទណាខ្លះ ដែលអាចកើតចេញពីប្រធានបទនេះ?

អ្នកសារព័ត៌មាន ដែលតាមដានរាយការណ៍ព័ត៌មានក្រុមហ៊ុន ចាំបាច់ត្រូវស្វែងរកមើលការប្រែប្រួលក្នុងប្រការមួយចំនួន ពីព្រោះទាំងនេះអាចជាអ្វី ដែលគេអាចយកទៅធ្វើជារឿងបាន៖

- អ្នកណាជាម្ចាស់ក្រុមហ៊ុន។
- អ្នកណាចាត់ចែងប្រតិបត្តិការក្រុមហ៊ុននោះ។
- អ្នកដែលក្រុមហ៊ុននោះរើសយកមកធ្វើការ។
- លុយដែលគេមានសម្រាប់ប្រតិបត្តិការក្រុមហ៊ុន។
- លុយដែលគេរកបានពីការរកស៊ីរបស់ក្រុមហ៊ុន។
- តើក្រុមហ៊ុននោះផលិតអ្វី ឬធ្វើអ្វី។
- តើគេប្រើបច្ចេកវិទ្យាអ្វី។
- តើគេប្រើការហ្វឹកហ្វឺនបណ្តុះបណ្តាលអ្វីខ្លះ។
- តើគេប្រើអ្វីសម្រាប់ធ្វើការស្រាវជ្រាវ។
- តើគេលក់ផលិតផល ឬសេវារបស់គេទៅឲ្យអ្នកណា។
- អ្នកណាដែលគេប្រកួតប្រជែងជាមួយ។
- តើគេប្រតិបត្តិក្រោមច្បាប់វិធានអ្វីខ្លះ។

ខាងក្រោមនេះជាអនុសាសន៍ ១០ យ៉ាង សម្រាប់សរសេររឿងអំពីក្រុមហ៊ុន៖

១. **វិនិច្ឆ័យរឿងទៅតាមតម្លៃដំណឹងរបស់វា**។ តើវាគួរឲ្យចាប់អារម្មណ៍ ថ្មី ធំ អធម្មតា និងដែលគេមិនបានរំពឹងទុកជាមុន?

២. **ពង្រីកវិសាលភាពរឿង**។ រកវិធីសិក្សាស្វែងយល់បញ្ហាឲ្យទៅហួសពីក្រុមហ៊ុនមួយ ដែលពាក់ព័ន្ធក្នុងសាច់រឿង។ បើសិនជាវាជាផលិតផលថ្មី រកមើលតើអ្នកណាខ្លះទៀត ដែលបានផលិតវត្ថុប្រហាក់ប្រហែលគ្នានេះដែរ។ បើសិនជាវាជាយុទ្ធសាស្ត្រគ្រប់គ្រងថ្មី រកមើលថាតើអ្នកណាទៀត ដែលកំពុងធ្វើដូចគ្នានេះដែរ។ បើវាជាលទ្ធផលហិរញ្ញវត្ថុ ចូរគួរនិយាយយោងទៅដល់លទ្ធផលរបស់ក្រុមហ៊ុនឯទៀតក្នុងវិស័យតែមួយនេះផងដែរ។

៣. **ឲ្យប្រាកដថាអ្នកយល់បញ្ហាដែលអ្នកកំពុងរាយការណ៍**។ មានអ្នកយកព័ត៌មានច្រើនអ្នកដែលត្រូវសន្ធប់ដោយតួលេខ គ្រាម-ភាសា និងបច្ចេកវិទ្យារបស់ក្រុមហ៊ុនមានទំនោរប្រាមយកតែអ្វី ដែលក្រុមហ៊ុនគេចង់ប្រាប់ ជាជាងបង្ហាញឲ្យអ្នកឯទៀតដឹងថា អ្នកសារព័ត៌មានខ្លួនឯងអត់យល់បញ្ហាក្នុងរឿងនោះទេ។ ធ្វើដូច្នេះ វាផ្តល់ឲ្យក្រុមហ៊ុននូវអំណាចថាមពលថែមទៀតមកគ្របដណ្តប់លើអ្នក និងអ្នកអានទៀតផង។ កុំញញើតសួរសំណួរ "ភ្លីភ្លើ"។ ដីកកកាយ និងសួរប្រភពនានាដែលអ្នកធ្លាប់ទាក់ទងឲ្យជួយពន្យល់មើលថាទាំងអស់នេះមានន័យថាម៉េច។

៤. **កុំសន្មតឲ្យសោះថាគណៈគ្រប់គ្រងវាដូចគ្នានឹងក្រុមហ៊ុនដែរ**។ បើសិនជាក្រុមហ៊ុនមួយបានចុះបញ្ជីលើផ្សារភាគហ៊ុន ម្ចាស់របស់វាគឺភាគហ៊ុននិក។ អ្នកទាំងនេះប្រហែលជាមិនមានទស្សនៈស្របគ្នាជាមួយនឹងក្រុមប្រតិបត្តិករដែលចាត់ការក្រុមហ៊ុននោះទេ។ ចូរធ្វើយ៉ាងណា អ្នកស្វែងយល់ពីមតិខុសៗគ្នាក្នុងក្រុមហ៊ុននោះ រួមទាំងបុគ្គលិកដែលតែងតែមានតំណាងរបស់គេផងដែរ។ ហើយក៏កុំភ្លេចផងដែរនូវអតិថិជន។ កាលណាក្រុមហ៊ុនមួយដូរផលិតផលរបស់ខ្លួន សួរអ្នកប្រើប្រាស់មើលតើគេគិតយ៉ាង-ណា។

៥. **ស្វែងរកអត្ថាធិប្បាយពីមនុស្សកំពូលក្នុងក្រុមហ៊ុន**។ បណ្តាក្រុមហ៊ុនតែងតែបង្កើតក្នុងស្ថាប័នរបស់ខ្លួននូវនាយកដ្ឋានសារគមនាគមន៍ និងទំនាក់ទំនងសាធារណៈ ដែលមានសភាពធំ រហូតដល់ថាវាពិបាកនឹងឲ្យគេរំលងវាបានណាស់។ ក៏ប៉ុន្តែនាយកដ្ឋានបែបនេះ ជួនកាល បង្ករការរាំងស្ទះជាជាងជួយសម្របសម្រួលព័ត៌មានទៅវិញ។ បើបានសម្តីដើមដោយផ្ទាល់ពីនាយកប្រតិបត្តិមកដាក់ក្នុងរឿង នោះវាមានតម្លៃស្មើនឹងមួយពាន់ពាក្យចេញពីប្រធាននាយកដ្ឋានសារគមនាគមន៍ទៅទៀត។

៦. **កុំរំភើបលង់ខ្លួនតាមការសំដែងសៀករបស់គេ**។ ពេលណាក្រុមហ៊ុនចង់ឲ្យពិភពលោកដឹងពីអ្វីមួយ វាពូកែធ្វើការសម្តែងណាស់ដើម្បីបម្រើគោលដៅរបស់គេ។ ក្រុមហ៊ុនផលិតរថយន្តតែងយកនារីស្អាតៗទៅឈរបង្ហាញតាំងឡានម៉ូដែលចុងក្រោយរបស់គេ ហើយបម្រើអ្នកសារព័ត៌មានជាមួយនឹងកុកតៃ និងអាហារឆ្ងាញ់ៗ (ជួនកាលឲ្យកាដូទៀតផង)។ ចូររក្សាស្មារតី និងការវិនិច្ឆ័យរបស់ខ្លួនឲ្យបាននឹងន។

៧. **សួរនាំមនុស្សឯករាជ្យ**។ ជានិច្ចកាល ចូររកមនុស្សឯករាជ្យមកផ្តល់អត្ថាធិប្បាយទៅលើអ្វី ដែលក្រុមហ៊ុនកំពុងធ្វើ ដូចជាអ្នកវិភាគផ្នែកហិរញ្ញវត្ថុ អ្នកបណ្ឌិតសិក្សាអង្គការស្រាវជ្រាវ និងអតិថិជនប្រើប្រាស់ផលិតផល។

៨. **ផ្តល់បរិបទ**។ គ្រប់រឿងទាំងអស់ ចូរអង្គុយផ្អែកទៅក្រោយ ហើយសួរខ្លួនឯងថា តើអ្នកអានត្រូវដឹងអ្វីទៀត ដើម្បីយល់រឿងឲ្យបានកាន់តែប្រសើរថែមទៀត? ព័ត៌មានថែមទៀតពីក្រុមហ៊ុន? ព័ត៌មានថែមទៀតអំពីទីផ្សារ? ព័ត៌មានថែមទៀតអំពីស្ថានភាពសេដ្ឋកិច្ច? ព័ត៌មានថែមទៀតអំពីមនុស្សពាក់ព័ន្ធ?



*គេពិបាកប្រមាណណាស់នូវតម្លៃពិតប្រាកដដែលត្រូវបង់ បើគេព្រងើយកន្តើយការថែទាំផ្នែកវេជ្ជសាស្ត្រពេលមានជំងឺផ្ទុះឡើង។*

៩. **ផ្តល់តួលេខ**។ ក្នុងនាមជាអ្នកសារព័ត៌មាន អ្នកជាតំណាងរបស់អ្នកអាន មិនមែនរបស់ក្រុមហ៊ុនទេ។ ដូច្នេះ អ្នកត្រូវប្រមើលមើលថា តើតួលេខអ្វីដែលអ្នកអាននឹងចង់ដឹង ឬមួយអ្វីដែល នឹងធ្វើឲ្យវាងាយឲ្យពួកគេយល់សាច់រឿង។ កុំអាស្រ័យតែទៅលើក្រុមហ៊ុនជាអ្នកផ្តល់តួលេខឲ្យ។ ភាគច្រើនក្រុមហ៊ុនឲ្យតែតួរលេខណាដែលគេយល់ឃើញថាវាទាក់ទងតែជាមួយរឿងតែប៉ុណ្ណោះ។

១០.**តាមដានថែមទៀត**។ គិតទុកជាមុនអំពីការសរសេរអត្ថបទវិភាគវែងមួយ អំពីអ្វីដែលក្រុមហ៊ុនបានធ្វើសម្រាប់ចុះលេខក្រោយទៀតរបស់កាសែតអ្នក។ បើមិនដូច្នោះទេ សម្លឹងមើលឲ្យវែងឆ្ងាយជាងនេះ ដើម្បីសរសេរអត្ថបទពិពណ៌នា ហើយកត់ត្រាទុកក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ដើម្បីតាមដាន មើលថាតើបញ្ហាមួយនោះវាវិវត្តន៍ទៅជាយ៉ាងណាក្នុងមួយខែប្រាំមួយខែ ឬមួយឆ្នាំក្រោយមកទៀត។

## គោលគំនិតសំខាន់ៗមួយចំនួន

បន្ថែមលើវាក្យសព្ទបច្ចេកទេសប្រើក្នុងគណនីក្រុមហ៊ុន គោលគំនិតសំខាន់ៗមួយចំនួនមាន៖

**យីហោ (Brand)** ៖ ជាសញ្ញា ឬម៉ាករបស់ក្រុមហ៊ុន ឬផលិតផលមួយ។ មួយផ្នែកវាជាឡូហ្គោ ឬនិមិត្តសញ្ញាផលិតផល និងសេវា (logo) ឬក៏ជាពាក្យពេចន៍ពាណិជ្ជកម្ម (ឧទាហរណ៍៖ Coke: “the real thing”)។ តែមួយផ្នែកទៀតមុខងាររបស់វា គឺទាក់ទាញអារម្មណ៍របស់អតិថិជនប្រើប្រាស់។

**ការប្រកាសផ្សាយបឋមលក់ភាគហ៊ុន (Initial Public Offering/IPO)** ៖ នេះ គឺនៅពេលដែលក្រុមហ៊ុនមួយប្រកាសដាក់លក់ជាលើកដំបូងនូវភាគហ៊ុនរបស់ខ្លួនទៅឲ្យវិនិយោគិនដទៃទៀត ក្នុងនោះមានសាធារណជនផងដែរ។

**ការរំលាយក្រុមហ៊ុនចូលគ្នា ឬការទិញក្រុមហ៊ុន (Mergers and acquisitions)** ៖ ប្រើជាអក្សរកាត់ M&A សកម្មភាពពីរនេះ សំដៅលើការច្របាច់ក្រុមហ៊ុនច្រើនចូលគ្នាទៅជាក្រុមហ៊ុនធំមួយ ឬក៏សំដៅលើការដែលក្រុមហ៊ុនមួយទិញក្រុមហ៊ុនមួយ

ទៀតបានមកកាន់កាប់។ សកម្មភាពបែបនេះឧស្សាហ៍កើតមានណាស់ក្នុងធុរកិច្ច ហើយតែងបង្កឲ្យមានការរំជើបរំជួលលើទីផ្សារ ឧទាហរណ៍ ដូចជានៅពេលដែលលោក Rupert Murdoch ទិញកាសែត The Wall Street Journal ជាដើម។

**អសាធនភាព និងភាពក្ស័យធន (Insolvency and bankrupcy)៖** ពាក្យទាំងនេះនិយាយសំដៅនៅពេលដែលក្រុមហ៊ុនជួបបញ្ហាក្នុងរបររកស៊ី។ ក្រុមហ៊ុនមួយស្ថិតក្នុងអសាធនភាព (insolvent) គឺនៅពេលដែលវាជាប់បំណុលក្នុងទំហំលើសពីអ្វីដែលខ្លួនកំពុងមានទៅទៀត។ បានន័យថា វាស្ថិតក្នុងស្ថានភាពមិនអាចសងបំណុលបានទេ បើទោះជាវាលក់អស់សម្បត្តិខ្លួនមានទាំងអម្បាលម៉ានហើយក៏ដោយ។ ក្នុងសភាពបែបនេះ វាក្ស័យធន (bankrupt) ដែលមានន័យថា វាត្រូវបិទទ្វារការរកស៊ីរបស់ខ្លួន ហើយសងបំណុលមួយផ្នែកតាមការលក់សម្បត្តិរបស់ខ្លួន។

**អភិបាលកិច្ចសាជីវកម្ម (Corporate governance)៖** របៀបដែលគេគ្រប់គ្រងក្រុមហ៊ុនយ៉ាងណានោះ វាប្រហាក់ប្រហែលគ្នានឹងរបៀបដែលគេគ្រប់គ្រងប្រទេសមួយដែរ។ តើការគ្រប់គ្រងនោះដោយយុត្តិធម៌ ដោយតម្លាភាព និងមិនពុករលួយប៉ុណ្ណាទៅ?

**ការទទួលខុសត្រូវរបស់សាជីវកម្មចំពោះសង្គម (Corporate social responsibility)៖** ប្រើជាអក្សរកាត់ CSR នេះ សំដៅលើអ្វីដែលក្រុមហ៊ុនមួយធ្វើដើម្បីបង្ហាញខ្លួនថាជាពលរដ្ឋល្អមួយ តាមរយៈការជួយរក្សាបរិស្ថាន បង្កើតការងារ និងរួមចំណែកទៅនឹងគោលនយោបាយល្អសម្រាប់សហគមន៍ដែលនៅជុំវិញខ្លួនគេនោះ។ តែតាមពិតទៅ នេះគ្រាន់តែជាផ្នែកមួយនៃយុទ្ធនាការ ដើម្បីលើកតម្កើងមុខមាត់ក្រុមហ៊ុនតែប៉ុណ្ណោះ តែវាមិនមានខ្លឹមសារប៉ុន្មានទេ។

# វិស័យហិរញ្ញវត្ថុ និងធនាគារ

## តើវាជាស្អី?

កាលពីសម័យបុរាណដែលមិនត្រូវការលុយកាក់នោះ មនុស្សបរិភោគតែអ្វីដែលគេអាចសម្លាប់បាន ឬអាចបេះបោចបានពីរុក្ខជាតិនៅក្បែរខ្លួនតែប៉ុណ្ណោះ។ តែពេលដែលមនុស្សចាប់ផ្តើមចេះចិញ្ចឹម សត្វ និងដាំដំណាំ គេក៏អាចលក់លក់ផលិតផលខ្លះទៅឲ្យអ្នកដទៃ ហើយទិញមកវិញនូវរបស់ផ្សេងទៀតដែលគេត្រូវការចាំបាច់។ ពេលនោះហើយដែលលុយ និងធនាគារកិច្ចចាប់កំណើត។ បច្ចុប្បន្ននេះ កសិករត្រូវខ្ចីលុយពីធនាគារ កាលណាគេត្រូវការពូជ និងជីដើម្បីដាំដំណាំអ្វីមួយ ទម្រាំនឹងគេលក់ផលិតផលវិញបានប្រាំមួយខែក្រោយមកទៀត។ ពេលណាក្រុមហ៊ុនមួយចង់សង់រោងចក្រ ផលិតទោចក្រយានយន្តដែលគេនឹងលក់ទៅវិញមួយឆ្នាំក្រោយមកទៀត គេត្រូវខ្ចីបុលពីធនាគារ ហើយសងវិញពេលណាគេបានចំណូលពីការលក់ផលិតផលឲ្យអតិថិជន។ ជារឿយៗលុយតែងតែមានសម្រាប់ឲ្យខ្ចី បើសិនជាអ្នកហ៊ានបង់តម្លៃឲ្យគេវិញ (គឺអ្វីដែលគេហៅថា ការប្រាក់) សម្រាប់សេវានោះ។ មានពេលខ្លះ "ពួករាប់លុយចងការ" (loan sharks) ផ្តល់សេវាបែបនេះដោយលក្ខណៈកេងប្រវ័ញ្ច ជាពិសេសលើអ្នកក្រ។ តែកាលណាប្រទេសកាន់តែអភិវឌ្ឍន៍ខ្ពស់ សេវាបែបនេះក៏កាន់តែសំបូរដែរ តែតាមរយៈធនាគារវិញ។ ធនាគារផ្តល់កន្លែងមានសុវត្ថិភាពសម្រាប់មហាជនសន្សំប្រាក់ និងផ្តល់ប្រាក់កម្ចីដល់អ្នកណាដែលអាចបង្ហាញថា គេមានលទ្ធភាពនឹងសងប្រាក់វិញនៅពេលអនាគត។ ជាថ្នូនឹងកម្ចីនេះ ធនាគារក៏ព្យាយាមរកចំណេញដែរ។ ជាការពិត របររកស៊ីធនាគារច្រើនតែប្រព្រឹត្តទៅមិនរលូនទាំងអស់នោះទេ។ ហេតុដូច្នេះហើយបានជារដ្ឋាភិបាលតាមឃ្លាំមើល និងធ្វើ

និយតិកម្មលើពួកគេ (ដោយសារខ្វះការឃ្លាំមើល និងនិយតិកម្មនេះហើយទើបបណ្ដាលឲ្យមានវិបត្តិហិរញ្ញវត្ថុឆ្នាំ ២០០៨)។

ដំបូងឡើយ ធនាគារគ្រាន់តែជាសហគ្រាសតូចៗដែលទទួលប្រាក់បញ្ញើពីបុគ្គល និងក្រុមហ៊ុននៅក្បែរៗខ្លួន ទៅធ្វើឥណទានដល់អ្នកទាំងឡាយណាដែលគេស្គាល់ទុកចិត្តតែប៉ុណ្ណោះ។ ក្រោយមកធនាគារបេះតែរីកធំធាត់ទូទាំងសកលលោក។ ក្នុងប្រទេសខ្លះ ធនាគារបានក្លាយជាឧបករណ៍របស់ពួកអ្នកមាន និងជនពុករលួយ ដែលជាហេតុនាំឲ្យមានបដិវត្តន៍វាយដណ្ដើមធនាគារ ហើយបិទទ្វារវាចោល។ ក៏ប៉ុន្តែបច្ចុប្បន្ននេះ សឹងតែគ្រប់ប្រទេសលើពិភព-លោកកំពុងមើលឃើញភាពចាំបាច់ឲ្យមានប្រព័ន្ធធនាគារមានសុវត្ថិភាពមួយ ហើយរដ្ឋាភិបាលក៏នាំគ្នាលើកទឹកចិត្តឲ្យមានការលូតលាស់**វិស័យហិរញ្ញវត្ថុ**ដែរ។ បណ្ដារដ្ឋាភិបាលជឿថា វិស័យហិរញ្ញវត្ថុដើរតួនាទីសំខាន់សម្រាប់ដើរក្នុងកិច្ចអភិវឌ្ឍ ដោយផ្ដល់ឥណទានសម្រាប់ការវិនិយោគ និងកំណើនសេដ្ឋកិច្ចផងដែរ។

យ៉ាងណាមិញ រឿងសំខាន់មួយដែលត្រូវដឹងអំពីធនាគារ គឺប្រព័ន្ធទាំងមូលត្រូវបានកសាងឡើងនៅលើសេចក្ដីទុកចិត្ត មិនមែនភាពជាក់ស្ដែងប្រាកដប្រជាទេ។ បើអ្នកដាក់លុយរបស់អ្នកក្នុងធនាគារថ្ងៃនេះ ធនាគារនឹងធ្វើឥណទានទៅអ្នកដទៃទៀតនៅថ្ងៃស្អែក។ បើអ្នកចង់បានលុយមកវិញ សប្ដាហ៍ក្រោយ ធនាគារពិតជាមិនអាចយកលុយពីអ្នកដែលគេបានឲ្យលុយរបស់អ្នកខ្ចីបានមកវិញ ភ្លាមនោះទេ។ វាត្រូវតែទៅយកចំនួនដែលអ្នកចង់បានពីអ្នកតម្កល់ប្រាក់ម្នាក់ផ្សេងទៀត។ ប្រព័ន្ធទាំងមូលដើរលើការសន្មតទុកចិត្តគ្នាថា ម្នាក់ៗនឹងមិនចង់បានលុយរបស់ខ្លួនត្រឡប់មកវិញក្នុងពេលតែមួយព្រមគ្នានោះទេ។ បើវាកើតឡើងដូច្នោះ ប្រព័ន្ធទាំងមូលនឹងដួលរលំជាមិនខាន (នេះហើយ គឺអ្វី ដែលបានកើតឡើងនៅឆ្នាំ ២០០៨)។ ត្រង់នេះគេហៅថា **"ការសម្រុកដកប្រាក់ពីធនាគារ (a run on the banks)**។

ក្នុងប៉ុន្មានទសវត្សរ៍កន្លងមកនេះ ធនាគារបានពង្រីករបររកស៊ីរបស់ខ្លួនទៅហួសពីការគ្រាន់តែទទួលប្រាក់បញ្ញើ និងផ្ដល់ប្រាក់កម្ចីទៅទៀត។ គឺវាបានឈានទៅដល់អ្វីដែលគេហៅថា **ធនាគារកិច្ចវិនិយោគ (investment banking)**។ ក្នុងនេះ គឺធនាគារផ្ដល់សេវាកម្មដល់មូលនិធិសោធននិវត្តន៍ មូលនិធិជានារ៉ាប់រង និងដល់អ្នកវិនិយោគគ្រប់ប្រភេទដែលតាមរយៈនេះធនាគារក្រឡុកទីផ្សារ ដើម្បីរកមហាផលចំណេញឲ្យខ្លួនឯង។ ពួកគេជួញដូរភាគហ៊ុន ឥណទេយ្យប័ណ្ណ (bonds) វត្ថុធាតុដើម និងរូបិយប័ណ្ណ ក្នុងទំហំដ៏ធំធេងរហូតដល់ថាបើទោះជាគេជួញដូរក្នុងតម្លៃភាគរយទាបក្នុងការជួញដូរនីមួយៗក្ដី ក៏គេនៅតែអាចរកបានប្រាក់ចំណេញសំបើមបានដែរ។ លើកលែងតែមានការជួបប្រទះភាពអាក់រអួលខ្លះៗ ល្បែងនេះនៅតែបន្តអស់ពេលជាងបីទសវត្សរ៍កន្លងមកនេះ ដោយក្រុមធនាគារ រកលុយបានកាន់តែច្រើនឡើងៗ មកបង្កើនបៀវត្សរ៍ និងប្រាក់រង្វាន់ច្រើនសន្ធឹកសន្ធាប់សម្រាប់ពួកអ្នកគ្រប់គ្រងចាត់ការធនាគារគ្នាគេនោះតែប៉ុណ្ណោះ។

ធនាគារត្រូវបានគ្រប់គ្រងចាត់ចែងដោយមនុស្សដូច្នេះមានន័យថា ជាញឹកញាប់ វាក៏មានអារម្មណ៍ ឬភាពរំជើបរំជួលដូចអារម្មណ៍មនុស្សដែរ គឺថាកាលណាមនុស្សយើងកាន់តែមានស្ដុកស្ដម្ភតាមរយៈការធ្វើអ្វីមួយ យើងនឹងធ្វើវាថែមទៀត គឺធ្វើរហូតទាល់តែយើងកាន់តែមានឡើងៗ។ ធនាគាររកចំណេញពីការឲ្យលុយគេខ្ចី គឺឲ្យគេខ្ចីហើយខ្ចីទៀតរហូតទាល់តែគេភ្ញាក់ខ្លួនថាគេបានឲ្យលុយខ្ចីទៅមនុស្សម្នាជាច្រើនដែលគ្មានលទ្ធភាពសងមកវិញបាន។ ពេលនោះ ធនាគារចាប់ផ្ដើមមានការភ័យព្រួយ

ហើយឈប់ផ្តល់កម្ចី ទោះបីជាមួយមនុស្សដែលមានលទ្ធភាពសងវិញក៏ដោយ ពីព្រោះថាការទុកចិត្តគ្នាទៅវិញទៅមកបានវិនាសបាត់អស់ទៅហើយ នៅលើភាគីទាំងសងខាង។ គេហៅស្ថានភាពបែបនេះថាជា**ការរឹតត្បិតឥណទាន (credit squeeze)** ដែលជាស្នូលនៃវិបត្តិហិរញ្ញវត្ថុឆ្នាំ ២០០៨។ តែក្នុងរយៈពេលមួយយ៉ាងខ្លីប៉ុណ្ណោះ ពិភពលោកបានប្រែប្រួលពីការដែលធ្លាប់តែមាន**ការផ្តល់ឥណទានច្រើនលើសលុប (over-lending)** ទៅជាស្ថានភាពមួយ**មិនសូវផ្តល់ឥណទាន (under-lending) ទៅវិញ**។ ឧទាហរណ៍ មានរថយន្តប៊ីសមួយកំពុងត្រូវភ្លើងឆាបឆេះដោយសារសាំងធ្លាយចេញពីធុងឥន្ធនៈ។ ប្រសិនបើអ្នកបើកបរប៊ីសគ្រប់រូបឃើញហេតុការណ៍នេះហើយនិយាយថា "សូមទោស ខ្ញុំនឹងឈប់ចាក់សាំងចូលរថយន្តរបស់ខ្ញុំទៀតហើយ ពីព្រោះហេតុការណ៍ដូចគ្នាអាចកើតមានដល់ខ្ញុំដែរ" ពេលនោះ សេវាកម្មដឹកជញ្ជូនដោយរថយន្តប៊ីស នឹងត្រូវគាំងស្ទើរជាមិនខាន។ នោះហើយ គឺអ្វីដែលបានកើតឡើងជាមួយនឹងប្រព័ន្ធធនាគារកាលពីឆ្នាំ ២០០៨។

បើទោះជាធនាគារផ្តល់កម្ចីច្រើនយ៉ាងណាក៏ដោយ ក៏ពួកគេមិនចូលចិត្តឲ្យលុយអ្នកក្រីក្រខ្ចីទេ ពីព្រោះគេមិនទុកចិត្តថា អ្នកទាំងនោះមានលទ្ធភាពសងបំណុលវិញ។ បណ្តារដ្ឋមួយចំនួនព្យាយាមដំនះបញ្ហានេះដោយបង្កើតធនាគាររដ្ឋ ឬ "ធនាគារកសិកម្ម" ឬមួយក៏គេអនុម័តច្បាប់ដែលអនុញ្ញាតគេឲ្យតម្រូវធនាគារឯកជនឲ្យផ្តល់ឥណទានដល់ប្រជាជន និងក្រុមហ៊ុនដែលត្រូវការកម្ចី ទោះជាធនាគារដឹងថាវាមិនមែនជាប្រការល្អសម្រាប់របររកស៊ីរបស់គេក៏ដោយ។ ដំណោះស្រាយមួយទៀត គឺគេបង្កើត**មីក្រូហិរញ្ញវត្ថុ (microfinance)**។ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនលើពិភពលោក មានក្រុមហ៊ុន (ខ្លះជាសាខារបស់ធនាគារធំៗ) ជាច្រើនដែលមានឯកទេសក្នុងការផ្តល់កម្ចីក្នុងចំនួនតិចតួចដល់បុគ្គលដើម្បីជួយពួកគេក្នុងគម្រោងមុខរបរជំនួញតូចតាច។ ឧទាហរណ៍ ដូចជាការជួយស្ត្រីក្នុងភូមិតូចមួយក្នុងការទិញម៉ាស៊ីនដេរ។ ការប្រាក់មីក្រូហិរញ្ញវត្ថុ តាមធម្មតា ច្រើនតែខ្ពស់ ប៉ុន្តែជិត ៩០ ភាគរយ នៃកម្ចីត្រូវបានសងមកវិញទាន់ពេលវេលា។ នេះក៏ដោយសារតែទំនាក់ទំនងជិតស្និទ្ធរវាងម្ចាស់កម្ចីមីក្រូហិរញ្ញវត្ថុ និងសហគមន៍ដែលអ្នកខ្ចីបុលកំពុងរស់នៅ និងធ្វើការ។

## ហេតុអ្វីបានជាវាសំខាន់ ឬគួរឲ្យចាប់អារម្មណ៍ដល់អ្នកអាន?

អ្នកអានមានការពាក់ព័ន្ធជាមួយធនាគារច្រើនបែបច្រើនយ៉ាង។ ភាគច្រើនជាអ្នកដែលដាក់ប្រាក់តំកល់ក្នុង ឬខ្ចីប្រាក់ពីធនាគារវិញ។ អ្នកដទៃទៀតធ្វើការឲ្យក្រុមហ៊ុនដែលខ្ចីលុយពីធនាគារយកមកធ្វើជំនួញរកស៊ី។ តាមការពិត មនុស្សជាច្រើននឹងមិនទទួលបានប្រាក់បៀវត្សរ៍ ឬប្រាក់កម្រៃការងារទេ បើសិនជាធនាគារមិនផ្តល់កម្ចីឲ្យក្រុមហ៊ុនដែលអ្នកទាំងនោះធ្វើការឲ្យ។ (ក្រុមហ៊ុនមិនរង់ចាំទាល់តែវារកលុយបានគ្រប់គ្រាន់ ទើបគេបង់កម្រៃពលកម្មការងារឲ្យបុគ្គលិករបស់ខ្លួននោះទេ។ ក្រុមហ៊ុនបង់កម្រៃការងារឲ្យបុគ្គលិកទៀងទាត់រៀងរាល់ថ្ងៃសុក្រ ឬមួយក៏រៀងរាល់ចុងខែ បើទោះជាក្នុងសប្តាហ៍នេះ ឬខែនេះ ក្រុមហ៊ុនលក់ផលិតផលមិនដាច់ ឬរកស៊ីខាតក៏ដោយ)។ ធនាគារក៏ឲ្យកសិករខ្ចីលុយដែរពីព្រោះផលិតផលស្បៀងពឹងអាស្រ័យលើកសិករ ហើយអ្នកណាក៏ត្រូវការស្បៀងមកទទួលទានដែរ។ ពេលណាមានបញ្ហាអ្វីមួយក្នុងប្រព័ន្ធធនាគារ វានឹងបង្កផលប៉ះពាល់លើមនុស្សគ្រប់រូប មិនថាអ្នកដែលមិនដែលចូលធនាគារសោះក្នុងមួយជីវិតរបស់គេក៏ដោយ។ តាមការពិត វិបត្តិហិរញ្ញវត្ថុភាគច្រើនផ្តើមឡើងនៅក្នុងប្រព័ន្ធធនាគារ។ ដូច្នេះ សុខភាពរបស់ប្រព័ន្ធធនាគារមានសារៈសំខាន់ណាស់ដល់អ្នកអានទាំងអស់។

## តើរឿងប្រភេទណាខ្លះដែលអាចកើតចេញពីប្រធានបទនេះ?

វិធីមួយក្នុងការត្រិះរិះសរសេររឿងអំពីធនាគារ គឺត្រូវចាត់ទុកវាថាដូចជាក្រុមហ៊ុនមួយ ដូចក្រុមហ៊ុនដទៃទៀតដែរ ប៉ុន្តែក្នុងនាមជាក្រុមហ៊ុនមួយ ដែលលក់ផលិតផលហិរញ្ញវត្ថុ មិនមែនលក់ទោចក្រយានយន្តទេ។ បន្ទាប់មកទៀត មើលឧទាហរណ៍ពីខាងមុននេះម្តងទៀត អំពីរបៀបសរសេររឿងអំពីក្រុមហ៊ុន ហើយធ្វើតាមការណែនាំក្នុងការសរសេរអត្ថបទដំណឹងអំពីធនាគារដែរ៖ អ្នកណាជាម្ចាស់ធនាគារ តើគេបើកសាខានៅឯណាខ្លះ តើគេផ្តល់សេវាតម្កល់ប្រាក់ និងកម្ចីបែបណាខ្លះ ហើយក្នុងអត្រាការប្រាក់កម្រិតណា តើអតិថិជនប៉ុន្មាននាក់ដែលគេមាន?

នៅមានរឿងច្រើនដែរដែលគេអាចសរសេរបាន អំពីគោលនយោបាយរដ្ឋាភិបាល និង**ការតាមដានពិនិត្យ (supervision)** ធនាគារ។ រឿងធំបំផុតនៅសហរដ្ឋអាមេរិកអស់រយៈពេល ២០ ឆ្នាំ មុននឹងវិបត្តិហិរញ្ញវត្ថុ ឆ្នាំ ២០០៨ ផ្ទុះឡើង គឺអំពីការដែលខ្វះការតាមដានត្រួតពិនិត្យបណ្តាធនាគារឲ្យបានដិតដល់ ដែលបណ្តោយឲ្យធនាគារទាំងនោះ ផ្តល់កម្ចីខ្វះការប្រុងប្រយ័ត្ន ហើយលក់ទៅឲ្យអតិថិជននូវផលិតផលវិនិយោគតែផ្តេសផ្តាស ដែលទង្វើរបៀបនេះត្រូវបានវិនិយោគិនល្បីឈ្មោះម្នាក់ហៅថា "អាវុធហិរញ្ញវត្ថុប្រល័យលោក" **(financial weapons of mass destruction)**។ មុននឹងវិបត្តិចូលមកដល់ គ្មាននរណាសូវយកចិត្តទុកដាក់សរសេរប៉ុន្មានទេ អំពីទង្វើទាំងនេះរបស់ធនាគារ ហើយនៅទីបំផុត ធនាគារទាំងនោះត្រូវខាតបង់យ៉ាងសម្បើម។

## គោលគំនិតសំខាន់ៗមួយចំនួន

**ធនាគារពាណិជ្ជ (Commercial bank)**៖ ធនាគារទាំងអស់ (លើកលែងតែធនាគារកណ្តាលចេញ *[សូមមើលខាងក្រោម]*) សុទ្ធតែជាធនាគារពាណិជ្ជ។ ពួកវាប្រតិបត្តិការរកស៊ី ដោយសារហេតុផលពាណិជ្ជកម្ម ដូចគ្នានឹង**ធុរកិច្ច** ដែលទាក់ទងផ្ទាល់ជាមួយ**អតិថិជន**ដែរ បើទោះជាថាធនាគារខ្លះស្ថិតក្រោមការកាន់កាប់របស់រដ្ឋក៏ដោយ។ ធនាគារពាណិជ្ជមានសកម្មភាពរកស៊ីច្រើនបែបខុសៗគ្នា ដូចជា **ធនាគារកិច្ចមហាជន (retail banking) ធនាគារកិច្ចជំនួញ (merchant banking) និង ធនាគារកិច្ចវិនិយោគ (investment banking)** *[សូមមើលខាងក្រោម]*។

**ធនាគារកណ្តាល** ៖ វាជា**ធនាគាររបស់ជាតិ**មួយ។ ធនាគារបែបនេះ មិនរកស៊ីដោយផ្ទាល់ជាមួយអតិថិជនទេ។ វាធ្វើនិយតកម្ម និងតាមដានពិនិត្យមើលប្រព័ន្ធធនាគារទាំងមូលក្នុងប្រទេស។ ធនាគារពាណិជ្ជទាំងអស់ត្រូវធ្វើការទាក់ទងរបររកស៊ីជាមួយធនាគារកណ្តាល។ ធនាគារពាណិជ្ជត្រូវតែតម្កល់ទុកបំណែកណាមួយនោះនៃមូលធនរបស់ខ្លួននៅក្នុងធនាគារកណ្តាល ហើយគេអាចខ្ចីវាយកមកប្រើប្រាស់ពេលណាដែលគេត្រូវការវាចាំបាច់។

**ធនាគារកិច្ចមហាជន (retail banking)**៖ នេះគឺអ្វីដែលមហាជនទូទៅយល់អំពីធនាគារកិច្ច។ វាជាប្រតិបត្តិការតាមរយៈការិយាល័យសាខា ដោយមានបុគ្គលិករាប់លុយចាំទទួលប្រាក់តម្កល់ និងបញ្ចេញការដកសាច់ប្រាក់។

**ធនាគារកិច្ចជំនួញ (merchant banking)**៖ កន្លែងនេះនិយាយសំដៅលើអ្វី ដែលធនាគារធ្វើសម្រាប់ក្រុមហ៊ុន នោះ គឺគេផ្តល់សេវាចាត់ចែងហិរញ្ញវត្ថុ (arrange finance) សម្រាប់ក្រុមហ៊ុនទាំងនោះក្នុងការជួញដូរពាណិជ្ជកម្មទាំងក្នុង និងក្រៅប្រទេស។

**ធនាគារកិច្ចវិនិយោគ (investment banking)**៖ នេះសំដៅទៅលើអ្វី ដែលធនាគារធ្វើជូនអ្នកវិនិយោគិនមានការផ្តល់សេវាកម្មអាជីពក្នុង

ការជួញដូរឧបករណ៍ហិរញ្ញវត្ថុ **(trading in financial instruments)** ដូចជា ការវិនិយោគភាគហ៊ុន ប័ណ្ណភាគហ៊ុនទំនិញប្រើប្រាស់ និងរូបិយវត្ថុជាដើម។

**គម្លាត (spread)៖** នេះសំដៅលើភាពខុសគ្នារវាងអត្រាការប្រាក់ដែលធនាគារមួយបង់ទៅឲ្យម្ចាស់តម្កល់ប្រាក់ណាមួយ និងអត្រាដែលខ្លួនដាក់កំណត់ដល់អ្នកខ្ចីបុលណាមួយ។ ចេញពីនេះឯងដែលគេរកបានផលចំណេញរបស់ធនាគារកិច្ចមហាជន *[សូមមើលខាងក្រោម]*។

**ឥណទាន/ទ្រព្យអសកម្ម (non-performing loan/asset)៖** នេះបានន័យថាជាឥណទាន ឬកម្ចីដែលអ្នកខ្ចីបុលមិនបានបង់ត្រឡប់មកវិញឲ្យទាន់ពេលវេលា។

# វិស័យទីផ្សារ

## តើវាជាអ្វី?

នៅលើពិភពលោកនេះ ទីណាក៏មានផ្សារដែរ សម្រាប់ជួញដូរអ្វីៗគ្រប់បែបយ៉ាង បើទោះជាផ្សារនោះខុសច្បាប់ក៏ដោយ ឬក៏វាមានអត្ថិភាពមិនផ្លូវការសម្រាប់ការជួញដូរលួចលាក់ ដូចជា គ្រឿងញៀន និងការជួញដូរផ្លូវភេទជាដើម។ តម្លៃលើរបស់របរទាំងនោះ ត្រូវបានកំណត់ដោយការផ្គត់ផ្គង់ និងតម្រូវការ។ "សេដ្ឋកិច្ចទីផ្សារ " គឺជាសេដ្ឋកិច្ចដែលទទួលស្គាល់ការណ៍ពិតនេះនៃទំនាក់ទំនងរវាងការផ្គត់ផ្គង់ និងតម្រូវការ ហើយដែលបង្កើតបានទីផ្សារផ្លូវការសម្រាប់វត្ថុសព្វសារពើ ដែលជាភាពចាំបាច់ធ្វើឲ្យសេដ្ឋកិច្ចមួយមានសុខភាពមាំមួន។ នៅក្នុងសង្គមភាគច្រើនមាន ផ្សារបន្លែ ផ្សារសម្លៀកបំពាក់ និងផ្សារសាមញ្ញៗផ្សេងទៀត។ តែក៏នៅមានផ្សារផ្លូវការដែលមានលក្ខណៈសាកលផងដែរ ក្នុងនោះមានការផ្ទេរដោះដូរទឹកប្រាក់ក្នុងបរិមាណច្រើនដែលដោយសារហេតុនេះហើយ ទើបគេហៅវាថា **ផ្សារហិរញ្ញវត្ថុ**។ ឈ្មួញផ្សារហិរញ្ញវត្ថុមិនមែនជាមនុស្សធម្មតាដូចរូបអ្នក និងខ្ញុំទេ បើទោះជាថាពេលខ្លះលុយរបស់យើងត្រូវបានគេប្រើក្នុងការជួញដូរនោះ។ ពួកគេជាអ្នករកស៊ីអាជីពក្នុងវិស័យនេះ ដែលមានឯកទេសលើផ្នែក**ឧបករណ៍ហិញ្ញវត្ថុ (financial instruments)** ជាក់លាក់។ លុយដែលគេប្រើប្រាស់ក្នុងការជួញដូរច្រើនតែជាលុយរបស់មូលនិធិនិវត្តន៍-ភាព មូលនិធិធានារ៉ាប់រង និងមូលនិធិវិនិយោគដែលទាំងអស់នេះគេឲ្យឈ្មោះថា **វិនិយោគិនស្ថាប័ន (institutional investors)**។ តួអង្គទីផ្សារដទៃទៀតជា **វិនិយោគិនរាយរង (retail investors)** ដែលជាបុគ្គល អ្នកខ្លះមានលុយ អ្នកខ្លះមិនសូវសំបូរលុយ ឬក៏ជាអ្នកល្បែងដែលសុបិនចង់មានចង់បាន។

ទីផ្សារក្នុងសេដ្ឋកិច្ចទំនើបមាន៖

១. **ផ្សាររូបិយវត្ថុ**។ រៀងរាល់ថ្ងៃ សាច់ប្រាក់ក្នុងបរិមាណច្រើនសន្ធឹកសន្ធាប់ ត្រូវបានដោះដូរពីដៃមួយទៅដៃមួយទៀតឥតឈប់ឈរ។ ឧទាហរណ៍ ក្នុងមួយថ្ងៃ ក្រុមហ៊ុនផលិតសំបកកង់អាចទទួលបានប្រាក់មួយលានដុល្លារពីការលក់សំបកកង់ឲ្យក្រុមហ៊ុនផលិតទោចក្រយានយន្តមួយ។ តែប្រាំថ្ងៃក្រោយមកទៀត ក្រុមហ៊ុនផលិតសំបកកង់នេះ ត្រូវបង់ប្រាក់រាប់លានឲ្យឈ្មួញជួញជ័រកៅស៊ូ សម្រាប់ថ្លៃវត្ថុធាតុដើមដែលក្រុមហ៊ុនបានទិញយកមកផលិតសំបកកង់។ គេមិនមែនយកលុយនោះទៅដាក់ក្នុងកិះតុរបស់នាយកគ្រប់គ្រងក្រុមហ៊ុនទេ ក្នុងរយៈពេលប្រាំថ្ងៃនោះ។ គឺគេទុកវានៅធនាគារមួយ ដើម្បីឲ្យធនាគារនោះយកទៅ "ធ្វើចលនាទីផ្សារ" **(play the market)**។ និយាយម្យ៉ាងទៀត

បានន័យថា ជំនួសមុខឲ្យក្រុមហ៊ុនដ៏រកៅស៊ូធនាគារនោះតាមរយៈធនាគារមួយទៀតផ្តល់លុយនោះជាកម្ចីដល់ក្រុមហ៊ុនមួយទៀត ដែលមិនអាចប្រមូលលុយបានគ្រប់គ្រាន់ក្នុងរយៈពេលប្រាំថ្ងៃ ហើយត្រូវការលុយរាប់លានជាបន្ទាន់យកទៅបង់ថ្លៃលើអ្វីមួយទៀត។ ការជួញដូរសាច់ប្រាក់រយៈពេលខ្លីបែបនេះ (និងការជួញដូរឧបករណ៍ហិរញ្ញវត្ថុរយៈពេលខ្លីឯទៀត) ត្រូវបានគេស្គាល់ថាជាផ្សារលុយ។ ធនាគារកណ្តាលក៏អាចផ្តល់កម្ចីដល់ទីផ្សារនេះបានដែរ។ តាមរបៀបនេះហើយដែលធនាគារកណ្តាលអាចគ្រប់គ្រងអត្រាការប្រាក់បានពីព្រោះដោយឲ្យខ្ចីលុយតិច ឬច្រើន វាក៏អាចរុញតម្លៃ (អត្រាការប្រាក់) ក្នុងផ្សារលុយឡើង ឬចុះតាមនោះដែរ។

២. **ផ្សារសញ្ញាប័ណ្ណ (Bond markets)**។ រដ្ឋាភិបាល ឬក្រុមហ៊ុនមួយ អាចខ្ចីលុយពីវិនិយោគិនបានដោយចេញសញ្ញាប័ណ្ណ។ ចេញសញ្ញាប័ណ្ណបានន័យថា រដ្ឋាភិបាល ឬក្រុមហ៊ុនឲ្យវិនិយោគិន ក្រដាសមួយសន្លឹកដែលបញ្ជាក់ថា យើងជំពាក់អ្នកឯងមួយលាន ដែលយើងនឹងសងវិញឲ្យអស់ក្នុងពេលប្រាំឆ្នាំ។ ជាមួយគ្នានេះ យើងនឹងបង់ឲ្យអ្នកនូវការប្រាក់ថេរប្រាំភាគរយក្នុងមួយឆ្នាំ។ អ្នកកាន់**សញ្ញាប័ណ្ណ (bondholders)** មិនចាំបាច់រង់ចាំរហូតដល់ប្រាំឆ្នាំដើម្បី **លោះ (redeem)** សញ្ញាប័ណ្ណនោះ (ឬលក់ប័ណ្ណបំណុលនោះយកលុយមកវិញទេ)។ គេអាចលក់សញ្ញាប័ណ្ណនោះទៅវិនិយោគិនម្នាក់ទៀតពេលណាក៏បានក្នុងរយៈពេលនោះ។ នេះជារបៀបផ្សារសញ្ញាប័ណ្ណដំណើរការ។ ដូច្នេះសញ្ញាប័ណ្ណគ្រាន់តែជាកម្ចីមួយ ដែលគេអាចលក់ទៅឲ្យអ្នកណាផ្សេងទៀតក៏បានដែរ។ វាអាស្រ័យលើវិនិយោគិននោះថា តើគេមានបេតនាទិញសញ្ញាប័ណ្ណនោះក្នុងតម្លៃណាហើយតម្លៃនោះ ក៏អាស្រ័យលើតម្រូវការដែរ។ បើសិនជាវិនិយោគិនម្នាក់មិនអាចទទួលបានចំណេញប្រាំភាគរយមកវិញទេ (ក្នុងផ្សារសញ្ញាប័ណ្ណ គេហៅវាថា **ទិន្នផល**) ពីការយកសញ្ញាប័ណ្ណនោះទៅវិនិយោគបន្តទៀត គេប្រហែលជាអាចបង់ឲ្យម្ចាស់ដើមនៃសញ្ញាប័ណ្ណនោះ លើសមួយលានបន្តិចបន្តួចតែប៉ុណ្ណោះ។

៣. **ផ្សារភាគហ៊ុន (Equity markets)**។ នេះ គឺអ្វីដែលយើងចង់មានន័យកាលណាយើងនិយាយដល់ការជួញដូរភាគហ៊ុន។ ចំណែកហ៊ុនរបស់ក្រុមហ៊ុនដែលចុះបញ្ជីលើតារាងភាគហ៊ុន ត្រូវបានគេជួញដូរក្នុងចំនួនរាប់សិបពាន់ ឬលាន ជារៀងរាល់ថ្ងៃរវាងពួកវិនិយោគិន។ តម្លៃរបស់ចំណែកហ៊ុនវាអាស្រ័យលើថាតើវិនិយោគិនម្នាក់សុខចិត្តបង់ប៉ុន្មាន។ កត្តាកំណត់លើការជួញដូរនេះមានច្រើនយ៉ាង រួមមានការជឿជាក់ទូទៅលើស្ថេរភាពនយោបាយ ការប្រមើលអនាគតសេដ្ឋកិច្ចរបស់ប្រទេសមួយ និងដំណើរការ និងលទ្ធភាពរកចំណេញរបស់ក្រុមហ៊ុនមួយ។ ផ្សារជួញដូរភាគហ៊ុនទាំងអស់ អាចផ្តល់នូវបារ៉ូម៉ែត្រនៃតម្លៃភាគហ៊ុនទាំងអស់បាន ដែលគេហៅថា **សន្ទស្សន៍ (index)**។ ជាឧទាហរណ៍មាន Dow Jones Industrial Average (New York), the Hang Seng Index (Hong Kong), the SET (Bangkok), and the VN-Index (Ho Chi Minh

City)។ កាលណាសន្ទស្សន៍ឡើង មានន័យថា តម្លៃភាគហ៊ុនទូទៅក៏កើនដែរ បើទោះជាថាសន្ទស្សន៍ខ្លះធ្លាក់ចុះក៏ដោយ។ តួលេខជាក់ស្ដែងរបស់សន្ទស្សន៍មិនសំខាន់ទេ គឺការប្រែប្រួលឯណោះវិញទេ ទើបសំខាន់។ (The VN-Index ចាប់ផ្ដើមប្រតិបត្តិការថ្ងៃទី ២៨ កក្កដា ឆ្នាំ ២០០០ ពេលដែលផ្សារភាគហ៊ុនត្រូវបានសម្ពោធ។ ស្រដៀងគ្នានឹងសន្ទស្សន៍ឯទៀតដែរ សន្ទស្សន៍នោះ ត្រូវបានគេឲ្យតម្លៃប៉ាន់ 100។ ដូច្នេះឧទាហរណ៍ថា បើអ្នកឃើញថា the VN-Index បិទការជួញដូរត្រឹមចំណុច 307.6 ថ្ងៃនេះ ហើយកាលពីម្សិលមិញ វាបិទត្រឹម 302.9 នេះមានន័យថា សន្ទស្សន៍បានកើន 4.7 ពិន្ទុ។ ក្នុងថ្ងៃជាមួយគ្នានេះដែរ អ្នកឃើញថា the Hang Seng Index បិទត្រឹម 14,220.79 ហើយម្សិលមិញវាបិទត្រឹម 14,001.50។ នេះបង្ហាញឲ្យឃើញនូវកំណើន 219.29 ពិន្ទុ។ តួលេខខុសគ្នាមែនទែន តែអ្វីសំខាន់គឺមិនមែនតួលេខសន្ទស្សន៍ទេ។ សំខាន់គឺការប្រែប្រួល ហើយក្នុងករណីទាំងពីរខាងលើ ការប្រែប្រួលក្នុងសន្ទស្សន៍មាន 1.6 ភាគរយ។


ប្រទេសក្រីក្រតែងប្រើប្រាស់វិស័យទេសចរណ៍ ដើម្បីរកចំណូលរូបិយប័ណ្ណបរទេសពីបណ្ដាប្រទេសអ្នកមាន។

៤. **ផ្សារវត្ថុធាតុដើម (Commodities markets)**។ ពាក្យ commodities គឺសំដៅលើវត្ថុធាតុដើមដែលមាន ដូចជា ប្រេង ឧស្ម័ន ធ្យូងថ្ម ជ័រកៅស៊ូ ទង់ដែង កប្បាស កូកូអា អង្ករ ស្រូវសាឡី ទឹកក្រូចប្របាច់ និងអ្វីៗច្រើនមុខទៀត។ វានឹងមិនមានប្រសិទ្ធភាពទេ បើសិនជាក្រុមហ៊ុនផលិតសរសៃខ្សែភ្លើងអគ្គិសនីរបស់ចិនមួយត្រូវបញ្ជូនតំណាងរបស់ខ្លួនទៅប្រទេសឈីលី នៅអាមេរិកខាងត្បូង រាល់ពេលដែលគេចង់ទិញរ៉ែទង់ដែង ហើយតថ្លៃទិញរ៉ែមកដាក់លក់លើនាវានាំមកប្រទេសចិនវិញនោះ។ ផ្ទុយទៅវិញ ឈ្មួញរកស៊ីវត្ថុធាតុដើមទិញលក់កុងត្រារ៉ែទង់ដែង (ដោយគ្មានវត្ថុមានរ៉ែទង់ដែងក្នុងពេលនោះទេ) នៅលើទីផ្សារវត្ថុធាតុដើមនៅក្រុងឡុងដ៍ ឈីកាហ្គោ ញូវយ៉ក និងសៀងហៃ ដែលទាំងនេះសុទ្ធតែជាផ្សារហិរញ្ញវត្ថុធំៗលើពិភពលោក។ ភាគច្រើន ការជួញដូរវត្ថុធាតុដើម ត្រូវបានធ្វើលើគោលការណ៍ **កក់ទុកជាមុន (forward basis)** គេព្រមព្រៀងកិច្ចសន្យាថានឹងបញ្ជូនទំនិញទៅឲ្យអ្នកទិញនៅថ្ងៃណាមួយនាអនាគត ក្នុងតម្លៃមួយដែលគេបានឯកភាពគ្នារួចហើយក្នុងពេលចុះកុងត្រា។

៥. **ផ្សារជួញដូររូបិយវត្ថុបរទេស (Foreign exchange markets)**។ ទឹកប្រាក់រាប់រយពាន់លាន (trillions) ដុល្លារត្រូវបានគេជួញដូរនៅលើទីផ្សារទាំងនេះ។ តែមានប្រហែលតែ ១០ ភាគរយប៉ុណ្ណោះ ដែលត្រូវបានគេធ្វើការជួញដូរសម្រាប់ធ្វើពាណិជ្ជកម្ម និងវិនិយោគ។ នៅសល់ពីនោះគឺជាការប៉ាន់ស្មាន ឆក់ឱកាសយកចំណេញសុទ្ធសាធ (pure speculation)។ តម្រូវការរូបិយវត្ថុ មួយផ្នែក គឺបណ្តាលមកពីចលនាលំហូរការនាំចេញ និងនាំចូល និងដោយសារលំហូរទុនវិនិយោគរវាងប្រទេស និងប្រទេស តែមួយផ្នែកធំក៏ដោយសារជំនឿជឿជាក់របស់វិនិយោគិនដែរ ដែលវានឹងជំរុញឲ្យតម្លៃរូបិយវត្ថុមួយឡើងខ្ពស់ ធៀបនឹងរូបិយវត្ថុដទៃទៀត ឬក៏យ៉ាងហោចណាស់ រក្សាតម្លៃរបស់វាឲ្យនៅថេរដែរ។ មួយផ្នែកទៀត តម្លៃរូបិយវត្ថុនេះក៏ប្រែប្រួលដោយសារអតិផរណាផងដែរ ពីព្រោះអតិផរណាខ្ពស់នឹងបង្កការខូចខាតតម្លៃរបស់រូបិយវត្ថុមួយជាមិនខាន។ ឧទាហរណ៍ បន្ទាប់ពីមានមហាអតិផរណាអស់ជាច្រើនឆ្នាំមក ប្រទេសវៀតណាមបានបញ្ចុះតម្លៃរូបិយវត្ថុរបស់ខ្លួននៅឆ្នាំ ២០០៨។

៦. **ទីផ្សារដេរីវេទីវ** (Derivatives markets)។ ទាំងនេះជាផ្សារផ្នែកឧបករណ៍ទាំងអម្បាលម៉ានដែលបានពិភាក្សានៅខាងលើនេះ (មានន័យថា តម្លៃរបស់វាត្រូវបានបម្លែងចេញពីផ្សារទាំងអស់នោះ)។ ភាពខុសគ្នានៅត្រង់ថា មានពេលខ្លះឈ្មួញទិញ និងលក់កុងត្រាសម្រាប់ភាគហ៊ុន សញ្ញាប័ណ្ណ វត្ថុធាតុដើម រូបិយវត្ថុនៅពេលអនាគត។ បន្ទាប់មក ពួកគេលក់កុងត្រាទាំងនោះទៅអ្នកផ្សេងនៅលើទីផ្សារដេរីវេទីវវិញ។ ឈ្មួញនិស្សន្ទនេះច្រើនតែជាអ្នកឆក់ឱកាសនិយម ដែលមិនមែនសុទ្ធតែជារឿងអាក្រក់នោះទេ។ អ្នកសេដ្ឋកិច្ចភាគច្រើនមិនគិតថា ការប៉ាន់ស្មានឆក់ឱកាសមិនបង្កឲ្យមានការប្រែប្រួលតម្លៃលើទីផ្សារទេ តែវាជួយសម្រួចនិន្នាការតម្លៃ និងធ្វើឲ្យផលិតករ និងអ្នកប្រើប្រាស់រៀបចំផែនការរបស់ខ្លួនបានកាន់តែប្រសើរជាងមុន។ ឧទាហរណ៍ បើសិនជាអ្នកជាអ្នកចាត់ចែងក្រុមហ៊ុនកង់កៅស៊ូ ហើយត្រូវត្រៀមថវិការបស់ខ្លួនសម្រាប់មួយឆ្នាំ អ្នកប្រហែលជាត្រូវសម្រេចចិត្តទិញជ័រកៅស៊ូ ១០០ តោននៅខែកក្កដា ទុក។ ប៉ុន្តែ អ្នកកំពុងស្ថិតក្នុងខែមករា នៅឡើយ ពេលដែលកំពុងរៀបចំថវិកា។ អ្នកមិនដឹងទេថា តម្លៃណាដែលអ្នកនឹងត្រូវបង់សម្រាប់ជ័រកៅស៊ូក្នុងខែកក្កដា។ ប៉ុន្តែជាជាងទស្សន៍ទាយ (ដែលវាអាចខុស ហើយនាំការខូចខាតដល់ការរកស៊ីរបស់ក្រុមហ៊ុន) អ្នកអាចទិញកុងត្រាមួយក្នុងពេលនេះដែលនឹងអនុញ្ញាតអ្នកឲ្យទិញជ័រកៅស៊ូក្នុងតម្លៃឯកភាពជាមុនមួយសម្រាប់ខែកក្កដា។ ឈ្មួញដែលអ្នកទិញជ័រកៅស៊ូពីគេបានប៉ាន់ប្រមាណទុកជាមុនថា តម្លៃនៅខែកក្កដា នឹងមានកម្រិតទាបជាងអ្វីដែលអ្នកបានព្រមព្រៀងហើយ។ ដូច្នេះ គាត់នឹងចំណេញ។ អញ្ចឹងហើយបានជាគេហ៊ានលេងល្បែងប៉ាន់ឆក់ឱកាសនោះ។ បើគាត់ត្រូវ គាត់នឹងបានចំណេញពីអ្នក។ ប៉ុន្តែអ្នកក៏ចំណេញដែរ ពីព្រោះអ្នកបានបង់លើសតែបន្តិចទេ សម្រាប់ភាពប្រាកដប្រជាមួយ ដើម្បីទទួលបានជ័រកៅស៊ូក្នុងតម្លៃមួយ

ដែលអ្នកបានគ្រោងទុកក្នុងថវិការបស់អ្នក។ បើតម្លៃខ្ពស់ជាង អ្នកក៏ចំណេញ ពីព្រោះអ្នកត្រូវបង់តែតាមតម្លៃ ដែលអ្នកបានព្រមគ្នាជាមួយឈ្មួញរួចទៅហើយ។ ឯអ្នកខាត គឺឈ្មួញដែលបានធ្វើការប៉ាន់ទុកនោះទៅវិញទេ។ និយាយរួមមក ផ្សារដេរីវេទីវពោរពេញទៅដោយល្បែងទស្សន៍ទាយអំពីអនាគតចលនារបស់ទំនិញសព្វសារពើ រាប់តាំងពីតម្លៃប្រេងឥន្ធនៈ ដល់តម្លៃលុយដុងទល់នឹងលុយដុល្លារ ឬក៏លុយបាត ទល់នឹងលុយយ៉េនជាដើម។

## ហេតុអ្វីបានជាវាសំខាន់ ឬគួរឲ្យចាប់អារម្មណ៍ដល់អ្នកអាន?

ក្នុងចំណោមអ្នកអានរបស់អ្នក មានតិចគ្នាណាស់ ដែលជាឈ្មួញជួញដូរទីផ្សារ ឬក៏មានការយល់អំពីទីផ្សារ ក៏ប៉ុន្តែចលនាតម្លៃលើវត្ថុក្នុងទីផ្សារទាំងអម្បាលម៉ានខាងលើនេះ អាចមានផលប៉ះពាល់ទៅលើពួកគេដែរ។ វាពិតជាមិនពិបាកនឹងយល់ទេថា តម្លៃប្រេងឥន្ធនៈមានផលប៉ះទង្គិចមកលើ យើងទាំងអស់គ្នា ដែលក្នុងចំណោមហ្នឹងអ្នកខ្លះជាអ្នកធ្វើដំណើរតាមរថយន្តប៊ីស និងទៅលើអ្នកដទៃទៀត ដែលទិញស្បៀងអាហារ ដែលត្រូវការដឹកជញ្ជូនទៅកាន់ទីផ្សារ។ តែបើតម្លៃជ័រកៅស៊ូធ្លាក់ទាបទៅវិញ នៅលើទីផ្សារវត្ថុធាតុដើម នោះវានឹងប៉ះពាល់ដល់ចំការកៅស៊ូដែលជាម្ចាស់ក្រុមហ៊ុន និងកម្មករចំការកៅស៊ូក្នុងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍។ តម្លៃស្បៀងអាហារដែលឡើងខ្ពស់មែនទែនក្នុងឆ្នាំ ២០០៧ និង ២០០៨ បានញ៉ាំងឲ្យអ្នកសេដ្ឋកិច្ចនិយាយអំពីអំពីវិបត្តិស្បៀងអាហារ។ កាលណាយើងតាមដាននិន្នាការផ្សារវត្ថុធាតុដើម វាអាចឲ្យយើងដឹងសញ្ញាជាមុនថា តើមានអ្វីនឹងអាចកើតឡើងនាពេលខាងមុខ។

វិបត្តិហិរញ្ញវត្ថុឆ្នាំ ២០០៨ ផ្តើមឡើងដោយបញ្ហាតម្លៃលំនៅដ្ឋាននៅសហរដ្ឋអាមេរិក ហើយក៏រីករាលដាលដូចភ្លើងឆេះព្រៃអញ្ចឹង។ មុនដំបូង វិបត្តិវាប៉ះទង្គិចផ្សារហិរញ្ញវត្ថុមុនគេ ដោយម្នាក់ៗមិនហ៊ានឲ្យលុយអ្នកផ្សេងទៀតខ្ចី ខ្លាចក្រែងមិនអាចទារលុយមកវិញបាន ដែលនេះបណ្តាលឲ្យមានការ**រឹតត្បិតឥណទាន** (credit crunch)។ ក្រោយមកទៀត វាក៏រាលដាលដល់ផ្សារភាគហ៊ុន និងផ្សារសញ្ញាប័ណ្ណ ដោយសារភាគហ៊ុនធនាគារធ្លាក់ចុះ ហើយម្នាក់ៗក៏ដឹងខ្លួនថាសភាពការណ៍នឹងឆ្ពោះទៅរកការធ្លាក់ចុះកំណើនសេដ្ឋកិច្ច ដែលនឹងប៉ះទង្គិចដល់គ្រប់ក្រុមហ៊ុនទាំងអស់។ វិបត្តិនេះបានបណ្តាលឲ្យក្រុមហ៊ុនចាប់ផ្តើមកាត់បន្ថយការវិនិយោគ និងផែនការពង្រីកធុរកិច្ចរបស់គេ ដែលនេះប៉ះទង្គិចផ្សារវត្ថុធាតុដើម ដោយសារថាលែងសូវមានតម្រូវការចំពោះវត្ថុធាតុដើមដូចមុនទៀត។ (ឧទាហរណ៍ តម្លៃប្រេងឥន្ធនៈ មុនពេលមានវិបត្តិហិរញ្ញវត្ថុស៊ីពេលតែពីរឆ្នាំទេ ក្នុងការហក់ឡើងពីតម្លៃ ៤០ ដុល្លារអាមេរិក ទៅដល់ ១៤៧ ដុល្លារក្នុងមួយធុង តែក្នុងពេលមានវិបត្តិ ធ្លាក់តម្លៃស្រឹតៗវិញក្នុងរយៈពេលតែប្រាំមួយសប្តាហ៍តែប៉ុណ្ណោះ)។ ពេលនោះ ផ្សាររូបិយវត្ថុទៅជាវង្វេងវង្វាន់អស់ហើយ ដែលក្នុងនោះ លុយយ៉េនរបស់ជប៉ុនឡើងតម្លៃខ្ពស់មួយរំពេចដែលមិនធ្លាប់មាន ហើយលុយដុល្លារអាមេរិកក៏ឡើងថ្លៃដែរ។ នេះដោយសារថា ក្នុងករណីទាំងពីរនេះ សាច់ប្រាក់រាប់ពាន់លានក្នុងការវិនិយោគផ្សារហិរញ្ញវត្ថុជុំវិញពិភពលោក បានជោរជន់ត្រឡប់ទៅរកប្រទេសជប៉ុន និងសហរដ្ឋអាមេរិកវិញ ដោយបង្កើនថែមទៀតនូវតម្រូវការបំពោះរូបិយវត្ថុទាំងពីរនេះ។

## តើរឿងប្រភេទណាខ្លះដែលអាចកើតចេញពីប្រធានបទនេះ?

រឿងអំពីផ្សារជួញដូរមានច្រើនតែងដែលៗ ហើយមិនសំខាន់ ឬគួរចាប់អារម្មណ៍ប៉ុន្មានដល់អ្នកអានទូទៅ ដូចគ្នានឹងលទ្ធផលបាល់ទាត់បំពោះអ្នកដែលមិនចូលចិត្តមើលកីឡានេះដែរអញ្ចឹង។ តាមធម្មតា គេដាក់ព័ត៌មានអំពីទីផ្សារតែនៅលើទំព័រដោយឡែកមួយដែលនិយាយតែអំពីទីផ្សារជួញដូរគ្រប់បែបយ៉ាង ដែលយើងបានពិភាក្សាខាងដើមរួចមកហើយ។ តែនៅមានរឿងច្រើនឯទៀតដែលគួរឲ្យចាប់អារម្មណ៍ និងមានសារៈសំខាន់ដល់អ្នកអាន។ កាលណាប្រទេសមួយបង្កើតផ្សារភាគហ៊ុន គេនឹងមានរឿងជាច្រើនដែលគេអាចសរសេរបានអំពីថាតើផ្សារនោះនឹងដំណើរការរបៀបម៉េច អ្នកណានឹងគ្រប់គ្រងវា ក្រុមហ៊ុនណាខ្លះនឹងចុះបញ្ជីជួញភាគហ៊ុនរបស់ខ្លួន និងថាតើវិធីសាស្ត្រអ្វីខ្លះដែលគេនឹងប្រើសម្រាប់ប្រែក្លាយក្រុមហ៊ុនកាន់កាប់ដោយរដ្ឋឲ្យទៅជា**ក្រុមហ៊ុនសាធារណៈចុះបញ្ជី (public private companies)** ដែលនេះជាដំណើរការមួយ ដែលគេឲ្យឈ្មោះថា ឯកជនភាវូបនីយកម្ម។ ក្រៅពីនោះក៏មានរឿងមនុស្សគួរឲ្យចាប់អារម្មណ៍ដែរ ដូចជាតើឈ្មួញ ធុរជនធំៗ និងវិនិយោគិនណាខ្លះដែលនឹងទទួលផលបំណេញ? លើសពីនោះទៀតមានរឿងអំពីអំពើពុករលួយ និងឧក្រិដ្ឋកម្ម។ (ឧក្រិដ្ឋកម្មហិរញ្ញវត្ថុធំបំផុតក្នុងប្រវត្តិសាស្ត្រត្រូវបានគេប្រព្រឹត្តឡើងអស់រយៈពេលជាង ២០ ឆ្នាំ ដែលក្នុងអំឡុងពេលនោះទីផ្សារ និងការវិនិយោគធនាគារបានឡើងដល់កំពូលរបស់ខ្លួនក្នុងតម្លៃ ៥០ ពាន់លានដុល្លារ-អាមេរិក ក្នុងការក្លែងបន្លំដោយលោក Bernie Madoff ដែលជាវិនិយោគិនធ្លាប់ល្បីឈ្មោះ និងមានបទពិសោធន៍ខ្ពស់មួយរូបសញ្ជាតិអាមេរិក)។

## គោលគំនិតសំខាន់ៗមួយចំនួន

**មូលបត្រ (Securities)៖** នេះជាពាក្យមួយទៀតសម្រាប់ការវិនិយោគមួយ ដូចជាចំណែកហ៊ុន និងសញ្ញាប័ណ្ណជាដើម ដែលអាចទិញ និងលក់បានលើផ្សារភាគហ៊ុន។

**ប៊ូម (Boom)៖** នេះសំដៅលើពេលទីផ្សារមានការលូតលាស់ខ្លាំងក្នុងរយៈពេលមួយវែង។

**ពពុះ (Bubble)៖** ជាស្ថានភាពកំណើនមួយដល់ចំណុចដែលតម្លៃលើទីផ្សារខ្ពស់មិនសមហេតុផល ហើយនឹងដួលរលំដូចពពុះសាប៊ូផ្ទុះបែកអញ្ចឹង។

**បែកខ្ចាយ (Bust)៖** ជាពេលដែលកំណើនឈប់លែងមានតទៅទៀត ហើយចាប់ផ្ដើមងាករកទិសដៅថ្មីវិញ។

**ការដួលរលំ (Crash)៖** នៅពេលដែលការបែកខ្ចាយនេះកើតឡើងយ៉ាងឆាប់រហ័សតែក្នុងប៉ុន្មានថ្ងៃប៉ុណ្ណោះ។

**ប៊ុល (Bull)៖** ពាក្យនេះ ក្នុងន័យត្រង់បានសេចក្ដីថាជា គោឈ្មោល ឬគោបា។ ក្នុងបរិបទនេះគេប្រើសម្រាប់វាសម្គាល់មនុស្សណា ដែលហ៊ានជឿថាតម្លៃលើទីផ្សារនឹងបន្តកើនទៅថ្ងៃមុខ។ និយាយឲ្យស្រួលស្ដាប់ គេជាជនសុទិដ្ឋិនិយមអំពីទីផ្សារ (market optimist)។

**ប៊ែរ (Bear)៖** ន័យត្រង់របស់វា គឺខ្លាឃ្មុំ។ តែក្នុងបរិបទនេះ ពាក្យនេះត្រូវបានប្រើសម្រាប់អ្នកមានទុទិដ្ឋិនិយមអំពីតម្លៃលើទីផ្សារ ដែលផ្ទុយគ្នាស្រឡះទៅនឹងពាក្យពីខាងលើ។

**ផលចំណូល (Yield)៖** គឺសំដៅលើភាគរយនៃចំណូលពីការវិនិយោគ។ ក្នុងនោះ សំខាន់ជាងគេគឺផលចំណូលសញ្ញាប័ណ្ណ ដែលពិបាកគណនា តែវាអាចប្រាប់អ្នកបានអំពីភាគរយចំណូលដែលអ្នកទទួលបានលើមូលដ្ឋានអត្រាការប្រាក់ថេរ និងតម្លៃដែលអ្នកបង់ក្នុងការទិញសញ្ញាប័ណ្ណនៅក្នុងរយៈ-

កាលមួយ មុនពេលដែលសញ្ញាប័ណ្ណនោះមិនទាន់ត្រូវបានរំលោះមកវិញ។ ត្រង់នេះគេក៏ស្គាល់វាផងដែរ ថាជាផលសងរំលោះ (yield to redemption)។

**អ្នកវិភាគ (Analyst)៖** គឺជាអ្នកអាជីពដែលសិក្សាអំពីក្រុមហ៊ុនចុះបញ្ជីផ្សារហ៊ុន ហើយផ្ដល់ប្រឹក្សាដល់អ្នកវិនិយោគិនថាគេគួរ ឬមិនគួរទិញ ឬលក់ភាគហ៊ុនរបស់ខ្លួន។

**កាក់ខៀវ (Blue chip)៖** ន័យជាឫសគល់របស់វា កាក់ខៀវ គឺជាប្រភេទកាក់ដែលមានតម្លៃជាងគេក្នុងកាស៊ីណូ។ ក្នុងបរិបទទីផ្សារ កាក់ខៀវ គឺជាសន្និធិ ឬហ៊ុនរបស់ក្រុមហ៊ុនមួយ ដែលមានកេរ្ដិ៍ឈ្មោះល្អ យូរអង្វែងក្នុងលទ្ធភាពរកចំណេញក្នុងរបររកស៊ីរបស់ខ្លួន។

**ប៊ួរស៍ (Bourse)៖** ជាពាក្យបារាំងដែលពេលខ្លះគេប្រើជំនួសឲ្យពាក្យអង់គ្លេស stock market។

**អ្នកឈ្មួញជើងហ៊ុន (Stockbroker)៖** ជាអ្នកអាជីពរកស៊ីទិញ-លក់ហ៊ុនជំនួសឲ្យម៉ូយណាម្នាក់។

**លុបពីបញ្ជី (Delist)៖** ពេលណាក្រុមហ៊ុនមួយជួលក្នុងការរកស៊ី ឬក៏មិនប្រតិបត្តិតាមវិធានគណនីក្នុងការជួញដូរភាគហ៊ុន ក្រុមហ៊ុននោះត្រូវបានគេបង្ខំឲ្យដកភាគហ៊ុនរបស់ខ្លួនចេញពីតារាង លែងឲ្យគេទិញលក់បានទៀតហើយ។

**វិនិយោគិនជាស្ថាប័នបរទេស (Foreign institutional investor/FII)៖** ជាមូលនិធិសោធនិវត្តន៍ ឬមូលនិធិវិនិយោគពីក្រៅប្រទេសដែលទិញហ៊ុនក្នុងផ្សារភាគហ៊ុនប្រទេសរបស់អ្នក។

**ថ្លៃរបស់ក្រុមហ៊ុនលើទីផ្សារ (Market capitalization)៖** ចំនួនហ៊ុនគុណដោយតម្លៃលើទីផ្សារនៃហ៊ុនមួយ ដែលវានឹងផ្ដល់ថ្លៃសរុបរបស់ក្រុមហ៊ុនលើទីផ្សារ។

**មូលនិធិការពារហានិភ័យ (Hedge fund)៖** ជាក្រុមហ៊ុនបង្កើតឡើងដោយពួកផ្សារអាជីពដែលគិតថាពួកគេជាអ្នកប៉ិនប្រសប់ ហ៊ានធ្វើឲ្យលុយពួកអ្នកមានកាន់តែមានស្ដុកស្ដម្ភថែមទៀត ហើយតាមរយៈនោះ ពួកគេទទួលបានប្រាក់បៀវត្សរ៍ខ្ពស់ និងប្រាក់បន្ថែមពីលើនោះច្រើនថែមទៀត។ ពួកនេះព្យាយាមរកលុយបានច្រើនសន្ធឹកសន្ធាប់ណាស់ ទាំងពីផ្សារដែលកំពុងរកស៊ីមានបាន និងផ្សារដែលបរាជ័យក្នុងការទិញលក់ភាគហ៊ុន តែវិបត្តិហិរញ្ញវត្ថុឆ្នាំ ២០០៨ បានធ្វើឲ្យពួកនេះវិនាសបាត់សឹងតែអស់ទៅវិញ។

**អន្តរាគមន៍ (Intervention)៖** គឺពេលដែលធនាគារកណ្ដាលទិញ ឬលក់រូបិយវត្ថុរបស់ខ្លួនក្នុងផ្សារប្ដូររូបិយវត្ថុបរទេស ដើម្បីប្រឹងជះឥទ្ធិពលលើតម្លៃរូបិយវត្ថុ (ឬអត្រាប្ដូរប្រាក់) របស់ខ្លួនទល់នឹងរូបិយវត្ថុដទៃទៀត។

**និយតកម្ម (Regulation)៖** ជាការពិនិត្យពិច័យដោយភ្នាក់ងាររដ្ឋាភិបាលលើទីផ្សារ ដើម្បីធានាឲ្យបានថា វិនិយោគិនមិនត្រូវបានគេបោកប្រាស់ ហើយឈ្មួញហ៊ុនមិនចេះតែក្រឡុកតម្លៃហ៊ុនផ្ដេសផ្ដាសតាមអំពើចិត្ត។ ពួកនិយតករ "បានលង់លក់ក្នុងដំណេក" អស់ជិតពីរទសវត្សរ៍ ដោយខ្វះការប្រុងប្រយ័ត្ន មុននឹងវិបត្តិហិរញ្ញវត្ថុវាយប្រហារលើពិភពលោកនៅឆ្នាំ ២០០៨។

**ផលធៀបរវាងថ្លៃហ៊ុនលើទីផ្សារ និងផលចំណេញក្នុងមួយហ៊ុន (Price-earnings ratio)៖** ជាវិធីមួយក្នុងចំណោមវិធីសំខាន់ជាច្រើនសម្រាប់វិនិច្ឆ័យថា តើថ្លៃហ៊ុនមួយ "ខ្ពស់" ឬ "ទាប"។ វាបានមកពីថ្លៃហ៊ុនមួយលើទីផ្សារចែកនឹងផលចំណេញរបស់វាក្នុងមួយហ៊ុន។

**បរិមាណ (Volume)៖** ជាចំនួនហ៊ុនដែលត្រូវបាន**ជួញដូរ** (តែមិនមែនជាតម្លៃដែលជាថ្លៃគុណជាមួយនឹងបរិមាណនោះទេ)។

# ពាណិជ្ជកម្ម និងសកលភាវូបនីយកម្ម

## តើវាជាស្អី?

ក្រោយសង្គ្រាមលោកលើកទីពីរត្រូវបានបញ្ចប់ អ្នកធ្វើសេចក្តីសំរេចនយោបាយធំៗលើឆាកអន្តរជាតិ (ជាពិសេសសហរដ្ឋអាមេរិក និងអង់គ្លេស) ជឿថា **សង្គ្រាមពាណិជ្ជកម្ម**រវាងប្រទេស និងប្រទេសនានាកាលពីទសវត្សរ៍ឆ្នាំ ១៩៣០ គឺជាដើមចមនាំឲ្យមានសង្គ្រាមលោកលើកទីពីរនេះឯង។ ពួកគេក៏ជឿដែរថា ភាពក្រីក្រជាលទ្ធផលនាំឲ្យមានគោលនយោបាយអាក្រក់ៗ និងបង្កើតចេញនូវមេដឹកនាំផ្តាច់ការពូកែបង្ករឿងហេតុ តួយ៉ាងដូចជាអតីតមេដឹកនាំអាល្លឺម៉ង់ឈ្មោះហ៊ីត្លែរ។ លើសពីនេះទៀត ពួកគេក៏មានទស្សនៈដែរថា ភាពចលាចលក្នុងប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ ដែលក្នុងនោះ អត្រាប្តូរប្រាក់លោតឡើងចុះស្រេចនឹងចិត្ត ក៏មានបំណែកក្នុងការនាំឲ្យផ្ទុះសង្គ្រាមនោះផងដែរ។ ផ្អែកលើហេតុផលទាំងអស់នេះ ពួកគេនាំគ្នាបង្កើតមូលនិធិហិរញ្ញវត្ថុអន្តរជាតិ (International Monetary Fund) ធនាគារពិភពលោក (World Bank) និងកិច្ចព្រមព្រៀងទូទៅស្តីពីតារាងពន្ធ និងពាណិជ្ជកម្ម (General Agreement on Tariffs and Trade – GATT) ដែលក្រោយមកបានក្លាយទៅជាអង្គការពាណិជ្ជកម្មពិភពលោក (World Trade Organization – WTO)។ មេដឹកនាំពិភពលោកទាំងនោះ ចង់ឲ្យស្ថាប័នទាំងបីនេះ - ដែលជារួមមានឈ្មោះថា **Bretton Woods institutions** (ពីព្រោះកិច្ចប្រជុំទាំងឡាយដែលបង្កើតស្ថាប័នទាំងនេះ ត្រូវបានគេធ្វើឡើងនៅរដ្ឋ New Hampshire សហរដ្ឋអាមេរិក) - សាកល្បងគ្រប់គ្រងសេដ្ឋកិច្ចពិភពលោក ដោយលើកទឹកចិត្តបើកចំហឲ្យមានលំហូរពាណិជ្ជកម្ម និងការវិនិយោគដែលទាំងអស់នេះធ្វើឡើងក្នុងគោលដៅធានាឲ្យមានសន្តិភាព បន្ទាប់ពីមានសង្គ្រាមលោកពីរដងរួចមក។ សែសិបឆ្នាំក្រោយមកទៀត GATT បានជោគជ័យក្នុងការដកចេញនូវរបាំងជាច្រើនក្នុងការធ្វើពាណិជ្ជកម្មលើពិភពលោក ក៏ប៉ុន្តែសង្គ្រាមត្រជាក់ និងការប្រៀកបែកពិភពលោកទៅជាប្លុកប្រទេសគាំទ្រ និងប្រឆាំងលទ្ធិមូលធននិយមនៅតែជាឧបសគ្គដល់ការរីកសាយភាយនៃលទ្ធិសេដ្ឋកិច្ចផ្សារសេរីនៅឡើយ។

ទើបតែមកដល់ទសវត្សរ៍ឆ្នាំ ១៩៨០ ទេ ទើបសកលភាវូបនីយកម្មចាប់ដំណើរការពិតប្រាកដ (ពាក្យ "សកលភាវូបនីយកម្ម" ត្រូវបានគេប្រើជាលើកដំបូងនៅឆ្នាំ ១៩៨៣)។ កម្មវិធីកំណែទម្រង់របស់លោក តេង ស៊ាវពិញ មេដឹកនាំប្រទេសចិននាពេលនោះ និងការរំលំជញ្ជាំងប៊ែរឡាំងប្រហែលមួយទសវត្សរ៍ក្រោយមកទៀត បានវែកផ្លូវឲ្យការសាយភាយទ្រឹស្តីសេដ្ឋកិច្ចទីផ្សារ ព្រមគ្នាជាមួយនឹងគោលនយោបាយសេរីភាវូបនីយកម្មហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ទៅដល់សឹងតែគ្រប់ក្រលៀតទាំងអស់នៃពិភពលោក។ ក្នុងអំឡុងពេលនោះ ក៏មានកើតឡើងនូវវិបត្តិហិរញ្ញវត្ថុច្រើនលើកផងដែរ រួមមានវិបត្តិហិរញ្ញវត្ថុនៅអាស៊ីបូព៌ានៅឆ្នាំ ១៩៩៧ ប៉ុន្តែសកលភាវូបនីយកម្ម និងសេរីភាវូបនីយកម្មនៅតែបន្តបោះជំហានទៅមុខដដែល។ បណ្តាគោលការណ៍របស់វាមានជំនឿថា៖

- បណ្តាប្រទេសកំពុងអភិវឌ្ឍន៍នឹង**ទាក់ទាញបានការវិនិយោគ**ពីបណ្តាប្រទេសអ្នកមាន ពីព្រោះការវិនិយោគនឹងបង្កើតការងារ នាំមកនូវបច្ចេកវិទ្យាថ្មីៗ និងជំនាញដែលប្រទេសកំពុងអភិវឌ្ឍន៍ទាំងនោះមិនអាចបង្កើតបានដោយខ្លួនឯង។ គេអាចធ្វើអ្វីៗទាំងអស់នេះបានតាមរយៈការហូរមូលធនដោយសេរី និងតាមរយៈអត្រាការប្រាក់ទីផ្សារ។

- ការប្រកួតប្រជែងពីសំណាក់វិនិយោគិន និងផលិតផលបរទេស នឹងជួយបង្កើន គុណភាពនៃទំនិញប្រើប្រាស់ និងសេវាកម្ម ក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍។
- បណ្ដាប្រទេសកំពុងអភិវឌ្ឍន៍គួរចូលរួមជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (ដែលបានកើតចេញពី GATT)។ តែដើម្បីក្លាយខ្លួនជាសមាជិកក្នុងអង្គការនេះបាន ប្រទេសទាំងនេះ ត្រូវតែបើកចំហទីផ្សាររបស់ខ្លួនដល់ការប្រកួតប្រជែងពីសំណាក់ការនាំចូលពីបរទេស ទន្ទឹមនឹងការទទួលបានប្រាក់ចំណេញច្រើនជាងមុនសម្រាប់នាំចេញផលិតផលរបស់ខ្លួនចូលទៅទីផ្សារប្រទេសទាំងនោះដែរ។

ឆ្នាំ ២០០៨ ពិភពលោកបានជួបប្រទះនូវវិបត្តិដ៏ធំធេង ប៉ុន្តែវិបត្តិនោះមិនបានបំផ្លាញដល់ការដើរតាមនយោបាយសកលភាវូបនីយកម្មនោះឡើយ តែវាអាចដែរនៅថ្ងៃណាមួយ បើគេមានការធ្វេស-ប្រហែស។

## ហេតុអ្វីបានជាវាសំខាន់ ឬគួរឲ្យចាប់អារម្មណ៍ដល់អ្នកអាន?

លើកលែងតែការលុកលុយឈ្លានពានចេញគ្មានអ្វីដែលបើកប្រទេសមួយឲ្យប្រឈមទៅនឹង**ឥទ្ធិពលបរទេស**ខ្លាំងជាងសេរីភាវូបនីយកម្មសេដ្ឋកិច្ចសកលលោកនោះទេ។ ការងារ ជំនាញប្រពៃណី វប្បធម៌ គុណធម៌សង្គម និងអ្វីៗផ្សេងទៀតអាចផ្លាស់ប្ដូរតាមការអភិវឌ្ឍយ៉ាងឆាប់រហ័ស និងការបើកប្រទេសឲ្យប្រឈមការប្រកួតប្រជែងសកលផលិតផល និងគុណធម៌បរទេស។ អ្នកធ្វើគោលនយោបាយ និងមនុស្សមួយចំនួន ដែលធ្លាប់ទទួលបានប្រយោជន៍ពីប្រព័ន្ធចាស់ ច្រើនជំទាស់នឹងនិន្នការថ្មីនៃសកល-ភាវូបនីយកម្ម។ អ្នកផ្សេងទៀតនិយាយថា គឺនយោបាយថ្មីនេះហើយ ដែលនឹងនាំទីបញ្ចប់ដល់ភាពក្រីក្រ កង្វះការអភិវឌ្ឍ និងជួយប្រជាជនឲ្យមានជីវភាពកាន់តែប្រសើរជាងមុន។ វាមិនសំខាន់ទេថា តើទស្សនៈណាមួយដែលអ្នកឯកភាពជាមួយ។ មិនខ្វះទេ មនុស្សដែលមានចំណាប់អារម្មណ៍ក្នុងប្រធានបទទាំងនេះ។ អ្វីដែលពិបាកសម្រាប់អ្នកក្នុងនាមជាអ្នកសារព័ត៌មាន គឺពន្យល់អំពីកងចង្វាក់ទាក់ទងរវាងគោលនយោបាយ និងលទ្ធផលរបស់វា ដូចជាការពន្យល់ថាហេតុអ្វីបានជាការធ្លាក់ចុះថ្លៃលំនៅដ្ឋាននៅក្រុងឡុសអាន់ជេឡេស អាចនាំឲ្យមានការបាត់បង់ការងាររបស់កម្មកររោងចក្រកាត់ដេរភ្នំពេញទៅវិញ។

## តើរឿងប្រភេទណាខ្លះដែលអាចកើតចេញពីប្រធានបទនេះ?

រឿងទាក់ទិននឹងគោលនយោបាយជារឿងដែលសំខាន់ជាងគេ នោះបានន័យថា តើរដ្ឋាភិបាលរបស់អ្នកកំពុងធ្វើ - ឬក៏មិនបានធ្វើ - អ្វីខ្លះដើម្បីទាក់ទាញការវិនិយោគបើកសេដ្ឋកិច្ចឲ្យមានការនាំចូលច្រើនទៀត ឬក៏ជំរុញការនាំចេញ? ពេលធ្វើសេចក្ដីរាយការណ៍អំពីគោលនយោបាយអ្វីល្អបំផុត ដែលអ្នកអាចធ្វើបាន គឺបង្ហាញដល់អ្នកអានរបស់អ្នកថា តើគោលនយោបាយទាំងនោះដើរបៀបម៉េច ហើយថា តើវានឹងមានឥទ្ធិពលដូចម្ដេចខ្លះទៅលើជីវភាពរបស់ប្រជាជនទូទៅ។ ទៅមើលកន្លែងណាដែលមានការងារថ្មី ទើបនឹងត្រូវបានបង្កើតឡើង ឬក៏កន្លែងណាដែលការងារបែបបទចាស់ត្រូវបានបាត់បង់ទៅវិញ។ ទៅមើលកន្លែងណាដែលមានទេសចរណ៍ចាយដុល្លារ ឬក៏កន្លែងណាដែលបរិស្ថានទទួលការបំពាន ឬកន្លែងណាដែលហាងត្រូវបានបិទទ្វារ ដោយសារគេមិនអាចប្រកួតប្រជែងបានតទៅទៀត។ សាករាយរ៉ាប់ប្រាប់រឿងទាំងនោះតាមការសង្កេតផ្ទាល់ និងតាមរយៈបទពិសោធន៍ ដែលមនុស្សពាក់ព័ន្ធបានជួបប្រទះ។

## គោលគំនិតសំខាន់ៗមួយចំនួន

**ពាណិជ្ជកម្មសេរី ៖** ជាគោលដៅគោលនយោបាយអនុញ្ញាតឲ្យការនាំចេញ និងនាំចូលរួមទាំងសេវាកម្មផង ធ្វើចលនាដោយសេរីរវាងប្រទេស និងប្រទេសដោយ**គ្មានរបាំង** ដូចជាតារាងពន្ធគយជាដើម *[សូមមើលខាងក្រោម]*។

**ពាណិជ្ជកម្មស្មើភាព (Fair trade) ៖** នេះជាជំនឿមួយថា សេរីមែន តែក៏វាមិនចាំបាច់ថាមានភាពស្មើភាពដែរ ពីព្រោះគ្មានសមភាពក្នុងការប្រកួតប្រជែងនោះ។ ប្រទេសខ្លះមានប្រៀបជាងប្រទេសផ្សេងទៀតក្នុងការប្រកួតប្រជែងនោះ។ ដូច្នេះ អ្នកធ្វើគោលនយោបាយត្រូវព្យាយាមជានាឲ្យបានថា ប្រទេសមានការអភិវឌ្ឍតិចតួចទទួលបាន**ឱកាសប្រសើរជាងមុន** ជាការប៉ះប៉ូវក្នុង "ទីលានប្រកួតមិនរាបស្មើ" មួយ។

**តារាងពន្ធគយ (Tariffs) ៖** ជាចំនួនតម្លៃបន្ថែមទៅលើថ្លៃការនាំចូល (ពេលខ្លះលើការនាំចេញផងដែរ) ដើម្បីបង្កើនតម្លៃដែលអ្នកប្រើប្រាស់ត្រូវបង់ពេលទិញឥវ៉ាន់។ តារាងពន្ធគយនេះធ្វើឲ្យទំនិញនាំចូលកាន់តែថ្លៃ ដើម្បីការពារទីផ្សារសម្រាប់វត្ថុផលិតក្នុងស្រុក។

**របាំងមិនមែនពន្ធគយ (Non-tariff barrier) ៖** រដ្ឋាភិបាលជាច្រើនប្រើរបាំង **"លាក់លៀម"** ដើម្បីទប់មិនឲ្យការនាំចេញពីប្រទេសដទៃចូលទីផ្សារក្នុងប្រទេសគេបាន។ ឧទាហរណ៍ មានការហាមឃាត់ទាំងស្រុង ការកំណត់កូតាលើការនាំចូលមុខទំនិញពីបរទេស វិធីស្មុគ្រស្មាញក្នុងការធ្វើឯកសារចាំសម្រាប់នាំទំនិញចូល និងការកំណត់ស្តង់ដារតម្រូវការសុខភាព បច្ចេកទេស និងបរិស្ថានដ៏ខ្ពស់សំដៅធ្វើឲ្យប្រទេសដទៃមិនអាចបំពេញបាន។

**ការគាំពារនិយម (Protectionism) ៖** ជាវិធានការ ឬគោលនយោបាយដែលរដ្ឋាភិបាលចាត់ការសំដៅការពារ**ផលិតករ**ទំនិញ និងសេវាកម្មក្នុងប្រទេសរបស់គេពីការប្រកួតប្រជែងពីបរទេស។ វិធានការនោះមានរបាំងមិនមែនពន្ធគយជាដើម។

**កម្មសិទ្ធិបញ្ញា (Intellectual property) ៖** នេះជាការងារទាក់ទិននឹងការសរសេរផ្នែកទន់នៃកុំព្យូទ័រ ច្រៀងចំរៀង ឬធ្វើភាពយន្តជាដើម។ អង្គការពាណិជ្ជកម្មពិភពលោកជឿថា ការចម្លងរបស់ទាំងអស់នេះ ដោយមិនបានបង់ថ្លៃឲ្យម្ចាស់ ដែលបង្កើតវាមក វាស្មើគ្នានឹងការលួច ហើយត្រូវតែបញ្ឈប់។

**ការលក់បង្ខូចថ្លៃ (Dumping) ៖** ពេលណាដែលក្រុមហ៊ុនមួយលក់ទំនិញរបស់ខ្លួនក្នុងប្រទេសមួយក្នុងតម្លៃមួយ ដែល**ទាបជាងថ្លៃផលិតរបស់វា** (បានន័យថា ទាបជាងថ្លៃដែលគេលក់ទំនិញដដែលនេះក្នុងប្រទេសរបស់ខ្លួនទៅទៀត)។ គោលដៅបែបនេះ គឺដើម្បីដណ្តើមចំណែកទីផ្សារពីទំនិញរបស់ម្ចាស់ស្រុក តែកាលណាគេដណ្តើមអតិថិជនបានហើយ គេនឹងតម្លើងថ្លៃទំនិញនោះវិញ។ ការលក់បង្ខូចថ្លៃធ្វើឲ្យផលិតករក្នុងស្រុកទទួលការខាតបង់ក្នុងរបររកស៊ី។

**ការប្រឆាំងនឹងការលក់បង្ខូចថ្លៃ (Anti-dumping) ៖** ជាវិធានការដែលរដ្ឋាភិបាលប្រកាន់យកក្នុងការព្យាយាមបញ្ឈប់ការលក់បង្ខូចថ្លៃនោះ គឺគេកំណត់ពន្ធគយលើទំនិញ ដែលត្រូវបានលក់បង្ខូចថ្លៃ។ តែពេលខ្លះរដ្ឋាភិបាលចេះតែស្រែកថាមានទំនិញលក់បង្ខូចថ្លៃ ដែលតាមពិតមិនមានទេ តែគេធ្វើដូច្នេះ ដើម្បីដាក់បន្ទុកពន្ធគយលើទំនិញនាំចូល ដើម្បីការពារផលិតករក្នុងស្រុករបស់គេ។ នេះជាទង្វើដែលអង្គការពាណិជ្ជកម្មពិភពលោកមិនឯកភាពជាមួយទេ។

**ជញ្ជីងពាណិជ្ជកម្ម ៖** កាលណាប្រទេសមួយនាំចេញទំនិញចេញច្រើនជាងវានាំចូល ប្រទេសនោះទទួលបាននូវអតិរេកពាណិជ្ជកម្ម តែបើផ្ទុយពីនេះវិញ គឺជាឱនភាពពាណិជ្ជកម្មទៅវិញ។

**ទ្វេភាគី ៖** ពេលដែលប្រទេសពីរបានឯកភាព លើអ្វីមួយរវាងគ្នានឹងគ្នា។ ពួកនិយមពហុភាគីមិន ចូលចិត្តលទ្ធិទ្វេភាគីនេះទេ *[មើលខាងក្រោម]*។

**ពហុភាគី ៖** គឺនៅពេលដែលប្រទេសច្រើន ពាក់ព័ន្ធជាផ្នែកនៃកិច្ចព្រមព្រៀងមួយ។ អង្គការ ពាណិជ្ជកម្មពិភពលោកជាស្ថាប័នពហុភាគីមួយ ដែលក្នុងនោះ **គ្មានអ្វីមួយត្រូវបានព្រមព្រៀងលើទេ ដរាបណាទាល់តែសមាជិកនីមួយៗផ្តល់ការព្រម ព្រៀង**។ ត្រង់នេះហើយដែលពន្យល់ថា ហេតុអ្វីបាន ជាសមាជិករបស់វាពិបាកនឹងឯកភាពទៅលើអ្វីមួយ ណាស់។

**កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ៖** វាជាកិច្ច-ព្រមព្រៀងរវាងប្រទេសពី ឬរវាងប្លុកប្រទេសជាច្រើន ដែលធ្វើពាណិជ្ជកម្មជាមួយគ្នា *[មើលខាងលើ]*។ គេច្រើនចាត់ទុកថាកិច្ចព្រមព្រៀងបែបនេះតែងនាំ ផលល្អដល់ប្រទេសខ្លាំង តែប្រទេសទន់ខ្សោយ មិនមានអំណាចពាណិជ្ជកម្មក្នុងការជជែកចរចា ឲ្យបានកិច្ចព្រមព្រៀងល្អសម្រាប់ខ្លួនគេទេ។ ដូច្នេះ ប្រទេសទន់ខ្សោយចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពាណិជ្ជកម្មសេរី ក៏ដោយសារថា បើគេមិនធ្វើដូច្នោះ ទេ គេនឹងមាន**ប្រកបង្អៀត**ណាស់សម្រាប់ចូលទៅ ក្នុងទីផ្សារប្រទេសអ្នកមាន។

**ការឧបត្ថម្ភធន (Subsidies) ៖** រដ្ឋាភិបាលក្នុង ប្រទេសជាច្រើនផ្តល់លុយអ្នកបង់ពន្ធទៅឲ្យក្រុម ឧស្សាហករ ឬកសិករ ដើម្បីជួយពួកគេក្នុងការផលិត ទំនិញរបស់ខ្លួនឲ្យបានកាន់តែថោក ដែលធ្វើឲ្យវា កាន់តែមានភាពប្រកួតប្រជែងទល់នឹងទំនិញនៃ ប្រទេសដទៃ។ កសិករអាមេរិក និងសហភាពអឺរ៉ុប ទទួលបានពីរដ្ឋាភិបាលរបស់គេនូវការឧបត្ថម្ភធន ជាង ៣.០០០ លានដុល្លារ ក្នុងមួយឆ្នាំ ដែលនេះជា ភាពគួរឲ្យអាម៉ាស់សម្រាប់បណ្តាប្រទេសដែលប្រាប់ គេឯងថា គេមានជំនឿក្នុងការធ្វើពាណិជ្ជកម្មដោយ សេរី និងស្មើភាព។

**ការតែល (Cartel) ៖** ជាក្រុមផលិតករ ដូចជា អង្គការប្រទេសនាំចេញប្រេងឥន្ធនៈ (Organization of Petroleum Exporting Countries) ដែលពួកគេបានប្រមូលផ្តុំចងក្រងគ្នាក្នុងការព្យាយាម គ្រប់គ្រងការផ្គត់ផ្គង់នូវអ្វីដែលគេផលិត ដោយធ្វើ ដូច្នេះគេអាចធ្វើឥទ្ធិពលទៅលើតម្លៃបាន (ដែលជា រឿយៗគេទុកឲ្យវានៅខ្ពស់ជានិច្ច)។

**សេវាកម្មនានា ៖** ការនាំចេញ និងនាំចូលទំនិញ គ្មានរូប (Non-goods exports/imports) ដូចជា វិស័យទូរគមនាគមន៍ ធនាគារកិច្ច និងសេវាកម្ម ហិរញ្ញវត្ថុឯទៀត រួមទាំងការធានារ៉ាប់រង ការផ្សព្វ-ផ្សាយ និងការលក់រាយ។ ប្រទេសជឿនលឿនមាន វិស័យសេវាកម្មអភិវឌ្ឍន៍ខ្ពស់ ហើយចង់ដាក់ ប្រតិបត្តិការក្នុងប្រទេសកំពុងអភិវឌ្ឍន៍ថែមទៀត ផង។ តែបណ្តាប្រទេសកំពុងមានការអភិវឌ្ឍ មានការបារម្ភថា សេវាកម្មរបស់ខ្លួនដែលនៅមាន ការលូតលាស់តិចតួច អាចនឹងត្រូវវិនាសហិនហោច បើសិនជាគេបណ្តោយឲ្យសេវាកម្មខ្លាំងពីបរទេស ចូលក្នុងទីផ្សាររបស់ខ្លួន។

# អនុសាសន៍ចុងក្រោយ

តាមរយៈមនុស្ស គឺជាមធ្យោបាយដ៏ល្អបំផុត សម្រាប់ការធ្វើសេចក្តីរាយការណ៍រឿងអំពីសេដ្ឋកិច្ច និងធុរកិច្ច។ ដូច្នេះគួរតែចេញពីការិយាល័យទៅរក មើលមនុស្សម្នាកំពុងផលិតរបស់លក់ទំនិញ ឬទិញ ឥវ៉ាន់ ដើម្បីប្រមូលព័ត៌មានយកមកសរសេរ។ ចូរធ្វើ ការសង្កេតមើលការផ្លាស់ប្តូរក្នុងសេដ្ឋកិច្ច តាមរយៈ ការយកព័ត៌មានពីហេតុការណ៍ជាក់ស្តែង។ ខាង ក្រោមនេះ ជាឧទាហរណ៍អត្ថបទពិពណ៌នាដ៏ល្អឥត ខ្ចោះមួយអំពីសេដ្ឋកិច្ចក្នុងកាសែត *Phnom Penh Post* ៖

## សេចក្តីអស់សង្ឃឹមមានកាន់តែខ្លាំងឡើង ពេលដែលឧស្សាហកម្មកាត់ដេរកសុីកាន់តែខាត និពន្ធដោយលោក Sam Rith

*ថ្ងៃទី ៩ ធ្នូ ២០០៨*

ព្រលឹមស្រាងៗបានមកដល់នាថ្ងៃមួយក្នុងខែធ្នូ កម្មករកាត់ដេរជាង ១០០ នាក់ នាំគ្នាប្រញាប់-ប្រញាល់ធ្វើដំណើរទៅកាន់រោងចក្រ Supreme Garments PTE ដែលជារោងចក្រកាត់ដេរធំមួយនៅក្បែរស្ពានតាខ្មៅ លើផ្លូវលេខ ១០២ ក្នុងខេត្តកណ្តាល។

ប៉ុន្តែថ្ងៃនេះមិនដូចសព្វដងទេ ព្រោះថាមានកម្មករមួយចំនួនបានចាកចេញពីរោងចក្រវិញ ៤០ នាទីក្រោយមក ហើយនាំគ្នាត្រឡប់ទៅលំនៅដ្ឋានរៀងៗខ្លួន។

អ្នកស្រី អុង ចន្ធូ អាយុ ៥៥ ឆ្នាំ ដែលលក់ផ្លែឈើនៅមុខរោងចក្រនេះជិតប្រាំឆ្នាំមកហើយ មានប្រសាសន៍ឲ្យដឹងពីការសង្កេតរបស់គាត់ដូច្នេះថា៖ "រាល់ថ្ងៃនេះ កម្មករចូលក្នុងរោងចក្រតែមួយភ្លែតៗប៉ុណ្ណោះ ហើយកន្លះម៉ោងក្រោយមកគេនាំគ្នាចេញទៅផ្ទះវិញអស់ហើយ"។

នាង អាណា អាយុ ២៧ ឆ្នាំ ស្ថិតក្នុងចំណោមកម្មករដែលមិនបានធ្វើការថ្ងៃនោះ ហើយនាងនិយាយថា សព្វថ្ងៃនេះ រោងចក្រភាគច្រើនជាងអត់តែងប្រាប់កម្មករឲ្យត្រឡប់ទៅផ្ទះវិញ ដោយសារថាគ្មានអ្វីសម្រាប់ឲ្យពួកគេធ្វើ។

នាងនិយាយថា៖ "តាំងពីពាក់កណ្តាលខែវិច្ឆិកាមកម្ល៉េះ រោងចក្រមិនសូវមានការងារឲ្យពួកយើងធ្វើទេ។"

ការបុះខ្សោយសេដ្ឋកិច្ចអាមេរិកកំពុងតែមានឥទ្ធិពលមកលើកម្មករកាត់ដេររាប់ពាន់នាក់ ដែលធ្វើការក្នុងផ្នែកមួយ ដែលធ្លាប់តែជាវិស័យមានការលូតលាស់រហ័សជាងគេក្នុងសេដ្ឋកិច្ចកម្ពុជា។

យោងតាមទិន្នន័យរបស់ក្រសួងពាណិជ្ជកម្មសហរដ្ឋអាមេរិក តម្លៃនាំចេញសម្លៀកបំពាក់ពីកម្ពុជាទៅសហរដ្ឋអាមេរិក - ដែលជាទីផ្សារផលិតផលវាយនភ័ណ្ឌធំជាងគេសម្រាប់ព្រះរាជាណាចក្រកម្ពុជា - មានប្រមាណ ១.៨ ពាន់លានដុល្លារអាមេរិក ក្នុងអំឡុងពេល ៩ ខែឆ្នាំ ២០០៨ ដែលចំនួននេះទាបជាងបន្តិចបើធៀបទៅនឹងរយៈពេលដដែលក្នុងឆ្នាំមុននេះ។

រីឯតួលេខពីក្រសួងពាណិជ្ជកម្មកម្ពុជាបានបង្ហាញថា ឆ្នាំ២០០៧ វិស័យកាត់ដេរនេះនាំចេញក្នុងតម្លៃ ២.៩ ពាន់លានដុល្លារ នៃផលិតផលដេរ ដោយ ៣១៩ រោងចក្រដែលប្រើកម្មករសរុបជាង ៣៨០.០០០ នាក់។

ប៉ុន្តែ លោក វ៉ាន់ ស៊ូអៀង ប្រធានសមាគមផលិតករកាត់ដេរកម្ពុជា (Garment Manufacturers Association of Cambodia/GMAC) និយាយថា រោងចក្រប្រមាណជា ៣០ ត្រូវបានបិទទ្វារហើយឆ្នាំនេះ ដោយបន្សល់ទុកនូវកម្មករជិត ២០.០០០ នាក់ គ្មានការងារធ្វើ។

ផលកើតចេញពីការបញ្ឈប់ពីការងារបណ្តោះអាសន្ននេះ អាចមានសភាពធ្ងន់ធ្ងរដល់គ្រួសារជាច្រើននៅជនបទ ដែលធ្លាប់តែពឹងពាក់លើប្រាក់កម្រៃដែលសាច់ញាតិធ្វើការក្នុងរោងចក្រផ្ញើឲ្យជាចំណូលជួយទ្រទ្រង់ជីវភាពរបស់ពួកគេ។

មន្ត្រីឧស្សាហកម្មកាត់ដេរបាននិយាយថា ការថយចុះផលិតផលកាត់ដេរនៅកម្ពុជាមានជាប់ឫសគល់ជាមួយនឹងការថមថយសេដ្ឋកិច្ចអាមេរិក ដែលនៅទីនោះការលក់ដូរសម្លៀកបំពាក់មានការធ្លាក់ចុះយ៉ាងគំហុក។

យោងតាមទីភ្នាក់ងារសេវាកម្មព័ត៌មាន Bloomberg ការលក់រាយសម្លៀកបំពាក់នៅសហរដ្ឋអាមេរិក បានដាំក្បាលចុះកាលពីខែវិច្ឆិកា ដែលនេះជាការធ្លាក់ចុះយ៉ាងអាក្រក់បំផុតមិនដែល

មានក្នុងពេលជិតបួនទសវត្សរ៍មកនេះ។ រីឯសេវាកម្ម *Dow Jones US Retail Index* ក៏បានធ្លាក់ចុះជិត ២៨ ភាគរយ ដែរក្នុងឆ្នាំនេះ។

ការលក់ដូរសម្លៀកបំពាក់នៅសហរដ្ឋអាមេរិក ត្រូវបានគេរំពឹងទុកថានឹងធ្លាក់ថែមទៀត ដោយសារអ្នកប្រើប្រាស់ផ្អាកការចាយវាយទៅលើរបស់របរមិនសូវចាំបាច់។

ក្នុងគោលដៅសម្រាលការខាតបង់ GMAC បានព្យាយាមរកទីផ្សារផ្សេងទៀតក្រៅពីសហរដ្ឋ-អាមេរិក មានជាអាទិ៍ដូចជាប្រទេសជប៉ុន និងចិនជាដើម។

កម្មការិនីអាយុ ៥០ ឆ្នាំ ម្នាក់ ដែលមិនចង់បង្ហាញឈ្មោះរបស់ខ្លួន និយាយថា ឆ្នាំនេះមានការធ្លាក់ចុះក្នុងរបររកស៊ីកាត់ដេរនេះខ្លាំងមែនទែន ចាប់តាំងតែពីពេលដែលនាងចូលធ្វើការនៅរោងចក្រ *Supreme Garments* កាលពីឆ្នាំ ១៩៩៥ មក។

នាយកគ្រប់គ្រងរដ្ឋបាលរបស់រោងចក្រ គឺលោក *Chhin Tak Khey* និយាយថា រោងចក្រនេះដែលមានម្ចាស់នៅប្រទេសសិង្ហបុរី អត់ទទួលបានការបញ្ជាទិញដូចរាល់ដងសោះពីបណ្ដាប្រទេសនៅអឺរ៉ុប ប្រទេសសិង្ហបុរី និងក្រុងហុងកុង។

លោកនាយកគ្រប់គ្រងរូបនេះនិយាយថា គាត់ខាតបង់ក្នុងការរកស៊ីនេះពី ២ ម៉ឺន ទៅ ៤ ម៉ឺនដុល្លារ ក្នុងមួយខែ ចាប់តាំងពីខែសីហា មក។ គាត់និយាយថា រោងចក្រនេះដែលបើកប្រតិបត្តិការនៅឆ្នាំ ១៩៩៣ ធ្លាប់ប្រើកម្មករ ២.០០០ នាក់។ តែឥឡូវនេះវានៅប្រើកម្មករតែ ៦២៤ នាក់ ប៉ុណ្ណោះ។

គាត់និយាយថា៖ "តាំងពីខែវិច្ឆិកា ឆ្នាំនេះមក យើងត្រូវបង្ខំចិត្តទៅយកសម្លៀកបំពាក់ពីរោងចក្រដទៃមកឲ្យកម្មកររបស់យើង ដើម្បីបង់ប្រាក់កម្រៃឲ្យពួកគេ"។

និន្នាការដាំក្បាលចុះនេះ ធ្វើឲ្យមន្ត្រីពាក់ព័ន្ធមានការខ្វល់ខ្វាយច្រើន។

លោក វ៉ាន់ ស៊ូអៀង និយាយថា៖ "ឆ្នាំក្រោយ ឧស្សាហកម្មកាត់ដេររបស់កម្ពុជានឹងជួបការលំបាកច្រើនជាងមុន ព្រោះថាឥឡូវនេះអត់មានការបញ្ជាទិញទេ ជាពិសេសពីសហរដ្ឋអាមេរិក។ រោងចក្រមិនអាចនៅបើកទ្វារចោលបានទេ បើគ្មានការបញ្ជាទិញនោះ"។ គាត់ថែមទៀតថា បច្ចុប្បន្ននេះរោងចក្រទាំងអស់នៅទូទាំងប្រទេសកំពុងដំណើរការត្រឹមតែ ៧០ ភាគរយ នៃសមត្ថភាពរបស់វាតែប៉ុណ្ណោះ។

លោក ជួន ម៉ុមថុល ប្រធានសម្ព័ន្ធសហជីពដែលងាកទៅរកខាងរដ្ឋាភិបាល និយាយថា រោងចក្រចំនួន ៣៥ ដែលមានប្រើកម្មករពី ១.០០០ ទៅ ៥.០០០ នាក់ ក្នុងមួយរោងចក្រ ត្រូវបានគេរំពឹងទុកថានឹងបិទទ្វារនៅចុងឆ្នាំ ២០០៨ បើសិនជាផ្សារសកលបន្តដាំក្បាលចុះតទៅទៀតនោះ។

លោក អ៊ុម មាន រដ្ឋលេខាធិការក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និយាយថា គាត់មិនអាចផ្ដល់តួលេខជាក់ស្ដែងអំពីចំនួនរោងចក្រដែលបិទទ្វារនោះទេ។ លោកទទួលស្គាល់ថារោងចក្រខ្លះ បានបិទទ្វារមែនពិត តែវាសុទ្ធតែជារោងចក្រខ្នាតតូចដែលបិទទ្វារ ដើម្បីសង់ជារោងចក្រធំវិញ។

ប៉ុន្តែលោក *Chhin Tak Khey* អ្នកគ្រប់គ្រងរោងចក្រ *Supreme Garments* និយាយថា រោងចក្ររបស់គាត់បានខាតបង់អស់ជាង ២ សែន-ដុល្លារ រួចមកហើយឆ្នាំនេះ ហើយថាគាត់មិនអាចទុកឲ្យវានៅដំណើរការចំពោះមុខការខាតបង់បែបនេះតទៅទៀតបានទេ។

ចាប់ពីខែមករាទៅ ក្រុមហ៊ុនរបស់គាត់នឹងផ្អាកការងារកម្មកររបស់ខ្លួនទាំងអស់រយៈពេលពីរខែ ដើម្បីបញ្ចៀសកុំឲ្យវិបត្តិកាន់តែធ្លាក់សភាពធ្ងន់ធ្ងរថែមទៀត។

គាត់និយាយថា៖ "យើងនឹងបញ្ឈប់ការងារបុគ្គលិកយើងទាំងអស់ជាបណ្ដោះអាសន្នសិន សម្រាប់ពេលពីរខែ ដើម្បីយើងស្វែងរកទីផ្សារថ្មី

និងប្រមូលការបញ្ជាទិញ។ បន្ទាប់ពីនោះ បើស្ថានភាពនៅតែដដែល យើងនឹងមិនមានលទ្ធភាពបន្តរបររកស៊ីរបស់យើងទៀតបានទេ"។

លោក នួន វាសនា អ្នកសម្របសម្រួលកិច្ចការអប់រំនិយោជិតរបស់អង្គការពលកម្មអន្តរជាតិ ប្រចាំកម្ពុជានិយាយថា ភាពប្រឬកប្របល់កាន់តែខ្លាំងឡើងលើទីផ្សារបានធ្វើឲ្យកាន់តែមានការលំបាកសម្រាប់ក្រុមសហជីពធ្វើការការពារសិទ្ធិរបស់កម្មករ។

គាត់និយាយថា៖ "វាតែងតែជាការលំបាកក្នុងការទាមទារឲ្យមានការការពារដល់កម្មករពីសំណាក់និយោជក ប៉ុន្តែវាកាន់តែមានការពិបាកថែមទៀតនៅពេលការបញ្ជាទិញកំពុងធ្លាក់ចុះ"។

តែលោក ជា មុន្នី ប្រធានសហជីពសេរីកម្មករ និយាយថា វិស័យកាត់ដេរកម្ពុជាមិនមានទទួលរងផលប៉ះពាល់ពីទីផ្សារអន្តរជាតិទេ។

គាត់និយាយថា៖ "សម្រាប់ខ្ញុំ ខ្ញុំមិនជឿថាវិបត្តិសេដ្ឋកិច្ចពិភពលោកមានការប៉ះទង្គិចខ្លាំងមកលើរោងចក្រនៅទីនេះទេ ព្រោះថាឧស្សាហកម្មនេះមានការលូតលាស់គ្រាន់បើដែរក្នុងពេលថ្មីៗនេះ"។ គាត់បន្ថែមទៀតថា ផ្ទុយទៅវិញ ការសម្រេចចិត្តរបស់បុគ្គលវិនិយោគិនមួយចំនួនឲ្យបិទទ្វាររោងចក្រជាដើមចមនាំឲ្យមានការបញ្ឈប់កម្មករពីការងារជាបណ្ដោះអាសន្ន។

លោក ជា មុន្នី និយាយថា៖ "ការបិទរោងចក្រកាត់ដេរនៅកម្ពុជា គឺមកពីវិនិយោគិនដែលចង់ដកខ្លួនពីប្រទេសកម្ពុជា បន្ទាប់ពីរកស៊ីនៅទីនេះយូរមកហើយ ដើម្បីចៀសវាងការប្រឈមមុខផ្លូវច្បាប់ជាមួយកម្មករ។ ខ្ញុំនៅតែមានការសង្ស័យដរាបណាមិនទាន់មានការបញ្ជាក់អះអាងពីក្រសួងពាក់ព័ន្ធ ឬក៏សវនករអន្តរជាតិថា រោងចក្រពិតជាត្រូវបានបិទទ្វារមែន ដោយសារតែវិបត្តិពិភពលោក"។

ហេតុផលនៃការធ្លាក់ចុះកាន់តែខ្លាំងក្នុងការលក់ទំនិញសម្លៀកបំពាក់ អាចខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ តែឥទ្ធិពលរបស់វាគ្មាននរណាអាចប្រកែកបានទេ។

លោក សែ ធី អាយុ ២៩ ឆ្នាំ ជាតំណាងឲ្យកម្មករ ៥០០ នាក់ ដែលស្វែងរកប្រាក់សងជំងឺចិត្តពីរោងចក្រ Phnom Penh Garment City Ltd នៅខណ្ឌមានជ័យ ក្រុងភ្នំពេញ។ ពេលកំពុងអង្គុយក្នុងអង្រឹងក្រោមដំបូលរោងកៅស៊ូមួយ ដែលគាត់សង់នៅមុខរោងចក្រ បុរសនោះនិយាយថា៖ "ខ្ញុំបានមករង់ចាំនៅទីនេះអស់ ១០ ខែ មកហើយ តាំងតែពីរោងចក្របិទទ្វារមក"។

ធ្វើសេចក្ដីរាយការណ៍បន្ថែមដោយលោក George McLeod

# ជំពូក ៧ បរិស្ថាន

យើងពិតជាពិបាករកឲ្យឃើញថាមានប្រធានបទណាមួយ ដែលគ្មានការពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន មិនថាវាជាវិស័យស្បៀងអាហារ ការដឹកជញ្ជូន សុខភាព វេជ្ជសាស្ត្រ ថាមពល ធុរកិច្ច ទេសចរណ៍ ភាពក្រីក្រ និងកីឡាទេ។ បរិស្ថានមានផលប៉ះពាល់មកលើយើងទាំងអស់គ្នា តាមរយៈរបៀបយើងរស់នៅ របស់របរដែលយើងទទួលទាន និងតាមរបៀបយើងធ្វើការ។

ការពឹងអាស្រ័យរបស់មនុស្សលើបរិស្ថាន - និងទង្វើរបស់ពួកគេដែលបំផ្លាញបរិស្ថាន - ជាបញ្ហាប្រឈមដ៏ធំបំផុតក្នុងសតវត្សរ៍ទី ២១ យើងនេះ។ ការអភិវឌ្ឍយ៉ាងឆាប់រហ័សនៅតំបន់អាស៊ី ការបំពុលឥតឈប់ឈរ និងការធ្វើអាជីវកម្មលើធនធានធម្មជាតិទូទាំងពិភពលោកបានរុញភពផែនដីរបស់យើងទៅដល់អ្វីមួយ ដែលពួកវិទ្យាសាស្ត្របារម្ភថាជា**ចំណុចក្រឡាប់ចាក់អន្តរាយ (tipping point)**។

ទាំងអស់នេះនាំមកនូវឱកាសគួរឲ្យចង់សរសេររឿងទាំងឡាយទាក់ទងនឹងបរិស្ថាន។ ក្នុងន័យនេះ អ្នកយកព័ត៌មានផ្នែកបរិស្ថានមានកិច្ចការច្រើនដែលត្រូវធ្វើ ដូចជា ចុះយកព័ត៌មានស្ដីអំពីគ្រោះមហន្តរាយ ឧប្បទ្វហេតុឧស្សាហកម្ម ដើររុករុលក្នុងព្រៃ ដើម្បីសរសេររឿងការវិនាសហិនហោចសត្វព្រៃ សម្ភាសន៍ពួកវិទ្យាសាស្ត្រអំពីការប្រែប្រួលអាកាសធាតុ ឬសរសេរអំពីធុរកិច្ចធ្វើផលិតផល ដែលមិនសូវប៉ះពាល់ដល់បរិស្ថាន (environmentally friendly)។ វិស័យបរិស្ថានជាប្រធានបទមួយទូលំទូលាយណាស់ ដូច្នេះរបៀបយកព័ត៌មានអំពីវិស័យនេះ មិនមែនមានតែមួយមុខនោះទេ គឺមានច្រើនយ៉ាង។ ជាមួយគ្នានេះ អ្នកយកព័ត៌មានផ្នែកផ្សេងដូចជា ផ្នែកធុរកិច្ច ផ្នែករដ្ឋាភិបាល និងផ្នែកទូទៅ ក៏អាចរកមុមរឿងបរិស្ថានមកសរសេរបានដែរ។

ពាក្យថា "បរិស្ថាន" មានមួយផ្នែក គឺ **"បរិស្ថានបង្កើតដោយមនុស្ស" (man-made environment)** មានលំនៅដ្ឋាន សាលារៀន រថយន្ត រោងចក្រ និងមួយផ្នែកទៀត គឺ **"បរិស្ថាន - ធម្មជាតិ" (natural environment)** ដែលក្នុងនោះមាន ខ្យល់ ដី ទឹក ដើមឈើ រុក្ខជាតិ សត្វ និងធនធានរ៉ែ។ និយាយយ៉ាងខ្លី បរិស្ថាន គឺអ្វីៗគ្រប់យ៉ាងនៅជុំវិញខ្លួនយើង ហើយយើងជាផ្នែកមួយរបស់វាដែរ។



*តើទីនេះមានបរិស្ថានស្អាតបរិសុទ្ធ ឬត្រូវបានបំពុលដោយទេសចរណ៍អស់ហើយ?*

## ហេតុអ្វីបានជាវាមានសារៈសំខាន់?

មនុស្សទាំងអស់គ្នាត្រូវការខ្យល់ និងទឹកស្អាត ដើម្បីរស់រានមានជីវិត។ អាហារដែលយើងទទួលទានសព្វថ្ងៃ ត្រូវបានគេដាំដុះលើដី ឬយកចេញមកពីសមុទ្រ។ សម្លៀកបំពាក់ដែលយើងពាក់លើខ្លួន ត្រូវបានគេផលិតចេញពី រុក្ខជាតិ និងសត្វ (មានសំឡី សរសៃសូត្រ ស្បែក និងរោមសត្វ)។ លំនៅដែលយើងសាងសង់ត្រូវបានកើតចេញពីដី និងព្រៃ (មានឥដ្ឋ ថ្ម ខ្សាច់ ឈើ និងឫស្សី)។

នៅទ្វីបអាស៊ី មនុស្សជាច្រើនរស់ដោយពឹងលើដីធ្លី (ដោយដាំដុះដំណាំ ចិញ្ចឹមសត្វ នេសាទត្រី) រីឯអ្នកដទៃទៀតរកបរចិញ្ចឹមជីវិតពីដីនេះតែម្តង។ នៅតាមបណ្តាទីក្រុង បរិស្ថានក៏សំខាន់ចាំបាច់ដែរ។ រថយន្ត និងទោចក្រយានយន្តរត់លើដងផ្លូវបានដោយសារថាមពលឥន្ធនៈហ្វូស៊ីល។ ថាមពលប្រើក្នុងគេហដ្ឋាន និងការិយាល័យបានមកពីការដុតធ្យូងថ្ម ឬពីវារីអគ្គិសនី។ ថ្នាំពេទ្យច្រើនមុខដែលជួយសង្គ្រោះជីវិត បានមកពីការផ្សំរុក្ខជាតិច្រើនមុខ។ រោងចក្រភាគច្រើនផលិតរបស់ចេញពីវត្ថុធាតុដើម។

បរិស្ថានសំខាន់ណាស់សំរាប់សុខភាពរបស់យើងទាំងអស់គ្នា។ បើសិនជាខ្យល់ដែលយើងដកដង្ហើម ឬទឹក និងអាហារដែលយើងហូប មានភាពក្រខ្វក់ វាអាចធ្វើឲ្យយើងឈឺ ហើយមិនអាចទៅធ្វើការរួច ហើយបើយើងមិនអាចទៅធ្វើការបាន យើងក៏មិនអាចមានអ្វីមកទ្រទ្រង់គ្រួសារបានដែរ។ យោងតាមការប៉ាន់ស្មានមួយ សារជាតុពុលនៅប្រទេសចិនបានរួមចំណែកដល់ការស្លាប់មនុស្សរាប់រយពាន់នាក់ជារៀងរាល់ឆ្នាំ នៅពេលដែលជំងឺបណ្តាលមកពីការបំពុល វាមានទំហំស្មើនឹងការខាតបង់ ៣ ភាគរយក្នុងសេដ្ឋកិច្ច។

បរិស្ថានក៏ដើរតួនាទីមួយដែរក្នុង**គុណភាពជីវិតរបស់យើង**។ ភ្នំ ដើមឈើ បឹងបួ ទន្លេ សួន និងឧទ្យាន ផ្តល់ឲ្យយើងនូវកន្លែងស្ងប់ស្ងៀម ដើម្បីសម្រាក និងហាត់កាយ។ ធម្មជាតិនានា ដូចជា ពន្លឺពណ៌លឿងនៃព្រះអាទិត្យហៀបអស្តង្គត និងល្បាក់ទឹកជ្រោះជាដើម ជាទិដ្ឋភាពធ្វើឲ្យមនុស្សនិពន្ធចេញជាកំណាព្យ ធ្វើសមាធិ និងបន់ស្រន់ ឬក៏ញុាំងឲ្យអ្នកឯទៀតសញ្ជឹងគិតអំពីអត្ថន័យនៃជីវិតរបស់ពួកគេផងដែរ។

ប្រទេសជាច្រើនក្នុងទ្វីបអាស៊ី កំពុងតែជួបប្រទះបញ្ហាប្រឈមនៃការប្រែប្រួលបរិស្ថានសំបើមណាស់។ ការលូតលាស់សេដ្ឋកិច្ចយ៉ាងឆាប់រហ័សបានបណ្តាលឲ្យមានភាពហិនហោចដល់ធនធានធម្មជាតិ ក៏ដូចជាការខូចខាតដល់ បឹងបួ ទន្លេ ព្រៃ និងដីចំការផងដែរ។ កំណើនសេដ្ឋកិច្ចពិតជារឿងល្អ កាលណាវាជួយបង្កើតបានការងារ បង្កើនគុណភាពសិក្សា និងផ្តល់ទឹកស្អាត និងអនាម័យដល់ពលរដ្ឋ។ ប៉ុន្តែកំណើនក៏នាំមកជាមួយផងដែរនូវរថយន្ត រោងចក្រ និងការសាងសង់ច្រើនថែមទៀត ហើយតាមរយៈនេះ វាក៏មានន័យថា ការបំពុលខ្យល់ តម្រូវការឈើសម្រាប់សង់ផ្ទះ និងគ្រឿងសង្ហារឹម និងភាពចាំបាច់ត្រូវការថាមពល នឹងកាន់តែកើនឡើងតាមនោះដែរ។ ការរីកសន្ធឹងនៃទីប្រជុំជន បំផ្លិចបំផ្លាញដីវាលទំនាប និងជម្រកសត្វព្រៃ នៅពេលដែលកំណើនការហូបចុករបស់មនុស្ស បង្កើតកាកសំណល់សំរាមកាន់តែច្រើនថែមទៀតដែរ។ កំណើនប្រជាជនបង្កើតសម្ពាធក្នុងការប្រែក្លាយ ដីព្រៃទៅជាដីចំការ និងបង្កើនប្រពលភាពថែមទៀតក្នុងការដាំដុះភោគផល តាមរយៈការប្រើប្រាស់កាន់តែច្រើនឡើងនូវថ្នាំសម្លាប់សត្វល្អិត និងជីបំប៉ន ដែលអាចបំពុលសត្វ ទឹក នឹងធ្វើឲ្យខូចគុណភាពដីផងដែរ។ អង្គការសហប្រជាជាតិបានប្រមាណឲ្យដឹងថា ចំនួនមនុស្សរស់លើភពផែនដី

យើងនេះនឹងកើនពីចំនួនបច្ចុប្បន្ន ៦.៧ ពាន់លាននាក់ ដល់ ៩ ពាន់លាននាក់នៅពាក់កណ្តាលសតវត្សរ៍យើងនេះ។ កំណើននេះ វាប្រៀបបាននឹងការថែមនូវប្រទេសឥណ្ឌា និងចិនមួយទៀតអញ្ចឹង នៅពេលដែលទំហំផែនដី និងបរិមាណធនធាននៅតែដដែល។

បញ្ហាប្រឈមរបស់យើង គឺនៅត្រង់ការដែលត្រូវនាំគ្នារៀបចំផែនការប្រកបដោយគតិបណ្ឌិត និងប្រើប្រាស់ធនធានធម្មជាតិតាមរបៀបមួយ ដែលធ្វើឲ្យយើងទាំងអស់គ្នា ទទួលបានបរិស្ថានមួយមានសុខភាពល្អ និងរស់ក្នុងជីវភាពមានគុណភាពសមរម្យ ព្រមជាមួយនោះ ក៏ត្រូវចេះសន្សំសំចៃធនធានឲ្យបានគ្រប់គ្រាន់សម្រាប់ចិញ្ចឹមមនុស្សជំនាន់ក្រោយៗទៀតដែរ។ គោលគំនិតបែបនេះ មានឈ្មោះថា **ការអភិវឌ្ឍប្រកបដោយចីរភាព**។

ដំណឹងល្អនៅត្រង់ថា ឥឡូវនេះមនុស្សម្នារួមទាំងអ្នកសារព័ត៌មានផង បាននាំគ្នាចាប់ផ្តើមយកចិត្តទុកដាក់លើបញ្ហាទាំងអស់នេះហើយ។ ទីក្រុងជាច្រើនតួយ៉ាងក្រុងបាងកក បានប្រឹងប្រែងធ្វើឲ្យគុណភាពខ្យល់ក្នុងទីក្រុងមានភាពប្រសើរជាងមុន និងចាប់ផ្តើមធ្វើការកែច្នៃកាកសំណល់បានកាន់តែច្រើន។ បណ្តាធុរកិច្ចនានាបានសម្លឹងរកវិធីសន្សំសំចៃថាមពល ហើយប្រើប្រាស់ឥន្ធនៈហ្វូស៊ីល ឲ្យកាន់តែតិច។ ប្រទេសខ្លះ មានចិនជាដើម កំពុងចាប់ផ្តើមនិយាយអំពី "ផលិតផលក្នុងស្រុកសរុប បៃតង" (green GDP) ដែលមានន័យ សំដៅរបៀបមួយក្នុងការវាស់វែងផលប៉ះពាល់របស់បរិស្ថានមកលើសេដ្ឋកិច្ចរបស់ពួកគេ។ កំណើនសេដ្ឋកិច្ចក៏អាចបង្កលទ្ធភាពក្នុងការរកដំណោះស្រាយដល់បញ្ហាបរិស្ថានផងដែរ ដោយក្នុងនោះបណ្តារដ្ឋាភិបាលជាច្រើន និងក្រុមធុរកិច្ច អាចវិនិយោគលើបច្ចេកវិទ្យាស្អាត និងលើកផលិតកម្ម ដែលប្រើថាមពលដោយប្រសិទ្ធភាព។ ពេលដែលប្រទេស និងសេដ្ឋកិច្ចចេះតែអភិវឌ្ឍន៍ទៅមុខជាយថាហេតុ ពលរដ្ឋនានាក៏រំពឹងចង់បានលើសពីការទទួលបានចំណូលកាន់តែខ្ពស់ ផ្ទះ និងឡាន កាន់តែស្អាតទៅទៀត។ បានន័យថា គេក៏ទាមទារឲ្យមានបរិស្ថានស្អាតដែរ។

## តួនាទីអ្នកសារព័ត៌មាន

អ្នកសារព័ត៌មានបរិស្ថានមានតួនាទីច្រើនណាស់ដែលត្រូវធ្វើ។ ក្នុងនោះមាន៖

- **លើកកំពស់ការយល់ដឹង**អំពីសារៈសំខាន់របស់បរិស្ថាន និងឥទ្ធិពលដែលមនុស្សធ្វើទៅលើវា។
- **អប់រំ**មនុស្សអំពីច្បាប់ និងគោលនយោបាយដែលមានសម្រាប់ការពារបរិស្ថាន។
- ដាក់រដ្ឋាភិបាលឲ្យមាន**គណនេយ្យភាព**ចំពោះគោលនយោបាយ និងទង្វើរបស់ខ្លួន និងធ្វើពួកគេឲ្យមានការទទួលខុសត្រូវក្នុងការអនុវត្តច្បាប់នានាអំពីបរិស្ថាន។
- **ស៊ើបអង្កេត**ទៅលើក្រុមធុរកិច្ច និងអ្នករកស៊ីណាដែលត្រូវបានសង្ស័យថា បានបំពុលបរិស្ថាន ឬបង្កភាពក្រខ្វក់ក្នុងស្បៀងអាហារ។
- ធ្វើសេចក្តីរាយការណ៍មិនត្រឹមតែអំពីបញ្ហាទេ តែអំពី**ដំណោះស្រាយ**ផង ដើម្បីឲ្យអ្នកផងទាំងពួងបានដឹងថា តើពួកគេអាចធ្វើអ្វីបានខ្លះ ដើម្បីការពារបរិស្ថាន។
- រកមើល**រឿងណាល្អៗ** មិនមែនតែរឿងអាក្រក់ៗមួយមុខនោះទេ ដើម្បីកុំឲ្យមនុស្សអស់សង្ឃឹម ឬធុញទ្រាន់នឹងការផ្តល់ព័ត៌មានអំពីបរិស្ថាននោះ។

- បេះធ្វើយ៉ាងណាឲ្យបញ្ហាបរិស្ថានមាន**ទំនាក់ទំនងសារៈសំខាន់**ដល់បញ្ហាដទៃទៀត ដូចជាផ្នែកសុខាភិបាលសាធារណៈជាដើម។
- ឆ្លុះបញ្ចាំងបញ្ហាពី**គ្រប់ជ្រុងជ្រោយ**ទាំងអស់ រួមទាំងសម្លេងរបស់អ្នកក្រីក្រផង ជាពិសេសអ្នកដែលរស់នៅផ្ទាល់ជាមួយបរិស្ថានធម្មជាតិ ហើយពឹងអាស្រ័យលើវា ដើម្បីជីវភាពរស់នៅ។

មិនមែនគ្រប់ក្រុមប្រព័ន្ធផ្សព្វផ្សាយទាំងអស់សុទ្ធអាចមានធនធានចាត់តាំងអ្នកយកព័ត៌មានបញ្ហាបរិស្ថានពេញម៉ោងបានទេ។ ក៏ប៉ុន្តែអ្នកយកព័ត៌មានម្នាក់ៗនឹងបៀសមិនផុតក្នុងការពើបប្រទះបញ្ហាបរិស្ថាននៅក្នុងមុខព្រួញការងាររបស់ខ្លួនជាមិនខាន។ ខាងក្រោមនេះ ជាចំណងជើងអត្ថបទស្តីពីបរិស្ថានមួយចំនួន ដែលត្រូវបានដកស្រង់ចេញពីទំព័រធុរកិច្ចរបស់កាសែតថៃមួយ៖

- "គ្រាប់ពោតធន់ភាពរាំងស្ងួតអាចប្រើបាននៅឆ្នាំ ២០១០"/'Drought-tolerant corn ready by 2010
- "ក្រុមហ៊ុនម៉ូតូរ៉ូឡាសម្ពោធទូរស័ព្ទមិត្តបរិស្ថាន (ទូរស័ព្ទធ្វើពីដបទឹកជ័រ)" / 'Motorola launched eco-friendly phone (made from recycled water bottles)
- "មនុស្សកាន់តែច្រើននឹងងាកទៅប្រើធនធានករកើតឡើងវិញ"/'More see switch to renewable resources
- "ក្រុមហ៊ុនផលិតរថយន្តប្រើបន្តអគ្គិសនី"/ 'Glint of green fails to lift gloom' (automakers promote cars run by electricity)
- "និម្មិតកម្មជីជីវសាស្ត្រជាសញ្ញាល្អមួយ កសិករសរីរាង្គជាអ្នកទទួលផល" / 'Bio-fertilizer innovation a healthy sign: organic farms will be main beneficiaries'
- "ព្រៃឈើផ្តល់ឱកាសសម្រាប់ទទួលឥណទានកាបោន" / 'Forests hold carbon credit opportunities'

ក្នុងវិស័យកីឡា គុណភាពខ្យល់នៅក្រុងប៉េកាំងជាកង្វល់ធំមួយដល់បណ្តាអត្តពលករដែលចូលរួមប្រកួតកីឡាអូឡាំពិក ឆ្នាំ ២០០៨។ រីឯការអភិវឌ្ឍទីលានវាយកូនគោលវិញ ការប្រើទឹក និងថ្នាំសម្លាប់សត្វល្អិតដើម្បីរក្សាស្មៅឲ្យនៅបៃតង អាចបង្កទំនាស់ជាមួយប្រជាជនរស់នៅក្បែរនោះដែរ។ ក្នុងមុខព្រួញយកព័ត៌មានអំពីរដ្ឋាភិបាល អ្នកយកព័ត៌មានតែងតែពើបប្រទះនឹងបញ្ហាបរិស្ថានទាក់ទិនជាមួយ ដូចជាគំរោងអភិវឌ្ឍន៍ ថាមពល ប្រព័ន្ធធារាសាស្ត្រ ការគ្រប់គ្រងសំណល់រឹង ធនធានធម្មជាតិ ការជួញដូរសត្វព្រៃខុសច្បាប់ និងក្នុងកិច្ចព្រមព្រៀងអន្តរជាតិជាដើម។

មិនថារឿងមួយណាទេ ដែលពួកគេកំពុងធ្វើ អ្នកសារព័ត៌មានគ្រប់រូប ពិតជាអាចធ្វើការបានកាន់តែប្រសើរ ដោយសួរសំណួរទាំងឡាយណាដែលពាក់ព័ន្ធនឹងបរិស្ថាន។ សំណួរសំខាន់ដែលគេគួរចងចាំទុកក្នុងខួរក្បាលនោះ គឺ៖

- **តើគំរោងអភិវឌ្ឍន៍/គោលនយោបាយ/ផលិតផល/សកម្មភាពមួយ នឹងមានផលប៉ះពាល់ដូចម្តេចខ្លះទៅលើបរិស្ថាន?**

អ្នកសារព័ត៌មានមិនចាំបាច់ថា ទាល់តែខ្លួនជាអ្នកឯកទេសទើបសរសេររឿងបរិស្ថានបាននោះទេ។ ប៉ុន្តែពួកគេចាំបាច់ត្រូវតែដឹងថា តើត្រូវទៅកន្លែងណាដើម្បីទទួលបានព័ត៌មានត្រឹមត្រូវយកមកអប់រំខ្លួនគេ

និងជម្រាបដល់មិត្តអ្នកអាន និងទស្សនិកជនឲ្យយល់។ ក្នុងប្រទេសជាច្រើន មានអង្គការក្រៅរដ្ឋាភិបាល ឬអង្គការអន្តរជាតិ ដែលធ្វើការលើបញ្ហាបរិស្ថាន។ ប្រភពព័ត៌មានដទៃទៀត អាចជាមហាវិទ្យាល័យក្នុងសាកលវិទ្យាល័យ អ្នកវិទ្យាសាស្ត្រ ធុរកិច្ចឯកជន និងមន្ទីរពេទ្យ។ សឹងតែថា រាល់ក្រសួងរដ្ឋាភិបាលនីមួយៗមានកិច្ចការខ្លះទាក់ទិនបរិស្ថាន និងប្រភពព័ត៌លើផ្នែកនេះដែរ។

ប្រការសំខាន់បំផុតដែលត្រូវចងចាំនោះ គឺសួរសំណួរល្អៗ រិះគិតរកគំនិតរឿងថ្មីៗ ជីកកកាយរកព័ត៌មានត្រឹមត្រូវ ជាក់លាក់ ប្រកាន់ឥរិយាបថហ្មត់ចត់ និងសមរម្យមិនលំអៀង ហើយចេះពន្យល់ឲ្យបានច្បាស់លាស់ និងប៉ិនប្រសប់សរសេររឿងទាក់ទាញអារម្មណ៍គួរឲ្យចង់អាន។

**បក្សី និងឃ្មុំ ...ឬតើអ្វីៗមានចំណងទាក់ទងគ្នាដោយរបៀបណា (The birds and the bees… or, how everything is connected)។**

គន្លឹះមួយក្នុងចំណោមគន្លឹះជាច្រើនក្នុងការសរសេរអំពីបរិស្ថាន គឺការយល់ដឹងអំពីខ្សែសង្វាក់ពីចំណុចមួយទៅចំណុចមួយទៀត។ ឧទាហរណ៍ បក្សីមួយត្រូវការដើមឈើ ដើម្បីធ្វើសំបុក។ ប៉ុន្តែដើមឈើ ក៏ត្រូវការបក្សីស៊ីផ្លែរបស់វា ហើយជុះគ្រាប់ទៅដី ដើម្បីឲ្យកូនឈើដុះបន្តពូជទៅថ្ងៃមុខទៀតដែរ។ ឃ្មុំ និងផ្កា ក៏ពឹងលើគ្នាទៅវិញទៅមកដែរ ហើយបើគិតមួយភ្លែតទៅ វាដូចជារឿងកំប៉ិកកំប៉ុកណាស់ ដែលមានតែអ្នកថៃទាំសួនទេ គួរខ្វល់ខ្វាយជាមួយរឿងនេះ។ រឿងសត្វឃ្មុំ និងផ្កានេះ ក៏បង្ហាញអំពីទំនាក់ទំនងមួយមានសារៈសំខាន់ដល់មនុស្សជាតិដែរ។ កាលណាឃ្មុំ បក្សាបក្សី និងសត្វល្អិតដទៃទៀតក្រេបស្រូបយកទឹកដមផ្កា គឺពួកវាបានក្រេបយកម្សៅលំអងពីផ្កាទាំងនោះ ទៅដាក់លើផ្កាមួយទៀត ហើយតាមរយៈនេះ វាធ្វើឲ្យរុក្ខជាតិលាស់តវេនគ្នា។ គេឲ្យឈ្មោះដំណើរការនេះថា ការបន្តពូជលំអងផ្កា (pollination) ហើយបើកុំតែបានឃ្មុំធ្វើរបៀបនេះ យើងប្រហែលជាមិនអាចដាំ មិនបានមួយភាគបីនៃបរិមាណផ្លែឈើ និងបន្លែ ដែលយើងត្រូវការសម្រាប់បរិភោគនោះផង។ តែគួរឲ្យសោកស្តាយ សត្វឃ្មុំកំពុងតែងាប់ហិនហោចអស់ជាច្រើន ដោយសារមូលហេតុដែលគេមិនទាន់រកឃើញច្បាស់លាស់នៅឡើយ។

ចូរនាំគ្នាមើលឧទាហរណ៍រឿងមួយខាងក្រោមនេះ ដែលត្រូវបានសង្ខេបចេញពីកាសែត *The Times of London*៖

***សេចក្តីវេទនារបស់សត្វឃ្មុំ***

*សត្វឃ្មុំនៅប្រទេសអង់គ្លេស កំពុងតែងាប់ជាបន្តបន្ទាប់ ហើយអ្វីដែលនឹងអាចបាត់បង់ទៅជាមួយវាដែរនោះ គឺពពួកបុប្ផា សត្វ និងប្រហែលជាមួយភាគបីរុក្ខជាតិ ដែលបំរើជាអាហារដល់យើងទាំងអស់គ្នា។ យើងអាចមានពេលមិនដល់មួយទសវត្សរ៍ទេ សម្រាប់សង្គ្រោះសត្វឃ្មុំរបស់យើង និងបញ្ចៀសភាពមហន្តរាយទៅថ្ងៃមុខ។ ដូច្នេះ ហេតុអ្វីបានជាមិនឃើញគេបាត់វិធានការអ្វីសោះលើបញ្ហានេះ?*

នៅក្នុងអត្ថបទរបស់គាត់ លោក Richard Girling បានផ្តល់ការពន្យល់គួរឲ្យជក់ចិត្តជាច្រើន ថាហេតុអ្វីបានជាយើងគួរខ្វល់ខ្វាយអំពីសត្វឃ្មុំ៖

*បើសិនជាអ្នកបន្ថែមផលចំណេញរបស់អ្នកលក់រាយទៅលើថ្លៃភោគផលពេលគេទិញវានៅចំការ តម្លៃរបស់ការបន្តពូជលំអងផ្កាដោយសារឃ្មុំក្នុងសេដ្ឋកិច្ចចក្រភពអង់គ្លេស មានប្រហែល ១ ពាន់លានផោន ក្នុងមួយឆ្នាំ ហើយ ៣៥ ភាគរយ នៃចំណីអាហាររបស់យើងពឹងអាស្រ័យដោយផ្ទាល់លើសត្វឃ្មុំទាំងនោះឯង។ ដូច្នេះ វាជាសមីការមួយយ៉ាងសាមញ្ញនោះ គឺបើគ្មានការបន្តពូជលំអងផ្កា វាក៏នឹងគ្មានរុក្ខជាតិលូតលាស់បន្តទៀតដែរ (No pollination, no crops)។ គេមិនចាំបាច់លើកទ្រឹស្តីអីច្រើន*

*ទេត្រង់នេះ ។ ភាពជាក់ស្តែង គឺមាននៅក្នុងសំបុកឃ្មុំតែម្តង ។ ក្នុងរយៈកាលដូវទឹកកកពីដូវកន្លងទៅថ្មីៗនេះ សហរដ្ឋអាមេរិកបានបាត់បង់អស់ប្រហែលជា ៧០ ភាគរយ នៃហ្វូងឃ្មុំក្នុងប្រទេសរបស់ខ្លួន ។ នៅចក្រភពអង់គ្លេសឯណោះវិញ ការបាត់បង់ពេលបច្ចុប្បន្ននេះមាន ៣០ ភាគរយក្នុងមួយឆ្នាំ ដែលកើនពី ៦ ភាគរយក្នុងមួយឆ្នាំ កាលពីឆ្នាំ ២០០៣ មក ។*

អ្នកនិពន្ធបានពន្យល់ផងដែរថា សត្វឃ្មុំមានសារៈសំខាន់ខ្លាំងណាស់ដល់ផលិតភាពនៃដំណាំមួយចំនួន ដូចជា គ្រាប់សណ្តែក ដែលកសិករអង់គ្លេសបានកំពុងចាប់ផ្តើមនាំចូលជាច្រើនពីអឺរ៉ុបភាគខាងត្បូង ។ អ្នកឯទៀតនាំគ្នាសង្ឃឹមថា សត្វឃ្មុំនឹងនាំគ្នាធ្វើអន្តោប្រវេសន៍ពីតំបន់ដទៃទៀតមកនៅប្រទេសអង់គ្លេសវិញ ។

*បើទោះជាថាមានឃ្មុំពូជថ្មីធ្វើអន្តោប្រវេសន៍មកនៅប្រទេសអង់គ្លេសក្តី ពួកវាពិតជាមិនអាចបំពេញមុខងារឲ្យបានពេញលេញដូចអំបូរឃ្មុំមុនៗបានទេ ។ ពពួកឃ្មុំធំ ក្នុងនោះ មានប្រភេទដែលកំពុងស្ថិតក្រោមការគំរាមកំហែងផងដែរនោះ ជាពូជឃ្មុំឯកទេសក្រេបជញ្ជក់រសជាតិ ដែលពឹងផ្អែកលើពពួករុក្ខជាតិពិសេសមួយក្រុមសម្រាប់ចិញ្ចឹមជីវិត និងបន្តពូជលំអងផ្កា ។ ដោយសារការវិវត្តរបស់វា ឃ្មុំខ្លះមានអណ្តាតវែងៗ ដែលអនុញ្ញាតឲ្យវាលូកចូលស្រូបយកទឹកដមពីក្នុងកទងផ្កាជ្រៅៗបាន ។ បើគ្មានឃ្មុំប្រភេទនេះទេ រុក្ខជាតិបែបនេះប្រាកដជាមិនមានលទ្ធភាពបន្តពូជរបស់វាបានឡើយ ។ ឃ្មុំចំណូលថ្មីគ្មានដំណោះស្រាយមកជាមួយទេ ពីព្រោះពួកវាមានអណ្តាតខ្លី ។ ដូច្នេះ អ្នករងគ្រោះមុនគេ ពីការដែលឃ្មុំធំៗវិនាសទាំងហ្វូងៗ គឺពពួកផ្កាមួយចំនួនដែលគេនិយមស្រឡាញ់ជាងគេនៅប្រទេសអង់គ្លេស ដូចជាផ្កា foxgloves,* irises, red clover, comfrey, toadflax, tufted vetch, ។ *ពពួកផ្លែឈើទន់ គ្រាប់ប្រេង និងគ្រាប់សណ្តែក ក៏នឹងត្រូវទទួលរងការប៉ះពាល់ពីការប្រែប្រួលនេះដែរ ។*

*នេះជាស្ថានភាពឈានបន្តិចម្តងៗឆ្ពោះទៅរកការវិនាសហិនហោចដ៏យូរអង្វែងមួយ ដែលយើងកំពុងប្រឈមមុខ ។ វាប្រៀបបាននឹងថា បើយើងដកឥដ្ឋមួយដុំចេញពីជញ្ជាំងអេកូឡូស៊ី ដុំឥដ្ឋដទៃទៀតនឹងដួលរលំមកជាមួយដែរម្តងមួយៗ រហូតទាល់តែជញ្ជាំងទាំងផ្ទាំងបាត់រូបរាងរបស់វា ។ អ្នកឯកទេសអេកូឡូស៊ី ឲ្យឈ្មោះស្ថានភាពបែបនេះថាជាស្ថានភាពខ្យល់គួចកំទេចឲ្យផុតពូជ ។ កាលណាយើងបាត់បង់ហ្វូងឃ្មុំ យើងក៏បាត់បង់រុក្ខជាតិនានាដែរ ។ យើងបាត់បង់រុក្ខជាតិកាន់តែច្រើនកាលណា យើងនឹងបាត់បង់ឃ្មុំកាន់តែច្រើនកាលនោះ ។ បន្ទាប់ពីនោះ រុក្ខជាតិ សត្វល្អិត បក្សាបក្សី និងសត្វដទៃទៀត ដែលអាស្រ័យលើសត្វឃ្មុំ និងពឹងពាក់គ្នាទៅវិញទៅមក នឹងវិនាសហិនហោចរហូតដល់ថា វាអាចនឹងបំផ្លាញដល់ខ្សែសង្វាក់ស្បៀងអាហារតែម្តង ។ និយាយយ៉ាងខ្លី មិនត្រឹមតែសត្វទាំងល្អិតតូចធំទេ គឺការរស់រានរបស់មនុស្សលោកនេះឯងតែម្តងដែលនឹងទទួលគ្រោះថ្នាក់ ។*

# ប្រព័ន្ធអេកូឡូស៊ី

ប្រព័ន្ធអេកូឡូស៊ី គឺជាចំណុចប្រសព្វមុខនៃអ្វីៗគ្រប់យ៉ាង - រាប់តាំងពីបក្សាបក្សី និងសត្វឃ្មុំ ដល់រុក្ខជាតិនានា និងមនុស្សលោក ។ ប្រព័ន្ធអេកូឡូស៊ីអាចមានទំហំតូច ឬធំ គឺវាអាចជាព្រៃមួយដុំ ឬទឹកមួយដំណក់ ។ តំបន់អាស៊ីអាគ្នេយ៍មានប្រព័ន្ធអេកូឡូស៊ីច្រើនប្រភេទ ដូចជា ជួរភ្នំ ទន្លេ ព្រៃទឹកភ្លៀង តំបន់ដីវាលទំនាប និងផ្កាថ្មក្រោមទឹកជាដើម ។ ចម្រុះភាពនៃអង្គធាតុមានជីវិតរស់នៅជាមួយគ្នាក្នុងរង្វង់ប្រព័ន្ធអេកូឡូស៊ីមួយ ត្រូវបានគេហៅថា



*ដោយសារបច្ចេកវិទ្យា គេអាចទាញយកធនធានមានតម្លៃមកប្រើប្រាស់ ប៉ុន្តែក៏ក្នុងតម្លៃមួយខ្ពស់ដែរ។*

**ជីវៈចម្រុះ** ដែលមានលក្ខណៈសំបូរបែបនៅទ្វីបអាស៊ីនេះ។ លោក James Fahn នាយកប្រតិបត្តិនៃអង្គការ Earth Journalism Network ដែលមានមូលដ្ឋាននៅប្រទេសថៃ និយាយថា៖ "ជីវៈចម្រុះមានសារៈសំខាន់ខ្លាំងណាស់សម្រាប់តំបន់នេះ។ មនុស្សជាច្រើននិយាយថា ភ្នំមួយនាប៉ែកខាងជើងប្រទេសថៃអាចមានពូជសត្វច្រើនប្រភេទ គឺច្រើនជាងនៅក្នុងប្រទេសអង់គ្លេសទាំងមូលទៅទៀត។ ប្រទេសទាំងអស់នៅក្នុងតំបន់នេះ មានកម្ពុជា និងឡាវជាអាទិ៍ ជាមហាអំណាចជង្រុកជីវៈចម្រុះនេះតែម្ដង"។

ចម្រុះភាពនៃអង្គធាតុមានជីវិតមានសារៈសំខាន់ ព្រោះថា ប្រភេទនីមួយៗសុទ្ធតែមានតួនាទីរបស់វា រាប់ទាំងវត្ថុដែលតូចបំផុត ដែលយើងមើលមិនឃើញនោះ គឺ **មីក្រូសរីរាង្គ (micro-organism)** ក្នុងដីដែលជួយបំបែកឲ្យល្អិតសារធាតុគ្មានជីវិតឲ្យក្លាយជាជីវជាតិចិញ្ចឹមដល់រុក្ខជាតិនានា។ រុក្ខជាតិត្រូវបានសត្វស្លាប និងសត្វចតុបាទតូចៗស៊ីជាចំណី ហើយសត្វស្លាបតូចៗ និងធំៗទាំងនេះ ក៏ជាចំណីរបស់សត្វធំៗតគ្នាដែរ។ នេះជាខ្សែសង្វាក់ស្បៀងអាហារ ហើយបើគេដកផ្នែកណាមួយពីខ្សែសង្វាក់នេះ វត្ថុ និងជីវិតដទៃទៀត នឹងទទួលផលប៉ះពាល់ជាមិនខាន។ ហេតុនេះហើយបានជាអ្នកបរិស្ថានកំពុងព្យាយាមនាំគ្នាការពារសង្គ្រោះពូជសត្វទាំងឡាយ ដែលកំពុងក្លាយជិតផុតពូជ។ មានហេតុផលផ្សេងទៀតក្នុងការការពារសង្គ្រោះពូជសត្វព្រៃ ក្រៅពីសារៈសំខាន់របស់ពួកវាចំពោះប្រព័ន្ធអេកូឡូស៊ីទៅទៀត។ សត្វព្រៃទាំងនោះ ក៏មានសារៈសំខាន់ផងដែរដល់វប្បធម៌ និងអត្តសញ្ញាណរបស់យើង។ នៅក្នុងជំពូក ១ យើងបានឃើញរួចមកហើយនូវរឿងមួយដែលនិយាយ អំពីសារៈសំខាន់របស់សត្វដំរីចំពោះប្រទេសឡាវ ដែលកាលពីមុនត្រូវបានគេហៅថាជាទឹកដីដំរីរាប់ពាន់ក្បាល។

កាលណាមនុស្សលោក**ជ្រៀតជ្រែកលុកលុយក្នុងប្រព័ន្ធអេកូឡូស៊ីខ្លាំងពេក** គេធ្វើឲ្យរំខានដល់តុល្យភាពជាធម្មជាតិរបស់វា ដោយពេលខ្លះបណ្ដាលឲ្យមានគ្រោះមហន្តរាយផង។ កាលណាយើងកាប់រំលំដើមឈើច្រើនពេក ព្រៃលែងមានលទ្ធភាពស្រូបយកទឹកភ្លៀងបានច្រើនទៀតហើយ។ ភូមិស្ថានជិតខាងនោះ នឹងអាចលិចលង់ក្នុងទឹកជំនន់ ឬទទួលរងគ្រោះពីការបាក់ស្រុតហូរច្រោះដី។ បើយើងកាប់បំផ្លាញព្រៃកោងកាងយកឈើធ្វើអុសដុត ឬក៏យកកន្លែងធ្វើកសិដ្ឋានចិញ្ចឹមបង្គា យើងនឹងបាត់បង់នូវជញ្ជាំងធម្មជាតិសម្រាប់ទប់ខ្យល់ព្យុះ ឬរលកទឹកសមុទ្រ។ បើយើងប្រើច្រើនពេកនូវទឹក ដែលផ្ទុកជាធម្មជាតិក្រោមដី វានឹងបណ្ដាលឲ្យអគារ និងទីក្រុងនានារបស់យើងចាប់ផ្ដើមស្រុតបន្តិចម្ដងៗ។

(ហេតុការណ៍បែបនេះមានឈ្មោះថា **ការស្រុតចុះ (subsidence)** ហើយកំពុងកើតឡើងនៅក្រុងបាងកក ហាណូយ និងហូជីមិញ។ ដោយថាហេតុការស្រុតចុះ បណ្តាលឲ្យមានទឹកជំនន់ច្រើនថែមទៀត និងបន្ថយនូវលទ្ធភាពការពារទល់នឹងការឡើងជន់កម្រិតទឹកសមុទ្រទៀតផង)។

បើកសិករមានសត្វពាហនៈច្រើនក្បាលពេក ពួកវាអាចនឹងស៊ីស្មៅច្រើនពេក និងរុក្ខជាតិទាំងឡាយក្នុងតំបន់នោះ។ កាលណាវល្លិស្មៅរុក្ខជាតិនានាវិនាសបាត់ទៅ ស្រទាប់ដីខាងលើដែលសំបូរជីវជាតិនឹងប៉ើងទៅតាមខ្យល់ ឬក៏ហូរច្រោះតាមទឹកភ្លៀងអស់ ដូច្នេះ គ្មានអ្វីអាចដុះលូតលាស់បានទៀតទេ ហើយសត្វពាហនៈនឹងអត់អ្វីស៊ីជាមិនខាន។ ការដែលសត្វពាហនៈស៊ីស្មៅច្រើនពេក ក៏ជាកត្តាមួយនាំឲ្យមាន**ភាពរហោស្ថាន (desertification)** ដែលជាដំណើរការមួយបង្កការគំរាមកំហែងដល់ប្រហែលមួយភាគបីនៃផ្ទៃលើរបស់ផែនដី ក្នុងនោះ មានផ្នែកមួយក្នុងប្រទេសមីយ៉ាន់ម៉ាផង។ កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិនិយាយថា ភាពរហោស្ថាននេះ "កំពុងតែប្លន់បកយកសាច់របស់ភពផែនដីយើងនេះតែម្តង"។ ធម្មជាតិខ្លួនឯងក៏អាចរំខានដល់តុល្យភាពនៃប្រព័ន្ធអេកូឡូស៊ីដែរ។ **ភាពរាំងស្ងួត** រួមបំណែកបណ្តាលឲ្យមាន**ការសឹករិចរិលដី** និងភាពរហោស្ថាន។ ព្យុះ និងគ្រោះមហន្តរាយអាចបំផ្លិចបំផ្លាញដល់ស្ថានទស្សនីយភាពដី បង្កការប្រែប្រួលដល់ចរន្តទឹកទន្លេ និងបំផ្លាញជីវិតមនុស្សរាប់ពាន់នាក់ទៀតផង។ ប៉ុន្តែធម្មជាតិក៏មានភាពធន់ស្វិតស្វាញ (resilient) របស់វាដែរ ហើយមានសមត្ថភាពអាចស្តារខ្លួនឡើងវិញ និងសម្របខ្លួនវាទៅតាមព្រឹត្តិការណ៍ប្រែប្រួលធម្មជាតិទាំងនោះ ដោយបង្កើតបានតុល្យភាពធម្មជាតិថ្មីមួយទៀត ពេលខ្លះនាំមកនូវប្រយោជន៍ដែលមិនបានគិតទុកជាមុនទៀតផង។ ឧទាហរណ៍ ទឹកជំនន់ អាចបំផ្លាញផ្ទះសម្បែង ដំណាំ និងភូមិស្ថានទាំងមូលក៏មានដែរ។ ប៉ុន្តែទឹកជំនន់ទាំងនោះបាននាំមកដីភក់ផ្លុកដោយ ជីវជាតិដែលជួយឲ្យដំណាំផ្សេងទៀតលូតលាស់បានល្អ។ មនុស្សអាចស្លាប់ ហើយផ្ទះសំបែងរបស់ពួកគេអាចត្រូវបាត់បង់ពេលណាមានការផ្ទុះភ្នំភ្លើង ប៉ុន្តែកំអែរផេះរបស់វាអាចធ្វើឲ្យការដាំដុះទទួលផលបានល្អជាងមុន។ ព្យុះសូណាមិនៅភាគខាងត្បូងរបស់ថៃបណ្តាលឲ្យមានការបំផ្លិចបំផ្លាញ និងបាត់បង់ជីវិតសម្បើមណាស់ តែវាបានលាងចេញបាត់ទៅនូវឆ្នេរក្រខ្វក់ដែលគេមានពីមុន ហើយនាំយកខ្សាច់ស្អាតមកដាក់ជំនួសពីលើវិញ។ ព្យុះរលកទឹកសមុទ្រក្នុងតំបន់ដីសណ្ត Irrawaddy បាននាំមកនូវកករដីសំបូរជីជាតិ ធ្វើឲ្យទិន្នផលស្រូវឡើងខ្ពស់ជាងមុន។

សរុបមក វាជាការងាររបស់អ្នកសារព័ត៌មានបរិស្ថានក្នុងការស្វែងរកមើល និងពន្យល់ទំនាក់ទំនងទាំងអស់នេះ។

## សុខភាព និងបរិស្ថាន

បញ្ហាបរិស្ថាន និងសុខភាពសាធារណៈមានទំនាក់ទំនងជាមួយគ្នាជិតស្និទ្ធណាស់។ បើសិនជារោងចក្រ កសិដ្ឋាន ឬក៏អគារនានានាំគ្នាបញ្ចេញការបំពុល **សារជាតុក្រខ្វក់ (contaminants)** នឹងពូនគរនៅក្នុងអាហារ និងប្រព័ន្ធសរសៃឈាមរបស់យើង ដែលអាចនាំឲ្យមានការពុលក្អួត កើតជំងឺមហារីក និងបញ្ហាសុខភាពដទៃទៀត។ សម្រាប់អេឡិចត្រូនិកពីប្រទេសបស្ចិមលោក ក្នុងនោះ មានកុំព្យូទ័រ និងកាមេរ៉ាផង គេច្រើនតែយកវាមកចោលនៅបណ្តាប្រទេសអាស៊ី ដើម្បី "កែច្នៃឡើងវិញ"។ ប៉ុន្តែមនុស្សដែលជាអ្នកដោះបំបែកឧបករណ៍ចាស់ៗទាំងនោះ (មានក្មេងៗ និងមនុស្សដែលមិនមានពាក់ប្រដាប់ការពារអ្វីសោះ) បានប៉ះពាល់ផ្ទាល់ជាមួយសារជាតុបង្កជំងឺមហារីក សារជាតុគីមីពុល និងសារជាតុ

ឌីអុកស៊ីន។ ឌីអុកស៊ីន ជាសារធាតុគីមីប្រកបដោយគ្រោះថ្នាក់ដែលអាចបង្កជំងឺមហារីក និងការខូចទ្រង់ទ្រាយទារក។ សារធាតុឌីអុកស៊ីននេះកើតចេញពីការដុតវត្ថុធ្វើពីប្លាស្ទិក។ កម្មករដែលធ្វើការក្នុងឧស្សាហកម្មនេះ តែងមានជំងឺផ្លូវដង្ហើម ជំងឺសើស្បែក និងអាចប្រឈមនឹងជំងឺយូរអង្វែងទៅថ្ងៃមុខផង។

ការបំពុលខ្យល់ក្នុងក្រុងឈៀងម៉ៃ ជាឧទាហរណ៍មួយទៀតនៃបញ្ហាសុខភាពបរិស្ថាន។ ការដុតវាលព្រៃ និងសំរាម បង្កើតបានជាបុណ្ណភាគល្អិតៗក្នុងបរិយាកាសរៀងរាល់រដូវក្តៅ។ បុណ្ណភាគទាំងនោះបានមកកកកុញក្នុងអាងធម្មជាតិមួយជុំវិញក្រុងឈៀងម៉ៃ ហើយប្រែក្លាយទៅជាភាពស្រអាប់ក្នុងតំបន់នោះ។ ជារៀងរាល់ឆ្នាំ វេជ្ជបណ្ឌិតបានឲ្យដឹងថាមានករណីជំងឺផ្លូវដង្ហើមជាច្រើនករណី ក្នុងនោះមានការក្អក និងការពិបាកដកដង្ហើម។ អ្នកស្រាវជ្រាវរបស់សាកលវិទ្យាល័យឈៀងម៉ៃ បានឲ្យដឹងថាហានិភ័យក្នុងការកើតជំងឺមហារីកសួតនៅភាគខាងជើងប្រទេសថៃ មានបួនដងធំជាងនៅក្នុងផ្នែកឯទៀតរបស់ប្រទេសទៅទៀត។

នៅសហរដ្ឋអាមេរិក ការសិក្សាស្រាវជ្រាវមួយបានលាតត្រដាងឲ្យដឹងថា សារធាតុគីមីមួយចំនួនក្នុងកញ្ចប់ម្ហូបអាហារ ថ្នាំសម្លាប់សត្វល្អិត សម្លៀក-បំពាក់ និងកម្រាលព្រំ អាចពន្យារដល់លទ្ធភាពមានគភ៌របស់ភរិយាដែលចង់បានកូន។ បើទោះជាសារធាតុគីមីទាំងនោះ ត្រូវបានគេបិទលែងឲ្យយកមកប្រើតទៅទៀតក៏ដោយ វានៅតែបន្តមានអត្ថិភាពក្នុងបរិស្ថាន និងខ្លួនប្រាណមនុស្សច្រើនទសវត្សរ៍ទៅមុខទៀត។

ជំងឺមួយចំនួនកើតមានមួយផ្នែក ដោយសារតែលក្ខខណ្ឌក្នុងការរស់នៅរបស់យើង។ ក្នុងនោះមានជំងឺរបេងអាចចម្លងទៅដល់ហ្វូងមនុស្សដទៃក្នុងកន្លែងដែលមិនមានប្រព័ន្ធខ្យល់ចេញចូលគ្រប់គ្រាន់។ ជំងឺគ្រុនចាញ់ ច្រើនមាននៅក្នុងព្រៃ និងតាមតំបន់ព្រំដែន។ ជនក្រីក្រ គឺជាអ្នកងាយរងគ្រោះជាងគេដោយសារពួកគេខ្វះលទ្ធភាពទទួលបានឲ្យទៀងទាត់នូវទឹកស្អាត និងអនាម័យ។ ទឹកជំនន់អាចនាំឲ្យមានជំងឺរាក និងរាកមួលនៅតាមកន្លែងដែលខ្វះការអភិវឌ្ឍ។ ជនក្រីក្រច្រើនតែប្រឈមជាមួយនឹងសារធាតុគីមីក្នុងវាលស្រែ និងរោងចក្រ ហើយភាគច្រើនមិនសូវមានប្រដាប់ប្រដាពាក់ការពារខ្លួនទេ។

ភាគច្រើននៃជំងឺធ្ងន់ធ្ងររបស់យើង គឺកើតមកពីការនៅប្រកៀកគ្នារវាងមនុស្ស និងសត្វ។ មេរោគហ៊ីវដែលនាំឲ្យកើតជំងឺអេដស៍ ត្រូវបានគេជឿថាមានប្រភពចេញមកពីពពួកស្វាឌី chimpanzee ដែលមនុស្សនាំគ្នាប្រមាញ់កាលពីជំនាន់ទសវត្សរ៍ឆ្នាំ ១៩៣០។ ជំងឺគ្រុនចាញ់ និងគ្រុនឈាម កើតមកពីពពួកប៉ារ៉ាស៊ីតនៅក្នុងមូស។ ជំងឺគ្រុនបក្សីអាចឆ្លងទៅមនុស្សបានតាមរយៈការពាល់ឈាម ទឹកមាត់ ឬក៏លាមកមាន់ដែលបានឆ្លងជំងឺនេះរួចមកហើយ។ **ជំងឺសារ - SARS/severe acute respiratory syndrome -** ត្រូវបានគេជឿថាវាឆ្លងទៅមនុស្សពីសត្វសំពោចនៅប្រទេសចិន។ ភាគច្រើនការរាតត្បាតជំងឺផ្តាសាយរបស់យើង គឺបណ្តាលមកពីវីរុសដែលមានប្រភពក្នុងសត្វជ្រូក។

## គ្មានដែនកំណត់

បញ្ហាបរិស្ថានគ្មានស្គាល់ព្រំដែនកំណត់ទេ។ ប្រសិនបើប្រទេសនៅខ្សែទឹកខាងលើទាញយកទឹកពីទន្លេច្រើនពេកទៅស្រោចស្រពការធ្វើកសិកម្ម និងធ្វើវារីអគ្គិសនី ទីក្រុងនានានៅខ្សែទឹកខាងក្រោមនឹងខ្វះទឹកប្រើប្រាស់ជាមិនខាន។ ការសង់ទំនប់វារីអគ្គិសនីច្រើនកន្លែងរបស់ចិនក្នុងផ្នែកខាងលើទន្លេមេគង្គ ជាកង្វល់មួយសម្រាប់សហគមន៍ជាច្រើននៅប្រទេសថៃ ឡាវ វៀតណាម និងកម្ពុជា ពីព្រោះទំនប់ទាំងនោះធ្វើឲ្យមានការប្រែប្រួលនូវរបបទឹកហូរក្នុងទន្លេ។ កម្រិតទឹកទន្លេទាប និងការកើនកម្រិតទឹក

សមុទ្រ នាំឲ្យមានការហូរចូលទឹកប្រៃទៅក្នុងតំបន់មេគង្គដែលតា ដីសណ្តមេគង្គ។ ការបំពុលខ្យល់បរិយាកាសនៅអាស៊ី អាចរសាត់ទៅដល់អាមេរិកខាងជើងឯណោះ ហើយការបំពុលខ្យល់នៅអាមេរិកខាងជើង ក៏រសាត់ទៅដល់ទ្វីបអឺរ៉ុបដែរ។ **ការបំពុលដោយសារធាតុកាបោន** ក្នុងប្រទេសឧស្សាហកម្មជឿនលឿន អាចជាការរួមចំណែកដល់ការកើតមានគ្រោះមហន្តរាយនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។

ជាមួយគ្នានេះដែរ សត្វព្រៃគ្មានស្គាល់ព្រំដែននយោបាយអ្វីទេ។ បក្សី និងមច្ឆា ធ្វើដំណើររាប់គីឡូម៉ែត្រ ដើម្បីទៅរកកន្លែងវាធ្លាប់បន្តពូជ ដូច្នេះការនេសាទត្រីច្រើនហួសហេតុពេក ឬក៏ការសាងសង់ទំនប់វារីអគ្គិសនីច្រើនក្នុងតំបន់មួយ អាចធ្វើធ្លាក់ចុះនូវការផ្គត់ផ្គង់ត្រី ដែលជាប្រភពប្រូតេអ៊ីននៅតំបន់មួយទៀត។

## ការប្រែប្រួលអាកាសធាតុ

គេអាចចាត់ទុកថា ការប្រែប្រួលអាកាសធាតុជាបញ្ហាមួយក្នុងចំណោមបញ្ហាសំខាន់ៗបំផុតក្នុងសតវត្សរ៍ទី ២១ យើងនេះ ហើយវាក៏ជាប្រភពនៃរឿងធំៗជាច្រើនផងដែរក្នុងសតវត្សរ៍នេះ។ ដូចគ្នានឹងបញ្ហាបរិស្ថានដទៃទៀតដែរ វាគ្មានព្រំដែនទេ ហើយពាក់ព័ន្ធសឹងថាគ្រប់ផ្នែកទាំងអស់នៃសកម្មភាពមនុស្ស។ ភាពកកកុញសារធាតុកាបោនឌីអុកស៊ីដក្នុងលំហអាកាស និងការកើនកំដៅសីតុណ្ហភាពលើផ្ទៃផែនដី នឹងបណ្តាលឲ្យមានការប្រែប្រួលក្រឡាប់ចាក់អំពីរបៀប និងកន្លែងដែលយើងរស់នៅ។

អ្នកវិទ្យាសាស្ត្រសឹងតែគ្រប់គ្នាបានឯកភាពថា **ភពផែនដីរបស់យើងឡើងកំដៅឧណ្ហជាមុន**។ សីតុណ្ហភាពជាមធ្យមបានកើនជិតមួយអង្សារសេក្នុងមួយសតវត្សរ៍កន្លងមកនេះ។ យើងអាចដឹងបានដោយសារយើងបានកត់ត្រាចំណាំទុកសីតុណ្ហភាពនៅរាប់ពាន់កន្លែងអស់ជាច្រើនឆ្នាំមកហើយ។ នៅដូចជាតំបន់អាក់ទិកជាដើម សីតុណ្ហភាពក្តៅឧណ្ហលឿនជាងកន្លែងផ្សេងទៀត ដែលធ្វើឲ្យផ្ទាំងទឹកកកនៅទីនោះចាប់ផ្តើមរលាយ។ កន្លែងផ្សេងមានសីតុណ្ហភាពត្រជាក់ជាងមុន។ ការឡើងចុះ និងភាពខុសគ្នាបែបនេះ ត្រូវបានគេរំពឹងទុកជាមុន ហើយវាក៏ជាហេតុផលមួយ ដែលអ្នកវិទ្យាសាស្ត្រនិយមប្រើពាក្យការប្រែប្រួលអាកាសធាតុជាងការឡើងកំដៅផែនដី។

ក្នុងពេលជាមួយគ្នានេះ មានការពូនគរសារធាតុកាបោនឌីអុកស៊ីដ និងឧស្ម័នច្រើនប្រភេទទៀតក្នុងលំហបរិយាកាសដែរ។ ម៉ូលេគុលទាំងនេះ (ពេលខ្លះគេហៅវាថា ពពួកឧស្ម័នខ្ទប់កំដៅ) ជារនាំងខ្ទប់កំដៅព្រះអាទិត្យ។ ប្រការនេះត្រឡប់មកវិញ វាទៅបង្កើនកំដៅក្នុងបរិស្ថាន គឺដូចគ្នាទៅនឹងអគារកញ្ចក់ខ្ទប់កំដៅ ដើម្បីជួយឲ្យរុក្ខជាតិដំណាំដុះបាននៅកន្លែងដែលមានអាកាសធាតុត្រជាក់ (គេឲ្យឈ្មោះវាថា ផលអនុភាពផ្ទះកញ្ចក់)។

សារធាតុកាបោនឌីអុកស៊ីដចេញមកពីច្រើនប្រភព រួមមានការបំពុលដោយរថយន្ត និងរោងចក្រដុតធ្យូងថ្មជាថាមពល។ ភាគច្រើនពីនេះកើតមកពីការកាប់បំផ្លាញព្រៃឈើ និងការដុតព្រៃនៅតាមប្រទេសកំពុងអភិវឌ្ឍ។ កាលណាដើមឈើងាប់ហើយត្រូវបានគេដុត វាបញ្ចេញនូវសារធាតុកាបោនមកក្រៅ។ បើកាលណាដើមឈើត្រូវបានបាត់បង់ទៅវាលែងអាចបំពេញមុខងារស្រូបស្តុកទុកសារធាតុកាបោនឌីអុកស៊ីដបានទៀតហើយ ដូច្នេះកាបោននឹងបន្តកើនកកកុញនៅក្នុងបរិយាកាស។ សារធាតុឧស្ម័នផ្ទះកញ្ចក់ដទៃទៀតមានមេតាន (ដែលបញ្ចេញដោយវល្លិស្មៅបន្លែផុយរលួយ និងលាមកសត្វ) និងនីត្រូអុកស៊ីដ (ពីការបំពុលដោយរោងចក្រ និងដោយយានយន្ត)។

អ្នកវិទ្យាសាស្ត្រភាគច្រើនយល់ស្របគ្នាថាមានភស្តុតាងគ្រប់គ្រាន់នឹងបញ្ជាក់ថា សកម្មភាពមនុស្សជាដើមចមនៃការពួនគរកាបោនឌីអុកស៊ីដក្នុងបរិយាកាស ដែលនាំឲ្យឡើងកំដៅផែនដី។ ភាពកកកុញសារជាតុកាបោនឌីអុកស៊ីកបានកើនប្រហែល ៣៥ ភាគរយ ចាប់តាំងពីសម័យបដិវត្តន៍ឧស្សាហកម្មមក និងនៅពេលចាប់កំណើតឧស្សាហកម្មបញ្ចេញផ្សែងច្រើន។ បើទោះជាថាវាមានតិចជាងមួយភាគរយនៃបរិយាកាសទាំងមូលក៏ដោយ សារជាតុកាបោនឌីអុកស៊ីដអាចនៅមានអត្ថិភាព រហូតដល់មួយសតវត្សរ៍ឯណោះ។ នេះមានន័យថា ការបំពុលដោយរថយន្ត និងទោចក្រយានយន្តរបស់យើងបច្ចុប្បន្ន នឹងបន្តមានអានុភាពលើអាកាសធាតុរបស់យើងច្រើនជំនាន់ទៅមុខទៀត។

ដោយប្រើគំរូគណនាតាមកុំព្យូទ័រ អ្នកវិទ្យាសាស្ត្របានទស្សន៍ទាយថា បរិមាណកាបោនឌីអុកស៊ីដក្នុងបរិយាកាស នឹងកើនទ្វេដងនៅពាក់កណ្តាលសតវត្សរ៍យើងនេះ។ បើវាកើតឡើងដូច្នោះមែន សីតុណ្ហភាពសកលអាចកើនពីមួយ ១.៥ ទៅ ៥ អង្សារសេ ឬច្រើនជាងផងក៏មិនដឹង។ ពួកវិទ្យាសាស្ត្របារម្ភថា បើសីតុណ្ហភាពកើនជាង ២ អង្សារ បរិស្ថាននឹងរងការប្រែប្រួលដោយគ្មានអ្វីទៅទប់វាបានទេ។ ការព្យាករណ៍ទាំងនេះមាននៅក្នុងរបាយការណ៍ដែលត្រូវបានរៀបរៀងឡើងដោយគណៈកម្មការអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ (International Panel on Climate Change/IPCC) ជាអង្គភាពមួយរបស់អង្គការសហប្រជាជាតិ ដែលបង្ហាញទៀងទាត់ការវាយតម្លៃអាកាសធាតុផ្អែកលើការសិក្សានានាពីទូទាំងពិភពលោក។ លោកអ្នកអាចមើលទិន្នន័យទាំងនេះនៅលើវ៉ិបសាយ www.ipcc.ch។

ការប្រែប្រួលអាកាសធាតុអាចបណ្តាលឲ្យមានផលប៉ះទង្គិចជាច្រើន ដែលមានសភាពខ្ទេចខ្ទាំអន្តរាយ ដូចជា៖

- ការលោយកំរាលទឹកកក និងផ្ទាំងទឹកកក ដោយធ្វើឲ្យកម្រិតទឹកសមុទ្រឡើងខ្ពស់ជាងមុន
- ធ្វើឲ្យភាពរាំងស្ងួត និងរដូវក្តៅ កាន់តែមានរយៈពេលវែងជាងមុន
- ភ្លៀងមានសន្ទឹកខ្លាំងជាងមុន ហើយទឹកជំនន់កាន់តែសំបូរជាងមុនដែរ
- ខ្យល់ព្យុះ និងគ្រោះធម្មជាតិមានសន្ទឹកកាន់តែខ្លាំង
- បំផ្លិចបំផ្លាញប្រព័ន្ធអេកូសឡូស៊ី និងប្រភេទសត្វ និងរុក្ខជាតិ
- ជំងឺច្រើនជាងមុន

នៅអាស៊ីអាគ្នេយ៍ តំបន់វាលទំនាបនានា ដូចជានៅដីសណ្តមេគង្គជាដើម អាចនឹងវិនាសបាត់ទាំងស្រុងតែម្តង បើសិនជាទឹកសមុទ្រឡើងកំពស់មួយម៉ែត្រទៀត។ កម្រិតទឹកសមុទ្រឡើង ដោយសារទឹករីកមាឌពេលណាវាឡើងកំដៅ ហើយដោយសារផ្ទាំងទឹកកករលាយបន្ថែមនូវម៉ាស់ទឹកថែមទៀតក្នុងសមុទ្រ។ ការព្យាករណ៍របស់អ្នកវិទ្យាសាស្ត្រមិនដូចគ្នាទាំងអស់ទេ ហើយវាអាចថាស៊ីពេលច្រើនឆ្នាំទៀតមុននឹងហេតុការណ៍ទាំងអស់នេះកើតឡើង។ តែកាលណាវាកើតមែននោះ ទីក្រុងតួយ៉ាងដូចជាទីក្រុងរ៉ង់ហ្គូននៃប្រទេសមីយ៉ាន់ម៉ា និងទីក្រុងហៃហ្វុង នៃប្រទេសវៀតណាមជាដើម ពិតជាអាចត្រូវលិចលង់។ ប្រជាជនក្នុងតំបន់នេះកំពុងប្រយុទ្ធជាមួយនឹងការប្រែប្រួលអាកាសធាតុរួចទៅហើយ បើទោះជាពួកគេមិនដឹងខ្លួនក៏ដោយ។ ប្រជាជនរស់នៅតំបន់ដីសណ្តមេគង្គ ប្រទេសវៀតណាមបាននាំគ្នាសង់ជញ្ជាំងខ្ពស់ដើម្បីទប់ទឹកសមុទ្រ។ រីឯនៅប្រទេសថៃ និងប្រទេសមីយ៉ាន់ម៉ា ប្រជាជនរស់នៅតាមតំបន់ឆ្នេរនាំគ្នាដាំព្រៃកោងកាង ដើម្បីទប់រលកសមុទ្រ។ បើទឹកសមុទ្រចេះតែឡើង មនុស្សរាប់លាននាក់ នឹងត្រូវបង្ខំចិត្តផ្លាស់ទីលំនៅដីស្រែមានដីជាតិ

និងត្រូវវិនាស ហើយការងារជាច្រើននៅក្នុងប្រទេសក៏នឹងត្រូវបាត់បង់ដែរ។

អ្នកវិទ្យាសាស្ត្រជាច្រើនបានសង្កេតឃើញវាមានការកើនឡើងនូវគ្រោះធម្មជាតិ ក្នុងនោះ មានព្យុះស៊ីក្លូន និងព្យុះទីហ្វុងខ្លាំងៗជាងមុនផង។ ពួកគេនិយាយថា ព្យុះនានាមានសន្ទឹកកាន់តែខ្លាំង ដោយសារវាទទួលបានថាមពលមកពីសមុទ្រ កាលណាទឹកសមុទ្រកាន់តែឡើងក្ដៅ ព្យុះក៏កាន់តែមានកំលាំងខ្លាំងដែរ។ ប៉ុន្តែមិនទាន់មានភស្តុតាងគ្រប់គ្រាន់ទេ សម្រាប់ភ្ជាប់ករណីព្យុះណាមួយទៅនឹងការប្រែប្រួលអាសធាតុនោះទេ។

នៅលើពិភពលោក បណ្ដារដ្ឋាភិបាលកំពុងពិភាក្សារិះរកមធ្យោបាយកាត់បន្ថយឲ្យបានច្រើននូវការបញ្ចេញឧស្ម័នកាបោន ក្នុងនោះ មានវិធានការប្រើប្រាស់ធនធានកកើតឡើងវិញសម្រាប់ធ្វើថាមពល និងការអភិវឌ្ឍបច្ចេកវិទ្យា ដែលកាត់បន្ថយការបំពុលបរិយាកាស។ មនុស្សម្នាក៏កំពុងពិភាក្សាគ្នាដែរ អំពីការផ្លាស់ប្ដូរទម្លាប់រស់នៅ ដោយរកវិធីប្រើប្រាស់ទទួលទានតិចជាងមុន តែអភិរក្សឲ្យបានច្រើន។ អង្គការអន្តរជាតិ និងរដ្ឋាភិបាលមូលដ្ឋានជាច្រើនកំពុងស្វែងរកវិធីជួយដល់ប្រជាជនឲ្យបន្សុំនឹងការប្រែប្រួលអាកាសធាតុ និងរកវិធីជួយពួកគេបេះសម្រាលផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដែរ។ ដំណោះស្រាយមួយ គឺអំពាវនាវឲ្យប្រទេសអ្នកមានបង់កម្រៃឲ្យប្រទេសក្រីក្រអភិរក្សព្រៃឈើរបស់ខ្លួន។ យន្តការមួយទៀតអនុញ្ញាតឲ្យក្រុមហ៊ុនក្នុងប្រទេសមួយចំនួន ដែលបញ្ចេញជាតិពុលលើសកម្រិតរបស់ខ្លួន ទិញ**ឥណទានកាបោន**ពីក្រុមហ៊ុនដទៃទៀត ដែលបញ្ចេញផ្សែងកាបោនទាបជាងកម្រិតដែលគេអនុញ្ញាត។ យន្តការនេះជាផ្នែកមួយនៃទីផ្សារលក់ផ្សែងកាបោន ដែលនៅទីនោះ ឥណទានកាបោនត្រូវបានគេទិញលក់ដូចមុខទំនិញដទៃទៀតដែរ។ បើផ្គុំវាចូលគ្នា ដំណោះស្រាយនានាអាចបង្ហាញឲ្យយើងឃើញនូវកម្រិតខូចខាតផ្នែកបរិស្ថានបាន។

# ភាពប្រឈមក្នុងការយកព័ត៌មានអំពីបរិស្ថាន

ការយកព័ត៌មានបរិស្ថាន គឺជាកិច្ចការមួយស្មុគស្មាញ ហើយភាពប្រឈមធំជាងគេសម្រាប់អ្នកយកព័ត៌មានផ្នែកនេះ គឺភាពស្មុគស្មាញនៃបញ្ហាបរិស្ថាននេះតែម្ដង។ រឿងអំពីបរិស្ថានតែងតែពាក់ព័ន្ធការពន្យល់ដំណើរការវិទ្យាសាស្ត្រ ឬបច្ចេកទេស ដូចជា ជីវវិទ្យា គីមីវិទ្យា ឬរូបវិទ្យា។ វាមានកត្តាច្រើនណាស់ដែលដើរតួក្នុងរឿង។ ឧទាហរណ៍ ពីដើមឡើយ គេបាត់ទុកថាការសង់ទំនប់វារីអគ្គិសនីជាវិធីមួយក្នុងការផ្ដល់ថាមពលស្អាត និងថាមពលកកើតឡើងវិញ។ ប៉ុន្តែទំនប់វារីអគ្គិសនីធ្វើឲ្យប្រជាជនផ្លាស់ប្ដូរទីលំនៅ ធ្វើឲ្យបាត់បង់ជំរកសត្វព្រៃ និងរាំងដល់ការធ្វើអន្តោប្រវេសន៍របស់ពួកមច្ឆា ហើយតាមរយៈការធ្វើឲ្យរុក្ខជាតិនានាលិចក្នុងទឹកផុយរលួយ វាក៏បញ្ចេញមេតាន ដែលជាឧស្ម័នមួយប្រភេទនាំឲ្យកើនកំដៅផែនដីដែរ។ ទាំងអស់នេះសុទ្ធតែជាបញ្ហាស្មុគស្មាញ មានជ្រុងវិជ្ជមាន និងអវិជ្ជមានរបស់វា ហើយពិបាកសរសេរឲ្យទាន់ឱសានវាទប្រចាំថ្ងៃណាស់។ លោក EJN's Fanh អតីតនិពន្ធនាយកផ្នែកបរិស្ថាននៃកាសែត The Nation របស់ថៃ និយាយថា៖ "វាស៊ីពេលវេលា និងលុយកាក់សម្រាប់ធ្វើសោហ៊ុយសម្រាប់ធ្វើដំណើរ និងស្រាវជ្រាវរឿងបែបនេះ។ បញ្ហាបរិស្ថានមានវិសាលភាពធំធេង និងស្មុគស្មាញ និងពិបាកយល់ណាស់។ ចូរជជែកជាមួយមនុស្សច្រើនតាមតែអ្នកអាចធ្វើទៅបាន។ ប្រមូលព័ត៌មានពីគ្រប់ជ្រុងជ្រោយទាំងអស់។ វាមិនមែនជារឿងសាមញ្ញប៉ុន្មានទេ"។

បន្ថែមលើភាពស្មុគស្មាញនេះ អ្នកវិទ្យាសាស្ត្រ វេជ្ជបណ្ឌិត អ្នកឯកទេសបរិស្ថានប្រើភាសាមួយដោយឡែករបស់ខ្លួន។ អ្នកសារព័ត៌មានអាចចាប់

ផ្ដើមតាក់តែងកំរងវាក្យសព្ទជាមូលដ្ឋានមួយរបស់ខ្លួន ចេញពីពាក្យ ដូចជា ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះជាដើម។ អ្នកអាចរៀនអំពីឃ្លាវាក្យសព្ទទាំងនេះ តាមរយៈវចនានុក្រមបរិស្ថាន (វចនានុក្រម Environment Words, A Dictionary in Plain English by Images Asia ជាវចនានុក្រមល្អមួយសម្រាប់ផ្នែកនេះ) ឬតាមរយៈការពិគ្រោះជាមួយវិបសាយ និងសន្ទានុក្រមមួយចំនួន។ អ្នកក៏គួរមានប្រភពល្អៗមួយចំនួន ដែលអាចចង់ជួយពន្យល់ដល់អ្នកដែរ ពេលណាដែលអ្នកត្រូវការ។ ចូរចាំថា ជៀសវាងការប្រើពាក្យពេចន៍បច្ចេកទេសក្នុងសាច់រឿង។ បើសិនជាអ្នកចាំបាច់ត្រូវតែប្រើវា ចូរពន្យល់ពាក្យទាំងនោះផង។ តែយកល្អប្រើប្រាស់ការប្រៀបធៀប និងការពន្យល់សាមញ្ញវាប្រសើជាង។

បញ្ហាបរិស្ថានជាដំណើរការ មិនមែនព្រឹត្តិការណ៍ទេ។ រឿងបរិស្ថានខ្លះ វាងាយនឹងមើលឃើញណាស់ ដូចជា ការបំពុលខ្យល់ ឬគ្រោះធម្មជាតិជាដើម។ ប៉ុន្តែដំណើរការបរិស្ថានភាគច្រើនកើតឡើងក្នុងរយៈពេលយូរអង្វែង មិនមែនក្នុងពេលតែមួយយប់នោះទេ។ វាសុទ្ធតែជាដំណើរការដែលពិបាកនឹងសង្កេត ដូច្នេះហើយបានជាវាពិបាកធ្វើសេចក្ដីរាយការណ៍ណាស់។ ឧទាហរណ៍ល្បីល្បាញមួយ គឺការពាល់សារជាតុបារតនៅទីក្រុងមីណាម៉ាតា ប្រទេសជប៉ុន នាទសវត្សឆ្នាំ ១៩៣០។ ប្រជាជនរស់នៅតំបន់នោះ កើតអាការៈមានបញ្ហាជាមួយសាច់ដុំត្រចៀក និងភ្នែករបស់ពួកគេ។ មនុស្សខ្លះទៅជាខ្វិន ខ្លះទៀតស្លាប់ ហើយមនុស្សរាប់ពាន់នាក់ពុលបារត។ ក្រោយមកអ្នកវិទ្យាសាស្ត្ររកឃើញថា ប្រជាជនពុលពីការទទួលទានត្រី និងគ្រុំ។ ក្នុងរបកគំហើញនោះ ត្រីមានផ្ទុកសារជាតុបារតដែលក្រុមហ៊ុនគីមីមួយបានចាក់ចោលទៅក្នុងទឹកតាំងពីឆ្នាំ ១៩៣២ ម្ល៉េះ។ វាស៊ីពេលយូរគួរសមដែរ ទំរាំនឹងសារជាតុបារតកកើតកុំគ្នាក្នុងខ្លួនមនុស្ស ហើយបង្កជារោគសញ្ញាឡើង។ ក្មេងខ្លះចាប់កំណើតមកមានជំងឺនេះមកជាមួយតែម្ដង។

ឧទាហរណ៍ផ្សេងទៀតមាន **កញ្ចុំអ្នកកើតជំងឺមហារីកដុំសាច់ (cancer clusters)** ដែលន័យនេះសំដៅលើក្រុមមនុស្សនៅតំបន់ភូមិសាស្ត្រណាមួយ ដែលមានកើតជំងឺដុំសាច់មហារីកប្រហាក់ប្រហែលគ្នា ដោយសារសារជាតុគីមី សារជាតុបំពុល ឬវិទ្យុសកម្មក្នុងបរិស្ថាន។ អ្នកសារព័ត៌មានចាំបាច់ត្រូវតែយល់អំពី**ខ្សែសង្វាក់ព្រឹត្តិការណ៍** និងទំនាក់ទំនងរវាងមនុស្ស និងបរិស្ថាន។ ការវិវត្ត និងដំណើរការឧស្សាហកម្ម តែងបណ្ដាលឲ្យមាននូវផលវិបាកធ្ងន់ធ្ងរ ដែលគេអាចមើលដឹងក្នុងរយៈពេលមួយយូរប៉ុណ្ណោះ។

ពេលខ្លះ ក៏វា**មិនប្រាកដប្រជា**ដែរ។ វាតែងតែពិបាកក្នុងការរកឲ្យមុខតំណាងរវាង**មូលហេតុ** និង



*របៀបរស់នៅរបស់យើងដែលសំបូរដោយសម្រាម អាចគំរាមដល់ការរស់នៅរបស់មនុស្សជំនាន់ក្រោយទៀត។*

**សមិទ្ធកម្ម (cause and effect)**។ ភស្តុតាងអាចមានភាពផ្ទុយគ្នាដែរ។ អ្នកវិទ្យាសាស្ត្រអាចមានមតិខុសៗគ្នា។ ជាឧទាហរណ៍ គឺការដែលសង់ទំនប់វារីអគ្គិសនីនៅប៉ែកខាងលើទន្លេមេគង្គ។ បន្ទាប់ពីការសាងសង់រួច សហគមន៍អ្នកនេសាទនៅរាប់រយគីឡូម៉ែត្រខាងក្រោមទន្លេនាំគ្នារអ៊ូថា របបទឹកមានភាពមិនទៀងទាត់ ហើយបរិមាណត្រីក៏ថយចុះដែរ។ ពួកគេក៏រអ៊ូផងដែរអំពីសំណឹកដី និងការបាត់បង់ព្រៃស្មៅវល្លិនៅតាមឆ្នេរទន្លេ។ បើទោះជាថាវាអាចមានមុខតំណាក៏ដោយ វាពិបាកដែរសម្រាប់អ្នកវិទ្យាសាស្ត្រនឹងនិយាយឲ្យប្រាកដប្រជាណាស់ដោយសារកង្វះទិន្នន័យព័ត៌មាន។ កត្តាបរិស្ថានមួយទៀតអាចមានចំណែកដែរ ដូចជារបបទឹកភ្លៀងធ្លាក់មិនទៀងទាត់ និងការនេសាទត្រីច្រើនពេក។ ដូច្នេះ វាពិបាកធ្វើសេចក្តីសន្និដ្ឋានដាច់ខាតបានណាស់លើដំណើរការបរិស្ថាន។ អ្នកយកព័ត៌មាន គួរតែប្រឹងប្រែងយកអស់សមត្ថភាពក្នុងការលើកមកបង្ហាញនូវ**កត្តារួមចំណែកទាំងអស់**។

**ពិបាកបន្តិចក្នុងការរកកន្លែងដាក់រឿងបរិស្ថាន**។ និពន្ធនាយកមួយចំនួន អាចមិនសូវផ្តល់ភាពលេចធ្លោដល់រឿងបរិស្ថានប៉ុន្មានទេ ដោយសារពួកគេមិនសូវធ្លាប់ជាមួយសារៈសំខាន់បញ្ហាបរិស្ថាន។ ដូច្នេះ អ្នកសារព័ត៌មានត្រូវត្រៀមខ្លួនប្រឹង "លក់" រឿងបរិស្ថានទៅឲ្យនិពន្ធនាយកយកទៅចុះផ្សាយ។ នេះមានន័យថា ពួកគេក៏ត្រូវជួយអប់រំនិពន្ធនាយករបស់ខ្លួនអំពីបរិស្ថាន ហើយពន្យល់ថាហេតុអ្វីបានជារឿងមួយនឹងសំខាន់ នឹងមានប្រយោជន៍ដល់អ្នកអាន។ អ្នកសារព័ត៌មានវៃឆ្លាតពពាយនាយរឿងបរិស្ថានរបស់ពួកគេសម្រាប់ចុះផ្សាយនៅថ្ងៃណាដែលមិនសូវសំបូរដំណឹង ដូចជានៅដើមសប្តាហ៍ ឬបន្ទាប់ពីថ្ងៃឈប់សម្រាក ពេលដែលមិនសូវមានការប្រកួតប្រជែងផ្នែកដំណឹងនយោបាយ។ គេអាចក្រិតរឿងរបស់គេទៅនឹងទិវានានាដែរ ដូចជា ទិវាបរិស្ថានពិភពលោកថ្ងៃទី ៥ មិថុនា។ បើចេះវេចខ្ចប់រឿងជាមួយរូបថតផែនទី និងរូបភាព អាចជួយជានាបានឱកាសឲ្យគេយកវាទៅចុះផ្សាយ។ រូបថតដ៏អស្ចារ្យមួយអាចជួយធ្វើឲ្យរឿងកាន់តែលេចធ្លោថែមទៀតដែរ។

**រឿងបរិស្ថានច្រើនតែបង្កប់ភាពអវិជ្ជមាន ហើយគួរភ័យខ្លាចទៀតផង**។ ភាគច្រើននៃរឿងអំពីបរិស្ថានតែងតែសង្កត់ធ្ងន់ទៅលើគ្រោះដែលកំពុងតែកើតមានទៅលើបរិស្ថាន និងផាត់ពណ៌អាប់អួឲ្យអ្វីដែលនឹងអាចកើតមានទៅថ្ងៃមុខ។ ចំណងជើងអំពីការប្រែប្រួលអាកាសធាតុច្រើនទាយទុកអំពីថ្ងៃវិនាសហិនហោចដល់ភពផែនដី។ ប៉ុន្តែការសរសេរផ្តោតតែទៅលើចំណុចអវិជ្ជមានច្រើនពេក អាចធ្វើឲ្យអ្នកអានធុញទ្រាន់ទៅវិញទេ។ ដូច្នេះ អ្នកសារព័ត៌មានគួរតែពិចារណារិះរកមើល**មុមរឿងវិជ្ជមាន**មកសរសេរផង។ ដូចជា តើមនុស្សម្នាកំពុងធ្វើអ្វីខ្លះដើម្បីកែលំអស្ថានភាព? តើពួកគេកំពុងទម្លាប់ដូចម្តេចខ្លះទៅនឹងការផ្លាស់ប្តូរក្នុងបរិស្ថាន? តើមនុស្សម្នាទូទៅអាចធ្វើអ្វីបានខ្លះឲ្យមានប្រយោជន៍?

ខាងក្រោមជាឧទាហរណ៍រឿងវិជ្ជមានមួយក្នុងទស្សនាវដ្តីព័ត៌មាន Time ស្តីអំពីស្ត្រីវៀតណាមម្នាក់ដែលប្រឹងធ្វើអ្វីមួយឲ្យមានប្រយោជន៍ដល់បរិស្ថាន៖

***ដោយ Kay Johnson, Hanoi***

*នាង Vu Thi Quyen បំណាយពេលជាងពីរឆ្នាំដើម្បីធ្វើការឡប់ប៊ី និងរៀបចំបែបបទឯកសារទៅបញ្ចុះបញ្ចូលរដ្ឋាភិបាលវៀតណាមឲ្យផ្តល់ភាពស្របច្បាប់ដល់អង្គការរបស់គាត់ឈ្មោះ Education for Nature-Vietnam (ENV) ដែលជាអង្គការបរិស្ថានទីមួយនៅក្នុងប្រទេស។ ពួកការិយាធិបតេយ្យមិនជំទាស់ទៅនឹងផែនការរបស់លោកនាង Quyen ទេ ក្នុងបង្រៀនដល់កូនសិស្សសាលាអំពីពពួកពូជសត្វព្រៃកម្រជិតផុតពូជក្នុងប្រទេសវៀតណាម។ លោកស្រីនិយាយថា បញ្ហានៅត្រង់ថា ដោយស្ថិត*

ក្នុងអាយុ ២៥ ឆ្នាំនៅឡើយ នាងទើបតែនឹងរៀនចប់ ហើយមិនទាន់មានបទពិសោធន៍ប៉ុន្មានទេ។ អ្នកស្រឡាញ់បរិស្ថានបាននាំគ្នាជួយគាំទ្រផ្តួចផ្តើមអង្គការថ្មីនេះ តែពួកគេមានវ័យកាន់តែក្មេងជាងនាងទៅទៀត ដែលរដ្ឋកុម្មុយនិស្តវៀតណាមមានការរើសទាល់ ព្រោះថានៅទីនោះគេផ្តល់សារៈសំខាន់ដល់វ័យចាស់ទុំ តែគេមិនសូវផ្តល់តម្លៃដល់ភាពរស់រវើករបស់យុវជនទេ។ នាង Quyen និយាយថា៖ "វាពិបាកមែនទែន ពីព្រោះពួកយើងនៅវ័យក្មេងពេក។ យើងគ្មានសាស្ត្រាចារ្យ ឬវេជ្ជបណ្ឌិតក្នុងចំណោមគ្នាយើងទេ ហើយយើងក៏គ្មានបទពិសោធន៍ធ្វើការជាមួយរដ្ឋាភិបាលដែរ។"

ចាប់តាំងពីពេលដែលអង្គការ ENV នេះត្រូវបានបង្កើតឡើងដោយស្របច្បាប់នៅឆ្នាំ ២០០២ មក ក្រុមនេះបានអះអាងបញ្ជាក់អ្នកដទៃអំពីភាពក្លាហានមោះមុតរបស់ខ្លួន។ កម្មវិធីការយល់ដឹងអំពីកិច្ចអភិរក្ស (Conservation Awareness Program) របស់ក្រុមនេះបានបង្កើតបាន "ក្លឹបអភិរក្ស" នៅក្នុងសាលារៀនវៀតណាមបានចំនួន ៥០ ហើយជួយផ្តល់ការអប់រំអំពីសត្វព្រៃវៀតណាមដល់ក្មេងៗជាង ១០០.០០០ នាក់ ទៀតផង។ គេបានផ្តល់ការបណ្តុះបណ្តាលពួករុក្ខារក្សក្នុងឧទ្យានជាតិចំនួន ៣០ ឲ្យបង្កើតកម្មវិធីសិក្សាអំពីពូជពពួកសត្វព្រៃជិតផុតពូជ ដែលនៅមានសេសសល់ក្នុងមូលដ្ឋាន។ តារាចម្រៀង My Linh បានសម្តែងក្នុងការឃោសនាពាណិជ្ជកម្មមួយកាលពីឆ្នាំ ២០០៤ ដោយអំពាវនាវប្រជាជនកុំឲ្យផឹកស្រាត្រាំប្រម៉ាត់ ដែលគេយកចេញពីខ្លាឃ្មុំជាប់អន្ទាក់។ ឆ្នាំនេះ អង្គការ ENV បង្កើតលេខទូរស័ព្ទហត់ឡាញមួយ ដើម្បីទុកឲ្យប្រជាជនរាយការណ៍អំពីការចាប់សត្វព្រៃ និងភោជនីយដ្ឋានណាដែលធ្វើម្ហូបសាច់សត្វព្រៃលក់ជូនភ្ញៀវ។ បុគ្គលិករបស់អង្គការនេះ ឥឡូវបានឡើងដល់ ២២ នាក់ហើយ។ នាង Quyen និយាយទាំងសើចដូច្នេះថា៖ "បច្ចុប្បន្ន ខ្ញុំជាមនុស្សមានវ័យចាស់ជាងគេក្នុងអង្គការនេះ"។

នៅប្រទេសវៀតណាម កិច្ចអភិរក្សខ្លួនឯងនេះតែម្តងជាគោលគំនិតដែលនៅមានវ័យក្មេងនៅឡើយ។ បន្ទាប់ពីមានសង្គ្រាម និងស្ថិតក្នុងភាពឯកោអស់ច្រើនទសវត្សរ៍កន្លងមក វៀតណាមបានបើកព្រៃរបស់ខ្លួនដល់ក្រុមអភិរក្សអន្តរជាតិនៅទសវត្សរ៍ឆ្នាំ ១៩៩០ ហើយមិនយូរប៉ុន្មានគេបានដឹងថា ប្រទេសនេះ ស្ថិតក្នុងចំណុចក្តៅមួយសម្រាប់ពពួកពូជសត្វព្រៃដែលសឹងតែនឹងផុតពូជទៅហើយ។ ពូជសត្វមួយក្នុងចំណោមពូជសត្វដែលកម្រជាងគេនោះ គឺស្វាក្បាលលឿង (golden-headed langur)។ ពពួកស្វានេះរស់នៅលើដើមឈើលើកោះ Cat Ba ភាគខាងជើងប្រទេសវៀតណាម ហើយចំនួនរបស់វាមានមិនដល់ ១០០ ក្បាលទេ។

នាង Quyen ធ្លាក់ចិត្តស្រលាញ់សត្វព្រៃរបស់ប្រទេសនាងសឹងតែដោយចៃដន្យបំផុត។ នៅឆ្នាំ ១៩៩៦ បន្ទាប់ពីនាងរៀនចប់បានសញ្ញាប័ត្រផ្នែកភូមិសាស្ត្រពីសាកលវិទ្យាល័យមក នាងធ្វើជាអ្នកហាត់ការនៅឧទ្យានជាតិ Cuc Phuong National Park ជាមួយអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយឈ្មោះ Fauna & Flora International។ នាងទទួលបន្ទុកក្នុងការអប់រំអ្នកស្រុកឲ្យចេះគោរពអភិរក្សសត្វព្រៃក្នុងឧទ្យាន ហើយកុំឲ្យប្រមាញ់ពួកវាយកមកធ្វើចំណី។ ប៉ុន្តែដល់ឆ្នាំ ២០០០ នាង Quyen ចាប់ផ្តើមរៀបចំផែនការបង្កើតក្រុមអភិរក្សវៀតណាមមួយឲ្យមានលក្ខណៈពឹងផ្អែកខ្លួនឯងជាង។ នាងនិយាយថា៖ "យើងមិនអាចពឹងលើជនបរទេសឲ្យមកសង្គ្រោះប្រទេសយើងទេ។ កិច្ចការនេះគួរតែជនជាតិវៀតណាមខ្លួនឯងជាអ្នកធ្វើ"។

នាងនិយាយថា រង្វាន់ផ្គាប់ចិត្តធំបំផុតដែលនាងទទួល គឺការដណ្តើមបានបេះដូងចិត្តគំនិតរបស់អ្នកស្នេហាធម្មជាតិវ័យក្មេងៗ ជាពិសេស កុមារា-កុមារី

*ដែលបានបញ្ចុះបញ្ចូលឳពុកម្តាយរបស់គេឲ្យឈប់ប្រមាញ់សត្វព្រៃតទៅទៀត។ នាងនិយាយថា៖ "ការអប់រំនាំឲ្យមានការប្រែប្រួល។ ប៉ុន្តែ វាស៊ីពេលរាប់ទសវត្សរ៍ដើម្បីប្តូរឥរិយាបថមនុស្ស"។ ជាក់ព្វសំណាងល្អដែរ ដែលនាងនៅមានពេលវេលាច្រើនគ្រប់គ្រាន់សម្រាប់លូតលាស់ទៅមុខទៀតក្នុងកិច្ចការនេះ។*

## ករណីសិក្សា៖ ធ្វើមនុស្សកម្មសាច់រឿង

**(Humanizing the story)**

ជាទូទៅ រឿងអំពីបរិស្ថាននឹងមានលក្ខណៈគួរឲ្យចង់អាន ប្រសិនបើគេផ្តោតលើមនុស្សដែលទទួលរងផលប៉ះពាល់ពីបញ្ហាបរិស្ថាន។ ខាងក្រោមនេះជាសេចក្តីផ្តើមរបស់បទពិពណ៌នាមួយអំពីការធ្លាក់ចុះចំនួនត្រីឆ្លាំងយក្ស (Giant Catfish) ដែលសរសេរដោយនាង Sunisuda Ekachai របស់កាសែត Bangkok Post។ ក្នុងសេចក្តីផ្តើមនេះ នាងបានថ្ពក់អ្នកអានជាប់ជាមួយនឹងការផ្តោតលើមនុស្សជាគោល៖

*លោក Sanan Suwanta ជាអ្នកនេសាទម្នាក់ប្រកបដោយមោទនភាព។ ដូចឳពុក និងជូនតារបស់គាត់ដែរ គាត់ជាមនុស្សឆ្នើមជាងគេក្នុងចំណោមនេសាទជននឯទៀត ដោយគាត់ជាអ្នកប្រមាញ់ត្រីឆ្លាំងយក្ស ឈ្មោះ pla buek ក្នុងទន្លេមេគង្គ ដែលត្រីនេះអាចមានប្រវែងដល់ទៅ ៣ ម៉ែត្រ និងទម្ងន់ជិត ៣០០ គីឡូក្រាម ឯណោះ។*

*ប៉ុន្តែមិនដូចត្រីជីផុតពូជមួយនេះ ដែលជាអំបូរត្រីទឹកសាបអត់ស្រកាធំជាងគេលើលោកនេះ លោក Sanan ក៏ប្រហែលជាមនុស្សចុងក្រោយគេហើយក្នុងអំបូររបស់គាត់។*

*លោក Sanan ដែលស្ថិតក្នុងវ័យជាង ៤០ ឆ្នាំនិយាយថា៖ "ទន្លេមេគង្គមិនមានសភាពដែលវាធ្លាប់មានពីមុនទៀតទេ"។ គាត់កំពុងតែរៀបចំឧបករណ៍នេសាទនៅលើកោះដុនវ៉ែង ទល់មុខភូមិបានហាដខៃ ដែលគាត់រស់នៅក្នុងស្រុកខុង ខេត្តឈៀងរ៉ៃ។*

*បាតទន្លេ បានហាដខៃ មានភាពស្មើផេងគ្មានគ្រួស គ្មានទឹកធ្លាក់ ដែលជាកន្លែងតែមួយគត់ក្នុងប្រទេសថៃ ដែលគេអាចនេសាទត្រីឆ្លាំងយក្សបាន។ រៀងរាល់ខែមេសា ពេលដែលទឹកទន្លេស្រកដល់កម្រិតទាបបំផុត អ្នកនេសាទពីប្រទេសថៃ និងប្រទេសឡាវនាំគ្នាមកបោះជំរំលើកោះតូចមួយនេះចាំចាប់ត្រីឆ្លាំងយក្ស។*

*សម្រាប់អ្នករស់នៅក្នុងស្រុកខុង ការប្រមាញ់នេះគឺជាការបន្តប្រពៃណីពីដូនតា។ ប៉ុន្តែសម្រាប់អ្នកអភិរក្សបរិស្ថានវិញ ទង្វើរបស់អ្នកស្រុកក្នុងការតាមប្រមាញ់ គឺជាការគំរាមដល់ត្រីជិតផុតពូជមួយនេះដែលគេអាចរកឃើញតែក្នុងទន្លេមេគង្គមួយប៉ុណ្ណោះ។*

*បច្ចុប្បន្ននេះ គេសម្លឹងមើលទៅលើអ្នកនេសាទក្នុងស្រុកខុង ជាមួយក្រសែភ្នែកមួយកាន់តែម៉ឹងម៉ាត់ឡើងៗ ដោយសារចំនួនត្រីឆ្លាំងយក្សនេះកាន់តែថយចុះ។*

*នៅឆ្នាំ ១៩៩០ ស្រុកខុងនេះ ចាប់ត្រីនេះបានចំនួនខ្ពស់បំផុត គឺ ៦៩។ ប៉ុន្តែចាប់តាំងពីពេលនោះមក ចំនួននេះចេះតែថយទៅៗស្របគ្នាជាមួយនឹងភាពថមថយស្ថានភាពអេកូឡូស៊ីក្នុងទន្លេមេគង្គខ្លួនឯងនេះតែម្តង។*

*ក្នុងអំឡុងឆ្នាំ ២០០១-៣ គ្មាននរណាចាប់បានត្រីឆ្លាំងយក្សមួយក្បាលសោះឡើយ។*

*លោក Rian Jinnarat អាយុ ៥៨ ឆ្នាំ និងជាមេដឹកនាំសហគមន៍ស្រុកខុង និងជានេសាទជន*

*ម្តងម្កាលដែរនោះនិយាយថា៖ "វាមិនត្រឹមត្រូវទាល់តែសោះក្នុងការបន្ទោសអ្នកនេសាទចំពោះការធ្លាក់ចុះចំនួនត្រីឆ្លាំងយក្សនេះ។ ពួកយើងបានជួបប្រទះក្តីវេទនាខ្លាំងណាស់ ដោយសារទឹកទន្លេកាន់តែល្អក់ទៅៗ និងមានក្លិនស្អុយ។ ការឡើងចុះកម្រិតទឹកទន្លេមានសភាពខ្លាំងហួសហេតុ ហើយលែងទស្សន៍ទាយបានដូចមុនទៀតផង។ ពពួកសារាយ និងរុក្ខជាតិក្នុងទឹកទាំងអម្បាលម៉ានប្រែក្លាយជាស្រពោនអស់ដោយសារតែទឹកក្រខ្វក់ពេក។ បរិមាណត្រីក៏ថយចុះយ៉ាងសម្បើម។ មិនត្រឹមតែត្រីឆ្លាំង pla buek នេះទេ គឺត្រីគ្រប់ប្រភេទទាំងអស់ - ពូជត្រីច្រើនប្រភេទដែលយើងធ្លាប់ឃើញកាលពីនៅក្មេង ត្រូវវិនាសបាត់អស់ទៅហើយ"។*

អត្ថបទនេះបន្តទៅពិនិត្យមើលហេតុផលដែលអាចមាននាំដល់ការថយចុះចំនួនត្រី រួមមានការសង់ទំនប់ទឹកនៅខ្សែទឹកខាងលើ និងការបំផ្ទុះថ្មបាតទន្លេ ដែលជាជម្រកល្អសម្រាប់ត្រីបន្តពូជ។

## ករណីសិក្សា ៖

### ផលិតផលអាវយឺតចិន សកលភាវូបនីយកម្ម និងការបំពុលខ្យល់បរិយាកាស

នៅទីបំផុត ខាងក្រោមនេះជាសម្រង់ខ្លះៗពីអត្ថបទលេចធ្លោមួយនៃសារព័ត៌មានបរិស្ថានដែលពិនិត្យមើលមុខតំណ និងទំនាក់ទំនងឆ្លងដែនដែលយើងបាននិយាយនៅមុននេះបន្តិច។ អត្ថបទនេះពន្យល់ថា តើអ្នកនៅលោកខាងលិចដែលប្រើប្រាស់អាវរងាធ្វើពីរោមពពែ បង្កបញ្ហាដូចម្តេចខ្លះដល់វាលឃ្វាលសត្វនៅប្រទេសចិន ដែលតាមរយៈនោះបង្កើតនូវការបំពុលខ្យល់នៅសហរដ្ឋអាមេរិក។ រឿងនេះផ្តោតលើប្រជាជនសាមញ្ញ តួយ៉ាងលោក Shatar ដែលជាបុរសគង្វាលម្នាក់ និងរួមទាំងអត្ថាធិប្បាយពីអ្នកជំនាញផង។ អត្ថបទនេះបង្ហាញជូននូវបរិបទប្រវត្តិកាល ហើយប្រើសេចក្តីពិស្តារក្នុងការគូសវាសទិដ្ឋភាពឲ្យបានច្បាស់ទៀតផង។

***តម្លៃដែលយើងបង់លើកំណើនសេដ្ឋកិច្ចចិន***
***និពន្ធដោយលោក Evan Osnos***
***កាសែត Chicago Tribune***

***ON THE ALASHAN PLATEAU, China***
***នៅវាលរាបអាឡាស្ហាន់ ប្រទេសចិន***

*លោក Shatar ជនគង្វាលសម្លឹងទៅរកថ្ងៃអស្តង្គតនៅលើវាលស្មៅ - ក្រៀមផ្ទះមួយ ដែល Genghis Khan ស្តេចម៉ុងហ្គោលីធ្លាប់លើកទ័ពវាយលុកលុយប្រទេសចិន។*

*រំពេចនោះ ស្រាប់តែគាត់ជ្រួញចិញ្ចើម ហើយស្រែកហៅហ្វូងពពែរបស់គាត់។ ខ្យល់ពោរពេញទៅដោយខ្សាច់។*

*នៅឯជ្រោយម្ខាងទៀតនៃពិភពលោកឯណោះវិញ អរុណោទ័យបានមកដល់ក្នុងចំណោងប្រវត្តិសាស្ត្រក្នុងជំនួញ រវាងរោងចក្រដែលប្រើថ្លៃទាបបំផុតលើពិភពលោក និងអតិថិជននៅប្រទេសអ្នកមាន។*

*កថាខណ្ឌពីរខាងលើជាក្បាលរឿង ដែលត្រូវបានតាក់តែងយ៉ាងប៉ិនប្រសប់ អានទៅដូចប្រលោមលោកអញ្ចឹង។*

*កាលពីឆ្នាំទៅ រៀងរាល់នាទី ពលរដ្ឋអាមេរិកចំណាយលើទំនិញចិន ក្នុងតម្លៃ ៤៦៣.២០០ ដុល្លារ រួមមាន អាវរងារាប់លាន អាវដែលធ្វើអំពីរោមពពែ តួយ៉ាងដូចជាពពែរបស់លោក Shatar នេះ។*

*តែយើងមិនរង់ចាំយូរទេ ដើម្បីឲ្យអ្នកនិពន្ធភ្ជាប់សាច់រឿងអំពីពពែនៅប្រទេសចិនទៅនឹងអ្នកប្រើប្រាស់នៅសហរដ្ឋអាមេរិក។*

*មិនដល់មួយទសវត្សរ៍ផង ការហូរជន់អាវរងាពីប្រទេសចិន បាននាំឲ្យឧស្សាហកម្មចំណាស់មួយនេះមានការប្រែប្រួល ដោយធ្វើឲ្យតម្លៃវត្ថុធាតុដើមរបស់វាធ្លាក់ចុះ។ ឥឡូវនេះ អាវរងាធ្វើនៅប្រទេសចិនមានលក់ក្នុងតម្លៃទាបរហូតដល់ ១៩.៩៩ ដុល្លារក្នុងអាវមួយ ក៏មានដែរ។*

*ប៉ុន្តែនៅពីក្រោយស្លាក Made in China លើទំនិញថោករបស់ចិន មានអ្វីមួយទៀតដែលពលរដ្ឋអាមេរិកកម្រមើលឃើញ នោះ គឺផលវិបាកច្រើនគន្លាក់នៅជុំវិញពិភពលោកនៅពេល ដែលអានុភាពនៃផលិតកម្មចិន និងតម្រូវការប្រើប្រាស់របស់អាមេរិកប្រសប់មុខគ្នានៅលើធនធានធម្មជាតិ ដែលឥឡូវនេះមិនសូវសំបូរបែបប៉ុន្មានទេ។*

*ខុសពីបទពិពណ៌នាដទៃ អត្ថបទនេះមិនមានកថាខណ្ឌស្នូលតែមួយទេ គឺមានច្រើនដែលពន្យល់អំពីគំនិតគោលរបស់រឿង។ អ្នកនិពន្ធបង្ហាញគំនិតគោលទាំងនោះតាមច្រើនរបៀប តែច្បាស់លាស់ថាតើរឿងនេះនិយាយអំពីអ្វី ហើយហេតុអ្វី គួរយើងយកចិត្តទុកដាក់ជាមួយរឿងនេះ (ពីកថាខណ្ឌទី៥ ដល់ទី៧)។*

*គេមានវិធីច្រើនណាស់ ដើម្បីវាស់វែងឥទ្ធិពលនៃការឡើងសេដ្ឋកិច្ចរបស់ចិន មានជាអាទិ៍ការនាំចេញទំនិញដូចភ្នំ មហានាវាដឹកប្រេងជាដើម ប៉ុន្តែប្រហែលជាមានហេតុផលតិចតួចណាស់សម្រាប់គេទៅពិនិត្យពិច័យទំនិញថោកៗ ដូចជាអាវរងានេះ។ យ៉ាងណាក្តី តំណភ្ជាប់រវាងអាវរងាថោកៗ វាលស្មៅឃ្វាលសត្វពាហនៈនៅអាស៊ី និងគុណភាពខ្យល់នៅអាមេរិក បង្ហាញអំពីការរេទិសដៅសេដ្ឋកិច្ចពិភពលោក ដែលញ៉ាំងឲ្យមានការប្រែប្រួលយ៉ាងអស្ចារ្យមួយ។*

*នេះជារឿងមួយបង្ហាញថា តើអាវរងាដែលអ្នកកំពុងពាក់ វាបំពុលខ្យល់ ដែលអ្នកកំពុងដកដង្ហើមដូចម្តេចខ្លះ ហើយថាតើការរីកចម្រើនលេចធ្លោរបស់ប្រទេសចិនមានឥទ្ធិពលដូចម្តេចខ្លះលើពិភពលោក។*

*ត្រង់នេះដងខ្លួននៃរឿងបានចាប់ផ្តើមជាមួយនឹងសាវតារ និងបរិបទ ដែលជួយឲ្យយើងយល់បាននូវទិដ្ឋភាពទូលំទូលាយរបស់រឿងបាន។*

*ប្រទេសចិនសំបូរហ្វូងគង្វាលពពែមែនទែន ដែលគេយកទៅផលិតអាវរងា ហើយចំនួនដ៏សម្បើមនេះបានទាញតម្លៃអាវរងាលើពិភពលោកឲ្យធ្លាក់ចុះ។ តែហ្វូងពពែទាំងនោះស៊ីស្មៅច្រើនណាស់ រហូតដល់ធ្វើឲ្យវាលស្មៅប្រទេសចិនត្រងោលដូចដីស្ពានព្រះច័ន្ទអញ្ចឹង។ ការបាត់បង់គម្របស្មៅបានបង្កឲ្យមានព្យុះធូលីដីដ៏អាក្រក់ ដែលគេមិនដែលឃើញពីមុនមក។ ការប្រែប្រួលនេះបានបញ្ចេញនូវការបំពុលដែលហោះហើរលើអាកាសឆ្ងាយ រហូតដល់លំហមេឃលើទ្វីបអាមេរិកខាងជើងឯណោះ។*

*ប្រទេសចិនត្រូវការធនធានធម្មជាតិខ្លាំងមែនទែន ដោយមិនគ្រាន់តែធ្វើឲ្យវាលស្មៅទៅជាវាលធូលីដីប៉ុណ្ណោះទេ តែវាបានថែមទាំងរុញឲ្យការកាប់ឈើខុសច្បាប់រុលចូលកាន់តែជ្រៅទៅក្នុងព្រៃត្រូពិកមានតម្លៃខ្ពស់នៅទូទាំងពិភពលោក និងរៀបចំជំហររបស់ខ្លួនឡើងវិញនៅក្នុងល្បែងប្រកបដោយគ្រោះថ្នាក់មួយ ក្នុងការដណ្តើមការគ្រប់គ្រងលើការផ្គត់ផ្គង់ប្រេងឥន្ធនៈទៀតផង ។*

*ផលិតផលគ្រប់មុខ - មានអាវយឺត រថយន្ត ឧបករណ៍ក្មេងលេង - សុទ្ធតែជាប់ដោយដានធនធាន និងថាមពល ដែលត្រូវការសម្រាប់ផលិតវាឡើង ។ ក្នុងករណីអាវរងា សហរដ្ឋអាមេរិកបំបែកឯកទគ្គកម្មដោយទិញអាវរងាចិនរហូតទៅដល់ ១០.៥ លានអាវ កាលពីឆ្នាំទៅដែល ១៥ ដង ច្រើនជាងកាលពីមួយទសវត្សរ៍មុន ហើយច្រើនហួសពីចំនួនអាវរងាដែលត្រូវបាននាំចូលពីប្រទេសអ៊ីតាលី និងអង់គ្លេសកាលពីឆ្នាំមុនទៅទៀត ។*

*គេពិបាកនឹងនិយាយថា តើផលិតផលនីមួយៗរបស់ចិន រួមចំណែកប៉ុណ្ណាដល់ការបំពុលខ្យល់អាកាស ។ ប៉ុន្តែការកើនតម្រូវការរបស់អាវរងា កំពុងតែបំផ្លិចបំផ្លាញដល់គុណភាពដី ខ្យល់ និងទឹក នៅប្រទេសចិន និងសហរដ្ឋអាមេរិក ដែលនេះជាតម្លៃដែលគេមិនដែលដាក់នៅលើស្លាកថ្លៃទំនិញទេ ។ ហើយអតិថិជនច្រើននាក់ណាស់មិនបានដឹងអំពីសង្វាក់តំណនេះទេ ។*

*នាង Colleen Young ដែលកំពុងឈរសម្លឹងមើលទូរទស្សន៍ក្នុងហាងមួយនៅទីក្រុង ឈីកាហ្គោ និយាយថា៖ "ខ្ញុំមិនដែលនឹកដល់ទេ ។ ពេលណាអ្នកទិញអាវរងា អ្នកពិតជាមិនដែលគិតអំពីការបំពុលបរិយាកាសទេ ។ អ្នកប្រហែលជាអាចគិតដល់សត្វដ៏កំសត់ទាំងនោះដែលគេសម្លាប់យករោម ឬក៏អាចគិតដល់ពលកម្មទាសករ តែមិនដែលនឹកដល់ការបំពុលទេ" ។*

*ត្រង់នេះយើងត្រឡប់មកនិយាយអំពីអ្នកគង្វាលពពែយើងវិញម្តងទៀត ជាពិសេសការគំរាមកំហែងដែលជាបេះដូងនៃម្ចាស់រឿងនេះ ។*

## *វាលស្មៅតែគ្មានស្មៅ*

*ពពែរបស់លោក Shatar ជាពពែពូជសុទ្ធអត់មានកាត់ជាមួយពូជដទៃទេ គឺវាមានរោមពណ៌ស និងភាពធន់ទៅនឹងអាកាសធាតុដ៏អាក្រក់នៅភាគខាងជើងរបស់ចិន ដែលនៅទីនោះសីតុណ្ហភាពខែក្តៅអាចឡើងដល់ជិត ៤២ អង្សារសេ ហើយធ្លាក់មកនៅ ១ អង្សារសេក្រោមសូន្យវិញក្នុងរដូវត្រជាក់ ។*

ចូរកត់សំគាល់មើលសេចក្ដីពិស្ដារ (មានមិនច្រើនប៉ុន្មានទេ) ដែលផ្ដុំចូលគ្នាបានជារូបភាពមួយ ឲ្យអ្នកអានយល់បាន និងការប្រៀបធៀបរវាងពោមពពែ និងសក់មនុស្ស។

ស្ថិតនៅជាប់ព្រំដែនជាមួយប្រទេសម៉ុងហ្គោលី វាលរាប Alashan ផលិតចេញនូវអាវរងាដែលថ្លៃជាងគេបំផុតលើពិភពលោក។ តម្លៃរបស់វាអាចលក់ប្រាំមួយដងថ្លៃជាងតម្លៃពោមសត្វធម្មតា។

លោក Shatar អាយុ ៥១ ឆ្នាំ ប្រើឈ្មោះតែមួយទេដូចជនពនេចរចិនដទៃទៀតដែរ។ គាត់ធំដឹងក្ដីនៅក្នុងតំបន់នេះតាំងពីតូចមក។ គាត់បានរួមចំណែកក្នុងបង្កើនផលិតផលអាវរងាចិនក្នុងរយៈពីរទសវត្សរ៍កន្លងមកនេះ ដោយបានពង្រីកចំនួនពពែក្នុងហ្វូងរបស់គាត់រហូតដល់ទៅជាង ៣០០ ក្បាល។ ប្រាក់ចំណេញពីការលក់ពោមពពែនេះ បានជួយឲ្យគាត់មានផ្ទះមួយ ដែលមានបីបន្ទប់ និងបង់ថ្លៃការសិក្សារបស់កូនស្រីគាត់។

សំណេរល្អ គឺតែងយោងទៅរកធាតុមុនៗ។ ក្នុងករណីនេះ គឺលោក Shatar "ស្រែកហៅពពែរបស់គាត់ម្ដងទៀត"។

ប៉ុន្តែធម្មជាតិនៅវាលរាប Alashan ត្រូវបានខូចខ្ទេចខ្ទាំខ្លាំងណាស់។

លោក Shatar ស្រែកហៅពពែរបស់គាត់ម្ដងទៀត។ ពពែទាំងនោះ ដើរចេប្រប់តាមជំរាលភ្នំ ហើយស្រាប់តែទន់ជើងក្រាបនៅក្បែរជើងគាត់។ ពួកវាកំពុងឃ្លានចំណី។

លោក Shatar និយាយថា៖ "មើលចុះ៎ ពួកវាគ្មានអីស៊ីទេ"។

គាត់បានបាចគ្រាប់ពោតស្ងួតមួយក្ដាប់ទៅលើដីឲ្យពពែស៊ី ហើយបន្លឺទៀតថា៖ "បើសិនជាស្ថានភាពនៅតែបន្តដូច្នេះទៀត ខ្ញុំនឹងត្រូវតែលក់ចំនួនពពែពាក់កណ្ដាលចេញហើយ"។

វាលនេះលាតសន្ធឹងធំណាស់នៅប្រទេសចិន ហើយជាវាលមួយក្នុងចំណោមវាលធំៗលើពិភពលោក តែពេលនេះវាលែងមានស្មៅដុះទៀតហើយ។ ដីនៅទីនេះមានសភាពគ្រោះលពេក រហូតដល់ថា លោក Shatar និងពួកគង្វាលឯទៀតបង្ខំចិត្តទិញស្មៅកាត់ពីកន្លែងដទៃ និងពោតដឹកតាមឡានមកចិញ្ចឹមពពែរបស់ពួកគេ។ ពពែខ្លះហេវមែនទែន ដើរលែងរួច ទាល់តែម្ចាស់វាដឹកលើម៉ូតូមកផ្ទះ។ លោក Shatar រំពឹងថា ពពែភាគច្រើនរបស់គាត់រស់បាន ១០ ឆ្នាំ គឺពាក់កណ្ដាលអាយុរបស់មេវា។

អត្រាកំណើតរបស់ពពែក៏ថយចុះដែរ។ កាលពីមុន លោក Shatar មានកូនពពែថ្មី ១០០ ក្បាលថែមទៀត រៀងរាល់និទាឃរដូវ។ ឆ្នាំនេះគាត់បានតែ ៤០ ក្បាលទេ។ ការលក់ពោមពពែក៏ពិបាកជាងមុនដែរ។ ដោយសារពពែស៊ីមិនគ្រប់គ្រាន់ ពោមរបស់វាក៏ដុះមកខ្លីៗដែរ។

*លោក Shatar អង្គុយចុះ ហើយច្បាមធូលីមួយដៃពីដីដែលគ្រួសារគាត់កាន់កាប់ជាយូរឆ្នាំមកហើយ។ កាលពីគាត់នៅក្មេង ដីនេះត្រូវបានគ្របដណ្តប់ដោយពណ៌បៃតង។*

*គាត់និយាយយ៉ាងស្រទន់ថា៖ "ជីវិតរបស់យើងពឹងផ្អែកទៅលើធម្មជាតិ។ តែអ្វីៗកាន់តែយ៉ាប់យ៉ឺនទៅៗពីមួយឆ្នាំទៅមួយឆ្នាំ"។*

*គាត់ក្រោកឡើង ហើយពោយធូលីដីពីក្នុងដៃរបស់គាត់រហូតទាល់តែវាប៉ើងរសាត់បាត់ទៅក្នុងខ្យល់អស់។*

ក្រោយមកទៀត រឿងនេះពន្យល់អំពីប្រវត្តិការផលិតសំពត់រោមពពែ ដែលពីមុនជាទំនិញបែបប្រណិត តែឥឡូវត្រូវបានផលិតក្នុងបរិមាណសន្ធឹកសន្ធាប់ក្នុងប្រទេសចិន បន្ទាប់ពីប្រទេសនេះចាប់យកកំណែទម្រង់សេដ្ឋកិច្ចបែបផ្សារសេរី។ គេបានប្រាប់ឲ្យយើងដឹងថា ប្រទេសចិនមានចំណែកយ៉ាងធំក្នុងជំនួញវាយនភ័ណ្ឌពិភពលោកទាំងមូលដែលមានតម្លៃប្រមាណ ៣៥០ ពាន់លានដុល្លារក្នុងមួយឆ្នាំ។ ប្រទេសចិននាំចេញផលិតផលវាយនភ័ណ្ឌសំរេចក្នុងតម្លៃប្រមាណជា ២០ ពាន់លានដុល្លារ ក្នុងមួយឆ្នាំ។ អ្នកនិពន្ធបានឲ្យយើងដឹងថាតួលេខនេះវា "ស្មើសម្លៀកបំពាក់ជាងបីឯកតាសម្រាប់មនុស្សម្នាក់ៗលើផែនដីនេះ" - ដែលនេះជាវិធីដ៏ល្អមួយជួយឲ្យយើងយល់លេខធំបានកាន់តែច្បាស់។

រឿងនេះរួមបញ្ចូលបទសម្ភាសន៍ជាមួយម្ចាស់រោងចក្រផលិតអាវរងារោមពពែ។ ក្រោយពីពន្យល់របៀបរកស៊ី ហើយគាត់វិលត្រឡប់មកនិយាយអំពីមូលបទសាច់រឿងរបស់គាត់វិញ គឺផលប៉ះពាល់បរិស្ថាន។ បដិវត្តន៍ក្នុងឧស្សាហកម្មផលិតរោមពពែកំពុងតែដាក់សម្ពាធមកលើបររកស៊ីផ្នែកនេះ និងដីដែលទ្រទ្រង់វា។

*រោងចក្រកែច្នៃរោមពពែ និងឧស្សាហកម្មជាច្រើនបានបើកនៅតំបន់ Alashan គឺច្រើនពេករហូតទាល់តែអាជ្ញាធរទីនោះដាក់កំណត់របបទឹកប្រើប្រាស់ ដែលជាលទ្ធផល រោងចក្រខ្លះត្រូវបង្ខំចិត្តបិទទ្វារម្តងៗជាច្រើនថ្ងៃក៏មានដែរ។ ពួកគង្វាលបានភ្លេចអស់ទៅហើយនូវឈ្មោះស្មៅដែលងាប់បាត់អស់ទៅនោះ។*

*លោក Francis Patthey ជនជាតិស្វីស និងនាយកប្រតិបត្តិផលិតកម្មរោមពពែបាននិយាយទៅកាន់អ្នកផ្គត់ផ្គង់ចិនថា៖ "ភាពរហោស្ថានកំពុងក្លាយជាបញ្ហាធំឥឡូវនេះ ហើយយើងដឹងថាពពែគ្រប់ប្រភេទមិនចេះស្កប់ស្កល់ក្នុងការស៊ីទេ ដែលនេះជាការបំផ្លិចបំផ្លាញដល់វាលស្មៅ"។*

*លោក Patthey និយាយថាបញ្ហានេះកំពុងត្រូវបានគេព្រងើយកន្តើយ។ ហើយវាងាយយល់ណាស់ថាហេតុអ្វី។ ដោយតម្រូវការនៅសហរដ្ឋអាមេរិកនៅតែខ្ពស់ដដែល បណ្ដាក្រុមហ៊ុននៅតែបន្តសង់រោងចក្រថ្មីៗ និងទិញបរិក្ខារកាន់តែថ្លៃៗជាងមុនយកមកបំរើផលិតកម្មនេះ។ បន្តិចម្តងៗ ក្រុមហ៊ុនទាំងនោះរុញខ្លួនធ្លាក់កាន់តែជ្រៅទៅក្នុងបំណុល។ ទន្ទឹមនឹងនោះ ការផ្គត់ផ្គង់លើសលុបនូវបរិមាណរោមពពែបានរុញថ្លៃរបស់វាឲ្យធ្លាក់ចុះកាន់តែទាបផងដែរ។*

*នៅរោងចក្រ Lingwu Zhongyin លោក Ma Feng ដែលជានាយកប្រតិបត្តិម្នាក់និយាយថា គាត់បារម្ភថាប្រព័ន្ធទាំងមូលក្នុងការរកស៊ីផលិតរោមពពែនេះកំពុងឡើងកំដៅជិតពុះហើយ។*

*គាត់មានប្រសាសន៍ថា៖ "មនុស្សម្នាក់កំពុងភ្លេចរឿងមួយហើយគឺថា រោមពពែមិនដូចកប្បាសទេ។ វាជាធនធានធម្មជាតិមួយមានកម្រិត"។*

*កម្រិតធនធាននេះបានវិវត្តន៍មកដល់ចំណុចមួយ ដែលគេមិនអាចព្រងើយកន្តើយបានទៀតទេ។ នៅមិនឆ្ងាយប៉ុន្មានពីរោងចក្រផលិតរោមពពែនៅតំបន់ Alashan ផ្នូកខ្សាច់ពណ៌លឿងបៃសកំពុងស្តែងលេចធ្លោនៅឯជើងមេឃប្រៀបបាននឹងឆាកថតភាពយន្តអញ្ចឹង។*

*ដោយគ្មានស្មៅ និងកូនរុក្ខជាតិណាផ្សេងទៀតគ្របពីលើផ្នូកខ្សាច់ទាំងនោះ វាលរហោស្ថាននៅ Alashan កំពុងតែលាតសន្ធឹងផ្ទៃរបស់វាជាង ១.០០០ គីឡូម៉ែត្រក្រឡា ក្នុងមួយឆ្នាំ។ មើលទៅវាប្រៀបបានថាដីកំពុងតែរំដោះខ្លួនចេញពីការគ្រប់គ្រងរបស់មនុស្សហើយ។*

ក្នុងផ្នែកបន្ទាប់មកទៀត យើងនឹងបានដឹងអំពីប្រវត្តិនៃការអភិវឌ្ឍវាលឃ្វាលសត្វនៅប្រទេសចិនក្រោមរបបគ្រប់គ្រងរបស់លោក ម៉ៅ សេទុង អំពីកំណើនប្រជាជន និងអំពីរបៀបដែលប្រជាជនព្យាយាមប្រើប្រាស់ទាញយកផលពីវាលស្មៅនោះ។ ផ្នែកនេះលាតត្រដាងនូវឆាកថ្មីមួយទៀតក្នុងរឿង ក្នុងនោះមានសម្ភាសន៍ជាមួយបុរសម្នាក់ ដែលបានផ្លាស់ប្តូរពីការចិញ្ចឹមសត្វអូដ្ឋមកចិញ្ចឹមសត្វពពែវិញ និងផលប៉ះពាល់វិនាសហិនហោច ដែលទម្លាប់នេះមានទៅលើដីធ្លី។

ដូចគ្នានឹងអ្នកចិញ្ចឹមសត្វឯទៀតក្នុងតំបន់វាលរាប Alashan នេះដែរ លោក Biligedeli អាយុ ៥១ ឆ្នាំ បានប្ដូរពីការចិញ្ចឹមអូដ្ឋមចិញ្ចឹមពពែវិញ ដោយរោមរបស់វាបានថ្លៃជាង។ គាត់និយាយថា៖ "គ្រួសារអ្នកគង្វាលមួយណាក៏ដោយ តែងតែពិនិត្យមើលថា តើសត្វប្រភេទណាដែលនឹងនាំមកនូវផលប្រយោជន៍ច្រើនជាងគេ"។

បំណុចពិស្ដារមួយចំនួន ដូចជា ទ្រង់ទ្រាយក្រចកជើងសត្វ និងរបៀបសត្វស៊ីស្មៅ ច្រើនត្រូវបានគេចាត់ទុកថាមិនមែនជាបញ្ហាសំខាន់ តែតាមពិត វាសុទ្ធតែរួមចំណែកដល់ធ្វើឲ្យវាលស្មៅរងនូវការប្រែប្រួលខ្ទេចខ្ទាំ។

សេចក្ដីអត្ថាធិប្បាយពីអ្នកឯកទេសដែលបានធ្វើការប្រៀបធៀបជើងពពែជាមួយនឹងកែងស្បែកជើងស្រួច។

លោក Martin Williams ជាអ្នកជំនាញផ្នែកបញ្ហាដីរហោស្ថាន នៅសាកលវិទ្យាល័យ Adelaide ប្រទេសអូស្ត្រាលី និយាយថា៖ "តើអ្នកដែលរាំរ៉ាំលជាមួយអ្នកណាម្នាក់ ហើយអ្នកនោះជាន់ជើងអ្នកទេ? សត្វពពែមានកែងជើងស្រួច ដែលកាលណាជាន់លើស្មៅ ធ្វើឲ្យស្មៅដាច់រលើងឫសលែងធ្វើជាកំរាលគ្របដីបានទៀតហើយ។ សត្វអូដ្ឋមានបាតជើងទូលាយ ហើយទន់ជាង។ ដូច្នេះ សត្វអូដ្ឋបើវាជាន់ជើងរបស់អ្នក អ្នកអាចមិនទទួលអារម្មណ៍ឈឺផងទេ"។

## ពពែជាសត្វជំនាញខាងទន្ទ្រានរកចំណីស៊ី

លោក Williams និយាយបន្តទៀតថា៖ "កាលណាវាស៊ី សត្វពពែកកេរដល់គល់ខ្ទេចខ្ទី រីឯសត្វអូដ្ឋ ពួកវាគ្រាន់តែកកេរបោះៗប៉ុណ្ណោះ។ សត្វពពែកកេរស៊ីសំបកជុំវិញពន្លក ដែលជួយចម្លងសារធាតុចិញ្ចឹមទៅឲ្យរុក្ខជាតិ ដូច្នេះ កាលណាសំបកត្រូវបានពពែកកេរស៊ីខូចអស់ទៅ រុក្ខជាតិនឹងងាប់ជាមិនខាន"។

នៅទូទាំងតំបន់ Inner Mongolia បំនួនសត្វពពែបានកើនឡើង ១០ ដង ពីចំនួន ២,៤ លានក្បាល ក្នុងឆ្នាំ ១៩៤៩ ដល់ ២៥,៨ លានក្បាល ក្នុងឆ្នាំ ២០០៤។ ជាមួយគ្នានេះ ចំនួនសត្វអូដ្ឋបានធ្លាក់ចុះ ៨ ភាគរយ មកនៅត្រឹម ១០.១០០ ក្បាលប៉ុណ្ណោះ។

យោងតាមរបាយការណ៍មួយរបស់កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ បច្ចុប្បន្ននេះ វាលស្មៅប្រទេសចិន ដែលជាវាលស្មៅធំទីបីលើពិភពលោកកំពុងតែក្លាយទៅជាវាលរហោស្ថាន។ ក្នុងអំឡុងពេលតែប្រាំឆ្នាំប៉ុណ្ណោះ គឺពីឆ្នាំ ១៩៩៤ ដល់ឆ្នាំ ១៩៩៩ តំបន់វាលខ្សាច់រហោស្ថាន Gobi Desert បានលាតសន្ធឹងធំជាងប្រទេសហុលឡង់ទៅទៀត។

*បណ្តាញចំណងបញ្ហាថ្មីថែមទៀត លើកនេះនិយាយអំពីអាចម៍ដីដែលហូរចូលក្នុងទន្លេ។*

*ស្ថានភាពនេះ មិនគ្រាន់តែប្លន់យកដីមានតម្លៃពីកសិករ និងអ្នកចិញ្ចឹមសត្វតែប៉ុណ្ណោះទេ ប៉ុន្តែស្ថានភាពវាលស្មៅរិចរិលប្រហាក់ប្រហែលនេះដែរ នៅតំបន់វាលរាបទីបេ ប៉ែកខាងលិចប្រទេសចិនកំពុងនាំអាចម៍ដីបន្តិចម្តងៗ មកចាក់ក្នុងតំបន់ក្បាលទឹកនៃបណ្តាទន្លេដែលហូរទៅកាន់ប្រទេសឥណ្ឌា ប៉ាគីស្ថាន បង់ក្លាដេស និងប្រទេសនានាក្នុងតំបន់អាស៊ីអាគ្នេយ៍ផងដែរ។*

*អ្នកគង្វាល Beligedeli កំពុងរស់ក្នុងកណ្តាលបច្ច័យអាក្រក់ទាំងអស់នេះ។ ដីរបស់គាត់ឡើងគ្រងិលជិតអស់ហើយ។ ពេលកំពុងឈរនៅក្បែរទ្រុងពពែរបស់គាត់ ភ្នែករបស់គាត់សម្លឹងទៅរកពពែឈឺមួយក្បាល ដែលឆ្នាំនេះកើតបានកូនតែពីរប៉ុណ្ណោះប្រៀបទៅនឹង ៧០ ក្បាលកាលពីមួយឆ្នាំមុន។*

*ត្រង់នេះ អ្នកនិពន្ធងាកមកនិយាយអំពីមនុស្សសាមញ្ញជាថ្មីម្តងទៀត ដើម្បីជួយឲ្យយើងយល់អំពីផលប៉ះពាល់ពីស្ថានភាពនេះ។*

*ខ្សាច់ម៉ត់ខ្ចៃដូចម្សៅលាបខ្លួន ពូនផ្តុំពីក្រោមគុម្ពស្មៅដែលនៅដុះរ៉ុយៗនៅឡើយ។ ប្រព័ន្ធស្រោចស្រពទាញទឹកទៅកាន់កន្លែងផ្សេងបានធ្វើឲ្យដីកាន់តែខ្សោះជាតិសើមថែមទៀត។ ពីជាយខាងលិចនៃដីរបស់លោក Beligedeli ខ្យល់គួចធូលីប៉ើងទៅទិសខាងកើតតម្រង់ទៅរកតំបន់បេះដូងឧស្សាហកម្មប្រទេសចិន។*

## *ព្យុះខ្សាច់បំផ្លិចបំផ្លាញ*

*ព្រឹកថ្ងៃអាទិត្យ ទី ៩ មេសា ប្រជាជនក្នុងទីក្រុងប៉េកាំង ក្រោកពីដំណេកទៅទទួលទិដ្ឋភាពគួរឲ្យខ្លបខ្លាចមួយ គឺផ្ទៃមេឃប្រែពណ៌ទៅជាពណ៌លឿងចាស់ដូចសំបកក្រូចទុំ។*



*មនុស្សអាចបង្កការខូចខាតដល់បរិស្ថានតាមរបៀបច្រើនយ៉ាងណាស់។*

*ខ្យល់បានប្រែប្រួលមានសភាពខ្មាប់ដោយសារព្យុះធូលី ដែលធ្លាក់មកជាកម្រាលគ្របដណ្តប់លើរថយន្ត ដើមឈើ និងដំបូលផ្ទះ។ ព្យុះនោះលាយឡំទៅដោយសារជាតិពុលឧស្សាហកម្មមកជាមួយផង ដែលប្រែក្លាយទៅជាពពកអាប់អួដេដាសក្នុងលំហអាកាស។ មន្ត្រីបរិស្ថានបានព្រមានក្មេងៗ និងមនុស្សចាស់ជរាកុំឲ្យបើកបង្អួច ឬក៏ចេញក្រៅផ្ទះ ក្នុងពេលដែលទីក្រុងប៉េកាំងទាំងមូលកំពុងរកវិធីលៃលកជាមួយការបំពុលខ្យល់ដ៏អាក្រក់មួយក្នុងឆ្នាំនោះ។*

ព្យុះរបៀបនេះឧស្សាហ៍កើតមានញឹកញាប់ណាស់។ យោងតាមការសិក្សាមួយ ដែលបេញផ្សាយឆ្នាំ ២០០៥ ដោយធនាគារអេកិវឌ្ឍន៍អាស៊ីក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ ប្រទេសចិនទទួលរងព្យុះធូលី និងព្យុះខ្សាច់ប្រាំដងជាមធ្យមក្នុងមួយឆ្នាំ។ នៅទសវត្សរ៍ឆ្នាំ ១៩៧០ ចំនួនមធ្យមនេះកើតដល់ ១៤ ដង ហើយក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ មានព្យុះរហូតដល់ទៅ ២៣ ដង ក្នុងមួយឆ្នាំ។ ការសិក្សានោះបានរកឃើញផងដែរថា ក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះ តំបន់ Alashan ជាប្រភពភាគច្រើននៃព្យុះខ្សាច់ ដែលកើតមានក្នុងប្រទេសចិន។

វិទ្យាស្ថាន Korea Environment Institute បាននិយាយថា ព្យុះខ្សាច់មួយនៅឆ្នាំ ២០០២ បានបង្ខំឲ្យជនជាតិកូរ៉េខាងត្បូង ១.៨ លាននាក់ ស្វែងរកជំនួយពេទ្យ ហើយបង្កការខូចខាតក្នុងតម្លៃប្រមាណជា ៧.៨ ពាន់លានដុល្លារ ដល់វិស័យឧស្សាហកម្ម ដូចជាផ្នែកអាកាសចរណ៍ និងផ្នែកឧស្សាហកម្មពាក់កណ្ដាលចម្លងជាដើម។

ពួកអ្នកវិទ្យាសាស្ត្រគិតថា នោះជាចម្ងាយឆ្ងាយបំផុតដែលការបំពុលបរិយាកាសរបស់ប្រទេសចិនអាចធ្វើដំណើរទៅដល់។ ប៉ុន្តែការស្រាវជ្រាវថ្មីៗក្រោយមកទៀត បានបង្ហាញលម្អិតអំពីការដែលធូលី និងខ្យល់ក្រខ្វក់របស់ចិន រសាត់ទូទាំងតំបន់ប៉ាស៊ីហ្វិក បំពុលលំហអាកាស និងធ្វើឲ្យអាកាសធាតុនៅអាមេរិកប្រែប្រួល។

លោក Barry Huebert អ្នកវិទ្យាសាស្ត្រសមុទ្រនៃសាកលវិទ្យាល័យ Hawaii និយាយថា៖ "យើងធ្លាប់មានព្យុះមួយនៅអាស៊ីបូព៌ា ដែលយើងឲ្យឈ្មោះថា ព្យុះធូលីល្អឥតខ្ចោះ។ ព្យុះនោះបញ្ចេញជារូបភាពល្អៗណាស់នៅលើសមុទ្រប៉ាស៊ីហ្វិក តួយ៉ាងដូចជារូបកញ្ចុំផ្សែងពណ៌លឿងជាដើម។ កាលណាព្យុះនេះបើងដល់រដ្ឋកូឡូរ៉ាដូ វាបង្កភាពអាប់អួក្នុងលំហអាកាស តែងតែជាចំណាប់អារម្មណ៍ដល់ការផ្សាយព័ត៌មានទូទាំងប្រទេស។ វាបន្តដំណើរទៅទិសខាងកើតទៀត រហូតដល់បណ្ដាកោះកាណារី នៅជ្រោយខាងលិចទ្វីបអាហ្វ្រិក។

អ្វីដែលអ្នកវិទ្យាសាស្ត្រឲ្យឈ្មោះថា យានចម្លងអន្តរប៉ាស៊ីហ្វិក គឺជាហាយវេ សម្រាប់ការធ្វើដំណើររបស់ធូលី និងអង្គធាតុបំពុលនានាផ្សេងទៀត។ ព្រមពេលនឹងខ្យល់ពុលចិនរសាត់មកអាមេរិក បរិយាកាសពុលរបស់អាមេរិកខាងជើង ក៏ធ្វើដំណើរឆ្លងកាត់មហាសាគរអាត្លង់ទិកដែរ។ ប៉ុន្តែខ្យល់ពីប្រទេសចិន មានសភាពគ្រោះថ្នាក់ជាងគេ ពីព្រោះវានៅក្នុងចំណោមខ្យល់ដែលគគ្រិចបំផុត។ យោងតាមការឲ្យដឹងរបស់វិទ្យាស្ថានមួយរបស់ចិនជារៀងរាល់ឆ្នាំ មានមនុស្សប្រហែល

*៣០០.០០០ នាក់ ស្លាប់ក្នុងប្រទេសចិន ដោយសារជំងឺពាក់ព័ន្ធនឹងការបំពុលបរិយាកាស។*

*ធ្យូងថ្ម គឺជាដើមចមធំជាងគេក្នុងបញ្ហានេះ។ ប្រទេសចិនមានតម្រូវការកើនឡើងជានិច្ចនូវថាមពល ហើយ ៧០ ភាគរយ នៃតម្រូវការនោះ គឺបានមកពីរោងចក្រថាមពលដុតដោយធ្យូងថ្ម។ លំនៅដ្ឋានឯកជនជាច្រើន ក៏ដុតធ្យូងថ្មជាថាមពលដែរ ដែលផ្សំគ្នាទៅ វាធ្វើឲ្យប្រទេសចិនប្រែក្លាយជាអ្នកបញ្ចេញឧស្ម័នស៊ុលហ្វួរឌីអុកស៊ីដ លំអងផ្សេង និងអង្គធាតុពុលដទៃទៀតច្រើនជាងគេលើពិភពលោក។*

*សត្វពពែក៏ដើរតួសំខាន់មួយដែរក្នុងបញ្ហានេះ។ ធូលីចេញពីវាលស្មៅខ្ទេចខ្ទាំនៅតំបន់ Alashan បើុងតាមខ្យល់ទៅទិសខាងកើត ដែលនៅទីនោះ កម្រាស់ផ្សេងក្រាស់ៗ បង្កកវាជាប់ក្នុងស្រទាប់សារធាតុពុលមួយ។ លោក Rudolf Lusar អ្នកគីមីវិទ្យាផ្នែកបរិយាកាស នៅ Washington University in St. Louis និយាយថា ល្បាយជាតិពុលទាំងអស់នេះ អាចរសាត់ទៅដល់សហរដ្ឋអាមេរិកតែក្នុងអំឡុងពេលប្រាំថ្ងៃប៉ុណ្ណោះ។*

*អ្វីដែលគួរឲ្យបារម្ភមែនទែននោះ គឺបំណែកល្អិតៗមែនទែនដែលនៅជិតជាប់ជ្រៅក្នុងសួត ដែលរួមចំណែកដល់ការធ្វើឲ្យខូចផ្លូវដង្ហើម ធ្វើឲ្យមានជំងឺបេះដូង និងមហារីក។ ព្យុះធូលីខ្សាច់មួយដែលមានប្រភពចេញពីប្រទេសចិន និងម៉ុងហ្គោលី នៅឆ្នាំ ១៩៩៨ បានបណ្តាលឲ្យមានកំណើនខ្ពស់ក្នុងកម្រិតបំពុលបរិយាកាស ដែលញ៉ាំងឲ្យមន្ត្រីសុខាភិបាលនៅរដ្ឋវ៉ាស៊ីនតោន អាយដាហូ អូរ៉េហ្គុន និង ប្រីធីសកូឡុមប៊ី ចេញសេចក្តីព្រមានដល់សាធារណជនឲ្យមានការប្រុងប្រយ័ត្ន។*

*ព្យុះនោះមានសន្ទុះកខ្លាំងគ្រាន់បើដែររហូតដល់ថា វាអាចប្រមូលផ្តុំទៅជាពពកពណ៌ត្នោតធំមួយ អណ្តែតពីលើតំបន់ឆ្នេរខាងលិចរបស់សហរដ្ឋអាមេរិក។ ភាគច្រើន ជនធម្មតាមើលធូលីក្រខ្វក់របស់ចិនមិនឃើញទេ លើកលែងតែក្រុមអ្នកស្រាវជ្រាវដែលកាន់តែមានក្តីបារម្ភអំពីផលប៉ះពាល់ពីបញ្ហានេះ។*

*បន្តមកទៀត អ្នកនិពន្ធបានបញ្ចូលព័ត៌មានថែមទៀត អំពីការងាររបស់អ្នកវិទ្យាសាស្ត្រកំពុងសិក្សាអំពីពពកធូលី មុននឹងគាត់ប្រាប់ឲ្យយើងដឹងថា តើមានអ្វីដែលគេកំពុងធ្វើសម្រាប់លៃលកជាមួយបញ្ហានេះ។*

*អាជ្ញាធរបរិស្ថានរបស់ចិន ទទួលស្គាល់ការខូចខាតដែលបង្កដោយសត្វពាហនៈស៊ីស្មៅអស់ពេក ហើយពួកគេកំពុងតស៊ូទប់ទល់បញ្ហានេះ។ ពួកគេបានត្បាញកម្រាលចំបើងធំៗពីលើផ្ទៃលើរបស់វាលខ្សាច់ បាចគ្រាប់ពូជស្មៅពីលើយន្តហោះ ហើយដាំដើមឈើរាប់លានដើមនៅទូទាំងប្រទេស។ តែនៅតែគ្មានអ្វីអាចដោះស្រាយបញ្ហាបានដដែល។*

*មន្ត្រីនៅសមរភូមិមុខទល់នឹងវាខ្សាច់ ដែលចេះតែរុលមកមុខមិនឈប់ឈរនោះ កំពុងតែប្រវេប្រវាធ្វើការប៉ះប៉ូវការខូចខាតកន្លងមក។ នៅក្នុងតំបន់ Inner Mongolia ពួកគេហាមមិនឲ្យមានការឃ្វាលសត្វពាហនៈស៊ីស្មៅលើផ្ទៃដី ៤២២.១៦៨ គីឡូម៉ែត្រក្រឡា ដែលស្មើនឹងមួយភាគបីនៃទំហំខេត្តនោះ ចាប់តាំងពីឆ្នាំ ២០០០ មក។ អ្នកគង្វាលជាច្រើន ត្រូវបានគេតម្រូវឲ្យឃាំងសត្វរបស់គេក្នុងទ្រុងឲ្យជាប់ ហើយឲ្យបញ្ចុកចំណីឲ្យវាស៊ីដោយដៃ។*

*ប្រសិនបើវិធានការនានារបស់ចិន មិនមានឥទ្ធិពលអ្វីទេក្នុងការដោះស្រាយបញ្ហា កម្រិតការបំពុលបរិយាកាសនឹងនៅតែបន្តកើនថែមទៀតទាំងនៅក្នុង និងក្រៅប្រទេសចិន។ សម្រាប់ពិភពលោកមួយដែលបានដាក់ខ្លួនពឹងពាក់លើចិនជាម៉ាស៊ីនផលិតកម្មពីចម្ងាយ ការពឹងពាក់បែបនេះនឹងនាំមកនូវតម្លៃបង់ខាតមួយដល់ផ្ទះរបស់ខ្លួនតែម្តង។*

*អត្ថបទនេះ វិលមកបញ្ចប់ត្រង់កន្លែងដែលវាចាប់ផ្តើម គឺលោក Shatar ដែលជាជនគង្វាលពពែ។*

### *ការសម្រេចចិត្តដកថយរបស់អ្នកចិញ្ចឹមពពែ*

*នៅឯជ្រុងម្ខាងទៀតនៃពិភពលោក នាយគង្វាលលោក Shatar គ្មានជម្រើសណាក្រៅតែពីចាកចេញពីដីរបស់គាត់ទេ។*

*បន្ទាប់ពីរដូវក្តៅដ៏វែងមួយកន្លងផុតទៅ សត្វពពែដែលធ្លាប់តែនាំដល់គាត់នូវសេចក្តីចម្រើនរុងរឿងនោះ ឥឡូវនេះវាបានធ្វើឲ្យគាត់រងនូវការខាតបង់ប្រាក់កាសអស់យ៉ាងច្រើនក្នុងការប្រឹងថែរក្សាវាឲ្យនៅរស់។ គាត់ត្រូវដឹកជញ្ជូនស្មៅតាមរថយន្តពីកន្លែងមួយឆ្ងាយដល់ទៅ ២២០ គីឡូម៉ែត្រ ពីកន្លែងគាត់រស់នៅ ដោយចំណាយអស់ទៅវិញនូវលាភទាំងឡាយ ដែលគាត់ធ្លាប់ទទួលបានពីការលក់រោមពពែកាលមុន។*

*ដូច្នេះ លោក Shatar និងគ្រួសាររបស់គាត់ក៏នាំគ្នាវេចបង្វេចហើយបិទទ្វារបោលផ្ទះដែលគេសង់បាន ដោយសារលក់រោមពពែ។*

ពួកគេបល័តពពែរបស់គេទៅ ៨០ គីឡូម៉ែត្រ នៅភាគខាងត្បូងក្នុងការស្វែងរកស្មៅឲ្យវាស៊ី។ គាត់បានចាកចោលដីដែលជាទីកំណើតរបស់ឪពុកគាត់។ ប៉ុន្តែគាត់នឹងធ្វើអ្វីៗគ្រប់បែបយ៉ាង ដើម្បីចៀសវាងការទៅរស់ក្នុងទីក្រុង ដែលទីនោះ ជាជោគវាសនាថ្មីរបស់អ្នកគង្វាលដទៃទៀត ដែលកំពុងបុះញ៉មចំពោះភាពហិនហោចពីការប្រើប្រាស់ដីហួសហេតុពេកក្នុងឧស្សាហកម្មលក់រោមពពែនេះ។ គេឃើញអតីតជនគង្វាលសត្វពនេចរជាច្រើននៅក្នុងទីប្រជុំជននានារបស់តំបន់ Alashan ដែលនៅទីនោះ ពួកគេរស់ក្នុងភាពរយីករយាកដោយដាំស្រូវសំឡី និងចញ្ចឹមគោយកទឹកដោះ។ សម្រាប់ពួកគង្វាលពនេចរ ការងារបែបនេះប្រៀបបានទៅនឹងការងារធ្វើលើតុក្នុងការិយាល័យដែរ។

លោក Shatar និយាយថា៖ "យើងស្គាល់តែជីវិតជាអ្នកគង្វាលសត្វអស់ជាច្រើនជំនាន់មកហើយ ដូច្នេះយើងមិនអាចរស់នៅក្នុងជីវិតកសិករធ្វើស្រែបានទេ"។

នៅខែវិច្ឆិកា គឺពីរខែបន្ទាប់ពីគាត់បានចាកចេញពីដីរបស់គាត់ លោក Shatar ក៏បានវិលត្រឡប់មកវិញ។ គាត់បានតាំងចិត្តរួចហើយថានឹងមិនឲ្យធ្លាក់ខ្លួនដូចអ្នកគង្វាលសត្វដទៃទៀតរស់ក្នុងទីប្រជុំជនទេ។ រោមពពែជាមុខរបរមួយល្អពេក ដែលពិបាកនឹងបោះបង់ចោលណាស់។

# ជំពូក ៨ នយោបាយ និង រដ្ឋាភិបាល

សម្តីរបស់ អុត កូនប្រុសរបស់នាង ផ្លយ ក្នុងប្រលោមលោក Four Reigns និពន្ធដោយ គុក្រឹត ប្រាមោជ (Kukrit Pramoj)

*នយោបាយជួយលាតសន្ធឹងព្រំដែនគំនិត ដកចេញនូវនាំងឧបសគ្គទាំងឡាយ ហើយអញ្ជើញមនុស្សគ្រប់រូបឲ្យចូលប្រឡូកជាមួយវា ។ ក្នុងទីលាននយោបាយ ទាហានម្នាក់ និងមេធាវីម្នាក់ក៏អាចជួបគ្នាបានដែរ ដើម្បីធ្វើការឆ្លោះទៅរកប្រយោជន៍រួមសម្រាប់ប្រទេសយើងទាំងអស់គ្នា ឬមួយដើម្បីបញ្ចេញការខ្វែងគំនិតថា តើស្អីទៅជាប្រយោជន៍រួមនោះ ហើយប្រយុទ្ធគ្នាដល់អវសានជីវិត ដើម្បីការពារអ្វីមួយដែលគេចាត់ទុកថាជាការត្រឹមត្រូវ ។ នយោបាយផ្តល់ដល់ជនគ្រប់រូបនូវសិទ្ធិក្នុងការគិតផ្ទុយ សិទ្ធិក្នុងការជឿជាក់របស់ខ្លួនទៅលើអ្វីមួយ មិនថាជននោះជាទាហាន មេធាវី ព្រះអង្គម្ចាស់ ឬជនសាមញ្ញនោះឡើយ ។ អ្នកខ្លះនិយាយថា នយោបាយ គឺជាវឌ្ឍនភាព អារ្យធម៌រុងរឿងនៃមនុស្សលោក អំពីយុត្តិធម៌ ដូច្នេះវាជាវត្ថុមួយគួរឲ្យស្ញប់ស្ញែងអស្ចារ្យណាស់ តែមនុស្សផ្សេងទៀតអាចប្រាប់អ្នកថា នយោបាយជាមុខរបរមួយដ៏គគ្រិច ។ វាស្រេចតែអ្នកទេ បើអ្នកចង់លើកទឡ្ហីករណ៍គាំទ្រ ឬប្រឆាំងខាងណាមួយ ។ នយោបាយអាចនាំមកនូវយសសក្តិ ហើយវាក៏អាចបំផ្លាញគុណធម៌ផងដែរ ។ នយោបាយអាចបណ្តុះឲ្យអ្នកមានឧត្តមគតិខ្ពង់ខ្ពស់ផ្តល់ឲ្យអ្នកនូវសេរីភាព និងឱកាសដើម្បីបំពេញសេចក្តីប្រាថ្នារបស់ខ្លួន ដើម្បីរីករាយជាមួយភាពពេញចិត្តនឹងធ្វើម្ចាស់ដោគវាសនារបស់ខ្លួនជាជាងមានម្ចាស់មកចាត់ចែងជីវិតជំនួសឲ្យអ្នក ។ នយោបាយក៏អាចធ្វើឲ្យបងប្អូនប្រុស ឬឪពុក និងកូន មើលមុខគ្នាមិនត្រង់ដែរ ។ ឃាតកម្ម ត្រូវបានគេប្រព្រឹត្តឡើងក្នុងនាមនយោបាយ តែក្នុងនាមនយោបាយនេះ ក៏មានទង្វើប្រកបដោយកិត្តិគុណធំៗជាច្រើន ដែលត្រូវបានគេសម្រេចជូនមនុស្សជាតិដែរ ។ មិត្តភាពស្ថិតស្ថេរយូរអង្វែង ត្រូវបានគេកសាងតាមរយៈនយោបាយ ហើយតាមរយៈនយោបាយនេះ អ្នកក៏អាចបាត់បង់ទៅវិញនូវមិត្តសម្លាញ់ ប្រាក់កាស សេរីភាពទាំងអស់ និងជីវិតរបស់ខ្លួនផងដែរ ។*

ការយកព័ត៌មានអំពីនយោបាយ និងរដ្ឋាភិបាល គឺជាបេះដូង និងព្រលឹងការងាររបស់ភ្នាក់ងារសារព័ត៌មានភាគច្រើន ពីព្រោះថាអ្នកណាគ្រប់គ្រងយើង តើគេគ្រប់គ្រងប្រទេសដូចម្តេច តើគេបែងចែកធនធានសាធារណៈដូចម្តេច - ទាំងអស់នេះសុទ្ធជាសំណួរសំខាន់ប្រចាំថ្ងៃសម្រាប់ជនគ្រប់រូប ។ រដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋានមានអំណាចឥទ្ធិពលខ្លាំងណាស់មកលើរបៀបរស់នៅរបស់យើង ក្នុងនោះ មានដូចជាការកំណត់ថ្លៃឥវ៉ាន់លើទីផ្សារ ការប្រមូលពន្ធដារ និងការសាងសង់សាលារៀន និងផ្លូវថ្នល់ជាដើម ។ រដ្ឋាភិបាលជាអ្នកផ្តល់នូវសេវាសាធារណៈដល់រាស្ត្រអនុវត្តន៍ច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈ ការពារសិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋ និងមានកម្លាំងប្រដាប់អាវុធសម្រាប់ការពារប្រទេស ។ រដ្ឋាភិបាលក៏ជាអ្នកធ្វើនិយតកម្មជំនួញ និងឧស្សាហកម្ម សាលារៀន សាកលវិទ្យាល័យ និងអាជីពជាច្រើនទៀតផងដែរ ។

នយោបាយជា **សិល្បៈ និងវិទ្យាសាស្ត្រ** នៃការងារអភិបាលកិច្ច ។ វាក៏អាចមានន័យថាជាការធ្វើយុទ្ធនាការបោះឆ្នោតដណ្តើមតំណែងសាធារណៈមួយ ដែលដំណើរការនេះមានការត្រួតពិនិត្យពិច្ច័យខ្លាំងនៅក្នុងប្រទេសមួយចំនួន ។

ការដែលត្រូវជម្រាបប្រជាជនឲ្យដឹងអំពីគោលនយោបាយថ្មីៗ ការដាក់រដ្ឋាភិបាលឲ្យមានគណនេយ្យភាពចំពោះទង្វើរបស់ខ្លួន ការរួមចំណែកធ្វើឲ្យពលរដ្ឋទទួលបានព័ត៌មានគ្រប់គ្រាន់អំពីការបោះឆ្នោត - ទាំងអស់នេះសុទ្ធជាកាតព្វកិច្ចខ្ពស់របស់អ្នកសារព័ត៌មាន។ យើងទទួលស្គាល់ថាប្រព័ន្ធនយោបាយនៅក្នុងតំបន់នេះមានភាពខុសៗគ្នា ហើយប្រទេសនីមួយៗមានប្រវត្តិ និងប្រពៃណីផ្សេងគ្នាអំពីរបៀបថាតើប្រព័ន្ធផ្សព្វផ្សាយធ្វើសេចក្តីរាយការណ៍ព័ត៌មានអំពីកិច្ចការរដ្ឋាភិបាលដូចម្តេចខ្លះ។ ក្នុងស្នារតីនេះ យើងសូមផ្តល់អនុសាសន៍ខ្លះៗអំពីរបៀបយកព័ត៌មានលើប្រធានបទទាំងនេះ។

## ស្វែងយល់ពីដំណើរការប្រព័ន្ធនយោបាយ និងរដ្ឋាភិបាល

ប្រទេសភាគច្រើនមានស្ថាប័ននយោបាយផ្លូវការដែលបង្កើតដោយរដ្ឋធម្មនុញ្ញ ឬមួយក៏កើតនៅចំណុចសំខាន់ណាមួយនៃប្រវត្តិសាស្ត្ររបស់ខ្លួន ដូចជាឯករាជ្យភាពពីពួកអាណានិគមកាន់កាប់ ឬក៏នៅពេលដែលគេលុបបំបាត់ចោលរាជានិយមផ្តាច់ការក្នុងប្រទេសរបស់ខ្លួនរួចមក។ ស្ថាប័នទាំងនោះត្រូវបានគេហៅថាជា **ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិប្បញ្ញត្តិ** និង**ស្ថាប័នតុលាការ**។ បន្ថែមលើនោះនៅមានផ្នែក**បំរើសេវាស៊ីវិល** (ដែលជារឿយៗ ត្រូវបានគេចាត់ទុកថាជាផ្នែកមួយរបស់នីតិប្រតិបត្តិដែរ) ដែលតាមដានមើលគោលនយោបាយរបស់រដ្ឋ រួមមាន ច្បាប់ដែលត្រូវបានអនុម័តរួចដោយរដ្ឋាភិបាលមុនៗផង។ ក្នុងន័យនេះ បុគ្គលិកសេវាស៊ីវិលជាអ្នកបំរើឯករាជ្យរបស់ប្រជាជាតិ តែមិនមែនជាឧបករណ៍របស់រដ្ឋាភិបាលទេ។ ប្រទេសជាច្រើនក៏មានរចនាសម្ព័ន្ធនយោបាយតំបន់ និងមូលដ្ឋានផងដែរ។

អ្នកយកព័ត៌មានតាមវិស័យត្រូវតែយល់ដឹងថាតើគេធ្វើច្បាប់របៀបម៉េច និងអ្វីខ្លះ ដែលជាតួនាទីរបស់ស្ថាប័ននីតិប្បញ្ញត្តិ ។ ប្រទេសជាច្រើនមានស្ថាប័ននីតិប្បញ្ញត្តិ ជាន់ទាប (ដូចជា សភា រដ្ឋសភាជាតិ ឬសភាតំណាង) ដែលក្នុងនោះ សមាជិករបស់វាជាទូទៅត្រូវបានជ្រើសតាំងដោយផ្ទាល់ពីសំណាក់ប្រជាជនតាមរយៈការបោះឆ្នោត។ គេច្រើនហៅសភាជាន់ខ្ពស់ថាជាព្រឹទ្ធសភា ដែលក្នុងនោះសមាជិកអាចត្រូវបានគេបោះឆ្នោតជ្រើសតាំង ឬក៏ត្រូវបានគេតែងតាំងជាសមាជិក។ សភាជាន់ទាបជាអ្នកអនុម័តច្បាប់ និងថវិកាប្រចាំឆ្នាំនៅពេលដែលសភាជាន់ខ្ពស់អាចមានការទទួលខុសត្រូវផ្សេងពីនេះបន្តិច ដូចជាអនុម័តសវនាការជាមួយប្រធានាធិបតី ឬក៏ផ្ទៀងផ្ទាត់ច្បាប់ពីសភាជាន់ទាប។

ប្រមុខរដ្ឋាភិបាល ដែលធម្មតាជានាយករដ្ឋមន្ត្រីអាចមានអំណាចចេញក្រឹត្យ ឬអនុក្រឹត្យដោយផ្ទាល់ពីខុទ្ទកាល័យរបស់គាត់ ឬតាមរយៈក្រុមប្រឹក្សារដ្ឋមន្ត្រី។ ដូច្នេះ អ្នកត្រូវតែដឹងថាតើទាំងអស់នេះមានដំណើរការដូចម្តេចខ្លះ រួមទាំងគោលការណ៍ និងបទបញ្ញត្តិទាំងឡាយស្តីអំពីការប្រព្រឹត្តទៅរបស់រដ្ឋាភិបាល។

## ស្វែងយល់ដូចម្តេចបានជាប្រព័ន្ធនយោបាយ និងរដ្ឋាភិបាលមិនដំណើរការ

ភាគច្រើនអ្នកសារព័ត៌មានស្គាល់រចនាសម្ព័ន្ធផ្លូវការរបស់រដ្ឋាភិបាល។ តែអ្នកយកព័ត៌មាននយោបាយដែលចំណាប់នោះ គឺគេដឹងថាតើរចនាសម្ព័ន្ធរដ្ឋាភិបាលនោះប្រព្រឹត្តទៅដូចម្តេចខ្លះ។ ការប្រព្រឹត្តទៅរបស់រដ្ឋាភិបាលអាចខុសគ្នាស្រឡះទៅនឹងការដែលគេបង្កើតវាឡើង ឬក៏ទៅនឹងអ្វីដែលរៀបរាប់

ក្នុងរដ្ឋធម្មនុញ្ញថាជាតួនាទីរបស់វា។ ឧទាហរណ៍ ក្នុងន័យផ្លូវការ នគរបាល និងកងកម្លាំងយោធា ត្រូវបានគេចាត់ទុកថានៅដោយឡែកពីនយោបាយ និងអ្នកនយោបាយ។ តែជាញឹកញាប់ គេឃើញមានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងកងកម្លាំងប្រដាប់អាវុធ និងអ្នកនយោបាយ។ ជារឿយៗ បុគ្គលិកស៊ីវិលជាន់ខ្ពស់ និងមន្ត្រីយោធា និងនគរបាល ត្រូវបានគេផ្លាស់ប្តូររៀងរាល់ពេលមានការផ្លាស់ប្តូរអ្នកនយោបាយ។ ពិតណាស់ យើងដឹងថានៅប្រទេសខ្លះការផ្លាស់ប្តូរគ្រាន់តែជារឿងដដែលៗប៉ុណ្ណោះ។

ជាញឹកញាប់ ស្ថាប័ននយោបាយត្រូវបានស្រូបឲ្យទៅនៅក្រោមទម្រង់ជាប្រពៃណី និងប្រវត្តិសាស្ត្រ ដែលមានស្រាប់នៃវប្បធម៌ និងអង្គការចាត់តាំងនយោបាយ ហើយវាក៏ត្រូវសម្របសម្រួលខ្លួនទៅតាមស្ថានភាពនោះដែរ។ អ្វីមួយជាប្រការសំខាន់ខ្លាំងដែរនោះ គឺ**ភក្តីភាពតាមតំបន់**។ ចូរនាំគ្នាអានសៀវភៅប្រវត្តិសាស្ត្ររបស់ខ្លួន និងការវិភាគនយោបាយបច្ចុប្បន្នភាព ដើម្បីស្វែងយល់ចំណុចទាំងនេះ។ ឧទាហរណ៍ នៅសហរដ្ឋអាមេរិក គេបានគិតគូរចំណុចនេះ ពេលដែលគេបង្កើតប្រព័ន្ធសហព័ន្ធរបស់រដ្ឋាភិបាល ដោយផ្តល់ឲ្យរដ្ឋនីមួយៗនូវលទ្ធភាពគ្រប់គ្រាន់ក្នុងការសម្រេចកិច្ចការក្នុងរដ្ឋរបស់ខ្លួន និងក្នុងរបៀបដែលគេជ្រើសតាំងអ្នកនយោបាយថ្នាក់ជាតិផងដែរ។ នៅប្រទេសខ្លះទៀត គេមិនខ្វល់ជាមួយនឹងភាពខុសគ្នាទេ។ ជាញឹកញាប់ ភក្តីភាពតំបន់នេះដើរទន្ទឹមគ្នាជាមួយភាសា រីឯភាពផ្ទុយគ្នាខាងសាសនា និងជាតិសាសន៍មិនសូវជាច្បាស់ក្រឡែតណាស់ណាទេ តែវាក៏មានឥទ្ធិពលខ្លាំងដែរក្នុងរបៀបដែលប្រជាជនសម្តែងជម្រើសនយោបាយ និងក្នុងរបៀបបោះឆ្នោតរបស់គេ។ ពេលខ្លះរបៀបចាស់ក្នុងការចាត់ចែងជីវិតនយោបាយត្រូវសម្របខ្លួនទៅតាមរបៀបថ្មីវិញ។ មានគណបក្សនយោបាយជាច្រើននៅអនុវត្តន៍ប្រព័ន្ធជាប្រពៃណីដែលនិយមញាតិនៅឡើយ ដែលក្នុងការអនុវត្តនោះ ស្តេចត្រាញ់តាមមូលដ្ឋានរំលែកការនិយមពេញចិត្តឲ្យតែអ្នកមានភក្តីភាពជាមួយគេតែប៉ុណ្ណោះ។ ទាំងអស់នេះគ្រាន់តែជាឥទ្ធិពល និងកម្លាំងលាក់លៀមដែលនៅមានជ្រៀតជ្រែកក្នុងប្រព័ន្ធនយោបាយទំនើបក្នុងប្រទេសមួយចំនួននៅឡើយ ដូច្នេះចូរតាមដានវាឲ្យបានជាប់លាប់ដើម្បីបង្កើនការយល់ដឹងរបស់ខ្លួន។

អ្នកយកព័ត៌មានឈ្មោះ Kong Rithdee របស់កាសែត Bangkok Post បានសរសេរអត្ថបទគួរឲ្យជក់ចិត្តមួយនេះ ដែលបានលាតត្រដាងឲ្យឃើញអំពីទំនាក់ទំនងញាតិនិយមរវាងសមាជិកសភា និងអ្នកបោះឆ្នោត។ អត្ថបទនេះនិយាយអំពីជីវិតអតីតកាលរបស់អ្នកនយោបាយជើងចាស់ម្នាក់ឈ្មោះ នេវីន ឈីដឆុប (Newin Chidchob)៖

*កាលពី ១៤ ឆ្នាំ មុនពេលដែលគាត់ជាសមាជិកសភាមានកេរ្តិ៍ខាងនិយាយមិនសំចៃមាត់ លោក នេវីន ឈីដឆុប បានផ្តល់បទសម្ភាសន៍មួយដល់ទស្សនាវដ្តី Sunday Magazine នៃកាសែត Bangkok Post អំពីឧប្បត្តិហេតុមួយដែលធ្វើឲ្យគាត់ កាលនោះអាយុ ១២ ឆ្នាំ តាំងចិត្តថានឹងមិនក្លាយខ្លួនជាអ្នកនយោបាយទេ។*

*លោកនិយាយថា៖ "នៅតាមខេត្ត ប្រជាជននាំគ្នាជឿថាតំណាងរាស្ត្រម្នាក់ៗ ត្រូវមានការទទួលខុសត្រូវបុគ្គលចំពោះមណ្ឌលបោះឆ្នោតនីមួយៗ។ បើពលរដ្ឋណាម្នាក់អត់មានលុយបង់ថ្លៃឈ្នួលរថយន្ត អ្នកឯងជាតំណាងរាស្ត្រ ត្រូវតែចេញលុយឲ្យគេ ឬបើមានកូនអ្នកស្រុកណាម្នាក់ឈឺ អ្នកត្រូវចេញលុយឲ្យគេទៅព្យាបាលជំងឺ។ បើអ្នកឯងមិនឲ្យលុយទេ អ្នកនឹងទទួលការប្រមាថបំពាន។ បើអ្នកឲ្យតិចពេក អ្នកក៏នឹងនៅតែទទួលការប្រមាថបំពាន។ បើអ្នកមិននៅទេ ប្រពន្ធរបស់អ្នកត្រូវតែចេញមុខជំនួស។*

*"មានថ្ងៃមួយនោះ បុរសម្នាក់បានមកជួបម្តាយរបស់ខ្ញុំ (ដោយឪពុករបស់ខ្ញុំ គឺតំណាងរាស្ត្រ*

*Chai Chidchob មិននៅផ្ទះ)។ បន្ទាប់ពីជជែកជាមួយបុរសនោះបានប៉ុន្មាននាទីមក ម្ដាយខ្ញុំក៏រត់ឡើងលើផ្ទះ។ ខ្ញុំទៅតាមពីក្រោយគាត់ ហើយឃើញគាត់កំពុងយំ។ ម្ដាយខ្ញុំនិយាយប្រាប់ខ្ញុំថា គាត់បានឲ្យបុរសនោះនូវលុយ ១០០ បាត តែបុរសនោះទៅជាចោទម្ដាយខ្ញុំថាបានមាក់ងាយលើរូបគាត់ទៅវិញនៅពេលដែលគាត់មកផ្ទះរបស់ខ្ញុំ គឺគ្រាន់តែដើម្បីសុំលុយតែប៉ុណ្ណោះ។ ដប់ប្រាំនាទីក្រោយមក ម្ដាយខ្ញុំតាំងស្មារតីឡើងវិញ ហើយចុះទៅជជែកជាមួយបុរសនោះម្ដងទៀត។*

*"សម្រាប់ខ្ញុំ វាពិតជារឿងដ៏សែនឲ្យឈឺចាប់ណាស់។ ខ្ញុំនឹងមិនភ្លេចហេតុការណ៍នេះជាដាច់ខាត។ ខ្ញុំសួរខ្លួនឯងថា តើគ្រួសាររបស់ខ្ញុំគួរទទួលបានការប្រព្រឹត្តមកលើបែបនេះឬ? ហេតុអ្វីបានជាម្ដាយរបស់ខ្ញុំត្រូវទទួលយកនូវរឿងអកុសលបែបនេះ? នោះហើយជាខណៈដែលខ្ញុំសម្រេចចិត្តថាខ្ញុំនឹងមិនចូលធ្វើនយោបាយទេ"។*

*ពិតណាស់ អ្វីៗមិនដូចអ្វីដែលគាត់បានព្រៀងទុកនោះទេ។ លោក Newin ដែលឪពុករបស់គាត់ដាក់ឈ្មោះឲ្យដូចឈ្មោះឧត្តមសេនីយ៍យោធា Ne Win នៅប្រទេសមីយ៉ាន់ម៉ា បានធំដឹងក្ដីក្នុងគ្រួសារព្រឹទ្ធាចារ្យមួយរូប ដែលជាអ្នកនយោបាយសំខាន់ជាងគេម្នាក់ក្នុងស្រុកប៊ូរីរ៉ាំ។ បន្ទាប់ពីជួយឪពុកគាត់ក្នុងការកាន់តំណែងក្នុងមណ្ឌលនេះអស់ ១០ ឆ្នាំ លោក Newin ពេលមានអាយុ ២៨ ឆ្នាំ ក៏បានជ្រៀតខ្លួនចូលឆាកនយោបាយថៃ - តែលើកនេះ គាត់ប្រហែលជាមិនមែនធ្វើផ្ទុយនឹងចេតនារបស់គាត់ទេ។*

## មើលឲ្យហួសពីនយោបាយផ្លូវការ

អ្នកយកព័ត៌មានចំណានៗផ្នែកនយោបាយតែងមើលហួសពីស្ថាប័ននយោបាយផ្លូវការ ដើម្បីរកសកម្មភាពនយោបាយ និងរឿងល្អៗមកសរសេរ។ ក្នុងប្រទេសជាច្រើន ចលនានយោបាយភាគច្រើនតែងកើតចេញពី**បណ្ដាក្រុមមិនមែននយោបាយ** រួមមានសហជីពកម្មករ អង្គការសាសនា ស្ថាប័នអប់រំ ឬសមាគមវប្បធម៌ ឬកាសាក៏មានដែរ។ ខ្លះក្នុងចំណោមក្រុមទាំងនេះរីកសកម្មភាពក្លាយខ្លួនជាក្រុមដាក់សម្ពាធលើរដ្ឋាភិបាល ឬជាចលនារំដោះ ហើយក្រោយមកក្លាយជាគណបក្ស និងជារដ្ឋាភិបាលតែម្ដង។ ក្រុមខ្លះក៏បែរគោលដៅក្លាយទៅជាក្រុមឧទ្ទាម ឬជាក្រុមភេរវកម្មទៅវិញ។ ប៉ុន្តែ បើសិនជាអ្នកនឹងធ្វើសេចក្ដីរាយការណ៍ព័ត៌មាននយោបាយមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ វាជាប្រការចាំបាច់ដែលអ្នកត្រូវតែដឹងអំពីប្រវត្តិរបស់ក្រុមទាំងនេះ និងចំណងទាក់ទិនរបស់ពួកគេជាមួយប្រជាជន និងអ្នកនយោបាយក្នុងស្រុក។ នេះមានន័យថា អ្នកចាំបាច់ត្រូវចេញពីរដ្ឋធានី ពីស្ថាប័នរដ្ឋាភិបាលផ្លូវការ ទៅកាន់ខេត្ត និងទីជនបទ ដើម្បីស្វែងរកមើលរឿងនយោបាយផ្សេងទៀតមកសរសេរ។

## កុំរំលងនយោបាយថ្នាក់មូលដ្ឋាន

មធ្យោបាយមួយក្នុងការមើលឲ្យហួសពីនយោបាយផ្លូវការ គឺសរសេររឿងអំពីនយោបាយមូលដ្ឋាន។ មានអ្នកយកព័ត៌មានច្រើននាក់ពេកដែលផ្ដោតតែទៅលើនយោបាយថ្នាក់ជាតិ ហើយព្រងើយកន្ដើយនឹងអ្វីៗ ដែលកំពុងកើតមាននៅសភាខេត្ត ឬតំបន់ ឬក៏នៅក្នុងក្រុមប្រឹក្សា និងស្ថាប័នថ្នាក់ភូមិផងដែរ។ ជួនកាល ស្ថាប័នទាំងនេះជាស្ថាប័នដែលត្រូវបានជ្រើសតាំងតាមការបោះឆ្នោត។ ជួនកាល មានតែមេដឹកនាំថ្នាក់មូលដ្ឋានទេ ដែលត្រូវបានជ្រើសតាំងដោយការបោះឆ្នោត។ ជួនកាលគ្មានការបោះឆ្នោតតែម្ដង។ ប៉ុន្តែនេះមិនមែនបានន័យថាគ្មានកិច្ចការនយោបាយកំពុងកើតមាន ឬ



*តើគម្រោងសាងសង់ល្បីឈ្មោះទាំងអស់ សុទ្ធតែបម្រើផលប្រយោជន៍ជាតិ ឬយ៉ាងណា?*

រឿងនយោបាយណាដែលអាចយកមកសរសេរបាននោះទេ។ អ្នកស្រុកក្នុងមូលដ្ឋានអាចមានការភ្ញាក់ផ្អើល ឬក៏មានការមន្ទិលសង្ស័យផងនៅពេលដែលគេឃើញអ្នកសារព័ត៌មានដើររករឿងក្នុងតំបន់របស់គេយកមកសរសេរ ដូច្នេះអ្នកចាំបាច់ត្រូវកសាងឲ្យបាននូវការជឿទុកចិត្ត និងប្រភពទាក់ទងនៅក្នុងចំណោមពួកគេជាមុនសិន មុននឹងអ្នកចាប់ផ្ដើមសរសេរអំពីពួកគេ។

ធ្វើដូច្នេះ វាដូចទៅនឹងធ្វើការស្រាវជ្រាវដោយក្រុមដែលផ្ដោតលើប្រធានបទដោយឡែកៗ។ ក្រុមហ៊ុនជាច្រើនដែលមានផលិតផលត្រូវលក់ប្រើប្រាស់ក្រុមតូចៗនៃអ្នកប្រើប្រាស់ ដើម្បីប្រមូលព័ត៌មានលម្អិតអំពីទីផ្សាររបស់គេ។ ក្រុមហ៊ុនទាំងនោះតែងជួបជាមួយអ្នកប្រើប្រាស់ ដើម្បីធ្វើការសួរនាំសាកល្បងផលិតផលរបស់គេ ហើយប្រមូលមកវិញនូវព័ត៌មាន ដើម្បីយកមកកែសម្រួលផលិតផលរបស់គេ។ គណបក្សនយោបាយដែលមានធនធានច្រើនក៏ធ្វើ ដូច្នេះដែរ នៅពេលដែលគេចង់ស្វែងយល់ថាតើអ្នកបោះឆ្នោតគិតដូចម្ដេចអំពីគោលនយោបាយរបស់គណបក្ស។ ដូចគ្នានឹងក្រុមផ្ដោតលើប្រធានបទដោយឡែកៗដែរ អ្នកយកព័ត៌មាននយោបាយគួរព្យាយាមចូលរួមកិច្ចប្រជុំរបស់ប្រជាជនសាមញ្ញឲ្យបានច្រើនតាមតែអាចធ្វើទៅបាន ដើម្បីយល់ឲ្យបានស៊ីជម្រៅនូវគំនិតរបស់ពួកគេ។ ចូរកត់ត្រាទុក តែមិនមែនបានន័យថា អ្នកត្រូវតែ សរសេររឿងអំពីកិច្ចប្រជុំទាំងនោះរហូតទេ។ តែក្រោយមកទៀត អ្នកនឹងអាចសរសេរបាន កាលណាអ្នកយល់បញ្ហាស៊ីជម្រៅបានច្បាស់លាស់ហើយ។

## តាមឃ្លាំមើលការស្រាវជ្រាវ

ជួនកាល ការសិក្សាស្រាវជ្រាវថ្នាក់មូលដ្ឋានបែបនេះ ត្រូវបានធ្វើឡើងដោយពួកបណ្ឌិតសភា។ ដូច្នេះ អ្នកគួរអភិវឌ្ឍន៍ឲ្យបានច្រើននូវប្រភពទាក់ទងក្នុងសាកលវិទ្យាល័យ (មិនត្រឹមតែសាកលវិទ្យាល័យក្នុងរដ្ឋធានីទេ) និងនៅតាមអង្គការស្រាវជ្រាវ និងអង្គការមិនមែនរដ្ឋាភិបាល។ យកល្អ ជួបជាមួយអ្នកស្រាវជ្រាវទាំងនោះ ហើយជជែកជាមួយពួកគេឲ្យបានយូរអំពីអ្វី ដែលពួកគេទើបនឹងបានធ្វើបេកគំហើញថ្មីៗ។ សួរគេ តើអ្នកអាចទៅជាមួយពួកគេហើយស្ដាប់ការសម្ភាសន៍ក្នុងការស្រាវជ្រាវនោះ។ ជាថ្មីម្ដងទៀត អ្នកមិនមានភាពចាំបាច់ថាត្រូវតែសរសេរអំពីការសម្ភាសន៍ទាំងអស់នោះទេ។ ឱកាសនៅមានសម្រាប់សរសេររឿងអំពីគម្រោងស្រាវជ្រាវដែលកំពុងតែដំណើរការ និងសរសេរម្ដងទៀតពេលណាគេប្រកាសរបកគំហើញនៃការស្រាវជ្រាវនោះ។ មាន

ការសិក្សាស្រាវជ្រាវច្រើនណាស់ ដែលត្រូវបានគេតម្កល់ចោលលើធ្នើបណ្ណាល័យក្នុងបន្ទប់របស់សាស្ត្រាចារ្យ ដែលគ្មានអ្នកណាដឹងថាក្នុងនោះវានៅមានអ្វីខ្លះ ដែលមហាជនមិនទាន់បានដឹងនៅឡើយ។

នៅប្រទេសមួយចំនួន មានក្រុមហ៊ុន ឬអង្គការដែលជំនាញខាងធ្វើការស្ទាបស្ទង់មតិ។ គេប្រើប្រាស់អ្នកសម្ភាសន៍ចំនួនច្រើននាក់ ហើយធ្វើការជ្រើសរើសអ្នកផ្ដល់សម្ភាសន៍មួយក្រុម (**គំរូអ្នកផ្ដល់សម្ភាសន៍**) ដែលគំនិតរបស់ពួកគេឆ្លុះបញ្ចាំងអ្វីដែលមនុស្សភាគច្រើនបានកំពុងគិត (តាមធម្មតាគំរូអ្នកផ្ដល់សម្ភាសន៍មានយ៉ាងតិច ៤០០ នាក់)។ ការសម្ភាសន៍ស្ទាបស្ទង់មតិបែបនេះ អាចមានភាពជាក់លាក់ល្អ ជាពិសេសសម្រាប់លទ្ធផលការបោះឆ្នោត តែក៏មានពេលដែលលទ្ធផលនោះខុសដែរ។ អង្គការ ឬក្រុមហ៊ុនខ្លះធ្វើការស្ទាបស្ទង់អំពីឥរិយាបថរបស់ប្រជាជនចំពោះគោលនយោបាយរបស់គណបក្ស។ ការស្ទាបស្ទង់បែបនេះ អាចធ្វើជារឿងបានល្អ តែអ្នកក៏ត្រូវតែអានរបាយការណ៍បែបនោះឲ្យបានល្អិតល្អន់ផង ដើម្បីបង្រៀនខ្លួនឯងឲ្យយល់អំពីគំនិតរបស់ប្រជាជនទាំងនោះ។

## ឃ្លាំមើលនិន្នាការ និងតារាកំពុងរះ

កាលណាអ្នកបានអប់រំខ្លួនឲ្យបានយល់អំពីការស្រាវជ្រាវ និងព័ត៌មាននានា ហើយចូរប្រុងប្រយ័ត្នចំពោះលទ្ធភាពនៃការលេចឡើងនូវ**គោលគំនិត និងបុគ្គលនយោបាយថ្មីៗ**។ នយោបាយ និងគំនិតនយោបាយមិនមែននៅនឹងថ្កល់ឥតប្រែប្រួលនោះទេ។ និស្សិតច្រើនតែជាមនុស្សដំបូងគេដែលក្រសោបយកគំនិតថ្មីៗ ដូច្នេះចូរតាមដានមើលការពិភាក្សាដេញដោលនៅតាមសាកលវិទ្យាល័យ។ តែនិស្សិតមិនមែនជាក្រុមមនុស្សតែមួយដែលចេះចាប់យកគំនិតថ្មីទេ។ ពេលខ្លះ ក៏មានក្រុមពួកក្នុងគណបក្សដែលមានផែនការប្ដូរទិសដៅរបស់បក្សដែរ។ សូម្បីតែនៅក្នុងប្រព័ន្ធឯកបក្សក៏មានភាគីច្រើនដែរ។ ពេលខ្លះមន្ត្រីក្មេងៗក្នុងឃោជាអាចអភិវឌ្ឍន៍បាននូវគំនិតថ្មីៗ។ ពេលខ្លះ អ្នកនយោបាយគួរឲ្យកត់សម្គាល់ម្នាក់ស្រាប់តែក្លាយជាជនលេចធ្លោ ប៉ុន្តែមិនត្រូវទាន់បានមនុស្សក្រៅតំបន់មូលដ្ឋានរបស់គាត់ស្គាល់នៅឡើយទេ។ មានមនុស្សមួយចំនួនដែលបានជួបលោក បារ៉ាក់ អូបាម៉ា កាលពីច្រើនឆ្នាំមុន ហើយនិយាយថា៖ "ថ្ងៃណាមួយ មៀមួយនេះនឹងធ្វើជាប្រធានាធិបតីអាមេរិកមិនខាន"។ ពិតណាស់ ទាំងអស់នេះសុទ្ធតែជារបស់ដែលពិបាករកឲ្យបាន និងសរសេរ។ ប៉ុន្តែ វាជាចំណុចដែលជាទីចាប់-អារម្មណ៍ខ្លាំងដល់អ្នកអាន និងគួរឲ្យពេញចិត្តនឹងសរសេរណាសសម្រាប់អ្នកសារព័ត៌មាន។

កាលណាមានពុទ្ធិយល់ដឹងបែបនេះ មានន័យថា អ្នកអាចបន្ថែមបរិបទបែបប្រវត្តិសាស្ត្រ និងអន្តរជាតិទៅក្នុងរឿងរបស់អ្នក។ អ្វីដែលកើតថ្ងៃនេះប្រហែលជាត្រូវគេយល់បានកាន់តែច្បាស់ថែមទៀត បើយើងអាចយោងរឿងនេះទៅដល់អ្វីមួយ ដែលកើតឡើងកាលពីមួយឆ្នាំមុន ឬក៏ដប់ឆ្នាំមុន ឬក៏រាប់ជំនាន់កន្លងផុតទៅក៏បានដែរ។ ហើយបើអ្វីមួយដែលមានលក្ខណៈដោយឡែកក្នុងប្រទេសអ្នក គេអាចយល់វាបាន ប្រសិនបើអ្នកប្រាប់ដល់អ្នកអាននូវរឿងប្រហាក់ប្រហែលនេះដែរ ដែលកើតមាននៅប្រទេសជិតខាង ឬនៅប្រទេសឆ្ងាយពីនេះទៀត។

## យកព័ត៌មានអំពីស្ថាប័ននីតិប្បញ្ញត្តិ

អង្គភាពសារព័ត៌មានជាច្រើនចាត់តាំងអ្នកយកព័ត៌មានឲ្យប្រចាំការនៅសភាតែម្ដង។ ក្នុងករណីខ្លះទៀតពួកគេមានការិយាល័យក្នុងអគារសភាដែលពួកគេទៅធ្វើការរាល់ថ្ងៃ។ ពួកគេតាមដាន

ដំណើរការធ្វើច្បាប់ ចាប់តាំងពីដំណាក់កាលព្រាង ដល់ការពិភាក្សាដេញដោល និងរហូតដល់ពេលវាត្រូវបានអនុម័ត និងចុះហត្ថលេខាដោយប្រមុខរដ្ឋ។ សម្រាប់អ្នកយកព័ត៌មាន វាជាការងារគួរឲ្យរំភើប ដោយគេអាចមានវត្តមានក្នុងចំណោមបុរស និងស្ត្រីដែលមានអំណាច។ តាមរយៈនេះហើយដែលពួកគេបង្កើតបាននូវប្រភពទាក់ទងព័ត៌មាន និងផលិតបានរឿងល្អៗ។ ប៉ុន្តែមានគ្រោះថ្នាក់ដែរ ដោយសារថាពេលខ្លះអ្នកសារព័ត៌មានខិតជិតស្និទ្ធស្នាលពេកជាមួយអ្នកធ្វើការក្នុងពិភពនេះ ហើយភ្លេចគិតដល់អ្វីដែលជាចំណាប់អារម្មណ៍ដល់អ្នកអាន។ ពេលខ្លះអ្នកយកព័ត៌មានបែបនេះចាប់ទម្លាប់យកមកប្រើនូវពាក្យឯកទេសក្នុងពិភពនយោបាយមកដាក់ក្នុងការសរសេររបស់ខ្លួន។ អ្នកខ្លះថែមទាំងធ្វើឲ្យខ្លួនកាន់តែពឹងផ្អែកខ្លាំងឡើងៗលើប្រភពទាក់ទងរបស់ខ្លួន រហូតដល់ថា ពួកគេបាត់អស់នូវការវិនិច្ឆ័យជាឯករាជ្យ និងសតិតុល្យភាពរបស់ខ្លួនអស់រលីង។ ផ្លូវល្អបំផុតសម្រាប់ចៀសវាងស្ថានភាពបែបនេះ គឺធ្វើយ៉ាងណាដាក់អ្នកយកព័ត៌មាននយោបាយក្រោមការទទួលខុសត្រូវរបស់និពន្ធនាយកចំណាស់ការនៅឯស្នាក់ការធំឯណោះវិញ។

ការពិភាក្សាដេញដោល ជាប្រភពមួយក្នុងចំណោមប្រភពធំៗសម្រាប់ធ្វើរឿងក្នុងសភា។ ភាគច្រើនការពិភាក្សាដេញដោលអាចវែង ហើយគួរឲ្យធុញ តែវាជួនកាលវាក៏អាចមានទស្សនីយភាព និងការប្រើភាសាគួរឲ្យជក់ចិត្តទៀតផង។ នៅប្រទេសខ្លះម្តងម្កាលក្នុងពេលពិភាក្សាដេញដោលក៏មានការវាយប្រតប់គ្នាផ្ទុះឡើងរវាងសមាជិកសភាពីគណបក្សផ្សេងៗដែរ។ ដូច្នេះ អ្នកយកព័ត៌មានត្រូវតែចេះធ្វើការសម្រេចជ្រើសរើសតើអ្វីសំខាន់ និងគួរឲ្យចាប់អារម្មណ៍ តែវាក៏គ្មានអ្វីខុសដែរក្នុងការសរសេរអំពីការពិភាក្សាក្នុងសភាសម្រាប់បម្រើដល់ផ្នែកកំសាន្ត។ សុន្ទរកថាល្អមួយក្នុងសភា ឬការតពាក្យសម្តីទៅមករវាងសមាជិកសភាពីររូបក្នុងការពិភាក្សា អាចនាំឲ្យផលិតបាននូវរឿងអស្ចារ្យបានផងដែរ។ ធ្វើយ៉ាងណាកត់ត្រាឲ្យបានច្រើន ហើយព្យាយាមសរសេររឿងអំពីការពិភាក្សានេះក្នុងទម្រង់ជាការសន្ទនា ដោយប្រើសម្តីដែលគេនិយាយឆ្លោះផ្តងគ្នាក្នុងពេលប្រជុំនោះ។

សូមជូនអនុសាសន៍មួយចំនួនសម្រាប់ការធ្វើសេចក្តីរាយការណ៍អំពីនីតិប្បញ្ញត្តិ ៖

- កុំនៅចាំទាល់តែច្បាប់ត្រូវបានគេអនុម័តទើបសរសេររឿងអំពីវា។ គួរផ្តល់ព័ត៌មានឲ្យអ្នកអានដឹងភ្លាមៗ ពេលណាដែលច្បាប់មួយត្រូវបានគេស្នើឡើងហើយ តើអ្នកណាខ្លះនឹងទទួលរងផលប៉ះពាល់ពីច្បាប់នោះ ហើយដូចម្តេចខ្លះ។ តើពេលណាទើបច្បាប់នោះចូលជាធរមាន?
- រាយការណ៍ឲ្យគេដឹងថាអ្នកណាជាអ្នកផ្តួចផ្តើមច្បាប់នេះ ហើយហេតុអ្វី និងថាតើអ្នកណាខ្លះដែលគាំទ្រដល់សំណើច្បាប់នេះ។
- រកឲ្យបានប្រតិកម្មពីមនុស្សពីគ្រប់ជ្រុងនៃបញ្ហា ដើម្បីឲ្យអ្នកតាក់តែងច្បាប់អ្នកឡប់ប៊ី និងសាធារណជនបានជ្រាបជាព័ត៌មានគ្រប់គ្រាន់មុននឹងគេធ្វើសេចក្តីសម្រេចចិត្តលើច្បាប់នោះ។

## គោលនយោបាយ និងការឡប់ប៊ី

គួរដឹងថា គោលនយោបាយកម្រត្រូវបានរៀបចំតាក់តែងឡើងទាំងស្រុងដោយនាយករដ្ឋមន្ត្រី ឬមេដឹកនាំជាន់ខ្ពស់ណាតែម្នាក់ឯងណាស់។ តាមធម្មតា គោលនយោបាយជាលទ្ធផលនៃអានុភាពជាច្រើនដែលធ្វើការក្នុងទិសដៅផ្សេងៗគ្នា។ សាកគិតពិចារណាមើលនូវឥទ្ធិពលបុគ្គលិកស៊ីវិលវ័យចំណាស់ៗ ក្រុមបញ្ញវន្ត ប្ដីប្រពន្ធ ឬញាតិសន្ដានដែលជិតស្និទ្ធនឹងមេដឹកនាំវ័យចំណាស់ ក្រុមសង្គមស៊ីវិលប្រទេសជិតខាង និងឧត្តមសេនីយយោធាចំណាស់ៗផង។ នៅពីក្រោយឆាក ការធ្វើច្បាប់មានការឡប់ប៊ី និងការតស៊ូមតិច្រើនណាស់។ ភាគច្រើនវាជាផ្នែកមួយលាក់លៀម តែសំខាន់ក្នុងដំណើរការទាំងមូល។ កាលណាមានប្រភពល្អៗ ហើយបើដឹងថាត្រូវសួរសំណួរណាខ្លះ អ្នកយកព័ត៌មានល្អម្នាក់ អាចលាតត្រដាងឲ្យអ្នកអានដឹងបានថាតើគេធ្វើគោលនយោបាយទាំងនោះដូចម្ដេចខ្លះ។

លើសពីនេះ ការតែងតាំងតាមចំណង់ឲ្យចូលកាន់តំណែងរដ្ឋមន្ត្រី ទៅកាន់បេសកកម្មការទូត ឬតំណែងក្នុងភ្នាក់ងាររដ្ឋាភិបាល តាមធម្មតាជាលទ្ធផលនៃសមយុទ្ធក្រោយឆាក ឬក៏ជាលទ្ធផលនៃការផ្គាប់ចិត្តអ្នកគាំទ្រយូរអង្វែងរបស់ខ្លួន។

អ្វីដែលគួរពិចារណា៖

- អ្នកណាទទួលបានតំណែងអ្វី ហើយដោយហេតុអ្វី?
- តើកិច្ចព្រមព្រៀងបែបណាខ្លះ ដែលគេសម្រេចបាន ដើម្បីបង្កើតរដ្ឋាភិបាលចម្រុះមួយ?
- តើមេដឹកនាំថ្មីមានលក្ខណៈសម្បត្តិអ្វីខ្លះ? សរសេរប្រវត្តិខ្លីៗរបស់ពួកគេ និងអ្វីខ្លះដែលមេដឹកនាំទាំងនោះគ្រោងនឹងធ្វើ

## ថវិកា

អ្នកយកព័ត៌មានត្រូវតែដឹងថាលុយចេញពីប្រភពណាមក ចំនួនប៉ុន្មានត្រូវបានគេបែកវែកទៅតាមក្រសួងរដ្ឋាភិបាល ហើយតើកម្មវិធីអ្វីខ្លះ និងសហគមន៍ណាខ្លះនឹងទទួលបានប្រយោជន៍ពីការបែងចែងថវិកានេះ។ ចម្លើយទៅនឹងសំណួរទាំងនេះច្រើនមានក្នុងថវិការបស់រដ្ឋាភិបាល។

រៀងរាល់ថ្ងៃ យើងម្នាក់ៗបង់ជូនរដ្ឋាភិបាលនូវលុយបន្តិចបន្តួច (នៅប្រទេសខ្លះប្រជាជនអាចបង់ច្រើនជាង)។ ចំណូលបានមកការបង់ពន្ធលើកម្រៃដែលរកបាន ពន្ធលើប្រេងឥន្ធនៈ និងការទិញទំនិញ និងសេវាកម្មនានា។ វាក៏បានមកតាមរយៈយន្តការផ្សេងទៀត ដូចជាការលក់ធនធានធម្មជាតិ (ដូចជាឧស្ម័ន និងប្រេង) និងពីផលចំណេញរបស់**សហគ្រាសកាន់កាប់ដោយរដ្ឋ**។ មានចំណូលទាំងនេះ រដ្ឋាភិបាលអាចសង់ផ្លូវថ្នល់ មន្ទីរពេទ្យ សាលារៀន និងបង់ប្រាក់បៀវត្សរ៍ជូនគ្រូបង្រៀន បុគ្គលិកសុខាភិបាល មន្ត្រីនគរបាល និងទាហាន។ ពេលខ្លះរដ្ឋាភិបាលខ្ចីបុលលុយ ដើម្បីបំពេញសេចក្ដីត្រូវការទាំងអស់នេះ ដោយបញ្ចេញសញ្ញាប័ណ្ណដែលរដ្ឋាភិបាលត្រូវសងវិញពីការប្រមូលពន្ធពេលអនាគត។

ភាពប្រឈមមួយក្នុងចំណោមភាពប្រឈមនានាសម្រាប់មន្ត្រីជាប់ឆ្នោត ឬដែលត្រូវបានតែងតាំង គឺសំណួរថាតើត្រូវធ្វើយ៉ាងណា ដើម្បីប្រមូលចំណូលឲ្យបានគ្រប់គ្រាន់ ហើយសម្រេចថា តើត្រូវបែងចែកវារបៀបម៉េច។ អ្នកណាត្រូវជាប់ពន្ធខ្លះ ហើយជាប់ប៉ុន្មាន? តើប៉ុន្មានពីក្នុងថវិកាគួរឲ្យទៅវិស័យការពារជាតិ ហើយប៉ុន្មានទៅខាងវិស័យអប់រំ និងសេវាសង្គម? តើតំបន់ណាខ្លះនៃប្រទេស ឬទីក្រុងទទួលបានប្រយោជន៍ច្រើនជាងគេពីថវិកា? តួនាទីរបស់អ្នកយកព័ត៌មាន គឺលាតត្រដាងឲ្យគេដឹងឲ្យបាន

ច្រើនតាមតែអាចធ្វើទៅបាននូវការធ្វើសេចក្ដីសម្រេចចិត្តទាំងអម្បាលម៉ានអំពីការបែងចែកថវិកា ហើយថាអ្នកណាខ្លះបញ្ចេញឥទ្ធិពលក្នុងដំណើរការនោះ។

ចូរចងចាំថា៖

- ថវិកាត្រូវបានគេចាត់ទុកជាទូទៅថាជាឯកសារសាធារណៈ តែអ្នកប្រហែលជាត្រូវធ្វើជាមិត្តជាមួយអ្នកណាដែលមានច្បាប់ចម្លងឯកសារថវិកានោះ ហើយសុំគេយកមកសិក្សាមុននឹងសរសេររឿង។
- ថវិកាជាផែនការចំណាយ មិនមែនជាការចំណាយជាក់ស្ដែងទេ។ ការតាមដានការចាយវាយរបស់រដ្ឋាភិបាលអាចនាំមកនូវគំនិតរឿងល្អៗច្រើន ដូចជា អ្នកណាខ្លះទទួលបានកិច្ចសន្យា តម្លៃទឹកប្រាក់ច្រើនៗពីរដ្ឋាភិបាល ឬមួយតើរដ្ឋាភិបាលចាយវាយលើសផែនការលើគម្រោងសាធារណការឬយ៉ាងណា។
- ជានិច្ចកាលត្រូវប្រៀបធៀបថវិកាថ្មីទៅនឹងថវិកាឆ្នាំមុន ដើម្បីឲ្យឃើញថា វានៅខ្វះអ្វីខ្លះ ហើយតើមានអ្វីថ្មីក្នុងនោះ។ ក្រសួងណាខ្លះត្រូវបាត់បង់ថវិកា ហើយតើកម្មវិធីសង្គមណាខ្លះ ដែលត្រូវកាត់បន្ថយ? តើមានគម្រោងសាធារណៈណាខ្លះដែលគេបានដាក់ក្នុងរបៀបវារៈថវិកាថ្មីនេះ - ការសង់ស្ថានីយរថភ្លើងថ្មី គម្រោងពង្រីកព្រលានយន្តហោះ ការជួសជុលឡើងវិញកីឡាដ្ឋានបាល់ទាត់?

# ឈ្មុសឈ្មុលតាមកម្មវត្ថុព័ត៌មាន

វាមានសារៈសំខាន់ណាស់ក្នុងការតាមមន្ត្រីជាន់ខ្ពស់ ដើម្បីស្ដាប់យកអត្ថាធិប្បាយរបស់គេលើបញ្ហាបច្ចុប្បន្នភាពប្រចាំថ្ងៃ។ ជារឿយៗ គេតែងឃើញអ្នកសារព័ត៌មានប្រជ្រៀតគ្នាដណ្ដើមជំហរនៅជុំវិញនាយករដ្ឋមន្ត្រី ដែលទិដ្ឋភាពនេះមើលទៅប្រៀបបាននឹងកីឡាករបាល់ឱបកំពុងប្រជែងគ្នាដណ្ដើមបាល់ក្នុងទីលានប្រកួតអញ្ចឹង។ តែពេលខ្លះយើងសួរខ្លួនឯងមើលថា តើយើងធ្វើជ្រុលពេកទេដឹង?

មានអ្នកសារព័ត៌មានថៃមួយចំនួន ដែលពូកែឈ្មុសឈ្មុលមែនទែន រហូតដល់ថាពួកគេសុខចិត្តនៅចាំជិតមួយម៉ោង នៅពេលដែលអតីតនាយករដ្ឋមន្ត្រី លោក សាម៉ាក់ ស៊ុនដារ៉ាវេជ (Samak Sundaravej) ព្យាយាមគេចខ្លួនពីអ្នកសារព័ត៌មានទៅពួនក្នុងបង្គន់សាធារណៈ។ ខាងក្រោមនេះជារឿងដែលចុះផ្សាយក្នុងកាសែត Bangkok Post៖

### *អ្នកសារព័ត៌មានផ្ទិះលោក សាម៉ាក់ ឲ្យចេញពីបង្គន់ទាល់តែបាន*

*បន្ទាប់ពីគាត់បញ្ចប់កម្មវិធីសន្ទនារួចកាលពីម្សិលមិញ នាយករដ្ឋមន្ត្រី សាម៉ាក់ ស៊ុនដារ៉ាវេជ បានលេងពួនជាមួយក្រុមអ្នកយកព័ត៌មាន ដោយលាក់ខ្លួនក្នុងបង្គន់សាធារណៈមួយនៅក្នុងផ្សារម្ហូបក្នុងទីក្រុងបាងកក។*

*ប៉ុន្តែ អ្នកសារព័ត៌មានមិនព្រមបុះញ៉មក្នុងការដេញតាមគាត់ទេ ហើយពួកគេមានវត្តមាននៅនឹងកន្លែងតែម្ដង នៅពេលដែលលោកនាយករដ្ឋមន្ត្រីក្នុងទឹកមុខស្រឡាំងកាំង បានចេញពីបន្ទប់បង្គន់ ហើយស្ដីឲ្យអ្នកសារព័ត៌មាន។*

*មុននេះ លោកនាយករដ្ឋមន្ត្រីទើបតែនឹងបញ្ចប់ការផ្សាយផ្ទាល់នៃកម្មវិធីសន្ទនា Sonthana Prasa Samak ក្នុងស្ថានីយផ្សាយទូរទស្សន៍រដ្ឋ ដែលស្ថិត*

*នៅលើផ្លូវ Phetchaburi ប៉ុន្តែលោក សាម៉ាក់ បដិសេធមិនឆ្លើយសំណួររបស់អ្នកយកព័ត៌មានអំពីការរុះរើគណៈរដ្ឋមន្ត្រី និងដំណើររបស់គាត់ទៅកាន់ខេត្តស៊ីសាកេតទេ។*

*ដូចសព្វមួយដង ក្រោយចប់កម្មវិធីនោះ លោកនាយករដ្ឋមន្ត្រីធ្វើដំណើរទៅកាន់ផ្សារ Or Tor Kor របស់ Marketing Organization for Farmers ក្នុងសង្កាត់ Chatuchak ដោយមានអ្នកយកព័ត៌មានដេញតាមពីក្រោយផង។*

*តែពេលទៅដល់ផ្សារ ក្រុមកាន់កាមេរ៉ា និងអ្នកយកព័ត៌មានរកលោក សាម៉ាក់ មិនឃើញទេ។ ក៏ប៉ុន្តែអ្នកលក់ដូរមួយចំនួនបានលបខ្សឹបថា គាត់កំពុងពួនក្នុងបង្គន់សាធារណៈមួយ។*

*សាមសិបនាទីបានកន្លងផុតទៅ រថយន្តវ៉ែនរបស់គាត់ និងរថយន្តប៉ូលិសអមបានចាកចេញបាត់ទៅហើយ រីឯអ្នកសារព័ត៌មានក៏ចាប់ផ្តើមសង្ស័យថាលោកនាយករដ្ឋមន្ត្រីមិននៅក្នុងបង្គន់ណាមួយនោះទេ ដែលមានទំហំតូច ហើយក្តៅហប់ទៀតផង។ អ្នកយកព័ត៌មានបុរសមួយចំនួនបានចប្រប់រកមើល ហើយក៏ឃើញអង្គរក្សពីនាក់កំពុងឈរពីមុខទ្វារបង្គន់ចុងក្រោយគេក្នុងបន្ទប់បុរស។*

*ប្រហែលជិតមួយម៉ោងក្រោយមក រថយន្ត BMW ពណ៌ខ្មៅរបស់លោក សាម៉ាក់ ក៏មកដល់។ លោក សាម៉ាក់ ចេញពីក្នុងបន្ទប់បង្គន់ក្នុងទឹកមុខហ្មម៉ង។*

*គាត់ដើរទៅរកអ្នកយកព័ត៌មាន ហើយសម្លក់ពួកគេម្តងមួយៗ មុននឹងហាមាត់ស្តីបន្ទោសពួកគេដោយសារដេញតាមគាត់។*

*គាត់មានប្រសាសន៍ថា៖ "ខ្ញុំមិនដែលឃើញអ្នកណាអីក៏អាក្រក់ដូចមនុស្សចង្រៃទាំងនេះទេ។ ខ្ញុំមិនដែលឃើញអ្វីក៏អាក្រក់ម្លេះដូចពេលនេះទេ។ នាយករដ្ឋមន្ត្រីចូលក្នុងបន្ទប់បង្គន់ ហើយពួកគេមកឈរឃាំងផ្លូវគាត់មិនឲ្យចេញរួច។ នេះ ឬអ្វីដែលនិពន្ធនាយករបស់អ្នកទាំងនេះបង្រៀនឲ្យគេធ្វើ?"*

*"វាអាក្រក់ ហើយសែនឲ្យអៀនខ្មាសណាស់។ តើខ្ញុំមិនអាចមានភាពឯកជនខ្លះទេ ឬយ៉ាងម៉េច? គួរខ្ញុំឲ្យគេថតវីឌីអូពេលដែលខ្ញុំកំពុងបន្ទោរបង់? ពួកគេគួរទៅពេទ្យឲ្យគេពិនិត្យមើលថា តើគេឡប់សតិ ឬយ៉ាងណា។ ធ្វើដូច្នេះគ្មានមនុស្សធម៌សោះ"។*

*"ខ្ញុំកំពុងអង្គុយក្នុងបង្គន់ ព្រោះវាជាសិទ្ធិរបស់ខ្ញុំ។ តើអ្នកណាខ្លះមានបញ្ហាត្រង់នេះ។ ខ្ញុំគ្រាន់តែចង់ទិញឥវ៉ាន់ ហើយទៅបង្គន់ តែពួកគេចេះតែថតរូបភាពរហូត។ ពួកអ្នកឯងឡប់សតិ ឬយ៉ាងម៉េច?"*

*"ម្ចាស់ស្ថានីយ និងនិពន្ធនាយកគេនឹងមិនផ្សាយកម្មវិធីបង្រៀនពីរម៉ោងរបស់ខ្ញុំទេ ប៉ុន្តែពួកគេថតមិនឈប់ទេ នូវសកម្មភាពនាយករដ្ឋមន្ត្រីដើរចូលបង្គន់"។*

*វត្តមានលោក សាម៉ាក់ បានទាក់ទាញការចាប់អារម្មណ៍ពីសំណាក់អ្នកលក់ និងអ្នកទិញក្នុងផ្សារ។*

*អ្នកខ្លះយល់ថា អ្នកសារព័ត៌មានបានទន្ទ្រានចូលជីវិតឯកជនរបស់លោកនាយករដ្ឋមន្ត្រី តែអ្នកខ្លះនិយាយថា អ្នកសារព័ត៌មានបានគ្រាន់តែបំពេញកាតព្វកិច្ចក្នុងតាមយកព័ត៌មានអំពីសកម្មភាពរបស់មន្ត្រីសាធារណៈប៉ុណ្ណោះ។*

*ល្បែងលេងពួននោះបានចប់នៅពេលដែលលោក សាម៉ាក់ ចេញពីផ្សារទៅដោយមិនបានទិញអ្វីទាំងអស់។*

# ទស្សនវិស័យ

ការយកព័ត៌មាននយោបាយត្រូវបានធ្វើឡើងតាមរបៀប **ពីលើចុះក្រោម**។ ការយកព័ត៌មាននយោបាយជាការងារមួយសំខាន់ និងគួរឲ្យជក់ចិត្តមែន ប៉ុន្តែគួរចាំថាភាគច្រើននៃរឿងនោះសំខាន់ចំពោះមួយភាគណាមួយនៃចំនួនប្រជាជនទាំងអស់តែប៉ុណ្ណោះ។ រាល់ថ្ងៃ មនុស្សម្នារវល់ខ្លាំងណាស់ក្នុងការរកស៊ីចិញ្ចឹមជីវិត និងថែរក្សាគ្រួសាររបស់គេ

ដូច្នេះពួកគេមិនមានពេលតាមដានរឿងក្នុងក្រោយរាក់ជ្រៅរបស់នយោបាយប៉ុន្មានទេ។ ភាគច្រើនគេមិនដាខ្វល់ប៉ុន្មានទេ បើអ្នកនយោបាយម្នាក់រិះគន់ម្នាក់ទៀត ហើយអ្នកយកព័ត៌មានសួរទៅកាន់អ្នកដែលត្រូវបានគេរិះគន់ថា តើគាត់មានអ្វីនិយាយតបវិញទេ (គេហៅការយកព័ត៌មានបែបនេះថាជា **ការយកព័ត៌មានបែបវាយប៉េងប៉ុង**)។

យកល្អ ចូរព្យាយាមធ្វើយ៉ាងណាឲ្យការយកព័ត៌មានអំពីនយោបាយ និងរដ្ឋាភិបាលមានភាពទាក់ទងទៅនឹងប្រជាជនទូទៅផង ដោយផ្តោតលើតម្រូវការ និងការតស៊ូប្រចាំថ្ងៃរបស់ពួកគេ។ អ្នកអាចចាប់ផ្តើមដោយរកប្រតិកម្មពីប្រជាជនសាមញ្ញ - ដូចជាកសិករ អ្នកជាក់ស៊ីក្លូ ឬអ្នកធ្វើការក្នុងការិយាល័យក្តី - ទៅនឹងសេចក្តីប្រកាសសំខាន់ណាមួយរបស់រដ្ឋាភិបាល។ ធ្វើដូច្នេះជួយប្រជាជនឲ្យមានភាពអង់អាចក្នុងការបញ្ចេញមតិទៅលើការគ្រប់គ្រងប្រទេស។ តាមរយៈការធ្វើសេចក្តីរាយការណ៍អំពីបញ្ហានយោបាយ ឬសង្គម ដោយផ្តើមពីទស្សនទានរបស់ប្រជាជនសាមញ្ញ អ្នកកំពុងដើរតួនាទីជាស្ពានរវាងរដ្ឋាភិបាល និងប្រជាជន ដែលជាស្ពានគេអាចធ្វើដំណើរលើក្នុងទិសដៅទៅវិញទៅមកបាន។

អត្ថបទរឿងខាងក្រោមនេះស្តីអំពីការជ្រើសរើសនាយករដ្ឋមន្ត្រីថ្មីក្នុងប្រទេសថៃ ហើយរឿងនេះត្រូវបានសរសេរឡើង តម្រូវអ្នកអានក្រៅប្រទេស ប៉ុន្តែវាក៏មានសារៈប្រយោជន៍ដែរសម្រាប់អ្នកអានក្នុងប្រទេសថៃដែរ។ រឿងនេះមានសារតោរ និងបរិបទល្អ បុគ្គលិកលក្ខណៈខ្លីមួយរបស់មេដឹកនាំថ្មី សេចក្តីពិស្តារនៃការបោះឆ្នោត និងប្រតិកម្មពីប្រជាជនសាមញ្ញ ដែលជារឿយៗត្រូវបានគេរំលងចោលក្នុងរឿងអំពីនយោបាយ។

### *មេដឹកនាំបក្សប្រឆាំងក្លាយខ្លួនជានាយករដ្ឋមន្ត្រី*

***ដោយ Ambika Ahuja, The Associated Press***

*បាងកក, ប្រទេសថៃ – សភាថៃ នៅថ្ងៃច័ន្ទនេះជ្រើសរើសមេដឹកនាំបក្សប្រឆាំងដែលធ្លាប់ទទួលការអប់រំនៅសាកលវិទ្យាល័យ Oxford ឲ្យធ្វើជានាយករដ្ឋមន្ត្រីដោយបញ្ចប់ពេលប្រាំមួយខែនៃការបះបោរដោយហិង្សាប្រឆាំងរដ្ឋាភិបាល រួមមានការកាន់កាប់ព្រលានយន្តហោះក្នុងក្រុងបាងកកអស់ពីរសប្តាហ៍ផង។*

*ការជ្រើសតាំងលោក អាប់ភីស៊ិត វេជចាជីវ៉ា (Abhisit Vejjajiva) ជាការសំគាល់ថានេះជាលើក*



*ដើម្បីរស់ មនុស្សត្រូវបង្ខំចិត្តទៅរករបរចិញ្ចឹមជីវិតនៅទីកន្លែងឆ្ងាយពោរពេញដោយការលំបាក។*

ទីមួយហើយក្នុងប្រាំបីឆ្នាំមកនេះ ដែលរដ្ឋាភិបាលត្រូវបានដឹកនាំដោយបក្ខាមិត្តរបស់នាយករដ្ឋមន្ត្រីនិរទេសខ្លួន លោក ថាក់ស៊ីន ស៊ីណាវ៉ាត្រា (Thaksin Shinawatra) ដែលនៅតែលេចស្មុងពីលើឆាកនយោបាយថៃនៅឡើយចាប់តាំងពីពេលដែលគាត់ត្រូវបានគេទម្លាក់ចេញពីអំណាចដោយរដ្ឋប្រហារយោធាកាលពីឆ្នាំ ២០០៦ មក។

លោក អាប់ភីស៊ិត អាយុ ៤៤ ឆ្នាំ ត្រូវប្រឈមមុខជាមួយបញ្ហាប្រឈមដ៏ធំធេងក្នុងការកិច្ចព្យាយាមបង្រួបបង្រួមប្រទេស" ដែលត្រូវបានបែងចែកជាក្រុមវណ្ណៈកណ្តាលដែលជាមូលដ្ឋានគាំទ្រគាត់ និងអ្នកក្រីក្រនៅជនបទដែលគាំទ្រលោក ថាក់ស៊ីន" និងក្នុងការប្រឹងចាត់ចែងសេដ្ឋកិច្ច ដែលទទួលរងប៉ះទង្គិចពីភាពវឹកវរនយោយបាយថៃ និងការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោកទាំងមូល។

បើទោះជាថាមានការបះបោរប្រឆាំងថ្មីពីសំណាក់អ្នកគាំទ្ររដ្ឋាភិបាលមុនក៏ដោយ ការជ្រើសតាំងលោក អាប់ភីស៊ិត ត្រូវបានគេរំពឹងទុកថានឹងនាំមកនូវភាពស្ងប់ស្ងាត់មួយរយៈខ្លី។ មុខមាត់របស់គាត់ជាមនុស្សអភិជន ក៏អាចជាឧបសគ្គដល់គាត់ក្នុងការប៉ុនប៉ងបញ្ចប់ភាពវឹកវរនេះ។

ក្នុងការបោះឆ្នោតដោយសភាជាន់ទាបកាលពីថ្ងៃច័ន្ទ លោក អាប់ភីស៊ិត ទទួលបានការគាំទ្រពីសមាជិកសភា ២៣៥ រូប ប្រៀបទៅនឹងចំនួន ១៩៨ រូប ដែលគាំទ្របេក្ខភាពរបស់អតីតមេប៉ូលីសជាតិដែលជាអ្នកនិយមលោក ថាក់ស៊ីន។

ពេលតំណាងរាស្ត្រធ្វើដំណើរមកដល់ដើម្បីរៀបចំការបោះឆ្នោតតែងតាំងនាយករដ្ឋមន្ត្រី ក្រុមអ្នកគាំទ្រលោក ថាក់ស៊ីន បាននាំគ្នាខ្ទប់ច្រកក្លោងទ្វារសភាក្នុងកិច្ចប៉ុនប៉ងចុងក្រោយ មិនឲ្យការបោះឆ្នោតចេញជាលទ្ធផលបាន។ បន្តិចក្រោយមក នគរបាលប្រឆាំងបាតុកម្មបានវែកផ្លូវឲ្យពួកតំណាងរាស្ត្រចេញពីទីធ្លាសភា។ ពួកបាតុករនាំគ្នាគប់ដុំថ្មទៅលើរថយន្តហើយដេរប្រមាថពួកតំណាងរាស្ត្រ ក្នុងនោះ តែភាគច្រើននៃពួកគេបាននាំគ្នាបំបែកហ្វូងទៅវិញដោយសន្តិវិធី។

បន្ទាប់ពីការបោះឆ្នោតភ្លាម លោក អាប់ភីស៊ិត ថ្លែងអំណរគុណចំពោះអ្នកតំណាងរាស្ត្រដូចគ្នា និងចំពោះសាធារណជន តែនិយាយថា គាត់នឹងមិនជជែកពីរឿងនយោបាយទេ ដរាបណាទាល់តែគាត់ទទួលបានការអនុម័តជាផ្លូវការ ឲ្យក្លាយជានាយករដ្ឋមន្ត្រី ដោយព្រះរាជាអាស្រ័យរដ្ឋធម្មនុញ្ញ គឺស្តេច Bhumibol Adulyadej។ គេរំពឹងថាស្តេចនឹង ប្រទានការអនុម័តក្នុងប៉ុន្មានថ្ងៃខាងមុខនេះ។

ជាកូនម្នាក់ក្នុងត្រកូលអ្នកស្តុកស្តម្ភ មានឈាមជ័រ ថៃ-ចិន លោក អាប់ភីស៊ិត កើតនៅប្រទេសអង់គ្លេស ហើយទទួលការអប់រំនៅ Eton និង Oxford ដែលនៅទីនោះគាត់ទទួលបានសញ្ញាប័ត្រកិត្តិយសផ្នែកទស្សនវិជ្ជា នយោបាយ និងសេដ្ឋកិច្ច។ នាមរបស់គាត់ អាប់ភីស៊ិត មានអត្ថន័យក្នុងភាសាថៃថា "ឯកសិទ្ធិ" (privilege) ហើយមិត្តរបស់គាត់តែងហៅគាត់តាមឈ្មោះហៅក្រៅមួយទៀតថា Mark។

នៅឆ្នាំ ១៩៩២ គាត់ចូលរួមគណបក្សប្រជាធិបតេយ្យ ដែលជាគណបក្សចំណាស់ជាងគេក្នុងប្រទេស ហើយបានក្លាយខ្លួនសមាជិកដ៏វ័យក្មេងជាងគេមួយរូបក្នុងសភា។ បន្តិចម្តងៗគាត់បានលេចធ្លោក្នុងជួរបក្ស និងក្នុងប្រជាប្រិយភាពជាពិសេសក្នុងចំណោមស្រទាប់មនុស្សមានការអប់រំខ្ពស់ក្នុងក្រុងបាងកក ដែលចាប់អារម្មណ៍ជាមួយកេរ្តិ៍ឈ្មោះមិនប្រឡាក់ប្រឡូសរបស់គាត់ កាយវិការគួរសម ទន់ភ្លន់ ការថ្លែងសម្តីស្រទន់តែច្បាស់លាស់ និងសម្រស់ដូចតួកុនរបស់គាត់។

ពួកប្រជាធិបតេយ្យបានគ្រប់គ្រងរដ្ឋាភិបាលនៅថៃ រហូតដល់ឆ្នាំ ២០០១ នៅពេលដែលលោក ថាក់ស៊ីន ដែលជាអតីតដង្ហៅទូរគមនាគមន៍ម្នាក់ឈ្នះឆ្នោត ហើយឡើងកាន់អំណាចនៅប្រទេសថៃ។

*លោក ថាក់ស៊ីន ត្រូវបានបង្ខំចិត្តរត់ចោលប្រទេសកាលពីពីរឆ្នាំមុនក្រោមការចោទប្រកាន់ពីបទបំពានអំណាច ហើយក្រោយមកទៀតត្រូវបានតុលាការកាត់ក្តីកំបាំងមុខឲ្យមានពិរុទ្ធពីបទប្រព្រឹត្តអំពើពុករលួយ។ យ៉ាងណាក្តី លោក ថាក់ស៊ីន ដែលពេលនេះគេមិនដឹងនៅទីណាទេ នៅតែទទួលបានការគាំទ្រច្រើននៅឡើងក្នុងចំណោមអ្នកក្រីក្រនៅជនបទ។ មុននឹងមកដល់ថ្ងៃច័ន្ទនេះ អ្នកគាំទ្រគាត់នៅកាន់កាប់រដ្ឋាភិបាលនៅឡើយ។*

*ប្រតិកម្មចំពោះការបោះឆ្នោតនៅថ្ងៃច័ន្ទនេះ បានគូសបញ្ជាក់កាន់តែច្បាស់ថែមទៀតនូវការបាក់បែកក្នុងប្រទេសថៃ។*

*លោក អាប់ភីស៊ិត និងគណបក្សគាត់ទទួលមានការគាំទ្រខ្លាំងពីសំណាក់ពួកវណ្ណៈកណ្តាល និងមនុស្សច្រើនទៀតក្នុងវិស័យធុរកិច្ច។ អ្នកអាសាស្ម័គ្រជាច្រើនក្នុងបក្សរបស់គាត់ មើលទៅកាន់អ្នកគាំទ្រលោក ថាក់ស៊ីន នៅតំបន់ជនបទថាជាមនុស្សងាយគេបោកយកបំណោញ ហើយងាយនឹងលុះទៅតាមការទិញទឹកចិត្តយកសន្លឹកឆ្នោតណាស់។*

*នាង Nutta Tangtrakulchai អាយុ ២៦ ឆ្នាំ ហើយជាបុគ្គលិកការិយាល័យម្នាក់នៅបាងកក និយាយថា៖ "ប្រពៃណាស់ ដែលមានការផ្លាស់ប្តូរដោយមានមនុស្សវៃឆ្លាតម្នាក់ឡើងកាន់តំណែង។ គាត់ក៏ជាអ្នកសេដ្ឋកិច្ចផងដែរ ដូច្នេះគាត់ពិតជាមានសុភនិច្ឆ័យយល់ដឹងក្នុងការដោះស្រាយបញ្ហាដែលសំខាន់បំផុតរបស់ប្រទេស"។*

*តែអ្នកគាំទ្រលោក ថាក់ស៊ីន បារម្ភថាលោក អាប់ភីស៊ិត នឹងព្រងើយកន្តើយចំពោះអ្នកក្រីក្រក្នុងប្រទេស។*

*លោក Chaiya Paitoonsiri អ្នកបរតាក់ស៊ីមកពីខេត្ត Maha Sarakam ចម្ងាយ ៣៨៥ គីឡូម៉ែត្រ ភាគឦសានពីក្រុងបាងកក និយាយថា៖ "លោក អាប់ភីស៊ិត កើតមកមានស្រាប់។ គាត់គ្មានស្គាល់អ្វីក្រៅពីសម្បត្តិស្តុកស្តម្ភ និងឯកសិទ្ធិទេ។ ដូច្នេះ តើគាត់អាចមកដោះស្រាយបញ្ហារបស់យើងម្តេចនឹងបាន?"*

*ការបោះឆ្នោតកាលពីថ្ងៃច័ន្ទ បានបញ្ចប់រយៈពេលប្រាំមួយខែនៃអស្ថិរភាព បង្កដោយបាតុកម្មប្រឆាំងរដ្ឋាភិបាលដែលចាប់ផ្តើមជាមួយនឹងការចូលកាន់កាប់វិមានរដ្ឋាភិបាលរបស់ថៃ និងបន្តដោយការចូលកាន់កាប់ព្រលានយន្តហោះកាលពីខែមុន។*

*កាលពីខែកញ្ញា អតីតនាយករដ្ឋមន្ត្រី សាម៉ាក់ ស៊ុនដារាវេជ ត្រូវបានគេដកចេញពីតំណែងក្រោយពីតុលាការចេញសាលក្រមថា គាត់បង្កឲ្យមានទំនាស់ផលប្រយោជន៍ដោយចេញមុខក្នុងកម្មវិធីទូរទស្សន៍ស្តីពីការធ្វើម្ហូប។*

*អ្នកបន្តវេនរបស់គាត់ លោក ស៊ុមឆៃ វង្សាវ៉ាត (Somchai Wongsawat) ត្រូវបានតុលាការធម្មនុញ្ញដកចេញពីតំណែងកាលពី ១០ ថ្ងៃមុនកន្លងទៅនេះ។ លោក ស៊ុមឆៃ បដិសេធមិនធ្វើអត្ថាធិប្បាយលើការបោះឆ្នោតកាលពីថ្ងៃច័ន្ទនេះទេ។*

*លោក Sukhum Nuansakul អ្នកវិទ្យាសាស្ត្រនយោបាយនៅ Ramkhamhaeng University ក្នុងក្រុងបាងកក និយាយថា ភាពស្រាកស្រាន្តពីអស្ថិរភាពនយោបាយថៃ ទំនងជាមានអាយុខ្លីណាស់។*

*គាត់មានប្រសាសន៍ថា៖ "បញ្ហាជាមូលដ្ឋានមិនទាន់ត្រូវបានដោះស្រាយនៅឡើយទេ។ ជ័យជំនះរបស់អ្នកប្រជាធិបតេយ្យម្នាក់នឹងបើកឆាកឲ្យមានការប្រឆាំងតាមដងផ្លូវថ្មីមួយទៀត លើកនេះធ្វើឡើងដោយបណ្តាក្រុមនេះគាំទ្រលោក ថាក់ស៊ីន"។*

*លោក អាប់ភីសិទ្ធ ក៏ត្រូវប្រឈមនឹងបញ្ហាសេដ្ឋកិច្ចជាច្រើនដែរ ដែលបណ្តាលមកពីការថមថយសេដ្ឋកិច្ចពិភពលោក និងបរិយាកាសក្នុងស្រុកដែលខ្វះភាពប្រាកដប្រជា។*

## ការបោះឆ្នោត

ក្នុងសង្គមប្រជាធិបតេយ្យ ការបោះឆ្នោតត្រូវបានគេធ្វើឡើងក្នុងចន្លោះពេលទៀងទាត់ ដើម្បីរើសថ្នាក់ដឹកនាំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ វាជាសកម្មភាពមួយក្នុងចំណោមសកម្មសំខាន់ៗនៃលទ្ធិប្រជាធិបតេយ្យ។ បន្ថែមលើនេះ ជួនកាលគេក៏ធ្វើដែរនូវការស្ទាបស្ទង់មតិសាធារណៈលើវិធានការជាក់លាក់ ដូចជា តើប្រទេសមួយគួរអនុម័តយកធម្មនុញ្ញមួយថ្មី ឬទេ។ គេឲ្យឈ្មោះការស្ទាបស្ទង់មតិនេះថាជាការធ្វើ**ប្រជាមតិ**។ ការបោះឆ្នោត និងប្រជាមតិ កំពុងតែមានសារៈសំខាន់នៅពេលដែលប្រទេសអាស៊ីជាច្រើនធ្វើអន្តរកម្មខ្លួនក្លាយទៅជាសង្គមបើកចំហ និងប្រជាធិបតេយ្យជាងមុន។ របៀបដែលការបោះឆ្នោតត្រូវបានធ្វើឡើង - ទោះជាដោយសេរី ត្រឹមត្រូវ អាចជឿទុកចិត្តបាន ឬយ៉ាងណានោះ - នឹងឲ្យយើងដឹងថា តើការធ្វើអន្តរកម្មនោះប្រព្រឹត្តទៅដូចម្ដេច។ អ្នកសារព័ត៌មានមានតួនាទីគន្លឹះមួយក្នុងការជម្រាបដល់ពលរដ្ឋឲ្យបានព័ត៌មានគ្រប់គ្រាន់ដើម្បីគេបោះឆ្នោតដោយគតិវាងវៃក្នុងការជ្រើសរើសមេដឹកនាំដ៏ល្អបំផុតរបស់គេ។

អ្នកសារព័ត៌មានអាច៖

- ជួយពន្យល់គោលនយោបាយដែលបានស្នើឡើងដោយបណ្ដាគណបក្ស និងបេក្ខជន និងថាតើវាខុសគ្នាដូចម្ដេចខ្លះ។
- ជម្រាបពលរដ្ឋឲ្យបានដឹងអំពីសិទ្ធិរបស់ពួកគេ ដូចជារបៀបចុះឈ្មោះបោះឆ្នោត និងថាតើត្រូវទៅបោះពេលណា និងនៅកន្លែងណា។
- ដើរតួជាឆ្មាំឃ្លាំមើលដោយធ្វើសេចក្ដីរាយការណ៍ពេលណាវិធាននានា ត្រូវបានរំលោភបំពាន ហើយអនុវត្តន៍មិនយុត្តិធម៌។
- ផ្ដល់វេទិកាដល់ម្ចាស់ឆ្នោតបញ្ចេញសម្លេង និងកង្វល់របស់ពួកគេឲ្យមេដឹកនាំនយោបាយបានឮ។

### ការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ

ក្រុមសង្គមស៊ីវិល និងអ្នកសង្កេតការអន្តរជាតិតែងតែតាមដានមើលការបោះឆ្នោតក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីឲ្យដឹងថា តើការបោះឆ្នោតនោះធ្វើឡើងដោយ **សេរី និងត្រឹមត្រូវ** ឬអត់។ សេរី និងត្រឹមត្រូវ ជាស្ដង់ដារទទួលស្គាល់ជាអន្តរជាតិដែលមានន័យថា បេក្ខជន និងគណបក្សទាំងអស់ត្រូវតែបានការអនុញ្ញាតឲ្យធ្វើយុទ្ធនាការដោយសេរី ម្ចាស់សន្លឹកឆ្នោតត្រូវតែបានការអនុញ្ញាតឲ្យបោះសន្លឹកឆ្នោតដោយសម្ងាត់ និងគ្មានការភ័យខ្លាច និងប្រព័ន្ធផ្សព្វផ្សាយត្រូវបានការអនុញ្ញាតឲ្យធ្វើសេចក្ដីរាយការណ៍អំពីគ្រប់ផ្នែកនៃដំណើរការបោះឆ្នោតបានដោយសេរី និងដោយចំហផងដែរ។

ភាគច្រើននៃគោលការណ៍ទាំងនេះ ត្រូវបានចែងក្នុងសេចក្ដីថ្លែងការណ៍សកលអំពីសិទ្ធិមនុស្សដែលនិយាយថា "ជនគ្រប់រូបមានសិទ្ធិចូលរួមក្នុងរដ្ឋាភិបាលរបស់ខ្លួនដោយផ្ទាល់ ឬតាមរយៈតំណាងដែលត្រូវបានជ្រើសរើសដោយសេរី "។ សេចក្ដីថ្លែងការណ៍នោះ ក៏និយាយថែមទៀតថា "ឆន្ទៈរបស់ប្រជាជន គួរត្រូវបានធ្វើជាមូលដ្ឋាននៃអំណាចរបស់រដ្ឋាភិបាល" ហើយអំពាវនាវឲ្យមានដំណើរការបោះឆ្នោតដោយសេរី និងសម្ងាត់។

យ៉ាងណាមិញ បរិបទនយោបាយខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ដូច្នេះអ្នកសារព័ត៌មាន និងអង្គភាពសារព័ត៌មានជាអ្នកសម្រេចថា តើគួរវាយតម្លៃការបោះឆ្នោតក្នុងប្រទេសរបស់ខ្លួនរបៀបម៉េច។

ការយកព័ត៌មានអំពីការបោះឆ្នោតអាចក្លាយជាបញ្ហាមួយ ពីព្រោះបេក្ខជនអាចមិនមានលទ្ធភាពស្មើគ្នាក្នុងការទទួលបានលំហគ្រប់គ្រាន់ក្នុងទំព័រ

កាសែត ឬម៉ោងគ្រប់គ្រាន់ក្នុងការផ្សាយរបស់វិទ្យុ និងទូរទស្សន៍ ដែលអាចស្ថិតក្រោមការគ្រប់គ្រង ឬឥទ្ធិពលរបស់គណបក្សណាមួយ។ ជួនកាលស្ថានីយទូរទស្សន៍កាន់កាប់ដោយរដ្ឋអាចមិនអើពើនឹងយុទ្ធនាការរបស់គណបក្សជំទាស់ និងការបោះឆ្នោតតែម្តង ហើយបន្តធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពរដ្ឋាភិបាល ដែលធ្វើឲ្យគណបក្សកំពុងកាន់អំណាចកាន់តែបានឧត្តមភាពជាងគណបក្សដទៃទៀត។ បេក្ខជនទាំងអស់មានសិទ្ធិនិយាយបញ្ចេញសាររបស់ខ្លួនឲ្យគេឮ។ ក្នុងតួនាទីរបស់ខ្លួនអ្នកសារព័ត៌មានត្រូវតែរក្សាជំហរយុត្តិធម៌ចំពោះគណបក្សទាំងអស់ ដោយទុកលំអៀងបុគ្គលណាមួយ ដែលខ្លួនមានឲ្យនៅដោយឡែកមួយអន្លើសិនទៅ។ វាអាចពិបាកនឹងធ្វើ ប៉ុន្តែកាលណាយើងធ្វើបាន វានឹងជួយឲ្យរឿងរបស់យើងអំពីដំណើរការបោះឆ្នោតកាន់តែមាន**ភាពគួរឲ្យជឿជាក់**បានថែមទៀត។

## យល់ដឹងអំពីដំណើរការ និង"ល្បិចកលក្រខ្វក់"

ជំហានដំបូង គឺត្រូវរៀនឲ្យចេះអំពីច្បាប់បោះ-ឆ្នោត និងរបៀបផ្សេងៗ ដែលគេអាចយកទៅប្រើដើម្បីរំលោភលើច្បាប់នោះបាន។ នៅប្រទេសជាច្រើនសភាជាអ្នកអនុម័តច្បាប់បោះឆ្នោត រីឯវិធាន និងបទបញ្ញាសំខាន់ៗនានាពាក់ព័ន្ធនឹងវា ត្រូវបានគណៈកម្មការបោះឆ្នោតជាអ្នកចេញ និងអនុវត្តន៍។ នៅក្នុងប្រទេសប្រជាធិបតេយ្យពហុបក្ស គេកំណត់កាលបរិច្ឆេទសម្រាប់គណបក្សបង្កើតជាផ្លូវការ និងចុះបញ្ជីសម្រាប់ចូលប្រឡូកក្នុងការបោះឆ្នោត។ គណបក្សនីមួយៗអាចមានដំណើរការរបស់ខ្លួនក្នុងការចាត់តាំង ឬជ្រើសតាំងបេក្ខជនសម្រាប់ការបោះឆ្នោតសកល។ ដូច្នេះអ្នកសារព័ត៌មានត្រូវតែស្វែងយល់ថា តើគេធ្វើដំណើរការនេះរបៀបម៉េច។

**បេក្ខជនឯករាជ្យ** អាចត្រូវបានអនុញ្ញាតឲ្យចុះឈ្មោះបាន បើសិនជាគេប្រមូលបានគ្រប់គ្រាន់នូវហត្ថលេខាជ្រើសតាំងពីអ្នកបោះឆ្នោតដែលបានចុះបញ្ជីរួច។ តាមធម្មតា គេប្រកាសឲ្យដឹងអំពីដំណាក់កាលផ្លូវការសម្រាប់ធ្វើយុទ្ធនាការ ម៉ោងបើកទ្វារស្ថានីយបោះឆ្នោត ទីតាំងស្ថានីយបោះឆ្នោត និងដំណើរការបោះឆ្នោតតែម្តង។ គួរតែរកឲ្យឃើញអ្នកណាខ្លះអង្គុយនៅក្នុងគណៈកម្មការបោះឆ្នោត ហើយតើគេតែងតាំងពួកនេះរបៀបម៉េច។ ធម្មតា អ្នកទាំងនេះច្រើនតែជាមនុស្សមានភក្តីភាពជាមួយគណបក្សមួយ ហើយតែងមានឥទ្ធិពលខ្លាំងទៅលើដំណើរការបោះឆ្នោត រួមមានអំណាចក្នុងការដកសិទ្ធិអ្នកបោះឆ្នោត និងបេក្ខជននៅលើមូលដ្ឋានបច្ចេកទេសផ្សេងៗផង។

ចូររាវរកសរវើរកឃ្លាំមើលផងនូវ "ល្បិចកលក្រខ្វក់"- គឺទង្វើមិនស្របច្បាប់ដែលគណបក្ស បេក្ខជន និងរដ្ឋាភិបាលធ្វើ ដើម្បីដណ្តើមជ័យជំនះក្នុងការបោះឆ្នោត។ ទង្វើខុសច្បាប់ទាំងនោះ អាចមានការគំរាម-កំហែងលើរាងកាយ និងអំពីហិង្សា **ការទិញសន្លឹកឆ្នោត** តាមរយៈការឲ្យអំណោយ និងលុយទៅអ្នកបោះឆ្នោត និងមេភូមិជាដើម។ ស្នៀតបែបនេះមើលទៅហាក់ដូចជាមិនចម្លែកទេនៅក្នុងប្រទេសមួយចំនួន ពីព្រោះវាជាទម្លាប់ដែលគេប្រើយូរឆ្នាំមកហើយតាំងពីមានការបោះឆ្នោតមក។ ក្នុងនាមជាអ្នកសារព័ត៌មាន អ្នកគួរចងចាំថា ការងាររបស់អ្នកមិនមែននៅត្រឹមតែការដឹងអំពីវិធាននានាអំពីការបោះឆ្នោតនោះទេ តែវាជាការងាររបស់អ្នកដែរក្នុងការអប់រំអ្នកដទៃអំពីវិធានទាំងនោះឲ្យគេយល់ថាហេតុអ្វីបានជាវាសំខាន់។ បេក្ខជន ឬគណបក្សណាមួយដែលបំពានវិធានទាំងនោះ អាចត្រូវបានគេហាមមិនឲ្យចូលប្រឡូកក្នុងនយោបាយទៀតទេ។

ជារឿយៗ នៅតាមខេត្តគេងាយសង្កេតឃើញណាស់នូវរបៀបដែលគណបក្សប្រើប្រាស់ក្នុងការព្យាមយាមធ្វើឥទ្ធិពលទៅលើការបោះឆ្នោត។



*សង្គមមួយអាចសម្បូរអាវុធ តែមិនមែនបានន័យថា វាមានរបៀបរៀបរយទាំងស្រុងនោះទេ។*

ហេតុដូច្នេះហើយបានជាវាមានសារៈសំខាន់ណាស់ ដែលអ្នកសារព័ត៌មានត្រូវតែចេញក្រៅរដ្ឋធានីក្នុងពេលបោះឆ្នោត។ នៅប្រទេសកម្ពុជា គណបក្សកាន់អំណាចបានធ្វើ **ការបោះឆ្នោតសាកល្បងក្លែងក្លាយ (mock elections)** នៅខេត្តបាត់ដំបង មុននឹងការបោះឆ្នោតជាតិជាផ្លូវការមកដល់។ អ្នកបោះឆ្នោតត្រូវបានគេបង្ហាញអំពីរបៀបបោះឆ្នោត "ត្រឹមត្រូវ" ដោយគូសសញ្ញាក្នុងប្រអប់ក្បែរនិមិត្តសញ្ញាគណបក្ស។ នៅខេត្តដទៃទៀត អ្នកបោះឆ្នោតត្រូវបានគេបង្ខំឲ្យផ្តិតមេដៃសន្យារក្សាភក្តីភាពជាមួយគណបក្ស។ ខាងក្រោមនេះជាសេចក្តីផ្តើមនៃរឿងមួយបែបនេះរបស់កាសែត The Cambodia Daily៖

*នៅពេលដែលអ្នកកេណ្ឌសមាជិករបស់គណបក្សប្រជាជន ចូលមកដល់ភូមិតូចមួយក្នុងខេត្តកណ្តាល កាលពីខែកន្លងទៅនេះ ពួកគេបាននាំមកជាមួយសម្រាប់មនុស្សម្នាក់នូវលុយ ២ ម៉ឺនរៀល ក្រមាមួយ និងប៊ិចមួយ។ ក្នុងចំណោមនោះ ក៏មានភ្ញៀវគួរឲ្យភ្ញាក់ផ្អើលម្នាក់ដែរ គឺប្រធានភូមិ។*

*យោងតាមការរៀបរាប់របស់អ្នកស្រុកនៅភូមិមួយក្នុងឃុំសៀមរាប ស្រុកកណ្តាលស្ទឹង គណៈប្រតិភូកេណ្ឌសមាជិកនេះ ច្រើនតែមកពេលយប់ ហើយពួកគេកម្រចេញទៅវិញ ដោយមិនបានយកទៅជាមួយនូវស្នាមផ្តិតមេដៃរបស់ប្រជាជនសន្យាថារក្សាភក្តីភាពជូនគណបក្សប្រជាជនឡើយ។*

*អ្នកភូមិម្នាក់ដែលសុំមិនបញ្ចេញឈ្មោះនិយាយថា៖ "យើងមិនអាចដើរបញ្ច្រាសពួកគេ ឬបញ្ច្រាសមេភូមិបានទេ។ យើងបារម្ភចំពោះសន្តិសុខរបស់យើងដែរ"។*

*បើទោះជាគាត់បានធ្វើការសន្យាដូច្នោះមែន គាត់និយាយថាគាត់នឹងបោះឆ្នោតឲ្យគណបក្សមួយផ្សេងទៀត។ គាត់និយាយថា៖ "យើងធុញទ្រាន់ជាមួយនឹងមេដឹកនាំចាស់ៗដូចជាលោក ហ៊ុន សែន នេះណាស់"។*

*នៅប្រហែលជា ៣០ គីឡូម៉ែត្រពីនេះ ក្នុងស្រុកសំរោងខេត្តតាកែវ អ្នកភូមិម្នាក់ទៀតបានរ៉ាយរ៉ាប់រឿងប្រហាក់ប្រហែលគ្នានេះដែរ។ បុរសអាយុ ៤៥ ឆ្នាំម្នាក់នេះ និយាយថា៖ "ថ្ងៃមួយនោះ មេភូមិចូលមកផ្ទះរបស់ខ្ញុំ ហើយសួរមកកាន់ខ្ញុំថា តើឯងជឿគណបក្សប្រជាជន ឬគណបក្សប្រឆាំង? ខ្ញុំត្រូវតែឆ្លើយទៅគាត់វិញថា ខ្ញុំគាំទ្រតែគណបក្សប្រជាជនទេ។ នេះជាជម្រើសតែមួយគត់សម្រាប់ខ្ញុំ "ដើម្បីសុវត្ថិភាពរបស់ខ្ញុំ"។*

*យុទ្ធនាការក្នុងសភាពមួយសុះសាយ និងបង្ខំផ្លូវចិត្ត ដែលគណបក្សប្រជាជនកំពុងធ្វើក្នុងគោលបំណងប្រមូលសមាជិកថ្មីសម្រាប់ការបោះឆ្នោតពេលខាងមុខនេះ បានញ៉ាំងឲ្យគណបក្សដទៃទៀតធ្វើការរិះគន់អំពីការបំភ័យ និងការទិញទឹកចិត្តអ្នកបោះឆ្នោត។ អ្នករិះគន់ជាច្រើនបាននិយាយថា*



*ហេដ្ឋារចនាសម្ព័ន្ធទ្រុឌទ្រោមអាចបង្កគ្រោះថ្នាក់ដល់សាធារណជន។*

*ទង្វើបែបនេះរំលោភទៅលើសេចក្ដីណែនាំក្នុងច្បាប់បោះឆ្នោត។*

*សារាចរណែនាំមួយ ដែលចេញដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ២២ មេសា បានហាមប្រាមគណបក្សមិនប្រើប្រាស់ការបំភិតបំភ័យ ឬឲ្យអំណោយ ឬលុយ ដើម្បីទទួលបានសន្លឹកឆ្នោតទេ។ ទណ្ឌកម្មចំពោះការបំពានបទបញ្ជាទាំងនេះ រួមមាន ការដកសិទ្ធិរបស់បេក្ខជនរបស់គណបក្ស និងការផាកពិន័យជាទឹកប្រាក់រហូតដល់ទៅ ៧ ពាន់ដុល្លារ ឯណោះ។*

ការបំពានក្នុងថ្ងៃបោះឆ្នោតតែម្ដង ក៏មានជាញឹកញាប់ផងដែរ។ ល្បិចកលក្រខ្វក់មានដូចជា អាជ្ញាធរអមដំណើរអ្នកបោះឆ្នោតចូលដល់ក្នុងបន្ទប់បោះឆ្នោត ដើម្បី "ជួយ" ពួកគេឲ្យគូសសន្លឹកឆ្នោតឲ្យបានត្រូវ។ កាលពីមុន មានករណីដែលអ្នកបានចុះបញ្ជីបោះឆ្នោតមិនត្រូវបានគេអនុញ្ញាតឲ្យបោះឆ្នោត ដោយឈ្មោះរបស់គេបានបាត់ចេញពីបញ្ជីយ៉ាងអាថ៌កំបាំង។ ក្រៅពីនោះ ក៏មានករណីដែលអ្នកសង្កេតការណ៍ការបោះឆ្នោត ត្រូវបានគេហាមមិនឲ្យតាមដានមើលដំណើរការបោះឆ្នោតដែរ។

កាលណាបង្ហាញលទ្ធផលការបោះឆ្នោតសាកពិចារណាប្រើក្រាហ្វិក ផែនទី និងតារាង ដើម្បីបង្ហាញចំនួនអាសនៈ ដែលត្រូវបានបែងចែកក្នុងសភា និងភាគរយដែលគណបក្សនីមួយៗទទួលបាន។

តាមធម្មតា គេត្រូវការពេលវេលាមួយក្រោយការបោះឆ្នោតទំរាំនឹងគេអាចប្រកាសលទ្ធផលជាផ្លូវការបាន។ ក្រៅពីនោះ គណបក្សអាចដាក់ពាក្យបណ្ដឹងជាមួយគណៈកម្មការបោះឆ្នោតអំពីភាពមិនប្រក្រតីក្នុងពេលយុទ្ធនាការ ដែលជាលទ្ធផលអាចបេក្ខជនឈ្នះឆ្នោតណាម្នាក់ត្រូវបានគេលុបសុពលភាពចោលវិញផងក៏ថាបាន។ គណបក្សចាញ់ឆ្នោតអាចមិនទទួលយកលទ្ធផល ហើយនាំគ្នាធ្វើការប្រឆាំងតាមទីសាធារណៈ ឬមួយក៏អាចមានករណីថា គណបក្ស

កាន់អំណាចទុកលទ្ធផលជាមោឃៈ ឬលុបចោលលទ្ធផលនោះតាំងស្រុងតែម្តង។ បើសិនជាមានអំពើហិង្សា ឬបាតុកម្មផ្ទុះឡើង បន្ទាប់ពីលទ្ធផលត្រូវបានប្រកាសឲ្យដឹង ចូរប្រយ័ត្នប្រយែងកុំសរសេររឿងដែលជុតពេលអំពើហិង្សាថែមទៀត តែគួរសរសេរក្នុងរបៀបមួយក្នុងន័យស្វែងរកដំណោះស្រាយចំពោះបញ្ហានយោបាយដែលកំពុងមាន។

## រាយការណ៍ព័ត៌មានផ្អែកលើអ្នកបោះឆ្នោត

តាំងពីដើមសៀវភៅរហូតមកដល់ជំពូកនេះ យើងបានសង្កត់ធ្ងន់ម្តងហើយម្តងទៀតលើសារៈសំខាន់នៃការបញ្ចូលសម្លេងរបស់ប្រជាជនសាមញ្ញក្នុងរឿង។ ដូច្នេះ វាមិននឹងមិនធ្វើឲ្យអ្នកភ្ញាក់ផ្អើលទេ កាលណាអ្នកឮការរំលឹកនេះម្តងទៀត - គឺកុំមិនអើពើនឹងសម្លេងរបស់អ្នកបោះឆ្នោត ដោយសារថាក្នុងប្រព័ន្ធប្រជាធិបតេយ្យ គឺប្រជាជនជាអ្នកកាន់អំណាចពិតប្រាកដ មិនមែនអ្នកនយោបាយទេ។ ផ្តោតលើសេចក្តីត្រូវការ និងការចង់បានរបស់ពលរដ្ឋ។ សម្ភាសន៍ជាមួយពលរដ្ឋជាក្រុមតូចៗនៅតាមផ្លូវ ក្នុងហាងកាហ្វេ ដើម្បីស្វែងយល់ថាតើប្រជាជនយកចិត្តទុកដាក់លើបញ្ហាអ្វី និងអំពីគំនិតរបស់គេថា តើគេយល់ថាអ្នកនយោបាយអាចធ្វើអ្វីបានខ្លះដើម្បីជួយប្រទេស។ ការធ្វើដូច្នេះអនុញ្ញាតឲ្យអ្នកបោះឆ្នោតជាអ្នកកំណត់របៀបវារៈ មិនមែនស្រេចតែអ្នកនយោបាយសម្រេចនោះទេ។

ចូរពិចារណាបង្កើតជាមគ្គុទេសក៍អ្នកបោះឆ្នោតមួយ ដែលផ្តល់ព័ត៌មានមានប្រយោជន៍អំពីការបោះឆ្នោត ក្នុងនោះ មានរឿងអំពីបញ្ហានានាក្នុងសហគមន៍ណាមួយ ឬប្រវត្តិរូបរបស់បេក្ខជនប្រជែងក្នុងការបោះឆ្នោតដែរ។ មគ្គុទ្ទេសក៍អ្នកបោះឆ្នោតផលិតឡើងសម្រាប់ការបោះឆ្នោតឃុំនៅកម្ពុជាមាន ១៩ រឿង រួមមាន រឿងមួយដែលរំលឹកដល់អ្នកបោះឆ្នោតអំពីពេលវេលា និងកន្លែងបោះឆ្នោត ឯកសារ អត្តសញ្ញាណប័ណ្ណបែបណាខ្លះដែលត្រូវការចាំបាច់ របៀបរាប់សន្លឹកឆ្នោត និងពេលណាដែលគេនឹងប្រកាសលទ្ធផល។ រឿងមួយទៀតមានបទសម្ភាសន៍ជាមួយអ្នកបោះឆ្នោត ដោយរំលេចឡើងនូវកង្វល់ដែលមានសារៈសំខាន់បំផុតរបស់ពួកគេ។ រឿងនោះចាប់ផ្តើមដូច្នេះ៖

### *ពួកយើងត្រូវការផ្លូវល្អជាងមុន!*

*នេះជាសេចក្តីប្រាថ្នាទូទៅមួយរបស់ប្រជាជនកម្ពុជានៅទូទាំងប្រទេស ពេលដែលពួកគេត្រូវបានសួរថា អ្វីជារឿងសំខាន់ជាងគេបំផុតដែលអ្នកចង់ឲ្យឃុំដោះស្រាយជូនអ្នក?*

*អ្នកស្រី យុន សុន អាយុ ៤៥ ឆ្នាំ និយាយថា៖ "មានការលំបាកមែនទែនក្នុងការដឹកជញ្ជូនផលស្រូវ ដូច្នេះ ខ្ញុំសង្ឃឹមថាមេឃុំថ្មីនឹងធ្វើផ្លូវល្អជាងមុនឲ្យយើងប្រើ"។ អ្នកស្រីរស់នៅក្នុងឃុំព្រៃរងៀត ខេត្តកំពង់ស្ពឺ ហើយគាត់ជាប្រធានក្រុមពិនិត្យការបោះឆ្នោតរបស់អង្គការ Neutral and Impartial for Free and Fair Elections for Cambodia ក្នុងស្រុកគងពិសី។*

*អ្នកស្រី យុន សុន ជាមនុស្សម្នាក់ក្នុងចំណោមមនុស្សជាង ៥ លាននាក់ ដែលបានចុះឈ្មោះរួចដើម្បីចូលរួមក្នុងការបោះឆ្នោតថ្ងៃ ៣ កុម្ភៈ ដើម្បីជ្រើសរើសថ្នាក់ដឹកនាំសម្រាប់ឃុំទាំង ១.៦២១ ឃុំ-សង្កាត់នៅទូទាំងប្រទេស។ អ្នកបោះឆ្នោតនឹងជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ដែលនឹងប្រើប្រាស់អំណាចថ្មីក្រោមប្រព័ន្ធមួយ ដែលគេហៅថាវិមជ្ឈការ។ ប្រព័ន្ធនេះផ្ទេរអំណាចពីរដ្ឋាភិបាលមជ្ឈិមទៅឲ្យមេដឹកនាំថ្នាក់ក្រោម ដែលត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ"។*

រឿងមួយទៀត ពិនិត្យមើលតើមានអ្វីកើតឡើងខ្លះជាមួយរដ្ឋាភិបាលថ្នាក់ក្រោម នៅក្រោយការបោះឆ្នោត ហើយរឿងមួយទៀតផ្តោតលើតួនាទីរបស់ស្ត្រីក្នុងរដ្ឋាភិបាលមូលដ្ឋាន។

អ្នកសារព័ត៌មានក៏គួរធ្វើតេស្តចំពោះការសន្យាក្នុងយុទ្ធនាការ និងសុន្ទរកថា ដែលអ្នកនយោបាយធ្វើមុនពេលបោះឆ្នោត។ តើពួកគេនិយាយការពិតឬក៏ពួកគេមួលបង្កាច់ការពិត? បើសិនគេជាអ្នកដែលកំពុងកាន់តំណែងកន្លងមក តើពួកគេសម្រេចបានអ្វីខ្លះក្នុងតំណែងនេះ ហើយថាតើពួកគេបោះឆ្នោតរបៀបម៉េចលើសេចក្តីស្នើច្បាប់សំខាន់ៗ? បើពួកគេជាអ្នកថ្មីឡើងមកប្រជែងយកតំណែងពីអ្នកកំពុងកាន់តំណែងស្រាប់ តើពួកគេនឹងអនុវត្តន៍គំនិត និងសេចក្តីស្នើគោលនយោបាយរបស់គេដូចម្តេចទៅ?

## សេចក្តីសន្និដ្ឋាន

បន្ទាប់ពីនាង ផ្លួយ ដែលជាតួអង្គសំខាន់ក្នុងប្រលោមលោកដែលយើងបានដកស្រង់សម្តីនៅខាងដើម បានស្តាប់កូនប្រុសរបស់គាត់ឈ្មោះ អុត ពន្យល់ចប់អំពីអត្ថន័យរបស់នយោបាយ នាងក៏នៅទ្រឹងសញ្ជឹងគិតមួយភ្លែត ហើយក៏បន្លឺពាក្យថា៖ "បើអញ្ចឹង ហេតុអ្វីបានជាយើងគួរមាននយោបាយ?"

# ជំពូក ៩ រាយការណ៍ព័ត៌មាន បែបស៊ើបអង្កេត និងស៊ីជម្រៅ

អ្នកសារព័ត៌មានខ្លះ មិនខ្វល់នឹងវាក្យសព្ទ "រាយការណ៍ព័ត៌មានបែបស៊ើបអង្កេត" ទេ ពីព្រោះគេជឿថាផ្នែកទាំងអស់នៃសារព័ត៌មានក្នុងកម្រិតណាមួយនោះ សុទ្ធតែស៊ើបអង្កេតទាំងអស់។ ក្នុងការងារប្រចាំថ្ងៃ អ្នកសារព័ត៌មានមិនត្រឹមតែព្យាយាមរកឲ្យឃើញថាមានអ្វីបានកើតឡើងនោះទេ ប៉ុន្តែគេក៏ត្រូវការដឹងថា ហេតុអ្វីបានជារឿងរ៉ាវនោះកើតឡើង ហើយវាកើតដោយរបៀបម៉េច អ្នកណាបង្កវាឡើង ហើយតើនឹងមានអ្វីទៀតកើតឡើងទៀតបន្ទាប់ពីនេះ។ គេពិបាកនឹងរកឲ្យបានចម្លើយឲ្យច្បាស់ថាស ឬខ្មៅណាស់ ហើយចម្លើយអាស្រ័យទៅតាមប្រភេទនៃរឿងដែរ។ ដើម្បីធ្វើឲ្យចេញនូវអត្ថបទស៊ើបអង្កេតមួយអ្នកយកព័ត៌មាន ត្រូវប្រឹក្សាជាមួយប្រភពផ្សេងៗគ្នា សម្ភាសន៍មនុស្សច្រើននាក់ ធ្វើដំណើរទៅច្រើនកន្លែង និងចំណាយពេលច្រើនក្នុងការអានឯកសារ។ ពួកគេបន្ត "ជីកកកាយ" រហូតទាល់តែគេរកឃើញចម្លើយទៅនឹងសំណួររបស់គេ។

ក្រៅពីការពន្យល់ខាងលើនេះ ការរាយការណ៍ព័ត៌មានស៊ើបអង្កេត មាននិយមន័យជាប្រពៃណីរបស់វាមួយទៀត នោះ គឺលាតត្រដាង**អំពីពុករលួយ និងការប្រព្រឹត្តខុស**ទាំងឡាយ ហើយធ្វើឲ្យសាធារណជនចាប់អារម្មណ៍ចំពោះអំពើ**អយុត្តិធម៌** ដែលជនណាម្នាក់ - ជានិច្ចកាលច្រើនតែជាជនសំខាន់ និងមានអំណាច - ចង់លាក់បាំងពីអ្នកដទៃ។ ត្រង់នេះហើយដែលអ្នកសារព័ត៌មានបំពេញតួនាទីរបស់ខ្លួនជា**សុនខឆ្មាំ** ឃ្លាំមើលការពារផលប្រយោជន៍សាធារណៈ ហើយព្រុសឲ្យខ្លាំងពេលណាឃើញទង្វើមិនត្រឹមត្រូវ។

ឧទាហរណ៍នៃសេចក្តីរាយការណ៍ព័ត៌មានស៊ើបអង្កេតអាច រួមមាន រឿងអំពីក្រុមហ៊ុនអភិវឌ្ឍន៍ណាមួយកាប់រំលំដើមឈើក្នុងតំបន់ឧទ្យានព្រៃការពារ ឬក៏អាចអំពីរឿងរ៉ាវដែលស្ថាប័នណាមួយរបស់រដ្ឋាភិបាលប្រើប្រាស់មិនសមស្របនូវជំនួយបរទេស។ មានម្តងនោះ កាសែត The Cambodia Daily បានលាតត្រដាងឲ្យដឹងថា ភ្នាក់ងារបោសសំអាតមីនរបស់រដ្ឋាភិបាលបានដោះមីនយកដី មិនមែនសម្រាប់ឲ្យទៅកសិករក្រីក្រទេ តែសម្រាប់ឧត្តមសេនីយយោធាយកទៅសង់ផ្ទះលើទៅវិញ។ កាសែតនោះក៏បានធ្វើសេចក្តីរាយការណ៍ដែរថា ភ្នាក់ងារដោះមីននេះមិនបានចងក្រងទុកឲ្យបានត្រឹមត្រូវនូវទិន្នន័យថាដីណាខ្លះ ដែលបានបោសសំអាតមីនរួចហើយ។

នៅឯទីក្រុងហាណូយឯណោះវិញ កាសែត Tien Phong (Vanguard) បានរាយការណ៍ថា ក្រុមហ៊ុនមួយរបស់វៀតណាមបាននាំចូលដោយខុសច្បាប់នូវសត្វស្វាជាច្រើនពីប្រទេសកម្ពុជា ដោយប្រើអាជ្ញាប័ណ្ណនាំចូលក្លែងក្លាយពីប្រទេសឡាវ។ គេយកសត្វស្វាទាំងនោះទៅលក់ទៅក្រៅប្រទេសដោយបំពានលើច្បាប់អន្តរជាតិសម្រាប់ការពារសត្វព្រៃ។ *[ចូរអានករណីសិក្សានៅចុងជំពូកនេះ]*។ ការធ្វើសេចក្តីរាយការណ៍បែបនេះ ត្រូវការពេលវេលាច្រើន ការប្រឹងប្រែង និងការស្រាវជ្រាវដោយប្រុងប្រយ័ត្ន។

យ៉ាងណាមិញ មិនមែនសេចក្តីរាយការណ៍ព័ត៌មានស៊ើបអង្កេតទាំងអស់ សុទ្ធតែចាំបាច់ត្រូវតែនិយាយអំពីការប្រព្រឹត្តខុសរបស់មនុស្ស ឬរបស់ស្ថាប័នណាមួយនោះទេ។ ច្រើនឆ្នាំកន្លងមកនេះ គោលគំនិតអំពីការធ្វើសេចក្តីរាយការណ៍ស៊ើបអង្កេតបានវិវត្តន៍បន្ថែមអត្ថន័យសំដៅ៖

- ការពន្យល់អំពីដំណើរការស្មុគស្មាញ
- ការរៀបរាប់អំពីរបៀបដែលស្ថាប័នធ្វើការ ឬមិនធ្វើការ
- ការកសាងមកបង្ហាញឡើងវិញនូវព្រឹត្តិការណ៍ស្មុគស្មាញដែលកន្លងផុតទៅ
- ការនិទានប្រាប់រឿងក្រោយឆាកឲ្យសាធារណជនបានដឹង
- ការកំណត់អត្តសញ្ញាណ និងការពន្យល់អំពីនិន្នាការថ្មីៗក្នុងសង្គម
- ការស្វែងរកដំណោះស្រាយចំពោះបញ្ហាស្មុគស្មាញ ដូចជា បញ្ហាភាពអនាថាគ្មានទីលំនៅ បញ្ហាភាពក្រីក្រ បញ្ហាការបំពានគ្រឿងញៀន ជាដើម

ជួនកាលគេហៅរបៀបនេះថា **សេចក្ដីរាយការណ៍ព័ត៌មានស៊ើបអង្កេតស៊ីជម្រៅ** ឬ**សេចក្ដីរាយការណ៍ព័ត៌មានគម្រោងពិសេស**។ ទោះជាអ្នកចង់ឲ្យឈ្មោះវាថាជាស្អីក៏ដោយ ការធ្វើសេចក្ដីរាយកាណ៍ព័ត៌មានបែបនេះ ធម្មតាត្រូវការពេលវេលាច្រើនថ្ងៃទម្រាំបានព័ត៌មានមកសរសេរឲ្យបានគ្រប់ជ្រុងជ្រោយ។ ជាទូទៅ ព័ត៌មានដែលប្រមូលបានមកច្រើនតែជាព័ត៌មានដែលអ្នកអានមិនដែលបានឃើញពីមុនមក។

# ធ្វើបែបណាខ្លះ

អ្នកយកព័ត៌មានស៊ើបអង្កេតប្រើឧបករណ៍ដូចគ្នានឹងអ្វីដែលអ្នកសារព័ត៌មានដទៃទៀតប្រើដែរ គឺគេធ្វើការស្រាវជ្រាវឯកសារ ប្រើការសង្កេត និងការសម្ភាសន៍ជាមួយមនុស្សច្រើននាក់។ អ្វីដែលញែកអ្នកសារព័ត៌មានស៊ើបអង្កេតឲ្យខុសពីអ្នកឯទៀត គឺភាពក្លាហាន ស្ទិតស្ទាញឈ្មុសឈ្មុល និងការតាំងចិត្តរបស់ពួកគេ។

**គោលគំនិត :** ការធ្វើរឿងច្រើនតែចាប់ផ្ដើមពី**គន្លឹះ (tip)** ពីប្រភពគួរឲ្យទុកចិត្តបានណាមួយដែលដឹងរឿងផ្ទៃក្នុង។ ប្រភពបែបនេះច្រើនតែរក្សាភាពអនាមិក **(anonymous)** ឬគ្រាន់តែផ្ដល់ព័ត៌មានដែលមិនអាចយកទៅចុះផ្សាយបាន **(off the record)** គឺមានន័យថា ពួកគេមិនចង់ចេញមុខជាប្រភពព័ត៌មានទេ ដូច្នេះអ្នកសារព័ត៌មានត្រូវតែធ្វើយ៉ាងណារកផ្ទៀងផ្ទាត់បញ្ជាក់ព័ត៌មាននោះនៅកន្លែងណាដែលខ្លួនអាចរកបាន។ វាអាចត្រូវចំណាយពេលច្រើនថ្ងៃ ច្រើនសប្ដាហ៍ ឬក៏យូរជាងនេះផងទម្រាំនឹងបញ្ជាក់ព័ត៌មាននោះបាន។ កាលណាអ្នកយកព័ត៌មានសំបូរប្រភពព័ត៌មានកាន់តែច្រើន ពួកគេក៏កាន់តែមានឱកាសច្រើនក្នុងការរកបានគំនិតសម្រាប់ធ្វើរឿងបែបស៊ើបអង្កេតដែរ។

ប៉ុន្តែជារឿយៗ គំនិតធ្វើរឿងស៊ើបអង្កេតកើតចេញពីអ្នកយកព័ត៌មានចង់ដឹង តាមដានព្រឹត្តិការណ៍ដំណឹងមួយ ដើម្បីរកមើលថា តើអ្វីពិតប្រាកដដែលបានកើតឡើង ហេតុអ្វីបានជាវាកើតឡើង ហើយវាកើតឡើងបែបម៉េច ហើយតាំងពីពេលនោះមកមានអ្វីទៀតកើតឡើង ឬទេ។ ការជជែកជាមួយមនុស្សម្នាក្នុងមុខព្រួញការងាររបស់យើង ការយល់ដឹងអំពីដំណើរប្រព្រឹត្តទៅនៃអ្វីៗគ្រប់បែបយ៉ាង និងការចេះងឿងឆ្ងល់អំពីការវិវត្តមិនធម្មតាណាមួយ ទាំងអស់នេះអាចនាំទៅរកការផុះគំនិតសម្រាប់ធ្វើរឿងស៊ីជម្រៅបានដែរ។ ឧទាហរណ៍ រដ្ឋាភិបាលបានដាក់ចេញគោលនយោបាយថ្មី ផ្ដល់ការថែទាំសុខភាពដោយឥតគិតថ្លៃជូនអ្នកក្រីក្រ។ អ្នកយកព័ត៌មានចំណានម្នាក់ ពិតជាស៊ើបអង្កេតមើលក្រោយមកទៀតថា តើប្រជាជនពិតជាបានទទួលសេវាថែទាំសុខភាពដោយឥតគិតថ្លៃមែនទេ តើសេវានោះមានគុណភាពល្អ ឬទេ ហើយថាតើប្រព័ន្ធសេវាកម្មថែទាំសុខភាពឥតគិតថ្លៃនោះ ពិតជាដំណើរការស្រួលដូចអ្នកនយោបាយសន្យាទេ។

***សាវតារ*** **:** តាមតែអាចធ្វើទៅបាន អ្នកយកព័ត៌មានចាំបាច់ត្រូវតែសិក្សាស្វែងយល់ឲ្យបានច្រើនអំពីប្រធានបទ និងស្ថាប័ន ដែលគេកំពុងធ្វើការស៊ើបអង្កេត។ អង្គផ្សំសាវតារ រួមមាន រឿងដែលបានចុះផ្សាយរួចមកហើយ របាយការណ៍រដ្ឋាភិបាល សៀវភៅសំណៅយោង ព្រឹត្តិបត្រក្រុមហ៊ុន ការស្រាវជ្រាវអ៊ិនធឺណិត និងបទសម្ភាសន៍ជាមួយមនុស្សដែលមានពុទ្ធិលើបញ្ហាដែលយើងកំពុងស៊ើបអង្កេត។

**ធ្វើសម្ភាសន៍ល្អិតល្អន់ :** សេចក្តីរាយការណ៍ស៊ើបអង្កេតច្រើនតែផ្តើមដោយសម្ភាសន៍ជាច្រើន ដែលមិនទាន់អាចយកទៅចុះផ្សាយបាន (off the record) ហើយបន្ទាប់ពីនោះ គេយកព័ត៌មានពីកិច្ចសម្ភាសន៍ទៅរកការផ្ទៀងផ្ទាត់ និងបញ្ជាក់អះអាងថែមទៀត។ ដំណាក់កាលនេះ អាចរួមបញ្ចូលសម្ភាសន៍ជាមួយអ្នកឯកទេស អ្នកធ្វើការអង្គការមិនមែនរដ្ឋាភិបាល មន្ត្រីរដ្ឋាភិបាល អ្នកនយោបាយ និងអ្នកស្រាវជ្រាវឯករាជ្យ។ អ្នកយកព័ត៌មានក៏មិនត្រូវមើលរំលងប្រជាជនសាមញ្ញដែលអាចមានការពាក់ព័ន្ធក្នុងរឿងក្នុងនោះ មានអ្នកស្រុក អ្នកជិតខាង និងម្ចាស់ហាងជាដើម។

ចុងបញ្ចប់មាន **បទសម្ភាសន៍ប្រឈមមុខ (confrontational interview)**។ នេះជាកន្លែងដែលអ្នកយកព័ត៌មានស្វែងរកអត្ថាធិប្បាយពីបុគ្គលដែលមានការទទួលខុសត្រូវដោយផ្ទែក ឬដោយផ្ទាល់ចំពោះទង្វើខុសឆ្គងណាមួយ។ បទសម្ភាសន៍បែបនេះពិបាកធ្វើណាស់ ប៉ុន្តែគេចាំបាច់ត្រូវតែធ្វើ មុននឹងគេអាចយករឿងទៅចុះផ្សាយបាន។ ជនសង្ស័យក្រោមការស៊ើបអង្កេតគួរទទួលបានឱកាសសម្រាប់ធ្វើការឆ្លើយតបទៅនឹងភស្តុតាងដែលគេប្រមូលបានមកដាក់បន្ទុកលើគាត់។ ជាញឹកញាប់ គេតែងឃើញមានការពន្យល់ហេតុផលសមរម្យថា តើហេតុអ្វីបានជាហេតុការណ៍ណាមួយនោះកើតឡើង។ គោលដៅក៏ប្រហែលជាអាចស្រាយបំភ្លឺអង្គផ្សំ ដើម្បីធ្វើរឿងឲ្យកាន់តែមានភាពត្រឹមត្រូវជាក់លាក់។ បើអ្នកយកព័ត៌មានមិនឲ្យឱកាសទៅមនុស្សណាម្នាក់ទៀតឲ្យឆ្លើយ គេមុខជាទទួលរងនូវការចោទប្រឆាំងថាមានភាពលំអៀង មិនយុត្តិធម៌ និងខ្វះភាពជាក់លាក់ត្រឹមត្រូវ។ កំហុសតែមួយក្នុងរឿងស៊ើបអង្កេតមួយអាចបំផ្លាញនូវការងារទាំងអម្បាលម៉ានដែលកាសែតប្រឹងសម្រេចបានកន្លងមក។ វាក៏អាចដែរថា មនុស្សដែលផ្តល់តម្រុយបឋមមិនបានឲ្យសាច់រឿងមួយពេញលេញទាំងស្រុងទេ។

**ឯកសារ** អាចទ្រទ្រង់ ឬបង្ហាញផ្ទុយទៅនឹងអ្វីដែលមនុស្សម្នាក់បាននិយាយចោទប្រកាន់ ហើយឯកសារបែបនេះច្រើនមានភស្តុតាង ដែលកាន់តែបង្កើនភាពជឿទុកចិត្តបាន ដែលតាមរយៈនោះ វាក៏អាចជួយបន្ថែមកិត្តិនាមរបស់សាច់រឿងផងដែរ។ ឯកសារអាចមានជាអ៊ីម៉េល កំនត់ត្រាទូរស័ព្ទ ការជួញដូរអចលនទ្រព្យ និងថវិការដ្ឋាភិបាល។ លទ្ធភាពទទួលបានឯកសារអាចមានសភាពខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយ តែប្រទេសខ្លះទៀត (ដូចជាប្រទេសថៃ និងវៀតណាម) មានច្បាប់ដែលអាចឲ្យសាធារណជន ក្នុងនោះមានអ្នកសារព័ត៌មានផងដែរ ធ្វើការស្នើសុំច្បាប់ចម្លងនៃឯកសារផ្លូវការ។ ក្នុងប្រទេសខ្លះ លទ្ធភាពទទួលបានព័ត៌មានបែបនេះត្រូវបានគេឲ្យឈ្មោះថាជា ច្បាប់ ស្តីពីសេរីភាពក្នុងការទទួលបានព័ត៌មាន **(freedom of information laws)**។

នៅក្នុងភាពជាក់ស្តែង វាអាចទាមទារពេលវេលាយូរក្រៃលែងដែរ ដើម្បីរកឯកសារបានតាមមធ្យោបាយផ្លូវការ។ ពេលខ្លះ វាងាយទៅវិញបើសិនជាយើងមានស្គាល់ជាមិត្តដែលធ្វើការក្នុងស្ថាប័ន ហើយមានលទ្ធភាពជួយរកឯកសារនោះឲ្យយើងបាន។ យ៉ាងណាក៏ដោយ សំខាន់អ្នកសារព័ត៌មានត្រូវចេះផ្តើមធ្វើសំណើសុំឯកសារណាដែលត្រូវបានគេកំណត់ថាជាសម្បត្តិសាធារណៈ។ ការទាមទារបែបនេះ

អាចរួមចំណែកក្នុងការលើកស្ទួយវប្បធម៌បើកចំហ គណនេយ្យភាព និងអភិបាលកិច្ចល្អ។

**ការសង្កេត** តែងតែជាមធ្យោបាយដ៏ប្រពៃបំផុតសម្រាប់អ្នកសារព័ត៌មានប្រើ ដើម្បីប្រមូលព័ត៌មាន និងធ្វើការផ្ទៀងផ្ទាត់វា។ ការប្រមូលបានព័ត៌មានពីការឃើញហេតុការណ៍ផ្ទាល់ភ្នែក ពិតជាពិបាកសម្រាប់អ្នកដែលពាក់ព័ន្ធក្នុងរឿងរ៉ាវនោះបដិសេធបានណាស់។ ការសង្កេតក៏មានប្រយោជន៍ដែរនៅត្រង់ថា វាផ្តល់ការពិពណ៌នារ៉ាយរ៉ាប់បានល្អ ដែលនេះជារបៀបមួយសម្រាប់ធ្វើការរាយការណ៍ព័ត៌មានស៊ើបអង្កេត និងស៊ីជម្រៅ ឲ្យកាន់តែមានលក្ខណៈទាក់ទាញគួរឲ្យចង់អានថែមទៀត។ គឺវាជួយធ្វើសាច់រឿងទាំងមូលឲ្យរស់រវើក។

អ្នកយកព័ត៌មាន អ៊ុង ចាន់សុភា របស់កាសែត Cambodge Soir ចង់ពិនិត្យមើលថាតើពលរដ្ឋដែលតាំងលំនៅខុសច្បាប់ ហើយត្រូវបានគេបណ្តេញចេញ មានជីវភាពរស់នៅដូចម្តេចខ្លះ ក្រោយពីត្រូវបានគេយកទៅឲ្យនៅកន្លែងថ្មីបីកន្លែង នៅជាយក្រុងភ្នំពេញ។ នាងបានជជែកសួរនាំជាមួយអតីតអ្នកតាំងលំនៅខុសច្បាប់ មន្ត្រីសាលាក្រុង បុគ្គលិកអង្គការសិទ្ធិមនុស្ស ហើយទៅមើលផ្ទាល់ដល់កន្លែងដែលជាទីតាំងលំនៅថ្មីនៅក្រៅក្រុង។ ក្នុងការសរសេរ នាងប្រើអានុភាពនៃការសង្កេតរបស់នាងធ្វើការរ៉ាយរ៉ាប់ចេញជាឆាកទិដ្ឋភាពនៃអត្ថបទស៊ីជម្រៅរបស់នាង ដូចមានក្នុងឧទាហរណ៍នៅខាងក្រោម៖

*នៅលើវាលមួយគ្មានដើមឈើ ចម្ងាយប្រមាណជា ២០ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ គេអាចមើលឃើញពីចម្ងាយនូវផ្ទះឈើឈរជាជួរៗ។ ស្ត្រីវ័យចំណាស់បួន-ប្រាំនាក់ ក្នុងទឹកមុខស្រងូតស្រងាត់ កំពុងជជែកគ្នាក្បែរគំនរឈើមួយ ដែលគេត្រៀមសម្រាប់ធ្វើខ្ទម។ ស្ត្រីទាំងនេះស្ថិតក្នុងចំណោមអ្នកដែលអាជ្ញាធរបណ្តេញចេញពីភូមិនៃសាទបុងកោះ ឲ្យមករស់នៅទីនេះលើដីទំហំ ៥ ម៉ែត្រ គុណនឹង ១២ ម៉ែត្រ ក្នុងមួយគ្រួសារ។*

*ទឹកភ្នែកចាប់ផ្តើមហូរធ្លាក់ចុះតាមថ្ពាល់របស់គាត់ ពេលដែលអ្នកស្រី ត្រេស នាង ជាស្ត្រីជនជាតិចាម រៀបរាប់ប្រាប់អំពីការបណ្តេញចេញពីតំបន់ជ្រោយចង្វារដែលគាត់ធ្លាប់រស់នៅតាំងពីឆ្នាំ ១៩៨០ និងដែលនៅទីនោះមានព្រះវិហារដែលគាត់ធ្លាប់ទៅធ្វើការសូត្រធម៌ព្រះ។ ឥឡូវនេះ គាត់គ្មានលទ្ធភាពនឹងចំណាយ ១ ម៉ឺនរៀល សម្រាប់បង់ថ្លៃម៉ូតូឌុប ដើម្បី*



*ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនមិនបានឲ្យគេដឹងអំពីទំហឹងនៃការបញ្ចេញឧស្ម័នកាបោនរបស់ខ្លួនទេ។*

*ទៅព្រះវិហារនោះទៀត ទេ។ គាត់មានក្ដីកង្វល់ ថាដូនតារបស់គាត់នឹងមានការខឹងសម្បារជាមួយ គាត់។ ហើយនៅទីកន្លែងថ្មីនេះ គាត់មិនដឹងថា តើត្រូវធ្វើអ្វីបានទេ ដើម្បីចិញ្ចឹមជីវិត។*

បន្ទាប់មក សុភា អ្នកយកព័ត៌មានបង្ហាញ ទិដ្ឋភាពនៅសហគមន៍មួយទៀត៖

*ស្ត្រីវ័យចំណាស់ម្នាក់ឈ្មោះ សែន ក្នុងពេលដែល កំពុងលេងបៀរជាមួយអ្នកជិតខាង បានបន្លឺឡើង ថា៖ "តើមានរបរអ្វីដែលយើងអាចធ្វើបាននៅក្នុង កន្លែងស្ងាត់ជ្រងុំដូចនេះ? គ្រួសាររបស់គាត់ពឹង អាស្រ័យលើប្ដីរបស់គាត់ ដែលជាកម្មករសំណង់ នៅទីក្រុងភ្នំពេញ ហើយរកបានប្រហែល ៥០ ដុល្លារ-អាមេរិកប៉ុណ្ណោះក្នុងមួយខែ។ អ្នកស្រី សែន និយាយ បន្តទៀតថា៖ "ឥឡូវនេះ អ្វីៗត្រូវបានក្លាយជាឯកជន អស់ ហើយថ្លៃទៀតផង។ ខ្ញុំមានអារម្មណ៍ថា ត្រូវបាន គេយកមកបំបោះបង់ចោលអញ្ចឹង"។*

*ខ្ទមជាច្រើនក្នុងភូមិអ្នកស្រី សែន ត្រូវបានបិទ ទ្វារ។ ម្ចាស់របស់វាបានលក់វាទៅឲ្យមន្ត្រី នគរបាល នៅទីក្រុងភ្នំពេញបាត់អស់ទៅហើយ។ ខ្ទមមួយចំនួន ទៀតត្រូវបានគេរឹបអូស ដោយសារម្ចាស់គ្មានលុយ សងបំណុល។ នៅក្បែរនោះ គេអាចស្ដាប់ឮសម្លេង ប្រកែកគ្នារវាងបុរសម្ចាស់លុយ កំពុងអង្គុយក្នុងឡាន មួយ និងស្ត្រីជំពាក់បំណុលម្នាក់។ ស្ត្រីនោះបានចោទ បុរសនោះថាបានកេងប្រវ័ញ្ចពីគាត់អស់ប្រាក់ ២៤ ដុល្លារ។ អ្នកស្រី សែន និយាយថា៖ "ប្ដីប្រពន្ធខ្លះ មានកូនច្រើន ហើយខ្ចីបុលគេគ្រាន់តែយកមកទិញ ម្ហូបឲ្យកូន។ ពួកគេមិនអាចសងបំណុលវិញបាន ទីបំផុតត្រូវតែលក់ផ្ទះ"។*

សុភា ក៏បានបង្ហាញក្នុងរឿងដែរថា ការជំពាក់ បំណុលច្រើនបានបង្ខំគ្រួសារជាងពាក់កណ្ដាលនៃ ចំនួនដែលអ្នករស់នៅទីតាំងថ្មី ឲ្យលក់ផ្ទះថ្មដែលគេ បានប្រគល់ឲ្យ ដើម្បីយកលុយសងបំណុល។ ជាមួយគ្នានេះ នាងក៏បានស្វែងរកចម្លើយពីមន្ត្រី សាលាក្រុង ដើម្បីធ្វើរឿងឲ្យមានតុល្យភាព។

**ភាពប្រឈម៖** រាយការណ៍ព័ត៌មានស៊ើបអង្កេត ជាកិច្ចការតឹងតែង ហើយមានភាពប្រឈមច្រើន។ អ្នកសារព័ត៌មានភាគច្រើនមិនមានលុយ និងពេល វេលាសម្រាប់ចំណាយលើការស្រាវជ្រាវស៊ីជម្រៅ ទេ។ឧបសគ្គផ្សេងទៀតមានជាអាទ៍ការលំបាកក្នុង ការរកឲ្យបាននូវឯកសារមកធ្វើជាភស្តុតាងបញ្ជាក់ រឿង ឬក៏មួយសម្ពាធពីអ្នកផ្សាយពាណិជ្ជកម្ម និង មន្ត្រីរដ្ឋាភិបាលមិនឲ្យបុះផ្សាយលទ្ធផលនៃការស៊ើប អង្កេត។ បញ្ហាធ្ងន់ធ្ងរមួយទៀត គឺសន្តិសុខផ្ទាល់ខ្លួន និងការគំរាមកំហែង ដែលអាចកើតមានមកលើអ្នក សារព័ត៌មាន។ អ្នកសារព័ត៌មានថៃម្នាក់នៅឈៀងម៉ៃ ត្រូវបង្ខំចិត្តពាក់អាវការពារគ្រាប់កាំភ្លើង បន្ទាប់ពីគាត់ បានសរសេររឿងអំពីអំពើពុករលួយក្នុងការិយាល័យ របស់អភិបាលខេត្តនោះ។ វាបានជួយស្រោចស្រង់ ជីវិតគាត់ ពេលខ្មាន់កាំភ្លើងបាញ់គាត់ក្នុងខណៈ ដែលគាត់ហៀបនឹងចូលក្នុងរថយន្តរបស់គាត់។

អ្នកសារព័ត៌មានក៏អាចត្រូវឆ្លាស់ការងាររវាង ការងាររាយការណ៍ស៊ីជម្រៅជាមួយនឹងកិច្ចការ ប្រចាំថ្ងៃផងដែរ។ អ្នកយកព័ត៌មានជោគជ័យក្នុង ការងារតែងបំរុងទុកមួយម៉ោងទៅពីរម៉ោង មួយថ្ងៃ ដើម្បីធ្វើកិច្ចការខ្លះសម្រាប់អត្ថបទស្រាវជ្រាវវែងៗ។ កាលណាគេប្រាស់ក្នុងខ្លួនថានឹងផលិតរឿងស៊ើប អង្កេតនោះចេញបាន គេនឹងសុំការគាំទ្រពីនិពន្ធ នាយកឲ្យជួយបញ្ចប់វា។ ពេលដែលត្រូវឡប់បី សុំពេលវេលា និងធនធានថែមទៀតសម្រាប់បញ្ចប់ គំរោងរឿងបែបនេះ ពួកគេត្រូវតែត្រៀមខ្លួនពន្យល់ និពន្ធនាយករបស់គេអំពីហេតុផលថា ហេតុអ្វីបាន ជារឿងនេះសំខាន់ត្រូវតែសរសេរបុះផ្សាយ។

**សីលធម៌៖** អ្នកសារព័ត៌មានខ្លះប្រើ**កាមេរ៉ា ឬ ឧបករណ៍ថតសម្លេងលាក់លៀម** ហើយបន្លំខ្លួនយក

ព័ត៌មាន ដែលធ្វើដូច្នេះមានន័យថា ពួកគេមិនបាន បង្ហាញអត្តសញ្ញាណខ្លួនថាជាអ្នកសារព័ត៌មានទេ ហើយតាំងខ្លួនជាអ្នកផ្សេងវិញ។ ធ្វើរបៀបនេះអាច ធ្វើឲ្យខូចខាតដល់កេរ្តិ៍ឈ្មោះអ្នកសារព័ត៌មាន ហើយក៏ អាចគេចាត់ទុកថាជាការលុកលុយចូលឯកជនភាព របស់អ្នកដទៃបានផងដែរ។ តែយ៉ាងណាមិញ នេះ អាចជាវិធីតែមួយដែលអាចរកការអំណះអំណាង បំពោះអ្វីមួយ ដូចជារឿងពុករលួយជាដើម។

អ្នកសារព័ត៌មានមកពីបណ្ដាញព័ត៌មានអនឡាញ របស់ឥណ្ឌា ឈ្មោះ Tehelka បានធ្វើឲ្យមានភាព ចម្រូងចម្រាសមួយនៅពេលដែលពួកគេបន្លំខ្លួនធ្វើជា ពួកធុរកិច្ចក្រុមហ៊ុនលក់សព្វាវុធមួយ។ ពួកគេបាន ណាត់ជួបជាមួយមន្ត្រីក្រសួងការពារជាតិឥណ្ឌា ហើយលបថតកិច្ចប្រជុំនេះ ដោយប្រើកាមេរ៉ាលាក់ក្នុង កាបូបយួរដៃ។ អ្នកសារព័ត៌មានទាំងនោះបានសូក លុយទៅឲ្យមន្ត្រីក្រសួងរៀបចំការជប់លាងស៊ីផឹក និង ជំនួបជាមួយនារីរកស៊ីផ្លូវភេទ ដើម្បីស្វែងរកឲ្យបាន នូវកុងត្រាលក់អាវុធបច្ចេកវិទ្យាខ្ពស់ ដែលតាមពិត មិនមានទេនោះ ទៅឲ្យក្រសួងការពារជាតិឥណ្ឌា។ ក្រោយពីមានការបុះផ្សាយព័ត៌មានលើបណ្ដាញរបស់ Tehelka មក រដ្ឋមន្ត្រីការពារជាតិឥណ្ឌាបានលាលែង ពីតំណែង ប៉ុន្តែភាពចម្រូងចម្រាសនេះបានឡងមក រកអ្នកយកព័ត៌មានវិញ ដោយសារប្រើមធ្យោបាយ បញ្ឆោត និង**ដាក់អន្ទាក់**ពួកមន្ត្រី។ ដោយប្រឈមមុខ នឹងសម្ពាធពីរដ្ឋាភិបាល បណ្ដាញព័ត៌មាន Tehelka នេះក៏បិទទ្វាររកស៊ីរបស់ខ្លួនមួយរយៈពេលដែរទៅ។

នៅសហរដ្ឋអាមេរិក អ្នកសារព័ត៌មានពីរនាក់ បានបន្លំខ្លួនចូលធ្វើការក្នុងផ្នែកសាច់នៅស៊ុបពែរ ម៉ាឃិតមួយ។ ពួកគេបានសង្កេតឃើញពីរបៀបដែល ក្រុមហ៊ុននោះលក់សាច់ ត្រីផុំក្លិន និងបន្លែរលួយ ហើយពួកគេបានប្រើកាមេរ៉ាលាក់លៀមក្នុងការថត សកម្មភាពទាំងអស់នេះ។ ក្រោយពីរឿងនេះត្រូវបាន ធ្វើការផ្សព្វផ្សាយតាមកញ្ចក់ទូរទស្សន៍ ក្រុមហ៊ុននោះ បានប្ដឹងអ្នកយកព័ត៌មានពីបទក្លែងបន្លំ បទទន្ទ្រាន ចូលគ្មានការអនុញ្ញាត និងបទក្បត់ក្រុមហ៊ុន។ គណៈវិនិច្ឆ័យបានបង្គាប់ឲ្យទីភ្នាក់ងារព័ត៌មាននោះ បង់ជាងប្រាំលានដុល្លារសងការខូចខាតដល់ក្រុមហ៊ុន តែចំនួននេះ ត្រូវបានបន្ថយដោយចៅក្រមតុលាការ ឧទ្ធរណ៍វិញ។

ច្រើនឆ្នាំមុននេះទៅទៀត អ្នកសារព័ត៌មានបាន បង្កើនជាផ្ទះសំណាក់ឈ្មោះថា The Mirage ដើម្បី លបមើលតាមដានពួកអធិការកិច្ចក្រុង និងរដ្ឋទទួល សំណូក។ វាជាកិច្ចការយកព័ត៌មានស៊ើបអង្កេតល្អ មួយ ប៉ុន្តែអ្នកយកព័ត៌មានត្រូវបានគេបដិសេធមិន ឲ្យរង្វាន់ Pulitzer Prize ដែលជារង្វាន់កំពូលផ្នែក សារព័ត៌មាននៅអាមេរិក ពីព្រោះក្រុមគណៈវិនិច្ឆ័យ យល់ឃើញថា វិធីដែលគេប្រើក្នុងការយកព័ត៌មាន នោះខុសនឹងក្រមសីលធម៌។ ពួកគេនិយាយថាអ្នក យកព័ត៌មានមិនគួរប្រឡូកក្នុងការនិយាយកុហក ទេ។

ដូច្នេះ អ្នកត្រូវពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយ នូវបច្ច័យអាក្រក់ដែលអាចកើតមាន មុននឹងអ្នក សម្រេចធ្វើការយកព័ត៌មានលាក់លៀម។

**ផ្គុំរឿងចូលគ្នា** ៖ មុននឹងអ្នកចាប់ផ្ដើមសរសេរ ចូរពិនិត្យវាយតម្លៃភស្តុតាង ដែលអ្នកប្រមូលបាន ដើម្បីឲ្យប្រាកដក្នុងខ្លួនថា អ្នកមានព័ត៌មានដែលអ្នក ត្រូវការអស់ហើយ។ តើអ្នកមានភ្លេចសម្ភាសន៍មនុស្ស សំខាន់ៗពាក់ព័ន្ធក្នុងរឿងនេះ ដែលអាចធ្វើឲ្យរឿងនេះ កាន់តែមានភាពជឿទុកចិត្តបានថែមទៀត? តើអ្នក ប្រមូលភស្តុតាងបានគ្រប់គ្រាន់យកមកបញ្ជាក់អះ-អាងរឿងហើយ ឬនៅ? តើអ្នកត្រូវកែសម្រួលគំនិត ដើមរបស់អ្នកក្នុងការធ្វើរឿងនេះដែរ ឬទេ?

មិនចាំបាច់ប្រើអ្វីៗទាំងអស់ដែលអ្នកប្រមូលបាននោះ ទេ។ ប្រើតែឧទាហរណ៍ល្អបំផុត សេចក្ដីពិស្ដារដែល មានអំណះអំណាងជឿបាន និងសម្រង់សម្ដីសំខាន់ៗ បានហើយ។ បើទោះជាថាអ្នកបានចំណាយពេលរាប់

សប្តាហ៍ រាប់ខែមើលរបាយការណ៍សម្ភាសន៍មនុស្សពាក់ព័ន្ធ វាមិនបានន័យថា អ្នកត្រូវតែចែករំលែកអ្វីៗគ្រប់បែបយ៉ាងឲ្យអ្នកអានដឹងទេ។ ចូរប្រកាន់យកស្ទីលបទពិពណ៌នាក្នុងការសរសេររឿងស៊ើបអង្កេតក្នុងរបៀបមួយដែលជាទីចាប់អារម្មណ៍ដល់អ្នកអាន។

ចុងក្រោយ ចូរពិចារណាមើលអំពីរបៀបដែលអ្នកវេចខ្ចប់ជាតុផ្សំដែលអ្នកប្រមូលបាន។ ចូរប្រើក្រាហ្វិក ផែនទី រូបថត ក្នុងការអធិប្បាយរឿងឲ្យរស់រវើក។ រឿងបែបនេះប្រហែលជាត្រូវចុះផ្សាយជាស៊េរី ពីរដង ឬក៏ច្រើនជាងនេះក៏ថាបាន ដោយមានអត្ថបទតូចៗអមជាមួយផង។ សម្រាប់ចុះផ្សាយលើអ៊ិនធឺណិត អ្នកអាចថែមបណ្តាញតភ្ជាប់ទៅនឹងឯកសារ ឬបទសម្ភាសន៍ទាំងស្រុងដែលអ្នកប្រមូលបាននោះជូនអ្នកអានមើលបានដែរ។

## ករណីសិក្សា :
## ការជួញដូរសត្វព្រៃខុសច្បាប់

ឥឡូវយើងងាកមកមើលឲ្យបានជិតដល់បន្តិចនូវរឿងការជួញដូរសត្វព្រៃខុសច្បាប់ដែលបុះផ្សាយក្នុងកាសែត Tien Phnong នៅវៀតណាម។ រឿងនេះសរសេរដោយលោក Quoc Dung ចែកចេញជាបួនផ្នែក ហើយមានចំណងជើងថា "**បណ្តាញជួញដូរសត្វព្រៃឆ្លងដែនមួយត្រូវបានវែកមុខ**" **/A Trans-border Wildlife Trade Network Unmasked**។ ការប្រមូលព័ត៌មានសម្រាប់ធ្វើរឿងនេះ ត្រូវចំណាយពេលបីឆ្នាំ និងការធ្វើដំណើររាប់ពាន់គីឡូម៉ែត្រទៀតផង។

ខាងក្រោមនេះជាសម្រង់ខ្លះៗនៃរឿង៖

*ក្រុមហ៊ុន Tan Hoi Dong Co., Ltd. ដែលស្ថិតក្នុងខេត្តតាយនិញ ប៉ែកនិរតីប្រទេសវៀតណាម និងនៅទីជាប់ស្រយាលមួយ កៀកច្រកទ្វារព្រំដែននៃប្រទេសកម្ពុជា ត្រូវបានគេស្គាល់ក្នុងប្រទេសវៀតណាមថាជាក្រុមហ៊ុនមួយ ក្នុងចំណោមក្រុមហ៊ុនមួយចំនួន ដែលទទួលបានប្រកាសនីយបត្រពីអង្គការ CITES [CITES = Convention on International Trade in Endangered Species of Wild Fauna and Flora/អនុសញ្ញាអន្តរជាតិស្តីពីការជួញដូរសត្វព្រៃ និងរុក្ខជាតិ ដែលធ្វើនីយតកម្មលើការជួញដូររុក្ខជាតិ និងសត្វព្រៃលើពិភពលោក]។*

*ប៉ុន្តែមនុស្សភាគច្រើនមិនបានដឹងទេថាទីតាំងនេះ ជាច្រកឆ្លងកាត់សំខាន់មួយសម្រាប់បណ្តាញដ៏ស្មុគស្មាញ និងធំរបស់ពួករកស៊ីរត់ពន្ធសត្វព្រៃឆ្លងដែននៅប្រទេសវៀតណាម។ បណ្តាញនេះមានរហូតដល់ការប្រើអាជ្ញាបណ្ណ CITES ក្លែងក្លាយយកមកពីប្រទេសឡាវ សម្រាប់នាំចេញសត្វស្វាដែលគេចាប់នៅប្រទេសកម្ពុជា ដែលនៅទីនោះការអនុវត្តច្បាប់ការពារសត្វព្រៃនៅមានភាពទន់ខ្សោយនៅឡើយ។*

*ដូចរឿងនេះ នឹងលាតត្រដាងឲ្យបានដឹងក្រុមហ៊ុន Tan Hoi Dong និងសាខារបស់វាបានអស់ពេលជាយូរមកហើយ ប្រើប្រាស់ឯកសារក្លែងក្លាយសម្រាប់នាំចូលសត្វព្រៃ ដោយយកកម្មវិធីបង្កាត់ពូជ ជាគម្របបិទបាំងការនាំចូលដោយខុសច្បាប់របស់ខ្លួន។*

*មកទល់ពេលនេះ មិនទាន់មានភស្តុតាងណាមួយបញ្ជាក់អំពីការបំពានច្បាប់ការពារព្រៃឈើ ពាក់ព័ន្ធមន្ត្រីរបស់នាយកដ្ឋានការពារព្រៃឈើ និងអាជ្ញាធរវៀតណាមទទួលបន្ទុក CITES។ ស្ថាប័នទាំងពីរនេះជាភ្នាក់ងារដែលរដ្ឋាភិបាល និងប្រជាជនបានទុកចិត្តឲ្យការពារព្រៃ និងអភិរក្សសត្វព្រៃ ដែលកំពុងរងគ្រោះជិតផុតពូជ។ បើភស្តុតាងក្នុងអត្ថបទនេះជាការពិត មន្ត្រីម្នាក់នៃអង្គការអភិរក្សអន្តរជាតិមួយ ដែលមានការិយាល័យក្នុងក្រុងហាណូយ បានចាត់ទុកថាករណីនេះថាជាអំពើទុច្ចរិតមួយហើយ។*

លោក Quoc Dung បានទទួលបានការលបខ្សឹបពីសំណាក់អ្នកអភិរក្សអន្តរជាតិម្នាក់ ដែលធ្វើការក្នុងឧទ្យានជាតិនាប៉ែកខាងជើងប្រទេសវៀតណាម។ គាត់សរសេរអត្ថបទទីមួយអំពីរឿងនេះនៅខែ សីហា ២០០៤ ហើយក្រោយមកទៀត គាត់ទទួលបានព័ត៌មានថែមទៀតពីប្រភព "រនុកក្នុង" ម្នាក់។ រឿងនេះត្រូវបានតដោយបួនភាគទៀតនៅឆ្នាំ ២០០៧។ លោក Dung និយាយថា គាត់មានការប្រយ័ត្នប្រយែងក្នុងការប្រមូលព័ត៌មានពីប្រភពច្រើន ដែលគាត់ត្រូវតែធ្វើការផ្ទៀងផ្ទាត់អង្គហេតុនីមួយៗទាំងអស់។ មានខណៈមួយនោះ គាត់បានគិតថានឹងបោះបង់ចោលការស៊ើបអង្កេតលើរឿងនេះ ហើយដោយសារតែការលំបាកក្នុងការរកភស្តុតាងមកបញ្ជាក់ថា មានការបំពានច្បាប់ក្នុងរបរនេះ។ តែគាត់ប្រឹងឈ្នះឈ្នួលរហូតទាល់តែគាត់ទទួលបានឯកសារចាំបាច់ក្នុងការស៊ើបអង្កេតរបស់គាត់។

ភស្តុតាងសំខាន់មួយ គឺអាជ្ញាបណ្ណរដ្ឋាភិបាលដែលអនុញ្ញាតឲ្យក្រុមហ៊ុន Trung Viet នាំចូលសត្វព្រៃ ៨០.០០០ ក្បាល ពីប្រទេសឡាវ ក្នុងនោះមាន ៥.០០០ ក្បាល ជាស្វាកន្ទុយវែង, ២.០០០ ក្បាល ស្វាកន្ទុយជ្រូក, ពស់កម្រចំនួន ១៣.០០០ និងអណ្តើកព្រៃជាង ៦០.០០០ ក្បាល។ អាជ្ញាបណ្ណនោះនាំឲ្យមានការមន្ទិលសង្ស័យ ដោយសារថាវាអនុញ្ញាតឲ្យនាំចូលសត្វព្រៃក្នុងបរិមាណមួយច្រើនមិនធម្មតា។

ស្វាព្រៃ ត្រូវទទួលបានការការពារនៅប្រទេសវៀតណាម ប៉ុន្តែច្បាប់មិនបានហាមឃាត់អ្នកណាម្នាក់ មិនឲ្យនាំចូលសត្វព្រៃពីប្រទេសដទៃទេ ដើម្បីនាំចេញបន្តទៀតទៅលក់ ប្រសិនបើគេមានលិខិតអនុញ្ញាតត្រឹមត្រូវ។ សត្វស្វាត្រូវបានគេច្រើនប្រើសម្រាប់ការស្រាវជ្រាវជីវៈឱសថ។ សត្វស្វាដែលគេរត់ពន្ធអាចនាំផលចំណេញរហូតដល់ទៅ ៥០០ ដុល្លារអាមេរិក ក្នុងមួយក្បាល។

លោក Dung ដែលកាលពីមុនធ្វើការជាមួយសហសេវិកបួននាក់មកពីអង្គការសារព័ត៌មានផ្សេងទៀត បានលាតត្រដាងឲ្យអ្នកអានដឹងថា តើគាត់ធ្វើការស៊ើបអង្កេតរបៀបម៉េច ហើយថាតើគាត់ជួបប្រទះការលំបាកដូចម្តេចខ្លះក្នុងការរកភស្តុតាង៖

*ក្នុងការប៉ុនប៉ងរកឲ្យឃើញការសម្ងាត់ដែលអនុញ្ញាតឲ្យក្រុមហ៊ុន Trung Viet នាំចូលសត្វស្វាបាន យើងព្យាយាមរកមើលក្រដាសស្នាមដើមពាក់ព័ន្ធនឹងការនាំចូលរបស់ពួកគេ។ ក្រោមច្បាប់សារព័ត៌មានវៀតណាម អ្នកយកព័ត៌មានត្រូវបានលើកទឹកចិត្តឲ្យសួរនាំមន្ត្រីសុំព័ត៌មាន ឬឯកសារដែលរដ្ឋាភិបាលមិនបានចែងថាជារបស់សម្ងាត់។ ដូចនឹងអ្វី ដែលយើងបានដឹងនៅឯច្រកព្រំដែន Cau Treo (ក្នុងខេត្តហាទិញ ៤០០ គីឡូម៉ែត្រខាងត្បូងក្រុងហាណូយ) ភ្នាក់ងារដទៃទៀតបានបន្ថែមឲ្យយើងបានដឹងថា សត្វស្វាទាំងអស់ដែលក្រុមហ៊ុន Trung Viet នាំចូល និងបណ្តាញរបស់វាត្រូវបានអនុញ្ញាតដោយអាជ្ញាបណ្ណពីប្រទេសឡាវឯណោះទៅវិញទេ។*

*ប៉ុន្តែ គ្មានទីភ្នាក់ងាររដ្ឋាភិបាលណាមួយហ៊ានបង្ហាញយើងឃើញក្រដាសអាជ្ញាបណ្ណពីទីភ្នាក់ងាររដ្ឋាភិបាលឡាវនោះទេ។ អាជ្ញាធរវៀតណាមព្យាយាមបង្អុលបន្តគ្នាឥតឈប់ឈរ បដិសេធឆ្លើយសំណួររបស់យើង ឬក៏ឲ្យចម្លើយផ្ទុយគ្នា ឬបើមិនដូច្នោះទេ គេនាំគ្នាអវត្តមានពីការិយាល័យរបស់គេតែម្តង។*

ក្រោយពីគាត់ចំណាយពេលរង់ចាំអស់ពីរខែ និងទូរស័ព្ទច្រើនលើកច្រើនសារ នាយកដ្ឋាន ការពារព្រៃឈើ ទីបំផុតក៏ឲ្យអ្នកសារព័ត៌មាននូវច្បាប់ចម្លងអាជ្ញាបណ្ណ ដែលអនុញ្ញាតឲ្យគេនាំចូលស្វាពីប្រទេសឡាវ។

លោក Dung ធ្វើដំណើរទៅប្រទេសឡាវទៅជួបមន្ត្រីរដ្ឋាភិបាល នៅទីនោះឲ្យបញ្ជាក់ព័ត៌មានដែលគាត់ទទួលបាន។ ក្នុងនោះគាត់រកឃើញថា៖

- អគ្គនាយកអាជ្ញាធរវិទ្យាសាស្ត្រឡាវ ដែលពិនិត្យមើលការនាំចេញសត្វព្រៃទាំងអស់ មិនដែលឮឈ្មោះក្រុមហ៊ុនវៀតណាមទាំងនោះផង។
- នាយកដ្ឋានគយរបស់ឡាវប្រាប់លោក Dung ថា គេមិនដែលចេញអាជ្ញាបណ្ណឆ្លងកាត់ឲ្យទៅក្រុមហ៊ុននាំចេញសត្វព្រៃទៅប្រទេសដទៃទេ។
- មន្ត្រីជាន់ខ្ពស់មួយរូបនៃនាយកដ្ឋានព្រៃឈើឡាវ បញ្ជាក់ប្រាប់លោក Dung ថា សំណុំឯកសារដែលថាអនុញ្ញាតឲ្យក្រុមហ៊ុនឡាវនាំចេញសត្វព្រៃ ៨០.០០០ ក្បាល ទៅឲ្យក្រុមហ៊ុន Trung Viet គឺជាឯកសារក្លែងក្លាយទាំងអស់។
- មន្ត្រីឡាវនិយាយថា ត្រា និងហត្ថលេខាលើឯកសារដែលអាជ្ញាធរវៀតណាមផ្តល់ឲ្យនោះ មិនត្រឹមត្រូវតាមច្បាប់ទេ។
- នាយកក្រុមហ៊ុនឡាវ Xay Savang Co. ដែលឈ្មោះរបស់គេមាននៅលើក្រដាសអាជ្ញាបណ្ណបានបដិសេធថា មិនបានធ្វើការនាំចេញសត្វព្រៃទេ។ គាត់ក៏បាននិយាយដែរថា គាត់មិនដែលបានឮឈ្មោះក្រុមហ៊ុន Trung Viet ឡើយ ហើយក៏សង្ស័យដែរថាអាជ្ញាបណ្ណទាំងនោះជាឯកសារក្លែងក្លាយ។ (លោក Dung បាន បុះផ្សាយសម្រង់កិច្ចសម្ភាសន៍របស់គាត់ជាមួយប្រភពទាំងឡាយដែលគាត់បានជួប ដើម្បីអះអាងបញ្ជាក់ដល់អ្នកអានរបស់គាត់។ ខាងក្រោមជាសម្រង់សេក្តីដែលជាឧទាហរណ៍សម្ភាសន៍ល្អមួយសម្រាប់អត្ថបទស៊ើបអង្កេត)។



*ជាទូទៅ មនុស្សម្នាតែងមានរឿងអាថ៌កំបាំងរៀងៗខ្លួន។*

***សម្ភាសន៍ជាមួយនាយកក្រុមហ៊ុន Xay Savang*** *ខាងក្រោមនេះជាផ្នែកខ្លះនៃកិច្ចសម្ភាសន៍ជាមួយនាយកក្រុមហ៊ុន Xay Savang ដោយមានជំនួយពីអ្នកបកប្រែឡាវម្នាក់ទៅជាភាសាវៀតណាម៖*

***អ្នកយកព័ត៌មាន*** *៖ តើលោកមានដែលដឹកជញ្ជូនសត្វព្រៃទៅកាន់ប្រទេសទីបីទេ រួមទាំងប្រទេសវៀតណាមផង?*

**Xay Savang:** មិនដែលទាល់តែសោះ។

***អ្នកយកព័ត៌មាន*** *៖ តើក្រុមហ៊ុនរបស់លោកធ្លាប់នាំចេញសត្វព្រៃដែលគេចាប់បាននៅប្រទេសឡាវទៅកាន់ប្រទេសណាផ្សេងទេ?*

**Xay Savang:** មិនដែលទាល់តែសោះ។

***អ្នកយកព័ត៌មាន*** *៖ តើលោកមានសមភាគីបរទេសណាទេ ក្នុងការជួញដូរសត្វព្រៃ?*

**Xay Savang:** មិនដែលទេ លើកលែងតែពីកិច្ចសហការកាលពីពេលថ្មីៗជាមួយដៃគូចិនមួយក្នុងការអភិវឌ្ឍកន្លែងបង្កាត់ពូជសត្វមួយលើដីទំហំ ២២ ហិកតា ដែលយើងទទួលបានអាជ្ញាបណ្ណប្រតិបត្តិការកាលពីឆ្នាំ២០០៥។

***អ្នកយកព័ត៌មាន*** *៖ តើលោកស្គាល់ក្រុមហ៊ុនវៀតណាមមួយឈ្មោះ Trung Viet ឬទេ? ក្រុមហ៊ុននេះមានមូលដ្ឋាននៅក្នុងក្រុង ហៃហ្វុង ប្រទេសវៀតណាម។*

**Xay Savang:** ខ្ញុំមិនដែលឮឈ្មោះក្រុមហ៊ុននេះម្តងណាទេ។ មានក្រុមហ៊ុនវៀតណាមច្រើនណាស់ ដែលរកស៊ីជាមួយយើងលើវិស័យជាច្រើន ដូចជាការនាំចេញនាំចូលឈើហ៊ុប និងទំនិញប្រើប្រាស់។ តែគ្មានក្រុមហ៊ុនណាមួយមានឈ្មោះដូច្នេះទេ។

***អ្នកយកព័ត៌មាន*** *៖ តើលោកធ្លាប់ឃើញឯកសារទាំងនេះទេ? (ខ្ញុំហុចឲ្យលោក Keosavang នូវឯកសារចម្លងមួយច្បាប់ ដែលនាយកដ្ឋានការពារព្រៃឈើបានឲ្យខ្ញុំ ក្នុងនោះ មានអាជ្ញាបណ្ណលេខ ០៨៥២ ចុះថ្ងៃទី ១២ មេសា ២០០៤ ដែលស្តីពីការរកស៊ីរវាងក្រុមហ៊ុន Xay Savang និងក្រុមហ៊ុន Trung Viet)។*

**Xay Savang:** *ខ្ញុំមិនដែលស្គាល់ឯកសារទាំងនេះទេ។ ប្រហែលជានរណាមួយលួចឈ្មោះក្រុមហ៊ុនរបស់ខ្ញុំទៅរកស៊ីទេដឹង?*

***អ្នកយកព័ត៌មាន*** *៖ ខ្ញុំសូមការអនុញ្ញាតសួរម្តងទៀត តើលោកធ្លាប់លឺឃើញ ឬទទួលឯកសារមួយសំណុំនេះទេ?*

**Xay Savang:** *នេះជាលើកទីមួយហើយដែលខ្ញុំបានឃើញវា។*

***អ្នកយកព័ត៌មាន*** *៖ តើលោកគិតថាឯកសារទាំងនេះក្លែងក្លាយឬ?*

**Xay Savang:** *ខ្ញុំគិតថាអញ្ចឹងដែរ។*

***អ្នកយកព័ត៌មាន*** *៖ សូមលោកប្រាប់ខ្ញុំផងបានទេ ថាតើកន្លែងចិញ្ចឹមសត្វរបស់លោក មានលទ្ធភាពនាំចេញសត្វព្រៃទៅវៀតណាមទេ?*

**Xay Savang:** *យើងទើបនឹងចាប់ផ្តើមរកស៊ី ហើយមិនដែលនាំចេញសត្វព្រៃទៅវៀតណាមទេ។*

***អ្នកយកព័ត៌មាន*** *៖ តើមានអ្នកណាក្នុងចំណោមដៃគូរបស់អ្នកក្នុងរបររកស៊ីនេះមកពីប្រទេសវៀតណាមទេ?*

**Xay Savang:** *អត់មានទេ។*

*យើងធ្វើការជាមួយដៃគូចិន។ ពួកគេរួមចំណែកក្នុងហ៊ុននូវទឹកប្រាក់ ១ លានដុល្លារ។ យើងចូលហ៊ុន ៣០០.០០០ ដុល្លារ តាមរយៈការប្រើប្រាស់ដី និងហេដ្ឋារចនាសម្ព័ន្ធ។*

កិច្ចសម្ភាសន៍នេះបញ្ជាក់ការមន្ទិលសង្ស័យរបស់អ្នកយកព័ត៌មានថា ឯកសារទាំងនោះសុទ្ធសឹងតែជាការក្លែងបន្លំទាំងអស់។

លោក Dung មានការប្រយ័ត្នប្រយែងក្នុងការប្រើចម្លើយរបស់ប្រធានក្រុមហ៊ុន Trung Viet

ដែលខ្ញុំប្រកែកថាបរបរកស៊ីរបស់គាត់ស្របច្បាប់ត្រឹមត្រូវទេ។ ប្រធានក្រុមហ៊ុននោះនិយាយថា៖ "ខ្ញុំនាំសត្វព្រៃចូលដោយផ្ទាល់ពីក្រុមហ៊ុនឡាវ នៅខេត្ត បូលីខាំសៃ ខេត្ត ចំប៉ាសាក់ ខេត្តសេកុង និង ខេត្តវៀងច័ន្ទ។ ទំនិញសត្វព្រៃដែលខ្ញុំនាំចូលទាំងអស់ពីប្រទេសឡាវមកវៀតណាម មានការអនុញ្ញាតពីអាជ្ញាធរគ្រប់គ្រប់ឡាវ និងវៀតណាម"។

លោក Dung ក៏បានធ្វើការប្រៀបធៀបផងដែរនូវទិន្នន័យពីភ្នាក់ងារផ្សេងៗគ្នា ហើយគាត់រកឃើញថាមានភាពខុសគ្នាច្រើន រវាងចំនួនសត្វព្រៃដែលក្រុមហ៊ុនបាននាំចូល។ នាយកដ្ឋានការពារសត្វព្រៃមានតួលេខមួយ រីបសាយរបស់អង្គការ CITES មានតួលេខមួយល្មៀងពីនោះបន្តិច រីឯប្រកទ្វារព្រំដែនបានកត់ត្រាចំនួនសត្វនាំចូលខ្ពស់ជាងគេ។ នៅទីបំផុតអ្នកយកព័ត៌មានសន្និដ្ឋានថា អាជ្ញាបណ្ណដើមមួយដែលអាជ្ញាធរឡាវ បានចេញសម្រាប់ការនាំចេញសត្វទៅប្រទេសម៉ាឡេស៊ី ត្រូវបានក្រុមហ៊ុនវៀត-ណាមលួចកែ ដោយមានការឃុបឃិតពីអាជ្ញាធរវៀតណាម។

លោក Dung និយាយថាភាពប្រឈមខ្លាំងជាងគេរបស់គាត់ក្នុងការស៊ើបអង្កេតនោះ គឺ"ភាពឯកោ"។ គាត់និយាយថា៖"សហសេវិករបស់ខ្ញុំទាំងអម្បាល-ម៉ាន ដែលប្រឡូកក្នុងករណីនេះពីដើមទី បានបោះបង់បោលរឿងនេះ ដោយសារហេតុផលវារសើបពេក។ ក្រុមជើងប៉ាវក្នុងរឿងនេះមានបណ្តាញខ្លាំងណាស់ ដែលវាអត់មានអីធ្វើឲ្យវាប្រែប្រួលបានទេ ក្រោយពីមានការចុះផ្សាយរឿងរបស់ខ្ញុំ។ ក្នុងចំណោមអ្នកដែលត្រូវទទួលការចោទប្រកាន់ អ្នកខ្លះលែងមាត់អ្វីទាំងអស់។ មន្ត្រីមួយចំនួនរបស់នាយកដ្ឋានការពារព្រៃឈើបានមកកាន់ទីស្នាក់ការកាសែតរបស់ខ្ញុំ។ ពួកគេបានបញ្ចេញប្រតិកម្មដ៏កំសោយចំពោះអត្ថបទស៊ើបអង្កេតរបស់ខ្ញុំ តែទន្ទឹមនឹងនោះ ពួកគេក៏បានសុំឲ្យខ្ញុំឈប់សរសេរអំពីរឿងនេះតទៅទៀត"។

ប៉ុន្តែលោក Dung ទទួលបានការគាំទ្រខ្លាំងពីអនុនិពន្ធនាយករបស់គាត់ និងពីអង្គការ Earth Journalism Network ឲ្យបន្តការស្រាវជ្រាវរបស់គាត់តទៅទៀត។ អត្ថបទស៊ើបអង្កេតជាច្រើនភាគរបស់គាត់បានទទួលរង្វាន់ថ្នាក់ជាតិ និងអន្តរជាតិជាច្រើន។

# ជំពូក ១០ យកព័ត៌មានអំពីបទល្មើសព្រហ្មទណ្ឌ និងតុលាការ

នៅក្នុងវិស័យសារព័ត៌មានមិនសូវមានផ្នែកណាដូចផ្នែករឿងព្រហ្មទណ្ឌ ដែលមានសក្ដានុពលក្នុងការរំលឹកឡើងវិញនូវឆាកវិនាដកម្ម និងធ្វើឲ្យអ្នកអានប្រឹងថប់ដង្ហើម។ ក្នុងនោះ មានឃាតកម្ម កិច្ចការអាថ៌កំបាំង ការសងសឹក សេចក្ដីលោភលន់ ការប្រណែននិន្ទា ជនសង្ស័យ ភាពគ្រាំគ្រារបស់ជនរងគ្រោះ និងសេចក្ដីសោកសៅរបស់គ្រួសារ។ ទាំងអស់នេះ សុទ្ធតែធ្វើឲ្យអ្នកអានជក់ចិត្ត។

ចូរនាំគ្នាក្រឡេកមើលរបៀបដែលអ្នកយកព័ត៌មាន Wassayos Ngamkhan របស់កាសែត Bangkok Post បង្កើតឡើងវិញនូវឆាកវិនាដកម្មនៃឧក្រិដ្ឋកម្មមួយ៖

*ដោយត្រូវបានគេភ្ជង់កាំបិតនឹងករបស់គាត់ លោក Silatharm Wicharach អ្នកបើកបរតាក់ស៊ីប្រឹងអង្វរករគេកុំឲ្យសម្លាប់គាត់ ក្នុងពេលដែលគាត់បានក្លាយខ្លួនជាជនរងគ្រោះរបស់ "ពួកចោរប្លន់ប្រើខ្សែនីឡុង"។*

*ក្នុងការរំលឹកអំពីហេតុការណ៍ដែលកើតឡើងកាលពីថ្ងៃទី ១២ កញ្ញា លោក Silatharm និយាយថា គាត់បានពោលទៅកាន់ក្រុមចោរនោះថា៖ "សូមមេត្តាកុំសម្លាប់ខ្ញុំ។ ខ្ញុំមានគ្រួសារ សូមលោកយកទៅ អ្វីដែលលោកចង់បាន"។*

ជាមួយនឹងសេចក្ដីផ្ដើមតែប៉ុន្មានបន្ទាត់ប៉ុណ្ណោះ រឿងនេះច្បាមអារម្មណ៍អ្នកអានបានភ្លាម។

*បុរសនោះនិយាយថា គាត់ចាត់ទុកខ្លួនគាត់ថាជាមនុស្សសំណាងដែលបានរួចផុតពីគ្រោះថ្នាក់នោះ ដើម្បីប្រាប់រឿងរ៉ាវឲ្យអ្នកទាំងពួងបានដឹង។*

*បុរសប្រាំនាក់ ដែលតាំងខ្លួនជាអ្នកធ្វើដំណើរបានប្លន់គាត់ដោយប្រើខ្សែនីឡុង ចងគាត់ផ្អោបនឹងកៅអីរថយន្ត មុននឹងពួកវាយករបស់របរពីគាត់អស់។ បន្ទាប់មកចោរប្លន់ទាំងនោះ បានហៅតាក់ស៊ីមួយទៀតជិះចេញទៅបាត់ហាក់ដូចជាគ្មានអ្វីកើតឡើងអញ្ចឹង។*

*តែក្នុងអំឡុងប្រាំនាទីប៉ុណ្ណោះ ពួកចោរប្លន់បានប្លន់យកលុយពីលោក Silatharm ប្រហែលជា ១២.០០០ បាត អស់រលីង ហើយពួកវាក៏បានលួចទូរស័ព្ទដៃរបស់គាត់ទៅជាមួយផងដែរ។*

*ក្រោយពីពួកវាត្រូវបានចាប់ខ្លួនបន្តិចក្រោយមកទៀត ពួកចោរប្លន់ទាំងនោះបានសារភាពថា ពិតជាបានប្រើខ្សែពួរនីឡុងចងជនរងគ្រោះមែន។*

*បួននាក់ក្នុងចំណោមចោរទាំងនោះត្រូវបានចាប់ខ្លួន និងជាប់ពន្ធនាគារពីបទគ្រឿងញៀន និងអវត្តមានអត់ច្បាប់បន្ទាប់ពីបានជាប់កំណែនយោធារួចហើយ។*

រឿងនេះបានផ្ដល់សេចក្ដីពិស្ដារអំពីពេលវេលាកើតឧក្រិដ្ឋកម្ម ហើយរំលឹកមកវិញនូវរាត្រីដែលលោក Silatharm ត្រូវបានគេប្លន់ និងអំពីរបៀបដែលគេចាប់បានចោរប្លន់ទាំងនោះ។ ការសរសេរបែបនេះជាការគួរឲ្យចាប់អារម្មណ៍ខ្លាំងជាងការសរសេរសេចក្ដីផ្ដើមដំណឹងទាន់ហេតុការណ៍ដូចសព្វមួយដង ឧទាហរណ៍ដូចមាននៅខាងក្រោមនេះ៖

*មនុស្សបួននាក់ត្រូវបានប៉ូលីសចាប់ខ្លួនកាលពីម្សិលមិញ ក្នុងការពាក់ព័ន្ធនឹងការប្លន់ប្រដាប់អាវុធទៅលើអ្នកបើកបរតាក់ស៊ីអស់ជាច្រើនលើកកន្លងមក។*

វាគ្មានអ្វីខុសទេ ក្នុងការសរសេរសេចក្ដីផ្ដើមព័ត៌មានទាន់ហេតុការណ៍ត្រង់ធ្លុតបែបនេះ ប៉ុន្តែសេចក្ដីផ្ដើមអត្ថបទកាសែត Bangkok Post បាននាំយើងទៅដល់ឆាកឧក្រិដ្ឋកម្មនោះដូចនៅក្នុងរឿងប្រលោមលោកអញ្ចឹង។

តែមិនមែនបានន័យថា រាល់រឿងព្រហ្មទណ្ឌសុទ្ធតែត្រូវសរសេរសេចក្តីផ្តើមដូចបទពិពណ៌នាបែបនេះទេ។ សេចក្តីពិស្តារនៃអ្វីដែលបានកើតឡើងតាមលំដាប់លំដោយរបស់វា អាចត្រូវបានតំរៀបដាក់ក្នុងដងខ្លួនសាច់រឿង ហើយក៏នៅតែចាប់អារម្មណ៍ចង់អានដដែល។

វិបាកនៃអំពើព្រហ្មទណ្ឌ គឺជនល្មើសត្រូវបានគេនាំខ្លួនឡើងតុលាការ។ ដូចគ្នានឹងហេតុការណ៍ដែរ ដំណើរការតុលាការតែងរំលេចនូវវិនាដកម្មពាក់ព័ន្ធជាមួយមនុស្សក្នុងរឿងរ៉ាវ។ ក្នុងនោះ ភស្តុតាងត្រូវបានគេលាតត្រដាង សាក្សីផ្តល់សក្ខីកម្ម សវនាការតុលាការបានដឹងឮនូវអ្វីដែលបានកើតឡើងកន្លងមក ហើយថាហេតុអ្វីបានជាវាកើត។ តាមធម្មតា ច្រើនតែមាននូវការថប់ដង្ហើមចង់ដឹងមុននឹងចៅក្រម ឬគណៈវិនិច្ឆ័យប្រកាសសេចក្តីសម្រេចចិត្តអំពីរឿងក្តីក្តាំនោះ។ ការសម្រេចអាចជាការដាក់ទណ្ឌកម្ម ឬការបង្គាប់ឲ្យកែប្រែកំហុស។ ការសន្និដ្ឋានចុងក្រោយតែងនាំមកនូវ "ការបិទបញ្ចប់" ជាផ្លូវការសម្រាប់ជនរងគ្រោះ និងគ្រួសាររបស់គេ។ រឿងព្រហ្មទណ្ឌសំបូរជាតុផ្សំសម្រាប់យកមកសរសេររៀបរាប់ណាស់។ អ្នកសារព័ត៌មានខ្លះចាត់ទុកថា ការសរសេរអំពីតុលាការ ជាកិច្ចការគួរឲ្យសែនរំភើប ហើយពួកគេក៏អភិវឌ្ឍន៍បាននូវឯកទេសផ្នែកនេះ ដោយសារមានតម្រូវការខ្ពស់ចំពោះការចង់ដឹងចង់ឮអំពីរឿងព្រហ្មទណ្ឌ និងតុលាការ។ នៅប្រទេសមួយចំនួនក៏មានផងដែរនូវភ្នាក់ងារឯកជនរាយការណ៍ព័ត៌មានតុលាការ ដោយពួកគេជាអ្នកបញ្ជូនករណីតុលាការទៅឲ្យអង្គភាពសារព័ត៌មាននៅគ្រប់ទិសទី។

តែអ្វីដែលគួរឲ្យស្តាយនោះ គឺនៅត្រង់ថា មានអ្នកសារព័ត៌មានច្រើននាក់ណាស់ដែលមិនបានរាយកាណ៍ព័ត៌មានអំពីបទព្រហ្មទណ្ឌ និងតុលាការ តាមរបៀបមួយដែលជាការផ្តល់ព័ត៌មានផង និងការកំសាន្តខ្លះផង។ គេដូចជាមិនសូវខិតខំប៉ុន្មានទេក្នុងការពន្យល់អំពីរបៀបនគរបាលដោះស្រាយបទព្រហ្មទណ្ឌមួយ និងធ្វើការចាប់ជនល្មើស។ អ្វីដែលជាចំណុចខ្វះខាតដែរនោះ គឺគេមិនសូវពន្យល់អំពីភស្តុតាងដែលចៅក្រមបានលើកឡើងសម្រាប់ធ្វើការវិនិច្ឆ័យឲ្យមនុស្សម្នាក់ជាប់ពិរុទ្ធនោះទេ។

ពេលដែលតុលាការកំពូលប្រទេសថៃបានសម្រេចរំលាយគណបក្សកាន់អំណាច និងដកសុពលភាពនាយករដ្ឋមន្ត្រីមិនឲ្យកាន់តំណែងតទៅទៀតបាន អ្នកអាននៃកាសែតភាគច្រើនគ្រាន់តែបានដឹងថាករណីនេះពាក់ព័ន្ធតែ "ការក្លែងបន្លំក្នុងការបោះឆ្នោត" តែប៉ុណ្ណោះ។ គ្មានការពន្យល់ក្បោះក្បាយអំពីភស្តុតាងនោះទេ ដូច្នេះអ្នកអានត្រូវបានគេទុកឲ្យធ្វើសេចក្តីសន្និដ្ឋានដោយខ្លួនឯងថាតើសេចក្តីសម្រេចនោះមានយុត្តិធម៌ ឬទេ។ ការធ្វើសេចក្តីរាយការណ៍បែបនេះ ធ្វើឲ្យអ្នកអានមានការមិនអស់ចិត្តនៅមន្ទិល។ គោលការណ៍មួយក្នុងចំណោមគោលការណ៍ជាមូលដ្ឋានធ្វើឲ្យសង្គមដំណើរការទៅបានល្អ គឺនៅត្រង់ថា មនុស្សគ្រប់រូបចាំបាច់ត្រូវតែដឹងឲ្យប្រាកដក្នុងខ្លួនថា បើរូបគេណាម្នាក់ត្រូវទទួលរកការចោទប្រកាន់ថាបានប្រព្រឹត្តខុសអ្វីមួយ (ឬមួយក៏ជាជនរងគ្រោះនៃទង្វើខុសរបស់អ្នកផ្សេង) ករណីមួយនេះនឹងត្រូវបានការកាត់ក្តីប្រកបដោយយុត្តិធម៌។ បើសិនជាប្រជាជនមិនអាចឃើញ (ឬក៏អាន) ក្នុងទំព័រសារព័ត៌មានអំពីអ្វីដែលបានកើតឡើងក្នុងសាលតុលាការ នេះមានន័យថា គោលការណ៍ដែលយើងទើបនឹងបាននិយាយកន្លងមកនេះ កំពុងមានគ្រោះហានិភ័យហើយ។ ដូច្នេះ បើទោះជាថាអ្នកធ្វើសេចក្តីរាយការណ៍ តែភាគបញ្ចប់នៃសវនាការក្តីពេលដែលចៅក្រមផ្តល់សាលក្រមរបស់គេ អ្នកត្រូវតែរកឲ្យឃើញថាហេតុអ្វីបានជាចៅក្រមនោះ ឬចៅក្រមទាំងនោះ ធ្វើសេចក្តីសម្រេចដូច្នោះ។ ក្រោយមកទៀត អ្នកត្រូវស្វែងរកប្រតិកម្មពីមនុស្សទាំងអស់ដែលពាក់ព័ន្ធក្នុងរឿងក្តីមួយនោះ និងយោបល់ពី

សំណាក់អ្នកឯកទេសថា តើករណីនេះមានសារៈ-សំខាន់ធំដុំប៉ុណ្ណាទៅ តែចូរកុំទិតៀនរិះគន់មូលហេតុចលករ និងភាពទៀងត្រង់របស់ចៅក្រមឲ្យសោះ ពីព្រោះថាធ្វើដូច្នោះ វាអាចនាំឲ្យរូបអ្នកមានបញ្ហាខាងផ្លូវច្បាប់ជាមួយតុលាការ។ *[សូមមើលជំពូកទី ១១ : អ្នកសារព័ត៌មាន និងច្បាប់]*

តុលាការជាស្ថាប័នសំខាន់ក្នុងការតម្រែតម្រង់ផ្លូវសង្គម ដោយឲ្យជាសញ្ញាគេដឹងបានថា តើឧក្រិដ្ឋកម្មមួយអាចទទួលទណ្ឌកម្មធ្ងន់ ឬស្រាលប៉ុណ្ណា ហើយតើសង្គមមើលមកវាយ៉ាងម៉េច។ ករណីតុលាការខ្លះអាចរួមវិភាគទានដល់ការវិវត្តនយោបាយក្នុងប្រទេសមួយបានដែរ ដូចជាសវនាការលើអំពើពុករលួយសាលក្រមលើករណីច្បាប់ធម្មនុញ្ញជាដើម។ បើយើងយល់ដឹងបានពិតប្រាកដអំពីមូលហេតុដែលតុលាការសម្រេចសេចក្ដី និងការដាក់ទណ្ឌកម្ម យើងអាចជួយឲ្យអ្នកអានយល់បានស៊ីជម្រៅនៅក្នុងការផ្លាស់ប្ដូរបទដ្ឋានសង្គម និងវប្បធម៌ នយោបាយនៃសង្គមរបស់គេបាន។

## ស្វែងយល់អំពីប្រព័ន្ធ

ការធ្វើសេចក្ដីរាយការណ៍បទល្មើសព្រហ្មទណ្ឌ និងតុលាការត្រូវការឲ្យមានពុទ្ធិជំនាញច្រើន។ នីតិក្រម និងប្រព័ន្ធច្បាប់ មានភាពខុសគ្នាច្រើនមែន-ទែនពីប្រទេសមួយទៅប្រទេសមួយទៀត ហើយក្នុងប្រទេសខ្លះ ច្បាប់ក៏មានភាពខុសគ្នាដែររវាងបណ្ដាទីក្រុង និងខេត្ត។ ដូច្នេះ អ្នកគួរតែចំណាយពេលរៀនសូត្រឲ្យបានយល់អំពីប្រព័ន្ធច្បាប់នៅក្នុងមុខព្រួញយកព័ត៌មានរបស់អ្នក។ សួរអ្នកច្បាប់ និងក្រឡាបញ្ជីក្នុងតុលាការឲ្យជួយពន្យល់អំពីទម្រង់ការនីតិវិធីលើករណីណាដែលអ្នកកំពុងយកព័ត៌មាន។ បន្តិចម្ដងៗ អ្នកនឹងកសាងបាននូវមូលដ្ឋានយល់ដឹងមាំទាំមួយអំពីប្រព័ន្ធច្បាប់នោះ។

មានគោលការណ៍ជាមូលដ្ឋានមួយចំនួនដែលគេអាចរកឃើញនៅក្នុងប្រព័ន្ធច្បាប់ភាគច្រើន បើទោះជាថា - ដូចយើងទាំងអស់គ្នាដឹងរួចហើយ - ទ្រឹស្ដី និងការអនុវត្តវាមិនដូចគ្នាទេ។ គេអាចបែងចែកនីតិក្រម ករណីក្ដីក្ដាំ និងតុលាការ ចេញជាចំណាត់ថ្នាក់ផ្សេងៗគ្នា ក្នុងនោះមាន៖

**តុលាការព្រហ្មទណ្ឌ :** ច្បាប់ព្រហ្មទណ្ឌមានគោលដៅការពារសង្គម និងបុគ្គល ដូច្នេះកាលណាច្បាប់ណាមួយក្នុងចំណោមច្បាប់ព្រហ្មទណ្ឌត្រូវបានគេបំពាន នគរបាលមានកាតព្វកិច្ចស៊ើបអង្កេតរកចាប់អ្នកទទួលខុសត្រូវក្នុងរឿងនេះ។ ពេលណាមានករណីមួយត្រូវបានគេប្ដឹងឡើងតុលាការ វាជាកាតព្វ-កិច្ចរបស់រដ្ឋ ក្នុងនាមប្រជាពលរដ្ឋ ជាអ្នកចាត់ការជាមួយជនជាប់ចោទ។ និយាយម្យ៉ាងទៀត រដ្ឋ គឺជាភាគីម្ខាងទៀតនៅក្នុងរឿងរ៉ាវនេះ។ ហេតុនេះហើយបានជានៅក្នុងប្រទេសខ្លះ គេចាត់ទុកការប្ដឹងផ្ដល់ថាជាការតទល់រវាងរដ្ឋ និងជនទុច្ចរិត ឬប្រជាជនតទល់នឹងជនទុច្ចរិត។

នៅក្នុងតុលាការព្រហ្មទណ្ឌ ជនជាប់ចោទត្រូវបានចាត់ទុកថាជានិរទោសជន ដរាបណាគេមិនទាន់កំណត់ថាជននោះមានពិរុទ្ធ។ ភាគីក្នុងរឿង គឺមានក្រុមរដ្ឋអាជ្ញា និងជនចុងចោទ។ មេធាវីរបស់រដ្ឋជារដ្ឋអាជ្ញា ហើយរីឯអ្នកទាំងឡាយដែលតំណាងឲ្យចុងចោទជាក្រុមមេធាវីការពារ។ តុលាការតែងតែត្រូវបានគេរៀបចំទៅតាមកម្រិតធ្ងន់ស្រាលរបស់បទ-ព្រហ្មទណ្ឌ។ ឧទាហរណ៍ បើអ្នកលួចអ្វីមួយពីហាងទំនិញ ហើយត្រូវគេចាប់ខ្លួនបាន អ្នកនឹងត្រូវគេនាំឡើងតុលាការជាន់ទាប។ បើសិនជាអ្នកត្រូវទទួលការចោទប្រកាន់ពីបទឃាតកម្ម អ្នកនឹងត្រូវបង្ហាញមុខនៅតុលាការព្រហ្មទណ្ឌជាន់ខ្ពស់។

**តុលាការរដ្ឋប្បវេណី :** មានករណីក្ដីក្ដាំខ្លះជាជម្លោះរវាងបុគ្គល និងក្រុមហ៊ុន ឬអង្គការ។ តែវាមិនមានជាតុព្រហ្មទណ្ឌក្នុងនោះទេ ដែលវាគ្រាន់តែជា



តើនេះជាការបង្ក្រាបគ្រឿងញៀនមែនទែន ឬគ្រាន់តែជាការសម្តែងឲ្យល្អមើល?

អធិករណ៍ ដូចជាការការខ្វែងគំនិតគ្នាក្នុងរបររកស៊ីជាដើម។ ភាគច្រើន រឿងក្តីក្តាំរដ្ឋប្បវេណីមិនចូលទៅដល់បន្ទប់សវនាការក្នុងតុលាការសម្រាប់កាត់ក្តីទេ តែវាត្រូវបានដោះស្រាយតាមរយៈមេធាវីរបស់ភាគីរៀងៗខ្លួន។ ក្នុងករណីដែលវាត្រូវឡើងដល់តុលាការ ក្នុងពេលនេះ រដ្ឋមិនមែនជាភាគីមួយក្នុងរឿងទៀតទេ តែគ្រាន់តែជាអ្នកផ្តល់វេទិកាមួយសម្រាប់ឲ្យមានការដេញដោល និងវិនិច្ឆ័យរករឿងក្តីប្រកបដោយយុត្តិធម៌។ ដូច្នេះជាទូទៅ ករណីរដ្ឋប្បវេណីត្រូវបានគេចាត់ទុកថាជារឿងក្តីក្តាំ ABC ទល់ នឹង XYZ។ ភាគីមាន **ភាគីដើមបណ្តឹង** និង**ភាគីចុងចោទ**។ ប្រភេទមួយនៃរឿងក្តីក្តាំរដ្ឋប្បវេណី ដែលច្រើនក្លាយជាប្រធានបទធ្វើរឿង គឺនៅពេលដែលមានអ្នកណាម្នាក់ប្តឹងអ្នកណាម្នាក់ទៀតអំពីបទបង្ខូចកេរ្តិ៍ ហើយសុំឲ្យតុលាការបង្គាប់ឲ្យភាគីចុងចោទបង់ប្រាក់សងជំងឺចិត្ត។

នៅប្រទេសមួយចំនួន តុលាការព្រហ្មទណ្ឌក៏ត្រូវបានគេប្រើសម្រាប់លៃលកករណីក្តីក្តាំរដ្ឋប្បវេណីដែរ។ ដូចនេះគេហៅថា **ករណីបរិហារកេរ្តិ៍ព្រហ្មទណ្ឌ** ដែលមានន័យថា រដ្ឋ គឺជាភាគីមួយនៅក្នុងរឿងនេះដែរ។ តែគេច្រើនតែប្រើប្រាស់ករណីបែបនេះបែបបំពាន ហើយប្រទេសជាច្រើនបានឈប់ប្រើវាហើយ ដោយសារថាតែអ្នកនយោបាយចេះតែយកវាទៅប្រើ ដើម្បីបំបិទមាត់អ្នកប្រឆាំងនឹងខ្លួន។ *[សូមមើលជំពូក ១១ : អ្នកសារព័ត៌មាន និងច្បាប់]*។

ក្នុងករណីខ្លះទៀត គេមានតុលាការគ្រួសារនៅក្នុងតុលាការរដ្ឋប្បវេណីដែរ។ គេប្រើតុលាការបែបនេះ ដើម្បីដោះស្រាយពាក្យបណ្តឹងលែងលះ និងពាក្យបណ្តឹងទាក់ទិននឹងរបបសុខុមាលភាពកូន។ គេតែងតែដាក់កំហិតលើការរាយការណ៍ព័ត៌មានអំពីករណីទាំងនេះ ដោយសារថាគេត្រូវការពារភាពឯកជនរបស់កុមារពីការចាប់អារម្មណ៍ទូទៅរបស់សាធារណជន។

**តុលាការធម្មនុញ្ញ :** ប្រទេសភាគច្រើនលើពិភពលោកមានធម្មនុញ្ញ ដែលជាវិធានទូទៅមួយសម្រាប់គ្រប់គ្រងប្រទេស។ ជួនកាល សភាអនុម័តច្បាប់មួយ ឬក៏ថារដ្ឋាភិបាល ឬបុគ្គលណាម្នាក់បានធ្វើអ្វីមួយដែលបំពានទៅលើប្រការនៅក្នុងធម្មនុញ្ញ។ ដូច្នេះ តុលាការជាន់ខ្ពស់មួយនឹងពិនិត្យមើល និងសម្រេចថា តើច្បាប់មួយ ឬទង្វើមួយនោះបានអនុលោមតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសដែរ ឬទេ។ ឧទាហរណ៍ នៅប្រទេសថៃ ទង្វើផ្ទុយនឹងរដ្ឋធម្មនុញ្ញអាចនាំទៅដល់ការដកសុពលភាពអ្នកនយោបាយ និងបំរាមលែងឲ្យចូលប្រឡូកក្នុងនយោបាយតទៅ

ទៀត។ នៅប្រទេសមួយចំនួនទៀតមានតុលាការពិសេសសម្រាប់លៃលកជាមួយករណីនយោបាយដែរ។

**តុលាការអន្តរជាតិ :** នៅលើពិភពលោកយើងនេះ មានវិធានអន្តរជាតិជាច្រើនដែលរដ្ឋាភិបាលនីមួយៗ អាចចុះហត្ថលេខាធ្វើជាសមាជិកក្នុងនោះបានដែរ។ ឧទាហរណ៍ដូចជា ធម្មនុញ្ញសមាគមន៍អាស៊ាន ដែលនៅពីក្រោមដំបូលនៃធម្មនុញ្ញនោះ ប្រទេសជាសមាជិកទាំងដប់ឯកភាពគ្នាថាប្រតិបត្តិតាមច្បាប់ជាក់លាក់មួយចំនួន។ ច្បាប់ទាំងនោះមានការបង្កើតផ្សារសេរីសម្រាប់ទំនិញ និងពលកម្មរវាងប្រទេសទាំងអស់ និងការអនុញ្ញាតឲ្យពលរដ្ឋក្នុងសមាគមន៍នេះទទួលបានការធានាសិទ្ធិ។ មានច្បាប់អន្តរជាតិច្រើនទៀត ដែលមានអត្ថិភាពជា "កុងសង់ស៊ុស" រវាងប្រទេស និងច្បាប់ឯទៀត ដូចជាសម្រាប់ការប្រតិបត្តិការចរាចរនាវាតាមសមុទ្រ និងវិធានក្នុងការធ្វើសង្គ្រាមជាដើម។ ផ្នែកមួយចំនួននៃច្បាប់នេះមានអង្គការសហប្រជាជាតិជាអ្នកចាត់ចែងតាមរយៈស្ថាប័ន មានជាអាទិ៍ តុលាការយុត្តិធម៌ អន្តរជាតិនៅក្រុងឡាអេ ប្រទេសហុឡង់។ ពេលដែលប្រទេសកម្ពុជា និងថៃ ខ្វែងគំនិតគ្នាលើព្រំដែនក្បែរប្រាសាទព្រះវិហារ ប្រទេសទាំងពីរបានសុំឲ្យតុលាការយុត្តិធម៌អន្តរជាតិសម្រេចលើវិវាទនេះនៅឆ្នាំ ១៩៦២។ នៅមានតុលាការអន្តរជាតិមួយចំនួនទៀត ដែលត្រូវបានបង្កើតឡើងដើម្បីលៃលកជាមួយការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ រួមមាន ការប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ឧទាហរណ៍ អង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលជាអង្គតុលាការអង្គការសហប្រជាជាតិ និងប្រទេសកម្ពុជាបង្កើតឡើងរួមគ្នា ដើម្បីសម្រាប់ជំនុំជំរះក្តីមេដឹកនាំខ្មែរក្រហម។

ក្រៅពីនោះ នៅមានតុលាការឯកទេសមួយចំនួនទៀតដែរ ដូចជាតុលាការសម្រាប់ជំរះក្តីជំលោះពលកម្មការងារ និងការក្ស័យធន់ក្នុងមុខរបរ។

ក្នុងប្រទេសភាគច្រើន អ្នកយកព័ត៌មានអាចត្រូវបានគេអនុញ្ញាតឲ្យអង្គុយស្តាប់សវនាការ ដើម្បីយកព័ត៌មានទៅសរសេរជារឿង តែចៅក្រមអាចដាក់កំហិតថា តើអ្វីខ្លះដែលអ្នកអាចយកទៅសរសេរបាន។ ដូច្នេះចូរអ្នកស្វែងយល់ថា អ្វីខ្លះទៅជាសិទ្ធិរបស់អ្នកសារព័ត៌មានក្នុងប្រទេសដែលអ្នកកំពុងធ្វើការ។

# ស្វែងយល់អំពីនីតិវិធី

ខាងក្រោមនេះ ជាចំណាត់ការជាមូលដ្ឋានមួយចំនួន (basic proceedings) របស់ប្រព័ន្ធព្រហ្មទណ្ឌ និងប្រព័ន្ធតុលាការ៖

កាលណាមានឧក្រិដ្ឋកម្មមួយកើតឡើង គេនឹងបើកជាករណី ហើយ **ការស៊ើបអង្កេត** នឹងចាប់ផ្តើម។ បើមាននរណាម្នាក់ត្រូវបានគេសង្ស័យថាបានប្រព្រឹត្តឧក្រិដ្ឋកម្មនោះ (ជននោះ ត្រូវបានគេហៅថាជាជនសង្ស័យ) នគរបាលនឹងសុំឲ្យមន្ត្រីច្បាប់ ដូចជា ចៅ-ក្រម ឬរដ្ឋអាជ្ញា ចេញ**ដីកាចាប់ខ្លួន**មួយ។ នគរបាលត្រូវតែប្រឹងល្បួងមន្ត្រីតុលាការថាមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ឲ្យនគរបាលជាថាមនុស្សម្នាក់ណានោះបានប្រព្រឹត្តអំពើឧក្រិដ្ឋដែលគេត្រូវតែចាប់ខ្លួន។ តាមធម្មតា មានកំហិតចំពោះរយៈពេលដែលនគរបាលអាចឃុំខ្លួនជនសង្ស័យ ហើយក្នុងប្រទេសជាច្រើន ជនសង្ស័យមានសិទ្ធិមានមេធាវីធ្វើជាតំណាងក្នុងពេលចាប់ខ្លួនភ្លាមៗតែម្តង។ បើសិនជនជាប់ចោទមិនអាចមានលទ្ធភាពជួលមេធាវីទេ រដ្ឋក៏មានកាតព្វ-កិច្ចបង់ថ្លៃជួលមេធាវីឲ្យធ្វើតំណាងឲ្យជននោះដែរ។

បើនគរបាលជឿថាគេប្រមូលបានភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹងជនសង្ស័យហើយ ពួកគេនាំជននោះទៅជួបចៅក្រម ដើម្បីទទួលបទ**ចោទប្រកាន់** អំពីបទល្មើសនោះជាផ្លូវការ។ វាអាចមានបទល្មើសច្រើន

ជាងមួយ ដែលគេនឹងយកទៅកាត់ក្តីជនជាប់ចោទ។ ឧទាហរណ៍ បុរសម្នាក់ពាក់ព័ន្ធជាមួយនឹងអំពើហិង្សា អាចត្រូវរកបទចោទពីការមានអាវុធគ្រោះថ្នាក់ ការ-វាយបែបស្រាលទៅលើអ្នកដទៃ ការវាយប្រហារធ្ងន់លើអ្នកដទៃ ឬពីបទប៉ុនប៉ងធ្វើឃាត ក៏ជាបានដែរ។ ពិតណាស់ បទចោទកាន់តែធ្ងន់ កាលណាទណ្ឌកម្មក៏កាន់តែធ្ងន់តាមនោះដែរ។

កាលណា **បទចោទប្រកាន់** ត្រូវបានគេអានឲ្យជនសង្ស័យស្តាប់ហើយ ជននោះ ប្រុស ឬស្រី ត្រូវបានគេហៅថាជា ជនជាប់ចោទ។ ចាប់ពីត្រង់ចំណុចនេះតទៅ អ្វីក៏ដោយដែលភាគីទាំងសងខាងនិយាយត្រូវតែជា "ការពិត" ហើយបើអ្នកណាមួយត្រូវបានគេរកឃើញថាភូតកុហកតុលាការ ( គេហៅករណីបែបនេះថា **សក្ខីកម្មទុច្ចរិត**/perjury) អាចត្រូវបានគេយកមកកាត់ទោសបានដែរ។ ជនជាប់ចោទអាចសុំនៅក្រៅឃុំ (bail) ដោយមានការធានា (bond) តាមការបង់ប្រាក់តំកល់ឲ្យរដ្ឋាភិបាលជាកិច្ចធានាថាជនជាប់ចោទនោះ នឹងមិនរត់គេចខ្លួនទេ។ បើតុលាការគិតឃើញថាអាចមានគ្រោះធំថាជននោះនឹងរត់គេចខ្លួន តុលាការអាចបង្គាប់ឲ្យដាក់ជននោះក្នុងមន្ទីរឃុំឃាំង។ បន្ទាប់ពីនោះ គេនឹងកំណត់ថ្ងៃសម្រាប់ធ្វើសវនាការក្តី។

ចាប់ពីខណៈដែលជនណាម្នាក់ត្រូវបានចោទប្រកាន់ជាផ្លូវការហើយ ករណីនេះត្រូវស្ថិតក្រោមដំណើរការផ្លូវច្បាប់។ ប្រទេសមួយចំនួនមានភាពតឹងរ៉ឹងត្រង់ចំណុចនេះ ហើយអនុញ្ញាតឲ្យគេសរសេរផ្សាយតែព័ត៌មានបន្តិចបន្តួចប៉ុណ្ណោះ។ អ្នកយកព័ត៌មានមិនអាចសម្ភាសន៍មេធាវី ក្រុមគ្រួសារអ្នកពាក់ព័ន្ធក្នុងក្តី និងធ្វើសេចក្តីរាយការណ៍អំពីរឿងនេះបានទេ នៅពេលដែលរឿងក្តីក្តាំនេះមិនទាន់ចប់។ គេធ្វើដូច្នេះ ដើម្បីការពារកុំឲ្យចៅក្រម ឬគណៈវិនិច្ឆ័យរងនូវឥទ្ធិពលណា ក្រៅតែពីអ្វីដែលគេស្តាប់ឮក្នុងបន្ទប់សវនាការក្រោមដំណើរការនីតិវិធីយ៉ាងតឹងរ៉ឹង។ ម្យ៉ាងវិញទៀត ឥទ្ធិពលបែបនេះអាចនាំឲ្យកើតបុរេនិច្ឆ័យទៅលើរឿងក្តី (prejudicing the case) ហើយបើមាននរណាម្នាក់ធ្វើដូច្នោះ ជននោះអាចត្រូវប្រឈមមុខនឹងការចោទប្រកាន់ពីបទមាក់ងាយតុលាការ។ *[សូមមើលជំពូក ១១ : អ្នកសារព័ត៌មាន និងច្បាប់]*។

ក្នុងករណីរដ្ឋប្បវេណី នគរបាលមិនចូលពាក់ព័ន្ធក្នុងការស៊ើបអង្កេត និងសវនាការទេ។ ករណីបែបនេះមេធាវីទាំងសងខាងប្រើលិខិតទាក់ទងគ្នាទៅវិញទៅមក រហូតទាល់តែពួកគេសម្រេចបានកិច្ចព្រមព្រៀងមួយ ឬបើពួកគេមិនអាចសម្រេចបាន ម្នាក់ក្នុងចំណោមពួកគេនឹងដាក់ពាក្យសុំឲ្យតុលាការរដ្ឋប្បវេណីបើកសវនាការ ដើម្បីដោះស្រាយវិវាទ។ ក្នុងដំណាក់កាលណាមួយមុននឹងថ្ងៃសវនាការមកដល់ ឬមួយក៏ក្នុងពេលសវនាការ ភាគីទាំងពីរអាចដោះស្រាយជម្លោះបានហើយ ករណីនឹងត្រូវបានគេបញ្ចប់ទៅតាមនោះដែរ។

ករណីបទព្រហ្មទណ្ឌខ្លះ ក៏មានចំណាត់ការស្រដៀងគ្នានេះដែរ ដែលគេហៅថា **ការចរចាប្តូរចម្លើយជាមួយការសម្រាលទោស (plea bargaining)**។ ក្នុងចំណាត់ការនេះ អយ្យការចរចាជាមួយជនជាប់ចោទ។ បើជនជាប់ចោទយល់ព្រមសារភាពហើយឆ្លើយទទួលកំហុសចំពោះបទចោទមួយ ឬពីរក្នុងចំណោមបទចោទបី ឬមួយក៏ផ្តល់សក្ខីកម្មប្រឆាំងនឹងគូកនជាប់ចោទរបស់ខ្លួន អយ្យការអាចនឹងគិតគូរទំលាក់ចោលបទចោទខ្លះ ក្នុងនោះអាចមានបទចោទខ្ពស់ៗផង។ ឧទាហរណ៍ បើជនជាប់ចោទឆ្លើយទទួលកំហុសចំពោះការដែលគេមានអាវុធគ្រោះថ្នាក់ខ្លាំង និងការវាយដំធ្ងន់ធ្ងរ អយ្យការអាចនឹងទំលាក់ចោលនូវបទចោទស្តីពីការប៉ុនប៉ងធ្វើឃាត។

ទាំងក្នុងករណីបណ្តឹងព្រហ្មទណ្ឌ និងបណ្តឹងរដ្ឋប្បវេណី មុននឹងសវនាការមកដល់ភាគីទាំងសងខាងត្រូវបង្ហាញគ្នាទៅវិញទៅមកនូវព័ត៌មានដែលគេ

មាន និងដែលគេប្រុងនឹងប្រើក្នុងសវនាការ។ ព័ត៌មាននោះ រួមមាន ឯកសារ **វត្ថុតាង** (exhibits/ដូចជាអាវុធ និងអ្វីក៏ដោយដែលគេរកឃើញនៅកន្លែងកើតហេតុ) និងឈ្មោះរបស់សាក្សី។ តាមធម្មតា ជនណាដែលត្រូវបានតុលាការហៅឲ្យផ្តល់សក្ខីកម្មក្នុងសវនាការ មិនអាចប្រកែកមិនបង្ហាញមុខបានទេ។ បើពួកគេមិនឡើងមកបង្ហាញខ្លួនដោយស្ម័គ្រចិត្តទេ តុលាការអាចចេញ**ដីកាកោះ (subpoena)** ដែលជាការបង្គាប់ឲ្យឡើងតុលាការក្នុងនាមជាសាក្សី។ បើបុគ្គលនោះនៅតែប្រកែកមិនព្រមឡើងតុលាការ គេអាចនឹងទទួលទណ្ឌកម្មពីតុលាការ។ ហើយបើសិនជាសាក្សីណាមួយនិយាយកុហក គេអាចប្រឈមមុខនឹងការចោទប្រកាន់ពីបទផ្តល់សក្ខីកម្មទុច្ចរិត។

ពេលណាសវនាការករណីព្រហ្មទណ្ឌមួយចាប់ផ្តើម ជនជាប់ចោទនឹងត្រូវបានតុលាការសួរឲ្យនិយាយបញ្ជាក់ទៅតុលាការថាមានកំហុស ឬមិនមានកំហុស (plead guilty or not guilty)។ បើទោះជាបុគ្គលជាប់ចោទនិយាយបញ្ជាក់ថាមានកំហុសក្តី ក៏តុលាការ (ចៅក្រម និងគណៈវិនិច្ឆ័យ) ត្រូវតែរកឲ្យឃើញ និងសម្រេចថាជននោះ ពិតជាបានប្រព្រឹត្តឧក្រិដ្ឋកម្មមែន។ ពិតណាស់ បើជនជាប់ចោទនិយាយបញ្ជាក់ថាមានកំហុស នេះមានន័យថា ភាគីអយ្យការមិនចាំបាច់ប្រឹងខ្លាំងទេក្នុងការបញ្ជាក់អះអាងបទចោទប្រកាន់នោះ។ តែបើសិនជាមានហេតុផលណាមួយ ដែលជនជាប់ចោទនិយាយបញ្ជាក់ថា ខ្លួនគេមានកំហុសនៅពេលដែលគេគ្មានកំហុសសោះ (ឧទាហរណ៍ គេធ្វើដូច្នេះដើម្បីការពារជនមានកំហុសពិតប្រាកដ) តុលាការចាំបាច់ត្រូវតែដឹងឮអំពីរឿងនេះ។

ភាគច្រើនក្នុងសវនាការដែលមានជនជាប់ចោទនិយាយបញ្ជាក់ថាគ្មានកំហុស នីតិវិធីនឹងប្រព្រឹត្តទៅដូចខាងក្រោមនេះ៖

ភាគីអយ្យការចាប់ផ្តើម **បើកទឡ្ហីករណ៍** ដោយសង្ខេបអង្គហេតុក្នុងករណី។ ភាគីការពារចុងចោទនឹងតបវិញជាមួយនឹងទឡ្ហីករណ៍ថា ហេតុអ្វីបានជាគេគិតថា តុលាការគួរសម្រេចថាជនជាប់ចោទគ្មានកំហុស។ បន្ទាប់ពីនោះគេនឹងពិនិត្យមើលយ៉ាងល្អិតល្អន់នូវភស្តុតាងក្នុងការជំរះក្តី។ គេធ្វើរបៀបនេះដោយមានសាក្សីអង្គុយទល់មុខភាគីទាំងអស់ក្នុងសវនាការ។ ភាគីអយ្យការសួរសំណួរទៅកាន់សាក្សី ហើយឲ្យគេបង្ហាញអត្តសញ្ញាណវត្ថុតាងដែលតាំងក្នុងសវនាការ។ មកដល់ដំណាក់កាលនេះ (គេហៅវាថា ការសាកសួរនាំមុខ/examination-in-chief) ចម្លើយជួយបញ្ជាក់បន្ថែមទៅនឹងភស្តុតាង



*បើវាជាទង្វើមិនស្របច្បាប់ តើពួកគេជាឧក្រិដ្ឋជន ឬជាជនរងគ្រោះ?*

ដែលសំដៅអះអាងថាជនជាប់ចោទបានប្រព្រឹត្តអំពើឧក្រិដ្ឋកម្មពិតមែន។

បន្ទាប់ពីអយ្យការបញ្ចប់ការសាកសួរសាក្សីនីមួយៗហើយ ភាគីការពារចុងចោទអាចចាប់ផ្តើមចោទសួរសាក្សីវិញភ្លាមៗតែម្តង (ត្រង់នេះគេហៅថា **ការសាកសួរផ្ទៀងផ្ទាត់/cross-examination)**។ សំណួររបស់គេធ្វើឡើងក្នុងគោលដៅបង្កើតការមន្ទិលថាតើជនជាប់ចោទ ពិតជាបានប្រព្រឹត្តអំពើឧក្រិដ្ឋមែន ឬទេ។ បន្ទាប់ពីនេះជាវេនរបស់អយ្យការម្តងទៀត ក្នុងការចោទសំណួរទៅកាន់សាក្សីក្នុងគោលដៅបំផ្លាញនូវការមន្ទិលសង្ស័យ (ត្រង់នេះគេហៅថា ការសាកសួរបញ្ជាក់ឡើងវិញ/re-examination)។

ពេលតំណាងអយ្យការបញ្ចប់ការកោះហៅសាក្សីរបស់ខ្លួន ហើយបានបង្ហាញភស្តុតាងរួចរាល់អស់ហើយ គេ "សំរាកករណីរបស់គេ"។ ពេលនោះក្រុមមេធាវីការពារចុងចោទ កោះហៅសាក្សីរបស់គេមកផ្តល់កសិណវិញម្តង។ ដំណាក់កាលនេះប្រព្រឹត្តទៅតាមនីតិវិធីដូចមុនដែរ គឺការសាកសួរនាំមុខដោយមេធាវីការពារ ការសាកសួរផ្ទៀងផ្ទាត់ដោយតំណាងអយ្យការ និងការសាកសួរបញ្ជាក់ឡើងវិញដោយមេធាវីការពារ។

កាលណារួចរាល់អស់ហើយ ភាគីទាំងសងខាងនឹងធ្វើទឡ្ហីករណ៍សន្និដ្ឋាន។ បន្ទាប់មកទៀតចៅក្រម ឬគណៈវិនិច្ឆ័យ ចាកចេញពីបន្ទប់សវនាការដើម្បីធ្វើការថ្លឹងថ្លែងភស្តុតាងទាំងអស់ មុននឹងពួកគេត្រឡប់មកវិញ (ប៉ុន្មានថ្ងៃ សប្តាហ៍ ឬក៏ខែក្រោយមកទៀត) ដើម្បីផ្តល់សាលក្រមរបស់គេ។ បើសិនជាគេរកឃើញថា ជនជាប់ចោទមានពិរុទ្ធជន នោះនឹងត្រូវបានទទួលការអនុញ្ញាតឲ្យសុំតុលាការធ្វើការពិចារណាសំណូមពរខ្លះៗ មុននឹងធ្វើការវិនិច្ឆ័យទោស។ ឱកាសរបស់ជនជាប់ចោទធ្វើសំណូមពរបែបនេះ ត្រូវបានគេហៅថា **ការអង្វរសុំសម្រាលទោស (plea in mitigation)**។ បន្ទាប់មកទៀតចៅក្រមនឹងសម្រេចការកាត់ទោស តើពិរុទ្ធជនត្រូវជាប់ពន្ធនាគារប៉ុន្មានឆ្នាំ។

មានតែករណីតូចតាចទេ ដែលចប់ត្រឹមនេះ។ ជាញឹកញយ ពិរុទ្ធជននឹងប្តឹងឧទ្ធរណ៍ទៅកាន់តុលាការជាន់ខ្ពស់មួយទៀត។ តែដំណើរការឧទ្ធរណ៍មិនមែនជាសវនាការកាត់ក្តីថ្មីទេ។ តាមធម្មតាដំណើរការរបស់វាមានកំហិតវិសាលភាពត្រឹមផ្នែកពាក់ព័ន្ធមួយចំនួននៃសវនាការពីដំបូងតែប៉ុណ្ណោះ ដូចជាផ្នែកជាក់លាក់ណាមួយនៃភស្តុតាង ភាពជឿទុកចិត្តបានរបស់សាក្សី ឬមួយក៏ផ្នែកណាមួយនៃនីតិវិធីសវនាការដែលប្រឆាំងនឹងគោលការណ៍ការកាត់ក្តីប្រកបដោយយុត្តិធម៌។ បើបណ្តឹងឧទ្ធរណ៍នេះចាញ់ ក្នុងករណីខ្លះអាចមានបណ្តឹងឧទ្ធរណ៍ទៅតុលាការជាន់ខ្ពស់មួយជាន់ទៀត។

# រាយការណ៍ព័ត៌មានបទព្រហ្មទណ្ឌ និងតុលាការ

**ប្រភពព័ត៌មាន៖** ភាគច្រើនអ្នកសារព័ត៌មានកាន់មុខព្រួញរឿងព្រហ្មទណ្ឌ អភិវឌ្ឍន៍បានទំនាក់ទំនងល្អជាមួយប៉ូលីស ដូចជាប៉ូលីសអង្កេតការណ៍ និងមេបញ្ជាការប៉ូលីសជាន់ខ្ពស់ជាដើម។ ជួនកាលគេក៏អាចរៀបចំឲ្យមានទស្សនកិច្ចនៅតាមស្ថានីយប៉ូលីសធំៗ ដើម្បីឲ្យឃើញផ្ទាល់ភ្នែកតើគេប្រតិបត្តិការបែបណា។ នៅប្រទេសខ្លះ អង្គភាពសារព័ត៌មានភ្ជាប់ហ្វ្រេកង់វិទ្យុប៉ូលីស ដើម្បីស្តាប់ហេតុការណ៍ធំៗដែលកើតឡើងប្រចាំថ្ងៃ។ ជួនកាល អ្នកអាចសាកសុំការអនុញ្ញាតពីប៉ូលីសឲ្យរួមដំណើរក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់គេនៅតាមមូលដ្ឋាន ដោយជាបឋមប្រមូលព័ត៌មាន**ក្រៅកំណត់ត្រា (off-the-record)** សិន។ កាលណាអ្នកកសាងបាននូវការទុកចិត្តពីសំណាក់ប៉ូលីសហើយ គេអាចអនុញ្ញាតឲ្យអ្នករួមដំណើរក្នុងការចុះឆែកឆេរកន្លែងណាមួយ ដែលអ្នកអាចសង្កេត

ផ្ទាល់ និងប្រមូលព័ត៌មានសរសេររឿងពីកន្លែងកើតហេតុបានតែម្តង។

អ្នកយកព័ត៌មានតុលាការព្យាយាមបង្កើតទំនាក់ទំនងជាមួយប្រភពនានានៅក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ និងនៅតុលាការ និងពន្ធនាគារ។ មេធាវីតំណាងឲ្យជនជាប់ចោទ និងជនរងគ្រោះក៏ជាប្រភពល្អៗដែរ ជាពិសេសសម្រាប់សេចក្តីត្រូវការយកព័ត៌មានពីទាំងសងខាង ដើម្បីសរសេររឿងឲ្យមានតុល្យភាព។ ទំនាក់ទំនងល្អជួយអ្នកយកព័ត៌មានមានលទ្ធភាពទទួលបានព័ត៌មាន និងស្វែងយល់នូវអ្វីកំពុងកើតឡើងបានកាន់តែច្បាស់។

ក្នុងប្រទេសជាច្រើន របាយការណ៍ប៉ូលីស និងកំណត់ហេតុតុលាការ ត្រូវបានគេចាត់ទុកថាជាឯកសារសាធារណៈ។ ក្នុងនោះ តែងតែមានសេចក្តីលម្អិតអំពីឧក្រិដ្ឋកម្ម ហើយគេអាចអនុញ្ញាតឲ្យអ្នកយកព័ត៌មានមើលបាន។ ក្រលាបញ្ជីតុលាការជាអ្នកគ្រប់គ្រងប្រកទៅកាន់ព័ត៌មានទាំងអស់នេះ ដូច្នេះគួរតែបង្កើតទំនាក់ទំនងជាមួយពួកគេធ្វើជាប្រភពផងដែរ។

ពេលណាអ្នកមានករណីធំមួយក្នុងដៃសម្រាប់ធ្វើការស្រាវជ្រាវ អ្នកគួរតែពង្លាតវិសាលភាពប្រភពរបស់អ្នកឲ្យកាន់តែធំទៅឲ្យហួសពីប៉ូលីស និងអាជ្ញាធរដទៃទៀត។ ចូរជជែកសួរនាំអ្នកជិតខាង សាក្សី មិត្ត និងក្រុមគ្រួសារនៃអ្នកទាំងឡាយ ដែលពាក់ព័ន្ធក្នុងរឿងរ៉ាវ។ មិនមែនអ្នកទាំងអស់នោះ សុទ្ធតែចង់និយាយជាមួយយើងទេ តែអ្នកអាចនឹងមានការភ្ញាក់ផ្អើលជាមួយនឹងអ្វីដែលអ្នកអាចរកឃើញ។ ធ្វើយ៉ាងណាការពារប្រភពព័ត៌មានទាំងនោះ បើវាអាចមានគ្រោះថ្នាក់ដល់ពួកគេ កាលណាយើងបង្ហាញឈ្មោះគេពេញក្នុងអត្ថបទ។ ក្នុងប្រទេសភាគច្រើនកាលណាករណីមួយឡើងដល់តុលាការហើយ អ្នកសារព័ត៌មាននឹងមិនត្រូវបានគេអនុញ្ញាតឲ្យចុះផ្សាយអ្វីអំពីករណីនេះបានទេ តែអ្នកអាចប្រមូលវាបានក្នុងពេលសវនាការ ហើយដល់ពេលណាមួយគេប្រកាសសាលក្រមអំពីរឿងនោះ អ្នកអាចសរសេរចុះផ្សាយបានជាមួយនឹងព័ត៌មានសាវតារ ដែលអ្នកប្រមូលបានរួចហើយនោះ។

**តុល្យភាព ៖** ក្នុងប្រទេសខ្លះ ប៉ូលីសយកជនសង្ស័យមកបង្ហាញក្នុងសន្និសីទព័ត៌មាន ដើម្បីឲ្យធ្វើការសារភាព តែបើមិនដូច្នោះទេ គេយកជនសង្ស័យទៅកន្លែងកើតហេតុ ហើយបង្ខំឲ្យពួកនោះបង្ហាញសកម្មភាពឡើងវិញនៅពីមុខកាមេរ៉ាទូរទស្សន៍កំពុងថត។ អ្នកសារព័ត៌មានគួរតែចងចាំថា បើទោះជាវានេះជាការអនុវត្តទូទៅក្នុងប្រទេសទាំងនោះក៏ដោយ ជនសង្ស័យអាចត្រូវបានគេបង្ខំឲ្យសារភាព - តាមរយៈការធ្វើទារុណកម្ម ឬការគំរាមអំពីការដាក់ទណ្ឌកម្មធ្ងន់។ ពួកគេអាចមាន ឬគ្មានកំហុស។ អ្នកសារព័ត៌មានគួរចាំថា ជនជាប់ចោទមានសិទ្ធិទទួលបានដំណើរកាត់ក្តីតាមផ្លូវច្បាប់ត្រឹមត្រូវ។ ដូច្នេះ អ្នកយកព័ត៌មានគួរប្រយ័ត្នក្នុងការរាយការណ៍ថា "ប៉ូលីសចោទជនសង្ស័យពីបទសម្លាប់" "ឬក៏ ប៉ូលីសនិយាយថាជននោះទទួលខុសត្រូវអំពីអំពើចោរកម្មអស់ជាច្រើនមកហើយ។ កុំយកមកសរសេរ ដូចជាអង្គហេតុពិតឲ្យសោះថាបុគ្គលម្នាក់បានប្រព្រឹត្តបទឧក្រិដ្ឋ បើកាលណាតុលាការមិនទាន់បានសម្រេចថា ជននោះមានពិរុទ្ធក្នុងឧក្រិដ្ឋកម្មនោះទេ។ ក្នុងឧទាហរណ៍ខាងលើស្តីអំពីក្រុមចោរប្រើខ្សែនីឡុង រឿងនោះមិនបានបញ្ជាក់ច្បាស់ទេថាករណីនោះ នឹងត្រូវឡើងតុលាការទៀត។ បើទោះជាមនុស្សបួននាក់បានសារភាពក្តី ពួកគេមិនទាន់មានពិរុទ្ធនៅឡើយទេ កាលណាតុលាការមិនទាន់បានកំណត់ថាពួកគេមានពិរុទ្ធ។ ដូច្នេះក្នុងការសរសេរសាកផ្តល់ព័ត៌មានផង តើពេលណាដែលគេរំពឹងថាករណីមួយនឹងឡើងដល់តុលាការ ហើយបើមិនទាន់អាចប្រាប់ថ្ងៃបានទេ ចូរសរសេរថា ជនសង្ស័យនឹងត្រូវគេឃុំខ្លួន រហូតដល់ថ្ងៃគេកំណត់យកពួកគេឡើងតុលាការបាន។

ប្រការមួយទៀតគួរចងចាំដែរ គឺកុំរាយការណ៍បង្ហាញឈ្មោះជនសង្ស័យឲ្យសោះ បើគេមិនទាន់ត្រូវ

បានទទួលការចោទប្រកាន់អំពីទង្វើឧក្រិដ្ឋណាមួយនោះជាផ្លូវការនៅឡើយទេ។ កុំភ្លេចថា ប៉ូលីសក៏ប្រព្រឹត្តកំហុសដែរ។ បើនរណាម្នាក់ត្រូវគេបង្ហាញដោយខុសឆ្គងក្នុងសារព័ត៌មានថាបានប្រព្រឹត្តបទឧក្រិដ្ឋនោះ កេរ្តិ៍ឈ្មោះរបស់គេនឹងត្រូវរងការបំផ្លិចបំផ្លាញបាត់អស់ហើយ។ ជនសង្ស័យទាំងអស់មានសិទ្ធិទទួលបានការការពារតាមផ្លូវច្បាប់ និងចំណាត់ការតាមផ្លូវច្បាប់ត្រឹមត្រូវ។ នេះមានន័យថា គេគួរចាត់ទុកជនទាំងនោះថាអពិរុទ្ធ ដរាបណាទាល់តែតុលាការច្បាប់កំណត់ថាពួកគេមានពិរុទ្ធ។ អ្នកមិនគួរធ្វើដូចគេទេ បើគ្រាន់តែឃើញសារព័ត៌មានឯទៀតផ្សាយឈ្មោះជនសង្ស័យនោះ។

មួយទៀត ចូរចៀសវាង **ការសន្មតទុក (stereotypes)** - ដែលជារបៀបពិពណ៌នាអំពីព្រឹត្តិការណ៍ ឬមនុស្សតាមបែបបុរេនិច្ឆ័យជាទូទៅ។ មានម្តងនោះ កាសែតបាងកកមួយបានរាយការណ៍រឿងមួយជាមួយនឹងចំណងជើងដូច្នេះ "នារីបើកតាក់ស៊ីចាប់ចោរជនជាតិភូមា"។ បើទោះជាវាត្រូវដូច្នោះមែន វាគ្មានភាពចាំបាច់ឯណាដែលត្រូវបង្ហាញសញ្ជាតិរបស់ចោរនោះទេ។ ធ្វើដូច្នោះវាបានត្រឹមតែពង្រឹងបន្ថែមនូវទស្សនៈអវិជ្ជមាន ដែលជនជាតិថៃជាច្រើនមានរួចទៅហើយចំពោះជនអន្តោប្រវេសន៍ដែលភាគច្រើនជាជនជាតិភូមា។ តើចំណងជើងនោះមិនជាចំណងជើងលីលាទេ បើសិនជាវាសរសេរថា "ចោរថៃ" ទៅវិញនោះ? នេះជាបញ្ហាមួយក្នុងកាសែតក្នុងប្រទេសជាច្រើនលើពិភពលោក។

**សង្កេតរកមើលលំនាំហេតុការណ៍ ៖** ចូរឧស្សាហ៍សង្កេតមើលថា តើមានចោរលបចូលក្នុងគេហដ្ឋាន ឬមានឃាតកម្មច្រើនកើតឡើងក្នុងផ្នែកមួយនៃទីក្រុងឬយ៉ាងណា? បើមាន តើដោយសារហេតុអ្វី? តើប្រជាជនអាចធ្វើអ្វីបានខ្លះទៅ ដើម្បីការពារខ្លួនគេ? ចុះប៉ូលីសវិញ តើគេអាចធ្វើអ្វីបាន? ពេលផ្គុំរឿងចូលគ្នា ចូរកុំភ្លេចផ្តល់ស្ថិតិ និងការវិភាគពីអ្នកឯកទេសដើម្បីឲ្យអ្នកអានបានយល់អំពីរឿងរ៉ាវដែលកើតមានក្នុងសង្គមរបស់គេបានប្រសើរជាងមុន។ ឧទាហរណ៍គួរឲ្យចាប់អារម្មណ៍មួយ គឺអ្វីដែលគេឲ្យឈ្មោះថា "ទ្រឹស្តីបង្អួចបែក" ដែលនិយាយថា បើអ្នកព្រងើយកន្តើយជាមួយឧក្រិដ្ឋកម្មតូចតាច អ្នកនឹងបង្កើតបរិយាកាសមួយសម្រាប់ឲ្យឧក្រិដ្ឋកម្មធំៗ រីកដុះដាលហើយ។ ទ្រឹស្តីនេះកើតលើកស្តុតាងពីការជួសជុលលំនៅដ្ឋានសាធារណៈក្នុងក្រុងញូវយ៉កនាទសវត្សរ៍ឆ្នាំ ១៩៨០។ កាលនោះ បើមានបង្អួចណាមួយបែកហើយទុកចោលមិនជួសជុល មិនយូរប៉ុន្មាននៅជុំវិញនោះចេះតែមានរឿងកើតឡើងមិនចេះចប់ ដោយសារមនុស្សមិនសូវមានការគោរព និងខ្វល់ខ្វាយចំពោះបរិស្ថានជុំវិញកន្លែងគេរស់នៅទេ។ ដូច្នេះ អាជ្ញាធរក្រុងញូវយ៉កចាប់ផ្តើមធ្វើឲ្យប្រាកដប្រជាថា កាលណាមានបង្អួចបែក វាត្រូវបានជួសជុលឡើងវិញភ្លាមហើយលុបចេញនូវគំនូរក្រវេមក្រវាមក្នុងទូរថភ្លើងក្នុងយុទ្ធនាការដែលគ្មានការអត់ធ្មត់ណាមួយ (zero tolerance) ចំពោះឧក្រិដ្ឋកម្ម ទោះជាឧក្រិដ្ឋកម្មតូចតាចក៏ដោយ។ មនុស្សជាច្រើនបានយល់ឃើញថា យុទ្ធនាការនោះបានជួយទាញទម្លាក់អត្រាឧក្រិដ្ឋកម្មក្នុងទីក្រុងញូវយ៉ក ឲ្យមកនៅទាបជាងមុនវិញ។

**ស្វែងរកមើលអ្វីដែលអធម្មតា ៖** រឿងឧក្រិដ្ឋកម្មធម្មតាមួយ អាចក្លាយទៅជារឿងចុះទំព័រទីមួយបាន បើសិនជាក្នុងនោះមានធាតុណាមួយ ដែលមានលក្ខណៈចម្លែកខុសពីធម្មតា។ ឧទាហរណ៍អាចថា បុរសម្នាក់ចូលប្លន់ធនាគារ តែដោយប្រការណាមួយនោះ គេទុកចោលនាមប័ណ្ណរបស់ខ្លួននៅពីក្រោយពេលដែលគេចាកចេញទៅ។ ឬមួយក៏ចោរម្នាក់ជាប់ខ្លួនក្នុងបង្អួច ពេលដែលវាព្យាយាមរត់ចេញពីផ្ទះមួយ។ ឬមួយ ចោរម្នាក់ព្យាយាមលួចម៉ូតូពីប៉ូលីសម្នាក់ដែលស្លៀកឯកសណ្ឋានស៊ីវិល។ ទាំងនេះសុទ្ធតែជា "ឧក្រិដ្ឋកម្មល្ងីល្ងើ" ហើយយើងពិតជាមិនអាចទប់ខ្លួនមិនអស់សំណើចក្នុងការអានរឿងភ្លីភ្លើរបស់អ្នកដទៃបានទេ។

នៅមានរឿងឧក្រិដ្ឋកម្មគួរឲ្យខ្លបខ្លាច និងចម្លែកទៀតដែរ ដែលអាចធ្វើឲ្យយើងមានភាពព្រឺព្រួច តែនៅតែចង់អាន ឧទាហរណ៍ដូចជារឿងមួយខាងក្រោមនេះពីបុណ្យណូអែលមួយនៅឆ្នាំ ២០០៨៖

*អាជ្ញាធរនិយាយថា បុរសម្នាក់ស្លៀកពាក់ជាលោកតាទឹកកក សាន់តាក្លូស បានបាញ់កាំភ្លើងទៅលើការជួបជុំបុណ្យណូអែលមួយ ហើយបន្ទាប់មកដុតផ្ទះនោះ ដោយសម្លាប់មនុស្សអស់ប្រាំបីនាក់។ ប៉ុន្មានម៉ោងក្រោយមកទៀត បុរសនោះក៏បាញ់សម្លាប់ខ្លួនឯងដែរ។*

*មេប៉ូលីស លោក Kim Raney និយាយថា ជនឈ្មោះ Bruce Jeffrey Pardo អាយុ ៤៥ ឆ្នាំ ដែលកាលពីពេលថ្មីៗនេះមានការលែងលះជាមួយភរិយាគាត់ ហើយត្រូវបានគេគិតថាទើបនឹងបាត់បង់ការងារផងនោះ មុនដំបូងឡើយបានទៅគោះទ្វារផ្ទះមួយ ដែលកាន់កាប់ដោយឪពុកម្ដាយរបស់អតីតភរិយាគាត់នៅម៉ោង ១១.៣០ នាទីយប់ កាលពីថ្ងៃពុធកន្លងទៅនេះ។*

*ប៉ូលីសនិយាយថា កុមារីអាយុ ៨ ឆ្នាំម្នាក់បានរត់ទៅបើកទ្វារឲ្យលោក Pardo។ បុរសនោះបានបាញ់ក្មេងស្រីតូចនោះចំកណ្ដាលមុខ ឈានចូលក្នុងផ្ទះ ហើយចាប់ផ្ដើមបាញ់រះដោយមិនរើសមុខ ដោយប្រើកាំភ្លើងដៃពាក់កណ្ដាលស្វ័យប្រវត្តិមួយ។*

*លោក Pardo បាននាំយកទៅជាមួយនូវអ្វីដែលទំនងជាស៊ីវីនៀរធំមួយ តែប៉ូលីសនិយាយថា តាមពិតវាជាបំពង់ប្រើសម្ពាធមួយ ដែលប្រើសម្រាប់បាញ់សាចសារធាតុមានចំហេះ។*

**មើលក្រោយឆាកផង** : តាមធម្មតាយើងនាំគ្នាសម្ដែងសមានចិត្តធំធេងចំពោះការចុកចាប់នៃមនុស្សម្នា (និងញាតិសន្ដានរបស់គេ) ដែលជាជនរងគ្រោះនៃអំពើហិង្សា។ យើងក៏មានអារម្មណ៍សោកស្ដាយដែរចំពោះប្រជាជនដែលត្រូវបានគេលួចឥវ៉ាន់ពីក្នុងផ្ទះ ឬត្រូវបានចោរលួចម៉ូតូ។ តែជាញឹកញយយើងក៏ហាក់ដូចជាមានកំហឹងផងដែរ កាលណាយើងអានរឿងឧក្រិដ្ឋកម្ម ដែលក្នុងនោះ ហាក់ដូចជាគ្មានឃើញជនរងគ្រោះសោះ ដែលនេះយើងហៅថា **ឧក្រិដ្ឋកម្ម ពួកកអាវស** (white-collar crime)។ ទាំងនេះច្រើនជាឧក្រិដ្ឋកម្មពាក់ព័ន្ធភាគច្រើននឹងការក្លែងបន្លំហិរញ្ញវត្ថុ ការគេចវេសពន្ធ និងការធ្វើបញ្ជីគណនេយ្យក្លែងក្លាយ។ ពិតណាស់ មានជនរងគ្រោះដែរ ដែលជួនកាលពួកគេជានិវត្តន៍ជន វិនិយោគិន ជួនកាលជាក្រុមហ៊ុន ពលរដ្ឋបង់ពន្ធ ឬបើមិនដូច្នោះទេ វាជារឿងដែលអ្នកនយោបាយលួចពីរដ្ឋ។ ជារឿយៗ ឧក្រិដ្ឋកម្មខ្លួនឯង និងភស្តុតាង មានភាពស្មុគស្មាញសម្រាប់យើងតាមយល់ ហើយសែនពិបាកនឹងយកមកសរសេរជារឿងណាស់។ តែបើយើងអាចតាមដានស្រាវជ្រាវវាបាន រឿងប្រភេទនេះគួរឲ្យពេញចិត្តពេញថ្លើមនឹងធ្វើណាស់។ ពេលខ្លះយើងត្រូវអត់ធ្មត់ ពីព្រោះយើងចាំបាច់ត្រូវ **កសាងទ្រង់ទ្រាយសាច់រឿងឲ្យបានពេញរូបពេញរាង** ចេញពីព័ត៌មានដែលយើងប្រមូលបានពីប្រភពទាំងអម្បាលម៉ាននោះ។ ករណីបែបនេះធ្លាប់មានពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុន Siemens ដែលជាក្រុមហ៊ុនធំមួយលើពិភពលោក។ វាជាក្រុមហ៊ុនអេឡិកត្រូនិក និងវិស្វកម្មរបស់អាល្លឺម៉ង់ ហើយក្នុងនោះ វាធ្លាប់មាននាយកដ្ឋានពិសេសមួយជាមួយបុគ្គលិក និងថវិកា ដែលគោលដៅរបស់វា គឺធ្វើសំណូកឲ្យមន្ត្រីរដ្ឋាភិបាលនៅតាមប្រទេសណា ដែលក្រុមហ៊ុននោះព្យាយាមប្រជែងយកកុងត្រារកស៊ី។ កាសែត New York Times សរសេររឿងនេះ ដោយប្រើឯកសារតុលាការ សក្ខីកម្មក្នុងសវនាការ និងបទសម្ភាសន៍ជាច្រើនក្រោយមកទៀត រួមទាំងបទសម្ភាសន៍ជាមួយបុរសម្នាក់ដែលត្រូវបានគេរកឃើញថា មានពិរុទ្ធនៅក្នុងការសូកប៉ាន់នោះផង៖

*លោក Reinhard Siekaczek កំពុងដេកលក់លើវៗលើគ្រែរបស់គាត់ ស្រាប់តែកណ្ដឹងទ្វារ*



*តើបេសារព័ត៌មានរស់បានដោយសារតែគ្រោះមហន្តរាយ ឬក៏វាជួយធ្វើឲ្យមហន្តរាយថយចុះជាងមុន?*

*គេហដ្ឋានរបស់គាត់នៅក្រុងមូនិក ប្រទេសអាល្លឺម៉ង់ រោទិ៍ឡើងនៅព្រឹកមួយកាលពីពីរឆ្នាំមុន។*

*ស្ថិតក្នុងសម្លៀកបំពាក់គេងនៅឡើយ គាត់ក្រោកចេញពីគ្រែ ហើយប្រញាប់ប្រញាល់ចុះទៅជាន់ខាងក្រោម។ ពេលគាត់បើកទ្វារឡើង នៅឈរពីមុខគាត់ គឺប៉ូលីសអាល្លឺម៉ង់ ៦ នាក់ និងរដ្ឋអាជ្ញាម្នាក់ផង។ ពួកគេលើកបង្ហាញគាត់នូវក្រដាសមួយសន្លឹកដែលជាដីកាចាប់ខ្លួនគាត់។*

*ក្នុងខណៈនោះ លោក Siekaczek ដែលជាមនុស្សសក់ស្កូវ ធ្លាប់ធ្វើជាគណនេយ្យកររបស់ក្រុមហ៊ុន Siemens A.G., ដែលជាក្រុមហ៊ុនវិស្វកម្មធំមួយរបស់អាល្លឺម៉ង់ ដឹងខ្លួនថាជីវិតអាថ៌កំបាំងរបស់គាត់បានមកដល់ទីបញ្ចប់ហើយ។*

*លោក Siekaczek និយាយទៅកាន់ក្រុមប៉ូលីសដែលកំពុងឈរនៅមាត់ទ្វារគាត់ថា៖ "ខ្ញុំដឹងហើយថាមានរឿងអីនោះ។ ខ្ញុំកំពុងរង់ចាំអស់លោកដែរ"។*

ពីឆ្នាំ ២០០២ ដល់ឆ្នាំ ២០០៦ លោក Siekaczek ទទួលខុសត្រូវក្នុងការចាត់ចែងថវិកាសម្រាប់ធ្វើសំណូកពី ៤០ ទៅ ៥០ លានដុល្លារ ក្នុងមួយឆ្នាំ។ ក្នុងអំឡុងពេលនោះ ក្រុមហ៊ុន Siekaczek ចុះបាន "កិច្ចព្រមព្រៀងប្រឹក្សាយោបល់ធុរកិច្ច" បានចំនួន ២.៧០០ កិច្ចព្រមព្រៀង ដែលតាមពិតសុទ្ធតែជាសំណូកទៅឲ្យមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលនៅតាមប្រទេសជាច្រើនក្នុងពិភពលោក។ យោងតាមអត្ថបទកាសែត New York Times នោះ មន្ត្រីប្រទេសទទួលសំណូកមានប្រទេសវៀតណាម វ៉េណេ ស៊ុយអេឡា អ៊ីតាលី អ៊ីស្រាអែល បង់ក្លាដេស នីហ្សេរីយ៉ា ចិន រុស្ស៊ី និងអាហ្សង់ទីន។

មន្ត្រីអនុវត្តន៍ច្បាប់ម្នាក់និយាយថា៖ "សំណូកសូកប៉ាន់ គឺជាម៉ូដែលមួយក្នុងរបៀបរកស៊ីរបស់ក្រុមហ៊ុន Siemens"។

ក្រុមហ៊ុន Siemens ត្រូវបានគេរកឃើញថាមានពិរុទ្ធ ហើយត្រូវបង់ប្រាក់ចំនួន ១,៦ ពាន់លានដុល្លារ ក្នុងការផាកពិន័យធំបំផុតក្នុងប្រវត្តិសាស្ត្រ ក្រុមហ៊ុនរកស៊ីបច្ចុប្បន្ន។ លោក Siekaczek ត្រូវបានតុលាការអាល្លឺម៉ង់ កាត់ឲ្យជាប់ការព្យួរទោសសាកល្បងរយៈ

ពេលពីរឆ្នាំ និងផាកពិន័យ ១៥០.០០០ ដុល្លារ។

ប៉ុន្តែអត្ថបទកាសែត New York Times មិនមែនផ្ដោតតែទៅលើបទឧក្រិដ្ឋ និងតួលេខក្នុងរឿងអាស្រូវមួយនេះទេ តែវាក៏បានផ្ដោតទៅលើបុរសនោះដែរ៖

*លោក Siekaczek មិនមែនជាប្រភេទសន្ធតទុកនៃបទឧក្រិដ្ឋរបស់ពួកអាវស មានក្រវាត់កនោះទេ។ គាត់គ្មានឡានទំនើប ដូចជា Ferrari ឬក៏វីឡានៅក្រុងម៉ូណាកូដូចអ្នកមានដទៃទេ។ គាត់ចូលចិត្តស្លៀកខោជីនស៍ និងពាក់អាវស្បែក។ ជាមួយនឹងសក់ពណ៌ស ហើយពាក់វ៉ែនតាហាមពណ៌មាស គាត់មើលទៅប្រៀបបាននឹងជីតាចិត្តធម៌មួយរូបដែរ គ្រាន់តែថាគាត់ជាជីតា ដែលអាចពិភាក្សាបានយ៉ាងងាយអំពីប្រៀបក្នុងការមានគណនីនៅក្រៅប្រទេស គឺស្រួលដូចការនិទានអំពីបាល់ទាត់កាលពីយប់មិញដែរ។*

ហើយរឿងនេះពន្យល់តួនាទីរបស់គាត់ក្នុងការសូកប៉ាន់នោះដូចតទៅ៖

*ក្នុងការលែលកជាមួយប្រតិបត្តិការសូកប៉ាន់ក្នុងរបររកស៊ី ក្រុមនាយកប្រតិបត្តិបាននាំគ្នាងាកទៅរកលោក Siekaczek ដែលល្បីឈ្មោះក្នុងក្រុមហ៊ុនថាជាមនុស្សមានភាពស្មោះត្រង់ និងកក្ដីភាពជ្រាលជ្រៅចំពោះក្រុមហ៊ុនរបស់គាត់។*

ការរ៉ាយរ៉ាប់ទាំងអម្បាលម៉ានកន្លងមកនេះគ្រាន់តែជាសម្រង់ខ្លះៗពីរឿងមួយមាន ២.៨០០ ពាក្យដ៏សែនជក់ចិត្ត ដែលនេះជាឧទាហរណ៍លេចធ្លោមួយអំពីការ**កសាងឡើងវិញ**នូវរឿងផ្ដោតលើមនុស្សម្នាក់ ហើយព្រមពេលជាមួយគ្នានោះដែរ ផ្ដល់សេចក្ដីលម្អិតអំពីករណីវិសាមញ្ញមួយ អំពីអំពើពុករលួយក្នុងពិភពធុរកិច្ច និងរដ្ឋាភិបាល ដែលយើងទាំងអស់គ្នាតែងដឹងតែកម្រឃើញ។

**ទង្វើបំពានគន្លងយុត្តិធម៌ (Perversion of justice):** ពេលខ្លះ មនុស្សព្យាយាមប្រើប្រាស់ប្រព័ន្ធតុលាការ ដើម្បីហេតុផលចម្លែក និងកំប៉ិកកំប៉ុកណាមួយរបស់គេ ដែលបង្កើតបានទៅជារឿងចាប់អារម្មណ៍របស់អ្នកអាននៅជុំវិញពិភពលោកទៅវិញ។

ចូរមើលឧទាហរណ៍មួយខាងក្រោមនេះ ដែលជាករណីរដ្ឋប្បវេណីគួរឲ្យចម្លែកមួយនៅក្នុងរដ្ឋធានីវ៉ាស៊ីនតោននៃសហរដ្ឋអាមេរិក។ ក្នុងរឿងនេះ ចៅក្រមមួយរូប (ដែលមិនមែនធ្វើសកម្មភាពក្នុងនាមគាត់ជាចៅក្រមទេ តែក្នុងនាមជាពលរដ្ឋសាមញ្ញមួយរូប ពេលដែលរឿងរ៉ាវនេះកើតឡើង) បានប្ដឹងហាងបោកគក់សម្លៀកបំពាក់ស្ងួតមួយ ដោយទាមទារសំណង ៥៤ លានដុល្លារ ដោយសារហាងនោះច្រឡំខោរបស់គាត់ជាមួយខោរបស់អតិថិជនដទៃ។

សម្រង់ខាងក្រោមនេះ បានគូសវាសឡើងវិញនូវ**ទិដ្ឋភាពរស់រវើក** នៃឆាកក្នុងតុលាការ ដែលកាសែត New York Times បានសរសេរអំពីករណីក្ដីក្ដៅនេះ៖

*ខោជើងវែងពណ៌ខ្មៅមួយគូ ដែលជាស្នូលនៃពាក្យបណ្ដឹងតម្លៃ ៥៤ លានដុល្លារមួយ ត្រូវបានគេយកមកលាតរលាស់ក្នុងបន្ទប់សវនាការកាលពីថ្ងៃពុធ កន្លងទៅនេះ ហើយត្រូវបានលើកមកបង្ហាញជាភស្តុតាងដោយមេធាវីការពារចុងចោទ ដែលបានចាត់ទុកពាក្យបណ្ដឹងនោះថាជា "សុបិនអាក្រក់" មួយសម្រាប់កូនក្ដីរបស់គេ។*

*"នេះជារឿងមួយស្ដីអំពីរបៀបដែលបុរសម្នាក់បំពានយ៉ាងព្រៃផ្សៃទៅលើប្រព័ន្ធច្បាប់ ហើយបង្កភាពពុកចាប់ចំផេងក្រៃលែងចំពោះរបររកស៊ីរបស់ឪពុកម្ដាយមួយគូ ដែលជាមនុស្សខំប្រឹងធ្វើការរកស៊ីនោះ" - នេះជាសម្ដីរបស់លោកមេធាវី Christo-pher Manning ដែលនិយាយសំដៅលោក Roy L. Pearson Jr. ដែលជាចៅក្រមច្បាប់រដ្ឋបាលនៅតុលាការសង្កាត់ District of Columbia ដែលកំពុងប្ដឹងម្ចាស់ហាងបោកគក់ស្ងួត។*

*លោក Pearson ចោទថាហាង Custom Dry Cleaners បានប្រគល់ឲ្យគាត់នូវខោផ្សេង ហើយមិន*

គោរពនូវពាក្យសន្យាដែលគេបានដាក់ក្នុងស្លាករបស់ហាង ដែលសរសេរថា "Same Day Service" និង "Satisfaction Guaranteed" ។

ចៅក្រមលោកស្រី Judith Bartnoff កំពុងធ្វើអធិបតីក្នុងការកាត់ក្តីរឿងនេះ ហើយត្រូវបានគេរំពឹងទុកថានឹងចេញសាលក្រមនៅចុងសប្តាហ៍ក្រោយ ។

នៅក្នុងការផ្តល់សក្ខីកម្ម គួរឲ្យរំជួលចិត្តមួយ លោកស្រី Soo Chung ដែលជាម្ចាស់ម្នាក់ក្នុងបំណោមម្ចាស់ច្រើននាក់ទៀតនៃមុខរបរនោះ និយាយថា ករណីក្តីក្តាំនេះបាននាំមកនូវក្តីវេទនាឲ្យនាង និងក្រុមគ្រួសាររបស់នាង ដែលអង្គុយលើកៅអីជួរមុខក្នុងបន្ទប់សវនាការ ។

ខោនោះ ត្រូវបានគេលើកមកបង្ហាញមុននឹងលោកស្រី Chung ឡើងផ្តល់សក្ខីកម្ម ។ គាត់ចង្អុលខោនោះ ហើយប្រាប់តុលាការថាគាត់នៅចងចាំថា គឺខោនោះ ហើយដែលលោក Pearson បានយកមកឲ្យហាងគាត់ជួយកែតម្រូវក្នុងថ្លៃ ១០.៥ ដុល្លារ ។

ប៉ុន្តែលោក Pearson និយាយថាខោនោះមិនមែនជារបស់គាត់ទេ ។ គាត់ប្តឹងក្រោយពេលដែលលោកស្រី Chung និងប្តីរបស់គាត់ លោក Jin Chung មិនព្រមឆ្លើយតបនឹងការទាមទាររបស់គាត់ឲ្យសងប្រាក់ ១.២៥០ ដុល្លារ ដើម្បីយកទៅទិញខោអាវធំមួយកុំផ្លេមកជំនួសវិញ ។

លោកស្រី Chung ពោលទាំងទឹកភ្នែកថា ៖ "យើងមានការលំបាកក្រៃលែងក្នុងរឿងនេះទាំងផ្នែកសេដ្ឋកិច្ច ផ្លូវចិត្ត និងសុខភាព ។ ជួនកាលគាត់ចូលក្នុងហាងរបស់យើងតាមតែចិត្តរបស់គាត់ ហើយថតរូបពួកយើងពេលដែលយើងកំពុងប្រកបមុខរបរប្រចាំថ្ងៃ" ។

ក្នុងការសាកសួរផ្ទៀងផ្ទាត់ មេធាវីកូនក្តី គឺលោក Manning សួរទៅកាន់លោក Pearson ថាតើវាសមហេតុផលទេ សម្រាប់ជនម្នាក់ក្នុងការប្តឹងអ្នកជំនួញម្នាក់ទាមទារសំណងរាប់លានដុល្លារ ដោយសារតែមិនទទួលបានការពេញចិត្តដូចមានសរសេរដាក់ក្នុងស្លាកសញ្ញា ។

លោក Manning សួរថា ៖ "ដោយមិនបាច់និយាយដល់ច្បាប់ ក្នុងនាមជាមនុស្សម្នាក់ ជាបុគ្គលមួយរូប តើលោកមិនគិតទេថាជាការមានសតិ បើគ្រាន់តែបកស្រាយសញ្ញាមួយក្នុងន័យសមហេតុសមផល ?"

លោក Pearson ដែលតំណាងខ្លួនឯងក្នុងសវនាការឆ្លើយតបវិញថា "ទេ" ។

ថែមលើវិនាដកម្មក្នុងសវនាការ (ក្នុងនោះមាន **សន្ធនាគ្រប់ម៉ាត់** នៅក្នុងការសាកសួរផ្ទៀងផ្ទាត់ផងនោះ) រឿងនេះបានផ្តល់សេចក្តីពិស្តារចាំបាច់គ្រប់គ្រាន់នៃករណី និងអំពីមេធាវី និងចៅក្រមពាក់ព័ន្ធក្នុងរឿងនេះផងដែរ ។

នៅក្នុងរបាយការព័ត៌មានមួយទៀតអំពីសវនាការនេះ ដែលធ្វើដោយទូរទស្សន៍ ABC យើងបានសិក្សាដឹងថែមទៀតអំពីលោក Pearson ដ៏ចម្លែកមួយនេះ ក្នុងអំឡុងពេលគាត់បង្ហាញខ្លួននៅតុលាការ ៖

លោក Pearson មានការរំជួលអារម្មណ៍នៅពេលដែលគាត់ពេលគាត់រៀបរាប់ឡើងវិញនូវការប្រឈមមុខរបស់គាត់ជាមួយលោកស្រី Soo Chung ។

គាត់និយាយថាគាត់បានប្រាប់ទៅលោកស្រីនោះថា ៖ "នេះមិនមែនជាខោរបស់ខ្ញុំទេ ។ លើកលែងតែពេលម្តងគត់ តែក្រៅពីនោះ ខ្ញុំ ក្នុងមួយជីវិតពេញវ័យរបស់ខ្ញុំ មិនដែលស្លៀកខោដែលមានផ្នត់ចុងជើងបត់ឡើងលើទេ" ។

លោក Pearson ផ្តល់សក្ខីកម្មថា លោកស្រី Chung នៅតែទទូចថា ៖ "វាពិតជាខោរបស់លោកមែនហើយ" ។

បន្ទាប់មក លោក Pearson បានរត់ចេញពីក្នុងសាលសវនាការដោយរំជួលក្នុងចិត្តខ្លាំងពេក ។

*អ្នកប្រហែលជាស្រាកស្រាន្តក្នុងចិត្តពេលដែលដឹងថា លោកស្រី Chung ឈ្នះក្នុងក្តីនេះ។ បន្ទាប់ពីការប្រកាសសាលក្រម ទូរទស្សន៍ ABC បានស្រង់សម្តីលោកស្រី Chung ដែលបាននិយាយថា៖*

*"វាមិនមែនជារឿងអស់សំណើចទេ ហើយក៏គ្មាននរណាម្នាក់អាចនឹងគិតដល់ថា នឹងមានរឿងរបៀបនេះកើតឡើង"។ លោកស្រី Soo Chung ពោលតាមរយៈអ្នកបកប្រែ។ ប្តីរបស់គាត់ឯកភាពជាមួយគាត់ដែរ។ [ស្វាមីភរិយាមួយគូនេះ ទើបនឹងធ្វើអន្តោប្រវេសន៍ពីកូរ៉េខាងត្បូងមករស់នៅសហរដ្ឋអាមេរិក]*

*លោក Jin Chung និយាយថា៖ "រឿងនេះមានផលប៉ះពាល់មកលើយើងមុនគេផ្នែកហិរញ្ញវត្ថុដោយសារតែថ្លៃឈ្នួលមេធាវីដែលយើងត្រូវបង់។ អស់ពេលពីរឆ្នាំហើយដែលយើងប្រឹងរកលុយបង់ថ្លៃមេធាវី ហើយយើងក៏មានកេរ្តិ៍ឈ្មោះមិនល្អដែរជាមួយធនាគារ;ម្យ៉ាងទៀត វាពិបាកមែនទែនទាំងផ្នែកផ្លូវចិត្ត និងទាំងផ្នែករាងកាយ ដោយសារតែការតានតឹងក្នុងអារម្មណ៍ដែលបណ្តាលមកពីរឿងនេះ"។*

*បន្តិចក្រោយមក លោកស្រី Soo Chung ស្រក់ទឹកភ្នែក។*

*គាត់ពោលថា៖ "ខ្ញុំមិនដែលនឹកគិតថា រឿងរ៉ាវនេះនឹងអូសបន្លាយវែងឆ្ងាយបែបនេះទេ។ ខ្ញុំមិនចង់រស់នៅទីនេះទៀតទេ។ វាមានការលំបាកខ្លាំងណាស់។ ខ្ញុំគ្រាន់តែចង់ត្រឡប់ទៅផ្ទះ គឺទៅនៅកូរ៉េវិញតែប៉ុណ្ណោះ"។*

*លោក Jin Chung និយាយតាមរយៈអ្នកបកប្រែថា៖ "ខ្ញុំរកស៊ីបោកគក់ស្ងួតនេះអស់ពេល ១៤ ឆ្នាំហើយ តែករណីបែបនេះមិនដែលមានកើតឡើងចំពោះខ្ញុំទេ។ បើមានអ្វីកើតឡើងដល់សម្លៀកបំពាក់របស់អតិថិជនយើង យើងតែងតែសងជំងឺចិត្តគេវិញតាមនោះ និងដោយសមស្របបំផុត"។*

ក្នុងគោលបំណងជួយអ្នកអានឲ្យគាត់តែយល់បានច្បាស់ថែមទៀត ទីភ្នាក់ងារព័ត៌មាន Associated Press បានឈានមួយជំហានទៅមុខទៀតក្នុងសេចក្តីរាយការណ៍របស់ខ្លួន។ ទីភ្នាក់ងារនេះរាយការណ៍ក្នុងពេលសវនាការថា៖

*មេធាវីម្នាក់របស់គ្រួសារ Chung បានពណ៌នាលោក Pearson ថាជាមនុស្សកំពុងប្រទះភាពជូរចត់ក្នុងជីវិត ដោយមានបញ្ហាហិរញ្ញវត្ថុមកពីការលែងលះគ្រួសារថ្មីៗនេះ តែបែរជាយកកំហឹងនោះមកសងសឹកជាមួយគ្រួសារមួយដែលខំប្រឹងរកស៊ីទៅវិញ។*

ក្រោយពីមានការប្រកាសសាលក្រមលើរឿងនេះភ្លាម Associated Press បានធ្វើសេចក្តីរាយការណ៍ថា៖

*ករណីក្តីក្តាំមួយនេះធ្វើឲ្យមានការចាប់អារម្មណ៍ជាអន្តរជាតិ ហើយអំពាវនាវសារជាថ្មីឡើងវិញឲ្យមានកំណែទម្រង់របៀបលៃលកជាមួយបណ្តឹងវិវាទ។*

*លោក Paul Rothstein សាស្ត្រាចារ្យច្បាប់នៅ Gerogetown Univeristy និយាយថា៖ "ករណីនេះ ប្រៀបបាននឹងគេដាល់ប្រព័ន្ធយុត្តិធម៌អាមេរិកបំភ្នែកឡើងជាំខ្មៅឲ្យពិភពលោកឃើញអញ្ចឹង ហើយវាធ្វើឲ្យកាន់តែរកាំចិត្តថែមទៀត ដោយសារថាគឺចៅក្រម និងមេធាវីជាអ្នកធ្វើរឿងនេះឲ្យទៅជាពាក្យបណ្តឹងល្បីសុះសាយ"។*

*លោក Rothstein និយាយថាសាលក្រមដែលតុលាការប្រកាសកាលពីថ្ងៃច័ន្ទកន្លងទៅនេះ "ធ្វើឲ្យមានជំនឿទុកចិត្តឡើងវិញក្នុងប្រព័ន្ធច្បាប់"។*

*ទន្ទឹមនឹងនោះ មានការអំពាវនាវមកពីជុំវិញពិភពលោកទាមទារឲ្យគេដកលោក Pearson ចេញពីតំណែងជាចៅក្រម ហើយដកចេញពីវិជ្ជាជីវៈមេធាវីតែម្តង។*

ជាលទ្ធផលចុងក្រោយ លោក Pearson បាត់បង់អាជីពរបស់គាត់មែន។ ពេលដែលទូរទស្សន៍

ABC ដឹងថា គាត់អាចនឹងបាត់បង់អាជីពមែន គេធ្វើសេចក្តីរាយការណ៍យ៉ាងវាងវៃដូច្នេះថា៖

*មុនដំបូងគាត់បាត់ខោរបស់គាត់។ បន្ទាប់មក គាត់ប្តឹងទៅតុលាការ ហើយបាត់អាវរបស់គាត់ទៀត។*

*ឥឡូវនេះ ទំនងជាថាជនដើមបណ្តឹងក្នុងពាក្យបណ្តឹងអាស្រូវមួយ ទារលុយ ៥៤ លានដុល្លារ ដើម្បីសងថ្លៃខោមួយ អាចនឹងបាត់បង់នូវអាវរ៉ូបពណ៌ខ្មៅ ដែលគេធ្លាប់ពាក់ធ្វើជាចៅក្រមដែរហើយ។*

*[First he lost his pants. Then he sued in court and lost his shirt.*

*Now it appears the plaintiff in the infamous $54 million pants lawsuit may be about to lose his black robe.]*

ពេលខ្លះរដ្ឋាភិបាលប្រើប្រាស់តុលាការ ដើម្បីគោលបំណងសេចក្តីថ្លែងការណ៍នយោបាយធំណាមួយ។ ការធ្វើបៀបនេះ ច្រើនគេឲ្យឈ្មោះថាជា **សវនាការសម្តែងល្ខោន (show trials)**។ ឧទាហរណ៍ដូចជាសវនាការប្រឆាំងអំពើពុករលួយ នៅប្រទេសចិន និងវៀតណាម។

**រំលេចមុខមនុស្សក្នុងសាច់រឿង ៖** ជារឿយៗ គេតែងប្រទះឃើញមានភាពខុសគ្នាតិចតួចស្តួចស្តើង មែនទែនរវាងពលរដ្ឋគោរពច្បាប់ និងពលរដ្ឋបំពានច្បាប់។ តើអ្វីដែលធ្វើឲ្យមនុស្សម្នាក់លួចលុយ កុហក ឬបោកប្រាស់អ្នកដទៃ? (ឃាតកដែលស្លៀកពាក់ជា Santa Clause បង់ជាក់ទណ្ឌកម្មអតីតភរិយាគាត់ និងគ្រួសាររបស់នាង ដោយសារតែការលែងលះ។ ហើយចៅក្រមដែលបាត់ខោរបស់គាត់ទំនងជាតានតឹងអារម្មណ៍ ដោយសារតែការលែងលះជាមួយប្រពន្ធផងដែរ។ ពិតណាស់ ហេតុផលទាំងអស់នេះមិនមែនជាលេសទេ តែវាជាផ្នែកមួយដែរ សម្រាប់ពន្យល់ហេតុការណ៍ដែលកើតឡើង)។

ព្រមពេលជាមួយគ្នានេះដែរ មនុស្សខ្លះដែលឡើងតុលាការជាអ្នកមានឈ្មោះបោះសំឡេង ដូច្នេះចរិយារបស់គេជាចំណាប់អារម្មណ៍ទ្វេសម្រាប់អ្នកអាន។ ទិដ្ឋភាពនៃនរណាម្នាក់ដែលពីមុនជាមនុស្សមានតំណែងខ្ពស់ក្នុងធនាគារ មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល (ជួនកាលជានាយករដ្ឋមន្ត្រី ឬប្រធានាធិបតី) ដៃជាប់ខ្នោះឡើងតុលាការ អាចធ្វើឲ្យយើងស្រឡាំងកាំង។ ក្នុងករណីបែបនេះ ធ្វើយ៉ាងណាឲ្យអ្នកអានបាន **"ឃើញ"** គ្រប់ទិដ្ឋភាពទាំងអស់។

ឧទាហរណ៍មួយនៃករណីបែបនេះ គឺអំពីបុរសម្នាក់ ដែលជីវិតរបស់គាត់ត្រូវបានគេយកទៅធ្វើភាពយន្ត។ គាត់ឈ្មោះ Victor Bout។ ខាងក្រោមនេះជាជារបៀបដែលកាសែត The Guardian រៀបរាប់អំពីការបង្ហាញមុខរបស់បុរសនេះនៅតុលាការក្រុងបាងកក៖

*បុរសដែលគេនិយមហៅថា ឈ្មួញមរណៈ (Merchant of Death) ដោយធ្វើជាមេខ្លោងក្នុងរបររកស៊ីលក់អាវុធដ៏ធំជាងគេលើពិភពលោកបាននិយាយជាសាធារណៈ កាលពីថ្ងៃច័ន្ទ ក្នុងបន្ទប់តុលាការថៃមួយជាលើកដំបូង តាំងតែពីពេលដែលគេចាប់ខ្លួនគាត់បាននៅខែមិនា ដើម្បីធ្វើបត្យាប័នទៅសហរដ្ឋអាមេរិកពីបទចោទប្រកាន់អំពីអំពើភេរវកម្ម។*

*លោក Victor Bout បានចំណាយពេលរកស៊ីរបស់គាត់ក្នុងរយៈពេល ១៦ ឆ្នាំកន្លងមកនេះ ដោយស្ថិតក្នុងភាពលាក់លៀម ប៉ុន្តែគាត់បានស្តែងខ្លួនជាមនុស្សល្បីល្បាញដូចក្នុងរឿងព្រេងនិទាន ដែលបានក្លាយជាកម្មវត្ថុសម្រាប់សៀវភៅ និងកុនហូលីវូតឈ្មោះ Lord of War កាលពីឆ្នាំ ២០០៥។ កាលពីម្សិលមិញ ស្ថិតក្នុងឯកសណ្ឋានពន្ធនាគារពណ៌ទឹកក្រូច ហើយឈរដោយមានខ្នោះដាប់ដៃជើងផងនោះ ជនជាតិរុស្ស៊ីអាយុ ៤១ ឆ្នាំម្នាក់នេះ បានច្រានចោលនូវកេរ្តិ៍ឈ្មោះមិនល្អថាជាការប្រឌិតរបស់អាមេរិក ហើយពិពណ៌នាខ្លួនគាត់ថាគ្រាន់តែជាធុរជនរកស៊ីក្នុងផ្នែកអាកាសយាន និងដំឡូញសំណង់។*

*លោក Bout ត្រូវបានគេឃុំខ្លួនក្នុងក្រុងបាងកក តាំងពីខែមិនា មកម្ល៉េះ ពេលដែលគាត់ត្រូវគេចាប់ខ្លួន ក្នុងបន្ទប់សណ្ឋាគារប្រណិតមួយក្នុងប្រតិបត្តិការសម្ងាត់របស់អាមេរិកមួយ ដែលក្នុងនោះ ភ្នាក់ងារសម្ងាត់របស់សហព័ន្ធនិយាយថា ពួកគេបានបង្កប់ខ្លួនជាសមាជិកកងកម្លាំងប្រដាប់អាវុធបដិវត្តន៍កូឡុំប៊ី (Revolutionary Forces of Colombia/ Farc) ស្វែងរកទិញសព្វាវុធទំនើប។ សហរដ្ឋអាមេរិកកំពុងព្យាយាមធ្វើបត្យាប័នជនជាតិរុស្ស៊ីម្នាក់នេះ នៅលើមូលដ្ឋានថា គាត់បានធ្វើការផ្គត់ផ្គង់សព្វាវុធទៅឲ្យពួកភេរវជន។*

*លោក Bout ដែលចេះប្រាំភាសាស្ទាត់ជំនាញ និយាយជាភាសារុស្ស៊ីក្នុងការបដិសេធចំពោះបទចោទប្រកាន់មកលើរូបគាត់ ហើយនិយាយថា គាត់មកទីក្រុងបាងកក ដើម្បីសម្រាកនឹងធ្វើការចរចាជាមួយ "ធុរជនថៃម្នាក់ដែលចង់ទិញយន្តហោះ"។ "ខ្ញុំមិនដែលជួបនរណាម្នាក់មកពីក្រុម Farc ទេ។ ខ្ញុំគ្មានធ្វើអ្វីខុសទេនៅក្នុងប្រទេសថៃ។ ខ្ញុំក៏មិនដែលទៅប្រទេសកូឡុំប៊ី ឬសហរដ្ឋអាមេរិកដែរ"។*

*គាត់ពន្យល់អំពីស្ថានភាពលំបាកបច្ចុប្បន្នរបស់គាត់ដោយនិយាយថា៖ "សហរដ្ឋអាមេរិកកំពុងតែព្យាយាមប្រើប្រាស់រឿងនេះ ដើម្បីបិទបាំងបញ្ហាផ្ទៃក្នុងរបស់ខ្លួន និងទប់ស្កាត់មិនឲ្យមានទំនាក់ទំនងល្អរវាងប្រទេសថៃ និងប្រទេសរុស្ស៊ី"។*

**ឧប្បទ្ទវហេតុ និងគ្រោះមហន្តរាយ ៖** គ្រោះឧប្បទ្ទវហេតុ គឺជាវត្ថុចាំបាច់ចិញ្ចឹមជីវិតសម្រាប់អង្គភាពព័ត៌មានភាគច្រើនលើពិភពលោក។ កាលណាឧប្បទ្ទវហេតុមានពាក់ព័ន្ធមនុស្សច្រើន ដូចជាគ្រោះថ្នាក់យន្តហោះ ឬរថភ្លើងជាដើម ឬក៏ការរលំអគារ វាក្លាយជាគ្រោះមហន្តរាយហើយ។ ជានិច្ចកាលជាអ្នកយកព័ត៌មាន អ្នកគួរប្រញាប់ប្រញាល់ទៅឲ្យដល់កន្លែងកើតហេតុ ដើម្បីសាកសួរនាំមនុស្ស ដែលជាសាក្សីហេតុការណ៍ ឬក៏បានរួចជីវិតពីគ្រោះថ្នាក់នោះ។ អ្នកក៏អាចសង្កេតមើលផ្ទាល់ភ្នែកផងដែរ នូវអ្វីដែលទើបនឹងកើតឡើង។ សម្លេង ក្លិន និងទិដ្ឋភាព ដែលអ្នកសង្កេតឃើញនឹងផ្តល់នូវការពិពណ៌នាមានប្រយោជន៍ដល់អ្នកអាន។



*ការលុកលុយរើកកាយទីកន្លែងមហន្តរាយមួយ អាចធ្វើឲ្យវាក្លាយជាកន្លែងស៊ើបអង្កេតបទឧក្រិដ្ឋទៅវិញ។*

តែកុំទៅលូកលាន់ជាមួយការងាររបស់បុគ្គលិកសង្គ្រោះឲ្យសោះ ហើយធ្វើយ៉ាងណារក្សាសុវត្ថិភាពរបស់ខ្លួន។

និពន្ធនាយកអាចចាត់តាំងអ្នកយកព័ត៌មានឲ្យទៅយកព័ត៌មានផ្នែកផ្សេងៗនៃគ្រោះធំៗ។ អ្នកណាម្នាក់អាចត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យ ដើម្បីឆែកមើលអំពីអ្នករបួស និងសម្ភាសន៍ជាមួយក្រុមវេជ្ជបណ្ឌិត និងបុគ្គលិកពេទ្យដទៃទៀត។ ម្នាក់ទៀតអាចត្រូវបានគេបញ្ជូនទៅឆែកមើលជាមួយប៉ូលីស និងមន្ត្រីសង្គ្រោះអគ្គីភ័យសុំឲ្យគេផ្តល់ព័ត៌មានជាផ្លូវការអំពីកិច្ចខិតខំសង្គ្រោះ និងស្តារពីគ្រោះមហន្តរាយនេះ។ អ្នកយកព័ត៌មាននៅកន្លែងកើតហេតុផ្ទាល់តែម្តង អាចរុករកមើលរឿងណាដែលសែនជក់ចិត្តពីក្នុងចំណោមសាក្សី ឬ "វីរជន" ក្នុងហេតុការណ៍នោះ។ អ្នកយកព័ត៌មាននៅក្នុងការិយាល័យ អាចជួយឆែកជាមួយក្រុមហ៊ុនជាម្ចាស់យន្តហោះ ឬរថយន្តដែលពាក់ព័ន្ធក្នុងគ្រោះថ្នាក់នោះ។ ក្នុងនោះ គេអាចស្រាវជ្រាវមើលប្រវត្តិកត់ត្រាសុវត្ថិភាពរបស់យានយន្តនោះដែរ ដូចជាពេលណាជាពេលចុងក្រោយ ដែលរថយន្តនោះបានទទួលការជួសជុល និងពិនិត្យពិច័យផ្នែកបច្ចេកទេស។ រីឯនាយកដ្ឋានក្រាហ្វិករបស់កាសែត អាចរៀបចំក្រាហ្វិកសម្រាប់ពន្យល់សាច់រឿងជាសោតទស្សន៍ថែមទៀត។

ក្នុងសាលផលិតដំណឹង គេអាចរៀបចំឲ្យមាននូវបញ្ជីបុគ្គលិកសង្គ្រោះបន្ទាន់ និងពួកអ្នកឯកទេសសម្រាប់ទាក់ទងក្នុងករណីមានគ្រោះមហន្តរាយ។ អ្នកឧតុនិយមអាចពិភាក្សាអំពីតួនាទីរបស់អាកាសធាតុក្នុងហេតុការណ៍នោះ។ អ្នកឯកទេសអាកាសយានអាចជួយផ្តល់បរិបទទាក់ទិននឹងគ្រោះមហន្តរាយយន្តហោះឯទៀតបានដែរ។ អ្នកវិទ្យាសាស្ត្រ និងអ្នកឯកទេសសុវត្ថិភាពអាកាសចរណ៍អាចជួយផ្តល់ការពន្យល់ថែមទៀត។ ពួកភូគព្ភសាស្ត្រអាចនិយាយអំពីហេតុផល ដែលអាចមាននៅពីក្រោយមហន្តរាយធម្មជាតិ ដូចជាការរញ្ជួយដី និងព្យុះស៊ូណាមិ ជាដើម។

**ដដែកជាមួយអ្នករួចជីវិតពីគ្រោះកាច :** ដដែកជាមួយអ្នករួចជីវិតពីគ្រោះថ្នាក់ គឺជាការលំបាកជាងគេមួយក្នុងចំណោមការលំបាកជាច្រើនទៀតក្នុងការយកព័ត៌មានអំពីគ្រោះមហន្តរាយ គ្រោះថ្នាក់ ឬឧក្រិដ្ឋកម្ម។ អ្នកខ្លះអាចមិនចង់និយាយអ្វីទាំងអស់ រីឯអ្នកឯទៀត អាចកំពុងនៅ**តក់ស្លុត**ពីហេតុការណ៍នោះនៅឡើយ។ អ្នកសារព័ត៌មានត្រូវតែប្រុងប្រយ័ត្នកុំធ្វើឲ្យអ្នករស់រានមានជីវិតមានអារម្មណ៍កាន់តែអាក្រក់ជាងអ្វី ដែលគេទើបនឹងបានឆ្លងកាត់នោះ។ ប៉ុន្តែក៏នៅមានអ្នករស់រានមានជីវិតច្រើននាក់ដែរ ដែលមានចេតនាចង់និយាយអំពីហេតុការណ៍ទើបនឹងកើតឡើង ហើយក្រុមគ្រួសារជារឿយៗក៏ចង់និយាយអំពីសមាជិកគ្រួសារជាទីស្រឡាញ់ដែលបាត់បង់ជីវិតទៅហើយដែរ។

តទៅនេះជាមគ្គុទេសក៍ទូទៅមួយចំនួនថា តើគួរធ្វើដូចម្តេចខ្លះ។ ចូលទៅកាន់អ្នករស់រានមានជីវិតដោយប្រយ័ត្នប្រយែង។ ផ្តើមសាកសួរជាមួយនឹងពាក្យពេចន៍រំលែកទុក្ខសោក ដូចជា "ខ្ញុំសូមចូលរួមសោកស្តាយផងចំពោះអ្វីដែលបានកើតឡើង"។ បើគេមិនចង់និយាយទេ កុំទៅរំខានគេទៀត ប៉ុន្តែដោយភាពគួរសម អ្នកគួរទុកឈ្មោះ និងលេខទូរស័ព្ទរបស់អ្នកដល់ជនរងគ្រោះទាំងនោះ ក្នុងករណីគេដូរចិត្តចង់ទាក់ទងអ្នកវិញ។ ពន្យល់ទៅអ្នកទាំងនោះថាតើអ្នកនឹងប្រើប្រាស់ព័ត៌មានដែលគេផ្តល់ឲ្យអ្នករបៀបម៉េច ហើយប្រាប់ទៅគេថា ការរ៉ាយរ៉ាប់របស់ពួកគេអាចជួយអ្នកឯទៀតឲ្យយល់បានឮនូវអ្វីដែលបានកើតឡើងនេះ។ ចូរស្តាប់ជាមួយនឹងក្តីអាណិតអាសូរ និងការគោរពគួរសមចំពោះអ្នកទាំងនោះ។

មជ្ឈមណ្ឌល Dart Center for Journalism and Trauma លើកទឹកចិត្តឲ្យអ្នកយកព័ត៌មាន

យកចិត្តទុកដាក់ចំពោះខ្លួនឯងផងដែរ។ ការយកព័ត៌មានគ្រោះមហន្តរាយ និងសោកនាដកម្ម ជាកិច្ចការតានតឹងអារម្មណ៍សម្រាប់អ្នកយកព័ត៌មានដែរ។ មានអ្នកសារព័ត៌មានខ្លះ ដែលយកព័ត៌មានស៊ូណាមិ ឆ្នាំ ២០០៤ យំ ពីព្រោះពួកគេរងការសន្ទប់ផ្លូវចិត្តខ្លាំងពេក ដោយសារទិដ្ឋភាពមនុស្សស្លាប់ និងទុក្ខសោកក្នុងហេតុការណ៍នេះ និងដោយសារពួកគេប្រឹងធ្វើការសឹងតែមិនបានគេងផង។ មជ្ឈមណ្ឌល Dart Center ដែលមានស្នាក់ការនៅសហរដ្ឋអាមេរិក និងអូស្ត្រាលី ផ្តល់អនុសាសន៍ឲ្យអ្នកសារព័ត៌មានយកពេលហាត់ប្រាណខ្លះ ឬសម្រាកមួយថ្ងៃ ឬពីរថ្ងៃ ក្រោយពីធ្វើការក្នុងសភាពបែបនេះ។ បើសិនជាភាពតានតឹងអារម្មណ៍នៅតែមានច្រើនសប្តាហ៍ក្រោយមកទៀត អ្នកសារព័ត៌មានគួរតែស្វែងរកជំនួយពីអ្នកជំនាញផ្នែកនេះ។

**ការពារជនរងគ្រោះអំពើឧក្រិដ្ឋកម្ម :** ជនរងគ្រោះក៏មានសិទ្ធិរបស់គេដែរ។ អ្នកសារព័ត៌មានគួរពិចារណាឲ្យបានដិតដល់ថាពុំគួរចុះផ្សាយឈ្មោះពេញ ឬរូបថតរបស់ជនទាំងឡាយដែលបានឆ្លងកាត់ និងរួចផុតជីវិតពីអំពើឧក្រិដ្ឋកម្មនោះទេ។ ធ្វើដូច្នេះមិនគ្រាន់តែជាការបំពានលើជីវិតឯកជនរបស់អ្នកទាំងនោះ និងនាំមកនូវភាពអាម៉ាស់ដល់គេប៉ុណ្ណោះទេ តែវាអាចធ្វើឲ្យជនសង្ស័យបទឧក្រិដ្ឋស្គាល់ជនរងគ្រោះ ហើយធ្វើការសងសឹកទៅលើគេទៀតផង។

អ្នកសារព័ត៌មានចំណាន១នឹងមិនប្រើឈ្មោះជនរងគ្រោះទេ លុះត្រាតែជនរងគ្រោះមានចេតនានិយាយជាសាធារណៈ ហើយយល់ច្បាស់អំពីផលពាក់ព័ន្ធក្នុងការយកសេចក្តីក្បោះក្បាយអំពីឧក្រិដ្ឋកម្មនោះទៅចុះផ្សាយ។ ចូរគោរពចំពោះភាពជាឯកជនរបស់អ្នកដទៃ។ ដាក់រហ័សនាមឲ្យគេក៏បាន ឬបើមិនដូច្នោះទេ បង្ហាញអត្តសញ្ញាណគេតាមរយៈឈ្មោះ និងភេទបានហើយ តែកុំប្រើឈ្មោះពិត។

ការប្រើឈ្មោះ និងរូបថតរបស់ក្មេងពាក់ព័ន្ធក្នុងឧក្រិដ្ឋកម្ម គួរអាចធ្វើទៅបានតែលុះត្រាតែការបង្ហាញអត្តសញ្ញាណពួកគេជួយសាធារណជនឲ្យយល់អំពីស្ថានការណ៍មានសារៈសំខាន់មួយ ហើយមិននាំគ្រោះថ្នាក់ដល់ក្មេងទាំងនោះ ឬបង្កភាពអាម៉ាស់ដល់ពួកគេទេ។

## អនុសាសន៍ចុងក្រោយមួយចំនួន

**ចូរកុំប្រើពាក្យឯកទេសតុលាការ និងប៉ូលីស ក្នុងសាច់រឿងឲ្យសោះ។** ពិតណាស់ ស័ព្ទបច្ចេកទេសខ្លះមានភាពចាំបាច់ត្រូវតែប្រើ តែកន្លែងណាដែលអាចធ្វើទៅបានប្រើពាក្យសាមញ្ញទៅល្អជាង។ ឧទាហរណ៍ កាលណាតុលាការនិយាយថាឧក្រិដ្ឋជនម្នាក់ត្រូវបាន "កាត់ទោសកំណត់ឲ្យជាប់ពន្ធនាគារ" នោះ វាមានន័យស្មើនឹង "កាត់ឲ្យជាប់គុក" (“sentenced to a term of imprisonment” is really “sent to jail”)។ ហើយបើប៉ូលីសនិយាយថា "បុរសដែលអាយុប្រហាក់ប្រហែល ៣០ ឆ្នាំ" ចូរសរសេរថា "បុរសអាយុជិត ៣០ ឆ្នាំ" ទៅបានហើយ (“a male of approximate age 30 years,” say “a man aged about 30”)។

**ចូរប៉ិនប្រសប់ក្នុងការធ្វើកំណត់ហេតុ។** វាជាប្រការសំខាន់មែនទែនថា អ្វីដែលអ្នករាយការណ៍ពីតុលាការ គឺមានភាពត្រឹមត្រូវដាក់លាក់ដាច់ខាត។

**ចូរបញ្ជាក់ឲ្យគេដឹងថា ករណីក្តីមួយវិវត្តន៍ដល់ណាហើយ។** ធ្វើយ៉ាងណាបង្ហាញឲ្យគេដឹងបានច្បាស់ថា រឿងបទឧក្រិដ្ឋ និងតុលាការរបស់អ្នក វាស្ថិតក្នុងដំណាក់កាលណា ការស៊ើបអង្កេតដើរដល់ដំណាក់កាលណា ឬតើសវនាការវិវត្តន៍ដល់ដំណាក់កាលណា ហើយតើពេលណាវាអាចនឹងត្រូវបានបញ្ចប់។

# ជំពូក ១១ អ្នកសារព័ត៌មាន និងច្បាប់

អាស្រ័យទៅតាមកន្លែងដែលពួកគេកំពុងស្ថិតនៅអ្នកសារព័ត៌មានប្រតិបត្តិការងារជាមួយសិទ្ធិ ការទទួលខុសត្រូវ ការរឹតត្បិតក្នុងកម្រិតផ្សេងៗគ្នា។ អ្នកខ្លះប្រតិបត្តិជាមួយនឹងសេរីភាព ដែលមានការការពារពិតប្រាកដពីសំណាក់រដ្ឋធម្មនុញ្ញ។ អ្នកខ្លះធ្វើការក្នុងបរិយាកាសដែលសេរីភាពមានភាពស្រពិចស្រពិល និងមានកំហិត។ អ្នកខ្លះទៀតប្រតិបត្តិការងារដោយស្វ័យត្រួតពិនិត្យអត្ថបទរបស់ខ្លួន ខ្លាចមានបញ្ហាជាមួយរដ្ឋាភិបាល និងក្រោមការត្រួតត្រារបស់អាជ្ញាធរលើខ្លឹមសារ មុននឹងគេអនុញ្ញាតឲ្យយកវាទៅបោះពុម្ពផ្សាយ។ ក្នុងសៀវភៅនេះ យើងពិតជាមិនអាចផ្ដល់អនុសាសន៍ឲ្យបានគ្រប់ជ្រុងជ្រោយថា តើគួរធ្វើយ៉ាងណាខ្លះ ដើម្បីបង្កើនឲ្យដល់អតិបរមានូវសេវាយើងចំពោះអ្នកអាន និងថាតើត្រូវធ្វើដូចម្ដេចខ្លះ ដើម្បីជំនះបាននូវបរិស្ថានសន្តិសុខ និងនយោបាយខុសៗគ្នាច្រើនបែបនេះ។ ប៉ុន្តែអ្វីដែលយើងអាចធ្វើបាន គឺក្រើនរំលឹកដល់អ្នកសារព័ត៌មានអំពីគោលការណ៍ច្បាប់ជាទូទៅ និងភាពលំបាកនានាដែលពួកគេពើបប្រទះក្នុងការងារ មិនថាពួកគេនៅទីណាទេ។ គោលការណ៍សំខាន់ៗបំផុតមាន៖

១. **អ្នកជាពលរដ្ឋស្ថិតក្រោមច្បាប់ក្នុងប្រទេសដែលអ្នកកំពុងប្រតិបត្តិការ**។ ក្នុងប្រទេសខ្លះ អ្នកសារព័ត៌មានមានឯកសិទ្ធិ តិចតួចតែក្នុងករណីភាគច្រើន យើងទាំងអស់គ្នាស្ថិតនៅពីក្រោមច្បាប់ដូចអ្នកឯទៀតដែរ។ ដូច្នេះ យើងមិនត្រូវធ្វើខ្វាក់ត្រង់ចំណុចនេះទេ ដោយសំអាងថាយើង "កំពុងដេញតាមរឿង" យកមកសរសេរ ហើយគិតថាធ្វើដូច្នេះ មានន័យថា គេមិនអាចយកយើងឡើងតុលាការកាត់ក្ដីពីបទឧក្រិដ្ឋណាមួយនោះបានទេ។ ការបំពាននានាដែលអាចនាំឲ្យយើងប្រឈមមុខជាមួយផ្លូវច្បាប់ មានដូចជាការរំលោភច្បាប់ចរាចរ ក្លែងបន្លំឯកសារ លាក់បាំងអត្តសញ្ញាណរបស់ខ្លួន ការឆ្លងចូលទីតាំងអចលនទ្រព្យរបស់អ្នកដទៃ ឬការចូលទីសាធារណៈដែលមានបំរាម។ ម្យ៉ាងទៀត អ្នកក៏អាចត្រូវបានគេហៅឡើងតុលាការធ្វើជាសាក្សីក្នុងសវនាការមួយដែរ ប្រសិនបើអ្នកបានដឹង ឬឃើញអ្វីមួយដែលតុលាការជឿថាជាភស្តុតាង។ ពេលណាអ្នកកំពុងត្រិះរិះរកវិធីល្អបំផុតសម្រាប់ដេញតាមរឿងមួយយកមកសរសេរ អ្នកអាចសួរខ្លួនឯងដូច្នេះវិញថា តើពលរដ្ឋគោរពច្បាប់នឹងធ្វើដូចម្ដេចទៅវិញក្នុងករណីដូចគ្នានេះដែរ? ក្នុងករណីដ៏កម្រខ្លះ សម្បជញ្ញៈអាជីពរបស់អ្នក អាចជំរុញចិត្តអ្នកឲ្យបំពានច្បាប់ តែចូរអ្នកកុំសន្មតឲ្យសោះថាអាជ្ញាធរ (ឬចៅហ្វាយរបស់អ្នកតែម្ដង) នឹងមានសមានចិត្តអាណិតអ្នក បើកាលណាអ្នកត្រូវបានគេចាប់ខ្លួនដោយសារបំពានច្បាប់នោះ។

២. **បទបរិហារកេរ្តិ៍រដ្ឋប្បវេណី បទនិយាយមួលបង្កាច់ បទបង្ខូចកេរ្តិ៍ (Civil defamation, slander and libel)**។ ច្បាប់ និងការអនុវត្តទាក់ទិនទៅនឹងចំណុចទាំងនេះ មានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត។ តែនិយាយឲ្យខ្លីមកអ្វីដែលជា

បេះដូងនៃចំណុចខាងលើនេះ គឺអ្នកណាក៏ដោយ ក៏មាន "កេរ្តិ៍ឈ្មោះ" ដែរ។ កេរ្តិ៍ឈ្មោះ គឺសំដៅលើអ្វី ដែលសាធារណជនយល់ឃើញអំពីបុរសម្នាក់ ឬនារីម្នាក់ ក្រៅពីខ្លួនគេ។ ដូចយើងទាំងអស់គ្នាដឹងហើយថា អ្វីដែលអ្នកដទៃនិយាយអំពីយើង ពិតក្ដី ឬមិនពិតក្ដី អាចមានឥទ្ធិពលទៅលើកេរ្តិ៍ឈ្មោះនេះ។ កាលណាគេនិយាយអាក្រក់អំពីយើង វាអាចបង្កការខូចខាតដល់កេរ្តិ៍ឈ្មោះរបស់យើង។ ខាងក្រោមនេះជានិយមន័យផ្លូវការមួយ៖ "ជាទង្វើសារគមនាគមន៍មួយដែលបណ្ដាលឲ្យមនុស្សម្នាក់ទៀតអាម៉ាស់ រងការបំអក រងការមាក់ងាយបន្ថោកបន្ទាបពីសំណាក់សហគមន៍ ឬក៏ធ្វើឲ្យគេបាត់បង់ឋានៈ មុខរបរ ចំណូល ហើយជាមួយគ្នានោះដែរខូចខាតកេរ្តិ៍ឈ្មោះ"។ បើធ្វើបែបនេះត្រូវបានធ្វើឡើងតាមការពោលចេញពីមាត់ គេហៅវាថាជាការ **និយាយមួលបង្កាច់**។ បើវាជាការបោះពុម្ពផ្សាយ គេហៅវាថាជា **ការបង្ខូចកេរ្តិ៍**។ កាលណាតុលាការរកឃើញថាអ្នកមានកំហុស អ្នកអាចត្រូវបានគេបង្គាប់ឲ្យបង់ប្រាក់សងការខូចខាតជូនជនដែលអ្នកបានធ្វើឲ្យខូចកេរ្តិ៍ឈ្មោះ ហើយបោះពុម្ពផ្សាយការកែតម្រូវ និងការសូមទោសទៀតផង។ បំនួនទឹកប្រាក់ត្រូវបានកំណត់ដោយទំហំនៃការខូចខាតចំពោះកេរ្តិ៍ឈ្មោះរបស់បុគ្គល និងឋានៈរបស់គេក្នុងសង្គម ឬក៏លទ្ធភាពរកចំណូលរបស់គេ។ ពិតណាស់ វាពិបាកនឹងធ្វើការប៉ាន់ប្រមាណបែបនេះណាស់ តែតុលាការតែងព្យាយាមកំណត់ក្នុងសាលក្រមនូវចំនួនទឹកប្រាក់ដែលអ្នកចាញ់ក្ដីត្រូវសងដល់អ្នកឈ្នះក្ដីក្នុងបទបរិហារកេរ្តិ៍។

**បំណុចមួយចំនួនទៀតដែលគួរចងចាំ៖**

- បើវាជាពាក្យពេចន៍បរិហារកេរ្តិ៍ចេញពីមាត់របស់អ្នកណាម្នាក់ ហើយអ្នកដែលជាអ្នកសារព័ត៌មានយកទៅថាតាមក្នុងការផ្សាយតាមរលកធាតុអាកាសក្ដី ឬចុះផ្សាយក្នុងទំព័រកាសែតក្ដី អ្នកនឹងមានការទទួលខុសត្រូវស្មើគ្នាដែរ។ អ្នកនឹងមានពិរុទ្ធពីបទយកមកថាតាម និងសាយភាយពាក្យបរិហារកេរ្តិ៍ឲ្យកាន់តែទូលំទូលាយថែមទៀត។
- បើអ្នកត្រូវបាននរណាម្នាក់ទៀតប្ដឹងឡើងតុលាការពីបទបរិហារកេរ្តិ៍ ជននោះមិនមានភាពចាំបាច់បញ្ជាក់តឹកតាងថា អ្វីដែលអ្នកនិយាយនោះខុសពីការពិតទេ។ ពួកគេក៏មិនត្រូវធ្វើការបញ្ជាក់តឹកតាងដែរទេថា អ្នកមានចេតនាបង្កការខូចខាតដល់កេរ្តិ៍ឈ្មោះអ្នកដទៃ។ បន្ទុកតឹកតាង វានៅលើស្រេចតែរូបអ្នក ហើយនៅក្នុងតុលាការ ការបញ្ជាក់តឹកតាងមានស្តង់ដារខ្ពស់ណាស់។
- បើទោះជាអ្នកអាចបញ្ជាក់អះអាងថាអ្វីមួយជាការពិតក៏ដោយ វាមិនមែនមានន័យថាអ្នកមានសេរីភាពយកវាទៅចុះផ្សាយបានស្រេចនឹងចិត្តទេ។ អ្នកក៏នៅតែអាចមានពិរុទ្ធពីបទបរិហារកេរ្តិ៍ ដែរ។ អ្នកត្រូវតែបញ្ចុះបញ្ចូលតុលាការឲ្យជឿដូចអ្នកថា វាជាប្រយោជន៍សាធារណៈក្នុងការធ្វើឲ្យការពិតនេះដឹងឮជាទូទៅ ឬក្នុងការអនុញ្ញាតឲ្យមានការធ្វើអធិប្បាយ ដែលជាអត្ថាធិប្បាយត្រឹមត្រូវ។ ជាក់ស្ដែងវាពិបាកនឹងធ្វើបានដូច្នេះណាស់។ (នៅប្រទេសមួយចំនួនអ្នកអាចមានសំណាងរួចខ្លួនពីការរករឿងខាងផ្លូវច្បាប់ ពីព្រោះអ្នកមានហេតុល្អក្នុងការជឿថាអ្វីមួយនោះជាការពិត បើទោះជា

ថាវាមិនពិតក្តី ហើយអ្នកយកវាមកចុះផ្សាយក៏ដោយ អ្នកជឿជាក់ថាធ្វើដូច្នោះ គឺដើម្បីប្រយោជន៍សាធារណៈ។ តែសំណាងបែបនេះមិនមែនកើតមានតែរហូតទេ ទោះជានៅក្នុងប្រទេសដែលប្រព័ន្ធច្បាប់មានលក្ខណៈសេរីក៏ដោយ)។ បើទោះជារឿងដែលអ្នកសរសេរជាការរ៉ាយរ៉ាប់អំពីព្រឹត្តិការណ៍ ឬកិច្ចប្រជុំមួយក្តី អ្នកត្រូវតែធ្វើយ៉ាងណាសរសេរឲ្យត្រឹមត្រូវមិនលំអៀង និងឲ្យត្រឹមត្រូវជាក់លាក់តាមអ្វីដែលបានកើតឡើងមែននោះដែរ។

- តុលាការមានសមានចិត្តតិចតួចណាស់ចំពោះអ្នកសារព័ត៌មានណា ដែលមិនប្រឹងប្រែងឲ្យអស់សមត្ថភាពក្នុងការផ្តល់ដល់ជនដែលជាកម្មបទក្នុងរឿងនូវឱកាសឆ្លើយតបទៅនឹងការចោទប្រកាន់ទៅលើរូបគេ។ ដូច្នេះ បើអ្នកសរសេររឿងមួយដែលនិយាយថាជនណាម្នាក់ភូតកុហកអំពីអ្វីមួយអ្នកត្រូវធ្វើយ៉ាងណាឲ្យជននោះ តាមរយៈរឿងរបស់អ្នកមានឱកាសបដិសេធការចោទប្រកាន់នោះ និងរៀបរាប់អំពីដំណើររឿងរ៉ាវពីខាងគេវិញផង។ ធ្វើដូច្នេះមានសារៈសំខាន់ណាស់ចំពោះថា តើតុលាការនឹងប្រកាន់យកការសម្រេចចិត្តបែបណាក្នុងការលែលកជាមួយអ្នក។ បើទោះជាថាគេរកឃើញថាអ្នកមានពិរុទ្ធបទបរិហារកេរ្តិ៍ក្តី គេអាចបង្គាប់ឲ្យអ្នកបង់ការសងជំងឺចិត្តតិចតួចតែប៉ុណ្ណោះ។
- យើងនៅតែអាចបរិហារកេរ្តិ៍នរណាម្នាក់ដែរ បើទោះជាយើងមិន និយាយចំឈ្មោះក៏ដោយ។ តុលាការអាចសម្រេចថាជនម្នាក់អាចត្រូវបានគេស្គាល់អត្តសញ្ញាណបានយ៉ាងងាយតាមរយៈព័ត៌មានក្នុងរឿងរបស់អ្នក ឬតាមរយៈរឿងដទៃទៀតលើប្រធានបទដូចគ្នានេះ។ ម្យ៉ាងវិញទៀត អ្នកអាចធ្វើឲ្យមនុស្សច្រើននាក់ខូចកេរ្តិ៍ឈ្មោះក្នុងពេលតែមួយផងដែរ ឧទាហរណ៍ គណៈនាយករបស់ក្រុមហ៊ុនមួយ ឬសមាជិកក្រុមប្រឹក្សាដែលធ្វើសកម្មភាពរួមគ្នាលើរឿងជាច្រើន។ បើអ្នកសរសេរចោទក្រុមហ៊ុន ឬក្រុមប្រឹក្សាថាបានធ្វើអ្វីមួយអាក្រក់ គណៈនាយក ឬសមាជិកក្រុមប្រឹក្សាអាចដាក់**បណ្តឹងតាងនាមក្រុម (class action)** ប្រឆាំងនឹងអ្នក ហើយអ្នកត្រូវសងការខូចខាតដល់ពួកគេគ្រប់ៗគ្នា។
- ក្នុងប្រទេសភាគច្រើនមានប្រព័ន្ធមួយនៃអ្វីដែលគេហៅថា **ឯកសិទ្ធិ** ដែលមានន័យថាអ្វីក៏ដោយដែលត្រូវបានគេនិយាយពិត ឬមិនពិតក្តី អាចយកទៅចុះផ្សាយបាន។ តាមធម្មតា គេប្រើឯកសិទ្ធិបែបនេះក្នុងការពិភាក្សាវែកញែកក្នុងសភា និងវែកញែករកភស្តុតាងក្នុងតុលាការ។ ឯកសិទ្ធិនេះសំដៅជានាថា មានការអនុវត្តសេរីភាពក្នុងការនិយាយស្តី និងប្រព័ន្ធយុត្តិធម៌ ហើយក៏ធានាផងដែរថា មានការបង្កលក្ខណៈល្អដល់ការអនុវត្តសេរីភាពបែបនោះមែន។ ដូច្នេះ អ្នកត្រូវតែស្វែងយល់ថាអ្វីខ្លះជាឯកសិទ្ធិក្នុងប្រទេសរបស់អ្នក ហើយថាតើឯកសិទ្ធិនោះមានកំហិតបែបណាខ្លះ។

ចូរអ្នកកុំស្មានឲ្យសោះថាអ្នកអាចរួចផុតពីបណ្តឹងបទបង្ខូចកេរ្តិ៍ ពីព្រោះអ្វីដែលអ្នកបានសរសេរមានតែនៅលើអ៊ីនធឺណិត មិនមែនចុះផ្សាយក្នុងទំព័រកាសែតនោះ។ ក្នុងន័យនេះ អ្នកអាចប្រឈមនឹង

ហានិភ័យច្រើនជាងមុន ដោយសារថាអ៊ីនធឺណិតជាការចុះផ្សាយជាសាកល។ ដូច្នេះ អ្វីដែលអ្នកបានសរសេរអំពីមនុស្សណាម្នាក់ទៀត អាចត្រូវបានមនុស្សនៅគ្រប់ប្រកល្ងកលើពិភពលោកអានបានដែរ ហើយការខូចខាតចំពោះកេរ្តិ៍ឈ្មោះរបស់គេក៏អាចមានសភាពធំធេងជាងការដែលអត្ថបទរបស់អ្នកត្រូវបានចុះផ្សាយក្នុងទំព័រកាសែត ដែលមានចំនួនផ្សាយមានកំណត់ទៅទៀត។ ម៉្យាងវិញទៀត អ្នកក៏អាចត្រូវបានគេប្ដឹងពីបទបរិហារកេរ្តិ៍ក្នុងប្រទេសដទៃទៀតដែរ បើសិនជាភាគីដើមបណ្ដឹងជឿថាអ្វីដែលអ្នកបានផ្សាយតាមរលកធាតុអាកាស ឬសរសេរកន្លងមក ត្រូវបានផ្សព្វផ្សាយទូលំទូលាយ (រួមទាំងនៅលើអ៊ីនធឺណិតផង) មិនគ្រាន់តែនៅក្នុងប្រទេសដែលជាស្នាក់ការរបស់ការផ្សាយរបស់អ្នកប៉ុណ្ណោះទេ។

ជាក់ស្ដែងគ្មានកិច្ចការអ្វីដែលមិនចេះឆ្លោយសោះនោះទេ ដូច្នេះវិធីប្រសើរបំផុតដើម្បីចៀសវាងការប្ដឹងពីបទបរិហារកេរ្តិ៍ គឺមានតែការដើរតាមគន្លងស្តង់ដារអាជីពខ្ពស់បំផុតក្នុងការធ្វើសេចក្ដីរាយការណ៍ព័ត៌មាន ដែលត្រូវតែយកទៅអនុវត្តន៍ក្នុងគ្រប់កាលៈទេសៈអមដោយសំណួរថា៖

- តើរឿងរបស់ខ្ញុំស្ថិតក្នុងប្រយោជន៍សាធារណៈទេ?
- តើខ្ញុំពេញចិត្តហើយឬនៅថា ព័ត៌មានមួយហ្នឹងជាការពិតនោះ?
- តើខ្ញុំបានសរសេររៀបរាប់ហេតុការណ៍មួយហ្នងបានត្រឹមត្រូវជាក់លាក់ និងមិនលំអៀងទេ?
- តើខ្ញុំមានបានផ្ដល់បុគ្គលមួយនោះនូវឱកាសសម្រាប់គេរៀបរាប់ហេតុការណ៍ពីខាងគេវិញទេ?

៣. **បទបរិហារកេរ្តិ៍ព្រហ្មទណ្ឌ (Criminal defamation)**។ ភាគច្រើននៃសង្គមសេរីមិនប្រើប្រាស់រដ្ឋធ្វើសកម្មភាពណាប្រឆាំងពលរដ្ឋដែលបានបរិហារកេរ្តិ៍អ្នកដទៃឡើយ បើទោះជាគេមានឧបករណ៍ច្បាប់នឹងធ្វើបែបនោះក្តី ពីព្រោះគេឲ្យតម្លៃសេរីភាពក្នុងការនិយាយស្តីណាស់។ គេទុករឿងបែបនេះឲ្យតុលាការរដ្ឋប្បវេណីជាអ្នកលៃលកវិញនូវពាក្យបណ្តឹងរបស់ជនដែលត្រូវបានគេបរិហារកេរ្តិ៍។ តែបទបរិហារកេរ្តិ៍ព្រហ្មទណ្ឌ - ដែលក្នុងនោះដើមចោទអាចសុំឲ្យរដ្ឋធ្វើការចោទប្រកាន់ជនណាម្នាក់ ឬអ្នកសារព័ត៌មានណាម្នាក់ពីការប្រព្រឹត្តបទឧក្រិដ្ឋបែបនេះ - នៅតែមានរដ្ឋាភិបាល និងអ្នកនយោបាយប្រទេសជាច្រើនកំពុងប្រើប្រាស់នៅឡើយ ដើម្បីបំបិទមាត់ការរិះគន់ទៅលើពួកគេ។ អ្នកដែលត្រូវបានគេរកឃើញថាមានពិរុទ្ធពីបទបរិហារកេរ្តិ៍ព្រហ្មទណ្ឌ ត្រូវបានគេដាក់ពន្ធនាគារ និងបង្គាប់ឲ្យបង់សំណងជំងឺចិត្តផងដែរ។ ភាគច្រើននៃអ្វីដែលយើងនិយាយខាងលើអំពីបទបរិហារកេរ្តិ៍ បទនិយាយមួលបង្កាច់ បទបង្ខូចកេរ្តិ៍ ស្ថិតនៅក្រោមបរិហារកេរ្តិ៍ព្រហ្មទណ្ឌ ប៉ុន្តែភាពខុសគ្នាធំបំផុតនៅត្រង់ថា ជាញឹកញាប់វា ត្រូវបានគេប្រើជាការគំរាមសម្លុតមុនការបោះពុម្ពផ្សាយ ឬដើម្បីបញ្ឈប់នូវការបោះពុម្ពផ្សាយសេចក្តីក្បោះក្បាយអំពីអ្វីមួយ ឬអំពីនរណាម្នាក់។

៤. **បទប្រមាថព្រះចេស្តាក្សត្រ (lese-majeste)**។ ប្រទេសភាគច្រើនដែលមានស្តេចសោយរាជ្យ មានច្បាប់ដែលត្រូវបានតាក់តែងឡើងសម្រាប់ការពារកិត្តិយសរបស់មហាក្សត្រ។ មានអត្ថន័យថា "ការខូចខាតដល់មហិទ្ធានុភាព ឬកិត្តិយស

មហាក្សត្រ" ច្បាប់ទាំងនេះមានអាយុកាលតាំងពីសម័យកាលរ៉ូម៉ង់ ដែលកាលជំនាន់នោះ តាមជាតុពិតដើមរបស់វា គេធ្វើវាឡើងដើម្បីការពារសាធារណៈរដ្ឋ រ៉ូម៉ង់ទៅវិញឯណោះទេ។ ក៏ប៉ុន្តែនាមជ្ឈិមសម័យ (សតវត្សទី ៥-១៥) រដ្ឋ និងរាជបល័ង្កនៅមិនទាន់បែកដាច់ចេញពីគ្នានៅឡើយទេ ហើយចាប់តាំងពីពេលនោះមក គេក៏បានប្រើប្រាស់ច្បាប់នេះសម្រាប់ការពារស្តេចឲ្យផុតពីការរិះគន់នានា។ ក្នុងសម័យបច្ចុប្បន្ន ប្រទេសជាច្រើនដែលកាន់របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ លែងយកច្បាប់នេះជាបានការទៀតហើយ។ នៅប្រទេសថៃ ជំនួសឲ្យច្បាប់បែបនេះ គឺមាត្រាទី ១២ នៃក្រមព្រហ្មទណ្ឌ ដែលចែងថា "ជនណាក៏ដោយដែលបរិហារកេរ្តិ៍ប្រមាថ ឬគំរាមព្រះមហាក្សត្រ ព្រះអគ្គមហេសី ព្រះរាជបុត្រស្នងរាជ្យព្រះរាជានុសិទ្ធិ នឹងត្រូវទទួលទណ្ឌកម្មដាក់ពន្ធនាគារក្នុងរយៈពេលពី ៣ ទៅ ១៥ ឆ្នាំ"។ នៅប្រទេសកម្ពុជា មាត្រាទី ៧ នៃរដ្ឋធម្មនុញ្ញចែងថា "អង្គព្រះមហាក្សត្រមិនអាចនរណារំលោភបំពានបានឡើយ"។ បន្ថែមពីលើនេះ មាត្រាទី ១៣ នៃច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ ១៩៩៥ ហាមអ្នកសារព័ត៌មានមិនឲ្យ "ចុះផ្សាយ ឬចុះផ្សាយឡើងវិញនូវព័ត៌មាន ដែលបន្ថុះបង្អាប់ ឬមាក់ងាយស្ថាប័នជាតិ"។ ស្ថាប័នជាតិនេះរួមមាន ស្ថាប័នព្រះមហាក្សត្រផងដែរ។ វាពិបាកណាស់សម្រាប់អ្នកសារព័ត៌នឹងដឹងបានថា ពេលណាច្បាប់នេះត្រូវបានយកមកប្រើចំពោះអ្នកសារព័ត៌មាន។ នៅប្រទេសថៃមានការពិភាក្សាច្រើនអំពីច្បាប់



*ការគោរពនឹងផ្លូវច្បាប់ ជាភាពប្រឈមធំមួយសម្រាប់អ្នកសារព័ត៌មាន។*

នេះ ហើយព្រមពេលជាមួយគ្នានេះដែរ គ្មានរណាហ៊ានប្រថុយប្រថានជាមួយច្បាប់នេះទេ។ រីឯអ្នកសារព័ត៌មានវិញ ពួកគេធ្វើយ៉ាងណាចៀសឲ្យឆ្ងាយស្រឡះពីការសរសេរអ្វីមួយដែលអាចត្រូវបានគេយកទៅបកស្រាយ និងចាត់ទុកថាជាការបង្ករការខូចខាតដល់កេរ្តិ៍ឈ្មោះរបស់រាជវង្សានុវង្ស។ ក្រុមអ្នករិះគន់ច្បាប់នេះនិយាយថា រាជវាំងមិនមែនជាអ្នកប្រើច្បាប់នេះទេ តែគឺពួកនយោបាយ និងបុគ្គលសកម្មជនមួយចំនួនជាអ្នកយកវាទៅប្រើ ដើម្បីបំបិទសម្លេងរិះគន់ និងវាយប្រហារទៅលើគូបដិបក្ខរបស់គេ ដោយប្រដូចអ្នកទាំងនោះទៅនឹងពួកមានទស្សនៈប្រឆាំងលទ្ធិរាជានិយម។ នៅប្រទេសកម្ពុជា គេមិនទាន់ឃើញមានការប្រើបទចោទប្រមាថព្រះបេស្កាទៅលើអ្នកសារព័ត៌មាននៅឡើយទេ។

៥. **សន្តិសុខជាតិ**។ ប្រទេសនៅលើពិភពលោកមានច្បាប់ខុសៗគ្នាដែលកែរៀបរៀងឡើងសំដៅការពារសន្តិសុខជាតិ។ ច្បាប់ទាំងនោះច្រើនតែផ្តល់និយមន័យទូលំទូលាយណាស់ដល់សន្តិសុខជាតិ ហើយវាច្រើនតែស្រេចតែទៅលើឆន្ទានុសិទ្ធិរបស់អាជ្ញាធរក្នុងការចាត់ទុកថា តើអ្វីមួយដែលសារព័ត៌មានចុះផ្សាយនោះ បង្កការគំរាមកំហែងដល់សន្តិសុខរបស់រដ្ឋដែរ ឬទេ។ បញ្ហារបស់ច្បាប់បែបនេះ នៅត្រង់ថា វាច្រើនតែអនុញ្ញាតឲ្យមានការឃុំឃាំងជនសង្ស័យដោយគ្មានសវនាការ។ ដូច្នេះ ជនជាប់ចោទពីបទបង្កគ្រោះថ្នាក់ដល់សន្តិសុខរដ្ឋកម្រទទួលបានឱកាសនិយាយក្នុងតុលាការថា ពួកគេគ្រាន់តែធ្វើសេចក្តីរាយការណ៍ព័ត៌មានធម្មតា ឬអនុវត្តន៍សេរីភាពសារព័ត៌មានរបស់គេតែប៉ុណ្ណោះ។ ដូច្នេះ អ្នកគួរស្នើរយោបល់ពីសហសេវិកមានបទពិសោធន៍យូរឆ្នាំថា តើគួរធ្វើដូចម្តេចខ្លះដើម្បីចៀសវាងមានបញ្ហាជាមួយច្បាប់ទាក់ទិននឹងសន្តិសុខជាតិ។

៦. **បទមាក់ងាយតុលាការ**។ ប្រទេសភាគច្រើនតែងអះអាងថាគេព្យាយាមការពារប្រព័ន្ធយុត្តិធម៌ ដោយធានាឲ្យមានការកាត់ក្តីត្រឹមត្រូវសម្រាប់ជនទាំងឡាយដែលជាប់ចោទពីបទព្រហ្មទណ្ឌ។ នេះមានន័យថា ពេលណាជនណាម្នាក់ត្រូវបានតុលាការធ្វើការចោទប្រកាន់រួចហើយ អ្វីក៏ដោយដែលអ្នកឯទៀតអាចនិយាយបានអំពីជននោះ មិនអាចធ្វើបុរេវិនិច្ឆ័យលើសវនាការ ដែលនឹងមកដល់នៅពេលខាងមុខបានទេ។ មានន័យថា វាមិនគួរជះឥទ្ធិពលលើទស្សនៈរបស់ចៅក្រម ឬរបស់គណៈវិនិច្ឆ័យអំពីមនុស្សម្នាដែលពាក់ព័ន្ធ ឬអំពីអង្គហេតុនៃករណីនោះឡើយ។ នៅប្រទេសដែលប្រកាន់ក្រឹត្យក្រមតឹងរ៉ឹងអំពីបទមាក់ងាយតុលាការ កាលណាគេធ្វើបទចោទទៅលើនរណាម្នាក់ហើយ ករណីនេះត្រូវស្ថិតក្រោមដំណើរការយុត្តិធម៌ (sub-judice) ហើយបន្ទាប់ពីនោះមានតែឯកសារ និងសេចក្តីប្រកាសផ្លូវការទេដែលគេអាចដកស្រង់យកមកសរសេរផ្សព្វផ្សាយបាន គឺនៅក្រោយពីករណីនោះចប់សព្វគ្រប់តែប៉ុណ្ណោះ។ ឯកសារផ្លូវការនោះ រួមមានកំណត់ត្រាដំណើរការក្នុងរឿងក្តីរបស់តុលាការដែលជាឯកសារមានឯកសិទ្ធ ដូច្នេះគេអាចដកស្រង់ព័ត៌មានរបស់វាបាន។ ក៏ប៉ុន្តែសេចក្តីរាយការណ៍ព័ត៌មានតុលាការ ត្រូវតែជាការសង្ខេបប្រកបដោយត្រឹមត្រូវមិនលំអៀង និងជាក់លាក់នៃដំណើរការក្តី (ដូច្នេះចូរកុំ

ថែមបរិបទ និងការវិភាគដូចដែលអ្នកធ្វើក្នុងរឿងផ្សេងទៀតទេ)។ តុលាការអាចចោទអ្នកពីបទមាក់ងាយតុលាការ ហើយបញ្ជូនខ្លួនអ្នកចូលគុក បើសិនជាអ្នកសរសេររឿងដោយប្រើប្រភពព័ត៌មានក្រៅបន្ទប់សវនាការ ឬក៏សរសេរអំពីដំណើរការតុលាការ ដោយខ្វះភាពមិនលំអៀង និងភាពត្រឹមត្រូវជាក់លាក់។ នៅប្រទេសដែលមិនសូវប្រកាន់ភាពតឹងរ៉ឹងលើចំណុចនេះ មេធាវី និងអ្នកធ្វើអត្ថាធិប្បាយតែងត្រូវបានគេដកស្រង់សម្ដីនិយាយអ្វី ដែលគេយល់ឃើញអំពីករណីមួយនោះ។ យ៉ាងណាក្ដី នៅប្រទេសភាគច្រើនមានកំហិត ហើយជួនកាលជាកំហិតដ៏តឹងរ៉ឹងបំផុតលើអ្វីដែលជនណាម្នាក់អាចនិយាយបានអំពីចៅក្រម និងឥទ្ធិពលដែលមានលើអ្នកទាំងនោះ។ បើសិនជាអ្នកគ្រោងនឹងសរសេរអ្វីមួយដែលមានការពាក់ព័ន្ធជាមួយទង្វើរបស់តុលាការ សូមអ្នកស្វែងយល់ឲ្យបានច្បាស់អំពីការប្រើប្រាស់បទមាក់ងាយតុលាការក្នុងប្រទេសរបស់អ្នកជាមុនសិន។

**៧. ការរក្សាសិទ្ធិស្នាដៃ និងការលួចចម្លងស្នាដៃនិពន្ធ (Copyright and Plagiarism)**។ អ្នកសារព័ត៌មានប្រកបរបរចិញ្ចឹមជីវិតពីលក់របស់ដែលហៅថា ទ្រព្យសម្បត្តិបញ្ញា (intellectual property) - បានន័យថា ផលិតផលការងារគំនិតប្រាជ្ញារបស់យើង។ យើងពិតជាមិនចូលចិត្តទេ បើមាននរណាម្នាក់យកអ្វីដែលយើងសរសេរទៅដាក់ក្នុងរឿងដែលមានឈ្មោះរបស់គេនៅពីលើ។ យើងហៅការធ្វើបៀបនេះថាជាការលួចចម្លងស្នាដៃនិពន្ធ។ យើងនឹងចាប់មានអារម្មណ៍កាន់តែមិនសប្បាយចិត្តថែមទៀត បើសិនជាពួកគេលក់រឿងរបស់យើងក្រោមឈ្មោះរបស់គេទៅឲ្យកាសែតផ្សេងទៀត ដើម្បីយកលុយដាក់ក្នុងហោប៉ៅរបស់ខ្លួន។ ទាំងអស់នេះវាដូចគ្នាដែរសម្រាប់ទម្រង់ទ្រព្យសម្បត្តិបញ្ញាដទៃទៀតមាន សៀវភៅ ល្ខោន សិល្បៈតន្ត្រី ការផ្សាយទូរទស្សន៍ និងវិទ្យុភាពយន្ត និងរូបថត ផ្នែកទន់កុំព្យូទ័រ និងយីហោក្រុមហ៊ុន ឬផលិតផល ជាដើម។ អ្នកសារព័ត៌មានដែលចម្លងការងាររបស់អ្នកដទៃអាចរងចោទប្រកាន់ពីបទរំលោភសិទ្ធិស្នាដៃផាកពិន័យ ដាក់ពន្ធនាគារ និងត្រូវគេបង្ខំឲ្យសងជំងឺចិត្តដល់ម្ចាស់សិទ្ធិស្នាដៃផងដែរ។ វាមិនមានភាពចាំបាច់ទេសម្រាប់ម្ចាស់សិទ្ធិស្នាដៃថាត្រូវតែចុះបញ្ជីសិទ្ធិស្នាដៃរបស់ខ្លួននោះ។ ពួកគេគ្រាន់តែត្រូវផ្ដល់តឹកតាងថាការងារមួយនោះជាការងារដើម និងជាការងារពិតប្រាកដរបស់គេ។ ច្បាប់រក្សាសិទ្ធិស្នាដៃ មិនការពារអង្គហេតុការណ៍ពិត ដំណឹង គំនិត ឬព័ត៌មានក្នុងសាច់រឿងទេ តែវាផ្ដល់ការការពារដល់របៀបសំដែងតាក់តែងអង្គហេតុការណ៍ពិត ដំណឹង គំនិត និងព័ត៌មានទាំងនោះ។ នៅប្រទេសកំពុងអភិវឌ្ឍន៍ ការការពារសិទ្ធិស្នាដៃនៅមានភាពទន់ខ្សោយនៅឡើយ ហើយបើមានក៏មានត្រឹមករណីរបស់ក្រុមហ៊ុនពហុសាស្ត្រធំៗក្នុងការប្ដឹងប្រឆាំង នឹងការលួចម្លងស្នាដៃ ទង្វើក្លែងក្លាយផលិតផល និងផលិតផលត្រាប់បន្លំតែប៉ុណ្ណោះ។ យ៉ាងណាក្ដី អ្នកសារព័ត៌មានគួរតែប្រតិបត្តិតាមស្តង់ដារក្រមសីលធម៌របស់ខ្លួនដូចគ្នានឹងគោរពច្បាប់ដែរ។ បើយើងមិនចង់ឲ្យគេលួចស្នាដៃរបស់យើងទេ ចូរកុំទៅលួចស្នាដៃរបស់អ្នកដទៃ។

# សេចក្ដីសន្និដ្ឋាន



*ពេលពួកខ្មែរក្រហមដណ្ដើមបានអំណាច នាខែមេសា ឆ្នាំ១៩៧៥ វាបានបង្កនូវវិនាសកម្មដ៏សែនអាក្រក់ដល់ប្រទេសកម្ពុជា*

តាំងពីឆ្នាំ ១៩៤៥ មក មានអ្នកសារព័ត៌មានជាង ៣២០ នាក់ បានស្លាប់ ឬបាត់ខ្លួនក្នុងសង្គ្រាមជាច្រើននៅតំបន់ឥណ្ឌូចិននេះ។ អង្គការ IMMF ត្រូវបានបង្កើតឡើងនៅទសវត្សរ៍ឆ្នាំ ១៩៩០ ដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធរបស់អ្នកក្លាហានទាំងនោះដោយរួមចំណែកក្នុងការអភិវឌ្ឍជំនាន់ថ្មីមួយនៃអ្នកសារព័ត៌មាននៅអាស៊ី-អាគ្នេយ៍។ សៀវភៅមួយក្បាលនេះជាផលិតផលរូបិយមួយនៃគំនិតផ្ដួចផ្ដើមរបស់យើង។

នៅពេលដែលសៀវភៅនេះហៀបនឹងចូលរោងពុម្ពដើម្បីធ្វើការបោះពុម្ពផ្សាយ ក្រុមអ្នកសារព័ត៌មានជាបងប្អូនមួយក្រុម បានមកជួបជុំគ្នាក្នុងក្រុងភ្នំពេញដើម្បីប្រារព្ធខួបលើកទី ៤០ ឆ្នាំ នៃការដែលប្រទេសកម្ពុជា ត្រូវបានគេអូសទាញធ្លាក់ចូលក្នុងសង្គ្រាមដ៏សែនវិនាសកម្មមួយ។ ក្នុងនោះ មានអ្នកសារ-ព័ត៌មានមួយចំនួន ដែលនៅរស់រានជីវិតពីការយកព័ត៌មានសេក្ដីវេទនារបស់កម្ពុជា មុននឹងការដួលរលំរបបសាធារណរដ្ឋនៅខែមេសា ឆ្នាំ១៩៧៥ និងការឡើងកាន់អំណាចឃោរឃៅកម្ពុជាប្រជាធិប-តេយ្យរបស់ពួកខ្មែរក្រហម។

របបខ្មែរក្រហមសម្លាប់ដោយគ្មានរើសមុខទេ ក្នុងនោះ ក៏មានអ្នកសារព័ត៌មាន និងកម្មាភិបាលរបស់ពួកវាផងដែរ។ យ៉ាងហោចណាស់មានអ្នកសារព័ត៌មាន ៣៧នាក់ ជាជនបរទេស និងជនកម្ពុជា ដែលបានស្លាប់បាត់បង់ជីវិត ឬបាត់ខ្លួនតែម្ដងក្នុងអំឡុងសង្គ្រាម។ ពីរភាគបីក្នុងចំនួននេះជាជនជាតិជប៉ុន បារាំង និងអាមេរិក។ អ្នកសារព័ត៌មានកម្ពុជាប្រាំនាក់ត្រូវបានគេដឹងថាបានស្លាប់ក្នុងពេលសង្គ្រាម ហើយ ៣១ នាក់ទៀត ត្រូវបានគេធ្វើឃាត។ អ្នកខ្លះស្លាប់ក្នុងភាពអនាមិក ហើយត្រូវបានគេចងចាំដោយសារតែឈ្មោះមួយកំណាត់នៅលើរូបថតតែប៉ុណ្ណោះ។

ពិតណាស់ ចំនួននេះតិចតួចណាស់ប្រៀបទៅនឹងចំនួនជាង ៣ លាននាក់ នៃប្រជាជនវៀតណាម និងប្រជាជនឡាវជាង ៣០០.០០០ នាក់ ដែលបានស្លាប់ក្នុងសង្គ្រាម និងបើប្រៀបជាមួយប្រជាជនកម្ពុជាប្រមាណជា ២ លាននាក់ ដែលបានបង់ជីវិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងទាហានអាមេរិកជាង ៥៨.០០០ នាក់ ដែលបានស្លាប់ក្នុងសង្គ្រាមឥណ្ឌូចិន។ យ៉ាងណាក្ដី មរណភាពរបស់ពួកគេឆ្លុះបញ្ចាំងឲ្យឃើញថា វិស័យសារព័ត៌មានអាចជាអាជីពមួយប្រកបដោយគ្រោះថ្នាក់ តែក៏មិនខ្វះមនុស្សដែលហ៊ានប្រថុយប្រថាន ដើម្បីប្រកបអាជីពនេះដែរ។

អ្នកសារព័ត៌មានជាច្រើនអ្នកដែលធ្លាប់តែសកម្មក្នុងជំនាន់ទសវត្សរ៍ឆ្នាំ ១៩៧០ បានទទួលមរណភាពបាត់ទៅហើយ ភាគច្រើនដោយសារវ័យជរា ឬជំងឺ និងមួយចំនួនស្លាប់ ដោយសារមូលហេតុផ្សេងៗទៀត។ លោក Neil Davis កាមេរ៉ាមែនទូរទស្សន៍អូស្ត្រាលីដ៏ល្បីឈ្មោះមួយរូប ដែលធ្លាប់បានចងក្រងសង្គ្រាមនៅឥណ្ឌូចិនទសវត្សរ៍ឆ្នាំ ១៩៦០ និង ១៩៧០ បានស្លាប់ក្នុងការបាញ់គ្នាយ៉ាងខ្លាំងពេលមានការប៉ុនប៉ងរដ្ឋប្រហារមិនសម្រេចមួយក្នុងក្រុងបាងកក ឆ្នាំ ១៩៨៥។ សហសេវិករបស់គាត់ លោក Bill Latch ដែលជាអ្នកបញ្ជាឧបករណ៍សម្លេងក៏ស្លាប់ក្នុងគ្រានោះដែរ។

មានអ្នកសារព័ត៌មានឯទៀត ដែលបានទទួលមរណភាពក្នុងភាពរំជើបរំជួលកាលពីពេលថ្មីៗនេះ។ អ្នកថតរូបជប៉ុន លោក Kenji Nagai ត្រូវបានទាហានបាញ់ស្លាប់ក្នុងគ្រាមានចលនាបះបោរនៅក្រុងយ៉ាំងហ្គូន ប្រទេសមីយ៉ាន់ម៉ា នាខែកញ្ញា ឆ្នាំ ២០០៧។ ជនរួមជាតិរបស់គាត់ និងជាកាមេរ៉ាមែន លោក Hiro Muramoto ត្រូវបានគេបាញ់ស្លាប់ក្នុងពេលមានភាពរំជើបរំជួលនយោបាយក្នុងក្រុងបាងកក ក្នុងខែមេសា ឆ្នាំ ២០១០។ ប្រាំសប្ដាហ៍ក្រោយមកទៀត អ្នកថតរូបជនជាតិអ៊ីតាលី លោក Fabio Polenghi ត្រូវស្លាប់ដោយសារគ្រាប់កាំភ្លើងក្នុងរដ្ឋធានីថៃដែរ។ ក្នុងអំឡុងពេលនោះ អ្នកសារ-ព័ត៌មាន ៨ រូបផ្សេងទៀត មាន ៤នាក់ ជាជនជាតិថៃ និង ៤ នាក់ ជាជនជាតិបរទេស ក៏រងរបួសផងដែរ។ ក្នុងឆ្នាំ ២០០៩ អ្នកសារព័ត៌មាន ៣៣ នាក់ ត្រូវបានគេសម្លាប់នៅប្រទេសហ្វីលីពីន ដែលនេះជាចំនួនខ្ពស់ជាងគេបំផុតក្នុងប្រទេសតែមួយ ក្នុងចំណោមចំនួនអ្នកសារព័ត៌មានសរុប ៧១ នាក់ ដែលត្រូវបានគេសម្លាប់នៅទូទាំងពិភពលោកនាឆ្នាំនោះ។

លោក Joel Simon មានប្រសាសន៍ថា៖ "ឆ្នាំ ២០០៩ ជាឆ្នាំនៃការបាត់បង់ដ៏អាក្រក់បំផុត មិនដែលធ្លាប់មានពីមុនមកសម្រាប់ប្រព័ន្ធផ្សព្វផ្សាយលើពិភពលោក ប៉ុន្តែអំពើហិង្សាទាំងនេះបញ្ជាក់ឲ្យឃើញនូវនិន្នាការយូរអង្វែងមកហើយ។ ភាគច្រើននៃជនរងគ្រោះជាអ្នកសារព័ត៌មានក្នុងស្រុក ដែលធ្វើការយកព័ត៌មានក្នុងសហគមន៍របស់គេតែម្តង"។ លោក Simon ជានាយកប្រតិបត្តិរបស់អង្គការ Committee to Protect Journalists នៅក្រុងញូវយ៉ក ដែលបានកត់ត្រាទុកនូវមរណភាពអ្នកសារព័ត៌មានជាង ៨០០ នាក់ មកហើយតាំងពីឆ្នាំ ១៩៩២ មកម្ល៉េះ។

បច្ចុប្បន្ននេះ នៅពេលដែលអ្នកសារព័ត៌មានភាគច្រើនកំពុងមានការខ្វល់ខ្វាយអំពីការប្រកបរបរចិញ្ចឹមជីវិតរបស់ខ្លួន និងអនាគតនៃអាជីពរបស់ពួកគេផងនោះ វាជាគុណតម្លៃមួយក្នុងរម្លឹកចងចាំអ្នកទាំងឡាយដែលបានប្រគល់ជីវិតរបស់គេជាថ្នូរនឹងអាជីពនេះបាត់ទៅហើយនោះ។ ការដែលត្រូវបានគេសម្លាប់ មិនមែនធ្វើឲ្យពួកគេក្លាយខ្លួនជាអ្នកសារព័ត៌មានកាន់តែពូកែទៀតនោះទេ តែវាជាតឹកតាងបញ្ជាក់ថាភាពស្វិតស្វាញដេញតាមរឿងមួយអាចមានតម្លៃមួយខ្ពស់ណាស់។

អ្នកសារព័ត៌មានជាប្រពៃណីច្រើននាក់ មានក្ដីមន្ទិលចំពោះអ្នកសារព័ត៌មានដទៃទៀត ដែលក្លាយខ្លួនជាផ្នែកមួយនៃរឿង ដោយអចេតនាក្ដី ឬនៅពេលដែលគេបាត់បង់ជីវិតហើយក្ដី ដោយសារថាអ្នកសារ-ព័ត៌មានទាំងនេះ អាចកន្ត្រាក់បង្វែរស្មារតីអ្នកសារ-ព័ត៌មានឯទៀតចេញពីប្រធានបទធំនៃរឿង ដែលគេកំពុងតាមដាននោះទៅវិញ។ ក្នុងទិសដៅអនាគតកង្វល់ដ៏ធំមួយប្រហែលជាគ្រោះថ្នាក់នៃការមិនសូវឲ្យតម្លៃដល់វិភាគទានពិតប្រាកដ ដែលអ្នកសារ-ព័ត៌មានល្អបំណានៗនៅតែអាចធ្វើបាន - តាមរយៈ

ការជូនព័ត៌មាន ផ្ដល់ការអប់រំ និងពេលខ្លះផ្ដល់ការកំសាន្ត - បំពោះសុខុមាលភាព និងការយល់ដឹងជាសាកលរបស់សាធារណជន។ សៀវភៅមគ្គុទេសក៍កម្រិតខ្ពស់មួយក្បាលនេះ ត្រូវបាននិពន្ធឡើងក្នុងគោលបំណងជាការវិនិយោគតូចមួយទៅក្នុងអនាគតនោះ។

DOMINIC FAULDER
និពន្ធនាយក
បាងកក ខែ ឧសភា ឆ្នាំ ២០១០

# អំពីអ្នកនិពន្ធ

JEFF HODSON ជាអ្នកសារព័ត៌មាន និងគ្រូបង្រៀនផ្នែកសារព័ត៌មានសញ្ជាតិអាមេរិក។ គាត់បានបង្រៀនអ្នកសារព័ត៌មានជាច្រើននៅអាស៊ី ក្នុងនោះ មានប្រទេសវៀតណាម និងអាហ្វហ្គានីស្ថានផង។ នៅឆ្នាំ ២០០០ នៅពេលដែលគាត់បានទទួលមូលនិធិផ្គត់ផ្គង់ពីអង្គការ Knight International Journalism Fellow គាត់បានដឹកនាំវគ្គបង្រៀន IMMF នៅតាមប្រទេសមួយចំនួនក្នុងអាស៊ី។ គាត់ជាសហអ្នកនិពន្ធសៀវភៅរបស់ IMMF ដែលមានឈ្មោះថា Reporting and Writing News – A Basic Handbook ដែលត្រូវបានបោះពុម្ពផ្សាយលើកទីមួយនៅឆ្នាំ ២០០១ និងលើកទីពីរនៅឆ្នាំ ២០០៩។ ឆ្នាំ ២០០៣ គាត់ជាសាស្ត្រាចារ្យទស្សនកិច្ចនៅ Indian Institute of Journalism & New Media ហើយធ្លាប់បង្រៀនសារព័ត៌មាននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញពីឆ្នាំ ២០០១ ដល់ឆ្នាំ ២០០២ ទៀតផង។ គាត់ធ្លាប់ធ្វើការឲ្យ Internews, Independent Journalism Foundation និងអង្គភាពសារព័ត៌មានអន្តរជាតិមួយចំនួនទៀត។ គាត់ជាអតីតនិពន្ធនាយករងកាសែត The Cambodia Daily និងធ្លាប់បានដឹកនាំវគ្គហ្វឹកហ្វឺនសារព័ត៌មានឲ្យអង្គភាពសារព័ត៌មានមួយចំនួនផង មានកាសែត Bangkok Post និង The Nation។ អស់រយៈពេលជាងមួយទសវត្សរ៍ គាត់ជាអ្នកយកព័ត៌មាន និងស្មេរ ដែលទទួលបានជ័យលាភីឲ្យកាសែតមួយចំនួននៅសហរដ្ឋអាមេរិក ក្នុងនោះមានកាសែត The Seattle Times។ លោក Hodson ទទួលបានសញ្ញាប័ត្រអនុបណ្ឌិតសារព័ត៌មានពី Northwestern University’s Medill School of Journalism។

GRAHAM WATTS មានសញ្ជាតិអាហ្វ្រិកខាងត្បូង ជាអ្នកប្រឹក្សាយោបល់ឯករាជ្យផ្នែកសារព័ត៌មាន ជាគ្រូហ្វឹកហ្វឺនសារព័ត៌មាន និងជានិពន្ធនាយកផងដែរ។ គាត់រស់នៅក្នុងក្រុងបាងកក ប្រកបរបរជាអ្នកនិពន្ធកែសម្រួលរបាយការណ៍ស្រាវជ្រាវ និងសៀវភៅរបស់ស្ថាប័នសិក្សាជាច្រើន និងក៏ធ្លាប់បានធ្វើជាអ្នកប្រឹក្សាយោបល់ឲ្យកាសែត Bangkok Post ដែរ។ ក្នុងរយៈពេល ៣០ ឆ្នាំកន្លងមកនេះ គាត់ធ្លាប់បានប្រឡូកក្នុងការហ្វឹកហ្វឺនអ្នកសារព័ត៌មានជាច្រើននាក់នៅអាស៊ី អឺរ៉ុប និងអាហ្វ្រិក ក្នុងនោះ មាននៅបណ្ដាសាកលវិទ្យាល័យនៅចក្រភពអង់គ្លេស អាហ្វ្រិកខាងត្បូង និងសហរដ្ឋអាមេរិក។ ក្រៅពីនោះ គាត់ក៏ធ្លាប់ធ្វើការឲ្យអង្គការហ្វឹកហ្វឺនសារព័ត៌មានអន្តរជាតិជាច្រើនទៀតដែរ។ គាត់ធ្វើការអស់ ២១ ឆ្នាំ នៅកាសែត Financial Times នៅទីក្រុងឡុងដ៍។ នៅទីនោះ គាត់ធ្វើជានិពន្ធនាយកដំណឹងពិភពលោក ដោយទទួលបន្ទុកដំណឹងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងបញ្ហាគោលនយោបាយសាកល។ ក្រោយមកទៀត គាត់មានឋានៈជានិពន្ធនាយកទស្សនាវដ្ដី *FT Magazine*។ គាត់បានដើរតួនាំមុខយ៉ាងសំខាន់



*ការដកធ្មេញនៅក្រុងម៉ាន់ដាឡាយ អាចធ្វើបានយ៉ាងរហ័ស និងមិនសូវចុកចាប់ ដូចការផលិតសៀវភៅមគ្គុទេសក៍វិជ្ជាជីវៈសារព័ត៌មានទេ។*

ក្នុងការបង្ហាត់ដល់អ្នកសារព័ត៌មាន *Financial Times* ហើយគាត់នៅតែបន្តជួយបង្រៀនពួកគេដដែលក្រោយពីបានលាលែងពីការងារនៅឆ្នាំ ២006 មក។ កាលពីឆ្នាំ ២000 គាត់បង្កើតវិបសាយបង្រៀនសារព័ត៌មានធុរកិច្ច ដែលបង្ហោះដោយទីភ្នាក់ងារអភិវឌ្ឍន៍រដ្ឋាភិបាលអាល្លឺម៉ង់ ដែលមានឈ្មោះថា InWEnt។ គាត់ក៏ធ្លាប់រួមចំណែកក្នុងការតាក់តែងសៀវភៅសារព័ត៌មានផ្នែកសេដ្ឋកិច្ច និងធុរកិច្ចផងដែរ ដែលក្នុងនោះ មានសៀវភៅមួយដែលគាត់សហានិពន្ធឲ្យសាកលវិទ្យាល័យ Fudan University នៅទីក្រុងសៀងហៃ។ លោក Watts ទទួលការសិក្សាអំពីវិស័យសារព័ត៌មាននៅសាកលវិទ្យាល័យ Rhodes University និងនៅសាលាសារព័ត៌មាននៃ University of Wisconsin-Madison ក្នុងសហរដ្ឋអាមេរិក។

**DOMINIC FAULDER** ជាអ្នកសារព័ត៌មានសញ្ជាតិអង់គ្លេស ដែលរស់នៅក្រុងបាងកកតាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៨0 មកម្ល៉េះ ហើយធ្លាប់បានផ្តល់អត្ថបទ រូបថត និងបទវិចារណកថាដល់អង្គភាពសារព័ត៌មានច្រើនរាប់មិនអស់យកទៅចុះផ្សាយ។ គាត់ធ្លាប់ធ្វើជាអ្នកឆ្លើយឆ្លងព័ត៌មានពិសេសរបស់ទស្សនាវដ្តីប្រចាំសប្តាហ៍ *Asiaweek* ដោយរាយការណ៍ព័ត៌មានអំពីប្រទេសកម្ពុជា និងប្រទេសមីយ៉ាន់ម៉ា មុននឹងទស្សនាវដ្តីនេះត្រូវបានបិទការផ្សាយរបស់ខ្លួននៅឆ្នាំ ២00១។ គាត់ធ្លាប់កាន់មុខងារផ្សេងៗជាច្រើនក្នុង Foreign Correspondents’ Club of Thailand រួមមានឋានៈជាប្រធានអស់រយៈពេលពីរអាណត្តិផង និងជាសហប្រធាន IMMF ពីឆ្នាំ ១៩៩៤ ដល់ ២00៨។ លោក Faulder ទទួលការអប់រំជាន់ខ្ពស់នៅ St Paul’s in London and the University of Warwick។

# សៀវភៅ ឯកសារ វិបសាយសម្រាប់អានបន្ថែម

ក្រៅពីសៀវភៅ Getting the Story សៀវភៅទាំងអម្បាលម៉ានខាងក្រោមនេះ សុទ្ធតែជាភាសាអង់គ្លេស ដែលអាចជាការលំបាកដល់អ្នកទាំងឡាយណា ដែលអង់គ្លេសមិនមែនជាភាសាកំណើតរបស់ខ្លួន។ ភាគច្រើន សៀវភៅទាំងនេះនិយាយអំពីស្ថានភាពសារព័ត៌មាននៅសហរដ្ឋអាមេរិក។ តែយ៉ាងណាក៏ដោយ វានៅតែផ្ដល់ព័ត៌មានណែនាំល្អៗបំផុតសម្រាប់ការយកព័ត៌មាន និងសរសេរអត្ថបទស៊ីជម្រៅបានដែរ។

## សៀវភៅ


*The AP Broadcast News Handbook,* by Brad Kalbfeld. Published in 2000 by McGraw-Hill Professional Publishing.

*The Associated Press Guide to News Writing* (3rd edition), by Rene J. Cappon. Published in 2005 by ARCO.

*Getting the Story.* This is a textbook and a video tape produced in 1990 by the International Center for Journalists, 1616 H Street, NW, 3rd Floor, Washington DC, 20006-4999, USA.

*A Handbook for Cambodian Journalists,* by Huw Watkin. Published in Phnom Penh in 1998 by the Konrad Adenauer Foundation.

*News Reporting and Writing* (11th edition), by Melvin Mencher. Published in 2007 by McGraw Hill College Division.

*The Newspapers Handbook* (3rd edition), by Richard Keeble. Published in 2001 by Routledge, London and New York.

*Reporting and Writing News, A Basic Handbook* (2nd edition), by Peter Eng and Jeff Hodson for the Indochina Media Memorial Foundation, published in 2009.

*Writing and Reporting News, A Coaching Method* (6th edition), by Carole Rich. Published in 2009 by Wadsworth Publishing Co., 10 Davis Drive, Belmont, CA 94002, USA.

*A Writer's Coach: The Complete Guide to Writing Strategies That Work,* by Jack Hart, published in 2007 by Anchor Books and in 2008 by Paw Prints.

*Writing Tools, 50 Essentail Strategies for Every Writer,* by Roy Peter Clark, published in 2006 by Little, Brown and Company.

*Covering Globalization: A Handbook for Reporters,* edited by Anya Schiffrin and Amer Bisat, published in 2004 by Columbia University Press.

# សៀវភៅ ឯកសារ វិបសាយសម្រាប់អានបន្ថែម

## កម្រងកូនសៀវភៅ

អង្គការ International Center for Journalists បានផលិតកម្រងកូនសៀវភៅមួយចំនួនដូចខាងក្រោមនេះ ៖

*Ten Practical Tips for Environmental Reporting,* by Peter Nelson.

*Ten Practical Tips for Business and Economic Reporting in Developing Countries,* by Paul Hemp.

*Ten Steps to Investigative Reporting,* by Lucinda Fleeson.

*Free and Fair: A Journalist's Guide to Improved Election Reporting in Emerging Democracies,* by Lisa Schnellinger.

## សៀវភៅអំពីបរិស្ថាន

*A Land on Fire, The Environmental Consequences of the Southeast Asia Boom,* by James David Fahn, published in 2004 by Silkworm Books.

*Environment Words,* a dictionary in plain English, published by Images Asia (no date).

*The Rough Guide to Climate Change, The Symptoms, the Science, the Solutions,* by Robert Henson (2nd edition), published in 2008 by Rough Guides, a division of Penguin.

## សៀវភៅក្បួនសរសេរបទពិពណ៌នា និងការរាយការណ៍ព័ត៌មានស៊ីជម្រៅ

*The Art and Craft of Feature Writing, Based on the Wall Street Journal Guide,* by William E. Blundell. Published in 1988 by Plume (Penguin Books USA).

*Writing for Story, Craft Secrets of Dramatic Nonfiction by a Two-Time Pulitzer Prize Winnder,* by John Franklin, Published in 1994 by Plume Printing (an imprint of Dutton Signet, a division of Penguin Books USA).

*Follow the Story, How to Write Successful Nonfiction,* by James B. Stewart, published in 1998 by Touchstone.

*On Writing Well, the Classic Guide to Writing Nonfiction,* by William Zinsser, 30th edition published in 2006 by Harper Collins.

# សៀវភៅ ឯកសារ វ៉ិបសាយសម្រាប់អានបន្ថែម



## សៀវភៅណែនាំអំពីការធ្វើសម្ភាសន៍

*Interviewing for Journalists,* by Sally Adams with Wynford Hicks, published in 2001 by Routledge.

## វ៉ិបសាយ

*The Columbia Journalism Review* (http://www.cjr.org) ផ្តល់មគ្គុទេសក៍ក្នុងការយកព័ត៌មានផ្នែកនីមួយៗជាក់លាក់ ដូចជា ផ្នែកឧក្រិដ្ឋកម្ម បម្រែបម្រួលអាកាសធាតុ សុខាភិបាល និងសំណៅយោងជាច្រើនផ្សេងទៀត។

*The American Journalism Review* (http://www.ajr.org) ផ្តល់មគ្គុទេសក៍សម្រាប់អ៊ិនធឺណិត ការស្រាវជ្រាវ ស្ថិតិ សេរីភាពសារព័ត៌មាន ។ល។ និង ។ល។

វិទ្យាស្ថាន The Poynter Institute (http://www.poynter.org) ផ្តល់ការពិភាក្សាអំពីបញ្ហាជាច្រើនទាក់ទិននឹងវិស័យសារព័ត៌មាន និងមគ្គុទេសក៍ណែនាំមានប្រយោជន៍ជាច្រើន ដូចជាតារាងជំនួយស្មារតី “tip sheets” ជាដើម។

គម្រោង The Initiative for Policy Dialogue ដែលមានការិយាល័យក្នុងសាកលវិទ្យាល័យ Columbia University (www2.gsb.columbia.edu/ipd/j_intro.html) មានបង្ហោះវ៉ិបសាយមួយសម្រាប់ជាជំនួយស្មារតីដល់អ្នកសារព័ត៌មានក្នុងការរាយការណ៍ព័ត៌មានអំពីវិស័យហិរញ្ញវត្ថុ និងសេដ្ឋកិច្ចក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។

អង្គការ The International Center for Journalists (http://www.icfj.org) មានបណ្តាញតភ្ជាប់ទៅនឹងជំនួយស្មារតីអនឡាញ និងឧបករណ៍យោងសម្រាប់បង្រៀនអ្នកសារព័ត៌មានជាច្រើនទៀត។ អង្គការនេះ ក៏ជាអ្នកប្រតិបត្តិវ៉ិបសៃត៍ www.ijnet.org ផងដែរ ដែលជាវ៉ិបសាយរបស់បណ្តាញ the International Journalists’ Network.

# សេចក្តីថ្លែងអំណរគុណ

មានមនុស្សច្រើននាក់ដែលមានទឹកចិត្តសប្បុរសក្នុងការចែករំលែកពេលវេលា និងជំនាញរបស់ពួកគេក្នុងការធ្វើឲ្យគម្រោងមួយនេះ ចេញជាផ្លែផ្កាបាន ក្នុងនោះ មានការផ្តល់អត្ថាធិប្បាយលើសេចក្តីព្រាងរបស់សៀវភៅនេះ ធ្វើការផ្ទៀងផ្ទាត់ជាមួយឯកសារបណ្ណាសារ និងការពិនិត្យពិច័យក្នុងការជ្រើសរើសរូបថត។ អ្នកទាំងនោះមាន ៖

MICK ELMORE, IMMF board member.

MIKEL FLAMM, IMMF board member and photography trainer.

DENIS D. GRAY, IMMF co-president, 1994-2009, and bureau chief for The Associated Press in Bangkok.

SARAH MACLEAN, IMMF project director, 1994-2009.

SUSANNE ROBINSON, IMMF supporter.

LANCE WOODRUFF, IMMF board member.

សៀវភៅជាច្រើនបានផ្តល់ជំនួយដល់ការសរសេរសៀវភៅក្បួននេះឡើង ហើយសៀវភៅទាំងនោះ ត្រូវបានរាយបញ្ជីឈ្មោះក្រោម "សៀវភៅឯកសារ វិបសាយសម្រាប់អានបន្ថែម" ។ ក្នុងនោះ មានសៀវភៅ និងមគ្គុទ្ទេសក៍ណែនាំដែលអង្គការ International Center for Journalists និង Knight International Press Fellowship Program បានផ្តល់ឲ្យសម្រាប់ធ្វើគម្រោងនេះ។

ជាមួយគ្នានេះដែរ យើងសូមថ្លែងអំណរគុណដល់ Foreign Correspondents' Club of Thailand (FCCT) ដែលបានបន្តការគាំទ្ររបស់ខ្លួនចំពោះគម្រោងសៀវភៅនេះរបស់ IMMF ហើយជាពិសេស គឺអរគុណចំពោះអតីតប្រធានរបស់ក្លឹបនេះ គឺលោក Nirmal Ghosh នៃកាសែត The Straits Times និងចំពោះប្រធានបច្ចុប្បន្ន គឺលោក Marwaan Macan-Markar របស់ Inter Press Service និងសមាជិកគណៈកម្មការនាយកទាំងអស់របស់ក្លឹបនេះ។ យើងសូមជូនសេចក្តីថ្លែងអំណរគុណវិសេសវិសាលចំពោះសមាជិកគណៈកម្មការនាយក FCCT គឺលោក Patrick Barta នៃកាសែត The Wall Street Journal និងចំពោះអ្នកគ្រប់គ្រងកិច្ចការទូទៅរបស់ក្លឹបនេះ គឺអ្នកស្រី Thanutra Teerasuphaset ដែលបានជួយក្នុងការសម្របសម្រួលយកមកប្រើនូវរូបថតមួយចំនួន ដែលជារូបថតជ័យលាភីក្នុងការប្រលងប្រជែងរូបថតលើកទីបី ដែលរៀបចំឡើងដោយ FCCT នៅឆ្នាំ ២០០៩។ ជាទីបញ្ចប់ យើងក៏សូមថ្លែងអំណរគុណផងដែរដល់លោក Peter Chralesworth និង Yvan Cohen របស់អង្គភាព OnAsia ដែលបានជួយដកយករូបភាពគុណភាពខ្ពស់ៗចេញពីបណ្ណាសារដ៏សំបូរបែបរបស់គេមកឲ្យយើងយកមកប្រើក្នុងសៀវភៅនេះ (www.onasia.com)។

# ម្ចាស់ស្នាដៃរូបថត

Cover, clockwise from top left:
DANNYBOY PATA (FCCT 2009,
Spot News, Third Place);
RICHARD HUMPHRIES (FCCT 2009,
Photo Essay, Honorable Mention);
JOHN JAVELLANA (FCCT 2009, Spot
News, Honorable Mention);
SANDIPAN MAJUMDAR (FCCT 2009,
Migrants, First Place); ANDREW BIRAJ
(FCCT 2009, Migrants, First Place);
RICHARD HUMPHRIES (FCCT 2009,
Photo Essay, Honorable Mention).

NICOLAS ASFOURI 30.
ANDREW BIRAJ 132. (FCCT 2009,
Migrants, First Place)
NIC DUNLOP 93,
MICK ELMORE 17, 38, 98
DOMINIC FAULDER 20, 72, 76, 88, 106,
110,122, 128,136, 140, 144, 162, 167.
MIKEL FLAMM 26, 34, 82, 114, 151.
ANAT GIVON 158.
HENG SINITH 51.
RICHARD HUMPHRIES 56, 62. (FCCT 2009,
Photo Essay, Honorable Mention)
BRENT LEWIN 68. (FCCT 2009,
Photo Essay, First Place)
ROLAND NEVEU 165.
NICK NOSTITZ 48.
MANIT SRIWANICHPOOM 148.
TANG CHHIN SOTHY 29.
THITI WANNAMONTHA 154. (FCCT 2009,
Spot News, Honorable Mention)
TRAN QUANG TUAN 166.
LANCE WOODRUFF vii, xi, xiii, 41, 135.

# ទៅហួសពីមូលដ្ឋានគ្រឹះ

## មគ្គុទេសក៍កម្រិតខ្ពស់ក្នុងវិជ្ជាជីវៈសារព័ត៌មាន

**ទស្សនៈឆ្លើយតបរបស់អតីតសិស្សរបស់ IMMF**

"ក្នុងចំណោមយើង អ្នកខ្លះក្រ អ្នកខ្លះមាន អ្នកខ្លះចេះភាសាអង់គ្លេសបានល្អ អ្នកខ្លះមិនសូវចេះ អ្នកខ្លះរស់នៅក្នុងប្រទេសដែលនៅមានសង្គ្រាមនៅឡើយ រីឯអ្នកខ្លះទៀតរស់នៅកន្លែងដែលពោរពេញដោយសន្តិភាព។ យើងរៀនយល់ពីគ្នាទៅវិញទៅមកបន្តិចម្តងៗ ស្វែងយល់អំពីវិស័យសារព័ត៌មាន វប្បធម៌ ក្នុងប្រទេសរបស់គេ អំពីចរិត ការលំបាករបស់គេ និងរបៀបដែលគេនៅតែបន្តប្រកបរបរជាអ្នកសារព័ត៌មាន។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះ យើងមិនចាំបាច់ចេះអង់គ្លេសច្រើនទេ ដើម្បីយល់ដឹងថាអ្នកឯទៀតចង់បានអ្វីនោះ។ យើងប្រៀបបាននឹងបងប្អូនប្រុសស្រី ដែលកំពុងរស់នៅយ៉ាងសប្បាយរីករាយក្រោមដំបូលតែមួយអញ្ចឹង"។

- VCG, Vietnam

"បន្ទាប់ពីទទួលការហ្វឹកហ្វឺនមក ខ្ញុំសង្កេតឃើញថាខ្ញុំបង្កើនជំនាញរបស់ខ្ញុំបានច្រើនណាស់។ អ្នកសារព័ត៌មានកម្ពុជាជាច្រើននាក់ និងអ្នកឯទៀតក្នុងតំបន់នេះដឹងគុណចំពោះអ្នក IMMF ខ្លាំងណាស់ ដែលគេគ្មានពេលណាបំភ្លេចបានទេ"។

- LN, Cambodia

"ខ្ញុំកំពុងតែឈរនៅទីនេះជាមួយនឹងសុបិនធ្វើជាអ្នកសារព័ត៌មានថតរូប ហើយ IMMF ជាទ្វារទីមួយ ដែលបើកឡើងនាំផ្លូវខ្ញុំមកដល់ទីនេះ"។

- VD, Thailand

"វាមានការលំបាកគួរសមដែរក្នុងការពន្យល់ថា តើការគាំទ្ររបស់ IMMF ចំពោះរូបខ្ញុំមានសារៈសំខាន់ប៉ុណ្ណាសម្រាប់ប្រទេសរបស់ខ្ញុំ ដែលជាប្រទេសមួយគ្មានសាលាបង្រៀនសារព័ត៌មានទាល់តែសោះនោះ"។

- YNM, Myanmar

"ខ្ញុំហ៊ាននិយាយថា ក្នុងបទពិសោធន៍សារព័ត៌មានដែលខ្ញុំមានកន្លងមក ដំណើររបស់យើងទៅកាន់ភាគខាងជើងប្រទេសថៃ គឺជាបទពិសោធន៍មានតម្លៃ និងអត្ថន័យខ្លាំងជាងគេទាំងអស់។ ដំណើរនេះអាចធ្វើទៅបាន ក៏ដោយសារតែ IMMF និងសមាជិកដទៃទៀត ដែលពោរពេញដោយស្មារតីឧស្សាហ៍ព្យាយាម និងគិតគូរពិចារណាក្នុងគ្រួសារ IMMF"។ - LJ, China

"រយៈពេលប្រាំឆ្នាំនៃវិភាគទានរបស់ IMMF ក្នុងការជួយអភិវឌ្ឍន៍វិទ្យុនៅប្រទេសឡាវ គឺពោរពេញដោយសារៈសំខាន់ និងប្រសិទ្ធភាព។ នាយកគ្រប់គ្រង និពន្ធនាយក និងផលិតករ សុទ្ធតែបានឆ្លងកាត់ការហ្វឹកហ្វឺន ដែលធ្វើឲ្យពួកគេទទួលបានជំនាញមានតម្លៃច្រើនណាស់"។ - VP, Laos

"ខ្ញុំចង់និយាយថា IMMF ជាផ្នែកមួយនៃជីវិតរបស់ខ្ញុំ ហើយត្រូវបានចារិកទុកក្នុងបេះដូងរបស់ខ្ញុំជាដរាបតរៀងទៅ"។

- CWM, Myanmar

THE INDOCHINA MEDIA MEMORIAL FOUNDATION

FCCT
FOREIGN CORRESPONDENTS' CLUB of THAILAND